មង្គលត្ថុតិបនីព្យែ

ភាគ ទី ១

ប្រែនិងរៀបរៀងដោយ

ភិក្ខុវិនយធរោ (មហាយិន-ឡឿន)

ជំនួយដល់សមណសិស្សពុទ្ធិកមធ្យមសិក្សា

និង

ពោះពុម្ពផ្សាយជាធម្មទាន

លើក ទី ២

បំផ្លូវ ៥,០០០ ក្បាល

រក្សាសិទ្ធិ

ព.ស. ២៥៥៧ គ.ស. ២០១៣

សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ បំពោះ **ព្រះភិក្ខុនីសង្ឃ វត្តបញ្ញា** ស្ថិតនៅក្នុងសង្កាត់ក្រាំងធ្នង់ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញនិង ពុទ្ធបរិស័ទជនជាតិតៃវ៉ាន់ ដែលបានជួយទទួលបោះពុម្ពសៀវភៅ **មង្គលត្ថទីបនីប្រែ** នេះ ដើម្បីចែកផ្សាយជាធម្មទាន ដល់សិក្ខាកាមទាំងឡាយ ។

សូមធម្មទាននេះ បានសម្រេចផល ដល់លោកអ្នកដែលបានចែកហានទៅហើយ មួយបំណែកផង ។

មួយបំណែកទៀត សូមព្រះភិក្ខុនីសង្ឃ ជនជាតិចិន ដែលមានទីស្នាក់ការ នៅប្រទេសកម្ពុជា និង ពួកពុទ្ធបរិស័ទ ដែលបានជួយឧបត្ថម្ភ ក្នុងធម្មទាននេះ បានសម្រេចប្រយោជន៍ តាមសេចក្តីប្រាថ្នា កុំបីខានឡើយ ។

ភិក្ខុវិនយធរោ មហាយិន-ឡឿន

វត្តខ្មែរសាន់តាអាណា

2630 N. Grand Ave.
Santa Ana, CA 92705
U. S. A

ថ្ងៃអាទិត្យ ៨ កើត ខែបុស្ស ឆ្នាំថោះ ត្រីស័ក ព.ស. ២៥៥៦
ត្រូវនឹងថ្ងៃទី ១៩ ខែមករា គ.ស. ២០១២

ធម្មទានឈ្នះអស់ទានទាំងពួង

សៀវភៅដែល **ព្រះតិក្ខុនីសច្ច** និង ពុទ្ធបរិស័ទ **ជនជាតិតៃង៉ាន់** បានមានសទ្ធាជ្រះថ្លា និង បានទទួលជួយបោះពុម្ព ចែកផ្សាយជាធម្មទាន នៅពេលនេះ មានចំនួន ដប់បីភាគ (១៣ ភាគ) ក្នុងមួយភាគៗ បោះពុម្ពចំនួនប្រាំពាន់ច្បាប់ (៥,០០០ច្បាប់) ។

សៀវភៅដែលបោះពុម្ពទាំង ១៣ ភាគ នេះ រួមមាន ៖

១- មង្គលត្ថទីបនីប្រែ	ភាគទី ១
២- មង្គលត្ថទីបនីប្រែ	ភាគទី ២
៣- មង្គលត្ថទីបនីប្រែ	ភាគទី ៣
៤- មង្គលត្ថទីបនីប្រែ	ភាគទី ៤
៥- វិសុទ្ធិមគ្គប្រែ	ភាគទី ១
៦- វិសុទ្ធិមគ្គប្រែ	ភាគទី ២
៧- វិសុទ្ធិមគ្គប្រែ	ភាគទី ៣
៨- គាថាធម្មបទប្រែ	
៩- សទ្ធាសុក្រមបាលី-ខ្មែរ	ភាគទី ១
១០- សទ្ធាសុក្រមបាលី-ខ្មែរ	ភាគទី ២
១១- សទ្ធាសុក្រមបាលី-ខ្មែរ	ភាគទី ៣
១២- សទ្ធាសុក្រមបាលី-ខ្មែរ	ភាគទី ៤
១៣- សទ្ធាសុក្រមបាលី-ខ្មែរ	ភាគទី ៥

រូបំ ជីវតិ មច្ចានំ នាមគោត្តំ ន ជីវតិ

ភិក្ខុឥនយឆរោ មហាយិន-ឡឿន

កើត ថ្ងៃទី១០ ខែកក្កដា ១៩៥២

ភូមិទួលព្រំ ស្រុកមោង៍ឫស្សី ខេត្តបាត់ដំបង

រូបកាយ របស់សត្វទាំងឡាយ តែងចាស់ជរាគ្រាំគ្រា
បំណែក នាមនិងគោត្រ មិនដែលចាស់ជរាឡើយ ។

មង្គលត្ថុតិបនីព្យែ

ភាគ ទី១

សម្រាប់តម្កល់ទុកជាសម្បត្តិសង្ឃ
ក្នុងបណ្ណាល័យ

វត្ត .....
ភូមិ .....
ឃុំ .....
ស្រុក .....
ខេត្ត .....
នៅថ្ងៃ.....*កើត*.....*រោច ខែ*.....
ឆ្នាំ ..... *ព. ស. ២៥៥*.....

អ្នកចែក **តិក្ខវិនយធរោ មហាយិន-ឆៀន**

អ្នកទទួល .....

មាតិការឿង

ឈ្មោះធម៌ ខំព័រ

អារម្ភកថា របស់អ្នករៀបរៀង ក

សេចក្តីថ្លែងអំណរគុណ ឆ

មង្គលសូត្រ ក្នុងខុទ្ទកបាឋ: ១

បណាមគាថា ៥

ឧប្បត្តិកថា ៧

ពណ៌នាសេចក្តីនៃនិទាន និង គាថាទួលសួរ ១៨

ពណ៌នាសេចក្តីនៃគាថា ទី១

ពណ៌នាការសេព និង មិនសេពពាល និង បណ្ឌិត ៣៣

ពណ៌នាអំពីការបូជា ១២៥

ពណ៌នាសេចក្តីនៃគាថា ទី២

ពណ៌នាអំពីការនៅក្នុងប្រទេសដ៏សមគួរ ១៩៤

ពណ៌នាអំពីភាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន ២២០

ពណ៌នាអំពីការដំកល់ខ្លួនដោយប្រពៃ ២៥៨

ពណ៌នាសេចក្តីនៃគាថា ទី៣

ពណ៌នាអំពីភាពជាអ្នកបានស្តាប់មកច្រើន ២៩៦

ពណ៌អំពីសិល្បៈ ៣២៣

* * *

អារម្ភកថា

របស់អ្នករៀបរៀង

សៀវភៅ មន្តលត្តនីបនីប្រែ ភាគ ទី១ នេះ គឺខ្ញុំ **ភិក្ខុវិនយធរោ មហាយិន-នឿន** បំរុងនឹងផ្តួចផ្តើមប្រែនិងរៀបរៀងមកជាភាសាខ្មែរយើង ជាយូរណាស់មកហើយ គឺតាំងពីពេលដែលខ្ញុំកំពុងនៅសិក្សាមកម្ល៉េះ (ព.ស. ២៥២៤ គ.ស. ១៩៨១) តែឱកាសពុំបានហុចឱ្យ ព្រោះជាប់រវល់ខ្លាំងពេក ក្នុងការសិក្សាភាសាបាលី ឱ្យបានរឹកបំរើនឡើងថែមទៀតផង និងក្នុងពេលនោះ នឹងរកឧបករណ៍ក្នុងច្បាប់ ដែលជាខេមរភាសាសម្រាប់ជាជំនួយ ក៏គ្មានផងដែរ ។ គម្រោងការនេះ ខ្ញុំក៏មិនបានបោះបង់ចោលដែរ ទោះបីជាខ្ញុំបានរសាត់អណ្តែតឆ្ងាយសែនឆ្ងាយ អំពីមាតុភូមិជាទីស្នេហា ហើយបានទៅរស់នៅឯបរទេស ជាប្រទេសដែលមិនកាន់ព្រះពុទ្ធសាសនា មានវប្បធម៌ ទំនៀមទំលាប់ខុសប្លែកផ្សេង ពីប្រទេសយើងក៏ដោយ ក៏គម្រោងការនេះ នៅតែដាក់ជាប់ក្នុងចិត្តខ្ញុំជានិច្ច ។

នៅក្នុងថ្ងៃពុធ ១១ រោច ខែពិសាខ ឆ្នាំវក បក្ខាស័ក ព.ស. ២៥៣៥ ត្រូវនឹងថ្ងៃ ទី២៧ ខែឧសភា គ.ស. ១៩៩២ (ឆ្នាំដែលក្រុមអង្គការសហប្រជាជាតិ ចូលមកជួយរៀបចំ ធ្វើការបោះឆ្នោត នៅប្រទេសកម្ពុជា) ខ្ញុំក៏បានវិលត្រឡប់ ចូលមកទស្សនាមាតុភូមិរបស់ខ្ញុំផងដែរ ហើយបានចូលទៅពិនិត្យមើលការសិក្សា

ព្រះបរិយត្តិធម៌ ទាំងផ្នែកបាលីទាំងផ្នែកព្រះធម្មវិន័យ ដែលព្រះសង្ឃ
កំពុងតែសិក្សា នៅតាមខេត្តនានា ដូចជាវត្តមហាមន្ត្រី វត្តលង្កា
វត្តនិរោធរង្សី ជាដើម ដោយមាន **សម្តេចមង្គលទេព្វាចារ្យ (អ៊ុំ-សុំ)**
អគ្គាធិការពុទ្ធិកសិក្សា បាននាំដំណើរផ្ញើនទៅផងដែរ ។

ពេលនោះ ខ្ញុំមានសេចក្តីសោមនស្ស រីករាយជាទីបំផុត
ដោយបានឃើញ នូវព្រះសង្ឃ អង្គសាមណេរ ទិតទំយកព្រះទ័យ ទុក
ជាក់ ក្នុងការសិក្សាព្រះបរិយត្តិធម៌ គឺបានឮព្រះភិក្ខុសង្ឃ សាមណេរ
អង្គខ្លះ កំពុងទន្ទេញបាលីវៃយ្យាករណ៍ អង្គខ្លះកំពុងទន្ទេញប្រជុំកង
ធម៌ អង្គខ្លះកំពុងហាត់ប្រែធម្មបទ លោកគ្រូអាចារ្យខ្លះ កំពុងបង្ហាត់
ប្រែលោតប្រយោគ តាមបែបបូរាណ... គំហើញ និង ការឮស្តរសព្ទ
ព្រះធម៌ដ៏ពិរោះត្រចៀកនេះ រឹតតែធ្វើឱ្យខ្ញុំរំភើបចិត្តឥតឧបមា ព្រោះ
នឹកសង្ឃឹមថា ព្រះពុទ្ធសាសនា ដែលបានវិនាសសាបសូន្យ ស្ទើរតែ
រលត់អស់ ដោយសារភ្លើងសង្គ្រាម ជាងពីរទសវត្សរ៍ មកហើយ
នោះ នឹងបានរីកចំរើនឡើងដោយពិត ហើយបានរុះញុំ ឱ្យរឹតតែ
មានសទ្ធាជ្រះថ្លាឡើងជាភេយ្យាភាព... ។ មួយទៀតសោត ក៏បាន
ធ្វើឱ្យខ្ញុំនឹកគិតថា តើនឹងរកពិធីដួយ ដល់សមណសិស្សបែបណា?
ខ្ញុំយល់ឃើញថា សមណសិស្សដែលកំពុងសិក្សា នៅសាលាពុទ្ធិក-
បឋមសិស្សា (ពេលនោះ) ដូចជាពុំមានបញ្ហាឡើយ ព្រោះមានគ្រូ និង
មានក្បួនច្បាប់សម្រាប់ដួយប្រើន តែបំណែកតទៅឆ្នាំក្រោយៗទៀត

នឹងមានសមណសិស្ស សាលាពុទ្ធិកមធ្យមសិក្សា ដោយពិត ឯគ្រូ និង
ក្មួនច្បាប់ ខ្ញុំយល់ឃើញថា ដួចជាមានបញ្ហាខ្លះ ព្រោះខ្វះខាតប្រើន ។

ហេតុនេះហើយ ខ្ញុំបានគិតថា នឹងស្រាវជ្រាវរកសៀវភៅ
មង្គលត្ថទីបនី ដែលនៅជាភាសាបាលី ទាំង ៤ ភាគ ដើម្បីយកមកប្រែ
ជាភាសាខ្មែរយើង និង ដើម្បីជាជំនួយដល់សមណសិស្ស សាលា
ពុទ្ធិកមធ្យមសិក្សា ដែលនឹងមានក្នុងអនាគតកាល ហើយក៏បានដើរ
ស្រាវជ្រាវរក នូវសៀវភៅទាំងនោះ តែរកពុំបានឡើយ សូម្បីតែ
សម្តេចព្រះមង្គលទេព្វាចារ្យ (អ៊ុំ-ស៊ុំ) ក៏ព្រះអង្គពុំទាន់មានដែរ ព្រោះ
រោងពុម្ព ដប៉ុន ពុំទាន់បានបោះពុម្ពជាជំនួយ ។

ក្រោយមក នៅថ្ងៃសៅរ៍ ១៥ កើត ខែបឋមាសាធ ឆ្នាំរកា
បញ្ចស័ក ព.ស. ២៥៣៦ ត្រូវនឹងខែកក្កដា ឆ្នាំ ១៩៩៣ គឺត្រូវបំថ្ងៃ
បុណ្យបញ្ចុះខណ្ឌសីមា **វត្តពុទ្ធិការាម** វ៉ាស៊ីងតោនឌីស៊ី ខ្ញុំក៏បានទៅ
ចូលរួម ក្នុងពិធីបុណ្យបញ្ចុះសីមានោះដែរ ហើយបានទទួលសៀវ
ភៅ មង្គលត្ថទីបនី ជាភាសាបាលី ភាគ ទី១-៤ [1] និង សៀវភៅ
បទានុក្រមធម្មបទ ៣ ក្បាល អំពី សម្តេចព្រះមង្គលទេព្វាចារ្យ ដែល
ព្រះអង្គបានតាំយកមកប្រទានឱ្យ ក្នុងពេលនោះផងដែរ ។ ខ្ញុំក៏បាន
ទទួលយក ដោយសេចក្តីត្រេកអរជាទីបំផុត ។ លុះខ្ញុំបានត្រឡប់

---

*១- ភាគទី ២ និង ភាគទី ៤ ខ្ញុំបានប្រែរួចមុនភាគទី១ ព្រោះភាគទី១ ខ្ញុំទើប
តែនឹងបានទទួលអំពី សម្តេចព្រះមង្គលទេព្វាចារ្យ ។*

មកកាន់ **វត្តខេមរពុទ្ធិការាម** ទីក្រុងឡងប៊ិចវិញ ខ្ញុំបានយកសៀវភៅមង្គលត្ថទីបនី ភាគទី១ នេះ មកបកប្រែជាភាសាសម្រាយខ្មែរយើង ដោយបានចាប់ផ្តើមបកប្រែ នៅថ្ងៃសៅរ៍ ២ រោច ខែបុស្ស ឆ្នាំរកា បញ្ចស័ក ព.ស. ២៥៣៦ ត្រូវនឹងថ្ងៃទី ៩ ខែមករា គ.ស. ១៩៩៣ ហើយក៏បានប្រែចប់សព្វគ្រប់ នៅថ្ងៃពុធ ៨ រោច ខែចេត្រ ឆ្នាំរកា បញ្ចស័ក ព.ស. ២៥៣៦ ត្រូវនឹងថ្ងៃទី ១៤ ខែមេសា ឆ្នាំ ១៩៩៣ ។

លុះប្រែចប់ហើយ ខ្ញុំក៏បានផ្ញើសំណៅមង្គលត្ថទីបនី នេះទៅប្រគេន ព្រះតេជព្រះគុណ **ព្រះធម្មលិខិត លាស់-ឡាយ** គង់នៅវត្តសន្សំកុសល ទីក្រុងភ្នំពេញ ដើម្បីត្រួតពិនិត្យឱ្យបានត្រឹមត្រូវ... ព្រះអង្គ ក៏បានជួយអនុគ្រោះ រហូតដល់បានសម្រេចជាស្តាពរ ។

ក្នុងការបកប្រែពីភាសាមួយទៅភាសាមួយទៀតនេះ គឺពិតជាមានការពិបាកខ្លាំងណាស់ ហើយពិតជាមានការភ្លាំងភ្លាត់ ខុស ឃ្លាត ចាកអំពីអត្ថន័យធម៌អាចិន្តៃ្យ ដោយអចេតនាខ្លះ ដោយការចេះមិនដល់ខ្លះ ជាពុំខានឡើយ ។ ក្នុងការបកប្រែនេះសោត គោលគំនិតរបស់ខ្ញុំ គឺប្រែរក្សាទុកភាសាបាលីភាគច្រើន មានន័យថា គឺមិនចង់ឱ្យឃ្លាតចាកអំពីភាសាបាលីច្រើនឡើយ ដើម្បីឱ្យអ្នកសិក្សាធ្លាប់រកសព្វប្រៃបានងាយ តែភាសាខ្មែរ ពិតជាពិបាកស្តាប់បន្តិច ។

ហេតុដូច្នេះ ខ្ញុំអ្នកប្រែ សូមមេត្តាខន្តី អភ័យទោស អំពីសំណាក់ព្រះតេជគុណ និង អស់លោកដែលឆ្លៀវឈ្លាស ក្នុងអក្សរ-

សេចក្តីថ្លែងអំណរគុណ

ខ្ញុំសូមថ្លែងអំណរព្រះគុណ និង អរគុណដ៏ជ្រាលជ្រៅ

-បំពោះ **សម្តេចមង្គលទេព្វាចារ្យ** (អ៊ុំ-ស៊ុំ) អគ្គាធិការពុទ្ធិកសិក្សា វត្តមហាមន្ត្រី ទីក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ដែលព្រះអង្គ បានផ្តល់យោបល់ដ៏ល្អៗ និងបានផ្តល់នូវក្បួនច្បាប់ផ្សេងៗមានសៀវ ភៅមង្គលត្ថទីបនីនេះ និង បទានុក្រមធម្មបទជាដើម តាមត្រូវការ ។

-បំពោះ ព្រះតេជព្រះគុណ **ព្រះធម្មលិខិត លាស់-ឡាយ** វត្តសន្សំ កុសល ក្រុងភ្នំពេញ ដែលបានបំណាយពេលវេលា ជួយត្រួតពិនិត្យ កែសម្រួលពាក្យពេចន៍ និង អត្ថន័យផ្សេងៗ ដើម្បីធ្វើសៀវភៅនេះ ឱ្យបានល្អប្រសើរឡើង តាំងពីដើម រហូតដល់បញ្ចប់សព្វគ្រប់ ។

-បំពោះព្រះតេជគុណ **បណ្ឌិត គង់-ឈាន** បៅអធិការ វត្ត ខេមរ-ពុទ្ធិការាម ទីក្រុងឡងប៊ិច សហរដ្ឋអាមេរិក ដែលបានជួយផ្តល់ យោបល់ គំនិត និង ឯកសារ ក្នុងការបោះពុម្ព ។

-បំពោះ **ភិក្ខុ ប៊ួ-ហួយ** ដែលបានឱ្យខ្ញុំសៀវភៅមង្គលត្ថទីបនី ភាគ ទី៣ និង ភាគទី៤ ដើម្បីយកមកប្រៃ ។

-បំពោះ **ភិក្ខុ អ៊ុង-អ៊ុន** វត្តប្រោះស្ន សហរដ្ឋអាមេរិក, **ភិក្ខុប្រាជ្ញ-សារាគ** វត្តឧណ្ណាលោម កុដិលេខ ៤២ ទីក្រុងភ្នំពេញ និង លោក កវីនិពន្ធ **ហៀម-ភឿន** ដែលបានជួយយកសំណៅ នៃមង្គលត្ថទីបនី នេះ ទៅប្រគេន ព្រះធម្មលិខិត លាស់-ឡាយ ដើម្បីត្រួតពិនិត្យឱ្យបាន

ល្អត្រឹមត្រូវឡើង ។

-បំពោះ ភិក្ខុ មហាសោម-សុភា វត្តធម្មបក្កាវាម ទីក្រុងស៊ីអាប៊ុលវ៉ាស៊ីតោនស្តេត និង ព្រះតេជគុណ ឯម-ភឿង ព្រះមេគណ ខេត្តកំពត, ព្រះមេគណ សុខ-ថាន ខេត្តកំបង់ឆ្នាំង ដែលបានជួយត្រួតពិនិត្យនូវអក្ខរាវិរុទ្ធ ដើម្បីធ្វើសៀវភៅនេះ ឱ្យបានប្រសើរឡើង ។

-បំពោះ ភិក្ខុ ព្រះមហាសម-ស័ក្តិ សុវណ្ណរតនោ ដែលបានយកសៀវភៅនេះ ទៅប្រូលរោងពុម្ព ដើម្បីបោះពុម្ព ឱ្យបានសម្រេច តាមសេចក្តីត្រូវការ ។

-បំពោះ លោកយឹម-ដ៏យ និង លោក ឃុំ-ឆយ ដែលបានជួយកែសម្រួល និង ជួយជំឡើងគ្រឿងកុំព្យូទ័រ ដោយយកចិត្តទុកដាក់ជាទីបំផុត ។

ម៉្យាងទៀត ខ្ញុំសូមថ្លែងអំណរព្រះគុណ និង អរគុណ ជាទីបំផុត បំពោះព្រះតេជគុណ ព្រះបេរាគុបេរៈ អស់លោក លោកស្រី ព្រមទាំងញាតិញោម ជាពុទ្ធបរិស័ទទាំងអស់ ដែលបានជួយឧបត្ថម្ភក្នុងការបោះពុម្ពនេះ ឱ្យបានសម្រេចជាស្តាពរ ។

សូមប្រគេននូវមគ្គផល ដែលកើតអំពីធម្មទានានិសង្សនេះ ដល់ព្រះតេជគុណ ព្រះបេរាគុបេរៈគ្រប់ព្រះអង្គ សូមមានព្រះជន្មាយុយឺនយូរ ជាងរយព្រះវស្សា ដើម្បីជាទីពឹង របស់ពុទ្ធសាសនិកជនទាំងឡាយ តរៀងទៅហោង ។

សូមឱ្យញាតិញោមទាំងឡាយ បានទទួលបុណ្យកុសលនេះ ស្មើៗ គ្នា និង សូមឱ្យបានជួបប្រទះតែនឹងសេចក្តីសុខ-បំរើន គ្រប់ប្រការ កុំបីខានឡើយ ។

សូមឱ្យព្រះរាជាណាចក្រកម្ពុជា ជាទីកំសត់ ធាប់បានទទួលនូវសុខសន្តិភាព ដែលប្រកបដោយព្រះធម៌ នៃអង្គព្រះសម្មាសម្ពុទ្ធបរមគ្រូ ដោយពិត, សូមឱ្យរាជរដ្ឋាភិបាល គ្រប់ជាន់ថ្នាក់ និង គ្រប់គណៈបក្សទាំងអស់ ដឹកនាំប្រទេសជាតិ ព្រះរាជាណាចក្រកម្ពុជា ប្រកបដោយសម្មាទិដ្ឋិ ដើម្បីជោគជ័យ សេចក្តីសុខ-បំរើន និង សុភមង្គល ជូនដល់ប្រជានុរាស្ត្រ ទូទាំងប្រទេស ដែលកំពុងក្រីក្រ លំបាក ស្រែកឃ្លាន នូវសេចក្តីសុខសន្តិភាព និង ស្អប់ខ្ពើមបំផុត នូវសង្គ្រាម សព្វថ្ងៃនេះ ។

សូមឧទ្ទិសបុណ្យកុសលនេះផងដែរ ដល់ពួកបញ្ញវន្ត អ្នកស្នេហាជាតិ យុវជន យុវតី ប្រជាពលរដ្ឋ អ្នកស្លូតត្រង់ គ្រប់ជាន់គ្រប់ស្រទាប់ ដែលបានបូជាជីវិត ដើម្បីមាតុភូមិ ដោយបិត្តស្មោះស្ម័គ្រ គ្រប់កាល:ទេស: សូមបានទទួលនូវបុណ្យកុសល ដែលកើតអំពីធម្មទាននេះ ហើយសូមឱ្យវិញ្ញាណក្ខន្ធ នៃអ្នក បានសោយនូវសុខដ៏ប្រសើរ ក្នុងសុគតិភព កុំបីអាក់ខានឡើយ ។

សៀវភៅ “**មង្គលត្ថទីបនីប្រែ**” ទាំង ៤ ភាគនេះ ខ្ញុំបានបកប្រែ ចេញពីភាសាបាលី មកជាខេមរភាសា នៅថ្ងៃសៅរ៍ ២ កើត ខែភទ្របទ ឆ្នាំវក បត្វាស័ក ព.ស. ២៥៣៥ ត្រូវនឹងថ្ងៃទី ២៩ ខែសីហា គ.ស. ១៩៩២ ... ហើយបានប្រែចប់សព្វគ្រប់បរិបូរ នៅថ្ងៃសុក្រ ១៥ កើត ខែមាឃ ឆ្នាំច ឆស័ក ព.ស. ២៥៣៧ ត្រូវនឹងថ្ងៃ ទី ២៥ ខែកុម្ភៈ គ.ស.១៩៩៤ អស់រយៈពេល ១ ឆ្នាំ ៥ ខែ ២៨ ថ្ងៃ ។

ដោយអំណាចផលានិសង្ស នៃធម្មទាន ដែលកើតឡើងអំពីការព្យាយាមប្រឹងប្រែង ប្រែក្លូវ **មង្គលត្ថទីបនី** នេះ ខ្ញុំសូមប្រាថ្នាឱ្យបានអស់ទៅក្លូវអាសវក្កិលេស ក្នុងអនាគតជាតិ កុំបីខានឡើយ ។

មង្គលសូត្រ ក្នុងខុទ្ទកបាឋៈ

(សូត្រនេះ ឈ្មោះមង្គលសូត្រ) គឺខ្ញុំ (ឈ្មោះអានន្ទ) បានស្តាប់មកហើយ យ៉ាងនេះថា ។ សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ទេវតា ១ អង្គ, កាលរាត្រីបឋមយាមកន្លងទៅហើយ, មានរស្មីដ៏ល្អ ញុំាងវត្តជេតពន ទាំងមូល ឲ្យភ្លឺស្វាងហើយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងទីណា, ក៏ចូលទៅគាល់ក្នុងទីនោះ លុះចូលទៅដល់ហើយ ទើបក្រាបថ្វាយបង្គំចំពោះព្រះដ៏មានព្រះភាគហើយ ក៏បានឈរនៅ ក្នុងទីដ៏សមគួរ ។ លុះទេវតានោះ ឈរក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះដ៏មានព្រះភាគ ដោយពាក្យជាគាថា (យ៉ាងនេះ) ថា ៖

ទេវតា និង មនុស្សទាំងឡាយជាច្រើន [1] ប្រាថ្នានូវសេចក្តីសួស្តី បានគិតរិះរកនូវមង្គលទាំងឡាយ, សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោសសំដែងប្រាប់ នូវមង្គលដ៏ឧត្តម ។

(ព្រះមានព្រះភាគ ទ្រង់ត្រាស់នូវមង្គល ៣៨ ប្រការ ដោយព្រះពុទ្ធភាសិត ជាពាក្យគាថា យ៉ាងនេះថា ៖)

១- ការមិនសេពគប់ នូវបុគ្គលពាលទាំងឡាយ ១ ការសេព

១- សុត្តន្តបិដក ភាគទី ៥២ ទំព័រទី ៤ ។

មង្គលសូត្រ ក្នុងខុទ្ទកបាឋៈ

គប់ នូវបុគ្គលជាបណ្ឌិតទាំងឡាយ ១ ការបូជា ដល់បុគ្គលដែលគួរបូជាទាំងឡាយ ១, ទាំង ៣ នេះ ជាមង្គល ដ៏ឧត្តម ។

២- ការនៅក្នុងប្រទេស ដ៏សមគួរ ១ ភាវៈនៃបុគ្គលបានធ្វើបុណ្យទុកហើយ ក្នុងកាលមុន ១ ការដំកល់ខ្លួនដោយប្រពៃ ១, ទាំង ៣ នេះ ជាមង្គលដ៏ឧត្តម ។

៣- ភាវៈនៃបុគ្គលបានស្តាប់ បានរៀនមកដោយប្រើន ១ សិល្បៈ គឺសេចក្តីឆ្លៀវឆ្លាត ក្នុងហត្ថកម្ម របស់អ្នកបួស និង គ្រហស្ថ ១ វិន័យដែលបុគ្គលសិក្សាដោយប្រពៃ ១ វាចាដែលជាសុភាសិត ១, ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

៤- ការបំរើមាតា ១ ការបំរើបិតា ១ សេចក្តីសង្គ្រោះដល់បុត្រ និង ភរិយា ១ ការងារទាំងឡាយ ដែលមិនប្រឡូកប្រឡល់ ១, ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

៥- ការបរិច្ចាគទាន ១ ការប្រព្រឹត្តិធម៌ ១ សេចក្តីសង្គ្រោះដល់ញាតិទាំងឡាយ ១ ការងារទាំងឡាយ ដែលមិនមានទោស ១, ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

៦- ការមិនត្រេកអរក្នុងបាប និងការវៀរចាកបាប ១ សេចក្តីសង្រួមចាកការផឹក នូវទឹកស្រវឹង ១ សេចក្តីមិនប្រមាទ ក្នុងធម៌

មង្គលសូត្រ ក្នុងខុទ្ទកបាឋៈ

ទាំងឡាយ ១, ទាំង ៣ នេះ ជាមង្គលដ៏ឧត្តម ។

៧- សេចក្តីគោរព ១ ការប្រព្រឹត្តិបន្ទាបខ្លួន ១ សេចក្តីត្រេកអរតាមមានតាមបាន ១ ភាវៈនៃបុគ្គលអ្នកដឹងនូវឧបការៈដែលអ្នកដទៃធ្វើហើយ ១ ការស្តាប់នូវធម៌តាមកាល ១, ទាំង ៥ នេះ ជាមង្គលដ៏ឧត្តម ។

៨- សេចក្តីអត់ធន់ ១ ភាវៈនៃបុគ្គលដែលគេប្រដៅបានដោយងាយ ១ ការជួបប្រទះនូវសមណៈទាំងឡាយ ១ ការសន្ទនាទៅវិញទៅមកនូវធម៌ តាមកាល ១, ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

៩- សេចក្តីព្យាយាមជាគ្រឿងដុតកំដៅនូវបាបធម៌ ១ ការប្រព្រឹត្តិនូវធម៌ដ៏ប្រសើរ ១ ការឃើញនូវអរិយសច្ចទាំងឡាយ ១ ការធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ១, ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

១០- បិត្ត នៃបុគ្គលណា ដែលលោកធម៌ទាំងឡាយ ៣ល់ត្រូវហើយ មិនរំភើបញាប់ញ័រ ១ មិនមានសេចក្តីសោក ១ មានធ្ងូលី គឺរាគៈ ទៅប្រាសហើយ ១ ជាចិត្តដ៏ក្សេមក្សាន្ត ១, ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

១១- ទេវតា និង មនុស្សទាំងឡាយ ធ្វើនូវមង្គលទាំងឡាយប្រាកដដូច្នេះហើយ ជាអ្នកមិនចាលចាញ់ ក្នុងទីទាំងពួង តែងដល់នូវ

មង្គលសូត្រ ក្នុងខុទ្ទកបាឋៈ

សិរីសួស្តី ក្នុងទីទាំងពួង នេះ ជាមង្គលដ៏ឧត្តម របស់ទេវតា និង មនុស្សទាំងឡាយនោះ” ។

មង្គលសូត្រ ចប់ ។

មង្គលត្ថទីបនីប្រែ

ភាគទី ១

បណាមគាថា

(១) ព្រះពុទ្ធអង្គឯណា ដែលឮល្បីទូទៅ ថា ជាមង្គល របស់ទេវតា និង មនុស្សទាំងឡាយ ដែលមានសេចក្តីប្រាថ្នា ដោយមង្គល ព្រះអង្គជាអ្នកទ្រង់សំដែង នូវសេចក្តីនៃមង្គល, ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះពុទ្ធអង្គនោះ ដែលជាមង្គល ។

ព្រះធម៌ឯណា ដែលឮល្បីសព្វសាយ ថា ជាមង្គល របស់ទេវតា និង មនុស្សទាំងឡាយ ដែលមានសេចក្តីប្រាថ្នា ដោយមង្គល ជាធម៌ដែលបំភ្លឺ នូវសេចក្តីនៃមង្គល, ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះធម៌នោះ ដែលជាមង្គល ។

ព្រះសង្ឃឯណា ដែលឮល្បីសព្វសាយ ថា ជាមង្គល របស់ទេវតា និង មនុស្សទាំងឡាយ ដែលមានសេចក្តីប្រាថ្នា ដោយមង្គល ជាអ្នកដែលធ្វើ នូវសេចក្តីនៃមង្គល, ខ្ញុំព្រះករុណា សូមនមស្សការ នូវព្រះសង្ឃនោះដែលជាមង្គល ។

ខ្ញុំព្រះករុណា ជាអ្នកបានធ្វើកិរិយានមស្សការ ល្អប្រពៃហើយ ដល់ព្រះរតនត្រៃ ដែលជាមង្គលយ៉ាងនេះ ដោយប្រការដូច្នេះ,

បណាមគាថា

ដោយអានុភាពនៃកិរិយានមស្សការថ្វាយបង្គំនោះ ខ្ញុំព្រះករុណា ជាអ្នក ញុំងសេចក្តីអន្តរាយ ឱ្យវិនាសបានហើយ, ព្រះសូត្រឯណា ដែល សំដែងនូវមង្គល គឺព្រះពុទ្ធជាម្ចាស់ដែលជាមង្គល ទ្រង់ត្រាស់សំដែង ទុកល្អប្រពៃហើយ ប្រាកដដោយឈ្មោះថា មង្គលសូត្រ ដែលមាន អាជ្ញាដ៏ក្រៃលែង និង អាជ្ញា នៃព្រះសូត្រឯណា ដែលបុគ្គលឯណា មួយ សំដែងទុកហើយ ដើម្បីជាមង្គល ដល់សត្វមានជីវិតទាំងឡាយ ក្នុងលោកនេះ បានផ្សព្វផ្សាយទៅហើយ ក្នុងសែនកោដិចក្រវាឡ, នឹងជ្រើសរើសយក នូវសេចក្តីដែលជាសារៈ ក្នុងគម្ពីរផ្សេង ៗ នោះ មកហើយ សំដែងអត្ថនៃព្រះសូត្រនោះ , សូមអ្នកទាំងឡាយតាំងចិត្ត ស្តាប់ នូវអត្ថនៃមង្គលសូត្រនោះចុះ ។

ខុទ្ទកបត្តិកថា

(២) អធិប្បាយថា ព្រះអាចារ្យ កាលនឹងពណ៌នានូវសេចក្តីនៃព្រះសូត្រ ពោលហេតុកើតឡើងនៃព្រះសូត្រ និង ការកំណត់នៃព្រះសូត្រ ជាមុនហើយ ទើបពណ៌នាសេចក្តី (នៃព្រះសូត្រនោះ) ជាខាងក្រោយ, ព្រោះហេតុនោះ ខ្ញុំនឹងពោលហេតុកើតឡើងនៃព្រះសូត្រជាដើម ។ មែនពិត ព្រះសូត្រទាំងអស់ មានហេតុកើតឡើង ៤ យ៉ាង គឺ កើតព្រោះអធ្យាស្រ័យ របស់ខ្លួនឯង ១ កើតព្រោះអធ្យាស្រ័យ របស់អ្នកដទៃ ១ កើតព្រោះកើតមានរឿងឡើង ១ កើតព្រោះអំណាចនៃពាក្យសួរ ១ ។ ក្នុងហេតុកើតឡើងទាំង ៤ យ៉ាងនោះ ព្រះសូត្រទាំងឡាយ មានទ្វយតានុបស្សនាសូត្រ ជាដើម កើតឡើង ព្រោះអធ្យាស្រ័យរបស់ខ្លួនឯង, ព្រះសូត្រទាំងឡាយ មានមេត្តសូត្រជាដើម កើតឡើង ព្រោះអាធ្យាស្រ័យ របស់អ្នកដទៃ, ឧគរសូត្រជាដើម កើតឡើង ព្រោះកើតមានរឿងឡើង, វម្មិកសូត្រជាដើម កើតឡើង ព្រោះអំណាចនៃពាក្យសួរ ។ បណ្តាហេតុកើតឡើងទាំងនោះ ហេតុកើតឡើង ដោយអំណាចពាក្យសួរ លោកសំដៅយកហើយ ក្នុងមង្គលសូត្រនេះ ។ សូម្បីមង្គលសូត្រ ក៏កើតឡើងដោយអំណាចនៃពាក្យជណ្តើងសួរ ដោយពិត្យជ្រាកដ ។

(៣) ក្នុងរឿងនោះ មានពាក្យពោលជាលំដាប់ដូចតទៅនេះ

មង្គលត្ថទីបនីប្រែ

បានឮមកថា មហាជន ក្នុងជម្ពូទ្វីប បានប្រជុំគ្នា ក្នុងទីនោះ ៗ មានមាត់ទ្វារនគរ សណ្ឋាគារ ផ្ទះទទួលភ្ញៀវ និង ទីប្រជុំជាដើម សូម្បីឲ្យប្រាក់ និង មាសហើយ ញុំាងពួកជន ឲ្យនិយាយរឿង របស់ពួកជន ដែលនៅខាងក្រៅព្រះពុទ្ធសាសនា មានប្រការ ផ្សេង ៗ មានរឿងនាំនាងសីតាមកជាដើម ។ រឿងមួយ ៗ ដោយ កាលកន្លងទៅបាន ៤ ខែ ទើបបានចប់ ។ ក្នុងថ្ងៃមួយ រឿង មង្គល បានកើតឡើងហើយ ក្នុងទីប្រជុំនោះ ថា អ្វីទៅហ្ន៎ ដែល ជាមង្គល, រូបដែលបុគ្គលបានឃើញហើយឬ ជាមង្គល, សំឡេង ដែលបុគ្គលស្តាប់ហើយឬ ជាមង្គល, អារម្មណ៍ដែលបុគ្គលបាន ដឹងហើយឬ ជាមង្គល, អ្នកណាទៅហ្ន៎ ដឹងនូវមង្គល ។

(ទិដ្ឋមង្គល)

គ្រានោះ បុរសម្នាក់ ឈ្មោះថា **ទិដ្ឋមង្គលិក** (អ្នកយល់ថា រូបដែលបុគ្គលឃើញហើយជាមង្គល) និយាយឡើង ថា " ខ្ញុំបាទ ស្គាល់នូវមង្គល, រូបដែលបុគ្គលឃើញហើយ ជាមង្គល ក្នុង លោក រូបដែលគេសន្មត ថា ជាមង្គលដ៏ខ្ពង់ខ្ពស់ ឈ្មោះថា រូប ដែលបុគ្គលបានឃើញហើយ គឺបុគ្គលពួកខ្លះ ក្នុងលោកនេះ បាន ក្រោកឡើង តាំងអំពីព្រឹកព្រលឹម ឃើញសត្វត្រជាង់ស្ងាប ហើរ តាមខ្យល់ខ្លះ ញៀវខ្លីខ្លះ ស្ត្រីមានផ្ទៃពោះខ្លះ ពួកក្មេងដែលប្រដាប់

ឱបត្តិកថា

តាក់តែងហើយខ្ញុះ ពាង៦ីកដែលពេញហើយខ្ញុះ ត្រីត្តិនខ្ញុះ សេះអាជានេយ្យខ្ញុះ រនេះដែលទឹម ដោយសេះអាជានេយ្យខ្ញុះ គោឧសភខ្ញុះ មេគោខ្ញុះ គោក្រហមខ្ញុះ ឬក៏ ឃើញរូបយ៉ាងដូច្នេះ ឯណានីមួយ សូម្បីដទៃទៀត ដែលគេសន្មត ថា ជាមង្គល ដ៏ខ្ពង់ខ្ពស់, នេះហៅថា រូបដែលបុគ្គលបានឃើញហើយ ជាមង្គល ។

(សុតមង្គល)

បុរសម្នាក់ ឈ្មោះថា ***សុតមង្គលិក*** *(ជាអ្នកយល់ថា សំឡេងដែលបុគ្គលស្តាប់ហើយ ជាមង្គល) បានឮពាក្យនោះហើយ ទើបបាននិយាយឡើងថា ម្នាលអ្នកដ៏ចំរើន ធម្មតាភ្នែកនេះរមែងឃើញនូវរូបស្អាតខ្ញុះ មិនស្អាតខ្ញុះ ប្រសើរខ្ញុះ មិនប្រសើរខ្ញុះ ជាទីពេញចិត្តខ្ញុះ មិនជាទីពេញចិត្តខ្ញុះ, ប្រសិនបើ រូបដែលចក្ខុនោះ ឃើញហើយ គប្បីជាមង្គល មែន ក៏គួរតែជាមង្គលទាំងអស់ពិត, ព្រោះដូច្នេះ រូបដែលបុគ្គលឃើញហើយ ទើបមិនមែនជាមង្គលឡើយ, ក៏សំឡេង ដែលបុគ្គលស្តាប់ហើយប៉ុណ្ណោះឯង ជាមង្គល, សំឡេងដែលគេសន្មតថា ជាមង្គលដ៏ខ្ពង់ខ្ពស់ ឈ្មោះថា សំឡេង ដែលបុគ្គលស្តាប់ហើយ, គឺបុគ្គលពួកខ្ញុះ ក្នុងលោកនេះ ក្រោកឡើងពីព្រលឹម បានឮថា ចំរើនឡើងហើយ ដូច្នេះខ្ញុះ ថា កំពុងចំរើនឡើង ដូច្នេះខ្ញុះ ថា ពេញហើយ ដូច្នេះខ្ញុះ ថា ស*

មង្គលត្ថទីបនីប្រែ

ដូច្នេះខ្លះ ថា ចិត្តល្អ ដូច្នេះខ្លះ ថា សិរី ដូច្នេះខ្លះ ថា ចំរើន ដោយសិរី ដូច្នេះខ្លះ ថា ថ្ងៃនេះ ឫក្សល្អ យាមល្អ ថ្ងៃល្អ មង្គលល្អ ដូច្នេះឬក៏ ស្តាប់នូវសំឡេង ដែលគេសន្មតថា ជាមង្គល ជ័ន្ធង់ខ្ពស់ ឯណានីមួយ, នេះ ឈ្មោះថា សំឡេង ដែលបុគ្គលស្តាប់ហើយ ជាមង្គល ។

(មុត្តមង្គល)

បុរសម្នាក់ ឈ្មោះថា ***មុត្តមង្គលិក*** *(ជាអ្នកយល់ថា អារម្មណ៍ដែលបុគ្គលដឹងហើយ ជាមង្គល) បានស្តាប់ពាក្យនោះហើយ ក៏បាននិយាយឡើង ថា ម្នាលអ្នកដ៏ចំរើន ធម្មតាត្រចៀកនេះ រមែងស្តាប់នូវសំឡេងល្អខ្លះ មិនល្អខ្លះ ជាទីពេញចិត្តខ្លះ មិនជាទីពេញចិត្តខ្លះ, ប្រសិនបើ សំឡេង ដែលត្រចៀកនោះបានស្តាប់ហើយ នឹងគប្បីជាមង្គល មែន, ក៏នឹងគប្បីជាមង្គល ទាំងអស់ពិត, ព្រោះហេតុនោះ សំឡេងដែលបុគ្គលស្តាប់ហើយ ទើបមិនមែនជាមង្គលឡើយ, ក៏អារម្មណ៍ ដែលបុគ្គលបានដឹងហើយ ប៉ុណ្ណោះឯង គឺ ជាមង្គល, ក្លិន រស និង ផោដ្ឋព្វៈ ដែលគេសន្មតថា ជាមង្គលជ័ន្ធង់ខ្ពស់ ឈ្មោះថា អារម្មណ៍ដែលបុគ្គលបានដឹងហើយ, គឺបុគ្គលពួកខ្លះ ក្នុងលោកនេះ ក្រោកឡើងពីព្រឹកព្រលឹម រមែងហិតនូវក្លិន នៃផ្កាមានផ្កាបទុម ជាដើមខ្លះ ទំពាំនូវឈើជំរះ*

ឱបត្តិកថា

ធ្មេញដែលសខ្លះ ពាល់ត្រូវនូវប្រឹថពីខ្លះ ពាល់ត្រូវនូវសំទូងខ្លះ នូវអាចម៍គោស្រស់ខ្លះ នូវអណ្តើកខ្លះ នូវរនេះដែលបន្ទុកហើយដោយល្ងខ្លះ នូវផ្តាឈើខ្លះ នូវផ្លែឈើខ្លះ លាបបូកដោយជីពណ៌ិសយ៉ាងប្រពៃខ្លះ ស្បៃកសំពត់ពណ៌ិសខ្លះ ជួតនូវសំពត់ឈួតក្បាលពណ៌ិសខ្លះ, ឬក៏ ហិតក្លិន ក្រេបជញ្ជក់រស ពាល់ត្រូវផោជ្ជព្យៈ យ៉ាងដូច្នោះ ជទៃទៀត ឯណានីមួយ ដែលសន្ធត ថាជាមង្គល ដ៏ខ្ពង់ខ្ពស់, នេះឈ្មោះថា អារម្មណ៍ដែលបុគ្គលដឹងហើយ ជាមង្គល ។

(ការជជែកគ្នាអំពីរឿងមង្គលមិនបេះបិទ)

បុរសទាំង ៣ នាក់នោះ មិនអាច ដើម្បីនឹងញុំាងគ្នានឹងគ្នាឲ្យយល់ព្រមបានឡើយ ។ ក៏បណ្តាមនុស្សជទៃទៀត ក្រៅអំពីបុរសទាំង ៣ នាក់នោះ មនុស្សពួកខ្លះ បានជឿតាមពាក្យ របស់បុរសទាំង ៣ នាក់នោះ, មនុស្សពួកខ្លះ មិនបានជឿឡើយ, មនុស្សទាំងឡាយណា មិនជឿហើយ, មនុស្សទាំងឡាយនោះ ក៏បានជំទាស់ហើយ ជាមួយនឹងពួកមនុស្ស ដែលបានជឿទាំងនោះ ។ មនុស្សទាំងឡាយណា ជឿហើយនូវពាក្យ របស់នាយទិដ្ឋមង្គលិក, មនុស្សទាំងឡាយនោះ ក៏ដល់នូវការជឿយ៉ាងស៊ប់ថា “ រូបដែលបុគ្គលឃើញហើយប៉ុណ្ណោះ ជាមង្គល” យ៉ាងដូច្នេះ,

មង្គលត្ថទីបនីប្រែ

មនុស្សទាំងឡាយ ឯណា ជឿហើយនូវពាក្យ របស់បុរសទាំង ២ នាក់ ក្រៅអំពីនេះ, មនុស្សទាំងឡាយនោះ ដល់នូវការជឿយ៉ាងស៊ប់ ថា " សំឡេង ដែលបុគ្គលស្តាប់ហើយនុ៎ះឯង ជាមង្គល, អារម្មណ៍ ដែលបុគ្គលជឹងហើយនុ៎ះឯង ជាមង្គល " ដូច្នេះ ។ រឿងមង្គលនេះ បានប្រាកដហើយ ក្នុងជម្ពូទ្វីបទាំងមូល ដោយប្រការដូច្នេះឯង ។

(រឿងមង្គលល្បីទៅដល់អកនិដ្ឋភព)

(៤) គ្រានោះ មនុស្សទាំងឡាយ ក្នុងជម្ពូទ្វីបទាំងមូល ជាពួក ៗ នាំគ្នាគិតនូវមង្គលថា " អ្វីទៅហ្ន៎ ជាមង្គល " ដូច្នេះ ។ សូម្បីពពួកទេវតា អ្នកថែរក្សា នូវមនុស្សទាំងឡាយនោះ បានស្តាប់ពាក្យនោះអំពីមនុស្សហើយ ក៏នាំគ្នាគិតរកមង្គលទាំងឡាយយ៉ាងដូច្នោះដែរ ។ ដោយឧបាយនុ៎ះឯង ពួកកុម្ភទេវតា ដែលជាមិត្រ របស់ពួកទេវតា អ្នកថែរក្សាពួកមនុស្សទាំងឡាយ ទេវតាទាំងឡាយ ដែលស្ថិតនៅលើអាកាស ដែលជាមិត្រ របស់ពួកកុម្ភទេវតាទាំងនោះ ពួកទេវតាជាន់ចាតុម្មហារាជិកា ដែលជាមិត្រ របស់ពួកអាកាសទេវតាទាំងនោះ ។ល។ ពួកអកនិដ្ឋទេវតា ដែលជាមិត្រ របស់ពួកសុទស្សីទេវតាទាំងនោះ សារុបទៅហើយ ថា ពួកទេវតា និង ព្រហ្មទាំងឡាយ បានស្តាប់ពាក្យនោះ អំពី

ឱបត្តិកថា

មិត្រសំឡាញ់ របស់ខ្លួននោះ ។ ហើយ ជាពួក ។ បានគិតរក នូវមង្គលទាំងឡាយ ។ ការគិតរឿងមង្គល កើតឡើងហើយ ក្នុងទីគ្រប់កន្លែង រហូតដល់ក្នុងមួយម៉ឺនចក្រវាល ដោយប្រការ ដូច្នេះ ។ ក៏ការគិតរឿងមង្គល ដែលកើតឡើងហើយនោះ ក៏មិន ទាន់បានវិនិច្ឆ័យ ឲ្យជាច់ស្រេចនៅឡើយ ថា " នេះជាមង្គល " ដូច្នេះ បានតាំងនៅហើយ អស់រយៈពេល ១២ ឆ្នាំ ។

(ទេវតាក្រាបទូលសួរបញ្ហាធំងព្រះសាស្តា)

ក្នុងកាលនោះ ពួកទេវតានិងមនុស្សទាំងអស់ លើកលែង តែព្រះអរិយសាវ័កចេញ បានបែកគ្នាហើយ ជា ៣ ពួក ដោយ អំណាចទិដ្ឋមង្គល សុតមង្គល និង មុត្តមង្គល ។ សូម្បីបុគ្គល ម្នាក់ ដែលបានសម្រេចចិត្ត តាមសេចក្តីពិតថា " នេះប៉ុណ្ណោះឯង ជាមង្គល " ដូច្នេះ មិនបានមានឡើយ ។

លំជាប់នោះ ពួកទេវតាជាន់សុទ្ធាវាស បានដឹងចិត្ត របស់ ពួកមនុស្សហើយ ទើបទៅជ្រាប់ ក្នុងទីលំនៅ នៃមនុស្ស ថា " ដោយកាលកន្លងទៅ ១២ ឆ្នាំទៀត ព្រះសម្មាសម្ពុទ្ធ នឹងទ្រង់ ត្រាស់សំដែងនូវមង្គល " ។ ក្រោយមក ដោយកាលកន្លងទៅ ១២ ឆ្នាំ ពួកទេវតា នៅជាន់តាវត្តិង្ស បានប្រជុំព្រមគ្នាហើយ ក៏ចូលទៅគាល់សក្កទេវរាជ ដែលធំជាងទេវតា បានក្រាបទូលថា

មង្គលត្ថទីបនីប្រែ

" បពិត្រព្រះអង្គ ទ្រង់និរទុក្ខ បញ្ហា ប្រារព្ធអំពីរឿងមង្គល បានតាំងឡើងព្រមហើយ, មនុស្សមួយពួក ពោលថា រូបដែលបុគ្គលឃើញហើយ ជាមង្គល មនុស្សមួយពួក ពោលថា សំឡេងដែលបុគ្គលស្តាប់ហើយ ជាមង្គល មនុស្សមួយពួក ពោលថា អារម្មណ៍ ដែលបុគ្គលដឹងហើយ ជាមង្គល ដូច្នេះ, ក្នុងបញ្ហានេះ ទាំងពួកយើងខ្ញុំ ទាំងពួកជនដទៃទៀត មិនទាន់បានចុះសម្រុងគ្នានៅឡើយទេ, សូមប្រទានឱកាសផងចុះ សូមព្រះអង្គទ្រង់ព្យាករដល់ពួកយើងខ្ញុំទាំងឡាយ តាមសេចក្តីពិត ឲ្យានផង " ។

ស្តេចសក្កទេវរាជ ទ្រង់ត្រាស់សួរ ថា " រឿងមង្គលនេះ នៅគ្រាដំបូង បានកើតឡើងហើយ នៅក្នុងទីឯណា " ។

ពួកទេវតា ឆ្លើយថា ក្នុងមនុស្សលោក ។

ស្តេចសក្កទេវរាជ សួរទៀតថា ចុះព្រះដ៏មានព្រះភាគទ្រង់គង់នៅ ក្នុងទីស្ថានឯណា ។

ពួកទេវតា ឆ្លើយថា ក្នុងមនុស្សលោក ។

ស្តេចសក្កទេវរាជ ទ្រង់ត្រាស់ ថា " បើដូច្នេះ អ្នកទាំងឡាយ ចូរមកចុះ, ម្នាលអ្នកនិរទុក្ខទាំងឡាយ ពួកយើងនឹងក្រាបទូលសួរ នូវមង្គលបញ្ហានោះ ចំពោះព្រះដ៏មានព្រះភាគ " ដូច្នេះហើយ ទើបទ្រង់ត្រាស់បញ្ជាទេវបុត្រមួយអង្គ ថា " អ្នកចូរក្រាប

ឱបត្តិកថា

ទូលសួរ នូវព្រះមានព្រះភាគ ” យ៉ាងដូច្នេះហើយ ទ្រង់នាំគណៈទេវបុត្រ យាងមកកាន់វត្តជេតពន ។

លំដាប់នោះ ទេវបុត្រនោះ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយក៏ឈរនៅ ក្នុងទីដ៏សមគួរ ហើយក្រាបទូលសួរនូវមង្គលបញ្ហា ។ ព្រះដ៏មានព្រះភាគ កាលទ្រង់ឆ្លើយនូវបញ្ហានោះរបស់ទេវបុត្រនោះ ទើបទ្រង់បានត្រាស់ហើយ នូវព្រះសូត្រនេះដោយប្រការដូច្នេះ ។

ពណ៌នាអំពីហេតុកើតឡើង ក្នុងមង្គលសូត្រនេះ
មានត្រឹមតែប៉ុណ្ណោះសិនបុះ ។

* * *

មង្គលត្ថទីបនីប្រែ

ការកំណត់ព្រះសូត្រ

(៥) ក្នុងមង្គលសូត្រនោះ ពាក្យជាដើមហេតុ ថា " **ឯវម្មេ សុតំ** " ខ្ញុំបានស្តាប់មកហើយ យ៉ាងនេះ ជាដើម ព្រះអានន្ទត្ថេរ គឺព្រះមហាកស្សបត្ថេរ កាលសង្គាយនា នូវព្រះធម៌ ដណ្តើងសួរ ហើយ ពោលហើយដល់ព្រះអរហន្តទាំងឡាយ ៥០០ អង្គ ក្នុង កាលសង្គាយនាដ៏ធំ ក្នុងលើកទីមួយ ។

១ គាថា ថា " **ពហូ ទេវា មនុស្សា ច** " ដូច្នេះជាដើម ទេវតា បានពោលហើយ ។

១១ គាថា មានជាអាទិ៍ ថា " **អាសវានា ច ពាលានំ** " ព្រះមានព្រះភាគ ទ្រង់បានត្រាស់ហើយ ។

ចំណែកនិគមវចន: ថា " **ឥទមវោច ភគវា, អត្តមនា សា ទេវតា ភគវតោ ភាសិតំ អភិនន្ទិត្វា ភគវន្តំ អភិវាទេត្វា តត្ថេវន្តរធាយិ** " ដូច្នេះជាដើម គឺព្រះអានន្ទត្ថេរ បានពោល ហើយ ។

ប្រមូលពាក្យនោះទាំងអស់ លោកហៅថា **មង្គលសូត្រ** ។

បើគេសួរថា "និទានវចន: និង និគមវចន: មានប្រយោជន៍ យ៉ាងដូចម្តេច? " ។ គប្បីឆ្លើយថា " មានប្រយោជន៍ ដើម្បី ញុំាងសេចក្តីល្អ ៣ យ៉ាង របស់ព្រះសូត្រ ឲ្យបានបរិបូណ៌ ។

មង្គលត្ថទីបនីប្រែ

មែនពិត ឯមង្គលសូត្រ ឈ្មោះថា ល្អខាងដើម ព្រោះនិទានវចនៈ, ឈ្មោះថា ល្អនៅទីបញ្ចប់ ព្រោះនិគមវចនៈ, ឈ្មោះថា ល្អត្រង់កណ្តាល ព្រោះត្រង់កណ្តាល នៃនិទានវចនៈ និង និគមវចនៈទាំង ២ យ៉ាងនោះ យ៉ាងដូច្នេះឯង ។

ការកំណត់ព្រះសូត្រ ក្នុងមង្គលសូត្រនេះ មានត្រឹមតែប៉ុណ្ណោះ ។

♣ ♣ ♣

ពណ៌នាសេចក្តីនៃនិទាន និង គាថាទូលសួរ

(៦) ឥឡូវនេះ ពាក្យជាដើមហេតុឯណានោះ គឺព្រះអានន្ទត្ថេរ កាលនឹងសំដែង នូវហេតុកើតឡើង នៃមង្គលសូត្រ ដោយអំណាចនៃពាក្យជណ្តើងសួរ បានពោលហើយ, អ្នកសិក្សា គប្បីជ្រាបសេចក្តីនៃពាក្យជាដើមហេតុនោះឯង, បណ្តាពាក្យជាដើមហេតុនោះ ក្នុងពាក្យ ថា " **ឯវម្មេ សុតំ** " នេះ **មេ** សព្ទ មាន **មយា** សព្ទ ជាអត្ថ, **សុតំ** សព្ទ មានវិញ្ញាណអាស្រ័យសោតទ្វារ ជាអត្ថ, **ឯវំ** សព្ទ មានអាការ និទស្សនៈ និង អវធារណៈ ជាអត្ថ ។

(ឯវំ សព្ទ មានអាការ ជាអត្ថ)

មែនពិត ដោយ **ឯវំ** សព្ទ ដែលមានអាការជាអត្ថនេះ ព្រះថេរៈ សំដែងថា " ព្រះតម្រាស់ របស់ព្រះសាស្តា បរិបូណ៌ទៅ ដោយនយផ្សេង ៗ ជ្រាលជ្រៅទៅដោយធម៌ អត្ថ ទេសនា និង បដិវេធ ជាសភាវៈដែលសព្វសត្វទាំងឡាយ នឹងគប្បីចូលទៅកំណត់ តាមសមគួរដល់ភាសារបស់រៀង ៗ ខ្លួនបាន, អ្នកណាទៅ នឹងអាចដើម្បីដឹងជាក់ច្បាស់ នូវព្រះតម្រាស់នោះ ដោយប្រការទាំងពួងបាន, តាមពិតហើយ សូម្បីខ្ញុំ (អានន្ទ) ក៏បានស្តាប់មកហើយ ដោយអាការនោះ គឺទ្រទ្រង់ទុកបានហើយ ដោយវិធីនៃសោតវិញ្ញាណ ដែលមានសោតវិញ្ញាណជាប្រធាន " ។

មង្គលត្ថទីបនីប្រែ

(ឯវំ សុតំ មាឧនិទស្សនៈ ជាអត្ថ)

ដោយ **ឯវំ** *សុតំ ដែលមានឧទ្ទេសៈ ជាអត្ថ ព្រះថេរៈសំដែងបង្ហាញ នូវព្រះសូត្រទាំងអស់ ដែលគួរពោល ក្នុងពេលនេះ ។ មែនពិត ព្រះថេរៈនោះ កាលនឹងរំដោះខ្លួនថា " ខ្ញុំនឹងមិនមែនជាព្រះសយម្ភូទេ, ព្រះសូត្រនេះសោត ក៏ខ្ញុំមិនបានធ្វើឲ្យជាក់ច្បាស់ដែរ " ដូច្នេះហើយ ទើបពោលថា " ខ្ញុំបានស្តាប់មកហើយ យ៉ាងដូច្នេះ " ។ អធិប្បាយថា " ព្រះសូត្រយ៉ាងនេះ គឺ នេះ បានដល់ ដែលកំពុងតែពោល ខ្ញុំបានស្តាប់មកហើយ " ។*

(ឯវំ សុតំ មាឧអវធារណៈ ជាអត្ថ)

ដោយ **ឯវំ** *សុតំ ដែលមានអវធារណៈជាអត្ថ ព្រះថេរៈសំដែងថា " ព្រះសូត្រនោះ មិនខ្វះ មិនលើស ដោយអត្ថ ឬ ដោយព្យញ្ជនៈ យ៉ាងដូច្នេះ គឺ មិនគប្បីឃើញ ដោយប្រការដទៃទៀត " ។ មែនពិត ព្រះថេរៈនោះ កាលនឹងសំដែងនូវកម្មាំង នៃការទ្រទ្រង់ចាំរបស់ខ្លួន ញុំាងភាពជាអ្នកប្រាថ្នា ដើម្បីនឹងស្តាប់ ឲ្យកើតឡើង ដល់សត្វទាំងឡាយ ទើបពោល ថា " ខ្ញុំបានស្តាប់មកហើយ យ៉ាងដូច្នេះ " ។ អធិប្បាយថា " ព្រះសូត្រនោះ គឺខ្ញុំបានស្តាប់មកហើយ យ៉ាងដូច្នេះ គឺ ប្រាកដដូច្នេះឯង " ។*

(៧) ២ បទថា " **ឯកំ សមយំ** *" គឺ កាលមួយ ឬ ក្នុង*

ពណ៌នាសេចក្តីនៃនិទាន និង គាថាទូលសួរ

កាលមួយ ។ បទថា “ ***សាវត្ថិយំ*** *” គឺ ក្បែរនគរ ដែលបាន ឈ្មោះថាសាវត្ថី ព្រោះជាស្ថានទីនៅអាស្រ័យ របស់តាបសឥសី ឈ្មោះ សវត្ថៈ មកអំពីមុន ។ ក៏សត្តមីវិភត្តិ ក្នុងបទ ថា “* ***សាវត្ថិយំ*** *” នេះ ចុះក្នុងអត្ថ នៃសមីបៈ ប្រែថា ក្បែរ ។ បទថា “* ***វិហរតិ*** *” គឺ ទ្រង់បំបាត់នូវសេចក្តីលំបាក នៃឥរិយាបថ ១ ដោយឥរិយាបថ មួយទៀត ទ្រង់នាំ គឺ ទ្រង់ញុំាងអត្តភាព ឲ្យ ប្រព្រឹត្តទៅ មិនឲ្យទ្រុឌទ្រោម ។ បទថា “* ***ជេតវនេ*** *” គឺ ក្នុងវត្ត ដែលបានឈ្មោះថា ជេតពន ព្រោះជាព្រះឧទ្យាន របស់ព្រះរាជ-កុមារ ទ្រង់ព្រះនាម ជេត ព្រោះភាវៈនៃឧទ្យាននោះ គឺ ព្រះរាជ-កុមារ ទ្រង់ព្រះនាមជេត ទ្រង់បានដាំនិងទំនុកបំរុងឲ្យចំរើនឡើង ហើយ ។ បទថា “* ***អនាថបិណ្ឌិកស្ស*** *” គឺ របស់គហបតី ដែល បានឈ្មោះថា “ អនាថបិណ្ឌិកៈ ” ព្រោះមានដុំបាយ ដើម្បីពួក ជនអនាថា ។ បទថា “* ***អារាមេ*** *” គឺ ក្នុងមហាវិហារ ដែល អនាថបិណ្ឌិកសេដ្ឋីនោះ កសាងហើយ ដោយការបរិច្ចាគច្រាក់ ៥៤ កោដិ ។*

(៨) សព្ទ ថា “ ***អថ*** *” ជានិបាត ចុះក្នុងអត្ថថា មិនដាច់ ខ្សែរយៈ ។ សព្ទ ថា “* ***ខោ*** *” ជានិបាត ចុះក្នុងអត្ថថា សំដែង រឿងដទៃទៀត ។ ដោយសព្ទទាំង ២ យ៉ាងនោះ ព្រះថេរៈសំដែង*

មង្គលត្ថទីបនីប្រែ

បង្ហាញ ថា " រឿង ជទៃទៀត បានកើតឡើងហើយ ក្នុងវិហារ របស់ព្រះដ៏មានព្រះភាគនោះ មិនដែលជាច់ខ្សែរយៈឡើយ " ។ ដើម្បីនឹងដោះស្រាយពាក្យសួរថា "រឿងជទៃទៀតនោះ គឺអ្វីទៅ?" ព្រះថេរៈ ទើបពោល ថា " ទេវតា មួយអង្គ " ជូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទ ថា " **អញ្ញតរា** " គឺ មួយអង្គ ដែល មិនបានប្រាកដ ដោយនាម និង គោត្រ ។ មែនពិត ពាក្យថា " **ទេវតា** " នោះ ជាឈ្មោះដែលទូទៅ ទាំងស្ត្រី ទាំងបុរស ។ តែក្នុងទីនេះ បុរសប៉ុណ្ណោះឯង គឺព្រះថេរៈ ហៅថា " **ទេវតា** " ។ សេចក្តីថា "ទេវបុត្រ" ក៏បាន ។

២ បទ ថា " **អភិក្កន្តាយ រត្តិយា** " គឺ កាលបើរាត្រីកាល ពោលគឺបឋមយាម អស់ទៅហើយ ។ មែនពិត ក្នុងពាក្យថា " **អភិក្កន្តាយ រត្តិយា** " នេះ **អភិក្កន្ត** សព្ទ ប្រព្រឹត្តទៅ ក្នុង អត្ថថា អស់ទៅ, **រត្តិ** សព្ទ ប្រព្រឹត្តទៅ ក្នុងអត្ថថា បឋមយាម ដូចជា ក្នុងប្រយោគទាំងឡាយ ថា " បពិត្រព្រះអង្គដ៏ចំរើន រាត្រី កន្ទង់ទៅហើយ, បឋមយាម កន្ទង់ផុតទៅហើយ " យ៉ាងដូច្នេះ ជាដើម ។

បទថា " **អភិក្កន្តវណ្ណា** " គឺ មានស្បែកបូបល្អ ។ មែនពិត **អភិក្កន្ត** សព្ទ ក្នុងពាក្យ ថា " **អភិក្កន្តវណ្ណា** " នេះ ចុះក្នុងអត្ថ ថា

ពណ៌នាសេចក្តីនៃនិទាន និង គាថាទូលសួរ

*រូបល្អស្អាត ដូចក្នុងប្រយោគទាំងឡាយ ថា " អ្នកណា មានរូបល្អស្អាត ញុាំងទិសទាំងពួង ឲ្យភ្លឺស្វាង" ដូច្នេះ ជាដើម, **វណ្ណ** សព្ទ ចុះក្នុងអត្ថថា សែ្បក ដូចក្នុងប្រយោគទាំងឡាយ ថា " ព្រះមានព្រះភាគ ទ្រង់មានព្រះឆវីវណ្ណដូចជាមាស " ដូច្នេះជាដើម ។*

*បទថា " **កេវលកប្បំ** " គឺ មិនមានសេសសល់ ដោយជុំវិញ ។ មែនពិត ក្នុងពាក្យថា " **កេវលកប្បំ** " នេះ ការមិនមានចំណែកសេសសល់ ជាអត្ថនៃ **កេវល** សព្ទ ដូចក្នុងប្រយោគទាំងឡាយ ថា " ព្រះដ៏មានព្រះភាគ ទ្រង់ប្រកាសនូវព្រហ្មចរិយ-ធម៌ បរិសុទ្ធ បរិបូណ៌ សព្វគ្រប់ " ដូច្នេះជាដើម, **ភាវៈ**ដោយជុំវិញ ជាអត្ថនៃ **កប្ប** សព្ទ ដូចក្នុងប្រយោគទាំងឡាយថា " ញុាំងវត្តវែឡុវន ឲ្យភ្លឺស្វាងហើយ ដោយជុំវិញ " ដូច្នេះជាដើម ។*

*បទថា " **ឯកាសេត្វា** " គឺ ផ្សាយរស្មីទៅ, អធិប្បាយថា " ធ្វើឲ្យមានរស្មីតែមួយ ដូចជាព្រះចន្ទ និង ព្រះអាទិត្យដូច្នោះ " ។*

*ច្រើនបទថា " **យេន ភគវា តេនុបសង្កមិ** " គឺ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងទីឯណា, ក៏ទៅហើយ ក្នុងទីនោះ ។ មែនពិត ២ បទ ថា " **យេន តេន** " នេះ ជាតតិយាវិភត្តិ ប្រើក្នុងអត្ថនៃសត្តមីវិភត្តិ ។ ម៉្យាងទៀត អធិប្បាយថា " ព្រះមានព្រះភាគ គឺទេវតា និង មនុស្សទាំងឡាយ គប្បីចូលទៅគាល់ ដោយ*

មង្គលត្ថទីបនីប្រែ

ហេតុ ពោលគឺសេចក្តីប្រាថ្នានូវគុណវិសេស មានប្រការផ្សេង ៗ ឯណា, ទេវតានោះ ក៏ចូលទៅគាល់ហើយ ដោយហេតុនោះ ។

(៩) ពាក្យថា " **ឧបសង្កមិត្វា** " ជាពាក្យសំដែង នូវទីបញ្ចប់នៃការចូលទៅគាល់ ។ ម៉្យាងទៀត អធិប្បាយថា "ទេវតានោះ ទៅហើយ យ៉ាងដូច្នោះ, គឺ ទៅកាន់ទីស្តាន ដែលរាប់ថាជិតព្រះសាស្តា ដែលជិតជាងនោះ" ។

បទថា " **អភិវាទេត្វា** " បានដល់ ក្រាបថ្វាយបង្គំហើយ ។

បទថា " **ឯកមន្តំ** " គឺ ឱកាសមួយ បានដល់ មួយខាង ។

បទថា " **ឯកមន្តំ** " នេះ ជានបុំសកលិង្គ សំដែងនូវការៈ (ជានបុំសកលិង្គ ជិតកិរិយា), មួយវិញទៀត ពាក្យនោះ ជាទុតិយាវិភត្តិ ប្រើក្នុងអត្ថសត្តមីវិភត្តិ, អធិប្បាយថា " ក្នុងឱកាសមួយ " ។

បទថា " **អដ្ឋាសិ** " បានដល់ សម្រេចហើយនូវការឈរ, អធិប្បាយថា "ជាអ្នកបានឈរនៅហើយ" ។

មែនពិត ទេវតា អ្នកឈរវៀរចាកទោស នៃការឈរ ៦ យ៉ាង គឺ ឈរនៅខាងក្រោយហួសពេក ១ ឈរនៅខាងមុខហួសពេក ១ ឈរនៅក្នុងទីជិតហួសពេក ១ ឈរនៅក្នុងទីឆ្ងាយហួសពេក ១ ឈរនៅក្នុងទីច្រាសខ្យល់ (លើខ្យល់) ១ ឈរនៅក្នុង

ពណ៌នាសេចក្តីនៃនិទាន និង គាថាទូលសួរ

ប្រទេសដ៏ខ្ពស់ ១ ឈ្មោះថា ឈរនៅក្នុងទីដ៏សមគួរ ។ សួរថា " ក៏ព្រោះហេតុអ្វី ទើបទេវតានេះមិនអង្គុយ" ។ ឆ្លើយថា " ព្រោះប្រាថ្នាចង់វិលត្រឡប់ទៅវិញយ៉ាងប្រញាប់ " ។ មែនពិត ទេវតាទាំងឡាយ អាស្រ័យនូវហេតុឯណាមួយប៉ុណ្ណោះ ទើបមកកាន់មនុស្សលោក ដែលប្រៀបដូចជាទីសម្រាប់បន្ទោបង់នូវរបច្ចៈ ដែលពោរពេញទៅ ដោយរបស់ដែលមិនស្អាត, ក៏តាមប្រក្រតីហើយ មនុស្សលោក រមែងជាទីស្ថានដែលបបជិកូលដល់ទេវតាទាំងឡាយនោះ ចាប់តាំងអំពី ១០០ យោជន៍ឡើងទៅ ព្រោះមនុស្សលោកនោះ មានក្លិនស្អុយ, ពួកទេវតាទាំងឡាយនោះ ទើបមិនត្រេកអរក្នុងមនុស្សលោកនោះ, ព្រោះហេតុនោះ ទេវតានោះ ទើបមិនអង្គុយ ព្រោះប្រាថ្នាដើម្បីនឹងធ្វើកិច្ច របស់អ្នកមកហើយ ប្រញាប់ប្រញាល់ត្រឡប់ទៅវិញ ។

(ទេវតាក្រាបទូលសួរបញ្ហា)

(១០) ទេវបុត្រនោះ ឈរនៅ ក្នុងទីដ៏សមគួរ យ៉ាងនោះហើយ បានឃើញ នូវទេវតា និង ព្រហ្មទាំងឡាយ ក្នុងមួយម៉ឺនចក្រវាល ដែលប្រជុំគ្នា ក្នុងចក្រវាលនេះ ហើយនិមិត្តអត្តភាពដ៏ល្អិតសុខុម ១០ ខ្នះ ២០ ខ្នះ ៣០ ខ្នះ ៤០ ខ្នះ ៥០ ខ្នះ ៦០ ខ្នះ ៧០ ខ្នះ ៨០ ខ្នះ មានទំហំប៉ុនឱកាស នៃចុងបំផុតដីខ្សាច់មួយដុំ

មង្គលត្ថទីបនីប្រែ

ហើយឈរពុំព័ទ្ធ នូវព្រះមានព្រះភាគ ព្រះអង្គទ្រង់ក្តីស្វាង កន្ទង នូវពួកទេវតា និង ព្រហ្មទាំងពួងនោះ ទ្រង់គង់នៅ លើអាសនៈ របស់ព្រះពុទ្ធដ៏ប្រសើរ ដែលបុគ្គលក្រាលទុកហើយ ព្រោះប្រាថ្នា ដើម្បីនឹងស្តាប់ នូវមង្គលបញ្ហា ជីងនូវសេចក្តីត្រិះរិះនៃចិត្ត របស់ មនុស្សទាំងឡាយ អ្នកអាស្រ័យនៅក្នុងជម្ពូទ្វីប សូម្បីមិនបានមក ក្នុងសម័យនោះ ដោយចិត្តហើយ ក៏ក្រាបទូលសួរនូវព្រះមាន ព្រះភាគ ដើម្បីដកកូនសរ គឺសេចក្តីសង្ស័យ របស់ពួកទេវតា និង មនុស្សទាំងពួង ។ ដោយហេតុនោះ ទើព្រះអានន្ទត្ថេរ ពោល ពាក្យថា "**ឯកមន្តំ បិតា ខោ សា**" ជូច្នេះជាដើម ។

(ឆន្ទលក្ខណៈ)

(១១) ក្នុងពាក្យថា "**ឯកមន្តំ បិតា ខោ សា**" នោះ មាន វិនិច្ឆ័យថា ក្នុងអដ្ឋកថា លោកបានពោលថា "បទថា **គាថាយ**" មានសេចក្តីថា ដោយពាក្យដែលកំណត់យក នូវអក្ខរបទ ។ ក្នុងពាក្យថា "**អក្ខរបទំ**" នោះ មានសេចក្តីថា "អក្ខរៈ ក្នុង បទ ពោលគឺបាទ ឈ្មោះថា អក្ខរបទ" ជូច្នេះ ទើបត្រឹមត្រូវ ។

ពិតមែនដូច្នោះ ក្នុងគម្ពីរឆន្ទវុត្តិបទីប លោកពោលថា ៖

ការនិយម សូម្បីអក្ខរៈក្នុង ១ បាទ ឈ្មោះថា ឆន្ទលក្ខណៈ

ពណ៌នាសេចក្តីនៃនិទាន និង គាថាទូលសួរ

បំណែកការនិយមគរុ និង លហុ ក្នុង ៤ បាទ ឈ្មោះថា ព្រឹត្តិលក្ខណៈ ។

*ម៉្យាងទៀត (ក្នុងពាក្យថា) អក្ខរបទនោះ មានសេចក្តីថា " បទ គឺអក្ខរៈ ឈ្មោះថា អក្ខរបទ " ដូច្នេះ ទើបត្រឹមត្រូវ ព្រោះលោកពោលទុកហើយ ក្នុងគម្ពីរសទ្ធិពាលាវតារ ថា " ការនិយមអក្ខរៈ គប្បីឈ្មោះថា ឆន្ទ, ការនិយមគរុ និងលហុ គប្បីឈ្មោះថាព្រឹត្តិ " ដូច្នេះ និង លោកពោលទុកហើយ ក្នុងដីកានៃសទ្ធិពាលាវតារនោះ ថា " ការនិយម គឺវិធីវិសេស ដែលលោកបានកំណត់ទុកហើយ ដោយអក្ខរៈទាំងឡាយនេះ គឺ **ឃ**, **រ**, **ត**, **ក**, **ជ**, **ស**, **ម**, **ន**, ពោលគឺ **យជមាន** (អ្នកបូជា), **រវិ** (ព្រះអាទិត្យ), **តោយ** ទឹក, **ភូមិ** (ផែនដី), **ជលន** (ភ្លើង), **សោម** (ព្រះចន្ទ), **មារុត** (ខ្យល់), **នភ** (អាកាស), គប្បីឈ្មោះថា ឆន្ទ ព្រោះអត្ថវិគ្រោះថាបិទបាំង នូវទោស ដូច្នេះ ការកំណត់ ដោយគរុ និង លហុ ទាំងឡាយ គប្បីឈ្មោះថា ព្រឹត្តិ ព្រោះអត្ថវិគ្រោះថា "ជាគ្រឿងពោល (គាថា) " ដូច្នេះ ។ ក៏គណៈទាំងឡាយ ៨ រមែងបានឈ្មោះថា **ឃ** គណៈ ជាដើម ដោយអំណាចនៃអក្ខរៈទាំងឡាយ ៨ ឯណា, អក្ខរៈ ៨ មាន **ឃ** អក្ខរៈ ជាដើមនោះឯង លោកប្រកាន់យកហើយ ដោយសព្ទថា អក្ខរៈ ក្នុងបទ ថា "**អក្ខរបទំ** " នេះ ។*

មង្គលត្ថទីបនីប្រែ

ក្នុងការនិយម ២ យ៉ាងនោះ ការនិយមអក្សរ បានក្នុងវណ្ណព្រឹត្តិ, ក៏ក្នុងវណ្ណព្រឹត្តិនោះ **ម** គណៈ មានគរុ ៣, **ន** គណៈ មានលហុ ៣ ។ ចំណែកឯការនិយមគរុ និង លហុ រមែងបាន ក្នុងមាត្រា-ព្រឹត្តិ, ក៏ក្នុងមាត្រាព្រឹត្តិនោះ **ម** គណៈ មានគរុ ២, **ន** គណៈ មានលហុ ៤ ។ ចំណែកឯគណៈទាំងឡាយ ដែលសេសសល់ ក្នុងព្រឹត្តិទាំង ២ នោះ រមែងដូចគ្នាតែមួយ ដូច្នេះឯង ។

(១២) បទថា " **អជ្ឈភាសិ** " ប្រែថា បានពោលហើយ, សេចក្តីថា " ក្រាបទូលសួរហើយ " ។ ឯសព្ទ ថា " **អធិ** " នោះ គ្រាន់តែជាឧបសគ្គ ។

បទថា " **ពហូ** " គឺ មិនមែនតែមួយ ។

ទេវតា ដោយកំណើត មានទេវតា ជាន់ចាតុមហារាជិកា ជាដើម ឈ្មោះថា ទេវតា ។

ពួកជនអ្នកអាស្រ័យនៅ ក្នុងជម្ពូទ្វីប ឈ្មោះថា មនុស្ស ។

បទថា " **មង្គលានិ** " មានសេចក្តីថា នូវហេតុការនៃការ ដល់នូវសេចក្តីចំរើន ដោយសម្បត្តិគ្រប់បែបយ៉ាង ។ ដោយ ហេតុនោះ ក្នុងអដ្ឋកថា ទើបលោកពោលទុក ថា " សត្វទាំង ឡាយ រមែងដល់ អធិប្បាយថា រមែងដល់ នូវសេចក្តីសម្រេច និង សេចក្តីចំរើន ដោយហេតុទាំងឡាយនេះ ព្រោះហេតុនោះ

ពណ៌នាសេចក្តីនៃនិទាន និង គាថាទូលសួរ

ហេតុទាំងនេះ ទើបឈ្មោះថា ***មង្គល*** *ដូច្នេះ" ។ សូម្បីក្នុងគម្ពីរ សទ្ទនីតិ លោកពោលសេចក្តីនៃធាតុ ថា "ក្នុងបទថា* ***មង្គលំ*** *នេះ* ***មគិ*** *ធាតុ ប្រព្រឹត្តទៅ ក្នុងការដល់" ដូច្នេះហើយ ទើបពោលបទកិរិយាថា "****មង្គតិ****" (ប្រែថា រមែងដល់) ។ ក៏* ***មគិ*** *ធាតុ ជា* ***ឥ*** *ការន្ត ហេតុនោះ ក្នុងការសម្រេចរូប ទើបចុះនិគ្គហិតអាគម ។*

*បទថា "****អចិន្តយុំ****" ប្រែថា បានគិតគ្នាហើយ ។*

*បទថា "****អាកង្ខមានា****" បានដល់ កាលប្រាថ្នា គឺត្រូវការ ។*

*បទថា "****សោត្ថានំ****" ប្រែថា នូវសេចក្តីសួស្តី, អធិប្បាយថា "នូវភាវៈនៃធម៌ដែលប្រព្រឹត្តទៅ ក្នុងបច្ចុប្បន្ន និង សម្បាយកព ដែលល្អគ្រប់បែបយ៉ាងមាន" ។*

*(១៣) បទថា "****ព្រូហិ****" ប្រែថា សូមទ្រង់ត្រាស់ប្រាប់ គឺ សូមទ្រង់ត្រាស់សំដែង ។ បទថា "****ឧត្តមំ****" ប្រែថា វិសេស គឺប្រសើរ បានដល់ នាំប្រយោជន៍សុខ មកដល់លោកទាំងពួង ។*

ក៏ក្នុងគាថាទូលសួរនេះ បណ្ឌិត គប្បីជ្រាបសន្និដ្ឋាន ថា "សេចក្តីខុសផ្សេងពីគ្នានៃវចនៈ គឺទេវតាធ្វើហើយ ដោយអំណាចការសំឡឹងនូវប្រកេទ ថា ***មង្គលានិ*** *ដូច្នេះ និង ដោយអំណាចការសំឡឹង នូវជាតិកំណើត ថា* ***មង្គលំ*** *ប្រៀបដូចជាសេចក្តីខុសផ្សេងពីគ្នានៃវចនៈ ដែលស្តេចសក្កទេវរាជ បានធ្វើហើយ ដោយ*

មង្គលត្ថទីបនីប្រែ

អំណាចការសំឡឹងដល់ប្រភេទ និង ជាតិ ក្នុងកន្លះ គាថានេះ ថា៖

បពិត្រព្រះរាជឥសី សូមព្រះអង្គទ្រង់ជ្រើសយកព្រះពរបុះ,
ទូលបង្គំនឹងថ្វាយព្រះពរ ៨ ប្រការ ដល់ព្រះអង្គ ដូច្នោះឯង ។

ចំណែក ក្នុងអដ្ឋកថា លោកពោលថា " ព្រះដ៏មានព្រះភាគ សូម្បីទេវបុត្រអារាធនាហើយ ដើម្បីឲ្យព្រះអង្គត្រាស់មង្គលមួយ ដោយពាក្យថា សូមព្រះអង្គ ទ្រង់ត្រាស់សំដែង នូវមង្គលដ៏ឧត្តម ដូច្នេះ ប៉ុន្តែទ្រង់ត្រាស់ ក្នុងគាថាមួយ ៣ មង្គល ប្រៀបដូចជាបុរសអ្នកមានអធ្យាស្រ័យដ៏ទូលំទូលាយ ត្រូវគេសុំតែបន្តិចបន្តួច ក៏ឲ្យ (គេ) ច្រើន យ៉ាងដូច្នោះឯង ។

(១៤) គាថានេះ ឈ្មោះថា បឋ្យាវត្ត ។

សមដូចពាក្យដែលលោក ពោលទុកក្នុងគម្ពីរវុត្តោទយ ថា

បឋ្យាវត្ត លោកពោលហើយ ដោយ ជ គណៈ ៣ងមុខ
អំពី ៤ អក្សរ ក្នុងបាទគូទាំងឡាយ ។

*បណ្តាបទទាំងនោះ បទថា " **សមេសុ** " បានដល់ ក្នុងបាទគូទាំងឡាយ ពោលគឺ បាទទី ២ និង បាទទី ៤ ។*

*បទថា " **សិន្ទុតោ** " គឺ បន្ទាប់អំពី ៤ អក្សរ ទៅទាំងនោះ ។ ពាក្យថា "បន្ទាប់អំពី ៤ អក្សរ ទៅទាំងនោះ" នុ៎ះ គឺគ្រាន់តែជា*

ពណ៌នាសេចក្តីនៃនិទាន និង គាថាទូលសួរ

និទស្សនៈ ព្រោះក្នុងបាទនៃគាថា ថា “ ***មង្គលានិ អាចិន្តយុំ*** *” នេះ សំដែងនូវ* ***ជ*** *គណៈ សូម្បីអំពីអក្សរខាងដើម ។*

បទថា “ ***ជេន*** *” ប្រែថា ដោយ* ***ជ*** *គណៈ ។*

បទថា “ ***បកិត្តិតំ*** *” គឺ ពោលហើយ ។*

គាថានោះ ឈ្មោះថា បហ្យា ព្រោះជាវាចា ដែលបុគ្គលត្រូវពោល និង ឈ្មោះថា វត្ត ព្រោះជាវាចា ដែលបុគ្គលត្រូវវាយ ដោយចតុភវត្ត ព្រោះហេតុនោះ ទើបឈ្មោះថា បហ្យាវត្ត ។

ចំណែក ក្នុងបាទដែលមិនមែនជាគូ ពោលគឺ បាទ ទី១ និង បាទ ទី ៣ ***ស*** *គណៈ និង* ***ន*** *គណៈ បន្ទាប់អំពីអក្សរ តួ ខាងដើមទៀងទៅ មិនមាន, គណៈដទៃទៀត លោកមិនបានហាមទេ្បីយ ។*

ពណ៌នាសេចក្តីនៃនិទាន និង គាថាទូលសួរ បប់ ។

ពណ៌នាសេចក្តីនៃគាថា ទី ១

(១៥) ព្រះដ៏មានព្រះភាគ គឺទេវបុត្រនោះ ក្រាបទូលសួរយ៉ាងដូច្នេះហើយ កាលទ្រង់វិសជ្ជនា នូវបញ្ហានោះ ទ្រង់បានត្រាស់នូវព្រះគាថាទាំងឡាយ ១០ ដែលសំដែង នូវមង្គល ៣៨ ប្រការ មានជាអាទិ៍ ថា " **អសេវនា ច ពាលានំ** " ដូច្នេះ ។ បណ្តាគាថាទាំងនោះ ខ្ញុំនឹងពណ៌នាសេចក្តី នៃគាថា ទី១ ជាមុនសិន ។

(១៦) ការមិនគប់រក ឈ្មោះថា **អសេវនា** ។ បទថា " **ពាលានំ** " បានដល់ នូវបុគ្គលពាលទាំងឡាយ ។ ឆដ្ឋីវិភត្តិ ប្រើក្នុងកម្ម ។ សូម្បីក្នុងបាទ ទី ២ ក៏នយនោះ ដូចគ្នាដែរ ។

ការបូជា ឈ្មោះថា បូជា ។ បទថា " **បូជនីយានំ** " បានដល់ ដល់វត្ថុដែលគួរបូជាទាំងឡាយ ។ ចតុត្ថីវិភត្តិ ប្រើក្នុងសម្បទាន ។ អាចារ្យពួកខ្លះ ពោលថា " ឆដ្ឋីវិភត្តិ ប្រើក្នុងកម្ម " យ៉ាងដូច្នេះ ក៏មាន ។

បទថា " **ឯតំ** " ជាដើម មានសេចក្តីថា កិរិយាមិនសេពគប់ នូវបុគ្គលពាលទាំងឡាយ ១ កិរិយាសេពគប់នូវបុគ្គលជាបណ្ឌិតទាំងឡាយ ១ កិរិយាបូជាដល់វត្ថុដែលគួរបូជាទាំងឡាយ ១, កម្មទាំង ៣ យ៉ាង មានការមិនសេពគប់ជាដើមនេះ ជាមង្គលដ៏ឧត្តម ។

មង្គលត្ថទីបនីប្រែ

មានព្រះតម្រាស់ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកថា " ម្នាលទេវតា បញ្ហាកម្មឯណា ដែលអ្នកសួរហើយថា សូមព្រះអង្គទ្រង់ត្រាស់សំដែងនូវមង្គលដ៏ឧត្តម ដូច្នេះ, ក្នុងបញ្ហាកម្មនោះ អ្នកចូរប្រកាន់យកថា កម្មទាំង ៣ យ៉ាង មានការមិនសេពគប់នូវបុគ្គលពាលទាំងឡាយជាដើមនោះ ជាមង្គលដ៏ឧត្តមដូច្នេះ " ។

សេចក្តីសង្ខេប ក្នុងគាថាទី ១ នេះ មានតែប៉ុណ្ណេះឯង ។

ឯសេចក្តីពិស្តារ ក្នុងគាថាទី ១ នេះ មានដូចតទៅនេះ ៖

* * *

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

(១៧) ការមិនគប់រក ការមិនមានបុគ្គលពាលនោះ ជាសំឡាញ់ ការមិនចូលជាពួក ជាមួយនឹងបុគ្គលពាលនោះ ឈ្មោះថា កិរិយាមិនសេពគប់ ។ សត្វទាំងឡាយ ឯណាមួយ ជាអ្នកប្រកបដោយអកុសលកម្មបថ ១០ មានបាណាតិបាត ជាដើម, សត្វទាំងឡាយនោះ ឈ្មោះថា ពាល ។ មួយវិញទៀត គ្រូទាំងឡាយ ៦ នាក់នេះ គឺ បូរណ កស្សប, មក្ខលិ គោសាល, និគ្រន្ថ-នាដបុត្រ, សញ្ជ័យ វេលដ្ឋបុត្រ, បកុទ្ធ កច្ចាយនៈ, អជិត កេសកម្ពល, និង ជាបបុគ្គលទាំងឡាយ ដទៃទៀត ក្រៅពីគ្រូទាំង ៦ នោះ មានភិក្ខុ ទេវទត្ត និង កោកាលិកភិក្ខុជាដើម គប្បីជ្រាបថា "**បុគ្គលពាល**" ។ មែនពិត ពួកបុគ្គលពាលទាំងអស់នោះឯង លោកហៅថា " **ពាល** " ព្រោះមិនរស់នៅ ដោយការរស់នៅដែលប្រកប ដោយបញ្ញា រស់នៅ ដោយហេតុត្រឹមតែការដកដង្ហើម ។ ដោយហេតុនោះ ក្នុងអដ្ឋកថា ទើបលោក ពោលថា " ជនទាំងឡាយឯណា រស់នៅ អធិប្បាយថា ចិញ្ចឹមជីវិត នៅដោយហេតុត្រឹមតែការដកដង្ហើមចេញ-ចូល, មិនរស់នៅ ដោយការរស់នៅប្រកបដោយបញ្ញា ដ៏ប្រសើរឡើយ, ហេតុនោះ ជនទាំងឡាយនោះ ទើបឈ្មោះថា ជនពាល " ។ សូម្បីក្នុងគម្ពីរសទ្ទនីតិ ក៏លោកពោលហើយថា " **ពាល** ជាតុ រមែងប្រព្រឹត្តទៅ

មង្គលត្ថទីបនីប្រែ

ក្នុងអត្ថថា ច្រាណ, ច្រាណ គឺការរស់នៅ និង ការដកដង្ហើម, បុគ្គលឯណា តែងរស់នៅ គឺដកដង្ហើមចូល និង ដកដង្ហើមចេញ, មានពាក្យដែលលោកពោលទុក ថា ចិញ្ចឹមជីវិត ដោយហេតុត្រឹមតែការដកដង្ហើមចូល-ចេញ, មិនមែនរស់នៅ ដោយការរស់នៅប្រកបដោយបញ្ញា ដ៏ប្រសើរឡើយ ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា បុគ្គលពាល " ។

ចំណែកលក្ខណៈ របស់បុគ្គលពាល គប្បីជ្រាប ដោយអំណាចនៃទុច្ចរិត មានការគិតរកនូវរឿងដែលគិតមិនល្អជាដើម ។ មែនពិត បុគ្គលពាល សូម្បីកាលគិត ក៏រមែងគិត តែរឿងដែលគិតមិនល្អ ដោយអំណាចនៃ អកិរិយា ព្យាបាទ និង មិច្ឆាទិដ្ឋិ តែប៉ុណ្ណោះឯង, សូម្បីកាលនិយាយ ក៏រមែងនិយាយចំពោះ តែពាក្យដែលនិយាយអាក្រក់ ផ្សេងដោយវចីទុច្ចរិត មានមុសាវាទជាដើមប៉ុណ្ណោះឯង, សូម្បីកាលធ្វើ ក៏រមែងធ្វើចំពោះតែកម្ម ដែលធ្វើអាក្រក់ ដោយអំណាចនៃកាយទុច្ចរិត មានបាណាតិបាត ជាដើមប៉ុណ្ណោះឯង ។ ព្រោះហេតុនោះ ទុច្ចរិតទាំងឡាយ មានការគិតរឿងដែលគិតមិនល្អជាដើម របស់បុគ្គលនោះ ទើបលោកហៅថា " ពាលលក្ខណៈ " ព្រោះវិគ្រោះថា " បុគ្គលពាល ជាហេតុដែលបុគ្គលកំណត់ គឺ ជីវិតបាន " ដូច្នេះ, ហៅថា " ពាលនិមិត្ត "

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

ព្រោះជាហេតុនៃការស្គាល់ច្បាស់ នូវបុគ្គលពាល និង ហៅថា “ពាលាបទាន” ព្រោះបុគ្គលពាលប្រព្រឹត្តមិនដែលខាន ។

ដោយហេតុនោះ ក្នុងពាលបណ្ឌិតសូត្រ ក្នុងឧបរិបណ្ណាសក: ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ថា “ ម្នាលភិក្ខុទាំងឡាយ ពាលលក្ខណៈ ពាលនិមិត្ត ពាលាបទាន របស់បុគ្គលពាល មាន ៣ ប្រការ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល ក្នុងលោកនេះ រមែងជាអ្នកគិតតែរឿង ដែលគិតអាក្រក់, និយាយតែពាក្យ ដែលនិយាយអាក្រក់ និង ធ្វើតែកម្ម ដែលធ្វើអាក្រក់ ” យ៉ាងដូច្នេះ ។

(១៨) សត្វទាំងឡាយ ឯណាមួយ ជាអ្នកប្រកបដោយកុសលកម្មបថ ១០ មានការវៀរចាកការសម្លាប់សត្វជាដើម, សត្វទាំងឡាយនោះ ឈ្មោះថា បណ្ឌិត ។ ម៉្យាងទៀត ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះមហាសាវក ៨០ ព្រះសាវករបស់ព្រះតថាគត ទាំងឡាយដទៃទៀត និង គ្រូសុនេត្រ និង អកិត្តិតាបស ជាដើម ក្នុងអតីតកាល គប្បីជ្រាបថា “ ជាបណ្ឌិត ” ។ អ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធជាដើម ទាំងអស់នោះ លោកហៅថា “ ជាបណ្ឌិត ” ព្រោះធ្វើដំណើរទៅ ក្នុងប្រយោជន៍ទាំងឡាយ ដោយបញ្ញាគតិ ។ ដោយហេតុនោះ ក្នុងអដ្ឋកថា ទើបលោកពោលថា

មង្គលត្ថទីបនីប្រែ

*" ជនទាំងឡាយណា ទៅ អធិប្បាយថា ធ្វើដំណើរទៅ ក្នុងប្រយោជន៍ទាំងឡាយ ដែលប្រព្រឹត្តទៅ ក្នុងបច្ចុប្បន្ន និងសម្បរាយិកភព ដោយញាណគតិ ព្រោះហេតុនោះ ជនទាំងឡាយនោះ ទើបឈ្មោះថា បណ្ឌិត " ។ សូម្បីក្នុងគម្ពីរសេទុនីតិ ក៏លោកបានពោលទុក ថា " **បឌិ** ជាតុ ប្រព្រឹត្តទៅ ក្នុងកិរិយាទៅ, បញ្ញា ឯណា រមែងទៅ គឺ ធ្វើដំណើរទៅ ក្នុងប្រយោជន៍ទាំងឡាយ សូម្បីដ៏ល្អិតសុខុម គឺជីងនូវអាការ សូម្បីមានជាអាទិ៍ គឺការបៀតបៀននូវអរិយសច្ច មានសេចក្តីទុក្ខជាដើម ហេតុនោះ បញ្ញានោះ ទើបឈ្មោះថា បណ្ឌា, បុគ្គលណា ទៅ គឺ ធ្វើដំណើរទៅ បានដល់ប្រព្រឹត្តទៅ ដោយបញ្ញា ដែលមានឈ្មោះថា បណ្ឌា ហេតុនេះ បុគ្គលនោះ ទើបឈ្មោះថា បណ្ឌិត, ម៉្យាងទៀត បញ្ញា ដែលមានឈ្មោះថា បណ្ឌា របស់បុគ្គលនេះ កើតព្រមហើយ ព្រោះហេតុនោះ បុគ្គលនេះ ទើបឈ្មោះថា បណ្ឌិត, បុគ្គលឯណា ទៅ គឺធ្វើដំណើរទៅ ដោយញាណគតិ ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា បណ្ឌិត " ។*

(លក្ខណៈរបស់បណ្ឌិត)

ចំណែកលក្ខណៈ របស់បណ្ឌិតគប្បីជ្រាប ដោយអំណាចនៃសុចរិតទាំងឡាយ មានការគិត នូវរឿងដែលគិតល្អជាដើម

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទុក ក្នុងពាលបណ្ឌិតសូត្រ យ៉ាងដូច្នេះ ថា "ម្នាលភិក្ខុទាំងឡាយ បណ្ឌិតលក្ខណៈ បណ្ឌិត-និមិត្ត បណ្ឌិតាបទាន របស់បណ្ឌិត មាន ៣ យ៉ាងនេះ, មាន ៣ យ៉ាង គឺ អ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិត ក្នុងលោកនេះ រមែងជាអ្នកគិតតែរឿងដែលគិតល្អ ជាអ្នកនិយាយតែពាក្យដែលនិយាយល្អ និង ជាអ្នកធ្វើកម្មដែលល្អ " ដូច្នេះ ។ ក៏ពាក្យថា " ***សុចិន្តិតចិន្តី*** " ដូច្នេះជាដើម បណ្ឌិតគប្បីប្រកប ដោយអំណាចនៃសុចរិត មានមនោសុចរិតជាដើម យ៉ាងដូច្នេះឯង ។

(១៩) នយជនៃទៀត ។ ជនទាំងឡាយណាតែងបានទទួលប្រយោជន៍ទាំង ២ នោះ គឺប្រតិបត្តិដើម្បីបានទទួលនូវប្រយោជន៍ទាំង ២ នោះ, ជនទាំងឡាយនោះ ឈ្មោះថា បណ្ឌិត ព្រោះព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ក្នុងឧភោអត្ថសូត្រ ក្នុងកោសលសំយុត្ត យ៉ាងដូច្នេះថា ៖

ធីរជនៈ លោកហៅថាបណ្ឌិត ព្រោះទាញយកប្រយោជន៍ទាំង ២ បាន គឺប្រយោជន៍បច្ចុប្បន្ន និង ប្រយោជន៍ក្នុងសម្បរាយភព ។

ជនទាំងឡាយ ឯណា កាត់ចោលនូវប្រយោជន៍ ទាំង ២ យ៉ាង កាន់យកនូវហេតុដែលមិនមែនជាប្រយោជន៍ទាំង ២ យ៉ាង, ជនទាំងឡាយនោះ ឈ្មោះថា ពាល ។ មែនពិត ជនទាំងឡាយ

មង្គលត្ថទីបនីប្រែ

នោះ លោកហៅថា " **ពាល** " ក៏ព្រោះកាន់យក នូវហេតុដែលមិនមែនជាប្រយោជន៍ទាំងឡាយ ២ ប្រការ និង លោកហៅថា " **ពាល** " ក៏ព្រោះកាត់ផ្តាច់ចោល នូវប្រយោជន៍ទាំងឡាយ ២ ប្រការ ។ កិរិយាសព្ទ ថា " **លន្តិ** " នោះ ចាត់ចូលក្នុងពួកធាតុ មាន **ភូ** ធាតុ ជាដើម ដោយការបង្គាប់ ថា " **លា** ធាតុ មាន **ទ្វិ** សព្ទ ជាបទប្រៀបធៀប ប្រព្រឹត្តទៅ ក្នុងអត្ថថា កាន់យក " ។ កិរិយាសព្ទ ថា " **លុនន្តិ** " នោះ ចាត់ចូលក្នុងពួកធាតុ មាន **កី** ធាតុជាដើម ដោយការបង្គាប់ថា " **លុ** ធាតុ មាន **ទ្វិ** សព្ទ ជាបទប្រៀបធៀប ប្រព្រឹត្តទៅ ក្នុងអត្ថថា កាត់ចោល " ដូច្នេះ ។

ជនទាំងឡាយឯណា កាត់ចោលនូវប្រយោជន៍ទាំង ២ យ៉ាង កាន់យកនូវហេតុដែលមិនមែនជាប្រយោជន៍ទាំង ២ យ៉ាង, ជនទាំងឡាយនោះ ឈ្មោះថា **ពាល** ។ មែនពិត ជនទាំងឡាយនោះ លោកហៅថា " **ពាល** " ក៏ព្រោះកាន់យកនូវហេតុដែលមិនមែនជាប្រយោជន៍ទាំងឡាយ ២ ប្រការ និង លោកហៅថា " **ពាល** " ក៏ព្រោះកាត់ផ្តាច់ចោល នូវប្រយោជន៍ទាំងឡាយ ២ ប្រការ ។ កិរិយាសព្ទ ថា " **លន្តិ** " នោះ ចាត់ចូលក្នុងពួកធាតុ មាន **ភូ** ធាតុ ជាដើម ដោយការបង្គាប់ថា " **លា** ធាតុ មាន **ទ្វិ** សព្ទ ជាបទប្រៀបធៀប ប្រព្រឹត្តទៅ ក្នុងអត្ថថា កាន់យក " ។

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

*កិរិយាសព្ទ ថា " **លុនន្តិ** " នោះ ចាត់ចូលក្នុងពួកធាតុ មាន **កី** ធាតុជាដើម ដោយការបង្គាប់ថា " **លុ** ធាតុ មាន **ន្ថិ** សព្ទ ជាបទប្រៀបធៀប ប្រព្រឹត្តទៅ ក្នុងអត្ថថា កាត់ចោល " ដូច្នេះ ។*

(បុគ្គលដែលគួរសេពគប់និងមិនគួរសេពគប់)

(២០) បណ្តាជនពាលនិងបណ្ឌិតទាំង ២ ពួកនោះ ពួកបណ្ឌិតប៉ុណ្ណោះ គឺបុគ្គលត្រូវសេពគប់, ពួកជនពាល គឺបុគ្គលមិនត្រូវសេពគប់ឡើយ, ព្រោះពួកជនពាល ប្រៀបដូចជាត្រីស្អុយ, បុគ្គលអ្នកសេពគប់ ជាមួយនឹងជនពាលនោះ ប្រៀបដូចស្លឹកឈើដែលសម្រាប់ខ្ចប់នូវត្រីស្អុយ ដល់នូវភាពជាអ្នក គឺពួកវិញ្ញូជនគប្បីបោះបង់ចោល និងស្អប់ខ្ពើម ។ (ចំណែក) បណ្ឌិត ប្រៀបដូចជាកណ្តុះ សម្រាប់រៃចខ្ចប់ នូវគ្រឿងក្រអូប មានក្រឹស្នា និងមាលាជាដើម, បុគ្គលអ្នកសេពគប់ ជាមួយនឹងបណ្ឌិតនោះ ក៏ប្រៀបដូចជាស្លឹកឈើ ដែលសម្រាប់ខ្ចប់ នូវគ្រឿងក្រអូប មានក្រឹស្នា និង មាលាជាដើម ដល់នូវភាពជាអ្នកគួរសរសើរ និង គួរជាទីពេញចិត្តនៃពួកវិញ្ញូជន ។ ក៏បុគ្គលណា សេពគប់នូវបុគ្គលណា, បុគ្គលនោះ រមែងមានបុគ្គលនោះជាគតិ ដោយពិត ។ ប៉ុន្តែដើម្បីនឹងសំដែង នូវសេចក្តីនេះ គប្បីពណ៌នារឿងកូនសត្វសេកជាដើម (ដូចតទៅនេះ) ៖

មង្គលត្ថទីបនីប្រែ

(រឿងកូនសត្វសេក)

(២១) បានឮមកថា ក្នុងអតីតកាល បានមានកូនសត្វសេក ២ បងប្អូនទីងគ្នា (នៅ) ក្នុងព្រៃរកា ក្បែរសានុបព៌ត ។ ក៏ក្នុងទីលើខ្ស់នៃបព្វតា មានផ្ទះ ជាទីនៅអាស្រ័យ របស់ចោរ ៥០០ នាក់, ក្នុងទីខាងក្រោមខ្ស់ មានអាស្រមជាទីនៅអាស្រ័យ របស់តាបសឥសី ៥០០ រូប ។ នៅក្នុងពេលដែលពេមស្ងាប របស់កូនសត្វសេកទាំងឡាយ មិនទាន់ដុះនៅឡើយ ក៏មានខ្ស់ព្យុះកំបុតត្បូង កើតឡើងហើយ ។ កូនសេកទាំង ២ នោះ ត្រូវខ្ស់ព្យុះកំបុតត្បូងនោះ ផាត់ទៅ ធ្លាក់ហើយ (ក្នុងទី) ផ្សេងៗ ពីគ្នា ។ បណ្តាកូនសេកទាំង ២ នោះ កូនសេក ១ បានធ្លាក់ទៅ ក្នុងចន្ទោះនៃគ្រឿងសស្ត្រាវុធ ក្នុងផ្ទះរបស់ចោរ ព្រោះធ្លាក់ទៅ ក្នុងទីនោះ ទើបពួកចោរជាក់ឈ្មោះ ថា “ សត្តិគុម្ព: ” ជាត់ធំឡើងហើយ ក្នុងចន្ទោះនៃពួកចោរទាំងនោះ ។ កូនសេក ១ បានធ្លាក់ទៅ ក្នុងចន្ទោះនៃផ្ការឈើ លើផ្ទៃនៃវាលដីខ្សាច់ ក្បែរអាស្រម ព្រោះហេតុដែលធ្លាក់ទៅ ក្នុងទីនោះ ទើបបានពួកតាបសឥសី ជាក់ឈ្មោះឲ្យថា “ បុប្ផក: ” បានជាត់ធំឡើងហើយ ក្នុងចន្ទោះនៃពួកតាបសឥសីទាំងនោះ ។

ក្នុងគ្រានោះ ព្រះរាជា ទ្រង់ព្រះនាមបញ្ចាល: ក្នុងនគរ

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

ឈ្មោះឧត្តរបញ្ហាល: ទ្រង់ប្រជាប់គ្រឿងអលង្ការសព្វគ្រប់ហើយ ទ្រង់ស្តេចយាងឡើងកាន់ព្រះរាជរថ យាងទៅកាន់ព្រៃ ដើម្បីទ្រង់បរបាញ់សត្វហើយ ទ្រង់មានព្រះរាជឱង្ការ ថា " សត្វម្រឹគ រត់ចេញទៅ តាមប្រទេ្បះ នៃបុគ្គលណា, បុគ្គលនោះឯង នឹងត្រូវមានទោស (អាជ្ញា)" យ៉ាងដូច្នេះហើយ ទ្រង់ស្តេចយាងចុះពីព្រះរាជរថ ទ្រង់បានគង់កាន់ធ្នូ ក្នុងទីកំបាំងហើយ ។

ក្នុងខណៈនោះ ម្រឹគទ្រាយ ១, កាលបើពួកមនុស្សកំពុងវាយគុម្ពោតព្រៃ, ក៏បានក្រោកឡើង សំឡឹងរកមើលផ្លូវ ដើម្បីនឹងទៅ ក៏ឃើញថា ទីស្តាន ដែលព្រះរាជាទ្រង់គង់នៅប៉ុណ្ណោះ ជាទីដែលស្រឡះ (ទំនេ) ទើបបែរមុខផ្តោះទៅទិសខាងនោះ ហើយស្ទុះ ចោលគេចទៅ ។ ពួកមនុស្ស ក៏បានធ្វើការចំអក ជាមួយនឹងព្រះរាជាហើយ ។ ព្រះអង្គ ទ្រង់តាំងព្រះទ័យ ថា " អញនឹងចាប់ម្រឹគ ក្នុងពេលឥឡូវនេះ " ហើយទើបស្តេចទ្រង់ឡើងរាជរថ ហើយទ្រង់ដេញ តាមម្រឹគទ្រាយទៅ យ៉ាងលឿន ។ ពួកបុរសមិនអាចតាមជាប់ព្រះអង្គបានឡើយ ។ ព្រះរាជា ទ្រង់មាននាយសារថីជាគម្រប់ ២ ទតមិនឃើញរម្រឹគទ្រាយហើយ ទើបទ្រង់ស្តេចយាងត្រឡប់មកវិញ ទ្រង់ស្រង់ទឹកនិងសោយទឹក ក្នុងជ្រោះភ្នំ ដែលជាទីគួរមនោរម្យ ហើយស្តេចទ្រង់បន្ទំ ក្រោមម្លប់ឈើ

មង្គលត្ថទីបនីប្រែ

ក្បែរផ្ទះនៃចោរ ។

គ្រានោះ ពួកចោរ បានចូលទៅកាន់ព្រៃទាំងអស់គ្នាហើយ ខាងក្នុងផ្ទះ នៅសល់តែសេកឈ្មោះ សត្តិគុម្ព: ជាមួយនឹងអ្នកចំអិនកត្តម្នាក់ ។ សេកសត្តិគុម្ព: ហើរចេញពីផ្ទះ ឃើញព្រះរាជាទ្រង់ព្រះបន្ទំ យ៉ាងដូច្នេះហើយ ក៏ (ហើរ) ចូលផ្ទះ បាននិយាយជាភាសាមនុស្ស ជាមួយនឹងអ្នកជាំស្ង ថា " ពួកយើង នឹងសម្លាប់ព្រះរាជាចោល ប្រមូលយកសំពត់ និង គ្រឿងអលង្ការ របស់ព្រះអង្គ ហើយចាប់ព្រះអង្គ ត្រង់កព្រះបាទ ទាញអូសមកហើយ យកស្បឹកឈើទាំងឡាយ មកគ្របបិទជាំង ក្នុងទីកន្លែងមួយ " ។ ព្រះរាជា ទ្រង់តើនពីព្រះបន្ទំហើយ ទ្រង់ព្រះសណ្តាប់ សំឡេងនោះ ទ្រង់ជ្រាបថា " ទីកន្លែងនេះ មានភ័យចំពោះមុខ " ហើយទ្រង់មានព្រះទ័យភ័យខ្លាច ទើបទ្រង់ស្តេចឡើងកាន់រាជរថហើយ ទ្រង់ចៀសចេញអំពីទីនោះ ស្តេចយាងទៅដល់អាស្រម របស់តាបសឥសីហើយ ។

ក្នុងគ្រានោះ ពួកតាបសឥសី ទៅហើយ ដើម្បីប្រយោជន៍ដល់ផលាផល, ក្នុងអាស្រម នៅសល់តែសត្វសេកឈ្មោះបុបួក: ប៉ុណ្ណោះ ។ សត្វសេកឈ្មោះ បុបួក:នោះ ឃើញព្រះរាជាហើយ ក៏បានធ្វើនូវបដិសណ្ឋារៈ ដោយនយមានជាអាទិ៍ ថា ៖

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

(២២) បពិត្រព្រះមហារាជ ព្រះអង្គទ្រង់ស្តេច [1] យាងមកប្រពៃហើយ, មួយទៀត ព្រះរាជដំណើរ របស់ព្រះអង្គ មិនមែនទាស់ទេ ។

ព្រះរាជា ទ្រង់មានព្រះទ័យជ្រះថ្លា ក្នុងបដិសណ្ឋារៈ របស់សត្វសេកឈ្មោះ បុបួកៈ នោះហើយ ទ្រង់ត្រាស់សរសើរ នូវសេក ឈ្មោះបុបួកៈ ទ្រង់បានតិះដៀល នូវសេកឈ្មោះសត្តិគុម្ពៈ ក្រៅនេះ ដោយព្រះតម្រាស់ ថា ៖

សត្វបក្សី ទ្វិ ជាតិនេះ ជាសត្វដ៏ល្អ ប្រកប [2] ដោយធម៌ដ៏ក្រៃលែង តើឬ?, បំផ្លែកតែបក្សីសេក ក្រៅពីនេះនុ៎ះ និយាយតែពាក្យអាក្រក់ ។

សេកឈ្មោះ បុបួកៈ ស្តាប់នូវព្រះរាជឱង្ការនោះហើយ ទើបបានក្រាបទូលថា " បពិត្រព្រះមហារាជ ទូលព្រះបង្គំ មានមាតាជាមួយគ្នា នឹងសត្វសេកសត្តិគុម្ពៈនោះ, ប៉ុន្តែសេកសត្តិគុម្ពៈនោះ ជាត់ធំឡើងហើយ ក្នុងសំណាក់នៃមនុស្សមិនល្អ ត្រូវពួកមនុស្សមិនល្អទាំងនោះ ដឹកនាំហើយ ដោយចោរធម៌, (ចំណែក) ទូលព្រះបង្គំ ជាត់ធំឡើងហើយ ក្នុងសំណាក់នៃពួកមនុស្សល្អ

១- សុត្តន្តបិដក ភាគទី ៦០ ទំព័រទី ៩៩ ។

២- សុត្តន្តបិដក ភាគទី ៦០ ទំព័រទី ១០០-១០១ ។

មង្គលត្ថទីបនីប្រែ

ត្រូវបានមនុស្សទាំងនោះ ដឹកនាំហើយ ដោយឥសីធម៌, ហេតុនោះ ទើបទូលព្រះបង្គំទាំង ២ ផ្សេងពីគ្នា ដោយធម៌ " ដូច្នេះហើយ កាលសំដែងធម៌ ដល់ព្រះរាជា ទើបបានពោលគាថាទាំងនេះ ថា៖

(២៣) បពិត្រព្រះរាជា ពិតណាស់ បុគ្គលគប់រកនូវបុគ្គលបែបណា ។ ទោះជាសប្បុរស ឬ អសប្បុរស មានសីល ឬ ឥតសីល រមែងលុះអំណាចបុគ្គលនោះឯង ។ បុគ្គល ធ្វើបុគ្គលបែបណាឲ្យជាមិត្រ និង ចូលទៅគប់រកនូវបុគ្គលបែបណា, បុគ្គលនោះ ក៏មានអាការបែបនោះដែរ, ព្រោះកិរិយាសៅរ្មៃ ក៏រមែងប្រាកដដូច្នោះ ។ អាចារ្យត្រូវកូនសិស្សគប់រក រមែងប្រទ្បាក់នូវកូនសិស្សអ្នកប៉ះពាល់ហើយ រមែងប្រទ្បាក់កូនសិស្សអ្នកប៉ះពាល់ ដែលមិនបានប្រទ្បាក់ហើយ ប្រៀបឧបមាដូចជាកូនសរ ដែលជ្រលក់ដោយថ្នាំពិស តែងប្រទ្បាក់បំពង់សរដូច្នោះឯង, ព្រោះភ័យខ្លាចអំពីការប្រទ្បាក់ អ្នកប្រាជ្ញទើបមិនយកបុគ្គលលាមកជាសំឡាញ់សោះឡើយ ។ ជនណាខ្ចប់នូវត្រីស្អុយ ដោយចុងស្បូវភ្លាំង, សូម្បីស្បូវភ្លាំង ក៏មានក្លិនស្អុយ ផ្សាយបេញទៅដែរ យ៉ាងណាមិញ, ការចូលទៅគប់រកនឹងបុគ្គលពាល (របស់ជនណោះ) ក៏យ៉ាងដូច្នោះដែរ ។

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

ជនណា ខ្ជប់ខ្ជឹមក្រឹស្នា ដោយស្លឹកឈើ សូម្បីស្លឹកឈើ ក៏មានក្លិនក្រអូប ផ្សាយបេញទៅដៃរ យ៉ាងណាមិញ, ការបួលទៅសេពគប់ នូវអ្នកប្រាជ្ញ (របស់ជនោះ) ក៏យ៉ាងដូច្នោះដៃរ ។ ព្រោះហេតុនោះ បុគ្គលជាបណ្ឌិត ដឹងច្បាស់នូវបញ្ញាចាស់ទុំរបស់ខ្លួន ដូចជាកញ្ចប់ស្លឹកឈើហើយ មិនគួរសេពគប់ នូវពួកអសប្បុរស គួរសេពគប់តែនឹងពួកសប្បុរស, (ត្បិត) ពួកអសប្បុរស តែងនាំទៅកាន់នរក, ពួកសប្បុរស តែងផ្តល់នូវសុគតិ ។

(២៤) បណ្តាបទទាំងនោះ បទថា “ ***សន្តំ*** *” បានដល់ សប្បុរស ។ បទថា “* ***អសំ*** *” បានដល់ អសប្បុរស ។ បទថា “* ***សេវមានោ*** *” បានដល់អាចារ្យ ។ បទថា “* ***សេវមានំ*** *” បានដល់ អន្តេវាសិក ។ បទថា “* ***សម្ពុដ្ឋោ*** *” បានដល់ អាចារ្យដែលអន្តេវាសិក ពាល់ត្រូវហើយ ។ ២ បទថា “* ***សម្ពុសំ បវំ*** *” បានដល់ បុគ្គលដទៃ គឺ អន្តេវាសិក ដែលប៉ះពាល់ នូវអាចារ្យ ។ បទថា “* ***អលិត្តំ*** *” មានសេចក្តីថា អាចារ្យនោះ រមែងប្រឡាក់នូវអន្តេវាសិកនោះ ជាអ្នកដែលបាបធម៌ មិនបានប្រឡាក់ហើយ ប្រៀបដូចជាកូនសរដែលកំណាច គឺ ដែលជ្រលក់ហើយដោយថ្នាំពិស ប្រឡាក់នូវបំពង់សរ ដែលមិនបានប្រឡាក់ យ៉ាង*

មង្គលត្ថទីបនីប្រែ

ដូច្នោះឯង ។ ពិតណាស់ បុគ្គលអ្នកសេពគប់ នូវបុគ្គលពាល សូម្បីមិនបានធ្វើនូវអំពើអាក្រក់ ក៏រមែងបានទទួល នូវការពោលតិះដៀល និង ការនិន្ទា ថា " ជាអ្នកសេពគប់ជាមួយនឹងបុគ្គលពាល " ដូច្នេះដែរ, ហេតុនោះ ទើបសេកបុប្ផកៈពោល ថា " **ឯវំ ពាលូបសេវនា** " ។ (ចំណែក) បុគ្គលអ្នកសេពគប់ជាមួយនឹងអ្នកប្រាជ្ញ សូម្បីមិនអាច ដើម្បីនឹងកើតជាអ្នកប្រាជ្ញ ក៏រមែងបានទទួល នូវឈ្មោះសំឡេងដ៏ល្អ ថា " ជាអ្នកសេពគប់ជាមួយនឹងកល្យាណមិត្ត " ដូច្នេះដែរ ព្រោះហេតុនេះ ទើបសេកបុប្ផកៈពោលថា " **ឯវំ ធីរូបសេវនា** " ។

បទថា "**បុត្តបុជស្សវ**" គឺដូចស្វឹកឈើសម្រាប់ខូបគន្ធជាតិ មានក្រស្នាជាដើមទុំៈឯង ។ បទថា "**សម្បាកំ**" គឺ ដឹងថាខ្លួនអប់រំហើយ ដោយអំណាចការជាប់ជំពាក់នឹងកល្យាណមិត្រ ។

បទថា " **សន្តោ** " មានសេចក្តីថា ពួកជន ជាសម្មាទិដ្ឋិ រមែងញុំាងពួកសត្វដែលអាស្រ័យខ្លួនឲ្យដល់ឋានសួគ៌តែម៉្យាង ។

ព្រះរាជា ទ្រង់ជ្រះថ្លាហើយ ក្នុងធម្មកថា របស់សត្វសេកបុប្ផកៈនោះ ទ្រង់ថ្វាយបង្គំនូវពួកតាឥសី ដែលត្រឡប់មកវិញហើយ ទ្រង់មានព្រះរាជឱង្ការ ថា " បពិត្រព្រះគុណម្ចាស់ដ៏ចំរើនទាំងឡាយ បើព្រះគុណម្ចាស់ទាំងឡាយ អនុគ្រោះយើងខ្ញុំ ក៏សូម

គង់ នៅក្នុងព្រះនគរ របស់យើងខ្ញុំចុះ " ដូច្នេះហើយ ក៏ស្តេចយាងទៅកាន់ព្រះនគរ ទ្រង់ព្រះរាជទានអភ័យ ដល់សត្វសេកទាំងឡាយ ហើយទ្រង់ត្រាស់ឲ្យគណៈតាឥសី ដែលមកហើយ ក្នុងព្រះនគរនោះ នៅក្នុងព្រះរាជឧទ្យាន ទ្រង់បានទំនុកបំរុងរហូតអស់ព្រះជន្មាយុហើយ ទ្រង់បំពេញផ្លូវទៅកាន់ឋានសួគ៌ ។ ចំណែកសត្វសេកបុបួក: អាស្រ័យនៅក្នុងព្រៃ ទៅតាមយថាកម្មហើយ ។ រឿងសត្វសេក ក្នុងអដ្ឋកថាសត្តិគុម្ពជាតក ក្នុងវីសតិនិបាត(ចប់)។

(២៥) ក្នុងអតីតកាល ព្រះរាជាព្រហ្មទត្ត ក្នុងព្រះនគរពារាណសី មានដំរីមង្គល ឈ្មោះមហិឡាមុខ ជាសត្វមានសីលបរិបូណ៌ដោយមារយាទ មិនចេះបៀតបៀនអ្នកណាម្នាក់ឡើយ ។

ក្រោយមក ថ្ងៃមួយ ក្នុងពេលរាត្រី ពួកចោរ មកហើយបានអង្គុយប្រឹក្សាគ្នា នៅក្បែរពោធដំរី របស់ព្រះរាជាអង្គនោះ ថា " ពួកយើង ត្រូវទំលាយខុមង្គ (រូង) យ៉ាងដូច្នេះ, ត្រូវធ្វើកម្ម គឺការកាត់ទី-ត យ៉ាងដូច្នេះ, ការដែលពួកយើងទំលាយខុមង្គ និងធ្វើនូវការកាត់ទី-ត ហើយ លួចយកនូវភណ្ឌៈ ទើបគួរ, កាលនឹងលួចយក ត្រូវតែសម្ងាប់ និង វាយដំ (ម្ចាស់ទ្រព្យ) ហើយទើបលួចយកទៅ, កាលធ្វើយ៉ាងដូច្នេះ នឹងមិនមានអ្នកណា អាចដើម្បីនឹងក្រោកឡើង (មកតស៊ូបាន), ក៏ធម្មតាចោរ មិនត្រូវ

មង្គលត្ថទីបនីប្រែ

មានសីលាចារវត្តឡើយ, ត្រូវតែជាអ្នកកំណាច យោរយៅ កាច សាហាវ ” ដូច្នេះ ។ ពួកចោរទាំងនោះ ប្រឹក្សាគ្នា ដូច្នេះហើយ ក៏បានណាត់គ្នាទៅវិញ្ញៅមកស្រេច ទើបនាំគ្នាទៅហើយ ។ ពួកចោរទាំងនោះ មកប្រឹក្សាគ្នា ក្នុងទីនោះ ដោយឧបាយនេះឯង អស់ពេលជាច្រើនថ្ងៃ ។

ជំរី បានស្តាប់ពាក្យ របស់ពួកចោរទាំងនោះហើយ ក៏សម្គាល់ ថា “ ពួកចោរទាំងនេះ ញុាំងអញឲ្យសិក្សា ” ហើយ គិតថា “ ក្នុងពេលឥឡូវនេះ អាត្មាអញ ត្រូវតែជាសត្វកាចសាហាវ យោរយៅ ”ដូច្នេះហើយ ក៏បានក្លាយជាសត្វ យ៉ាងដូច្នោះមែន ។ ជំរីនោះ បានយកប្រមោយ ចាប់អ្នកថែរក្សាជំរី ដែលមកហើយ ។ អំពីព្រឹកព្រលឹមស្រាង ចោកទៅលើផែនដី ឲ្យស្លាប់ហើយ ។

ពួកមនុស្ស បានក្រាបទូលហើយ ដល់ព្រះរាជា ។ ព្រះរាជា ទ្រង់បានបញ្ជូនទូវអាមាត្យម្នាក់ទៅ ដោយព្រះរាជឱង្ការ ថា “ នែបណ្ឌិត អ្នកចូរទៅចុះ, ចូរ (ពិនិត្យ) ឲ្យបានដឹងថា ព្រោះហេតុអ្វី បានជាជំរីនោះ ក្លាយទៅជាសត្វកាចសាហាវ ដូច្នេះ ” ។

អាមាត្យនោះ ទៅហើយ ក៏មិនឃើញមានរោគ ក្នុងខ្លួននៃជំរី ទើបគិតថា “ ជំរីនេះ បានកាចសាហាវហើយ ព្រោះហេតុអ្វី ? ” ដូច្នេះ កាលពិចារណាទៅ ទើបធ្វើការសន្និដ្ឋាន ថា “ ជំរី

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

នោះ ពិតជាបានស្តាប់ពាក្យអាក្រក់ របស់ជនពួកខ្លះ ក្នុងទីដែលមិនគ្រាយ ដោយពិត ទើបបានក្លាយទៅជាសត្វ ដ៏កាចសាហាវ ” ហើយ បានសួរពួកជនអ្នកថែរក្សាជំរី ថា “ តើមានបុគ្គលណាខ្លះ ធ្លាប់និយាយអ្វី ៗ ក្នុងពេលរាត្រី នៅក្បែរពោធជំរីដែរឬទេ ” ។ ពួកអ្នកថែរក្សាជំរី ពោលថា “ បពិត្រនាយ មាន, ពួកចោរ បានមកប្រឹក្សាគ្នា ” ។ អាមាត្យនោះ បានទៅហើយ ក្រាបទូលថា “ បពិត្រព្រះសម្មតិទេព ក្នុងខ្ទួននៃជំរី មិនមានការចំឡែកអ្វីដទៃឡើយ, ជំរីនោះ បានស្តាប់ពាក្យរបស់ពួកចោរហើយ ទើបបានជាសត្វ ដ៏កាចសាហាវ, ឥឡូវនេះ គួរតែនិមន្តពួកសមណៈ និងព្រាហ្មណ៍ អ្នកមានសីល ឲ្យគង់អង្គុយនៅ ក្បែរពោធជំរី ហើយសូត្រវឿងសីល និង មារយាទ ” ។ ព្រះរាជា ទ្រង់ត្រាស់ឲ្យធ្វើហើយយ៉ាងដូច្នោះ ។ សមណៈនិងព្រាហ្មណ៍ទាំងឡាយនោះ បានពោលវឿងសីល ថា “ អ្នកមិនគួរចាប់អ្នកណាមួយឡើយ, មិនគួរសម្លាប់អ្នកណាម្នាក់ឡើយ, គួរជាអ្នកបរិបូណ៌ដោយសីល និង មារយាទ ប្រកបដោយខន្តី មេត្តា និង សេចក្តីអនុគ្រោះ ” ។ ជំរីស្តាប់ពាក្យនោះហើយ ទើបសម្គាល់ថា “សមណៈ និងព្រាហ្មណ៍ទាំងនេះ ញុាំងអញឲ្យសិក្សា ” ហើយគិតថា “ តាំងតែអំពីពេលនេះតទៅ អញ ត្រូវតែមានសីល ” ដូច្នេះហើយ ក៏បានប្រែក្លាយ

មង្គលត្ថទីបនីប្រែ

ទៅជាសត្វមានសីលវិញហើយ ។

រឿងដ៏រឹមហិឡាមុខ ក្នុងអដ្ឋកថាមហិឡាមុខជាតក ក្នុងឯកនិបាត ចប់ ។

(រឿងសេះឈ្មោះបណ្ឌវៈ)

(២៦) ក្នុងអតីតកាល បានមានព្រះរាជា ទ្រង់ព្រះនាមថា សាមៈ ក្នុងក្រុងពារាណសី ។ ព្រះពោធិសត្វ បានជាអាមាត្យអ្នកបង្រៀនអត្ថ និង ធម៌ របស់ព្រះរាជាអង្គនោះ ។ ក៏ព្រះរាជា ទ្រង់មានសេះមង្គល ឈ្មោះបណ្ឌវៈ ។ អ្នកគង្វាលសេះរបស់ព្រះអង្គ ឈ្មោះ គិរិទត្ត ជាមនុស្សខ្វក ។ សេះ ឃើញអ្នកគង្វាលសេះនោះ ចាប់ខ្សែបង្ហៀរ (ដឹក) នាំមុខហើយ ក៏សម្គាល់ ថា " អ្នកគង្វាលសេះនេះ ញុំាងអញឲ្យសិក្សា " ដូច្នេះហើយ ទើបយកជាតម្រាប់តាមអាការ របស់អ្នកគង្វាលសេះនោះ បានក្លាយទៅជាសេះខ្វកហើយ ។ ព្រះរាជា ទ្រង់ជ្រាបថា សេះ របស់ព្រះអង្គនោះខ្វកហើយ ទើបទ្រង់បានត្រាស់បញ្ជូនទូវពួកទេព្យទៅ (ឲ្យត្រួតពិនិត្យមើល) ។ ពួកពេទ្យទាំងនោះ ទៅហើយ មិនឃើញរោគនៅក្នុងខ្លួន របស់សេះនោះ ទើប (ត្រឡប់មក) ក្រាបទូលព្រះរាជា ថា " ទូលព្រះបង្គំ មិនបានឃើញរោគ របស់សេះនោះទេ " ។ ព្រះរាជា ទ្រង់បញ្ជូន ទូវព្រះពោធិសត្វទៅ ដោយព្រះរាជឱង្ការថា " ចូរអ្នកទៅ (ត្រួតពិនិត្យមើលឲ្យ) ដឹងនូវហេតុ ក្នុងដំណើរ

នោះ ” ។ ព្រះពោធិសត្វនោះ ទៅហើយ បានដឹងថា សេះនោះ ជើរខ្វក ។ ព្រោះការជាប់ទាក់ទងជាមួយគ្នា នឹងអ្នកគង្វាលសេះ ជើងខ្វក ទើបបានក្រាបទូលថា “ បពិត្រមហារាជ សេះ មាន ជើងខ្វក យ៉ាងដូច្នេះ ព្រោះទោស នៃការជាប់ទាក់ទងជាមួយគ្នា ” ដូច្នេះហើយ ទើបបានក្រាបទូលថា “ សេះនោះបានទូវអ្នកគង្វាល សេះ ដែលល្អហើយ ក៏និងក្លាយជាសេះដូចដើមវិញ ” ។ ព្រះ រាជា ទ្រង់ត្រាស់បញ្ជាឲ្យធ្វើហើយ យ៉ាងដូច្នោះ ។ សេះ បាន តាំងនៅ ក្នុងភាពជាប្រក្រតីហើយ ។

រឿងសេះបណ្ដាវ: ក្នុងអដ្ឋកថាគិរិទត្តជាតក ក្នុងទុកនិបាត ចប់ ។

(រឿងផ្លែស្វាយ)

(២៧) ក្នុងអតីតកាល ក្នុងក្រុងពារាណសី បានមានព្រះ រាជា ទ្រង់ព្រះនាមថា ធនិវាហនៈ ។ ព្រះពោធិសត្វ ជាអាមាត្យ អ្នកបង្រៀនអត្ថ និង ធម៌ របស់ព្រះអង្គ ។ ក្រោយមក ថ្ងៃមួយ ព្រះរាជា ទ្រង់ត្រាស់បញ្ជាឲ្យតាំងបន្ទាយ នៅទិសខាងជើង និង ខាងត្បូង ក្នុងមហានទីហើយ ទ្រង់ក្រសាលព្រះរាវី ។ ផ្លែស្វាយទុំ ជាគ្រឿងសោយ របស់ទេវតា មួយផ្លែ បានអណ្ដែតមក អំពីស្រះ កណ្ដាមុណ្ដា បានមកជាប់ ត្រង់បន្ទាយហើយ ។ ពួករាជបុរស កាលតាំងបន្ទាយ ក៏ឃើញផ្លែស្វាយនោះហើយ ទើប (យកទៅ)

ថ្វាយដល់ព្រះរាជា ។ ព្រះរាជា ទ្រង់ត្រាស់សួរពួកព្រានព្រៃ ថា " នេះជាផ្លែឈើអ្វី " ហើយ ទ្រង់ព្រះសណ្តាប់ ថា " នេះ គឺជាផ្លែស្វាយ " ដូច្នេះ ទើបទ្រង់សោយហើយ ត្រាស់បញ្ជា ឲ្យបណ្តុះគ្រាប់ ក្នុងព្រះឧទ្យាន របស់ព្រះអង្គស្រេចហើយ ទើបទ្រង់ត្រាស់បញ្ជា ឲ្យយកទឹកដែលផ្សំដោយទឹកដោះ មកស្រោច ។ ដើមឈើ (ស្វាយ) បានធំឡើងហើយ ក៏ឲ្យផល ក្នុងឆ្នាំ ទី ៣ ។ ដើមស្វាយ បានមានសក្ការៈ ដ៏ច្រើនហើយ ។ ពួកអ្នកនគរ យកទឹកដែលផ្សំ ដោយទឹកដោះស្រស់ មកស្រោច ឲ្យនូវការក្បិត ដោយគ្រឿងក្រអូប ៥ កន្ទេង បំពាក់ នូវកម្រងផ្កាទាំងឡាយ ទ្រោលប្រទីប ដោយប្រេងក្រអូប ។ មួយទៀត បានមានការរុំព័ទ្ធដើមស្វាយនោះ ដោយសំពត់រនាំងវាំងនន ។ ផ្លែ (ស្វាយ) ទាំងឡាយ បានមានរសជាតិដ៏ផ្អែមឆ្ងាញ់ មានពណ៌សម្បុរដូចមាស ។ ព្រះរាជា កាលទ្រង់បញ្ជូននូវផ្លែស្វាយទៅថ្វាយ ដល់ព្រះរាជាទាំងឡាយជទៃ ។ ទៀត ទ្រង់បានត្រាស់បញ្ជា ឲ្យយកចុងដែកកណ្តារមកចោះ ត្រង់ទីកើតនៃពន្លកហើយ ទើបត្រាស់ឲ្យបញ្ជូនទៅ ។ គ្រាប់ស្វាយ ដែលព្រះរាជាទាំងនោះ សោយផ្លែស្វាយហើយ ទ្រង់ត្រាស់បញ្ជា ឲ្យអាមាត្យបណ្តុះ មិនបានសម្រេចឡើយ ។

គ្រានោះ ព្រះរាជាមួយព្រះអង្គ ទ្រង់ជ្រាប នូវហេតុនោះ

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

ទើបទ្រង់ព្រះរាជាទានទ្រព្យមួយពាន់ហើយ ទ្រង់បញ្ជូនបុរសអ្នកថែរក្សាឧទ្យានម្នាក់ទៅ ដោយព្រះរាជឱង្ការ ថា " ចូរអ្នកទៅចុះ, ចូរធ្វើរសជាតិនៃផ្លែស្វាយ របស់ព្រះបាទធនវាហនៈ ឲ្យវិនាសហើយ ធ្វើឲ្យមានរសជាតិល្វីងវិញ " ។ បុរសអ្នកថែរក្សាឧទ្យាននោះ ទទួលព្រះរាជឱង្ការ ថា " ព្រះករុណាថ្លៃវិសេស " ហើយក៏បានចូលទៅគាល់ព្រះរាជាព្រះនាមធនវាហនៈ បានក្រាបទូលថា ខ្ញុំជាអ្នកថែរក្សាឧទ្យានហើយ ទើបក្រាបទូលនូវអានុភាព របស់ខ្លួន ។ ព្រះរាជា ទ្រង់បញ្ជាឲ្យបុរសអ្នករក្សាឧទ្យាននោះ នៅក្នុងសំណាក់របស់អ្នករក្សាឧទ្យាន របស់ព្រះអង្គហើយ ។ តាំងអំពីពេលនោះមក ជនទាំង ២ នាក់ ក៏នាំគ្នាជួយរក្សានូវឧទ្យាន ។ បុរសអ្នកថែរក្សាព្រះឧទ្យាន ដែលទើបនឹងមកថ្មី ញាំងផ្កាឈើដែលមិនមែនជារដូវកាល ឲ្យរីកស្គុសស្គាយ ញាំងផ្លែឈើដែលមិនមែនជារដូវកាល ឲ្យមានផ្លែ បានធ្វើហើយនូវឧទ្យាន ឲ្យក្លាយទៅជារម្មណីយស្ថាន ។ ព្រះរាជាទ្រង់សព្វព្រះរាជហឫទ័យហើយ ទ្រង់ដកអ្នកថែរក្សាព្រះឧទ្យានចាស់ចេញ ទ្រង់បានព្រះរាជទានហើយ នូវព្រះឧទ្យាន ដល់អ្នកថែរក្សាព្រះឧទ្យាន ដែលមកថ្មីនោះតែម្នាក់ឯងគត់ ។ អ្នកថែរក្សាព្រះឧទ្យានដែលមកថ្មីនោះ ក៏ដាំដើមស្ពៅ និង វល្លិពេជ្រទាំងឡាយ ព័ទ្ធព័ន្ធជុំវិញដើមស្វាយហើយ ។

មង្គលត្ថទីបនីប្រែ

ដើមស្ដៅ និង វល្លិបណ្ដូលពេជ្រទាំងនោះ ក៏បានដុះលូតលាស់ឡើងហើយ ដោយលំដាប់ ។ ឫសនិងមែកទាំងឡាយរបស់ដើមស្វាយ បានពាក់ព័ន្ធគ្នាហើយ ជាមួយនឹងឫស និងមែកទាំងឡាយ (របស់ដើមស្ដៅ និង វល្លិបណ្ដូលពេជ្រ), ព្រោះការពាក់ព័ន្ធគ្នានឹងរបស់ដែលគ្មានរសជាតិផ្អែមនោះ ដើមស្វាយ ដែលមានរសជាតិផ្អែមប្រមាណប៉ុណ្ណោះ ទើបក្លាយទៅជាមានរសជាតិល្វីង ដូចជារសជាតិ នៃស្ងឹកស្ដៅ ។ អ្នកថែរក្សាព្រះឧទ្យាន ដឹងថា ផ្លែស្វាយមានរសជាតិល្វីងហើយ ក៏គេចចេញទៅហើយ ។ ព្រះរាជាទ្រង់ស្ដេចយាងទៅកាន់ព្រះឧទ្យាន កាលទ្រង់សោយផ្លែស្វាយទ្រង់មិនអាច ដើម្បីលេបសាច់នៃផ្លែស្វាយ ដែលដូចជាកាក នៃស្ដៅបានឡើយ ទ្រង់ខាក ស្ដោះចេញហើយ ទ្រង់ត្រាស់សួរព្រះពោធិសត្វថា " នែបណ្ឌិត ដើមឈើ (ស្វាយ) នេះ មិនមានការខូចខាត អំពីការបរិហារមុនៗ ឡើយ, កាលបើយ៉ាងដូច្នោះ ផ្លែរបស់ដើមស្វាយនោះ ក៏បានក្លាយទៅជាមានរសជាតិល្វីងវិញ, តើមានហេតុអ្វីទៅហ្ន៎ ? " ។

ព្រះពោធិសត្វនោះ កាលក្រាបទូល នូវហេតុនៃផ្លែស្វាយមានរស់ជាតិល្វីងនោះ ទើបក្រាបទូល ថា ៖

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

(២៨) បពិត្រព្រះរាជាទ្រង់ព្រះនាមទធិវាហនៈ[1] ដើមស្វាយរបស់ព្រះអង្គ មានដើមស្តៅ ដុះរួបរឹតជុំវិញ ឫស ប្រឡំគ្នាដោយឫស, មែកពាក់ព័ន្ធគ្នានឹងមែក, ដោយការនៅជាមួយនឹងដើមស្តៅ ដែលមិនមានរសជាតិផ្អែម ព្រោះហេតុនោះ បានជាស្វាយត្រឡប់ជាមានផ្លែល្វីងទៅវិញ ។

ដើមស្តៅ ឈ្មោះថា បុថិមនូ: ក្នុងគាថានោះ ។ មែករបស់ដើមស្តៅ ឈ្មោះថា សាខា ។ ២ បទថា " ***សាខំ និសេវតេ*** *" គឺ រមែងពាក់ព័ន្ធនូវមែករបស់ដើមស្វាយ ។ បាទគាថាថា "* ***អសាត-សន្និវាសេន*** *" គឺ ព្រោះការនៅរួមជាមួយ នឹងដើមស្តៅដែលមិនមានរសជាតិផ្អែម ។ បទថា "* ***តេន*** *" ប្រែថា ព្រោះហេតុនោះ ។ បទថា "* ***កដុកប្ផលោ*** *" គឺ ប្រែត្រឡប់ទៅជាមានផ្លែល្វីងទៅវិញ ។ ព្រះរាជា ទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ ទ្រង់ត្រាស់បញ្ជា ឲ្យកាត់នូវដើមស្តៅ និង រលិបណ្តូលពេជ្រទាំងអស់ចោល ហើយទ្រង់ឲ្យជកឫសចេញ ទ្រង់ត្រាស់ឲ្យនាំយកអាចម៍ដី ដែលមិនមានរសជាតិផ្អែម ដោយជុំវិញចេញហើយ ទ្រង់ត្រាស់ឲ្យដាក់អាចម៍ដីដែលមានរសជាតិផ្អែម ទ្រង់ត្រាស់បញ្ជា ឲ្យស្រោចនូវដើមស្វាយដោយទឹកដែលផ្សំដោយទឹកដោះស្រស់ ទឹកផ្សំដោយស្ករ និង ទឹក*

១- សុត្តន្តបិដក ភាគទី ៥៨ ទំព័រទី ៩១ ។

ដែលផ្សំដោយគ្រឿងក្រអូបថ្មីទៀត ហើយទ្រង់បានប្រគល់នូវព្រះឧទ្យានឲ្យដល់អ្នកថែរក្សាព្រះឧទ្យានមុន ដូចដើមវិញម្តងទៀត ។ ស្វាយ ក៏បានក្លាយទៅជាមានរសជាតិផ្អែមឆ្ងាញ់ ដូចដើមវិញម្តងទៀត ព្រោះជាប់ទាក់ទងគ្នានឹងរបស់ដែលមានរសជាតិផ្អែម ។

រឿងស្វាយ ក្នុងអដ្ឋកថាទធិវាហនជាតក ក្នុងទុកនិបាត ចប់ ។

(២៩) សូម្បីតែរបស់ដែលមិនមានជីវិត ក៏ក្លាយទៅជារបស់ដែលគេមិនត្រូវការចង់បាន ព្រោះប្រកបជាមួយនឹងរបស់ដែលគេមិនត្រូវការចង់បាន បានក្លាយទៅជារបស់ដែលគេប្រាថ្នាចង់បាន ព្រោះប្រកបដោយរបស់ដែលគេប្រាថ្នាចង់បាន ដូចបានពណ៌នាមកនេះឯង, នឹងចាំបាច់ពោលធ្វើអ្វី ក្នុងរបស់ដែលមានជីវិតនុ៎ះឡើយ ។

ដោយហេតុនោះ ក្នុងអត្ថុប្បត្តិហេតុ នៃទធិវាហនជាតក ទើបព្រះដ៏មានព្រះភាគ ទ្រង់បានត្រាស់ថា “ ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា ការនៅរួមជាមួយមនុស្សមិនល្អ ជារឿងលាមក បង្កើតតែរឿងរ៉ាវដែលគ្មានប្រយោជន៍, មិនចាំបាច់ពោលទៅធ្វើអ្វី ក្នុងការនៅរួមជាមួយនឹងមនុស្សមិនល្អនោះឡើយ ព្រោះការនៅរួមជាមួយនឹងមនុស្សអាក្រក់ ធ្វើសេចក្តីអន្តរាយមិនមែនជាប្រយោជន៍ដល់បុគ្គលជាមនុស្សទាំងឡាយ មុនសិន, សូម្បីដើមស្វាយដែល

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

មិនមានចេតនា មានរសជាតិផ្អែម ប្រៀបស្មើនឹងរសជាតិទឹកអាស្រ័យការនៅរួម ជាមួយគ្នានឹងដើមស្ពៃ ដែលមានរស់ជាតិល្វីង មិនមានរសជាតិផ្អែម ក៏បានក្លាយទៅជាដើមឈើ ដែលមានរសជាតិមិនផ្អែម មានរសជាតិល្វីងទៅវិញ ក្នុងកាលមុន" ។

(ជំនពាលដូចអមិត្រ បណ្ឌិតដូចជាញាតិ)

(៣០) មួយវិញទៀត បុគ្គលពាលទាំងឡាយ ប្រៀបដូចជាអមិត្រដែលមានជាវនៅនឹងដៃ, បណ្ឌិតទាំងឡាយ ប្រៀបដូចជាញាតិដែលជាទីស្រឡាញ់ ។ ពិតមែនដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់ប្រថាប់គង់ ធ្វើតំបន់វេឡុវគ្រាម ដែលតាំងនៅមិនឆ្ងាយ ខាងទិសទក្សិណ នៃទីក្រុងវេសាលី ឲ្យជាគោចរគ្រាម បានកើតព្រះប្រឈួនធ្ងាក់ព្រះលោហិត ។ ស្តេចសក្កទេវរាជ ទ្រង់ជ្រាបហេតុនោះហើយ ស្តេចយាងមក ឧបដ្ឋាកព្រះសាស្តា ទ្រង់មិនឲ្យអ្នកជំទែប៉ះពាល់ នូវភាជន:សម្រាប់រងសរីរវេលញ្ជ: (លាមកក្នុងសរីរ:) របស់ព្រះសាស្តា សូម្បីដោយដៃឡើយ ទ្រង់ទូលលើព្រះសិរសីតែម្តង ហើយនាំយកទៅ ជួចជាបុគ្គលនាំយកនូវភាជន:សម្រាប់ជាក់គ្រឿងក្រអូបទៅដូច្នោះ ។ ស្តេចសក្កទេវរាជនោះ ទ្រង់ឧបដ្ឋាក យ៉ាងដូច្នេះហើយ ក្នុងពេលដែលព្រះបរមសាស្តា ទ្រង់បានសប្បាយហើយ ទើបស្តេចយាងទៅកាន់ទេវលោក ។

មង្គលត្ថទីបនីប្រែ

ពួកភិក្ខុទាំងឡាយ បាននិយាយគ្នាថា "គួរឲ្យអស្ចារ្យមែន ស្តេចសក្កទេវរាជ មានសេចក្តីស្រឡាញ់ ចំពោះព្រះសាស្តា, ព្រះអង្គ ទ្រង់បានលះបង់ នូវទិព្វសម្បត្តិ ទ្រង់មកឧបដ្ឋាកហើយ " ។ ព្រះសាស្តា ទ្រង់ត្រាស់ថា " ម្នាលភិក្ខុទាំងឡាយ ស្តេចសក្កទេវ-រាជ ទ្រង់ពិចារណាឃើញថា កិរិយាជួបប្រទះ នូវព្រះអរិយៈទាំងឡាយក្តី ភាវៈគឺកិរិយាមានការអង្គុយជាដើម ក្នុងទីកន្លែងជាមួយនឹងព្រះអរិយៈទាំងឡាយនោះក្តី ភាវៈគឺការបានធ្វើនូវវត្ត និង វត្តតប ដល់ព្រះអរិយៈទាំងឡាយនោះក្តី ជាហេតុញុំាងប្រយោជន៍ឲ្យសម្រេចបាន ដូច្នេះហើយ ទើបទ្រង់ស្តេចយាងមកឧបដ្ឋាក នូវតថាគត " យ៉ាងដូច្នេះ កាលទ្រង់សំដែង (នូវសេចក្តីនោះ) ទើបទ្រង់បានភាសិតគាថាទាំងឡាយ ក្នុងវឿងនៃស្តេចសក្កទេវិន្ទ ក្នុងសុខវគ្គ នៃធម្មបទ ថា ៖

(៣១) មែនពិត បុគ្គលអ្នកប្រព្រឹត្តសេពគប់ [1] ដោយជន ពាល រមែងសោកសៅ អស់កាលដ៏យូរអង្វែង, ការនៅរួមជាមួយនឹងជនពាល រមែងជាទុក្ខ សព្វកាល ដូចការនៅរួមជាមួយគ្នានឹងសត្រូវ, បំណែកខាងបណ្ឌិត មានការនៅរួមជា

១- សុត្តន្តបិដក ភាគទី ៥២ ទំព័រទី ៦៤-៦៥ ។

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

សុខ ប្រៀបដូចជាការជួបជុំ នៃញាតិទាំងឡាយ, ព្រោះហេតុនោះឯង បុគ្គល គួរសេពគប់នូវសប្បុរស ជាអ្នកមាំមួនផង មានបញ្ញាផង មានសេចក្តីបេះដឹងប្រើនផង មានកិរិយានាំទៅនូវធុរៈជាប្រក្រតីផង មានសីលវត្ត និង ធុតង្គវត្តផង ជាអ្នកឆ្ងាយចាកកិលេសផង មានបញ្ញាដ៏ល្អផង មានសេចក្តីបេះដឹងប្រើនផង មានកិរិយានាំទៅនូវធុរៈ ជាប្រក្រតីផង មានសីលវត្ត និង ធុតង្គវត្តផង ជាអ្នកឆ្ងាយចាកកិលេសផង មានបញ្ញាដ៏ល្អផង ប្រាកដដូច្នោះនោះ ឱរ្យដូចជាព្រះបន្ទូគប់រកនូវផ្លែវនៃនក្ខត្តឫក្ស យ៉ាងដូច្នោះឯង ។

បណ្តាបទទាំងនោះ ជាទគាថា ថា “ ***ពាលសង្គតចារីហិ*** *” មានសេចក្តីថា មែនពិត គឺ ពិតណាស់ បុគ្គលអ្នកមានកិរិយាប្រព្រឹត្តិសេពគប់ ជាមួយនឹងជនពាល ។ បទថា “* ***ទីឃមទ្ធានំ*** *” មានសេចក្តីថា ជាអ្នកមានធនូ: ដូចគ្នា ជាមួយនឹងជនពាល កាលធ្វើ នូវកម្មអាក្រក់ មានការកាត់នូវទី-ត ជាដើម ទើបបានជួបប្រទះនូវសេចក្តីទុក្ខ មានត្រូវគេកាត់ដៃជាដើម ឈ្មោះថា រមែងសោកសៅ អស់កាលដ៏យូរអង្វែង ។ ការរស់នៅជាមួយគ្នា ឈ្មោះថា ការនៅរួមគ្នា ។ បទថា “* ***អមិត្តេនេវ*** *” មានសេចក្តីថា ប្រៀបបីដូចជាការនៅរួម ជាមួយគ្នានឹងសត្រូវ ដែល*

មង្គលត្ថទីបនីប្រែ

មានជាវជាប់នឹងដៃ ឬ សត្វសាហាវ មានអសិរពិសជាដើម ។ បទថា “ **សព្ភិ** ” គឺ ការនៅរួមជាមួយ នឹងពួកជនពាល រមែងជាទុក្ខជាប់ជានិច្ច ។ ការនៅរួមជាមួយនឹងបណ្ឌិតនោះ រមែងជាសុខ ព្រោះហេតុនោះ បណ្ឌិត ទើបឈ្មោះថា មានការនៅរួមជាសុខ, អធិប្បាយថា “ ការនៅរួមក្នុងទីជាមួយនឹងបណ្ឌិត ជាហេតុឲ្យបានសេចក្តីសុខ ” ។ ប្រៀបដូចជាអ្វី ។ ប្រៀបដូចសមាគមនៃពួកញាតិ ។ អធិប្បាយថា “ ប្រៀបបីដូចជាការជួបជុំ នៃពួកញាតិទាំងឡាយ ដែលជាទីស្រឡាញ់ ជាហេតុឲ្យបានសុខ ” ។ បទថា “ **តស្មា ហិ** ” មានសេចក្តីថា ការនៅរួមជាមួយនឹងជនពាល រមែងជាទុក្ខ ព្រោះហេតុណា, ការនៅរួមជាមួយបណ្ឌិត រមែងជាសុខ ព្រោះហេតុនោះ ។ បទថា “ **ធីរំ** ” គឺ ជាអ្នកដល់ព្រមដោយបញ្ញាជាគ្រឿងទ្រទ់ចាំ ។ បទថា “ **បញ្ញំ** ” បានដល់ អ្នកដល់ព្រមដោយបញ្ញាដែលជាលោកិយៈ និងលោកុត្តរៈ ។ បទថា “ **ពហុស្សុតំ** ” គឺ ជាពហុស្សូត ដោយបរិយត្តិ បដិបត្តិ និងបដិវេធ ។ បទថា “ **ធោរយ្ហសីលព្ឫតវន្តំ** ” បានដល់ ឈ្មោះថាជាអ្នកមានកិរិយានាំទៅនូវធុរៈ ព្រោះនាំទៅនូវធុរៈ ពោលគឺការញុំាងខ្លួន ឲ្យបានសម្រេចព្រះអរហត្តផល ជាអ្នកមានសីល និងមានធុតង្គ ។ បទថា “ **អរិយំ** ” ប្រែថា អ្នកឋិតនៅឆ្ងាយចាក

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

កិលេស ។ បទថា “ ***សុមេធំ*** *” បានដល់ អ្នកមានបញ្ញាល្អ ។ បទថា “* ***នក្ខត្តបថំ វ*** *” មានសេចក្តីថា ប្រៀបដូចជាព្រះចន្ទ គឺវិមាននៃព្រះចន្ទ គប់រកនូវអាកាសដែលជាផ្លូវ នៃនក្ខត្តឫក្សទាំងឡាយ ដូច្នោះឯង ។*

(តាបសឱ្យដំបូន្មានដល់បុត្រ)

(៣២) សូម្បីព្រះពោធិសត្វ កាលកើតជាតាបស នៅក្នុងហិមវន្តប្រទេស កាលនឹងទូន្មាននូវតាបសកុមារ ជាបុត្ររបស់ខ្លួន ដែលធុញទ្រាន់ ប្រាថ្នាចង់ចេញអំពីព្រៃហើយ ទៅរស់នៅ ក្នុងទីលំនៅស្ថាននៃមនុស្ស ទើបបានពោលនូវគាថាទាំងឡាយនេះ ក្នុងហាលិទ្ទកជាតក ក្នុងនវកនិបាត ថា ៖

បុគ្គលណា មិនមានអំពើអាក្រក់ ដោយកាយ [๑] វាចា និងចិត្ត, អ្នកចេញអំពីព្រៃនេះហើយ ប្លែរតាំងខ្លួន ឱ្យដូចជាកូនដំរីកើតអំពីទ្រុងហើយ ចាំសេពគប់រក នូវបុគ្គលនោះបុះ, មួយទៀត បុគ្គលណា ប្រព្រឹត្តតាមធម៌ ទោះបីកំពុងប្រព្រឹត្ត ក៏មិនប្រកាន់ខ្លួន, អ្នកចេញអំពីព្រៃនេះទៅហើយ ប្លែរសេពគប់នូវបុគ្គល ដែលជាអ្នកធ្វើអំពើដ៏បរិសុទ្ធ ប្រកបដោយបញ្ញានោះបុះ, នែបា បុគ្គលណា មានចិត្តដូចជា

๑- សុត្តន្តបិដក ភាគទី ๕๘ ទំព័រទី ๑๕๓ ។

មង្គលត្ថទីបនីប្រែ

សំពត់ដែលជ្រលក់ល្មៀត មានបិត្តដូចសត្វស្វា ត្រែកអរ ហើយ បែរជាមិនត្រែកអរវិញ បើទុកជាផ្ទៃនៃដីមួយទ្វីបទាំង មូលនេះ មិនមានមនុស្សសោះក៏ដោយ, អ្នកចូរកុំសេពគប់នូវបុរសបែបនោះឡើយ, អ្នកចូរបៀសវាង (បុគ្គលបែប នោះ) អំពីបម្ងាយ ឲ្យដូចជាបុគ្គលអ្នកភ័យខ្លាច បៀសវាង អាសិរពិសដ៏កាចសាហាវ អំពីបម្ងាយ ឬ ដូចជាបុគ្គលឆ្នើម លាមក បៀសវាងនូវផ្លូវធំ ដែលប្រឡាក់ដោយលាមក ឬ ដូចបុគ្គលអ្នកទៅដោយយាន បៀសវាងនូវផ្លូវដែលមិនរាប ស្មើ ដូច្នោះ, នែបា អំពើដែលមិនមែនជាប្រយោជន៍ទាំង ឡាយ រមែងបំរើនដល់បុគ្គលដែលសេពគប់នូវបុគ្គលពាល ជ្រុលពេក, អ្នកចូរកុំគប់រក ជាមួយនឹងបុគ្គលពាលឡើយ, ព្រោះការនៅរួមជាមួយនឹងបុគ្គលពាល ជាហេតុនាំសេចក្តី ទុក្ខមកឲ្យ ប្រៀបដូចជាការនៅរួមជាមួយនឹងសត្រូវ សព្វ ៗ កាល, នែបា ព្រោះហេតុនោះហើយ បានជាយើងសូមអង្វរ អ្នក, ចូរអ្នកធ្វើតាមពាក្យ របស់យើង, ចូរអ្នកកុំគប់រក ជា មួយនឹងបុគ្គលពាលឡើយ, (ព្រោះ) ការសមាគមជាមួយ បុគ្គលពាលទាំងឡាយ រមែងជាហេតុនាំសេចក្តីទុក្ខមកឲ្យ ។

*បណ្តាបទទាំងនោះ បទថា “**ឧរសីវ**” មានសេចក្តីថា*

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

ចូរតាំង គឺចូរតាំងចំពោះ (នូវខ្លួន) ឲ្យដូចជាកូនដែលកើតហើយ អំពីទ្រូងនៃមាតា ដូច្នោះ ។ អធិប្បាយថា " អ្នកលុះតាំង (ខ្លួន) ទុក យ៉ាងដូច្នេះហើយ គប្បីសម្គាល់ឲ្យដូចជាមាតារបស់ខ្លួនហើយ សេពគប់នូវបុគ្គលនោះចុះ " ។

បទថា " **ធម្មេន** " បានដល់ ដោយធម៌ គឺសុចរិតទាំង ៣ យ៉ាងនុ៎ះឯង ។ បទថា " **ន មញ្ញតិ** " មានសេចក្តីថា ម៉្យាងទៀត សូម្បីកាលប្រព្រឹត្ត យ៉ាងដូច្នោះ ក៏មិនធ្វើកិរិយាប្រកាន់ខ្លួន ថា " អាត្មាអញ ប្រព្រឹត្តនូវធម៌ " ។ បទថា " **វិសុទ្ធិការី** " បានដល់ អ្នកធ្វើកម្មដែលបរិសុទ្ធ គឺកុសលកម្មបថ ១០ ប្រការ ។

បទថា " **ហលិទ្ទវគ៌** " គឺ ឈ្មោះថា ជាអ្នកប្រៀបដូចជាសំពត់ដែលជ្រលក់ដោយល្មៀត ព្រោះជាអ្នកមានចិត្ត មិនស្ថិតស្ថេរ ។ បទថា " **កបិចិត្តំ** " បានដល់ មានចិត្តកម្រើកញាប់ញ័រ គឺមានចិត្តរំជើបរំជួល ។ បទថា " **បុរិសំ** " បានដល់ បុគ្គល ។ បទថា " **រាគវិរាគិនំ** " គឺត្រេកអរហើយ និង បែរជាមិនត្រេកអរទៅវិញ, អធិប្បាយថា មានសភាវៈ គឺស្រឡាញ់ហើយ ស្អប់ខ្ពើមទៅវិញ ក្នុងខណៈនោះភ្លាម ៗ " ។ បាទគាថា ថា " **និម្មនុស្សំបិ ចេ សិយា** " មានសេចក្តីថា ក៏ទោះបីជាផៃនៃជម្ពូទ្វីប ទាំងមូលនឹងជាទីស្ថានដែលគ្មានមនុស្សក៏ដោយ, មានជនពាលនោះ ជា

មង្គលត្ថទីបនីប្រែ

មនុស្ស ស្ថិតនៅតែម្នាក់ឯងប៉ុណ្ណោះ, សូម្បីជាដូច្នោះក៏ដោយ ចូរអ្នកកុំសេពគប់ នូវបុគ្គលបែបនោះឡើយ ។

*បាទគាថាថា " **មិទ្ធិលិត្តំ មហាបថំ** " គឺ ប្រៀបដូចជាផ្លូវដ៏ធំ ដែលប្រឡាក់ ដោយឈាមក ។ បទថា " **យានីវ** " គឺ ប្រៀបដូចជាបុគ្គលអ្នកធ្វើដំណើរទៅ ដោយយានយន្ត ។ បទថា " **វិសមំ** " បានដល់ មិនបានរាបស្មើ ដោយការៈជាទីដែលទំនាប និង ទីដែលទួល និង ដោយវត្ថុមានដង្គត់ និង ថ្ម ជាដើម ។*

*បាទគាថា ថា " **ពាលំ អច្ចុបសេវតោ** " បានដល់ ជាអ្នកសេពគប់ យ៉ាងស្និទ្ធស្នាល នូវបុគ្គលអ្នកមានបញ្ញាតិច ។ បទថា " **សព្ភទា** " មានសេចក្តីថា ឈ្មោះថា ការនៅរួមជាមួយនឹងបុគ្គលពាល រមែងនាំសេចក្តីទុក្ខមកឲ្យ អស់កាលជានិច្ចតែម្តង ប្រៀបដូចជាការនៅរួម ជាមួយនឹងសត្រូវ យ៉ាងដូច្នោះឯង ។*

*បទ ថា " **តន្តាហំ** " មានសេចក្តីថា ព្រោះហេតុនោះ បានជាយើង (ឪពុក) សូមអង្វរអ្នក ។*

(ភ័យឧបទ្រព និង ឧបសគ្គ កើតមានព្រោះជិនពាល)

(៣៣) មួយទៀតសោត ភ័យ ឧបទ្រព និង ឧបសគ្គទាំងឡាយណាមួយដែលមាន, ភ័យ ឧបទ្រព និង ឧបសគ្គទាំងឡាយទាំងអស់នោះ កើតឡើង ព្រោះអាស្រ័យបុគ្គលពាលទាំងស្រុង ។

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

មែនពិត បុគ្គលពាល កាលប្រាថ្នានូវភាវៈជាព្រះរាជាក្តី ភាវៈជាឧបរាជក្តី ឬក៏ នូវមុខដំណែងដ៏ធំផ្សេងទៀត បបួលពួកអ្នកលេងធំ ៗ ចំនួន ២-៣ នាក់ ដែលស្មើ នឹងខ្លួនបានហើយ និយាយថា " អ្នកទាំងឡាយ ចូរមកចុះ, ខ្ញុំនឹងធ្វើពួកអ្នកឲ្យជាធំ " យ៉ាងដូច្នេះហើយ អាស្រ័យទីស្ថានស្ងាត់ៗ មានទីញៀតស្បាត នៃភ្នំ ជាដើម ហើយប្លន់ស្រុកដែលនៅជាប់ស្រយាល ប្លន់និគមខ្លះ ជនបទខ្លះ តាមលំដាប់ ។

មនុស្សទាំងឡាយ នាំគ្នាបោះបង់ចោលផ្ទះហើយ ប្រាថ្នានូវស្ថានទីដ៏ក្សេមក្សាន្ត កៀសខ្លួនចេញទៅ ។ ពួកភិក្ខុក្តី ពួកភិក្ខុនីទាំងឡាយក្តី ដែលនៅអាស្រ័យមនុស្សទាំងឡាយនោះ ក៏រមែងនាំគ្នាបោះបង់ចោលនូវទីលំនៅរបស់ខ្លួន ៗ ចៀសចេញទៅដែរ ។ កិក្ខាក្តី សេនាសនៈក្តី ក្នុងពេលដែលភិក្ខុ និង ភិក្ខុនីទាំងនោះ បានទៅហើយ ៗ ជារបស់រកបានដោយកម្រ ។ សូម្បីក្នុងបព្វជិតទាំងឡាយ ភិក្ខុពាល ២ រូប បង្កើតនូវវិវាទដល់គ្នានឹងគ្នាហើយ ចាប់ផ្តើមចោទគ្នាឡើង ។ ព្រោះហេតុនោះ សេចក្តីឈ្លោះប្រកែកគ្នាដ៏ធំ រមែងកើតឡើង ដល់ពួកបព្វជិតទាំងនោះ ប្រៀបបីដូចជាសេចក្តីឈ្លោះវិវាទគ្នា ដែលកើតឡើង ដល់ពួកភិក្ខុក្រុងកោសម្ពី យ៉ាងដូច្នោះ ។ ហេតុនៃសេចក្តីទុក្ខ មានភ័យជាដើម មកដល់ពួក

មង្គលត្ថទីបនីប្រែ

បរិស័ទទាំង ៤ ព្រោះអាស្រ័យនូវជនពាល ដោយប្រការដូច្នេះ ។

ព្រោះហេតុនោះ ក្នុងលក្ខណសូត្រ [1] មុនព្រះសូត្រ ទាំងពួង ក្នុងតិកនិបាត អង្គុត្តរនិកាយ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ថា " ម្នាលភិក្ខុទាំងឡាយ ក្លើង តែងឆេះ ពាលអំពីផ្ទះបបុស ឬ ផ្ទះស្មៅ មកឆេះផ្ទះកំពូលទាំងឡាយ ដែល គេលាប ទាំងខាងក្នុង ទាំងខាងក្រៅ មិនមានខ្យល់ចូលបាន មាន សន្ទះទ្វារដ៏ជិតស្និទ្ធ មានបង្អួចបិទជិតហើយ ដូចម្តេចមិញ, ម្នាល ភិក្ខុទាំងឡាយ ភ័យទាំងឡាយ ណាមួយ កើតឡើង, ភ័យទាំង អស់នោះ តែងកើតឡើង អំពីជនពាល, មិនមែនកើតឡើង អំពី បណ្ឌិតទេ, ឧបទ្រពទាំងឡាយណាមួយ កើតឡើង, ឧបទ្រពទាំង អស់នោះ តែងកើតឡើង អំពីជនពាល, មិនមែនកើតឡើង អំពី បណ្ឌិតទេ, ឧបសគ្គទាំងឡាយ ណាមួយ កើតឡើង, ឧបសគ្គ ទាំងអស់នោះ តែងកើតឡើង អំពីជនពាល, មិនមែនកើតឡើង អំពីបណ្ឌិតទេ ក៏យ៉ាងដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ពាល ប្រកបដោយភ័យដ៏ពន្លឹក, បណ្ឌិត មិនមានភ័យដ៏ពន្លឹកទេ, បុគ្គលពាល ប្រកបដោយឧបទ្រពដ៏ពន្លឹក, បណ្ឌិត មិនមាន ឧបទ្រពដ៏ពន្លឹកទេ, បុគ្គលពាល ប្រកបដោយឧបសគ្គដ៏ពន្លឹក,

---

๑- សុត្តន្តបិដក ភាគ ទី ៤១ ទំព័រ ទី ២ ។

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

បណ្ឌិត មិនមានឧបសគ្គជ៏ពន្ធីកទេ ដោយប្រការដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ កំយ មិនមានមក អំពីបណ្ឌិត, ឧបទ្រព មិនមានមក អំពីបណ្ឌិត, ឧបសគ្គ មិនមានមក អំពីបណ្ឌិតឡើយ " យ៉ាងដូច្នេះ ។

(៣៤) អដ្ឋកថា នៃលក្ខណសូត្រនោះ ថា " បណ្តាបទទាំងនោះ បទថា " **នឡាគារ វា** " គឺ អំពីផ្ទះ ដែលគេប្រក់(ចាំង) ដោយបបុសទាំងឡាយ, ប៉ុន្តែគ្រឿងសម្ភារៈដែលសេសសល់ទាំងឡាយ ក្នុងផ្ទះនេះ រមែងសម្រេច ដោយឈើពិត ។ ។ សូម្បីក្នុងផ្ទះស្មៅ ក៏មានន័យដូចនេះដែរ ។ បទថា " **កូដាគារានិ** " គឺ ផ្ទះ ដែលសង្រ្គោះដោយកំពូល ។ បទថា " **ឧល្លិត្តាវលិត្តានិ** " គឺ ដែលគេបូកហើយ ទាំងខាងក្នុង ទាំងខាងក្រៅ ។ បទថា " **និវាតានិ** " គឺ បិទផ្លូវខ្យល់ មិនឲ្យចូលទៅបាន ។ បទថា " **ផុសិតគ្គឡានិ** " គឺ ឈ្មោះថា មានសន្ទះទ្វារ ត្រង់ក្របខាងខ្នងបិទជិតល្អហើយ ព្រោះជារបស់ដែលនាយជាងទាំងឡាយ ដែលឆ្លាត ធ្វើទុកហើយ ។ បទថា " **បិហិតវាតបានានិ** " បានដល់ដែលគេភ្ជាប់បង្អួចទុកហើយ ។ ដោយ ២ បទនេះ ព្រះដ៏មានព្រះភាគ ទ្រង់មិនបានត្រាស់ភាវៈនៃសន្ទះទ្វារ និង បង្អួច ថា ជារបស់ដែលបុគ្គលបិទហើយ ជាប្រចាំឡើយ (តែ) ទ្រង់ត្រាស់

មង្គលត្ថទីបនីប្រែ

ការដល់ព្រម (នៃផ្ទះកំពូល) តែប៉ុណ្ណោះ ។ ក៏សន្ទុះទ្វារ និងបង្អួចទាំងឡាយនោះ គឺបុគ្គលតែងបិទ និង បើកបាន គ្រប់ពេលដែលខ្លួនប្រាថ្នាហើយ ។ ។ ២ បទថា “ **ពាលតោ ឧប្បជ្ជន្តិ** ” គឺ តែងកើតឡើង ព្រោះអាស្រ័យនូវបុគ្គលពាលទាំងស្រុង ។ សេចក្តីតក់ស្លុត នៃចិត្ត ឈ្មោះថា ភ័យ ។ អាការ គឺ ភាវៈនៃចិត្ត មានអារម្មណ៍មិនមែនតែមួយ ឈ្មោះថា ឧបទ្រព ។ អាការ គឺភាវៈនៃចិត្តទើសទាក់ ចានជល់ អាការ គឺភាវៈនៃចិត្ត ជាប់ជំពាក់នៅក្នុងអារម្មណ៍នោះ ។ ឈ្មោះថា ឧបសគ្គ ” ដូច្នេះ ។

(៣៥) ជីកា នៃលក្ខណសូត្រនោះ ថា “ ពាក្យថា **ឆន្នបវិច្ឆន្នា** គឺខាងលើគេប្រក់បាំង ដោយដើមបបុសទាំងឡាយ ដោយសង្វេប គឺការប្រក់បាំងដោយស្មៅ ដោយជុំវិញ គឺគេប្រក់បាំង ដោយដើមបបុសទាំងឡាយនោះ ដូចគ្នាដែរ ដោយទំនងនៃជញ្ជាំងឈើ (ក្តារ) ។ សេចក្តីតក់ស្លុតនៃចិត្ត របស់បុគ្គលដែលភ័យខ្លាចហើយ ឈ្មោះថា ភ័យ ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោលថា សេចក្តីតក់ស្លុតនៃចិត្ត ។ សេចក្តីអន្តរាយ ឈ្មោះថា ឧបទ្រព ។ ក៏ព្រះអដ្ឋកថាចារ្យ ពោលថា អាការ គឺ ភាវៈនៃចិត្ត មានអារម្មណ៍មិនមែនតែមួយ ព្រោះសេចក្តីអន្តរាយនោះ ជាហេតុនៃសេចក្តីរាយមាយចិត្ត ។ សេចក្តីទើសទាក់ គឺ

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

ការជួបប្រទះនូវសេចក្តីចង្អៀតចង្អល់ ព្រោះការធ្វើតបវិញមិនបាន ដោយហេតុមានត្រូវទេវតាបៀតបៀនជាដើម ឈ្មោះថា ឧបសគ្គ ក៏ការជួបប្រទះ នូវសេចក្តីចង្អៀតចង្អល់នោះ ជាហេតុនៃសេចក្តីរញ្ជួរ ស្ញាក់ស្ញើរ របស់បុគ្គលដែលកំពុងក្តៅក្រហាយ អ្នកមិនអាច ដើម្បីធ្វើអ្វី ៗ បាន ដោយភាវៈគឺធ្វើតបវិញមិនបាន ព្រោះហេតុណា ព្រោះហេតុនោះ ទើបលោកពោលថា អាការ គឺ ភាវៈដែលចិត្តជាប់ជំពាក់ ក្នុងអារម្មណ៍នោះ ៗ យ៉ាងដូច្នេះ” ។

(៣៦) ព្រោះហេតុនោះ បុគ្គលពាលទាំងឡាយ គឺអ្នកមានប្រាជ្ញា គប្បីជ្រាបច្បាស់ថា ប្រៀបដូចជាផ្ទះ ដែលត្រូវភ្លើងឆេះហើយ ដូច្នោះ ។ ព្រោះថា បុគ្គលពាលទាំងនោះ ជាអ្នកអាចក្នុងការនាំសេចក្តីទុក្ខ មានភ័យគ្រប់យ៉ាង មកប្រគល់ឲ្យ ដល់បុគ្គលទាំងឡាយ អ្នកធ្វើតាមពាក្យរបស់ខ្លួន ។ គប្បីជ្រាបបណ្ឌិតទាំងឡាយ ប្រៀបដូចជាការថែរក្សា ក្នុងទីដែលមានភ័យ ប្រៀបបីដូចជាប្រទីប ក្នុងទីដែលងងឹត និង ប្រៀបបីដូចជាការបានទទួលបាយ និង ទឹកជាដើម ក្នុងវេលាដែលត្រូវសេចក្តីទុក្ខ មានការស្រេក និង ឃ្លានជាដើម មកគ្របសង្កត់ដូច្នោះឯង ។ ព្រោះថា បណ្ឌិតទាំងឡាយនោះ ជាអ្នកអាច ក្នុងការកម្ចាត់សេចក្តីទុក្ខមានភ័យជាដើម គ្រប់យ៉ាង ដល់បុគ្គលទាំងឡាយ ដែលធ្វើតាម

ពាក្យរបស់ខ្លួនបាន ដូច្នេះឯង ។ បុគ្គលជ្រាបនូវភាវៈនៃជនពាលទាំងឡាយ ប្រៀបស្មើនឹងរបស់ដែលស្មោកគ្រោក មានត្រីស្អុយជាដើម និង បណ្ឌិតទាំងឡាយ ប្រៀបស្មើនឹងគ្រឿងសំអាង មានគ្រឿងក្រអូបជាដើម ទាំងការសេពគប់រកនូវបុគ្គលពាលជាហេតុនាំឲ្យកើតទុក្ខ និង ការសេពគប់នូវបណ្ឌិត ជាហេតុនាំឲ្យបានសេចក្តីសុខ យ៉ាងដូច្នេះហើយ គប្បីសេពគប់តែបណ្ឌិតប៉ុណ្ណោះ មិនគួរសេពគប់នឹងបុគ្គលពាលឡើយ ។

សូម្បីព្រះដ៏មានព្រះភាគ កាលនឹងទ្រង់អប់រំទូន្មានព្រះធនុត្តេរ ទ្រង់បានត្រាស់ហើយ នូវព្រះគាថានេះ ក្នុងបណ្ឌិតវគ្គ នៃធម្មបទ ថា ៖

(៣៧) អ្នកមានប្រាជ្ញា មិនគួរគប់រកមិត្រអាក្រក់ [១] មិនគួរគប់បុរសថោកទាប, គួរគប់រកតែមិត្រដ៏ឈ្លប្រសើរ គួរគប់រកតែបុរសខ្ពង់ខ្ពស់ ។

បណ្តាបទទាំងនោះ បទថា “ **ភជេ** ” មានសេចក្តីថា បណ្ឌិត គួរគប់រក គឺចូលទៅអង្គុយជិត ។ បទថា “ **បុរិសាធមេ** ” បានដល់ នូវបុរសថោកទាប គឺបុរសដែលអាក្រក់ ។ បទថា

១- សុត្តន្តបិដក ភាគទី ៥២ ទំព័រទី ៣៨ ។

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

" ***ភជេថ*** " ប្រែថា គួរសេពគប់ ។ ក៏ក្នុងបុគ្គលទាំង ២ ពួកនេះ បុគ្គលទាំងឡាយណា រមែងត្រេកអរក្រៃលែង ក្នុងទុច្ចរិតទាំងឡាយ មានកាយទុច្ចរិត ជាដើម, បុគ្គលទាំងនោះ ឈ្មោះថា បាបមិត្រ ។ ចំណែកបុគ្គលទាំងឡាយណា រមែងប្រកប ក្នុងទីមិនមែនជាហ៊ាន: មានការកាត់នូវទី-ត ជាដើម ឬ ផ្សេងដោយកម្ម មានអនេសនា ២១ ប្រការ ជាដើម, បុគ្គលទាំងឡាយនោះ ឈ្មោះថា បុរសថោកទាប ។ ម៉្យាងទៀត បុគ្គលទាំង ២ នុ៎ះឯង ជាបាបមិត្រផង ជាបុរសដែលថោកទាបផង ។ បុគ្គលដែលផ្ទុយអំពីបុគ្គលទាំង ២ ពួកនោះ ជាកល្យាណមិត្រផង ជាបុរសខ្ពង់ខ្ពស់ផង ដោយប្រការដូច្នេះឯង ។

(៣៨) ក៏ការសេពគប់ នូវបណ្ឌិត សូម្បីតែអស់រយៈមួយជង្គង់ ក៏ឈ្មោះថា រមែងរក្សាឃុំគ្រង់ខ្លួនបាន, ការសេពគប់នូវបុគ្គលពាល សូម្បីអស់កាលជ័យូរ ក៏មិនឈ្មោះថា ជាការថែរក្សាឃុំគ្រងនូវខ្លួនបានឡើយ ។ ពិតមែនដូច្នោះ នន្ទព្រាហ្មណ៍ បានទៅកាន់នគរឥន្ទបត្តបុរី ក្នុងទីបំផុតនៃចម្ងាយ ១២០ យោជន៍ អំពីទីក្រុងតក្កសីលា កាលនឹងសម្តែងធម៌ ដល់ព្រះរាជា ទ្រង់ព្រះនាមមហាសុតសោម បានពោលគាថានេះ ក្នុងមហាសុតសោម-ជាតក ថា ៖

មង្គលត្ថទីបនីប្រែ

បពិត្រព្រះមហារាជ ទ្រង់ព្រះនាមសុតសោម [1] ការជួបប្រទះ ដោយសប្បុរសទាំងឡាយ សូម្បីអស់វារៈតែម្តង, ការជួបប្រទះនោះ រមែងថែរក្សាបុគ្គលនោះបាន, ការជួបប្រទះដោយអសប្បុរសទាំងឡាយសូម្បីអស់វារៈប្រើនដងង, រមែងថែរក្សានូវបុគ្គលនោះ ពុំបានឡើយ ។

បណ្តាបទទាំងនោះ បទថា “ ***សកិទេវ*** *” ប្រែថា អស់វារៈមួយដងប៉ុណ្ណោះ ។ បទថា “* ***សព្ភិ*** *” ប្រែថា ដោយសប្បុរសទាំងឡាយ ។ ច្រើនបទថា “* ***សា នំ សង្គតិ*** *” មានសេចក្តីថា ការសមាគម ដោយសប្បុរសទាំងឡាយនោះ សូម្បីប្រព្រឹត្តទៅអស់វារៈតែម្តង រមែងឃុំគ្រង គឺ ថែរក្សា នូវបុគ្គលនោះបាន ។ ជាទគាថា ថា “* ***នាសព្ភិ ពហុ សង្គមោ*** *” មានសេចក្តីថា ចំណែកការសមាគម គឺការនៅអាស្រ័យ ក្នុងទីស្តានជាមួយគ្នា ដោយពួកអសប្បុរសទាំងឡាយ ដែលបុគ្គលបានធ្វើហើយ សូម្បីអស់កាលជ័យូរ ក៏រមែងឃុំគ្រង (បុគ្គលនោះ) មិនបានឡើយ, អធិប្បាយថា “មិនមែនជាការស្ថិតស្ថេរបានឡើយ” ។*

(៣៩) ព្រោះហេតុនោះ បុគ្គល គួរសេពគប់តែពួកបណ្ឌិតប៉ុណ្ណោះ មិនគួរសេពគប់ពួកជនពាលឡើយ ។ មិនមែនតែមិន

១- សុត្តន្តបិដក ភាគទី ៦១ ទំព័រទី ២០២ ។

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

គួរសេពគប់នូវពួកជនពាល គួរសេពគប់តែពួកបណ្ឌិត តែម៉្យាង ប៉ុណ្ណោះទេ, តាមពិតហើយ បុគ្គលនឹងធ្វើបុណ្យអ្វីមួយ ក៏គួរតែធ្វើ សេចក្តីប្រាថ្នាផងដែរ ថា " ដោយបុណ្យនេះ ខ្ញុំ គប្បីជួបប្រទះ តែពួកបណ្ឌិតទាំងឡាយប៉ុណ្ណោះ មិនគួរជួបប្រទះនូវពួកជនពាល ឡើយ " ដូច្នេះ ប្រៀបដូចជាអកិត្តិបណ្ឌិត យ៉ាងដូច្នោះឯង ។

(អកិត្តិបណ្ឌិតមិនបង់ជួបប្រទះជនពាល)

បានឮមកថា អកិត្តិបណ្ឌិតនោះ កើតជាបុត្រ របស់ ព្រាហ្មណ៍មហាសាល អ្នកមានទ្រព្យសម្បត្តិដល់ទៅ ៨០ កោដិ ក្នុងក្រុងពារាណសី, កាលបើមាតា និងបិតា បានស្លាប់ចោលទៅ ហើយ, ក៏បានលះបង់ទ្រព្យសម្បត្តិទាំងអស់ហើយ បានបួសជា តាបសឥសី បានមកដល់ទីក្រុង ឈ្មោះកបិឡវដ្ឋ ដោយលំដាប់ ហើយក៏អាស្រ័យនៅ ក្នុងឧទ្យាន ក្បែរទីក្រុងកបិឡវដ្ឋ ញុំាង ឈាន និង អភិញ្ញា ឲ្យកើតឡើងហើយ ក៏ហោះមកតាមអាកាស ចុះត្រង់កោះដើមជង្អៀបក្តាម នៅក្បែរកោះដើមខ្ទឹង អាស្រ័យនូវ ដើមជង្អៀបក្តាមដ៏ធំហើយ ក៏បានសាងបណ្ណសាលានៅ ក្នុងកោះ ដើមខ្ទឹងនោះហើយ ។ តាបសឈ្មោះអកិត្តិបណ្ឌិតនោះ មិនបាន និមន្តទៅ ក្នុងទីណាមួយឡើយ ព្រោះជាអ្នកមានសេចក្តីប្រាថ្នាតិច ក្នុងពេលដែលដើមឈើនោះ មានផ្លែ ក៏នាន់ផ្លែ ក្នុងពេលដែល

មង្គលត្ថទីបនីប្រែ

មានសន្ទឹក ក៏ធាន់សន្ទឹក ដែលស្រុះដោយទឹកក្តៅ ។ អាសនៈ របស់ស្តេចសក្កទេវរាជ បានក្តៅហើយ ព្រោះតេជនៃសីលរបស់តាបសនោះ ។ ស្តេចសក្កទេវរាជ ទ្រង់ជ្រាបហេតុនោះហើយ ទ្រង់បានផ្លាស់កេទ ជាព្រាហ្មណ៍ ទ្រង់ស្តេចយាងទៅប្រថាប់ឈរ ធ្វើទំនង់ដូចជាអ្នកសុំ នៅក្នុងកោះនោះ ។ តាបស ស្រុះស្ទឹកជង្អៀបក្តាមហើយ ជាក់ចុះ (អំពីជើងក្រាន) ហើយបានគង់នៅត្រង់មាត់ទ្វារបណ្ណសាលា ដោយតាំងចិត្តថា " អាត្មាអញ នឹងធាន់ស្ទឹកជង្អៀបក្តាម ដែលត្រជាក់ហើយ " ដូច្នេះហើយ បានឃើញស្តេចសក្កទេវរាជនោះ ក៏សោមនស្ស បានជាក់ស្ទឹកជង្អៀបក្តាមទៅក្នុងកាជនកិក្ខា របស់ស្តេចសក្កទេវរាជនោះ មិនបានទុកឲ្យនៅសល់ សម្រាប់ខ្លួនសោះឡើយ មិនបានស្រុះ ម្តងទៀតហើយ ញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅដោយសេចក្តីសុខ ដែលកើតអំពីបីតិតែប៉ុណ្ណោះឯង ។ ចំណែក ស្តេចសក្កទេវរាជ ទ្រង់បានទទួលយកស្ទឹកជង្អៀបក្តាមនោះហើយ ស្តេចយាងទៅបានបន្តិច ទ្រង់បានបាត់ទៅហើយ ។ ស្តេចសក្កទេវរាជ ទ្រង់ស្តេចយាងទៅដោយឧបាយនោះឯង រហូតដល់ ៣ ថ្ងៃ ។ ចំណែកឯ តាបស ក៏បានថ្វាយអាហារទាំងអស់ ដល់ស្តេចសក្កទេវរាជនោះ រហូត ៣ ថ្ងៃ (ដែរ) ខ្លួនឯង ក៏បានអត់អាហារហើយ ។ ក្រោយមក ក្នុងថ្ងៃ

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

ទី ៣ ស្តេចសក្កទេវរាជ ទ្រង់ជ្រះថ្លាហើយ ក៏ទ្រង់បានប្រទានពរដល់តាបសនោះ ។

តាបសនោះ កាលនឹងទទួលនូវពរ បានពោលគាថានេះក្នុងអកិត្តិជាតក ក្នុងតេរសនិបាត ថា ៖

(៤០) អាត្មា សូមកុំឲ្យជួបប្រទះនឹងមនុស្សពាល [1] សូមកុំឲ្យឮដំណឹងមនុស្សពាល សូមកុំឲ្យនៅរួមនឹងមនុស្សពាល សូមកុំឲ្យបានធ្វើ ទាំងកុំឲ្យពេញចិត្តនឹងការបរបាចទៅមក នឹងមនុស្សពាល ។

បណ្តាបទទាំងនោះ បទថា “ ***ន សុណេ*** *” មានសេចក្តីថា អាត្មា មិនគប្បីបានឮ ដោយត្រចៀកទាំងសងខាងនេះ ថា “ ជនពាល រស់នៅ ក្នុងទីឈ្មោះនោះ ” ដូច្នេះឡើយ ។*

ស្តេចសក្កទេវរាជ ទ្រង់ព្រះសណ្តាប់ នូវពាក្យនោះហើយ កាលនឹងទ្រង់ត្រាស់សួរហេតុ ក្នុងការមិនចង់ជួបប្រទះ នូវមនុស្សពាលនោះ ទ្រង់បានត្រាស់គាថានេះ ថា ៖

បពិត្រកស្សប: ជនពាលបានធ្វើអ្វី ដល់លោក [2] សូមលោកមេត្តាប្រាប់ហេតុ, បពិត្រកស្សប: ព្រោះហេតុអ្វីបាន

១-២- សុតន្តបិដក ភាគទី ៥៩ ទំព័រទី ២៨៧ ។

មង្គលត្ថទីបនីប្រែ

ជាលោកមិនប្រាថ្នាបង់ផ្លែប នូវមនុស្សពាល ។

បណ្តាបទទាំងនោះ ច្រើនបទថា “ ***កិំ នុ តេ អការំ*** *” មានសេចក្តីថា មាតា ឬ បិតា របស់លោកត្រូវជនពាលសម្លាប់ហើយ ឬ ឬក៏ បុគ្គលពាល បានធ្វើនូវសេចក្តីវិនាសអ្វីមួយ ដល់ទៃទៀតដល់លោក ។*

តាបសនោះ កាលទូលហេតុ ដល់ស្តេចសក្កៈនោះ បានពោលថា ៖

បុគ្គលពាល រមែងណែនាំនូវអំពើដែលមិនគួរណែនាំ រមែងប្រកប ក្នុងកិច្ចមិនមែនជាធុរៈ, ការណែនាំទៅរកអាក្រក់ជាការប្រសើរ (របស់ជនពាលនោះ) ជនពាល បើទុកជាគេនិយាយត្រូវ ក៏នៅតែទឹង, ជនពាលនោះ មិនដឹងវិន័យទេ, ការមិនផ្លែបប្រទះជនពាលនោះ ជាការប្រពៃ ។

បណ្តាបទទាំងនោះ ២ បទថា “ ***អនយំ នយតិ*** *” មានសេចក្តីថា បុគ្គលពាល ប្រកាន់យកវបស់ដែលមិនមែនជាហេតុថា ជាហេតុ នឹកគិតតែអំពើដែលគ្មានប្រយោជន៍ យ៉ាងដូច្នេះថា អញ នឹងធ្វើនូវកម្មទាំងឡាយ មានបាណាតិបាតជាដើម ហើយចិញ្ចឹមជីវិត” ដូច្នេះ ។ បទថា “* ***អធុរាយំ*** *” គឺមិនប្រកប ក្នុង*

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

សទ្ធាធុរៈ សីលធុរៈ និង បញ្ញាធុរៈ ទាំងឡាយ (បែរជា) ប្រកបក្នុងរឿងដែលមិនគួរប្រកបទៅវិញ ។ បទថា “ ***ទុន្នយោ*** *” មានសេចក្តីថា ការណែនាំអាក្រក់ប៉ុណ្ណោះ ជាការប្រសើរ របស់បុគ្គលពាលនោះ ។ គឺបុគ្គលពាលនោះ តែងប្រកាន់យ៉ាងនេះ ថា “ ការសមាទានកម្ម គឺ ការទ្រុស្តសីល ៥ យ៉ាង ហើយប្រព្រឹត្តនុ៎ះឯង ជាការប្រសើរ ” ។ ម៉្យាងទៀត បុគ្គលពាលនោះ គឺបណ្ឌិតណែនាំបានដោយលំបាក គឺជាអ្នកដែលបុគ្គលណាមួយ មិនអាចដើម្បីនឹងណែនាំ ក្នុងខប្រតិបត្តិ ដែលមានប្រយោជន៍បានឡើយ ។ បទថា “* ***សម្ម*** *” គឺសូម្បីអ្នកជនៃ និយាយហើយ ដោយហេតុ គឺដោយការណ៍ ។ បទថា “* ***វិនេយ្យំ*** *” មានសេចក្តីថា ជនពាលមិនស្គាល់ច្បាស់ នូវមារយាទ និង ឧបាយគ្រឿងណែនាំ ថា “ គប្បីឈានទៅខាងមុខ យ៉ាងនេះ ” ដូច្នេះជាដើម និង មិនព្រមទទួលយកនូវឱវាទឡើយ ។ បទថា “* ***សាធុ តស្ស*** *” មានសេចក្តីថា ដោយហេតុទាំងឡាយនេះ ការមិនជួបប្រទះ នូវជនពាល ជាដាច់ខាត ជាការប្រសើរណាស់ ។*

តាបស កាលនឹងទទួលពរដទៃថ្មីទៀត ទើបបានពោលថា៖

អាត្មាភាព សូមឱ្យបានជួបប្រទះតែនឹងអ្នកប្រាជ្ញ សូមឱ្យបាន
ស្តាប់ឮតែពាក្យអ្នកប្រាជ្ញ សូមឱ្យបានរៀរួមជាមួយនឹងអ្នក

មង្គលត្ថទីបនីប្រែ

ប្រាជ្ញ សូមឱ្យបានធ្វើ ទាំងសូមឱ្យបានបួលចិត្ត នូវការបរបាប្រាស្រ័យគ្នាទៅវិញទៅមក ជាមួយនឹងអ្នកប្រាជ្ញនោះ[1] ។

ស្តេចសក្កទេវរាជ ទ្រង់បានត្រាស់សួរ ថា ៖

បពិត្រកស្សប: អ្នកប្រាជ្ញ បានធ្វើប្រយោជន៍អ្វីខ្លះ ដល់លោក សូមលោកប្រាប់នូវហេតុ, បពិត្រកស្សប: ព្រោះហេតុអ្វី បានជាលោកចង់ជួបប្រទះតែនឹងអ្នកប្រាជ្ញ ។

តាបស បានទូលហើយ ថា ៖

អ្នកប្រាជ្ញ មិនណែនាំនូវហេតុដែលមិនគួរណែនាំ រមែងមិនប្រកប ក្នុងកិច្ចដែលមិនមែនជាធុរៈ ការណែនាំ ជាការប្រសើរ របស់អ្នកប្រាជ្ញនោះ អ្នកប្រាជ្ញបើទុកជាគេនិយាយត្រូវហើយ ក៏នៅតែមិនក្រោធទឹងដែរ, អ្នកប្រាជ្ញនោះ រមែងដឹងប្បាស់នូវឧបាយគ្រឿងណែនាំ, ការសេពគប់រកជាមួយនឹងអ្នកប្រាជ្ញនោះ ជាការប្រពៃណាស់ ។

(៤១) មែនពិត ការជួបប្រទះនឹងបណ្ឌិត ជាហេតុនាំឲ្យបាននូវសេចក្តីសុខ, ឯការជួបប្រទះនឹងបុគ្គលពាល ជាហេតុនាំឲ្យបាន នូវសេចក្តីទុក្ខ, ដោយហេតុនោះ ក្នុងសក្កទេវិន្ទវត្ថុ

១- សុត្តន្តបិដក ភាគទី ៥៩ ទំព័រទី ២៨៨ ។

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ថា ៖

ការជួបប្រទះ នូវព្រះអរិយៈទាំងឡាយ ជាការប្រពៃ, [1] ការនៅរួមជាមួយគ្នា ជាហេតុឲ្យបានសេចក្តីសុខ ក្នុងទីសព្វ ។ កាល, បុគ្គលគប្បីជាអ្នកមានសេចក្តីសុខ អស់កាលជានិច្ច និរន្តរ៍ ដោយពិតប្រាកដបាន ព្រោះការមិនជួបប្រទះ នូវជនពាលទាំងឡាយ ។

បណ្តាបទទាំងនោះ បទ ថា “ ***អរិយានំ*** *” មានសេចក្តីថា ម្នាលភិក្ខុទាំងឡាយ កិរិយាជួបប្រទះ នូវសប្បុរសទាំងឡាយ គឺបណ្ឌិតទាំងឡាយ មានព្រះពុទ្ធជាដើម ជាការប្រពៃ គឺជាការប្រសើរ បានដល់ ជាការល្អ, អធិប្បាយថា “ជាហេតុនាំឲ្យបានសេចក្តីសុខ” ។ មិនមែនតែការបានជួបប្រទះ នូវព្រះអរិយទាំងឡាយនោះ តែម៉្យាងប៉ុណ្ណោះទេ (ជាការប្រសើរ), តាមពិតហើយ សូម្បីការៈគឺការអង្គុយជាដើម ក្នុងទីជាមួយព្រះអរិយទាំងឡាយនោះ ក៏ជាការប្រសើរបានដូចគ្នាដែរ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ ថា “ ការនៅរួមជាមួយគ្នា ” ដូច្នេះជាដើម ។*

បទថា “ ***អទស្សនេន*** *” គឺព្រោះហេតុនៃការមិនជួបប្រទះ ។*

១- សុត្តន្តបិដក ភាគទី ៥២ ទំព័រទី ៦៤ ។

មង្គលត្ថទីបនីប្រែ

បទថា "**សុខី**" គឺបុគ្គលអ្នកមានសេចក្តីសុខ ។

បាឋៈថា "**សុខំ**" ដូច្នេះ ក៏មានខ្លះដែរ ។

(៤២) មែនពិត បុគ្គលអ្នកសេពគប់នូវជនពាលជាប្រក្រតី កាលធ្វើតាមពាក្យរបស់ជនពាល រមែងជួបប្រទះ នូវសេចក្តីទុក្ខ, ចំណែកឯ អ្នកសេពគប់ នូវបណ្ឌិតជាប្រក្រតី កាលធ្វើតាមពាក្យរបស់បណ្ឌិត រមែងបាននូវសេចក្តីសុខ ។ ក៏ក្នុងដំណើរនេះ មានកិក្ខុអ្នកប្រាថ្នាចង់សឹក ជាឧទាហរណ៍ ។

(រឿងវិព្ភន្តិកភិក្ខុ)

បានឮមកថា កិក្ខុរូបនោះ ជាសទ្ធិវិហារិក របស់ព្រះថេរៈឈ្មោះព្រះមហាកស្សបៈ ជាអ្នកបានសម្រេចចតុត្ថជ្ឈាន បានឃើញនូវអារម្មណ៍ដែលជាសឹកសត្រូវ ក្នុងផ្ទះរបស់ឪពុកធំ របស់ខ្លួនហើយ ក៏មានចិត្តប្រតិពទ្ធ ក្នុងអារម្មណ៍នោះ សឹកមកហើយត្រូវគេដេញចេញអំពីផ្ទះ ព្រោះជាអ្នកខ្ជិលច្រអូស ជឿតាមពាក្យរបស់ពួកជនដែលជាបាបមិត្រ ដើរធ្វើការចិញ្ចឹមជីវិត ដោយចោរកម្ម ។ ក្នុងថ្ងៃមួយ បុរសនោះ ត្រូវពួករាជបុរស ចាប់ខ្លួនបាន ចងស្ងាបសេក យ៉ាងជាប់ហើយ យកផ្តៅមកវាយ មួយកន្ទែង ៤ ៗ នាំបណ្តើរទៅកាន់ទីសម្លាប់ តាមមាត់ទ្វារខាងត្បូង នៃទីក្រុងរាជគ្រឹះ ។

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

ក្នុងថ្ងៃមួយ ព្រះមហាកស្សបៈ និមន្តចូលទៅ កាន់នគរ ដើម្បីបិណ្ឌបាត ឃើញបុរសនោះហើយ ក៏បានឲ្យពួកពាជបុរស បន្ទរខ្សែចំណងហើយ បានពោលថា " ចូរអ្នកនឹកពិចារណាយក កម្មដ្ឋាន ដែលអ្នកធ្លាប់បានអប់រំមកហើយ ក្នុងកាលមុន សាឡើង វិញ" ។ បុរសនោះ ជឿតាមពាក្យ របស់ព្រះថេរៈហើយ ក៏បាន ញុាំងឈាន ទី ៤ ឲ្យកើតឡើងម្តងទៀត ត្រូវពួកពាជបុរសទាំង នោះនាំបណ្តើរ ទៅកាន់ទីស្តានសម្ងាប់ហើយ ឲ្យដេកផ្ងារ នៅលើ ចម្រូងដែកក្តី ត្រូវពាជបុរសសម្ងុត ដោយគ្រឿងអាវុធទាំងឡាយក្តី ក៏មិនកិតក័យ ។ ពួកពាជបុរសទាំងឡាយ ឃើញនូវបុរសនោះ មិនភ័យខ្លាច ក៏បានក្រាបទូល ដល់ព្រះបាទពិម្ពិសារ ។ ព្រះពាជា ទ្រង់ត្រាស់ថា " អ្នកទាំងឡាយ ចូរដោះលែងបុរសនោះទៅចុះ " ដូច្នេះហើយ ស្តេចយាងទៅកាន់វត្តវេឡុវន បានក្រាបទូលព្រះ សាស្តាហើយ ។ ព្រះសាស្តា ទ្រង់គង់ ក្នុងវត្តវេឡុវន ទ្រង់បាន ផ្សាយព្រះរស្មីទៅ ហើយទ្រង់សម្តែងនូវធម៌ ដល់បុរសនោះ ។ បុរសនោះ បានអង្គុយ ស្តាប់ព្រះធម៌ទេសនា នៅលើចុងចម្រូង ដែកនេះឯង ពិចារណានូវសង្ខារទាំងឡាយ លើកឡើងកាន់ត្រ័យ លក្ខណ៍ ក៏បានសម្រេចជាព្រះសោតាបន្នហើយ បានទៅកាន់ សំណាក់នៃព្រះសាស្តា តាមវេហាស៍ បួសហើយ ក៏បានសម្រេច

មង្គលត្ថទីបនីប្រែ

ព្រះអរហត្ត នៅត្រង់កណ្តាលពួកបរិស័ទ ព្រមទាំងព្រះរាជាទុំះ ឯង ដោយប្រការដូច្នេះ ។

រឿង វិព្ភន្តិកភិក្ខុ ក្នុងតណ្ហាវគ្គ នៃធម្មបទ ចប់ ។

(៤៣) ម៉្យាងទៀត បុគ្គលពាលទាំងឡាយ រមែងញុំាងខ្លួន និង ពួកជនដែលធ្វើតាមពាក្យរបស់ខ្លួន ឲ្យវិនាស ដោយហេតុ ដែលខ្លួនប្រកាន់ហើយមិនល្អ ដូចជាបាបជនទាំងឡាយ មានភិក្ខុ ឈ្មោះទេវទត្ត ជាដើម យ៉ាងដូច្នោះឯង ។

(រឿងភិក្ខុទេវទត្ត)

បានឮថា ភិក្ខុទេវទត្ត បួសតាមព្រះសាស្តា ជាអ្នកបានឫទ្ធិ ជាបុថុជ្ជន ក្រោយមក បានជាអ្នកមានលាភសក្ការៈ គឺព្រះបាទ អជាតសត្រូវ ទ្រង់ធ្វើថ្វាយហើយ ។ ព្រះទេវទត្តនោះ ត្រូវលាភ សក្ការៈគ្របសង្កត់ហើយ បានញុំាងចិត្តដ៏លាមក ឲ្យកើតឡើង ហើយថា " អាត្មាអញ នឹងគ្រប់គ្រងនូវព្រះភិក្ខុសង្ឃ " យ៉ាងដូច្នេះ ហើយ ក៏បានវិនាសសាបសូន្យចាកឫទ្ធិ ព្រមទាំងការកើតឡើង នៃចិត្ត, ថ្ងៃមួយ បានទៅកាន់វត្តវេឡុវន ថ្វាយបង្គំព្រះសាស្តា ហើយ ក្រាបទូលថា " បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ព្រះដ៏ មានព្រះភាគ ទ្រង់ចាស់ជរា ចម្រើនវ័យ ចាស់គ្រាំគ្រាណាស់ទៅ ហើយ សូមទ្រង់មានសេចក្តីខ្វល់ខ្វាយតិច ប្រកបនៅជាសុខ ជា

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

និច្ច ក្នុងបច្ចុប្បន្នចុះ, ទូលព្រះបង្គំ នឹងគ្រប់គ្រងនូវព្រះកិកុសង្ឃ, សូមព្រះអង្គប្រគល់ នូវកិកុសង្ឃ ដល់ទូលព្រះបង្គំចុះ " ដូច្នេះ ហើយ ត្រូវព្រះសាស្តាមិនទ្រង់ជ្រះថ្លាហើយ ទ្រង់បដិសេធ ដោយ វាទៈ ថា ព្រះទេវទត្ត ជាអ្នកស៊ីនូវបច្ច័យ ៤ ដូចជាទឹកមាត់ ទើប ខូចចិត្ត ក៏បានចងគំនុំ ក្នុងព្រះសាស្តាហើយ បានចៀសចេញ ទៅ ។ ក្រោយមក ព្រះទេវទត្តនោះ បានប្រឹក្សាគ្នា ជាមួយនឹង ព្រះបាទអជាតសត្រូវហើយ បញ្ជូនពួកខ្មាន់ធ្នូទៅ ដើម្បីនឹងធ្វើ គុតព្រះសាស្តា, កាលបើពួកខ្មាន់ធ្នូទាំងនោះ សម្រេចនូវផលទី ១ ហើយត្រឡប់មកវិញ, ក៏បានឡើងទៅ លើភ្នំគិជ្ឈកូដ ដោយខ្លួន ឯង ប្រមៀលដុំសីលា ធ្វើកម្ម គឺការញាំងព្រះលោហិត ឲ្យរងជាំ ហើយ ឲ្យគេលែងដំរី ឈ្មោះនាឡាគិរី ទៅ ដើម្បីនឹងធ្វើគុតព្រះ សាស្តា ម្តងទៀត ឲ្យទាល់តែបាន ក៏មិនអាចដើម្បីនឹងធ្វើគុតព្រះ អង្គបានឡើយ ។ ព្រះទេវទត្តនោះ មានលាភ និង សក្ការៈ សាប សូន្យហើយ តាំងតែអំពីពេលនោះមក ជាអ្នកមានបំណងនឹង ចិញ្ចឹមជីវិត ដោយការបោកបញ្ឆោតគេ ទើបចូលទៅគាល់ព្រះ សាស្តាហើយ ក្រាបទូលសុំនូវវត្ត ៥ យ៉ាងថា " បពិត្រព្រះអង្គ ដ៏ចំរើន សូមទ្រង់ប្រទានឱកាស, ភិក្ខុទាំងឡាយ គប្បីជាអ្នកនៅ ក្នុងព្រៃជាវត្ត, គប្បីជាអ្នកត្រាច់ទៅបិណ្ឌបាតជាវត្ត, គប្បីប្រើ

មង្គលត្ថទីបនីប្រែ

ប្រាស់សំពត់បង្សុកូលជាវត្ត, គប្បីជាអ្នកនៅក្រោមដើមឈើជាវត្ត, មិនគួរធាន់នូវត្រី និង សាច់ រហូតអស់មួយជីវិត " ។ ព្រះសាស្តា មិនទ្រង់យល់ព្រមឡើយ ។ ព្រះទេវទត្តនោះ ពោលថា " កិក្ខុរូបណា ប្រាថ្នាចង់រួចចាកសេចក្តីទុក្ខ, កិក្ខុរូបនោះ ចូរនិមន្តមកជាមួយនឹងខ្ញុំចុះ " ដូច្នេះ, កិក្ខុ ទាំងឡាយណា ជឿនូវពាក្យរបស់ព្រះទេវទត្តនោះ, ក៏បបួលនូវកិក្ខុទាំងឡាយនោះ ទៅហើយ ញុាំងជនដែលជ្រះថ្លាហើយ ក្នុងវត្តុដែលសៅហ្មង ឲ្យយល់ព្រមដោយវត្តុទាំងឡាយ ៥ យ៉ាង ឲ្យសូម (បច្ចុ័យ ៤) ក្នុងត្រកូលទាំងឡាយ យកមកធាន់ ព្យាយាមដើម្បីនឹងបំបែកសង្ឃ ក្នុងថ្ងៃឧបោសថ បានគង់រួមជាមួយនឹងបរិស័ទ របស់ខ្លួន ហើយពោលថា " វត្តុទាំងឡាយ ៥ យ៉ាងនេះ រមែងសមគួរ ដល់កិក្ខុរូបណា, កិក្ខុ រូបនោះ ចូរចាប់នូវសលាកចុះ " ដូច្នេះ, កាលបើកិក្ខុទាំងឡាយ ៥០០ រូប អ្នកមិនវៃឆ្លាត ក្នុងព្រះធម្មវិនយ នាំគ្នាចាប់សលាកហើយ, ក៏បំបែកសង្ឃស្រេចហើយ ទើបបានទៅ កាន់គយាសីលវិហារ ។ តាំងតែអំពីពេលនោះមក ព្រះទេវទត្តនោះ ក៏កើតអាពាធ រហូត ៩ ខែ ជាអ្នកប្រាថ្នាចង់គាល់ព្រះសាស្តា ត្រូវបានពួកសាវក របស់ខ្លួន សែងនឹងគ្រែតូច ទៅកាន់ទីក្រុងសាវត្ថី បានទៅដល់មាត់ស្រះបោក្ខរណី ដែលស្ថិតនៅខាងក្រៅ

វត្តជេតពនហើយ ក៏បានចូលទៅកាន់ផែនដី (គឺផែនដីស្រូប) ហើយក៏បានទៅកើត ក្នុងអវីចិនរក ហើយ ។

រឿង ភិក្ខុទេវទត្ត បប់ ។

(រឿងព្រះចាន្ទអជាតសត្រូវ)

(៤៤) ចំណែកព្រះបាទអជាតសត្រូវ អាស្រ័យភិក្ខុទេវទត្ត ហើយ បានកាត់ផ្តាច់នូវឧបនិស្សយនៃមគ្គនិងផលខាងដើម ដែលព្រះអង្គត្រូវបាន ក្នុងបច្ចុប្បន្ន (តែ) ទ្រង់បានទទួល នូវសេចក្តីវិនាសដ៏ធំ ព្រោះទ្រង់ធ្វើកម្ម គឺការធ្វើគុតព្រះបិតា ។

បានឮថា ព្រះបាទអជាតសត្រូវអង្គនោះ ក្នុងពេលដែលព្រះអង្គជាព្រះឧបរាជ ទ្រង់ជ្រែថ្វាហើយក្នុងឥទ្ធិបាដិហារិយ៍ របស់ព្រះទេវទត្ត ទ្រង់បានស្តេចយាងទៅ កាន់ទីឧបដ្ឋាក របស់ព្រះទេវទត្តនោះ ទាំងពេលព្រឹក ទាំងពេលល្ងាច ជារៀងរាល់ថ្ងៃ ។ ក្រោយមក ថ្ងៃមួយ ព្រះទេវទត្ត បានចូលទៅរកព្រះបាទអជាត-សត្រូវនោះហើយ ថ្វាយព្រះពរ ថា " បពិត្រព្រះរាជកុមារ ក្នុងកាលមុន មនុស្សទាំងឡាយ ជាអ្នកមានអាយុវែង, ឥឡូវនេះ មនុស្សទាំងឡាយ ជាអ្នកមានអាយុខ្លី, បើដូច្នោះ ចូរព្រះអង្គធ្វើគុតនូវព្រះរាជបិតា ហើយឡើងជាព្រះរាជា (ដោយព្រះអង្គឯង) (ចំណែកឯ) អាត្មាភាព នឹងធ្វើគុតព្រះដ៏មានព្រះភាគ ហើយនឹង

ទ្បើង៎ជាព្រះពុទ្ធ " ។ ព្រះបាទអជាតសត្រូវនោះ ទ្រង់ជឿនូវពាក្យ
របស់ព្រះទេវទត្តនោះហើយ ទ្រង់កាន់យកនូវកាំបិតស្នៀត យាង
ចូលទៅខាង៎ក្នុង នៃព្រះនគរ ក្នុងវេលាថ្ងៃត្រង់ ។ អាមាត្យទាំង
ឡាយ ចាប់ព្រះបាទអជាតសត្រូវនោះហើយ ក៏បានក្រាបទូល
សាកសួរហើយ ទើបបានក្រាបទូលរឿងនោះថ្វាយដល់ព្រះរាជា ។

ព្រះរាជា ទ្រង់ត្រាស់សួរ ថា " នែព្រះកុមារ អ្នកប្រាថ្នា
ដើម្បីនឹង៎ធ្វើគុតបិតា តើដើម្បីប្រយោជន៍អ្វីទៅ ? " ។

ព្រះបាទអជាតសត្រូវ ក្រាបទូលថា " បពិត្រព្រះសម្មតិ
ទេព ទូលព្រះបង្គំ ជាអ្នកត្រូវការ ដោយរាជសម្បត្តិ " ។

ព្រះរាជា ទ្រង់បានព្រះរាជទានរាជសម្បត្តិ ដល់ព្រះបាទ
អជាតសត្រូវនោះហើយ ។ ព្រះបាទអជាតសត្រូវនោះ ទ្រង់បាន
ទូលដល់ព្រះទេវទត្ត ថា "សេចក្តីប្រាថ្នា របស់ខ្ញុំព្រះករុណា បាន
សម្រេចហើយ" ។

ព្រះទេវទត្ត. ព្រះអង្គទ្រង់ប្រៀបបាននឹង៎បុរសដែលឃាំង
ឆ្កែចចក ទុកខាង៎ក្នុង (ស្គរ) ហើយ ជាស់ស្គរទុក ដូច្នោះឯង ទ្រង់
សម្គាល់ ថា អាត្មាអញ ជាអ្នកធ្វើកិច្ចការជ័ឍ្ស ដូច្នេះ, ដោយ
រយៈពេល ២-៣ ថ្ងៃប៉ុណ្ណោះ ព្រះបិតា របស់ព្រះអង្គ នឹង៎ទ្រង់
ព្រះតម្រិះនូវការមើលងាយ ដែលព្រះអង្គទ្រង់បានធ្វើហើយ ក៏នឹង

ទ្រង់ឡើងជាព្រះរាជាខ្លួនព្រះអង្គឯង ដោយពិតប្រាកដ ” ។

ព្រះបាទអជាតសត្រូវ. បពិត្រលោកម្ចាស់ជីចំរើន តើខ្ញុំព្រះករុណា នឹងធ្វើដូចម្តេចទៅ ។

ព្រះទេវទត្ត. ចូរព្រះអង្គ ទ្រង់ធ្វើគុតព្រះបិតានោះចុះ ។

ព្រះបាទអជាតសត្រូវ. បពិត្រលោកម្ចាស់ជីចំរើន ព្រះរាជបិតា របស់ខ្ញុំព្រះករុណា ជាអ្នកដែលគេមិនគួរធ្វើគុត ដោយសស្ត្រាវុធ មិនមែនទេឬ ។

ព្រះទេវទត្ត. ចូរព្រះអង្គ ទ្រង់ធ្វើគុតព្រះរាជបិតា របស់ព្រះអង្គនោះ ដោយការបង្អត់ព្រះក្រយាស្ងោយចុះ ។

ព្រះបាទអជាតសត្រូវនោះ ទ្រង់ត្រាស់បញ្ជា ឲ្យរាជបុរសចាប់ឃុំឃាំងព្រះរាជបិតា ទុកក្នុងពន្ធនាគារដែលក្តៅ ពោលគឺពន្ធនាគារ ដែលពោរពេញទៅដោយផ្សែងភ្លើង ដែលគេសាងហើយ ដើម្បីសម្រាប់ដាក់ នូវទណ្ឌកម្ម ហើយទ្រង់ត្រាស់បញ្ជា ថា “ លើកលែងតែព្រះវរមាតា របស់យើងចេញ ពួកអ្នកចូរកុំឲ្យអ្នកដទៃចូលគាល់ឡើយ ” ។

ព្រះរាជទេវី ទ្រង់បានដាក់ព្រះក្រយាស្ងោយក្នុងផ្តិលមាស ទ្រង់ដាក់នឹងថ្នក់ព្រះកូសា យាងចូលទៅថ្វាយ ដល់ព្រះរាជា ។

ព្រះបាទពិម្ពិសារអង្គនោះ ទ្រង់ញុាំងអត្តភាព ឲ្យប្រព្រឹត្ត

ទៅ ដោយព្រះក្រយាស្ងោយនោះ ។

ព្រះបាទអជាតសត្រូវ ទ្រង់ត្រាស់សួរថា " ព្រះរាជបិតា របស់ខ្ញុំ ទ្រង់ញុាំងព្រះវរកាយ ឲ្យប្រព្រឹត្តទៅ យ៉ាងដូចម្តេច ? " ដូច្នេះហើយ ទ្រង់ព្រះសណ្តាប់ នូវរឿងនោះ ទើបទ្រង់ត្រាស់ ថា " អ្នកទាំងឡាយ ចូរកុំឲ្យព្រះរាជមាតា របស់យើង ស្តេចវេចខ្ជប់ ព្រះក្រយាស្ងោយ ក្នុងថ្នក់ព្រះកូសា យាងចូលទៅឡើយ " ។

ព្រះរាជទេវី ទ្រង់បានដាក់ព្រះក្រយាស្ងោយ ក្នុងព្រះមោលី ហើយស្តេចយាងចូលទៅ ។

ព្រះបាទអជាតសត្រូវ ទ្រង់ព្រះសណ្តាប់រឿងនោះហើយ ទើបទ្រង់ត្រាស់ ថា " អ្នកទាំងឡាយ ចូរកុំឲ្យព្រះរាជមាតា របស់យើង ស្តេចចងព្រះមោលី យាងចូលទៅឡើយ " ។

ព្រះរាជទេវី ទ្រង់បានដាក់ព្រះក្រយាស្ងោយ ក្នុងព្រះសុពណ៌ាបាទុក ទ្រង់បិទជិតហើយ ទើបទ្រង់ឆ្លងព្រះបាទុក ស្តេចយាងចូលទៅ ។

ព្រះបាទអជាតសត្រូវ ទ្រង់ព្រះសណ្តាប់រឿងនោះហើយ ទើបទ្រង់ត្រាស់ ថា " អ្នកទាំងឡាយ ចូរកុំឲ្យព្រះវរមាតា របស់យើង ទ្រង់ឆ្លងព្រះបាទុក ស្តេចយាងចូលទៅឡើយ " ។

ព្រះរាជទេវី ទ្រង់បានស្រង់ (ព្រះវរកាយ) ដោយទឹក

ដែលមានក្លិនក្រអូប ទ្រង់លាបព្រះវរកាយ ដោយគ្រឿងក្រអូប ៤ យ៉ាងហើយ ទ្រង់ព្រះភូសា ស្តេចយាងចូលទៅ ។

ព្រះរាជា ទ្រង់លិទ្ធព្រះវរកាយ របស់ព្រះរាជទេវីហើយ ទ្រង់ញ៉ាំងព្រះវរកាយ ឲ្យប្រព្រឹត្តទៅ ។

មានពាក្យសួរថា " ការស្ងាប់ ដោយសេចក្តីព្យាយាម របស់ខ្លួនឯង (គឺសម្លាប់ខ្លួនឯង) មិនគួរទេឬ ? " ។

មានពាក្យឆ្លើយថា " មែនពិត ព្រះអរិយសាវ័កទាំងឡាយ រមែងមិនញ៉ាំងខ្លួន ឲ្យធ្លាក់ចុះ (សម្លាប់ខ្លួនឯង) ឡើយ " ។

ព្រះបាទអជាតសត្រូវ ទ្រង់ត្រាស់សួរ ម្តងទៀតហើយ ទ្រង់ព្រះសណ្តាប់ នូវរឿងនោះហើយ ទើបទ្រង់ត្រាស់បញ្ជា ថា " ចាប់តាំងអំពីពេលនេះទៅ អ្នកទាំងឡាយ ចូរហាមប្រាម កុំឲ្យ ព្រះវរមាតា របស់យើង ស្តេចយាងចូលទៅឡើយ " ។

ព្រះរាជទេវី ទ្រង់គង់នៅ ក្បែរមាត់ទ្វារហើយ ទ្រង់បាន ក្រាបទូលថា " បពិត្រព្រះបាទពិម្ពិសារ ព្រះរាជស្វាមី ឥឡូវនេះ នេះជាការចូលគាល់ព្រះអង្គ នៅគ្រាចុងក្រោយហើយ, ចាប់តាំង អំពីថ្ងៃនេះទៅ ទូលព្រះបង្គំ នឹងមិនបានចូលគាល់ព្រះអង្គឡើយ, បពិត្រព្រះសម្មតិទេព បើទោស របស់ទូលព្រះបង្គំ មាន, សូម ព្រះអង្គទ្រង់អត់ទោសផងចុះ " ដូច្នេះ ទ្រង់ព្រះកន្សែងហើយ ទើប

ស្តេចយាងត្រឡប់ទៅវិញ ។

តាំងអំពីថ្ងៃនោះមក ព្រះរាជា ទ្រង់អត់ព្រះក្រយាស្ងោយ ទ្រង់ញុាំងព្រះវរកាយ ឲ្យប្រព្រឹត្តទៅ ដោយការស្តេចយាងចង្រ្កម ដែលប្រកបដោយសេចក្តីសុខ ដែលកើតពីមគ្គ និង ផល ។ ក៏ព្រះវរកាយ របស់ព្រះអង្គនោះ ទ្រង់ក្តីស្វាងរុងរឿង យ៉ាងក្រៃលែង ។

ព្រះបាទអជាតសត្រូវ ទ្រង់ត្រាស់សួរថា " តើព្រះរាជបិតា របស់យើង ទ្រង់ញុាំងព្រះវរកាយ ឲ្យប្រព្រឹត្តទៅ យ៉ាងដូចម្តេចដែរ? " ដូច្នេះ ទ្រង់ព្រះសណ្តាប់ ថា " ដោយការស្តេចយាងចង្រ្កម " ហើយ ទ្រង់បានបញ្ជូន នូវខ្នាន់ព្រះកេសទាំងឡាយ ទៅដោយព្រះរាជឱង្ការ ថា " អ្នកទាំងឡាយ ចូរយកកាំបិតកោរ អារព្រះបាទទាំងទ្វេ របស់ព្រះរាជបិតា របស់យើង ហើយប្រឡាក់ប្រេងដែលផ្សំដោយអំបិលស្រេចហើយ យករងើកក្តីងខសសង្កែមកគោល " ។

ខ្នាន់ព្រះកេសទាំងនោះ បានទៅក្រាបទូលព្រះរាជឱង្ការដល់ព្រះរាជា ត្រូវបានព្រះអង្គត្រាស់ ថា " អ្នកទាំងឡាយ ចូរធ្វើ (តាម) ព្រះរាជហឫទ័យ នៃព្រះរាជា របស់អ្នកទាំងឡាយចុះ " យ៉ាងដូច្នេះហើយ ទើបក្រាបទូលថា " បពិត្រព្រះសម្មតិទេព សូមព្រះអង្គទ្រង់គង់ចុះ, ទូលព្រះបង្គំទាំងឡាយ នឹងធ្វើ (តាម) ព្រះ

រាជអាជ្ញា របស់ព្រះរាជា, សូមព្រះអង្គកុំទ្រង់ព្រះពិរោធ ដល់ពួក ទូលព្រះបង្គំឡើយ, កម្មនេះ ជាកម្មមិនសមគួរ ដល់ព្រះរាជាដែល ទ្រទ្រង់នូវធម៌ ដូចជាព្រះអង្គឡើយ " ដូច្នេះហើយ ក៏បានធ្វើតាម ព្រះរាជបញ្ជា ដូច្នោះហើយ ។

(បុព្វកម្មរបស់ព្រះបាទពិម្ពិសារ)

បានឮថា ក្នុងកាលមុន ព្រះរាជា ទ្រង់បានទ្រង់ព្រះបាទុក លើលានព្រះចេតិយ ដែលជាស្ថានទីបូជា ដោយគ្រឿងសក្ការៈ ទាំងឡាយ មានគ្រឿងក្រអូប និង ផ្កាជាដើម ។ អាចារ្យពួកខ្លះ ពោលថា " ព្រះបាទពិម្ពិសារអង្គនោះ ទ្រង់យាងលើកនេះដែល គេក្រាលហើយ ដើម្បីប្រយោជន៍ដល់ការគង់ របស់ព្រះកិក្ខុសង្ឃ ដោយព្រះបាទទាំង ២ ដែលមិនបានលាងហើយ, នេះ គឺជាផល នៃកម្មនោះ " ដូច្នេះ ក៏មានដែរ ។

ព្រះរាជា ទ្រង់ទទួលវេទនាដ៏ធ្ងន់ ទ្រង់នឹករឭកតែម៉្យាង ប៉ុណ្ណោះ ថា " អស្ចារ្យមែន ! ព្រះពុទ្ធ, អស្ចារ្យមែន ! ព្រះធម៌, អស្ចារ្យមែន ! ព្រះសង្ឃ " យ៉ាងដូច្នេះ ស្តេចទ្រង់ចុតិ ទៅកើតជា យក្សឈ្មោះជនវសភៈ ជាអ្នកបំរើស្តេចវេស្សវណ្ណ ក្នុងទេវលោក ជាន់ចាតុមហារាជិកា ដោយអំណាចនៃការសព្វព្រះរាជហឫទ័យ ដែលព្រះអង្គទ្រង់បានអប់រំមក ជាយូរអង្វែង ព្រោះព្រះអង្គទ្រង់

ផ្ទាប់បានទៅកើត ក្នុងទេវលោក ជាន់ចាតុមហារាជិកានោះ ជាច្រើនដងហើយ ។

ព្រះបាទអជាតសត្រូវអង្គនោះ ទ្រង់បានធ្វើគុតព្រះវរបិតាដូចបានពណ៌នាមកហើយនេះ ជាខាងក្រោយមក ក៏ទ្រង់កើតសេចក្តីស្រឡាញ់ ចំពោះព្រះវររាជបិតា ទើបទ្រង់ព្រះកន្សែងខ្សឹកខ្សួលហើយ ទ្រង់បានថ្វាយព្រះភ្លើងព្រះសព របស់ព្រះបាទពិម្ពិសារនោះហើយ ។

(ព្រះបាទអជាតសត្រូវទ្រង់ឆឹកឃើញកំហុស)

បន្តអំពីនោះមក កិកុ ទេវទត្ត បានប្រឹក្សាគ្នា ជាមួយនឹងព្រះបាទអជាតសត្រូវនោះហើយ ធ្វើអំពើអាក្រក់ រាប់តាំងអំពីបញ្ជូននាយខ្វាន់ធ្នូទៅ ដើម្បីធ្វើគុតព្រះសាស្តាជាដើម រហូតទល់គ្នានឹងការបំបែកបំបាក់ព្រះសង្ឃ ហើយក៏បានចូលទៅកាន់ផែនដី (ផែនដីស្រូប) ដោយនយ័ដែលបានពោលមកហើយនុ៎ះឯង ។

ព្រះរាជា ទ្រង់ព្រះសណ្តាប់រឿងនោះហើយ ទ្រង់មានព្រះរាជហឫទ័យកិតក័យ តក់ស្លុត ដោយទ្រង់ព្រះតម្រិះ ថា " ផែនដីនឹងគប្បីស្រូបយកនូវអាត្មាអញផងដែរ ឬក៏ទេហ្ន៎ ? " ដូច្នេះហើយ ទើបទ្រង់មិនបានសោយនូវសេចក្តីសុខ ក្នុងព្រះរាជសម្បត្តិ មិនទ្រង់បានទទួល នូវការសព្វព្រះទ័យ ក្នុងការបន្ទំឡើយ ទ្រង់រសាប់

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

រសល់ ស្តេចយាងទៅ ប្រៀបដូចជាសត្វប្រេត ដែលត្រូវគេចាក់ដោយគ្រឿងសម្រាប់ជាក់ទណ្ឌកម្មដូច្នោះឯង ។ ក៏ព្រះបាទអជាតសត្រូវអង្គនោះ ទ្រង់ពិចារណាឃើញព្រះកាយព្រះអង្គ ដូចជាត្រូវផែនដីស្រូប ដូចជាកំពុងតែចេញ អំពីអណ្តាតភ្លើងអវិចីនរក និងប្រៀបបីដូចជាត្រូវពេជ្ឈឃាត កំពុងតែឲ្យផ្ចំផ្ងារ នៅលើផែនដីហើយបុកច្រំដោយលំពែងដែក ។ ដោយហេតុនោះ កាលព្រះបាទអជាតសត្រូវអង្គនោះ ទ្រង់រសាប់រសល់ ប្រៀបដូចជាសត្វមាន់ដែលត្រូវគេប្រហារ យ៉ាងដូច្នោះ ទើបទ្រង់មិនបានមានសេចក្តីស្ងប់ព្រះរាជហឫទ័យ ត្រឹមតែមួយរំពេចសោះឡើយ ។ ព្រះរាជាអង្គនោះ សូម្បីតែទ្រង់មានព្រះបំណង ចង់គាល់ព្រះសាស្តា និងក្រាបទូលសួរបញ្ហា ហើយទ្រង់ញុាំងព្រះសាស្តាឲ្យទ្រង់អត់ទោសឲ្យ ក៏ទ្រង់មិនអាច ដើម្បីនឹងចូលទៅគាល់ព្រះសាស្តាបានឡើយ ព្រោះព្រះអង្គទ្រង់មានទោសកំហុសដ៏ធំធេង ។ ក្នុងថ្ងៃពេញបូរមីថ្ងៃមួយ ព្រះបាទអជាតសត្រូវអង្គនោះ ទ្រង់គ្រាស់សួរគ្រូពេទ្យជីវកកោមារភ័ច្ច ថា " ឥឡូវនេះ តើព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងទីឯណា ? " ។ គ្រូពេទ្យ ជីវក ក្រាបទូលថា " ក្នុងឧទ្យានព្រៃស្វាយ នៃទូលព្រះបង្គំ " ។

ចានឮថា ក្នុងកាលមុន គ្រូពេទ្យ ជីវក បានធ្វើទីសម្រាប់

មង្គលត្ថទីបនីប្រែ

សម្រាក ក្នុងវេលាយប់ និង វេលាថ្ងៃ ទីសម្ងំ កុដិ និង មណ្ឌប ជាដើមឲ្យសម្រេចហើយ និង បានឲ្យនាយជាងកសាងព្រះគន្ធកុដិ ដើម្បីព្រះសាស្តា ក្នុងឧទ្យានព្រៃស្វាយនោះ ធ្វើឧទ្យានអម្ពវ័ន ដែលព្រះបាទពិម្ពិសារ ទ្រង់បានព្រះរាជទានហើយ ដល់ខ្ជូននោះ ឲ្យជាវត្ត ហើយវេរប្រគេនហើយ ។ ពាក្យនោះ គ្រូពេទ្យជីវកបាន ពោលសំដៅយកឧទ្យាននោះ ។

គ្រានោះ ព្រះរាជា ទ្រង់បានធ្វើគ្រូពេទ្យជីវក ឲ្យជាមគ្គ-នាយក ហើយស្តេចយាងទៅកាន់ជីវកម្ពវនារាម ក្នុងពេលរាត្រី ក្នុងថ្ងៃនោះភ្លាម ទ្រង់បានថ្វាយបង្គំព្រះសាស្តា និង ធ្វើអញ្ជលីកម្ម ដល់ព្រះភិក្ខុសង្ឃ ទ្រង់គង់ ក្នុងទីដ៏សមគួរហើយ ក្រាបទូលសួរ បញ្ហា ដោយនយដែលបានពោលហើយ ក្នុងសាមញ្ញផលសូត្រ នុ៎ះឯង ។

គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ព្រះតម្រិះថា " ព្រះរាជា ព្រះអង្គនេះ ចាប់តាំងអំពីពេលដែលព្រះអង្គ ទ្រង់គ្រាស់បញ្ជា ឲ្យ ពួកអាមាត្យធ្វើគុតព្រះរាជបិតា មក ទ្រង់មិនបានព្រះបន្ទំ រហូត ទាំងយប់ទាំងថ្ងៃឡើយ, ព្រោះថា ព្រះរាជាអង្គនោះ ប្រៀបដូចជា ត្រូវគេចាក់នឹងលំពែង ១០០ ដើម កាលបើគ្រាន់តែទ្រង់ធ្មេច ព្រះនេត្រចុះ ដោយទ្រង់មានព្រះបំណង ថា " អាត្មាអញ នឹងផ្ទំ "

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

ដូច្នេះប៉ុណ្ណោះ ក៏ស្តេចបែរជាទ្រង់តើនឡើង រសាប់រសល់ទៅវិញ, ក៏ក្នុងថ្ងៃនេះ ព្រះរាជាអង្គនេះ ស្តេចយាងមកគាល់តថាគត ហើយ ក៏នឹងទ្រង់ចូលកាន់ព្រះបន្ទំ ចាប់តាំងអំពីពេលដែលព្រះអង្គទ្រង់បានព្រះសណ្តាប់ព្រះធម្មទេសនានេះហើយ ក៏នឹងទ្រង់ធ្វើសក្ការៈ ដល់ព្រះរតនត្រៃ, ឈ្មោះថា បុគ្គលអ្នកដល់ព្រមដោយសទ្ធាជាបុថុជ្ជន ដូចជាព្រះរាជាព្រះអង្គនេះឯង នឹងមិនមានឡើយ, មួយទៀត ក្នុងវេលាចប់ទេសនា ព្រះរាជាអង្គនេះនឹងទ្រង់តាំងនៅក្នុងព្រះត្រៃយសរណៈ, ក៏ព្រះរាជា ព្រះអង្គនេះ ទ្រង់បានដល់ នូវព្រះត្រៃសរណៈ ព្រោះហេតុណា, ព្រោះហេតុនោះ ព្រះរាជា ព្រះអង្គនេះ ក៏នឹងទ្រង់ទៅកើត ក្នុងនរក ឈ្មោះលោហកុម្ភី ហើយធ្លាក់ចុះទៅ ដល់បាតក្រោម មកដល់បាតឆ្នាំង ដោយកាលប្រមាណ ៣ ម៉ឺន ឆ្នាំ បានផុសឡើងមកខាងលើ ម្តងទៀត ហើយបានមកដល់មាត់ឆ្នាំង អស់កាលប្រមាណ ៣ ម៉ឺន ឆ្នាំ ហើយ ក៏នឹងបានរួចផុត ប្រៀបឧបមាដូចជាបុគ្គលពួកខ្លះ ធ្វើការសម្ងាប់បុរស គប្បីបានរួចផុត អំពីអាជ្ញា ដោយវត្ថុត្រឹមតែផ្តាមួយក្តាប់ យ៉ាងដូច្នោះឯង ព្រោះព្រះសាសនា របស់តថាគតជាព្រះសាសនាដ៏ធំ, ម៉្យាងវិញទៀត ព្រះរាជា ព្រះអង្គនេះ នឹងទ្រង់បានជាព្រះបច្ចេកពុទ្ធ ទ្រង់ព្រះនាមថា ជីវិតវិសេស ហើយនឹង

ទ្រង់បរិនិព្វាន ក្នុងអនាគតកាល " យ៉ាងដូច្នេះហើយ ទ្រង់ជ្រាបនូវអានិសង្សដ៏ច្រើន ដែលព្រះរាជាអង្គនោះគប្បីបាន ព្រោះទ្រង់ព្រះសណ្តាប់ព្រះធម៌នេះ កាលនឹងទ្រង់ព្យាករនូវបញ្ហា របស់ព្រះរាជាអង្គនោះ ទើបទ្រង់សំដែងសាមញ្ញផលសូត្រ ក្នុងសីលក្ខន្ធវគ្គ ។

ក្នុងវេលាចប់ទេសនា ព្រះរាជា ទ្រង់បានសាបសូន្យហើយចាកព្រះសោតាបត្តិផល ព្រោះព្រះអង្គជាអ្នកមានឧបនិស្ស័យ នៃមគ្គ គឺព្រះអង្គបានកាត់ផ្តាច់ហើយ ទើបទ្រង់បានដល់ នូវព្រះត្រៃសរណៈ ដោយទ្រង់បានថ្វាយនូវព្រះអង្គ ។ ក៏ប្រសិនបើព្រះរាជ-បិតា នឹងមិនត្រូវព្រះបាទអជាតសត្រូវអង្គនោះ ទ្រង់ធ្វើគុតហើយ, ព្រះបាទអជាតសត្រូវនោះ ក៏នឹងបានសម្រេចជាព្រះសោតាបន្ន ក្នុងទីទ្រង់គង់នោះតែម្តង, តែសេចក្តីអន្តរាយនៃមគ្គ បានកើតឡើងហើយ ដល់ព្រះអង្គ ព្រោះទ្រង់សេពគប់នឹងបាបមិត្រ ។

ព្រះរាជា ទ្រង់ដល់នូវសរណៈ យ៉ាងដូច្នេះហើយ ទ្រង់បានប្រកាសនូវទោសកំហុស ដែលព្រះអង្គទ្រង់បានធ្វើហើយ ចំពោះព្រះភក្ត្រនៃព្រះសាស្តា ទ្រង់ញុាំងព្រះសាស្តា ឲ្យអត់ទោស ឲ្យហើយ ទើបស្តេចក្រោកចាកអាសនៈ ទ្រង់ធ្វើប្រទក្សិណ ៣ ជុំ ហើយទ្រង់ប្រណមអញ្ជលី ជាក់លើព្រះសិរសី ទ្រង់បានបែរព្រះភក្ត្រ តម្រង់ត្មោះទៅព្រះសាស្តាហើយ ទ្រង់ស្តេចយាងថយក្រោយ

ចេញមក ដរាបដល់ស្ថានទីដែលទ្រង់ទតព្រះនេត្រឃើញ ទ្រង់ថ្វាយបង្គំ ដោយកិរិយាតម្កល់ចុះចំពោះនូវអវយវៈ ប្រកបដោយអង្គប្រាំ លើផែនដី ក្នុងស្ថានទីដែលទ្រង់ទតព្រះនេត្រមិនឃើញហើយ ទើបស្តេចយាងគេចចេញទៅ ។

រឿងព្រះបាទអជាតសត្រូវ ក្នុងអដ្ឋកថាសាមញ្ញផលសូត្រ ចប់ ។

(កិរិយាប្រកាន់ខ្លួនជាំឱ្យធ្លាក់នរក)

(៤៥) ក្នុងអតីតកាល សូម្បីបង្កប្រុស របស់និគ្រន្ថ ឈ្មោះទីឃវិថៈ មានអត្តភាពប្រមាណ ៦០ យោជន៍ ជាអ្នកដេកផ្ងារ ផ្ងាក់ទៅឆេះ ក្នុងមហានរក អស់ ៤ ពុទ្ធន្តរ ព្រោះកម្មដែលខ្លួនបានប្រកាន់ខុស ។ ត្រកូលទាំង ៥០០ ដែលរាប់អាននូវទិដ្ឋិ របស់គេនោះ បានចូលដល់ភាពជាសំឡាញ់ របស់អ្នកនោះឯង ហើយក៏បានឆេះ ក្នុងមហានរក ដូចគ្នាដែរ ។

រឿងនេះ មកហើយ ក្នុងអដ្ឋកថា ។

(ជិនពាលធ្វើខ្លួនមិនឱ្យមានសិរី)

(៤៦) សូម្បីគ្រូទាំង ៦ មានបូរណកស្សបៈជាដើម ប្តេជ្ញាថា "ពួកយើង ជាអ្នកបានសម្រេចអនុត្តរសម្មាសម្ពោធិញ្ញាណ" ដូច្នេះ រមែងធ្វើខ្លួនឲ្យវិនាស ព្រោះអំពើដែលខ្លួនប្រកាន់ខុស ។ សូម្បីជនអន្ធពាលទាំងឡាយជាច្រើន ដែលចូលចិត្តនូវទិដ្ឋិ របស់

មង្គលត្ថទីបនីប្រែ

គ្រូទាំង ៦ នាក់នោះ ក៏តែងជល់នូវសេចក្តីវិនាស ។ មែនពិត ជនពាលទាំងនោះ ជាអ្នកមានទុគ្គតិ ប្រព្រឹត្តទៅខាងមុខគ្រប់ៗ គ្នា ។

សួរថា " ក៏គ្រូទាំង ៦ នាក់នោះ បានឈ្មោះថា បូរណៈជាដើម តើព្រោះហេតុអ្វី ? " ។ ខ្ញុំនឹងឆ្លើយ ដូចតទៅនេះ ។

(ប្រវត្តិរបស់បូរណាកស្សបៈ)

បានឮថា ត្រកូលមួយ មានខ្ញុំបម្រើ ៩៩ នាក់ ខ្ញុំបម្រើម្នាក់ បានកើតមកគម្រប់ (ត្រូវជា ១០០ នាក់ល្មម) ។ ព្រោះហេតុដូច្នោះ ពួកចៅហ្វាយនាយ ទើបបានដាក់ឈ្មោះឲ្យអ្នកបម្រើនោះថា " បូរណៈ " ។ ក៏ពួកចៅហ្វាយនាយ អ្នកដែលពោលថា " ការងារ គឺនាយបូរណៈនោះ ធ្វើល្អហើយ ធ្វើមិនល្អ " ដូច្នេះឬក៏ " ការងារ គឺនាយបូរណៈនោះ មិនបានធ្វើហើយ ឬ បានធ្វើហើយ" ដូច្នេះ មិនមានឡើយ ព្រោះនាយបូរណៈនោះ ជាអ្នកបម្រើដែលមានសិរីសួស្តី ។ នាយបូរណៈនោះ គិតថា " នឹងមានប្រយោជន៍អ្វីទៅ ជល់អាត្មាអញ ដោយការរស់នៅ ក្នុងទីនេះ " ដូច្នេះហើយ ក៏បានរត់គេចចេញទៅ ។

គ្រានោះ ពួកចោរ ក៏ដណ្តើមយកសំពត់ទាំងឡាយ របស់នាយបូរណៈនោះហើយ ។ នាយបូរណៈនោះ កាលមិនដឹងសូម្បីដើម្បីនឹងបិទបាំង ដោយស្មៅ និង ស្លឹកឈើ ក៏ជាអ្នកអាក្រាត ចូល

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

ទៅកាន់ស្រុកមួយ ។ មនុស្សទាំងឡាយ ឃើញនាយបូរណៈនោះ ហើយ ក៏សម្គាល់ថា " បុរសនោះ ជាសមណៈ ជាព្រះអរហន្ត ជាអ្នកមានសេចក្តីប្រាថ្នាតិច, បុគ្គលដទៃទៀត ដែលស្មើនឹងបុរសនេះ រមែងមិនមាន " ហើយ ទើបបានឲ្យហើយ នូវវត្ថុទាំងឡាយ មានន្ទុំ និង កត្តជាដើម ។ នាយបូរណៈនោះ គិតថា " ន្ទុំ និង កត្តជាដើមនេះ បានកើតឡើងហើយ ព្រោះតែអញមិនស្ងៀកសំពត់ " ដូច្នេះ តាំងអំពីពេលនោះមក សូម្បីបានសំពត់ហើយ ក៏មិនព្រមស្ងៀកពាក់ បានប្រកាន់យកភេទអាក្រាតនោះឯង ធ្វើជាបព្វជ្ជា ។ ពួកមនុស្ស ៥០០ នាក់ បានបួសហើយ ក្នុងសំណាក់ របស់នាយបូរណៈនោះ ។ នាយបូរណៈនោះឯង បាននូវឈ្មោះ ដោយអំណាចនៃគោត្រ ថា " កស្សបៈ " ។

(ប្រវត្តិរបស់មក្ខលិគោសាល)

ចំណែក បុរសម្នាក់ ជាអ្នកបម្រើ របស់ចៅហ្វាយនាយម្នាក់ សែងក្រឡប្រេង ដើរទៅលើផែនដី ដែលមានភក់ ត្រូវចៅហ្វាយនាយប្រាប់ ថា " នែអ្នក ចូរកុំអើលដួលទៅយ " ដូច្នេះ ក៏រអើលដួល ដោយសេចក្តីប្រមាទហើយ បានប្រាវឮ ដើម្បីរត់គេចទៅ ព្រោះភ័យខ្លាចចៅហ្វាយនាយ ។ ចៅហ្វាយនាយ បានរត់តាម ទៅចាប់ជាយសំពត់ ។ បុរសនោះ បានចោះចោលសំពត់

ជាអ្នកអាក្រាត បានរត់គេចទៅហើយ ។ ពាក្យដែលសេសសល់ ក៏ដូចគ្នា នឹងនាយបូរណកស្សបៈនុ៎ះឯង ។ នាយមក្ខលិនោះឯង គេហៅថា " គោសាលៈ " ដូច្នេះ ក៏មាន ព្រោះជាអ្នកកើត ក្នុងក្រោលគោ ។

(ប្រវត្តិរបស់និគ្រន្ថ នាដបុត្រ)

ចំណែកឯ បុរសម្នាក់ បានឈ្មោះថា " និគ្រន្ថ " ព្រោះជាអ្នកមានប្រក្រតីពោល យ៉ាងនេះថា " ពួកយើង មិនមានកិលេសដែលជាគ្រឿងចងរឹត, ពួកយើង ជាអ្នកជ្រាសចាកកិលេស ដែលជាគ្រឿងចងរឹត " ដូច្នេះ និង គេហៅថា " នាដបុត្រ " ព្រោះគេជាកូន របស់អ្នកវេជ្ជ ។

ក៏កិលេស ជាគ្រឿងចងរួបរឹត ឈ្មោះថា " កិលេសជាគ្រឿងចងរឹត " ក្នុងពាក្យនោះ ។

កិលេសមានភាគៈជាដើម របស់បុរសនោះ មានការជាប់ជំពាក់ ក្នុងផ្ទះសម្បែង ជាកិច្ច មានស្រែ ចំការ បុត្រ និង ភរិយា ជាដើម ជាអារម្មណ៍ ។

(ប្រវត្តិរបស់សញ្ជ័យវេលដ្ឋបុត្រ)

ចំណែកបុរសម្នាក់ គេហៅថា "សញ្ជ័យ " ដោយអំណាចនៃឈ្មោះ និង គោត្រ ថា "វេលដ្ឋបុត្រ " ព្រោះគេជាកូន របស់

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

ជាឥតម្បាញផែង ។

(ប្រវត្តិរបស់បកុធកច្ចាយនៈ)

ចំណែក បុរសម្នាក់ គេហៅថា " បកុធ " ដោយអំណាចនៃឈ្មោះ និង គេហៅថា " កច្ចាយនៈ " ដោយអំណាចគោត្រ ។ បុរសនេះ ជាអ្នកបជិរសេធនូវទឹកត្រជាក់ ។ មែនពិត បុរសនោះ បន្ទោបង់ឧច្ចារៈក្តី បរិភោគភោជនក្តី របស់មិនស្អាត ឯណាមួយ ប្រឡាក់ក្តី ក៏មិនធ្វើកិច្ចជម្រះដោយទឹក (ត្រជាក់) ដែរ, បានទឹកក្តៅ ឬ ទឹកជាយហើយទើបធ្វើ, ឆ្ងន់ទន្ទេ ឬ ទឹកកណ្តាលផ្លូវ ក៏គិតថា " សីលអញ ធុះធ្លាយហើយ " ដូច្នេះ ពួនជីខ្ជាច់ជាពំនូកដោយអំណាចវត្តហើយ ក៏អធិដ្ឋានសីលស្រេចហើយ ទើបដើរទៅ ។ បុរសនេះ ប្រកាន់នូវលទ្ធិដែលមិនមានសិរី យ៉ាងដូច្នេះ ។

(ប្រវត្តិរបស់អជិតកេសកម្ពល)

ឯបុរសម្នាក់ គេហៅថា " អជិតៈ " ដោយអំណាចឈ្មោះ និង គេហៅថា "កេសកម្ពល" ព្រោះអត្ថថា " ទ្រទ្រង់សំពត់កម្ពលដែលគេធ្វើហើយ ដោយសក់មនុស្សទាំងឡាយ " ដូច្នេះឯង ។

រឿងគ្រូទាំង ៦ នាក់ មកក្នុងអដ្ឋកថា សាមញ្ញផលសូត្រ ។

ពួកជនពាល រមែងញុំាងខ្លួន និង ពួកជន ដែលធ្វើតាមពាក្យ របស់ខ្លួន ឲ្យវិនាស ព្រោះកម្មដែលខ្លួនប្រកាន់យកហើយ

មិនល្អ ដោយប្រការដូច្នេះឯង ។

(បណ្ឌិតធ្វើខ្លួនដូចជនអ្នកធ្វើតាមខ្លួនឲ្យបំរើន)

(៤៧) ចំណែកបណ្ឌិតទាំងឡាយ រមែងមិនញុំាងខ្លួន និង ពួកជនអ្នកដែលធ្វើតាមពាក្យ របស់ខ្លួន ឲ្យវិនាសឡើយ រមែងឲ្យ បានដល់ (តែ) សេចក្តីចំរើន ព្រោះកម្ម ដែលខ្លួនបានប្រកាន់យក ហើយល្អ ដូចជាអ្នកជ្រាជ្រទាំងឡាយមានព្រះពុទ្ធជាដើម ។ មែន ពិត ព្រះពុទ្ធ ទ្រង់បានសម្រេច នូវព្រះសព្វញ្ញុតញ្ញាណ ដែល ប្រដាប់ដោយគុណទាំងពួង ព្រោះកម្មដែលព្រះអង្គ ទ្រង់ប្រកាន់ យកល្អហើយ, ព្រះថេរៈទាំងឡាយ មានព្រះសារីបុត្រជាដើម ក៏ យ៉ាងដូច្នោះដែរ បានសម្រេចគុណជាត មានសាវកបារមីញ្ញាណ ជាដើម ។ ក៏ទេវតា និង មនុស្សទាំងឡាយ ប្រមាណមិនបាន អាស្រ័យនូវព្រះពុទ្ធហើយ ក៏បានសម្រេច នូវអាសវក្ខយញ្ញាណ ហើយ បានចូលទៅកាន់ព្រហ្មលោក, ត្រកូល ៨ ម៉ឺន ញុំាង ចិត្តឲ្យជ្រះថ្លា ក្នុងព្រះសារីបុត្តត្ថេរហើយ ឧបត្ថម្ភព្រះថេរៈ ដោយ បច្ច័យ ៤ បានកើតហើយក្នុងឋានសួគ៌, មួយទៀត ត្រកូលទាំង ៨ ម៉ឺន ញុំាងចិត្តឲ្យជ្រះថ្លាហើយ ក្នុងព្រះមហាសាវ័កទាំងពួង មាន ព្រះមហាមោគ្គល្លានត្ថេរ និង ព្រះមហាកស្សបៈជាដើម ក៏យ៉ាង ដូច្នោះដែរ ។

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

(រឿងគ្រូសុនេត្រ)

(៤៨) ក្នុងអតីតកាល ព្រះពោធិសត្វ មានព្រះនាមថា សុនេត្រ ជាសាស្តា នៃគណៈ ធ្វើលទ្ធិដូចជាកំពង់ ជាទីចុះកាន់សុគតិ ជាអ្នកប្រាសចាកសេចក្តីតម្រេកក្នុងកាមទាំងឡាយ ដោយអំណាចនៃវិក្ខម្ភនបហាន: ដែលព្រះសាស្តាទ្រង់ត្រាស់សំដៅយកក្នុងសុត្តសុរិយសូត្រ ក្នុងសត្តកនិបាត អង្គុត្តរនិកាយ ថា " ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង គ្រូសុនេត្រ បានអប់រំចិត្ត ប្រកបដោយមេត្តា រហូត ៧ ឆ្នាំ, លុះបានអប់រំមេត្តាចិត្ត អស់ ៧ ឆ្នាំហើយ ទើបមិនបានមកកាន់លោកនេះ ម្តងទៀត រហូតដល់ ៧ សំវដ្តវិវដ្តកប្ប, ម្នាលភិក្ខុទាំងឡាយ បានឮថា កាលបើលោកវិនាស, គ្រូសុនេត្រនោះ ជាអ្នកចូលទៅដល់ព្រហ្មលោក ជាន់អកស្សរ:, កាលបើលោកចំរើន រមែងចូលទៅ កាន់វិមានព្រហ្មដែលស្វាត់សូន្យ " ។

បណ្តាបទទាំងនោះ ២ បទ ថា " ***មេត្តចិត្តំ ភាវេត្វា*** " គឺ លុះអប់រំចិត្ត ដែលប្រកបព្រមដោយមេត្តា ដែលប្រកបដោយតិកឈាន និង ចតុក្កឈាន ធ្វើឲ្យប្រណីតហើយ ។ ក៏ក្នុងបទទាំង ២ នេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់សមាធិ ដោយសព្ទ គឺចិត្ត ជាប្រធាន ព្រោះហេតុនោះ ទើបមានសេចក្តី ថា " លុះញុំងមេត្តា

មង្គលត្ថទីបនីប្រែ

*សមាធិ គឺមេត្តាព្រហ្មវិហារ ឲ្យកើតហើយ និង ឲ្យចំរើនឡើងហើយ" ។ ២ បទថា " **សត្ត សំវដ្តវិវដ្តកប្បេ** " គឺ អស់មហាកប្ប ៧ ។ សូម្បីកប្បដែលតាំងនៅក្នុងផ្លូវវិនាស និង កប្បដែលតាំងនៅ ក្នុងផ្លូវចំរើន ក៏ព្រះមានព្រះភាគ ទ្រង់ប្រកាន់យកហើយ ដោយសំវដ្ត និង វិវដ្តសព្វទុំ:ឯង ។ ២ បទថា " **ឥមំ លោកំ** " គឺ កាន់កាមលោក ។ បទថា " **សំវដ្តមានេ សុទំ** " មានសេចក្តីថា កាលបើលោកវិនាស គឺត្រូវភ្លើងឆេះ បានដល់ វិនាសសាបសូន្យ ។ ឯពាក្យថា " **សុទំ** " គ្រាន់តែជានិបាត ។ បទថា " **លោកេ** " គឺ កាលបើកប្ប ។ បទថា " **អាកស្សរុបគោ** " គឺ គ្រូសុនេត្រ ចូលទៅកាន់ព្រហ្មលោក ជាន់អាកស្សរៈ ដោយអំណាច នៃការចាប់បដិសន្ធិ ក្នុងព្រហ្មលោក ជាន់អាកស្សរៈនោះ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងកប្បដែលវិនាសព្រោះភ្លើង ដោយពាក្យនោះ ។ បទថា " **វិវដ្តមានេ** " គឺ តាំងនៅ បានដល់ កើតមក ។ បទថា " **សុញ្ញំ** " គឺ ឈ្មោះថា ស្ងាត់សូន្យ ព្រោះមិនមានសត្វ ណាមួយកើត ក្នុងព្រហ្មលោកនោះ, អធិប្បាយថា " វិមានព្រហ្ម ពោលគឺភូមិនៃបឋមឈានឯណា កើតហើយខាងដើម, គ្រូសុនេត្រ រមែងកើតឡើង គឺចូលដល់វិមានព្រហ្មនោះ ដោយអំណាច នៃការចាប់បដិសន្ធិ" ។*

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

បានឮថា ក្នុងកាលនោះ ព្រះពោធិសត្វ សូម្បីជាអ្នកបាន
នូវសមាបត្តិ ៨ ជាប្រក្រតី យ៉ាងដូច្នោះក៏ដោយ ក៏នៅតែត្រួត
មើល នូវប្រយោជន៍សុខដើម្បីសត្វ និងការបំពេញបារមីរបស់ខ្លួន
ញុំាងសេចក្តីត្រេកអរ ឲ្យកើតឡើងហើយ ក្នុងភូមិ នៃឈានទាំង
២ យ៉ាងនោះឯង បានអន្ទោលទៅមក ដោយអំណាចនៃមេត្តា-
ព្រហ្មវិហារ ។ ក៏គ្រូសុនេត្រ មានសាវ័កជាច្រើនរយនាក់ ។ ពួក
សាវ័កទាំងអស់នោះ បានស្តាប់ទេសនា របស់ព្រះពោធិសត្វហើយ
ក៏ស្ថិតនៅ ក្នុងឱវាទនៃព្រះពោធិសត្វនោះហើយ ជាអ្នកមានសុគតិ
ជាទីប្រព្រឹត្តទៅ ព្ធជ៏ខាងមុខ ។ ក៏បណ្តាសាវ័កទាំងនោះ សាវ័ក
ពួកខ្លះ បានចូលទៅដល់ព្រហ្មលោក, សាវ័កពួកខ្លះ បានចូលទៅ
ដល់កាមាវចរសួគ៌ ៦ ជាន់, សាវ័កពួកខ្លះ បានចូលទៅដល់ភាព
ជាខត្តិយមហាសាល ព្រាហ្មណ៍មហាសាល និង គហបតីមហា-
សាល យ៉ាងដូច្នេះឯង ។

(រឿងពាណិជ ៧០០)

(៤៩) ក្នុងអតីតកាល ពួកពាណិជ ៧០០ នាក់ បានឆ្លង
សមុទ្រដោយសំពៅ ។ ក្នុងថ្ងៃទី ៧ សំពៅ ក៏បានលិចកណ្តាល
មហាសមុទ្រ ។ ទឹកបានសំផុលឡើងហើយ ។ ពួកពាណិជ ជួប
ប្រទះភ័យហើយ ក៏បានកំណត់យកឈ្មោះ នៃពួកទេវតា របស់

ខ្លួន ។ ហើយធ្វើកម្មផ្សេង ។ មានការសុំបួងសួងជាដើម ។

ក៏នៅកណ្តាលនៃពាណិជទាំងនោះ មានបុរសម្នាក់ រលឹកដល់ទាន ដែលខ្លួនបានប្រគេនហើយ ចំពោះព្រះកិក្ខុសង្ឃ និង សរណៈ និង សីល ដែលខ្លួនបានទទួលហើយ ក្នុងថ្ងៃដែលខ្លួនចុះសំពៅ បានអង្គុយ មិនតក់ស្លុតសោះឡើយ ។ ពួកពាណិជក្រៅពីនេះ ឃើញបុរសនោះ មិនកិតភ័យហើយ ទើបសួរនូវហេតុនៃការមិនកិតភ័យ ។ បុរសនោះ បានប្រាប់នូវហេតុនោះ ដល់ពួកពាណិជទាំងនោះ ។

ពួកពាណិជ. នែនាយ ! ក៏សីល រមែងសមគួរ ដល់ជនទាំងឡាយឯទៀត ដែរឬទេ ? ។

បុរស. មែនហើយ សីលរមែងសមគួរដល់ជនទាំងនោះ ។

ពួកពាណិជ. បើដូច្នោះ ចូរអ្នកឲ្យសីល ដល់ពួកយើងខ្ញុំទាំងឡាយផងចុះ ។

បុរសនោះ ក៏បានរៀបចំមនុស្សទាំងនោះ មួយពួក មួយរយ ។ ចែកចេញជា ៧ ពួក ហើយទើបបានឲ្យនូវសីល ៥ ។

បណ្តាមនុស្សទាំង ៧០០ នាក់នោះ មនុស្ស ១០០ នាក់ ទី ១ បានឈរនៅក្នុងទីកប្រមាណត្រឹមកជើង ហើយទទួលសីល, ទី ២ បានឈរនៅក្នុងទីកប្រមាណត្រឹមជង្គង់ ហើយទទួលសីល,

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

ទី ៣ បានឈរនៅ ក្នុងទីកប្រមាណត្រឹមចង្កេះ ហើយទទួលសីល,
ទី ៤ បានឈរនៅ ក្នុងទីកប្រមាណត្រឹមផ្ចឹតហើយទទួលនូវសីល,
ទី ៥ បានឈរនៅក្នុងទីកប្រមាណត្រឹមដោះហើយទទួលនូវសីល,
ទី ៦ បានឈរនៅក្នុងទីកប្រមាណត្រឹម-ក ហើយទទួលនូវសីល,
ទី៧ កាលបើទីកប្រែកំពុងហូរចូលក្នុងមាត់ បានឈរទទួលសីលៗ

បុរសនោះ បានឲ្យសីល ដល់ជនទាំងនោះហើយ ទើបប្រកាសថា " ទីពឹងជនៃរបស់អ្នកទាំងឡាយ មិនមានឡើយ, អ្នកទាំងឡាយ ចូររលឹកចំពោះសីលតែម៉្យាងបុណ្ណោះ " ដូច្នេះហើយ ក៏បានស្លាប់ទៅកើត ក្នុងកពតាវត្តិង្ស ។ ចំណែកឯ ពួកជនទាំង ៧០០ នាក់នោះ ក៏បានកើតហើយ ក្នុងកពតាវត្តិង្សនោះ ដូចគ្នាដែរ ព្រោះអាស្រ័យសីលដែលខ្លួនបានទទួលហើយ ក្នុងពេលទៀបនឹងស្លាប់ ។

ទេវបុត្រទាំងនោះ លោកហៅថា "**សតុល្លបកាយិកា** (អ្នកស្ថិតនៅ ក្នុងគណៈដែលលើកតម្កើងនូវសេចក្តីល្អ)" ព្រោះជាអ្នកលើតតម្កើងនូវធម៌ របស់ពួកសប្បុរស ដោយអំណាច នៃការសមាទានហើយ ទៅកើតក្នុងពួកទេវតា ក្នុងឋានសួគ៌ ។

វិមាន របស់ពួកទេវតាទាំងនោះ កើតឡើងហើយ ដោយអំណាចនៃការបៀតត្រសៀតគ្នា តែម្តង យ៉ាងដូច្នេះ គឺបណ្តាពួក

មង្គលត្ថទីបនីប្រែ

ទេវបុត្រទាំងនោះ វិមានមាស របស់ទេវបុត្រជាអាចារ្យ មានប្រវែងប្រមាណ ១០០ យោជន៍ កើតឡើងហើយ នៅកណ្តាលនៃវិមានទាំងពួង, វិមានទាំងឡាយ របស់ពួកទេវបុត្រ ដែលជាអន្តេវាសិក កើតឡើង លោមព័ទ្ធជុំវិញនូវវិមាន របស់ទេវបុត្រជាអាចារ្យនោះ, វិមានថ្នាក់ទាបជាងគេទាំងអស់ របស់ទេវបុត្រទាំងនោះ មានប្រវែងប្រមាណ ១២ យោជន៍ ។

ទេវបុត្រទាំងឡាយនោះ នឹករលឹកនូវកម្ម ក្នុងខណៈដែលខ្លួនកើតហើយនុ៎ះឯង ជឿនូវការបានសម្បត្តិ ព្រោះអាស្រ័យអាចារ្យ ហើយជាអ្នកមានបំណងចង់ពោលសរសើរគុណ របស់អាចារ្យ ក្នុងសំណាក់នៃព្រះសាស្តា ទើបនាំគ្នាមកកាន់វត្តជេតពន ក្នុងចន្លោះ នៃមជ្ឈិមយាម ថ្វាយបង្គំព្រះសាស្តា ទើបបានឈរនៅក្នុងទីដ៏សមគួរ ។ បណ្តាទេវបុត្រទាំងនោះ ទេវតា ៦ អង្គ ប្រាថ្នាចង់ពោលគាថា មួយអង្គ មួយគាថា ។ តាមលំដាប់ បានពោលគាថាទាំងឡាយ ៦ ធ្វើបាទ ទី ៤ ឲ្យខុសផ្សេងពីគ្នា និង ៣ បាទក្រៅអំពីនេះ ឲ្យដូចគ្នា តែមួយ ថា ៖

(១) បុគ្គលគប្បីគប់រកនឹងពួកសប្បុរសតែម្យ៉ាង [1] គប្បីធ្វើនូវការស្និទ្ធស្នាលនឹងពួកសប្បុរស, ព្រោះដឹងព្រះសទ្ធម្ម របស់

១- សុត្តន្តបិដក ភាគទី ៦១ ទំព័រទី ២០២ ។

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

ពួកសប្បុរស គុណធម៌ដ៏ប្រសើរ រមែងកើតមាន មិនមែនជាទោសដ៏លាមកទេ ។

(២) បុគ្គល គប្បីគប់រកនឹងពួកសប្បុរសតែម្យ៉ាង, គប្បីធ្វើនូវការស្និទ្ធស្នាលនឹងពួកសប្បុរស, ព្រោះដឹងនូវព្រះសទ្ធម្ម របស់ពួកសប្បុរស បុគ្គល តែងបាននូវបញ្ញា, នឹងបានអំពីបុគ្គលដទៃ មិនបានឡើយ ។

(៣) បុគ្គលគប្បីគប់រកនឹងពួកសប្បុរស តែម្យ៉ាង, គប្បីធ្វើនូវការស្និទ្ធស្នាលនឹងពួកសប្បុរស, ព្រោះដឹងនូវព្រះសទ្ធម្ម របស់ពួកសប្បុរស, បុគ្គល រមែងមិនសោកសៅ ក្នុងកណ្តាលនៃបុគ្គលអ្នកសៅសោក ។

(៤) បុគ្គលគប្បីគប់រកនឹងពួកសប្បុរស តែម្យ៉ាង, គប្បីធ្វើនូវការស្និទ្ធស្នាលនឹងពួកសប្បុរស, ព្រោះដឹងនូវព្រះសទ្ធម្ម របស់ពួកសប្បុរស បុគ្គល រមែងរុងរឿង ក្នុងកណ្តាល នៃញាតិ ។

(៥) បុគ្គលគប្បីគប់រកនឹងពួកសប្បុរស តែម្យ៉ាង, គប្បីធ្វើនូវការស្និទ្ធស្នាលនឹងពួកសប្បុរស, ព្រោះដឹងនូវព្រះសទ្ធម្ម របស់ពួកសប្បុរស សត្វទាំងឡាយ រមែងទៅកាន់សុគតិ ។

(៦) បុគ្គលគប្បីគប់រកនឹងពួកសប្បុរស តែម្យ៉ាង, គប្បីធ្វើ

មង្គលត្ថទីបនីប្រែ

ឆ្លៀវការស្និទ្ធស្នាលនឹងពួកសប្បុរស, ព្រោះដឹងឆ្លៀវព្រះសទ្ធម្ម របស់ពួកសប្បុរស សត្វទាំងឡាយ រមែងស្ថិតនៅ អស់កាលដ៏យូរអង្វែង ។

គ្រានោះ ទេវតា ដទៃទៀត ក្រាបទូលសួរថា " បពិត្រព្រះដ៏មានព្រះភាគ ពាក្យរបស់អ្នកណាទៅ ជាសុភាសិត ? " ។

ព្រះសាស្តា ទ្រង់ត្រាស់ថា " ពាក្យ របស់អ្នកទាំងអស់គ្នា ជាសុភាសិត ដោយបរិយាយ, ចូរអ្នកទាំងឡាយ ស្តាប់នូវពាក្យរបស់តថាគតខ្ញុះផង " ដូច្នេះហើយ ទើបទ្រង់ត្រាស់គាថានេះ ថា៖

បុគ្គល គប្បីសេពគប់នឹងពួកសប្បុរស តែម៉្យាង, គប្បីធ្វើឆ្លៀវការស្និទ្ធស្នាលនឹងពួកសប្បុរស, ព្រោះដឹងឆ្លៀវព្រះសទ្ធម្ម របស់ពួកសប្បុរស បុគ្គល រមែងបានរួចផុត ចាកសេចក្តីទុក្ខទាំងពួង ។

*(៥០) បណ្តាបទទាំងនោះ បទថា " **សព្ភិរេវ** " ប្រែថា ជាមួយនឹងបណ្ឌិតទាំងឡាយ គឺជាមួយនឹងពួកសប្បុរស តែម៉្យាង ។ អក្សរ រ ធ្វើនូវការតបទ ។ បទថា " **សមាសេថ** " ប្រែថា គប្បីអង្គុយរួមជាមួយ ។ ក៏ពាក្យនុ៎ះ ជាប្រធានដើមបទ នៃទេសនាតែប៉ុណ្ណោះ ។ សេចក្តីថា " បុគ្គល គប្បីសម្រេចឥរិយាបថទាំងពួង ជាមួយនឹងសប្បុរសទាំងឡាយ តែប៉ុណ្ណោះ " ។*

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

*បទថា "**កុព្ភេថ**" ប្រែថា គប្បីធ្វើ ។ បទថា "**សន្ថវំ**" បានដល់ នូវការស្និទ្ធស្នាល ដូចជាមិត្រសំឡាញ់ ។ មែនពិត ការស្និទ្ធស្នាលដោយភាពជាមិត្រសំឡាញ់ បុគ្គលគប្បីធ្វើ ជាមួយនឹងព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និង ព្រះសាវ័ករបស់ព្រះពុទ្ធ, ចំណែក ការស្និទ្ធស្នាលដោយអំណាចតណ្ហា បុគ្គលមិនត្រូវធ្វើជាមួយនឹង អ្នកណាមួយឡើយ ។ បទថា "**សតំ**" គឺ របស់សប្បុរសទាំងឡាយ មានព្រះពុទ្ធជាដើម ។ បទថា "**សទ្ធម្មំ**" បានដល់ ព្រះសទ្ធម្មដែលផ្សែងដោយសីល ៥ សីល ១០ និង សតិបដ្ឋាន ៤ ជាដើម ។ ប៉ុន្តែ ក្នុងទីនេះ ទេវបុត្រទាំងឡាយ សំដៅយកសីល ៥ ។ បទថា "**អញ្ញាយ**" បានដល់ ព្រោះដឹង គឺព្រោះហេតុ នៃការដឹង ។ បទថា "**សេយ្យោ**" គឺ សេចក្តីចំរើន ។ បទថា "**ន បាបិយោ**" មានសេចក្តីថា សេចក្តីលាមក រមែងមិនមានបន្តិចសោះឡើយ ។*

*(៥១) គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថា ទី ២ (ដូចតទៅនេះ) ៖ បទថា "**នាញ្ញតោ**" មានសេចក្តីថា រមែងមិនបាននូវបញ្ញា អំពីបុគ្គលដទៃ គឺអំពីបុគ្គលអន្ធពាល ។ ពិតមែនដូច្នោះ ធម្មតា បញ្ញា គឺបុគ្គលណាមួយ រមែងមិនបាន អំពីបុគ្គលអន្ធពាលឡើយ ដូចជាបុគ្គលមិនបាននូវវត្ថុមានប្រែងជាដើម អំពីវត្ថុទាំងឡាយ មាន*

មង្គលត្ថទីបនីប្រែ

ជីវ្យាច់ជាអាទិ៍បានឡើយដូច្នោះ, បុគ្គលដឹងនូវធម៌របស់សប្បុរសទាំងឡាយ សេពគប់នឹងបណ្ឌិតតែប៉ុណ្ណោះ រមែងបាន ប្រៀបដូចជាបុគ្គលបានវត្ថុទាំងឡាយ មានប្រេងជាដើម អំពីវត្ថុមានល្ងជាដើម យ៉ាងដូច្នោះឯង ។

(៥២) គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថា ទី ៣ (ដូចតទៅនេះ) បទថា " ***សោកមជ្ឈេ*** " មានសេចក្តីថា នៅក្នុងកណ្តាល នៃសត្វទាំងឡាយដែលជាទីតាំងនៃសេចក្តីសោក ឬ ជាអ្នកដែលទៅតាមនូវសេចក្តីសោក រមែងមិនសៅសោក ប្រៀបដូចជាឧបាសិកា របស់ពន្ធុលសេនាបតី និង ប្រៀបដូចជាសង្កិច្ចសាមណេរ ក្នុងកណ្តាលនៃពួកចោរ ៥០០ នាក់ ដូច្នោះឯង ។

(រឿងព្រះនាងមល្លិកា)

បានឮមកថា ក្នុងទីក្រុងកុសិនារា មានព្រះរាជបុត្រ របស់ព្រះបាទមល្លរាជ ព្រះនាមពន្ធុលៈ ទ្រង់បានសិក្សាសិល្បសាស្ត្រក្នុងសំណាក់នៃអាចារ្យតែមួយ ជាមួយគ្នានឹងព្រះបាទបសេនទិ ។ ពន្ធុលសេនាបតីនោះ នាំព្រះនាងទេវីព្រះនាមមល្លិកា ស្តេចយោងទៅកាន់ក្រុងសាវត្ថី ចាកទីក្រុងកុសិនារា ទ្រង់បានជាសេនាបតី របស់ព្រះបាទបសេនទិ ។ ព្រះនាងមល្លិកា អាស្រ័យពន្ធុលសេនាបតីនោះ បានប្រសូត្រ នូវព្រះរាជបុត្រទាំងឡាយក្លោះ ដល់ទៅ

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

១៦ ជង ។ ព្រះរាជបុត្រ ទាំងអស់អង្គនោះ ជាអ្នកអង់អាច ក្លា ហាន បរិបូណ៌ដោយកម្លាំងខ្លាំងក្លា ទ្រង់បានសម្រេចនូវសិល្ប-សាស្ត្រ គ្រប់បែបយ៉ាង ។ បណ្តាព្រះរាជបុត្រទាំងនោះ ព្រះ រាជបុត្រមួយអង្គ ។ ទ្រង់មានបុរសមួយពាន់នាក់ ជាបរិវារ ។

ក្រោយមក ថ្ងៃមួយ ពួកមនុស្សទាំងឡាយ អ្នកដែលបាន បរាជ័យ ព្រោះក្តីកោង បានឃើញពន្ធុលសេនាបតី យាងមក ហើយ ទើបបានក្រាបទូលនូវហេតុ នៃការកាត់សេចក្តីមិនយុត្តិធម៌ របស់ពួកអាមាត្យអ្នកវិនិច្ឆ័យ ដល់ពន្ធុលសេនាបតីនោះ ។ ពន្ធុល សេនាបតីនោះ ស្តេចយាងទៅកាន់ទីវិនិច្ឆ័យ ហើយពិចារណានូវ សេចក្តីនោះ ទ្រង់បានធ្វើអ្នកម្ចាស់ទុំៈឯង ឲ្យទៅជាម្ចាស់ (ដូច ដើមវិញ) ។ មហាជន បានថ្វាយសាធុការពរហើយ ។ ព្រះរាជា ទ្រង់បានព្រះសណ្តាប់នូវសំឡេងនោះហើយ ទើបទ្រង់ត្រាស់សួរ ទ្រង់ជ្រាបសេចក្តីនោះហើយ ទ្រង់ត្រាស់បញ្ជា ឲ្យបណ្តេញនូវពួក អាមាត្យ អ្នកវិនិច្ឆ័យចេញហើយ ទ្រង់ព្រះរាជាទានការវិនិច្ឆ័យ ដល់ពន្ធុលសេនាបតីទុំៈឯង ។ តាំងពីនោះមក ពន្ធុលសេនាបតី នោះ ក៏កាត់សេចក្តីដោយត្រឹមត្រូវ ។

ក្នុងពេលនោះ ពួកអាមាត្យ អ្នកដែលកាត់សេចក្តីជំនាន់ ចាស់ កាលមិនបានការស៊ីសំណូក ជាអ្នកមានលាភតិច ទើបនាំ

គ្នា ក្រាបទូលចាក់ដោតដល់ព្រះរាជាថា “ពន្ធុលសេនាបតី ប្រាថ្នាចង់បាន នូវរាជសម្បត្តិ ” ។ ព្រះរាជា ទ្រង់បានជឿពាក្យរបស់ពួកអាមាត្យទាំងនោះហើយ ទ្រង់ត្រាស់បញ្ជាពួកបុរស ដែលព្រះអង្គទ្រង់ប្រកបហើយ ឲ្យប្លន់ស្រុកជាយដែនហើយ ទ្រង់បញ្ជូនពន្ធុលសេនាបតី ទៅ ដោយព្រះឱង្ការថា “ បានឮថា បច្ចន្តជនបទ កើតចលាចហើយ, ចូរអ្នកទៅ ជាមួយនឹងកូនទាំងឡាយ របស់អ្នកហើយ ចាប់ពួកចោរឲ្យបាន ” ដូច្នេះហើយ ទើបទ្រង់បានបញ្ជូនពួកទាហានធំ ៗ ដែលមានសមត្ថភាពផ្សេងទៀតទៅ ដោយព្រះរាជឱង្ការថា “អ្នកទាំងឡាយ ចូរកាត់ក្បាលរបស់ពន្ធុលសេនាបតី ព្រមទាំងកូនទាំងឡាយ ៣២ នាក់ ក្នុងទីនោះតែម្តង ” ។ ពួកនាយទាហានធំ ៗ ទាំងនោះ បានធ្វើហើយ យ៉ាងដូច្នោះ ។

ក្នុងថ្ងៃនោះ ព្រះនាងមល្លិកា បាននិមន្តព្រះអគ្គសាវ័កទាំង ២ ព្រះអង្គ មួយអន្ទើដោយកិកុសង្ឃ ៥០០ អង្គ ។ ក្នុងខណៈនោះ មនុស្សទាំងឡាយ បានបញ្ជូនព្រះចុតហ្មាយ ទៅថ្វាយព្រះនាងមល្លិកា ក្នុងវេលាព្រឹក មានសេចក្តីថា “ ទាហានទាំងឡាយកាត់ព្រះសិរសីរបស់ព្រះស្វាមី របស់ព្រះអង្គ ព្រមទាំងព្រះរាជ-បុត្រទាំងឡាយ ” ។ ព្រះនាងមល្លិកានោះ ទ្រង់ជ្រាបហេតុនោះហើយ មិនទ្រង់មានព្រះបន្ទូលអ្វី ៗ ដល់អ្នកណាមួយឡើយ ទ្រង់

សៀតនូវចុតហ្មាយក្នុងថ្នក់ ហើយទ្រង់អង្គាសកិក្ខុសង្ឃរឿយៗ ។

គ្រានោះ នាងបវិចារិកា របស់ព្រះនាងមល្លិកានោះ កាលនាំភាជន:នៃទឹកដោះថ្លាមក ក៏បានធ្វើភាជន:បែក នៅខាងមុខនៃព្រះថេរៈទាំងឡាយ ។ ព្រះធម្មសេនាបតី ពោលថា " របស់របរមានការបែកធ្លាយជាធម្មតា បែកទៅហើយ, ព្រះនាង មិនគួរគិតដល់ឡើយ " ។ ព្រះនាងមល្លិកានោះ ទ្រង់បាននាំយកចុតហ្មាយចេញមក អំពីថ្នក់ហើយ ទ្រង់មានព្រះបន្ទូល ថា " ខ្ញុំព្រះករុណាសូម្បីបានស្តាប់រឿងនោះហើយ ក៏មិនបានគិតឡើយ, បពិត្រព្រះគុណម្ចាស់ដ៏ចំរើន កាលបើភាជន:នៃទឹកដោះថ្លា បែកហើយ, ខ្ញុំព្រះករុណា នឹងគិតដល់យ៉ាងដូចម្តេចទៅ" ។ ព្រះថេរៈបានសំដែងធម៌ដល់ព្រះនាងហើយ ទើបបាននិមន្តទៅវត្តហើយ ។ ព្រះនាងមល្លិកានោះ ទ្រង់ត្រាស់ឲ្យហៅព្រះសុណិសាទាំង ៣២ មកហើយ ត្រាស់ប្រទានឱវាទ ថា " ស្វាមីទាំងឡាយ របស់អ្នកទាំងឡាយ ជាអ្នកមិនមានកំហុស បានទទួលនូវផលកម្ម ពីបុព្វជាតិរបស់ខ្លួនហើយ, អ្នកទាំងឡាយ ចូរកុំសោកសៅឡើយ និង ចូរកុំធ្វើសេចក្តីក្រោធខឹងចំពោះព្រះរាជាឡើយ " ដូច្នេះហើយ ទ្រង់មិនសោកសៅ ក្នុងកណ្តាល នៃព្រះនាងសុណិសា ដែលបានដល់នូវការសោកសៅទាំងនោះ ។

មង្គលត្ថទីបនីប្រែ

(រឿងសង្កិច្ចសាមណេរ)

នយនេះ លោកបានពោលហើយ ក្នុងអដ្ឋកថាកទូសាល-ជាតក ជាដើម ។

(៥៣) ចំណែក សង្កិច្ចសាមណេរ ជាកូនប្រុស របស់ព្រាហ្មណ៍មហាសាល ក្នុងទីក្រុងសាវត្ថី ក្នុងពេលដែលមានអាយុ ៧ ឆ្នាំ ក៏បានបួស ក្នុងសំណាក់នៃព្រះសារីបុត្រត្ថេរ ហើយបានសម្រេចនូវព្រះអរហត្ត ព្រមទាំងបដិសម្ភិទាទាំងឡាយ ក្នុងពេលដែលកំពុងកោរសក់រួចនុ៎ះឯង ។ សាមណេរនោះ ក្នុងពេលនៅជាសាមណេរ កាលរស់នៅក្នុងព្រៃ ជាមួយភិក្ខុទាំងឡាយ ៣០ រូប ត្រូវពួកចោរ ៥០០ ចាប់ឃាំងទុក ក្នុងទីដ៏សមគួរមួយ ដោយប្រឹក្សាគ្នា ថា " ពួកយើង នឹងសម្លាប់សាមណេររូបនេះហើយ ធ្វើពលីកម្ម ដល់ទេវតា " ដូច្នេះ ក៏គង់ចូលឈាន ក្នុងទីនោះឯង ។ មេចោរ បានបញ្ជាឲ្យកូនចៅធ្វើកិច្ច មានការដុតភ្លើងជាដើមហើយ យកជាវមកកាប់ក របស់សាមណេរ ។ ជាវបានរមូរបត់មកប៉ះមុខនឹងមុខគ្នា ។ មេចោរ បានពត់ជាវនោះឲ្យត្រង់ហើយ ក៏កាប់ជាថ្មីម្តងទៀត ។ ជាវបានរមូរកោង មកដល់គល់នៃដង ប្រៀបដូចជាស្លឹកគ្នោត ។ ពួកចោរទាំងអស់នោះ ឃើញហេតុអស្ចារ្យនោះ និង បានស្តាប់ នូវព្រះធម៌ទេសនា របស់សង្កិច្ចសាមណេរ

នោះហើយ ក៏ជ្រះថ្លា បានបួសក្នុងសំណាក់សង្ឃិច្ចសាមណេរនោះ ហើយ ទើបបាននិមន្តទៅកាន់វត្តជេតពន ជាមួយនឹងសាមណេរ នោះ ហើយបានស្តាប់ព្រះធម៌ទេសនា របស់ព្រះសាស្តា ក៏បាន សម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទាទាំងឡាយ ។

នយនេះលោកបានពោលហើយ ក្នុងអដ្ឋកថាធម្មបទជាដើម ។

(៥៤) គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថា ទី ៤ (ដូចតទៅ) ៖ បទថា " **ញាតិមជ្ឈេ វិរោចតិ** " មានសេចក្តីថា រមែងល្អប្រសើរ ក្នុងកណ្តាលនៃពួកញាតិ ដូចជាអធិមុត្តកសាមណេរ ដូច្នោះឯង ។

(រឿងអធិមុត្តកសាមណេរ)

បានឮមកថា អធិមុត្តកសាមណេរនោះ ត្រូវជាក្មួយ របស់ ព្រះសង្ឃិច្ចត្ថេរ ។ អធិមុត្តកសាមណេរនោះ ត្រូវបានព្រះថេរៈ បញ្ជូនទៅ ដោយពាក្យថា " ចូរអ្នកនិមន្តទៅចុះ, ចូរអ្នកសួរអាយុ ហើយ ត្រឡប់មកវិញ, ខ្ញុំ នឹងឲ្យអ្នកឧបសម្បទ " ដូច្នេះហើយ ទើបចាប់បាត្រនិងចីពរ និមន្តទៅកាន់ផ្ទះ របស់បងស្រី ធ្វើកត្តកិច្ច ក្នុងផ្ទះនោះស្រេចហើយ ទើបបានសួរនូវអាយុ ។ បងស្រី របស់ សាមណេរនោះ ពោលថា " នាងខ្ញុំ មិនដឹងទេ, មាតា របស់យើង នឹងដឹង " ។ អធិមុត្តកសាមណេរនោះ ពោលថា " សូមអ្នកនៅ សិនចុះ, អាត្មា នឹងទៅកាន់សំណាក់នៃមាតា " ហើយ ទើបបាន

មង្គលត្ថទីបនីប្រែ

ចូលទៅកាន់ព្រៃនៃចោរ ។ ពួកចោរ ចាប់សាមណេរនោះហើយ, ពួកខ្លះ បានពោលថា " យើងនឹងសម្លាប់សាមណេរនេះ " ។ ពួកខ្លះ ពោលថា "ពួកយើងនឹងលែងសាមណេរនេះ" ។ សាមណេរ គិតថា " អាត្មាអញ ជាសេក្ខបុគ្គល ជាអ្នកមានកិច្ចដែលត្រូវធ្វើ, អញនឹងចរចាជាមួយនឹងពួកចោរទាំងនេះ ហើយនឹងធ្វើខ្លួនឲ្យមានសិរីសួស្តី " ហើយពោលថា " បើអ្នកទាំងឡាយ សម្លាប់អាត្មាចោល, បើយ៉ាងដូច្នោះ ពួកអ្នកដើរផ្លូវដ៏ឆ្ងាយនោះហើយក៏នឹងមិនមក, ការសាបសូន្យចាកទ្រព្យ ក៏នឹងមាន ដល់អ្នកទាំងឡាយ " ។ ចោរទាំងឡាយនោះ គិតថា " សាមណេរនេះ និយាយត្រឹមត្រូវ " ដូច្នេះហើយ ក៏ពោលថា "បើអ្នកបានឃើញនូវមនុស្ស ឯទៀត ៗ ដែលដើរផ្លូវជួបគ្នា នឹងមិនប្រាប់ទេណា, ចូរលោកនិមន្តទៅចុះ " ដូច្នេះហើយ, កាលបើសាមណេរនោះទទួលព្រមថា " ចំរើនពរ " ដូច្នេះហើយ, ទើបលែងសាមណេរនោះទៅហើយ ។ សាមណេរ ត្រូវពួកចោរទាំងនោះស្រាយលែងហើយ កាលនិមន្តទៅសូម្បីបានជួបនូវញាតិទាំងឡាយ មានមាតានិងបិតាជាដើមហើយ ក៏មិនបានប្រាប់ ដល់ញាតិទាំងឡាយ មានមាតាបិតាជាដើមនោះដែរ ។ ពួកចោរទាំងឡាយ ចាប់ពួកមនុស្សទាំងនោះ ដែលដើរមកដល់ តាមក្រោយបានហើយ ក៏បានធ្វើបាបបៀតបៀន ។

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

លំដាប់នោះ ចំណែក មាតា របស់សាមណេរ កាលខ្សឹកខ្សួល ត្រូវពួកចោរសួរហើយ ទើបបានប្រាប់ថា " នាងខ្ញុំជាមាតា របស់អធិមុត្តកសាមណេរ, អ្នកនេះ ជាបិតា, អ្នកទាំងឡាយនេះ ជាបងប្រុសអ្នកប្រុស " ។ ពួកចោរ គិតថា " សមណៈរូបនេះ ជាអ្នកពោលពាក្យសច្ចទៀងត្រង់ " ហើយ ក៏បានជ្រះថ្លា ដោះលែងញាតិទាំងឡាយ របស់សាមណេរនោះទៅ ហើយក៏បានបួស នៅក្នុងសំណាក់ របស់សាមណេរនោះឯង ។ អធិមុត្តកសាមណេរនោះ បាននាំយកសាមណេរទាំងនោះ ទៅកាន់សំណាក់ នៃព្រះសង្ឃិច្ចត្ថេរហើយ ក៏បានឧបសម្បទ ធ្វើឲ្យជាអន្តេវាសិក របស់ខ្លួន ។ កិក្ខុទាំងនោះ ស្ថិតនៅក្នុងឱវាទ របស់ព្រះអធិមុត្តកត្ថេរហើយ ក៏បានសម្រេចនូវព្រះអរហត្ត ។

*(៥៥) គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថា ទី៦ (ដូចតទៅនេះ) បទថា " **សាតតំ** " មានសេចក្តីថា ស្ថិតនៅជាសុខ អស់កាលជានិច្ច ឬ ស្ថិតនៅជាសុខ អស់កាលដ៏ឃ្លេវអង្វែង ។*

*បទថា " **វោ** " ប្រែថា របស់អ្នកទាំងឡាយ ។ បទថា " **បរិយោយេន** " គឺ ដោយហេតុ ។ បទថា " **សព្ពទុក្ខា** " មានសេចក្តីថា និងមានគុណ ដ៏ប្រសើរ តែម៉្យាងក៏ទេ, មួយទៀត បុគ្គលរមែងបាននូវបញ្ញា តែម៉្យាងក៏ទេដែរ, រមែងមិនសោកសៅ*

មង្គលត្ថទីបនីប្រែ

ក្នុងកណ្តាលនៃសត្វដែលសោកសៅ, រមែងរុងរឿង ក្នុងកណ្តាលនៃញាតិ, តែងទៅកើត ក្នុងសុគតិភព ឬ រមែងស្ថិតនៅជាសុខអស់កាលជ័យូរអង្វែង, តាមពិតហើយ រមែងរួចផុតចាកសេចក្តីទុក្ខ ក្នុងវដ្តសំសារទាំងអស់បានមែនពិត ដូច្នោះឯង ។

រឿង សមុទ្ទពាណិជ មកក្នុងអដ្ឋកថាទេវតាសំយុត្ត ។

បណ្ឌិតទាំងឡាយ រមែងមិនញុាំងខ្លួន និងពួកជនអ្នកដែលធ្វើតាមពាក្យរបស់ខ្លួន ឲ្យវិនាស ដោយប្រការដូច្នេះឯង ។

(៥៦) បុគ្គលណាមិនសេពគប់នូវពួកបុគ្គលពាល, បុគ្គលនោះ ឈ្មោះថា សេពគប់នូវពួកបណ្ឌិត, បុគ្គលណា សេពគប់នូវពួកបណ្ឌិត, បុគ្គលនោះ ឈ្មោះថាមិនសេពគប់នូវពួកបុគ្គលពាល ព្រោះហេតុណា, ព្រោះហេតុនោះ ពាក្យទាំង ២ យ៉ាងនោះ ដោយសេចក្តី ក៏ជាពាក្យជាមួយគ្នាទុំៈឯង, ជាពាក្យជាមួយគ្នា ក៏ពិតមែនហើយ, ទោះជាដូច្នោះក៏ដោយ បណ្តាពាក្យទាំង ២ យ៉ាងនោះ ពាក្យនេះថា " ការមិនសេព នូវជនពាលទាំងឡាយ ១ " ដូច្នេះ សូម្បីក្នុងគាថា ទី១ នេះ គប្បីជ្រាបថា " ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកហើយ ដើម្បីឲ្យដឹងច្បាស់សូម្បីនូវសេចក្តីដែលផ្ទុយអំពីគ្នានេះ ថា ការសេពគប់ នូវបុគ្គលពាលទាំងឡាយ មិនមែនជាមង្គល ដូច្នេះ, ពាក្យនេះថា "ការសេពគប់ នូវបុគ្គលជាបណ្ឌិត

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

ទាំងឡាយ ១ " ដូច្នេះ គប្បីជ្រាបថា " ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ដើម្បីឲ្យដឹងច្បាស់ សូម្បីនូវសេចក្តីដែលផុយអំពីគ្នានេះថា ការមិនសេពគប់នូវបុគ្គលជាបណ្ឌិតទាំងឡាយ មិនមែនជាមង្គល ដូច្នេះ ប្រៀបដូចជាបុរសដែលធ្លាតក្នុងផ្លូវ កាលបង្ហាញប្រាប់នូវផ្លូវ បានបង្ហាញប្រាប់នូវផ្លូវ ដែលមិនគួរកាន់យកជាមុនសិនហើយ ទើបបង្ហាញប្រាប់នូវផ្លូវដែលគួរកាន់យក ជាខាងក្រោយ យ៉ាងដូច្នេះថា " ចូរអ្នកលះបង់ចោលនូវផ្លូវខាងឆ្វេង, ចូរកាន់យក នូវផ្លូវខាងស្តាំ " ដូច្នេះ, បុគ្គលណា លះបង់នូវផ្លូវខាងឆ្វេង, បុគ្គលនោះ ឈ្មោះថា កាន់យកនូវផ្លូវខាងស្តាំ, បុគ្គលណាកាន់យកនូវផ្លូវខាងស្តាំ, បុគ្គលនោះ ឈ្មោះថា លះបង់ចោលនូវផ្លូវខាងឆ្វេង ព្រោះហេតុណា, ព្រោះហេតុនោះ សូម្បីពាក្យទាំង ២ យ៉ាងនោះ ដោយសេចក្តី គឺពាក្យតែមួយនុ៎ះឯង, ជាពាក្យតែមួយ ក៏ពិតមែនហើយ, ទោះបីជាយ៉ាងដូច្នេះដ៏ដោយ បណ្តាពាក្យទាំង ២ យ៉ាងនោះ ពាក្យនេះថា " ចូរអ្នកលះបង់ចោលនូវផ្លូវខាងឆ្វេង " ដូច្នេះ គប្បីជ្រាបថា " បុរសនោះ ពោលហើយដើម្បីឲ្យដឹងជាក់ច្បាស់ សូម្បីនូវសេចក្តីដែលផុយគ្នានេះ ថា ចូរអ្នកកុំលះបង់ចោល នូវផ្លូវខាងស្តាំ យ៉ាងដូច្នេះ, ពាក្យនេះថា ចូរអ្នកកាន់យក នូវផ្លូវខាងស្តាំ ដូច្នេះ គប្បីជ្រាប ថា " បុរសនោះ

មង្គលត្ថទីបនីប្រែ

ពោលហើយ ដើម្បីឲ្យដឹងជាក់ច្បាស់ សូម្បីនូវសេចក្តីដែលផ្ទុយគ្នានេះ ថា ចូរអ្នកកុំកាន់យក នូវផ្លូវខាងឆ្វេងឡើយ យ៉ាងដូច្នោះឯង, ក៏ព្រោះធ្វើអធិប្បាយយ៉ាងដូច្នេះ ទើបព្រះមានព្រះភាគ មិនទ្រង់ត្រាស់នូវការសេពគប់ នូវបណ្ឌិតទុកជាមុន (តែ) ទ្រង់ត្រាស់ការមិនសេពគប់នូវបុគ្គលពាលទុកជាមុន ។ ក៏ប្រសិនបើព្រះអង្គគប្បីត្រាស់នូវការសេពគប់នូវបណ្ឌិតទុកជាមុន, សេចក្តីនៃពាល-សព្ទ គឺវិនេយ្យសត្វក៏រមែងមិនយល់ជាក់ច្បាស់បានឡើយ ព្រោះទ្រង់ត្រាស់នូវបណ្ឌិត ជាមុន, កាលបើអត្ថនៃពាលសព្ទនោះ គឺវិនេយ្យសត្វ មិនបានដឹងជាក់ច្បាស់ហើយ, ចំណែកឯ ការសេពគប់នូវបុគ្គលពាល ក៏វិនេយ្យសត្វ រមែងមិនដឹងជាក់ច្បាស់ ដូចគ្នាផងដែរ ។ ក៏ព្រោះព្រះមានព្រះភាគ ទ្រង់ប្រាថ្នាដើម្បីឲ្យវិនេយ្យ-សត្វ បានដឹងច្បាស់ នូវការសេពគប់នូវបុគ្គលពាលជាមុន ដូច្នោះ ទើបព្រះអង្គ ទ្រង់ត្រាស់ការមិនសេពគប់ នូវបុគ្គលពាលនុ៎ះឯងទុកជាមុន ។ មែនពិត ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា " ការមិនសេពគប់នូវបុគ្គលពាលទាំងឡាយ ១ " ដូច្នេះ ចំណែកការសេពគប់បុគ្គលពាល ក៏ឈ្មោះថា រមែងឲ្យវិនេយ្យសត្វដឹងជាក់ច្បាស់ផងដែរ ។ ព្រោះព្រះមានព្រះភាគ ប្រៀបដូចជាបុរសដែលឆ្ងាតក្នុងផ្លូវ, ហេតុដូច្នោះ ព្រះអង្គ ទ្រង់ញុំាងឲ្យវិនេយ្យសត្វដឹងច្បាស់

ពណ៌នាការសេព និង មិនសេពពាលនិងបណ្ឌិត

នូវការសេពគប់នូវបុគ្គលពាល ពោលគឺការមិនសេពគប់បណ្ឌិត ដែលមិនគួរកាន់យក ប្រៀបដូចជាផ្លូវខាងធ្វេង ជាមុនហើយ ទើបទ្រង់ញុំាងឲ្យវិនេយ្យសត្វ បានដឹងច្បាស់នូវការមិនសេពនូវបុគ្គលពាល ពោលគឺការសេពគប់នូវបណ្ឌិត ដែលគួរកាន់យក ប្រៀបដូចជាផ្លូវខាងស្តាំ ឮជាខាងក្រោយ ។

(សេពគប់ជនពាលមិនមែនជាមង្គល)

(៥៧) មែនពិត សូម្បីការសេពគប់រក នូវបុគ្គលពាល ក៏ឈ្មោះថា មិនមែនជាមង្គល ព្រោះជាហេតុនៃសេចក្តីវិនាស, ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ៖

បុគ្គលមានពួកអសប្បុរស ជាទីស្រឡាញ់ បុគ្គលនោះ រមែងមិនធ្វើសេចក្តីស្រឡាញ់ បំពេះពួកសប្បុរសទេ, គេតែងស្រឡាញ់ពេញចិត្ត បំពេះតែធម៌របស់ពួកអសប្បុរស, កម្មទាំង ៣ យ៉ាងនោះ ជាប្រធាននៃបុគ្គលអ្នកដែលវិនាស ។

*បណ្តាបទទាំងនោះ បទថា “ **អសន្តស្ស** ” មានសេចក្តីថា ពួកអសប្បុរស គឺមនុស្សមិនល្អទាំងឡាយ មានគ្រូទាំង ៦ នាក់ ជាដើម រមែងជាទីស្រឡាញ់ របស់បុគ្គលនោះ ។*

*បាទគាថា ថា “ **សន្តេ ន កុរុតេ បិយំ** ” មានសេចក្តីថា បុគ្គលនោះ រមែងមិនធ្វើ នូវសប្បុរសទាំងឡាយ មានព្រះពុទ្ធ ជា*

មង្គលត្ថទីបនីប្រែ

ដើម ឲ្យជាទីស្រឡាញ់ របស់ខ្លួនឡើយ ។

ក៏ក្នុងបាទគាថានេះ ព្រះមានព្រះភាគទ្រង់ធ្វើការខុសផ្សេងគ្នានៃវចនៈ ថា " ***សន្តេ បិយំ*** " ដោយអំណាចវោនេយ្យសត្វ ។

ទិដ្ឋិ ៦២ និង អកុសលកម្មបថ ១០ ឈ្មោះថា ធម៌របស់អសប្បុរស, បុគ្គលនោះ រមែងចូលចិត្ត គឺស្រឡាញ់ បានដល់សេពគប់នូវធម៌ របស់អសប្បុរសនោះ ។

បទថា " ***តំ*** " សេចក្តីថា កម្ម ៣ យ៉ាង គឺ ភាពជាអ្នកមានអសប្បុរសជាទីស្រឡាញ់ ១ ភាពជាអ្នកមានសប្បុរសមិនជាទីស្រឡាញ់ពេញចិត្ត១ ការស្រឡាញ់ពេញចិត្តធម៌របស់អសប្បុរស ១ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ជាប្រធាន របស់បុគ្គលអ្នកវិនាស គឺជាហេតុនៃសេចក្តីវិនាស របស់បុគ្គល អ្នកវិនាស គឺអ្នកដែលកំពុងតែវិនាស, មែនពិត បុគ្គលដែលប្រកបព្រមដោយកម្មទាំង ៣ ប្រការនោះ រមែងវិនាស គឺរមែងសាបសូន្យ បានដល់រមែងមិនបានសម្រេចនូវសេចក្តីចំរើន ទាំងក្នុងលោកនេះ ទាំងក្នុងលោកខាងមុខ ដោយពិតប្រាកដ, ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ថា " ជាប្រធាន នៃបុគ្គលអ្នកវិនាស " ដូច្នេះឯង ។

ពណ៌នាអំពីការសេព និង មិនសេពពាលនិងបណ្ឌិត ចប់ ។

ប្រែចប់ថ្ងៃសុក្រ ១៣ កើត ខែកត្តិក ឆ្នាំរកា បញ្ចស័ក ព. ស. ២៥៣១

ត្រូវនឹងថ្ងៃទី ២៦ ខែវិច្ឆិកា ១៩៩៣ វេលាព្រឹក ម៉ោង ៩:០០

ពណ៌នាអំពីការបូជា

(ការបូជា មាន ២ យ៉ាង)

(៥៨) ឈ្មោះថា ការបូជា មាន ២ យ៉ាង ដោយអំណាច នៃអាមិសបូជា និង បដិបត្តិបូជា ។

បណ្តាការបូជាទាំង ២ យ៉ាងនោះ ការបូជាដោយគ្រឿង សក្ការមានផ្ការឈើជាដើម និងដោយបច្ច័យ ៤ ឈ្មោះថា ការបូជា ដោយអាមិស ។ ការបូជា ដោយសេចក្តីប្រតិបត្តិ ឈ្មោះថា បដិបត្តិបូជា ។ ចំណែកក្នុងអដ្ឋកថា លោកពោលហើយ ថា "ការធ្វើសក្ការ គោរព រាប់អាន និងការក្រាបថ្វាយបង្គំ ឈ្មោះថា ការបូជា " ។ ដោយការកំណត់យកបុគ្គលដែលប្រសើរខ្ពង់ខ្ពស់ បំផុត ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និង ព្រះអរិយសាវ័កទាំងឡាយ ឈ្មោះថា បុគ្គលដែលគួរបូជា ។ មែនពិត បុគ្គលដ៏ប្រសើរទាំង ឡាយ មានព្រះពុទ្ធជាដើមនោះ លោកហៅថា " ជាបូជនេយ្យ-បុគ្គល" ព្រោះធ្វើនូវភាវៈនៃការបូជា ដែលបុគ្គលបានធ្វើហើយ ក្នុងខ្លួន សូម្បីមានចំនួនតិចតួចក៏ដោយ នាំប្រយោជន៍ និងសេចក្តី សុខ មកប្រគល់ឲ្យបាន អស់កាលជាយូរអង្វែង ព្រោះហេតុជា ទក្ខិណេយ្យបុគ្គល ។

*ក្នុងបទថា " **បូជនេយ្យា** " នោះ គប្បីជ្រាបអត្ថវិគ្រោះ ដូចតទៅនេះ ៖ ដែលបុគ្គលតែងបូជា ឈ្មោះថា ការបូជា, ចុះ*

មង្គលត្ថទីបនីប្រែ

ឃុ *បច្ចយ ក្នុងការសាធនៈ ខាងមុខ* ***បូជ*** *ជាតុ, បុគ្គលទាំងឡាយណា រមែងគួរនូវការបូជា គឺ ជាអ្នកសមគួរ ដល់ការបូជា ព្រោះហេតុនោះ បុគ្គលទាំងឡាយនោះ ឈ្មោះថា បូជនេយ្យ (អ្នកសមគួរដល់ការបូជា), អធិប្បាយថា " ជាអ្នកគួរនូវការបូជា គឺ សមគួរដល់ការបូជា " ។ ចុះ* ***ឯយ្យ*** *បច្ចយ ដោយសូត្រ ក្នុងសទ្ទនីតិបករណ៍ ថា " បច្ចយ គឺ* ***ណ្យ*** *និង* ***ឯយ្យ*** *ចុះ ក្នុងអត្ថថា គួរ " ។ តែក្នុងពេលឥឡូវនេះ ពុទ្ធសាសនិកជន តែងសូត្រថា " ***បូជនីយានំ*** " ដូច្នេះក៏មានដែរ ។ ចុះ* ***ណ្យ*** *បច្ចយ ដោយសូត្រនោះ ដូចគ្នាដែរ ។ អាចារ្យពួកខ្លះ ពោលថា " ចុះ* ***អនីយ*** *បច្ចយ " ។ តែពាក្យនោះ មិនសម (ដោយពាក្យ) ក្នុងអដ្ឋកថា ថា " បទថា* ***បូជនេយ្យានំ*** *បានដល់ អ្នកដែលគួរនូវការបូជា" ។*

(ពុទ្ធបូជាមានអានិសង្សប្រើន)

(៥៩) ក៏ឈ្មោះថា ការបូជា ក្នុងបូជនេយ្យបុគ្គលទាំងឡាយ មានព្រះពុទ្ធជាដើម សូម្បីតិចតួច ក៏រមែងនាំប្រយោជន៍សុខ មកប្រគល់ឲ្យ អស់កាលដ៏យូរអង្វែង ។

ក្នុងដំណើរនោះ មាននាយសុមនមាលាការជាដើមជាឧទាហរណ៍។

(រឿងនាយសុមនមាលាការ)

បានឮថា ក្នុងក្រុងរាជគ្រឹះ មាននាយមាលាការម្នាក់ឈ្មោះ

ពណ៌នាអំពីការបូជា

សុមនៈ។ នាយសុមនមាលាការនោះកាលបម្រើព្រះបាទពិម្ពិសារ ដោយផ្កាម្ទិះ ៨ នាឡិ អំពីព្រឹកព្រលឹម ជារៀងរាល់ថ្ងៃ រមែងបាន នូវទ្រព្យ ៨ កហាបណៈ ។ ថ្ងៃមួយ នាយសុមនមាលាការនោះ កាន់ផ្ការឈើដើរទៅកាន់ទីឧបដ្ឋាកព្រះរាជា បានឃើញព្រះសាស្តា ដែលមានព្រះភិក្ខុសង្ឃ ចោមរោមហើយ ទ្រង់បញ្ចេញព្រះរស្មី ដែលមានពណ៌ ៦ ប្រការ ទ្រង់ស្តេចយាងចូលទៅកាន់ព្រះនគរ ដើម្បីទ្រង់បិណ្ឌបាត ក៏មានចិត្តជ្រះថ្លាហើយ បានគិតថា " ព្រះរាជា ទ្រង់មិនបាន នូវផ្កាឈើទាំងឡាយនេះ ទ្រង់សម្ងាប់អាត្មាអញ ក្តី ទ្រង់និរទេសអាត្មាអញ ចាករាជធានី ក្តី, ព្រោះព្រះអង្គសូម្បីទ្រង់ ព្រះរាជទាន ដល់អាត្មាអញ ក៏គប្បីព្រះរាជទានទ្រព្យ ដើម្បី ប្រយោជន៍ ដល់ការចិញ្ចឹមជីវិត ក្នុងបច្ចុប្បន្ននេះ តែប៉ុណ្ណោះឯង, ចំណែកការបូជាព្រះសាស្តា មានផលានិសង្សរាប់មិនបាន តែងនាំ ប្រយោជន៍សុខមកប្រគល់ឲ្យ អស់កាលដ៏យូរអង្វែង, អាត្មាអញ នឹងបូជាព្រះសាស្តា ដោយផ្កាឈើទាំងនេះ " ដូច្នេះហើយ ក៏បាន លះបង់ជីវិត របស់ខ្លួនហើយ ទើបបោះផ្កាទាំង ៨ នាឡិ ទៅ ចាត់ ជា ៨ ក្តាប់ ។ ក៏ផ្កា ២ ក្តាប់ ដែលនាយសុនមាលាការ បាន បោះទៅហើយ ជាដំបូង បានក្លាយទៅជាពិតានមាលា អណ្តែតនៅ ពួដ៏ខាងលើ នៃព្រះសាស្តា, ផ្កា ២ ក្តាប់ ដែលបានបោះទៅហើយ

មន្តលត្តនីបនីប្រែ

លើកទី ២ បានស្ថិតនៅ ឰដ៏ខាងស្តាំ, ផ្កា ២ ក្តាប់ដែលបានបោះ ទៅហើយ លើកទី ៣ បានស្ថិតនៅ ឰដ៏ខាងក្រោយ, ផ្កា ២ ក្តាប់ ដែលបានបោះទៅហើយ លើកទី ៤ បានស្ថិតនៅ ឰដ៏ខាងឆ្វេង សរុបទៅហើយ ផ្កា ៦ ក្តាប់បានក្លាយទៅជាគ្រឿងមាលាសម្រាប់ បិទបាំង បានស្ថិតនៅហើយ ឰដ៏ខាងទាំង ៣ ។ ឰដ៏ខាងព្រះ កក្តូ បានមានត្រឹមតែមាត់ទ្វារ សម្រាប់ព្រះអង្គស្តេចយាងទៅ តែ ប៉ុណ្ណោះ ។ ទង់ផ្កាទាំងឡាយ មាននៅខាងក្នុង, ត្របកផ្កា មាននៅ ខាងក្រៅ, ព្រះសាស្តា ប្រៀបដូចជាត្រូវចោមរោមហើយ ដោយ ស្វ័កប្រាក់ ស្តេចយាងទៅហើយ ។ សូម្បីផ្កាទាំងឡាយ ក៏មិនបាន របេះមិនបានជ្រុះរោយឡើយ អណ្តែតទៅស្ថិតនៅត្រង់ទីដែលព្រះ អង្គគង់ជាមួយនឹងព្រះសាស្តាតែម្តង ។ ព្រះនគរទាំងមូលបានផ្អើល ឱឡោហើយ ព្រោះឃើញហេតុដ៏អស្ចារ្យនោះ ។ ក៏ខាងក្នុងព្រះ នគរមានមនុស្ស ៩ កោដិ ។ បណ្តាមនុស្សទាំងនោះសូម្បីមនុស្ស ម្នាក់ ឈ្មោះថា មិនកាន់នូវភិក្ខាហើយចេញក្រៅមិនមាន ។ មហា ជន ធ្វើការស្រែកហ៊ោកញ្ជ្រៀវ ១,០០០ និង ការលើកឡើងនូវទង់ ជ័យ ១,០០០ គ្រាប់ទៅ ជាមួយនឹងព្រះសាស្តា ។ ចំណែកនាយ មាលាការ បូជា សរសើរ ថ្វាយបង្គំ នូវព្រះសាស្តា យ៉ាងដូច្នេះ ហើយ ក៏កាន់យកតែកញ្ជ្រែងទទេនុ៎ះឯង ត្រឡប់ទៅផ្ទះ ត្រូវភរិយា

ពណ៌នាអំពីការបូជា

ជណ្តើងសួរថា " ផ្កាទាំងឡាយ នៅឯណា ? " ដូច្នេះហើយ ច្រាប់ថា " ខ្ញុំបានយកផ្កាទាំងនោះ ទៅបូជាព្រះសាស្តា អស់ហើយ " ។

ភរិយា សួរថា " ឥឡូវនេះ បងនឹងធ្វើអ្វី ដល់ព្រះរាជា " ។

នាយមាលាការ ពោលថា " ព្រះរាជា ចូរសម្លាប់ខ្ញុំក្តី ចូរនិរទេសខ្ញុំចេញពីរដ្ឋធានីក្តី, ខ្ញុំលះបង់ជីវិតហើយបូជាព្រះសាស្តា, ការបូជាដោយផ្កា យ៉ាងដូច្នេះ កើតមានហើយ " ដូច្នេះ បានច្រាប់ហើយ នូវរឿងវ៉ាទាំងពួង ។

ក៏ភរិយារបស់នាយមាលាការនោះ ជាស្ត្រីអន្ធពាលមិនធ្វើសេចក្តីជ្រះថ្លា ក្នុងការអស្ចារ្យនេះឡើយ ជេរប្រទេចនាយមាលាការនោះហើយ ពោលថា " ធម្មតាព្រះរាជាទាំងឡាយ ជាអ្នកកាចសាហាវ ទ្រង់ក្រោធខឹងមួយរំពេច រមែងធ្វើសេចក្តីវិនាសដ៏ច្រើនណាស់, សេចក្តីវិនាសគប្បីមានដល់ខ្ញុំផង ព្រោះកម្មដែលអ្នកបានធ្វើហើយ " ដូច្នេះហើយ ក៏បាននាំកូនទាំងឡាយ ចូលទៅគាល់ព្រះរាជា ក្រាបទូលនូវពាក្យ ដែលនាយមាលាការនោះ និង ខ្លួនពោលហើយ គ្រប់សព្វហើយ បានក្រាបទូលថា " បពិត្រព្រះសម្មតិទេព កម្មដែលនាយមាលាការនោះ បានធ្វើហើយ ជាកម្មដែលធ្វើល្អ ឬធ្វើអាក្រក់, កម្មនោះ ចូរជាកម្មរបស់នាយមាលាការនោះម្នាក់ឯងចុះ, សូមព្រះអង្គទ្រង់ជ្រាបថា ទូលព្រះបង្គំបានលែង

លះនាយមាលាការនោះហើយ " ។

ព្រះបាទពិម្ពិសារ ទ្រង់ព្រះសណ្តាប់រឿងនោះហើយ ទ្រង់ព្រះតម្រិះ ថា " ឱហ្ន៎ ! ស្ត្រីនេះ ចំជាមនុស្សអន្ធពាល មិនញុំាងសេចក្តីជ្រះថ្លា ឲ្យកើតឡើងហើយ ក្នុងគុណ យ៉ាងនេះឡើយ " ដូច្នេះហើយ ទ្រង់ធ្វើដូចជាទ្រង់ព្រះពិរោធហើយ ទ្រង់ត្រាស់សួរថា " សាមីរបស់នាងនោះ បានធ្វើការបូជា ដោយផ្កាសម្រាប់ឧបដ្ឋាកយើងឬ ? " កាលបើនាងក្រាបទូលថា " បពិត្រព្រះសម្មតិទេពត្រឹមត្រូវហើយ " ដូច្នេះ, ទើបទ្រង់ត្រាស់ថា " ការដែលនាងបានលែងលះស្វាមីរបស់នាងនោះ ចាត់ថា នាងបានធ្វើល្អហើយ, ការបូជាដោយផ្ការបស់យើង គឺស្វាមីរបស់នាងបានធ្វើហើយ, យើងនឹងដឹងកិច្ចដែលយើងគប្បីធ្វើ ដល់ស្វាមី របស់នាងនោះ " ដូច្នេះ ទ្រង់បានបញ្ជូននាងទៅហើយ ទើបស្តេចយាងទៅ កាន់សំណាក់នៃព្រះសាស្តា ដោយប្រញាប់ ទ្រង់ស្តេចយាងទៅ ជាមួយនឹងព្រះសាស្តាទុំៈឯង ។

ព្រះសាស្តា ទ្រង់ជ្រាបសេចក្តីជ្រះថ្លា នៃព្រះរាជហឫទ័យនៃព្រះរាជាហើយ ដើម្បីទ្រង់ធ្វើនូវគុណ របស់នាយមាលាការឲ្យប្រាកដ ទើបទ្រង់ស្តេចយាងទៅ តាមមាគ៌ានៃភេរីចរណ៍ ក្នុងព្រះនគរ ដែលមានទីប្រមាណ ៣ គាវុត មិនទ្រង់ប្រទានបាត្រ ដល់

ពណ៌នាអំពីការបូជា

បុគ្គលណាម្នាក់ឡើយ ទ្រង់ស្តេចយាងទៅកាន់ព្រះលាន នៃព្រះរាជាហើយ ក៏ទ្រង់ប្រទានបាត្រ ដល់ព្រះរាជា ដែលទ្រង់មានព្រះបំណងចង់ទទួលយក ទ្រង់មិនបានយាងចូលទៅ កាន់ព្រះរាជសំណាក់ឡើយ ទ្រង់គង់នៅ ក្នុងទីស្ថាននោះតែម្តង ទ្រង់បានព្រះរាជាអង្គាស ដោយព្រះក្រយាហារដ៏ប្រណិត ក្នុងវេលាស្រេចភត្តកិច្ចហើយ ទ្រង់បានធ្វើអនុមោទនាស្រេច ទើបស្តេចយាងទៅកាន់ព្រះវិហារហើយ ស្តេចយាងចូលទៅ កាន់ព្រះគន្ធកុដី ។ ចំណែកផ្កាទាំងឡាយ, កាលបើព្រះសាស្តា ទ្រង់ស្តេចយាងទៅ, ក៏អណ្តែតទៅដែរ, កាលបើព្រះសាស្តា ទ្រង់ស្តេចគង់, ក៏ឈប់នៅដែរ, កាលបើព្រះសាស្តា ទ្រង់យាងចូលទៅ កាន់ព្រះគន្ធកុដីហើយ, ក៏ជ្រាក់ទៅ ក្នុងស៊ុមមាត់ទ្វារ ។

ចំណែក ព្រះរាជា ទ្រង់ស្តេចយាង តាមព្រះសាស្តាហើយ ទ្រង់ស្តេចយាងត្រឡប់មកវិញទ្រង់ត្រាស់បញ្ជាឲ្យហៅនាយមាលាការមកហើយ ទ្រង់មានព្រះទ័យជ្រះថ្លា ក្នុងនាយមាលាការនោះ ទ្រង់បានព្រះរាជទាន នូវដំរី ជាដើម មួយមុខ ៨ ៗ ៧ យ៉ាង គឺ ដំរី, សេះ, ខ្ញុំប្រុស, ខ្ញុំស្រី, ពួកនារី ដែលប្រដាប់តាក់តែងហើយ ដោយគ្រឿងអលង្ការគ្រប់យ៉ាង, ស្រុកដ៏ប្រសើរ, កហាបណៈមួយពាន់ និង គ្រឿងប្រដាប់ ឈ្មោះមហាបសាធនៈ ដល់នាយ

មាលាការនោះ ។

ព្រះសាស្តា ស្តេចយាងទៅកាន់ព្រះវិហារហើយ ត្រូវព្រះអានន្ទត្ថេរ ក្រាបទូលសួរថា " បពិត្រព្រះអង្គដ៏ចំរើន តើវិបាកនឹងមាន ដល់នាយមាលាការ យ៉ាងដូចម្តេចទៅហ្ន៎ ? " ដូច្នេះហើយ ទើបទ្រង់ត្រាស់ថា "ម្នាលអានន្ទ នាយមាលាការនេះលះបង់ជីវិតដើម្បីតថាគត ធ្វើការបូជា ដោយផ្កា នឹងមិនទៅកាន់ទុគ្គតិ អស់មួយសែនកប្ប អន្ទោលទៅមក ក្នុងទេវតា និងមនុស្សទាំងឡាយហើយ នឹងបានជាព្រះបច្ចេកពុទ្ធ ព្រះនាមសុមនៈ " ដូច្នេះ កាលទ្រង់សំដែងធម៌ ទើបត្រាស់គាថានេះ ក្នុងពាលវគ្គ នៃធម្មបទ ថា៖

> បុគ្គលធ្វើកម្មណាហើយ រមែងមិនក្តៅក្រហាយ [1] ជាខាងក្រោយ ឬ ដល់នូវសេចក្តីពេញចិត្ត មានចិត្តល្អ ទទួលផលនៃកម្មណា, កម្មដែលគេធ្វើហើយនោះឯង ឈ្មោះថា ជាកម្មដ៏ប្រសើរ ។

ក្នុងទីបញ្ចប់គាថា ការបានសម្រេចធម៌ បានមានហើយ ដល់សត្វ ៨ ម៉ឺន ៤ ពាន់ ដោយប្រការដូច្នេះឯង ។

រឿង នាយសុមនមាលាការ ចប់ ។

១-សុត្តន្តបិដក ភាគទី ៥២ ទំព័រទី ៣៥ ។

ពណ៌នាអំពីការបូជា

(រឿងព្រះសុធាបិណ្ឌិយត្ថេរ)

(៦០) បានឮថា កុលបុត្រម្នាក់បានបំពេញបុណ្យជារមីទុកមកហើយ ក្នុងព្រះពុទ្ធអំពីមុនទាំងឡាយ កសាងសន្សំបុណ្យទុកក្នុងភពនោះ ៗ ក្នុងកាលនៃព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថ បានមកកើត ក្នុងផ្ទះនៃត្រកូល, កាលបើព្រះដ៏មានព្រះភាគ ទ្រង់ស្តេចជារមាននៅឡើយ, មិនអាច ដើម្បីនឹងបំពេញបុណ្យ បានឡើយ កាលបើព្រះដ៏មានព្រះភាគ ទ្រង់បានបរិនិព្វានទៅហើយ, បានដាក់ដុំនៃកំបោរស ១ ដុំ ក្នុងចន្លោះ នៃដុំឥដ្ឋទាំង ២ ដុំ កាលដែលមហាជននាំគ្នាធ្វើបន្ទប់សម្រាប់បញ្ចុះនូវព្រះធាតុចេតិយ របស់ព្រះដ៏មានព្រះភាគអង្គនោះ ។ ដោយបុញ្ញកម្មនោះ កុលបុត្រនោះ បានអន្ទោលទៅមក ក្នុងទេវតានិងមនុស្សទាំងឡាយទុំ៎ឯង អស់ ៩៤ កប្ប ក្នុងពុទ្ធុប្បាទនេះ បានមកកើតហើយ ក្នុងផ្ទះនៃត្រកូលមួយ ដល់នូវការដឹងក្តីហើយ កើតជ្រះថ្លា ក្នុងព្រះសាស្តា បួសមិនយូរប៉ុន្មានឡើយ ក៏បានសម្រេចជាព្រះអរហន្ត ។ លោកបានប្រាកដនាមថា “ព្រះសុធាបិណ្ឌិយត្ថេរ” ។

ព្រះថេរៈនោះ កាលប្រកាស នូវការមិនខាតរយៈ នៃការប្រព្រឹត្តិ ក្នុងកាលមុន របស់ខ្លួន ទើបបានពោលគាថាទាំងនេះ ថា៖

បុគ្គលណាមួយ ក៏មិនអាច ដើម្បីនឹងរាប់បុណ្យ របស់បុគ្គល

មង្គលត្ថទីបនីប្រែ

អ្នកបូជានូវបុគ្គលដែលគួរបូជាទាំងឡាយ គឺព្រះពុទ្ធ ឬក៏ ពួកសាវ័ក ជាអ្នកកន្លងនូវធម៌គ្រឿងធ្វើឲ្យយឺតយូរបានហើយ ជាអ្នកឆ្លងផុតសេចក្តីសោក និងសេចក្តីខ្សឹកខ្សួលបានហើយ ថា បុណ្យនេះ មានប្រមាណប៉ុណ្ណោះឯង បានឡើយ, មួយទៀត អ្នកណាមួយ ក៏មិនអាច ដើម្បីនឹងរាប់បុណ្យ របស់បុគ្គលអ្នកបូជា នូវបូជារហបុគ្គលទាំងឡាយនោះ ជាអ្នកមិនមានភ័យមកអំពីទីណា ។ ថា បុណ្យនេះ មានប្រមាណប៉ុណ្ណោះឯង ដូច្នេះ បានឡើយ ។ មួយទៀត បុគ្គលណា ក្នុងលោកនេះ គប្បីគ្រប់គ្រងនូវភាពជាឥស្សរៈ (ជាធំ) នៃទ្វីបទាំង ៤, ទ្រព្យទាំងអស់របស់បុគ្គលនោះនុ៎ះ រមែងមិនដល់នូវចំណែកទី ១៦ នៃការបូជានេះឡើយ ។ ខ្ញុំមានចិត្តជ្រះថ្លាហើយ បានយកដុំកំបោរ (បាយអ) ដាក់ហើយ ក្នុងចន្លោះ នៃដុំឥដ្ឋ ក្នុងព្រះចេតិយរបស់ព្រះពុទ្ធ ទ្រង់ព្រះនាមសិទ្ធត្ថ ព្រះអង្គប្រសើរជាងនរជន ។ ខ្ញុំបានធ្វើហើយ នូវអំពើណាមួយ ក្នុងកាលនោះ, ព្រោះអំពើនោះ ទើបខ្ញុំមិនដែលបានស្គាល់ទុគ្គតិ រហូតអស់ ៩៤ កប្បអំពីភទ្ទកប្បនេះទៅ, នេះគឺជាផលនៃការដួសដុំលឿ ក្នុងកប្ប ទី ៣០ អំពីភទ្ទកប្បនេះឯង ខ្ញុំ បានកើតជាស្តេច

ពណ៌នាអំពីការបូជា

បក្រពត្តិ ទ្រង់មានព្រះនាមថា ព្រះបាទបដិសង្ខារៈ ជាអ្នកដល់ព្រមហើយ ដោយរតនៈ ៧ ប្រការ រហូតអស់ ១៣ លើក, ធម៌ទាំងឡាយនេះ គឺ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ ខ្ញុំ បានធ្វើឱ្យជាក់ច្បាស់ហើយ, ពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។

(៦១) យោជនា ថា " បណ្តាបទទាំងឡាយនោះ បទថា ***បូជារហោ*** *មានសេចក្តីថា បុគ្គលទាំងឡាយ មានព្រះពុទ្ធ, ព្រះបច្ចេកពុទ្ធ, ព្រះសាវ័ក, អាចារ្យ, ព្រះឧបជ្ឈាយ៍, មាតា និង បិតា និង គ្រូជាដើម ឈ្មោះថា បូជារហបុគ្គល (បុគ្គលដែលគួរបូជា), អ្នកណាមួយ ក៏មិនអាច ដើម្បីនឹងរាប់នូវបុណ្យ របស់បុគ្គលអ្នកបូជា នូវបូជារហបុគ្គលទាំងនោះ ដោយវត្ថុទាំងឡាយ មានផ្ការក្រមុំ, គ្រឿងប្រទីប, ធូប, គ្រឿងក្រអូប, គ្រឿងប្រជាប់តាក់តែង និង បច្ច័យ ៤ ជាអាទិ៍ និង ដោយកិច្ចមានការថ្វាយបង្គំជាដើម ថា បុណ្យនេះ មានប្រមាណប៉ុណ្ណេះ យ៉ាងដូច្នេះ បានឡើយ " ។*

*ឥឡូវនេះ ព្រះថេរៈ ពោលពាក្យ ថា " **ពុទ្ធេ** " ដូច្នេះ ជាអាទិ៍ ដើម្បីសំដែង នូវបូជារហបុគ្គលបុគ្គលទាំងឡាយ ដោយអំណាចការកំណត់បូជារហបុគ្គល យ៉ាងប្រសើរខ្ពង់ខ្ពស់ ។*

*បណ្តាបទទាំងឡាយនោះ បទថា " **ពុទ្ធេ** " គឺ ទាំងព្រះ*

មង្គលត្ថទីបនីប្រែ

សម្មាសម្ពុទ្ធ ទាំងព្រះបច្ចេកពុទ្ធទាំងឡាយ ។ ពាក្យ “ ***យទិ ច*** *” មានសេចក្តីថា ឬថា ។ បទថា “* ***សាវកេ*** *” បានដល់ ពួកព្រះសាវ័ក របស់ព្រះពុទ្ធ ។ បាទគាថាថា “* ***បបញ្ចសមតិក្កន្តេ*** *” បានដល់ ជាអ្នកមានធម៌គ្រឿងយឺតយូរ គឺតណ្ហា ទិដ្ឋិ និងមានះ បានកន្លងហើយ ។ បាទគាថាថា “* ***តិណ្ណសោកបរិទ្ទវេ*** *” បានដល់ ឆ្លងហើយ គឺកន្លងផុតហើយនូវសេចក្តីសោក និង ការខ្សឹបខ្សួល ។*

ព្រះថេរៈ ពោលថា “ ***តេ តាទិសេ*** *” ដូច្នេះជាដើម ដើម្បីនឹងសំដែងសេចក្តី ថា “ អ្នកឯណាមួយ ក៏មិនអាច ដើម្បីនឹងរាប់បុណ្យ របស់បុគ្គលអ្នកបូជានូវបូជារហបុគ្គលទាំងឡាយ មានព្រះពុទ្ធជាដើម ដែលទ្រង់ធរមាននៅឡើយ តែម៉្យាងប៉ុណ្ណោះក៏ទេដែរ, សូម្បីក្នុងបុណ្យ របស់បុគ្គលអ្នកបូជានូវបូជារហបុគ្គល មានព្រះពុទ្ធជាដើម ដែលទ្រង់បរិនិព្វានទៅហើយ ក្តី នូវព្រះចេតិយ និងរូបព្រះបដិមា ជាដើម របស់បូជារហបុគ្គលទាំងឡាយនោះ ក្តី ក៏នយនេះ ដូចគ្នាដែរ ” ។*

បណ្តាបទទាំងនោះ បទថា “ ***តេ*** *” បញ្ចូល* ***ពុទ្ធាទិកេ*** *មក (ប្រែថា នូវបូជារហបុគ្គល មានព្រះពុទ្ធ ជាដើម) ។ បទថា “* ***តាទិសេ*** *” គឺជាអ្នកប្រកបដោយគុណ នៃបុគ្គលជាអ្នកនឹងធឹងដោយអំណាចនៃគុណ តាមដែលបានពោលមកហើយ ។ បទថា*

ពណ៌នាអំពីការបូជា

" **និព្វុតេ** " គឺ ជាអ្នករលត់ហើយ ដោយការរលត់នូវកិលេស មានរាគៈជាដើម ។ ភ័យអំពីទីណា ៗ គឺអំពីភព ឬ អំពីអារម្មណ៍ រមែងមិនមាន ដល់បូជារហបុគ្គលទាំងឡាយ មានព្រះពុទ្ធជាដើម នោះ ព្រោះហេតុនោះ បូជារហបុគ្គលទាំងឡាយ មានព្រះពុទ្ធជា ដើមនោះ ឈ្មោះថាមិនមានភ័យអំពីទីណាៗ ។ បទថា " **ឥមេតុំ** " មានសេចក្តី ថា អ្នកណាមួយ ក៏មិនអាច ដើម្បីនឹងរាប់ គឺ ដើម្បី នឹងធ្វើនូវការរាប់ បានដល់ ដើម្បីនឹងរៀបរាប់ ដោយអំណាចចំនួន មានមួយរយ និងមួយពាន់ជាដើម ថា " បុណ្យនេះ មានប្រមាណ ប៉ុណ្ណេះ " ដូច្នេះ បានឡើយ ។ បទថា " **អបិ កេន ចិ** " ប្រែថា គឺអ្នកណាមួយ គឺ បុគ្គលសូម្បីជាអ្នកមានអានុភាពច្រើន ។ ម៉្យាង ទៀត មានសេចក្តីថា បណ្តាការរាប់ ៣ យ៉ាង ដោយអំណាច នៃការវាស់ ការថ្លឹង និង ការវាល់ ដោយការរាប់ ឯណាមួយ ។ បណ្តាការរាប់ទាំង ៣ យ៉ាងនោះ ការកំណត់យកសេចក្តី ថា " របស់នេះ មានប្រមាណប៉ុណ្ណេះ " ដូច្នេះ ឈ្មោះថា ការវាស់ ។ ការថ្លឹង ដោយជញ្ជីង ឈ្មោះថា ការថ្លឹង ។ ការវាល់ឲ្យពេញ ក្នុងគ្រឿង សម្រាប់វាល់ទាំងឡាយមានកន្ទះទូកដៃ ១ ទូកដៃ និង ១ នាឡិ ជាដើម ហើយរាប់ ឈ្មោះថា ការវាល់ ។ ឥឡូវនេះ ដើម្បីនឹងសំដែង នូវការបូជានោះ ទើបលោកពោលថា " **ចតុន្នំបិ**

ច ទីបានំ *” ដូច្នេះ ជាដើម ។*

បណ្តាបទទាំងនោះ បទថា “ ***ទីបានំ*** *” បានដល់ ទ្វីបធំទាំងឡាយ ដែលមានទ្វីបតូច ៗ ២ ពាន់ ជាបរិវារ ។ បទថា “* ***ឥស្សរំ*** *” មានសេចក្តីថា គប្បីឲ្យធ្វើភាពជាឥស្សរៈ គឺភាពជាស្តេចចក្រពត្តិ ក្នុងផ្ទៃចក្រវាឡទាំងមូល រួមទ្វីបទាំងឡាយដូចបានពោលមកហើយ ចូលរួមជាមួយគ្នា ។ បាទគាថា ថា “* ***ឯតិស្សា បូជនាយេតំ***” *មានសេចក្តីថា ទ្រព្យទាំងអស់ មានរតនៈ ៧ ប្រការជាដើម ក្នុងសកលទ្វីបនោះ រមែងមិនដល់នូវចំណិត ទី១៦ នៃការបូជា ព្រោះដុំកំបោរមួយដុំ ក្នុងបន្ទប់សម្រាប់បញ្ចុះព្រះធាតុ ក្នុងព្រះចេតិយ ។*

បទថា “ ***កលំ*** *” មានសេចក្តីថា រមែងមិនដល់នូវចំណិត នៃចំណែកទី ១៦ ដែលបានបែងចែក អស់ ១៦ ជង ១៦ លើក នៃកិរិយាបូជា ដែលបុគ្គលបានធ្វើហើយ ក្នុងព្រះចេតិយ ” ។*

បទថា “ ***នរគ្គស្ស*** *” មានសេចក្តីថា កាលបើមហាជននាំគ្នាធ្វើការបូកដោយកំបោរ ក្នុងបន្ទប់សម្រាប់បញ្ចុះព្រះធាតុ ក្នុងព្រះចេតិយ របស់ព្រះមានព្រះភាគទ្រង់ព្រះនាមថាសិទ្ធត្ថ ព្រះអង្គទ្រង់ប្រសើរខ្ពង់ខ្ពស់ ជាងនរទាំងឡាយ ។ បទថា “* ***ឥដ្ឋកន្តរេ*** *” គឺ ចំត្រង់កណ្តាលចន្លោះ នៃដុំឥដ្ឋទាំង ២ ។ ម៉្យាងទៀត មាន*

ពណ៌នាអំពីការបូជា

*សេចក្តីថា ក្នុងចន្លោះ នៃទីដែលជាកំពូល នៃទីជាទីទ្រ នូវផ្តា ។ បទថា “**និន្នោ**” ប្រែថា បានជាក់ហើយ ។*

រឿង ព្រះសុធាបិណ្ឌិយត្ថេរ មកក្នុងទសមគ្គវគ្គ នៃអបទាន ។

សូម្បីរឿងសុវណ្ណចេតិយ ក្នុងពុទ្ធវគ្គ នៃធម្មបទ ក៏គប្បីសំដែងផងដែរ ។

(រឿងកោសាតកីទេពធីតា)

(៦២) កាលបើព្រះបាទអជាតសត្រូវ ទ្រង់បាននាំយកព្រះសរីរិកធាតុ របស់ព្រះមានព្រះភាគ ដែលព្រះអង្គបានទទួលហើយ កាលដែលព្រះមានព្រះភាគទ្រង់បានបរិនិព្វានទៅហើយ ទ្រង់បានសាងព្រះស្តូប និង ការឆ្លងព្រះស្តូប, ឧបាសិកា អ្នកអាស្រ័យនៅ ក្នុងទីក្រុងរាជគ្រឹះម្នាក់ ជម្រះសរីរៈរាងកាយ តាំងពីព្រលឹមស្រាង កាន់ផ្តាវល្លិ៍នោងព្រៃ ៤ ទង ដោយតាំងចិត្តថា “អាត្មាអញ និងបូជាព្រះស្តូប របស់ព្រះសាស្តា” ដូច្នេះ ជាអ្នកមានចិត្តគឺកម្លាំងនៃសទ្ធា ឲ្យប្រឹងប្រែងព្រមហើយ មិនទាន់ត្រូតមើលនូវសេចក្តីអន្តរាយតាមផ្លូវផង ក៏បានដើរមានមុខចំពោះព្រះស្តូប ។

គ្រានោះ មេគោកូនខ្ចីចោលឆ្ពោះមកយ៉ាងលឿន ជល់នាងឲ្យដល់នូវការអស់ទៅនៃជីវិតហើយ ។ នាងបានធ្វើកាលកិរិយាក្នុងទីនោះ មួយរំពេចហើយ ក៏បានទៅកើត ក្នុងពួកទេវតា ជាន់

មង្គលត្ថទីបនីប្រែ

តាវត្តិង្ស បានជ្រាកដហើយ ព្រមទាំងរថ ក្នុងកណ្តាល នៃបរិវារ របស់ស្តេចសក្កទេវរាជ ដែលស្តេចទ្រង់យាងទៅ ដើម្បីទ្រង់ព្រះក្រសាលក្នុងព្រះឧទ្យាន ។ ស្តេចសក្កទេវរាជ ទ្រង់ទតព្រះនេត្រ ឃើញនាងហើយ កាលទ្រង់ត្រាស់សួរ ទ្រង់បានត្រាស់ហើយនូវ គាថាទាំងឡាយ ថា ៖

ម្នាលនាងដ៏បំរើន អ្នកមានសំពត់លឿង មាន [1] ទង់លឿង ស្អិតស្អាង ដោយគ្រឿងប្រដាប់មានពណ៌លឿង មានអវយវៈលាប ដោយខ្លឹមចន្ទន៍លឿង ទ្រទ្រង់ផ្កាឧប្បលលឿង មានប្រាសាទនិងទីដេកលឿង មានទីអង្គុយលឿង មានភោជនពណ៌លឿង មានឆត្រលឿង មានរថលឿង មានសេះលឿង មានផ្ទៃតលឿង ក្នុងភពជាមនុស្ស ក្នុងកាលមុន នាងបានធ្វើកម្មដ៏ឫបម្តេច ម្នាលនាងទេវធីតា យើងសួរហើយ នាងប្រាប់ប្រាប់ចុះ នេះគឺជាផលនៃកម្មអ្វី ។

បណ្តាបទទាំងនោះ បទថា “ ***បីតចន្ទនលិត្តង្គេ*** *” គឺជាអ្នកមានសរីរៈ ដែលប្រដាប់ហើយ ដោយខ្លឹមចន្ទន៍មានពណ៌ ដូចមាស ។ បានគាថាថា “* ***បីតប្បាសាទសយានេ*** *” គឺ ប្រកបព្រមហើយ ដោយប្រាសាទដែលសម្រេចហើយដោយមាស និង ដោយ*

១-សុត្តន្តបិដក ភាគទី ៥៥ ទំព័រទី ៩៩ ។

ពណ៌នាអំពីការបូជា

ទីជេក ដែលគេបិទបាំងដោយមាស ។ ស្តេចសក្កទេវរាជ ទ្រង់ប្រកាន់យកមាសទាំងអស់ ដោយបីតសព្ទ ទាំងខាងក្រោម ទាំងខាងលើ ដោយប្រការដូច្នេះឯង ។

(៦៣) លំដាប់នោះ ទេវធីតានោះ កាលនឹងក្រាបទូលដល់ស្តេចសក្កទេវរាជនោះ ទើបបានពោលគាថាទាំងនោះ [1] ថា ៖

បពិត្រព្រះអង្គដ៏ចម្រើន មានវល្លិ៍នោងព្រៃ ជាវល្លិ៍មានជាតិល្វីង ដែលគេមិនត្រូវការហើយ ខ្ញុំម្ចាស់មានបិត្តជ្រះថ្លាហើយ បានយកផ្កានោងព្រៃនោះ ៤ ទង ទៅបូជាព្រះស្តូប ក្នុងបំពោះព្រះសរីរៈរបស់ព្រះសាស្តា ខ្ញុំម្ចាស់កំពុងមានបិត្តប្រព្រឹត្តទៅ ក្នុងព្រះធាតុ នៃព្រះមានព្រះភាគនោះ មិនបានក្រឡេកមើលផ្លូវមេគោនោះផង គ្រានោះ ស្រាប់តែមេគោ មកជល់ខ្ញុំម្ចាស់ ដែលមានអធ្យាស្រ័យមិនទាន់ដល់ព្រះស្តូប (ស្លាប់ទៅ) បើខ្ញុំម្ចាស់ គប្បីសន្សំបុណ្យនោះសម្រេច ម្ល៉ះសមជាមានសម្បត្តិ ដ៏លើសលុបជាងនេះ ពិតមែន, បពិត្រព្រះអង្គជាធំជាងទេវតា នាមមឃវៈ ជាទេវកុញ្ជរ ខ្ញុំម្ចាស់បានលះបង់រាងកាយជាមនុស្ស មកកើតជាមួយនឹងព្រះអង្គ ព្រោះកម្មនោះ ។

១- សុត្តន្តបិដក ភាគទី ៥៥ ទំព័រទី ៩៩ ។

មង្គលត្ថទីបនីប្រែ

បណ្តាបទទាំងនោះ បទថា "**លតត្តិ**" កាត់បទជា **លតា អត្តិ** មានវិស្ស៌ ។ នាងទេពធីតា ហៅស្តេចសក្កទេវរាជ ដោយសេចក្តីគោរព ថា " បពិត្រព្រះអង្គ ដ៏ចម្រើន " ។ បទថា "**អនកិញ្ជិតា**" ប្រែថា ដែលគេមិនត្រូវការហើយ ។

បទថា " **សរីរំ** " បានដល់ ព្រះធាតុដែលជាព្រះសរីរៈ ។ សព្ទនេះ ជាសព្ទហៅរួម ប្រើក្នុងសេចក្តីសង្ខេប តែប៉ុណ្ណោះ ដូចជាឧទាហរណ៍ ថា " សំពត់ ត្រូវភ្លើងឆេះ " និង ថា " ខ្ញុំ បានឃើញសមុទ្រហើយ " ដូច្នេះឯង ។

បទថា " **អស្ស** " បញ្ចូល **គោរូបស្ស** (ប្រែថា រូបគោ) ។ បទថា " **មគ្គំ** " គឺជាផ្លូវទីមក ។ បទថា " **ន អវេក្ខិស្សំ** " គឺ មិនទាន់បានក្រឡេកមើលហើយ ។ បាទនៃគាថាថា " **តទគ្គមនសា សតិ** " មានសេចក្តីថា ខ្ញុំម្ចាស់កំពុងតែមានចិត្តប្រព្រឹត្តទៅ ក្នុងព្រះស្តូប នៃព្រះសាស្តានោះតែម៉្យាង ។ អធិប្បាយថា " ព្រោះខ្ញុំម្ចាស់ កំពុងតែមានចិត្តប្រព្រឹត្តទៅ ក្នុងព្រះស្តូប របស់ព្រះសាស្តាតែប៉ុណ្ណោះ មិនបានមានចិត្តប្រព្រឹត្តទៅ ក្នុងមេគោនោះឡើយ, ដូច្នោះ ទើបខ្ញុំម្ចាស់ មិនទាន់បានក្រឡេកមើលផ្លូវនៃមេគោនោះ ។ បាលីថា " **តទគ្គមនសា** " ដូច្នេះ ក៏មានដែរ ។ សេចក្តីថា " ចិត្តរបស់ខ្ញុំម្ចាស់ ប្រព្រឹត្តទៅ ក្នុងអង្គនៃព្រះស្តូបនោះ គឺក្នុងព្រះសរីរៈ

ជានដល់ ក្នុងព្រះធាតុ របស់ព្រះសាស្តានោះ ព្រោះហេតុនោះ ខ្ញុំម្ចាស់នេះ ទើបឈ្មោះថា មានចិត្តប្រព្រឹត្ត ក្នុងព្រះសរីរៈ របស់ព្រះសាស្តាអង្គនោះ" ។

បទថា " **ថូបំ** " គឺព្រះចេតិយ ។ បទថា "**អប្បត្តមានសំ**" គឺមានអធ្យាស្រ័យមិនទាន់ដល់ព្រមហើយ ។ ក៏ធនូៈ មានក្នុងចិត្ត ព្រោះហេតុនោះ ទើបឈ្មោះថា មានសៈ គឺ អធ្យាស្រ័យបានដល់មនោរថ ។ នាងទេពធីតា ពោលហើយ យ៉ាងដូច្នោះ ព្រោះការៈនៃមនោរថដែលកើតឡើងហើយថា " អាត្មាអញ នឹងចូលទៅកាន់ព្រះស្តូប ហើយបូជា ដោយផ្កាទាំងឡាយ " ដូច្នេះ មិនទាន់បានបរិបូណ៌នៅឡើយ ។ ក៏នាងទេពធីតានោះ បានកើតឡើងហើយក្នុងទេវលោក ដោយចិត្តគិតនឹងបូជាដោយផ្កា ក្នុងព្រះស្តូបឯណា, ចិត្តគិតបូជាដោយផ្កា ក្នុងព្រះស្តូប របស់នាងនោះ បានសម្រេចហើយ ដោយពិតប្រាកដ ។

បទថា " **តំ** " បានដល់ បុណ្យនោះ ។ បទថា " **ចាហំ** " កាត់បទជា **ចេ អហំ** ។ បទថា " **អភិសញ្ចេយ្យំ** " មានសេចក្តីថា ខ្ញុំម្ចាស់គប្បីដល់ចំពោះ គឺចូលទៅដល់ព្រះស្តូប ហើយកសាង គឺសន្សំ ដោយប្រពៃ ដោយការបូជា ដោយផ្កា តាមដែលបានពោលមកហើយ ។ ពាក្យថា " **កិយ្យោ នូន ឥតោ** "

មង្គលត្ថទីបនីប្រែ

មានសេចក្តីថា " ម្ល៉ះសមមានសម្បត្តិ ដ៏លើសលប់ ជាងសម្បត្តិ តាមដែលខ្ញុំម្ចាស់បានហើយ " ។

*បទថា " **មយា** " ជាអាលបន: (ពាក្យសម្រាប់ហៅ) ។ បទថា " **ទេវកុញ្ញរ** " គឺ ជាអ្នកប្រាកដស្មើនឹងស្តេចដំរី ក្នុងពពួកទេវតា ដោយគុណវិសេសទាំងឡាយ មានកម្លាំង និង សេចក្តីព្យាយាម ប្រឹងប្រែង គ្រប់បែបយ៉ាងជាដើម ។ បទនេះ ជាបទវិសេសន: នៃបទថា **មយា** នោះ ។ បទថា " **សហព្យតំ** " គឺ កាន់ភាពជាសំឡាញ់ ។*

(ស្តេចសក្កទេវរាជសំដែងធម៌ដល់ទេវតា)

(៦៤) ស្តេចសក្កទេវរាជ ទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ កាលនឹងសម្តែងធម៌ដល់ពួកទេវតា មានមាតលិទេវបុត្រជាប្រធាន ទើបទ្រង់បានត្រាស់ នូវគាថាទាំងឡាយនេះ ថា ៖

ម្នាលមាតលិ អ្នកចូរមើលនូវសេចក្តីអស្ចារ្យ [1] នេះជាផលនៃកម្មដ៏វិបិត្រ, ទេយ្យធម៌ ស្ងួមតែបន្តិចបន្តួច ដែលបុគ្គលបានធ្វើហើយ បុណ្យត្រឡប់ទៅជាមានផលច្រើន កាលបើបិត្តជ្រះថ្លាហើយ បំពោះព្រះតថាគត ជាព្រះសម្ពុទ្ធ ព្រះ

១- សុត្តន្តបិដក ភាគទី ៥៥ ទំព័រទី ១០០ ។

ពណ៌នាអំពីការបូជា

បច្ចេកពុទ្ធ ឬ សាវ័ក របស់ព្រះតថាគតនោះ, ទក្ខិណាទាន ឈ្មោះថា មានផលតិចតួចមិនមែនសោះឡើយ, ម្នាលមាគលិ អ្នកចូរមកចុះ សូម្បីយើងទាំងឡាយ ក៏នឹងបូជាព្រះធាតុ របស់ព្រះតថាគត ឱ្យលើសលប់ ជាងនេះទៅទៀត ការសន្សំនូវបុណ្យទាំងឡាយ ជាហេតុនាំឱ្យមានសេចក្តីសុខ, សូម្បីកាលព្រះតថាគតបរិនិព្វានទៅហើយក្តី បើគាំងចិត្តស្មើផលក៏មានស្មើ ដ្បិតថា សត្វទាំងឡាយ អ្នកមានការតម្កល់បិត្តទុកជាហេតុ ទើបទៅកាន់សុគតិបាន, ទាយកទាំងឡាយរមែងទៅកាន់ស្ថានសួគ៌បាន ព្រោះធ្វើការបូជា បំពោះព្រះតថាគត ទាំងឡាយណា, ព្រះតថាគត ទាំងឡាយនោះ ទ្រង់កើតឡើងក្នុងលោក ដើម្បីប្រយោជន៍ ដល់ជនច្រើនហ្ន៎ ។

យោជនា ថា " បណ្តាបទទាំងឡាយនោះ បទថា ***ចិត្តំ*** *ប្រែថា ដ៏វិចិត្រ គឺ ដែលគេមិនគួរគិត ។ បទថា "* ***កម្មផលំ*** *" មានសេចក្តីថា អ្នកចូរមើលនូវផល នៃបុញ្ញកម្ម សូម្បីកាលបើទេយ្យធម៌ ជារបស់ដែលមិនប្រសើរត្រឡប់ជាប្រសើរវិញ ព្រោះការដល់ព្រម នៃខេត្តគឺអ្នកទទួល និង ព្រោះការដល់ព្រមនៃចិត្ត (ចេតនា) " ។ បទថា "* ***កតំ*** *" គឺ ប្រកបហើយ ក្នុងខេត្ត ដែល*

ជាទីកើត ដោយអំណាចនៃសក្ការៈតែម៉្យាង ។ របស់ដែលទាយកគប្បីឲ្យ ឈ្មោះថា ទេយ្យទាន ។ កម្ម ដែលជាបុណ្យ ឈ្មោះថា បុណ្យ ។

បុណ្យដែលបុគ្គលបានធ្វើហើយ បន្តិចបន្តួច ក្នុងបុញ្ញខេត្ត ណា ជាបុណ្យមានផលច្រើន ឥឡូវនេះ ស្តេចសក្កទេវរាជ កាលនឹងសម្តែង នូវបុញ្ញខេត្ត (ស្រែបុណ្យ) នោះ ធ្វើឲ្យជ្រាកដ ទើបទ្រង់ត្រាស់នូវគាថា ថា “**នត្ថិ ចិត្តេ**” ជាដើម ។

បណ្តាបទទាំងនោះ បទថា “**សម្ពុទ្ធេ**” គឺ ព្រះសម្មាសម្ពុទ្ធ ជាម្ចាស់ ។ **ច** អក្សរ បញ្ចូលព្រះបច្ចេកពុទ្ធផងដែរ ។ បទថា “**អម្ហេបិ**” ប្រែថា សូម្បីយើងទាំងឡាយ ។ បទថា “**មហេម សេ**” គឺ នឹងធ្វើ បានដល់ នឹងបូជា ។

បាទគាថា ថា “**ចេតោបណិធិហេតូ ហិ**” មានសេចក្តីថា ជាអ្នកមានការតាំងចិត្ត របស់ខ្ជនទុក ដោយប្រពៃ មែនពិត ជានិមិត្ត, អធិប្បាយថា “ព្រោះការតម្កល់ខ្ជនទុក ដោយប្រពៃ” ។

ស្តេចសក្កទេវរាជ លុះទ្រង់ត្រាស់សម្តែង យ៉ាងដូច្នេះហើយ ទ្រង់រម្ងាប់នូវព្រះឧស្សាហ៍ ក្នុងការស្តេចយាងទៅប្រពាត ក្នុងព្រះឧទ្យាន ស្តេចយាងត្រឡប់ អំពីទីនោះឯងហើយ ទ្រង់ធ្វើការបូជា ក្នុងព្រះចូឡាមណីចេតិយ រហូតមួយសប្តាហ៍ ក្នុងកាល

ពណ៌នាអំពីការបូជា

ក្រោយមក ទ្រង់បានត្រាស់ នូវរឿងភ័ាវនោះ ដល់ព្រះនារទគ្គៅ ដ៏មានអាយុ ដែលកំពុងតែគ្រាច់ទៅទីចារិក ក្នុងទេវលោក ដោយគាថាទាំងឡាយនោះ ។ ក្នុងពេលដែលធ្វើបឋមសង្គាយនា ព្រះថេរៈ បានសម្តែងប្រាប់ហើយ ដល់ព្រះធម្មសង្គាហកាចារ្យទាំងឡាយ ។ ព្រះថេរៈ ទាំងឡាយ បានលើកយកពាក្យនោះ ឡើងកាន់សង្គាយនាហើយ យ៉ាងដូច្នោះឯង ។

រឿង នាងកេសាតកីទេពធីតា ក្នុងអដ្ឋកថាបីតវិមាន ចប់ ។

ពុទ្ធបូជា រមែងនាំមកនូវប្រយោជន៍សុខ អស់កាលដ៏យូរអង្វែង ដូចបានពណ៌នាមកហើយនេះឯង ។

(រឿងនាងបញ្ចបាបា)

(៦៥) ក្នុងអតីតកាល ក្នុងក្រុងពារាណសី មាននាងធីតារបស់អ្នកក្រីក្រម្នាក់ បានជាន់ដីស្អិតលាបជញ្ជាំងផ្ទះ ។

គ្រានោះ ព្រះបច្ចេកពុទ្ធ មួយព្រះអង្គ បានចូលទៅកាន់នគរ ដើម្បីសុំនូវដីស្អិត ដើម្បីបូកនូវជញ្ជាំងនៃគូហា របស់ខ្លួន ហើយបានឈរនៅ ក្នុងទីមិនឆ្ងាយពីនាងធីតានោះ ។ នាងធីតានោះ ក្រោធហើយ មើលបណ្តើរ ពោលបណ្តើរ ថា " បពិត្រសមណៈ តើព្រះគុណម្ចាស់មិនបានដីស្អិតខ្លះទេឬ? " ហើយក៏បានជាក់ជុំនៃដីស្អិត យ៉ាងធំ ក្នុងបាត្រ របស់ព្រះបច្ចេកពុទ្ធអង្គនោះ ។

មង្គលត្ថទីបនីប្រែ

ព្រះបច្ចេកពុទ្ធ បានទទួលយកដីស្អិតនោះហើយ ក៏និមន្តទៅ ។ នាងចុតចាកអំពីអត្តភាពនោះហើយ ក៏បានមកកើតជាធីតា របស់អ្នកទីទ័លក្រម្នាក់ ក្នុងស្រុកក្បែរមាត់ទ្វារ ឰដ៏ទិសខាងកើត នៃទីក្រុងឈ្មោះ ពារាណសី ។ ដៃ ជើង មាត់ ក្អែក និង ច្រមុះ របស់នាង កើតជារបស់អាក្រក់អាក្រី ខុសពីប្រក្រតី ព្រោះនាងក្រោធខឹង ហើយក្រឡេកមើលព្រះបច្ចេកពុទ្ធ ។ ដោយហេតុនោះ ពួកជនទាំងឡាយ ទើបបានស្គាល់នាងច្បាស់ថា “បញ្ចបុបា” ។ ប៉ុន្តែសរីរៈរបស់នាង បានដល់ព្រម ដោយសម្ផស្ស ព្រោះផលនៃការប្រគេនដុំនៃដីស្អិត ។

គ្រានោះ មានព្រះរាជាក្រុងពារាណសី ទ្រង់ព្រះនាម ថា ពកៈ ។ ក្នុងរាត្រី ថ្ងៃមួយ ព្រះរាជាអង្គនោះ ទ្រង់ស្តេចយាងត្រួតព្រះនគរ ដោយបន្ទំកេទ មិនឲ្យអ្នកណាមួយដឹង ទ្រង់ស្តេចយាងទៅដល់ទីស្ថាននោះហើយ ។

ចំណែក នាងបញ្ចបុបា កំពុងតែលេងជាមួយនឹងពួកក្មេងស្រីអ្នកស្រុក មិនទាន់ដឹងផង ក៏ចាប់ព្រះហស្តព្រះរាជា ។ ព្រះរាជា ប្រៀបដូចជាត្រូវសម្ផស្សទិព្វពាល់ត្រូវហើយ ទ្រង់មិនអាចដើម្បីនឹងស្ថិតនៅ ដោយភាពជាព្រះអង្គឯងបានឡើយ ទ្រង់បានសព្វព្រះទ័យហើយ ដោយអំណាចនៃសេចក្តីត្រេកត្រអាល ក្នុង

ផស្សៈ ទើបត្រាស់សួរថា “ តើនាងជាធីតា របស់អ្នកណា? ” ។

នាង បានឆ្លើយតប ថា “ នាងខ្ញុំ ជាធីតា របស់អ្នករស់នៅ ក្បែរទ្វារ (ព្រះនគរ) ” ។

ព្រះរាជាអង្គនោះ ទ្រង់ត្រាស់សួរនូវភាវៈនៃនាងជាអ្នកមិនមានស្វាមីហើយ ទ្រង់ត្រាស់ថា “ ខ្ញុំ នឹងជាស្វាមី របស់នាង, ចូរនាងទៅចុះ, ចូរនាងញុំាងមាតាបិតា ឲ្យយល់តាមនាងផងចុះ ” ។ នាងបញ្ជូបាបានោះ បានទៅដល់ផ្ទះហើយ ក៏ប្រាប់ដល់មាតាបិតាហើយ ។ មាតាបិតាទាំងនោះ បានអនុញ្ញាតឲ្យហើយ ។ នាងបានត្រឡប់មកក្រាបទូល ដល់ព្រះរាជាហើយ ។ ព្រះរាជា ទ្រង់ស្តេចយាងទៅកាន់ផ្ទះ (របស់នាង) មួយអន្ទើយនឹងនាង ទ្រង់គង់នៅរួមរស់ហើយ ទើបស្តេចយាងទៅព្រះរាជដំណាក់ តាំងអំពីព្រឹកព្រលឹម ។ តាំងពីពេលនោះមក ព្រះអង្គមិនទ្រង់ប្រាថ្នា ដើម្បីនឹងទតព្រះនេត្រនូវស្ត្រីជនៃទៀត ទ្រង់ស្តេចយាងទៅ ក្នុងទីនោះ ជាប់ជានិច្ច ដោយបានដំណែងកេទ មិនឲ្យអ្នកណាមួយស្គាល់ ។

ក្រោយមក ថ្ងៃមួយ រោគជ្រាក់ឈាម បានកើតឡើងហើយ ដល់បិតា របស់នាងបញ្ជូបាបានោះ ។ បាយបាយាស ដែលផ្សំហើយ ដោយទឹកដោះស្រស់ ទឹកឃ្មុំ និងស្ករក្រួស ដែលមិនបានផ្សំ (ដោយវត្ថុឯទៀត) ជាដើម ជាថ្នាំសម្រាប់កែរោគ របស់បិតា

នាងនោះ ។ ជនទាំងនោះ មិនអាចដើម្បីនឹងញុំាងបាយបាយាសនោះ ឲ្យកើតឡើងបានឡើយ ព្រោះជាអ្នកទីទ័លក្រ ។ គ្រានោះ មាតារបស់នាង បានពោលថា " ម្នាលនាង ស្វាមីរបស់នាង នឹងអាច ដើម្បីនឹងញុំាងបាយបាយាស ឲ្យកើតឡើងបានឬទេ ? " ។ នាងបញ្ជូបាបានោះ បានក្រាបទូលសេចក្តីនោះ ដល់ព្រះរាជា ក្នុងពេលដែលព្រះអង្គស្តេចយាងមក ។

ព្រះរាជា ទ្រង់ត្រាស់ថា "ម្នាលនាងដ៏ចំរើន នេះ គឺជាថ្នាំសម្រាប់កែរោគ របស់អ្នកធំ, ខ្ញុំ នឹងបានមកអំពីទីណា? " ដូច្នេះហើយទ្រង់មានព្រះបំណងនឹងនាំនាងទៅ ខាងក្នុងព្រះរាជដំណាក់ដោយឧបាយកល លុះព្រឹកឡើង ទើបស្តេចយាងទៅកាន់ព្រះរាជដំណាក់ ទ្រង់ត្រាស់ឲ្យចំអិនបាយបាយាសជូថ្នោះហើយ ទ្រង់បានធ្វើជាពីរកញ្ចប់ ទ្រង់បានជាក់ផ្ងនសក់កែវមណី ក្នុងកញ្ចប់មួយស្រេចហើយ ទ្រង់ស្តេចយាងមក ក្នុងរាត្រី ទ្រង់ត្រាស់ ថា " ម្នាលនាងដ៏ចំរើន ក្នុងថ្ងៃនេះ បិតារបស់នាង ចូរបរិភោគកញ្ចប់បាយាសនេះចុះ, លុះដល់ថ្ងៃស្អែកឡើង ចូរបរិភោគកញ្ចប់បាយបាយាសនេះចុះ " ។ នាងបានធ្វើតាមព្រះរាជតម្រាស់នោះហើយ ។ រោគរបស់បិតានាង បានស្ងប់រម្ងាប់ហើយ ។

លុះថ្ងៃស្អែកឡើង ព្រះរាជា ទ្រង់បានស្តេចយាងទៅកាន់

ពណ៌នាអំពីការបូជា

ព្រះរាជដំណាក់ ទ្រង់លាងព្រះកគ្រែហើយ ទើបទ្រង់ត្រាស់ ថា " អ្នកទាំងឡាយ ចូរនាំយកទូវផ្ចង់សក់កែវមណីមកឲ្យយើង " ។

ពួករាជបុរស បានក្រាបទូល ថា " បពិត្រព្រះសម្មតិទេព ពួកទូលព្រះបង្គំ រកមិនឃើញទេ " ។ ព្រះរាជា ទ្រង់ត្រាស់ ថា " ពួកអ្នកទាំងឡាយ ចូរត្រួតពិនិត្យមើល ក្នុងទីគ្រប់កន្លែង តាំងអំពីខាងក្នុងព្រះនគរ រហូតដល់ខាងក្រៅព្រះនគរ ដោយទីបំផុតទៅសូម្បីក្នុងកញ្ចប់ចាយ " ។ ពួករាជបុរស កាលត្រួតមើលទៅ ក៏បានឃើញកែវមណី ក្នុងផ្ទះ របស់នាងបញ្ចបាបា ហើយបានចាប់ចងមាតាបិតា របស់នាង នាំយកទៅហើយ ។

គ្រានោះ បិតារបស់នាងបញ្ចបាបានោះ បានប្រាប់ថា " ពួកយើងខ្ញុំ មិនមែនជាចោរទេ, កែវមណីនេះ កូនប្រសា (របស់ពួកយើង) បាននាំយកមក " ។ ពួករាជបុរស បានសួរថា " តើកូនប្រសា របស់ពួកអ្នកនោះ នៅក្នុងទីឯណា? " ។ បិតា របស់នាងបញ្ចបាបានោះ ប្រាប់ថា " កូនស្រីរបស់នាងខ្ញុំស្គាល់ " យ៉ាងដូច្នេះហើយ ទើបបានសួរនាងបញ្ចបាបានោះ ។ នាង បានឆ្លើយប្រាប់ថា " បពិត្រលោកឪពុក ស្វាមីនាងខ្ញុំនោះ បានមក ក្នុងវេលាងងឹតហើយទៅវិញ ក៏ក្នុងវេលាងងឹតដូចគ្នាដែរ, ដោយហេតុនោះ ទើបនាងខ្ញុំ មិនស្គាល់រូប របស់ស្វាមីនោះ, តែនាងខ្ញុំ អាចស្គាល់ស្វាមី

នោះបាន ដោយការសម្លុតនៃដៃ" ។ បិតា របស់នាងនោះ បានប្រាប់ហើយដល់ពួកពាជបុរស ។ ឯពួកពាជបុរសទាំងនោះ ក៏បានក្រាបទូលហើយ ដល់ព្រះរាជា ។ ព្រះរាជាទ្រង់ធ្វើដូចជាមិនទ្រង់ជ្រាប ទ្រង់ត្រាស់ ថា " បើដូច្នេះ ពួកអ្នកទាំងឡាយ ចូរជាក់ស្តែនោះ នាងក្នុងវាំងននក្នុងព្រះលាននៃព្រះរាជា ហើយចោះប្រហោងវាំងនន ប្រមាណប៉ុនដៃ ស្រេចហើយ ឲ្យនាងចាប់ចោរ ដោយការសម្លុតនៃដៃ " ។ ពួកពាជបុរសទាំងនោះ បានធ្វើ យ៉ាងដូច្នោះហើយ ញុាំងពួកនគរទាំងមូលឲ្យប្រជុំគ្នាហើយ ។ នាងបញ្ចបាបានោះ បានចាប់ដៃមនុស្សដែលមកហើយ ។ លាតដៃ (ឲ្យចាប់) ពោលថា " បុរសនេះ គឺមិនមែនជាបុរសនុ៎ះទេ " ។ ពួកមនុស្សទាំងឡាយ ជាប់ចិត្ត ក្នុងសម្លុតរបស់នាង ដូចជាជាប់ចិត្ត ក្នុងសម្លុតដែលជាទិព្វ និកគិតថា " បើស្ត្រីរូបនេះ ជាអ្នកគួរ ដល់អាជ្ញា, ពួកយើង សូម្បីជាត្រូវបង់ពិនយ័ក្តី ចូលដល់ភាពជាទាសកម្មករក្តី ក៏នឹងធ្វើស្ត្រីនេះ ទុកក្នុងផ្ទះ " ដូច្នេះ មិនអាចដើម្បីចាកចេញទៅបានឡើយ ។ ខណៈនោះ ពួកពាជបុរស បានយកជំបងវាយមនុស្សទាំងនោះ ឲ្យចេញទៅហើយ ។ ពួកជនទាំងឡាយ មានឧបពាជជាដើម ក៏ដូចជាមនុស្សឆ្កួតគ្រប់ៗ គ្នា ។

គ្រានោះ ព្រះរាជា ទ្រង់ត្រាស់ថា " ទំនងដូចជាអាត្មាអញ

ទេដឹង‌ហ្ន៎ ? " យ៉ាងដូច្នេះហើយ ទើបទ្រង់បានលាតព្រះហស្តទៅ ។ នាងបញ្ចុបាបានោះ ចាប់ព្រះហស្តបានភ្លាមហើយ ក៏ស្រែកយ៉ាងខ្លាំង ថា " នាងខ្ញុំ ចាប់ចោរបានហើយ " ។ ព្រះរាជា ទ្រង់បានជ្រាប់ហើយ តាមសេចក្តីពិត ទ្រង់អភិសេកនាងបញ្ចុបាបានោះ ធ្វើជាព្រះអគ្គមហេសី ទ្រង់ព្រះរាជទានឥស្សរិយយស ដល់មាតាបិតារបស់នាងបញ្ចុបាបានោះ ចាប់តាំងអំពីពេលនោះមក ទ្រង់មិនបានក្រឡេកមើលនូវពួកស្ត្រីស្នំដទៃទៀតឡើយ ។ ពួកស្រីស្នំទាំងនោះ ខឹងចំពោះព្រះនាងបញ្ចុបាបានោះហើយ ស្វែងរកមើលកំហុស ។

ក្រោយមក ថ្ងៃមួយ ព្រះនាងបញ្ចុបាបានោះទ្រង់ព្រះសុបិននិមិត្តឃើញថា ព្រះនាងនឹងបានជាព្រះអគ្គមហេសី របស់ព្រះរាជាទាំងឡាយ ២ ព្រះអង្គ ទើបបានក្រាបទូល ដល់ព្រះរាជាហើយ ។

គ្រានោះ ពួកស្រីស្នំទាំងនោះ បានដឹងហេតុនោះហើយ ទើបបានឲ្យហើយ នូវសំណូក ដល់ពួកអ្នកទាយសុបិនទាំងឡាយ ។ ពួកអ្នកទាយសុបិនទាំងនោះ ត្រូវព្រះរាជាត្រាស់សួរហើយ ក៏បានក្រាបទូលថា " បពិត្រព្រះមហារាជ ការដែលព្រះនាងទេវី (ទ្រង់ព្រះសុបិន) ថា ទ្រង់បានគង់នៅលើ-ក ជំរីសសុទ្ធ គឺជាបុព្វនិមិត្តនៃការទ្រង់ចូលទិវង្គត របស់ព្រះអង្គ និង ការដែលព្រះនាងទេវី (ទ្រង់ព្រះសុបិន) ថា ទ្រង់ស្ថិតនៅលើ-ក ជំរី ទ្រង់ចាប់ពាល់ព្រះ

មង្គលត្ថទីបនីប្រែ

ចន្ទ ជាបុព្វនិមិត្តនៃការនាំមកនូវព្រះរាជាដែលជាបច្ចាមិត្រ ចំពោះព្រះអង្គ ” យ៉ាងដូច្នេះ, កាលបើព្រះរាជាអង្គនោះ ទ្រង់ត្រាស់សួរថា “ តើឥឡូវនេះ យើងគួរធ្វើ យ៉ាងដូចម្តេចទៅ ? ” ដូច្នេះហើយ, ទើបបានក្រាបទូលថា “ បពិត្រព្រះសម្មតិទេព ការដែលព្រះអង្គ ទ្រង់សម្លាប់ព្រះនាងទេវីនេះចោល មិនសមគួរទេ, (ប៉ុន្តែ) គួរតែដាក់ព្រះនាងទេវីទៅ ក្នុងទូកហើយ បណ្តែតចោលទៅ ក្នុងទន្លេ ” ។ ព្រះរាជា ទ្រង់បានដាក់ព្រះនាងទេវីនោះទៅ ក្នុងទូកហើយ ទ្រង់ត្រាស់បញ្ជា ឲ្យបណ្តែតទៅហើយ ក្នុងរាត្រី ព្រមទាំងព្រះក្រយោ-ហារ ព្រះភូសា និង គ្រឿងអលង្ការទាំងឡាយ ។

គ្រានោះ ព្រះរាជាមួយអង្គ ទ្រង់ព្រះនាមថា ទីបាវរិកៈ ទ្រង់ព្រះក្រសាលទឹក ខាងក្រោម ទ្រង់ទតព្រះនេត្រឃើញនូវព្រះនាងបញ្ចបាបានោះ ក្នុងទូកដែលអណ្តែកមក ទើបទ្រង់ត្រាស់សួរថា “ នាងដូចជាបិសាច តើឈ្មោះអ្វី ? ” ។ ព្រះនាងបញ្ចបាបានោះ ទ្រង់ធ្វើនូវការសើចហើយ ទ្រង់បានក្រាបទូលភាព នៃព្រះនាងជាព្រះអគ្គមហេសី នៃព្រះរាជាទ្រង់ព្រះនាមពកៈ ។ បានឮមកថា ព្រះនាងទេវីនោះ ទ្រង់បានប្រាកដហើយ ក្នុងសកលជម្ពូទ្វីបថា “ បញ្ចបាបា ” ។

គ្រានោះ ព្រះរាជា បានចាប់ព្រះនាងហើយ ទ្រង់សព្វព្រះ

ពណ៌នាអំពីការបូជា

រាជហឫទ័យ ដោយអំណាចនៃសេចក្តីត្រេកត្រអាល ក្នុងផស្សៈ ទ្រង់មិនបានធ្វើ សូម្បីនូវសេចក្តីសម្គាល់ ចំពោះពួកស្រីស្នំ ដទៃទៀតឡើយ ទ្រង់បានធ្វើព្រះនាងបញ្ចបាបានោះ ឲ្យជាព្រះអគ្គ-មហេសី ។

ព្រះរាជា ព្រះនាមពកៈ ទ្រង់ព្រះសណ្តាប់ហេតុនោះហើយ ទ្រង់ព្រះតម្រិះ ថា " អាត្មាអញ នឹងមិនឲ្យព្រះនាងបញ្ចបាបានោះ ដល់ព្រះរាជាព្រះនាមទីបាវរិកៈនោះទេ " ហើយទ្រង់ប្រមូលកងទ័ពទៅតាំងបន្ទាយ នៅត្រង់ព្រំប្រទល់ជាយដែន របស់ព្រះរាជាព្រះនាមទីបាវរិកៈនោះ ហើយទ្រង់បញ្ជូនព្រះរាជសាសន៍ ទៅមានសេចក្តី ថា " ព្រះបាទទីបាវរិកៈ នឹងទ្រង់ប្រទាន នូវព្រះជាយា ឬក៏ ការធ្វើសង្គ្រាម " ។

ចំណែកព្រះបាទទីបាវរិកៈ ទ្រង់បានស្តេចត្រៀម ដើម្បីនឹងធ្វើសង្គ្រាមស្រេចហើយ ។ ពួកអាមាត្យ របស់ព្រះរាជាទាំង ២ ព្រះអង្គ បានប្រឹក្សាគ្នា ថា " ការស្ងាប់ ព្រោះអាស្រ័យនូវស្ត្រី មិនគួរឡើយ, ព្រះនាងបញ្ចបាបានេះ រមែងដល់ព្រះរាជាព្រះនាមពកៈ ព្រោះព្រះអង្គជាព្រះរាជស្វាមី មកអំពីមុន, រមែងដល់ព្រះរាជាព្រះនាមទីបាវរិកៈ ព្រោះព្រះអង្គបានព្រះនាងលើទូក, ព្រោះហេតុនោះ ព្រះនាងបញ្ចបាបា ចូរទ្រង់គង់នៅ ក្នុងព្រះរាជដំណាក់

នៃព្រះរាជា មួយអង្គ ៗ មួយសប្តាហ៍ " ដូច្នេះហើយ ទើបបានក្រាបទូលឲ្យព្រះរាជាទាំង ២ ព្រះអង្គ ទ្រង់យល់ព្រមហើយ ។

ព្រះរាជាទាំង ២ ព្រះអង្គនោះ ទ្រង់មានព្រះរាជាហឫទ័យត្រេកអរ ទើបទ្រង់បានត្រាស់បញ្ជាឲ្យសាងព្រះនគរ ២ ត្រង់ទីកំពង់នៃព្រំដែន ទ្រង់គង់នៅហើយ ។ ព្រះនាងបញ្ចបាបានោះបានគ្រប់គ្រងភាពជាព្រះអគ្គមហេសី នៃព្រះរាជាទាំង ២ ព្រះអង្គ ដោយប្រការដូច្នេះឯង ។

រឿង ព្រះនាងបញ្ចបាបា មកក្នុងអដ្ឋកថាកុណាលជាតក ។

(រឿងនាងបទុមវតី)

(៦៦) ក្នុងអតីតកាល មានស្ត្រីម្នាក់ ក្នុងស្រុកមួយ ក្នុងទីក្រុងពារាណសី បានធ្វើការងារដោយដៃរបស់ខ្លួន ហើយចិញ្ចឹមជីវិត ។ ថ្ងៃមួយ នាងទៅខ្ទមស្រែ បានឃើញនូវផ្កាឈូកវែក តាំងពីព្រឹកព្រលឹម ក្នុងស្រះមួយ ត្រង់ចន្លោះផ្លូវ ទើបបានចុះទៅកាន់ស្រះនោះហើយ ក៏កាច់ផ្កាឈូកនោះឯង និង ស្លឹកឈូក ដើម្បីប្រយោជន៍ ដល់ការវេចខ្ចប់នូវលាជ បានក្តិចទង្រែវសាលីទាំងឡាយ ក្បែរភ្លឺស្រែ ហើយអង្គុយលើខ្ទម បែងចែកលាជហើយរាប់បាន ៥០០ គ្រាប់ ។

ក្នុងខណៈនោះ ព្រះបច្ចេកពុទ្ធមួយព្រះអង្គ បានចេញអំពី

ពណ៌នាអំពីការបូជា

និរោធសមាបត្តិ លើភ្នំគន្ធមាទន៍ បាននិមន្តមកឈរនៅ ក្នុងទីមិនឆ្ងាយពីនាង ។ នាងបានឃើញព្រះបច្ចេកពុទ្ធអង្គនោះហើយ បានកាន់យកផ្ការឈូក ព្រមទាំងលាជ ចុះមកអំពីខ្នមហើយ ដាក់លាជទៅ ក្នុងបាត្រ របស់ព្រះបច្ចេកពុទ្ធហើយ យកស្បឹកឈូកបិទបាត្រប្រគេនហើយ, កាលបើព្រះបច្ចេកពុទ្ធ និមន្តទៅបានបន្តិចហើយ, ទើបគិត ថា " ធម្មតាបព្វជិតទាំងឡាយ ជាអ្នកមិនត្រូវការ ដោយផ្ការឈូកទេ, អាត្មាអញ នឹងទៅយកផ្ការឈូកមកប្រដាប់ " ដូច្នេះហើយ បានទៅយកផ្ការឈូកពីព្រះហស្តព្រះបច្ចេកពុទ្ធ ហើយបានគិតសាជាថ្មីទៀត ថា " បើព្រះគុណម្ចាស់ដ៏ចំរើន នឹងមិនត្រូវការដោយផ្ការឈូកទេ, គង់នឹងមិនឲ្យដាក់លើបាត្រឡើយ, ព្រះគុណម្ចាស់ដ៏ចំរើន គង់នឹងត្រូវការដោយពិត " ដូច្នេះហើយ ក៏បានដើរទៅតាម ដាក់ផ្ការឈូក លើបាត្រ សូមខមាទោសព្រះបច្ចេកពុទ្ធហើយ ក៏បានធ្វើសេចក្តីប្រាថ្នាថា " បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ដោយផលានិសង្សនៃលាជ របស់នាងខ្ញុំទាំងនេះ នាងខ្ញុំ សូមឲ្យមានបុត្រ តាមចំនួននៃលាជ, ដោយផលានិសង្សនៃផ្ការឈូក សូមឲ្យផ្ការឈូកផុសឡើង ដើម្បីនាងខ្ញុំ គ្រប់ ៗ ជំហាន ក្នុងទីដែលនាងខ្ញុំបានកើតហើយ ៗ " ។

ព្រះបច្ចេកពុទ្ធ, កាលបើនាងមើលឃើញនុ៎ះឯង, ក៏បាន

មន្តលត្តនីបនីប្រែ

និមន្ត ទៅកាន់ភ្នំគន្ធមាទន៍ តាមអាកាស បានដាក់ផ្កាឈូកនោះ នៅក្បែរជណ្តើរ ដែលជាទីសម្រាប់ព្រះបច្ចេកពុទ្ធទាំងឡាយជាន់ ទីញុកភ្នំ ឈ្មោះនន្ទមូលកៈ ធ្វើជាគ្រឿងសម្រាប់ជូតជើង ។ ចំណែកឯ នាងបានកើតហើយ ក្នុងទេវលោក ព្រោះផលនៃកម្មនោះ ។ ក៏ចាប់តាំងពីពេលដែលនាងកើតហើយ ផ្កាឈូកដ៏ធំ បានផុសឡើងហើយ ដើម្បីនាងគ្រប់ ៗ ជំហាន ។ នាងបានច្យុត ចាកទេវលោកនោះហើយ បានមកកើត ក្នុងត្រពកនៃផ្កាឈូក ក្នុងស្រះឈូកមួយ ក្បែរជើងភ្នំ ។

តាបសមួយអង្គ នៅអាស្រ័យស្រះនោះ បាននិមន្តទៅកាន់ស្រះដើម្បីប្រយោជន៍ ដល់ការលប់លាងមុខ តាំងពីព្រឹកព្រលឹម ក៏បានឃើញផ្កា (ឈូក) នោះហើយ ក៏គិតថា " ផ្កា (ឈូក) នេះធំជាងផ្កាទាំងឡាយ ដ៏សេសសល់, ឯផ្កាដ៏សេសសល់ បានរីកហើយ, ផ្កានេះនៅក្រពុំតែម្តង, ក្នុងផ្កាឈូកនេះ គួរនឹងមានហេតុ " ដូច្នេះហើយ ក៏ចុះទៅកាច់ផ្កា (ឈូក) នោះមក ។ ផ្កាឈូកនោះ គ្រាន់តែតាបសនោះចាប់ប៉ុណ្ណោះ ក៏រីកឡើងហើយ ។ តាបសបានឃើញក្មេងស្រីដេក ខាងក្នុងត្រពកផ្កាឈូក ក៏ត្រឡប់បានសេចក្តីស្រឡាញ់ ដូចជាកូនស្រី ទើបនាំទៅកាន់បណ្ណសាលា ព្រមជាមួយ នឹងផ្កាឈូកទាំងនោះឯង ឲ្យនាងគេងហើយ ក្នុងគ្រែតូច ។

ពណ៌នាអំពីការបូជា

ពេលនោះ ទឹកដោះស្រស់ កើតឡើងហើយ ត្រង់ចង្អុលដៃ (របស់តាបស) ដោយបុញ្ញានុភាពរបស់នាង ។ តាបសនោះ, កាលបើផ្កានោះស្រពោនហើយ, ក៏បាននាំយកផ្កាថ្មីដទៃទៀតមកហើយ ឲ្យនាងកុមារិកានោះគេង ។

គ្រានោះ ផ្កាឈូកបានផុសឡើងហើយ ដើម្បីនាងកុមារិកានោះ គ្រប់ ៗ ជំហាន តាំងអំពីពេលដែលនាងអាច ដើម្បីនឹងលេង ដោយការរត់ទៅរត់មកបាន ។ តាបស បានដាក់ឈ្មោះឲ្យថា " នាងបទុមវតី " ។ ពណ៌សម្បុរនៃសរីរៈ របស់នាងបទុមវតីនោះប្រៀបដូចជាគំនរផ្កាថ្លាន់ ។ នាងមិនបានដល់នូវពណ៌សម្បុរ របស់ទេវតាទេ (តែ) បានកន្ទងនូវពណ៌សម្បុរ របស់មនុស្ស ។ អ្នកថ្មើរព្រៃ របស់ព្រះរាជាក្រុងពារាណសី បានឃើញនាងហើយ ក៏ទៅកាន់ក្រុងពារាណសីហើយ បានក្រាបទូលដល់ព្រះរាជា ។

ព្រះរាជា ទ្រង់ព្រះសណ្តាប់នូវហេតុនោះហើយ ទើបទ្រង់ស្តេចយាងទៅ ក្នុងអាស្រមបទនោះ ទ្រង់ថ្វាយបង្គំតាបសហើយ ទ្រង់បានគង់នៅ ក្នុងទីដ៏សមគួរ ទ្រង់នាំយកធីតា របស់តាបសមកហើយ ទ្រង់ស្តាបនានាង ក្នុងគំនរនៃកហាបណៈ ទ្រង់ធ្វើការអភិសេកហើយ ក្នុងទីនោះឯង ស្រេចហើយ ទ្រង់នាំនាងមកកាន់ព្រះនគរ របស់ព្រះអង្គ ចាប់តាំងពីពេលដែលព្រះអង្គស្តេចយាង

មង្គលត្ថទីបនីប្រែ

ត្រឡប់មកវិញហើយ ទ្រង់មិនបានក្រឡេកមើល នូវស្ត្រីដ៏សេស សល់ទាំងឡាយឡើយ ទ្រង់អភិរម្យ ជាមួយនឹងនាងបទុមវតីនោះ តែប៉ុណ្ណោះ ។ ក៏សត្វដែលកើតក្នុងផ្ទៃ បានកើតឡើងហើយ ដល់នាង ព្រោះការនៅរួមគ្នាទុំះឯង ។ ក៏កាលបើព្រះនាង មានព្រះគភ៌គ្រប់ហើយ, ក៏បានប្រសូត្រព្រះរាជឱរស ។ ព្រះមហាបទុម-កុមារ តែមួយព្រះអង្គគត់ អាស្រ័យនៅ ក្នុងព្រះគ៌ភ ។ ចំណែកឱរស ៤៩៩ ព្រះអង្គ ដែលនៅសេសសល់ ជាសំសេទជៈ បានប្រសូតហើយ ក្នុងពេលដែលព្រះមហាបទុមកុមារ ប្រសូតចាកព្រះគភ៌នៃព្រះមាតា ទ្រង់បន្ទំហើយ ។ ព្រះរាជកុមារ គ្រប់ព្រះអង្គនោះ ក្នុងពេលដែលព្រះអង្គ ទ្រង់មានព្រះជន្មាយុ ១៦ ព្រះវស្សា ទ្រង់បានព្រមគ្នាតែមួយ ទ្រង់ក្រសាល ក្នុងស្រះមង្គលបោក្ខរណីយ៍ ដែលដេរដាស់ទៅដោយផ្កាឈូក ក្នុងព្រះឧទ្យាន ទ្រង់ទតព្រះនេត្រឃើញផ្កាឈូកប្ដី រីកស្គុសស្គាយ និង ផ្កាឈូកចាស់ ជ្រុះធ្លាក់ហើយ ចាកទង ទើបទ្រង់ព្រះតម្រិះថា " សេចក្ដីចាស់ជរាគ្រាំគ្រា យ៉ាងនេះ រមែងមានដល់ផ្កាឈូកនេះ ដែលមិនមានវិញ្ញាណ គ្រប់គ្រង ដល់ម្ល៉ះទៅហើយ, ក៏នឹងចាំបាច់ពោលទៅធ្វើអ្វី ដល់សរីរៈរាងកាយរបស់ពួកយើងនោះ, ព្រោះថា សូម្បីសរីរៈរាងកាយ របស់ពួកយើងនេះ ក៏នឹងមានគតិយ៉ាងនេះ ដូចគ្នា

ដែរ " ហើយ បានកំណត់យកជាអារម្មណ៍ ក៏បានសម្រេចជាព្រះបច្ចេកពុទ្ធ ហោះទៅកាន់ញ្ជកភ្នំនន្ទមូលកៈតាមអាកាស អាស្រ័យនៅក្នុងទីនោះ ក្នុងពេលអស់ព្រះជន្មាយុ ក៏បានបរិនិព្វានហើយ ។

ឯព្រះនាងបទុមវតី ច្យុតចាកភពនោះហើយ កាលទ្រង់អន្ទោលទៅមក ក្នុងពុទ្ធុប្បាទនេះ បានជាព្រះឧប្បលវណ្ណាថេរី ។

រឿង នាងបទុមវតី មកក្នុងអដ្ឋកថាអបទានជាដើម ។

សូម្បីការបូជាព្រះបច្ចេកពុទ្ធ ក៏រមែងនាំមកនូវប្រយោជន៍សុខ ដោយប្រការដូច្នេះឯង ។

(រឿងស្ត្រី ៤ នាក់)

(៦៧) ក្នុងអតីតកាល មានស្ត្រី ៤ នាក់ ក្នុងព្រះនគរឈ្មោះបណ្ណកជៈ ក្នុងរដ្ឋឈ្មោះ ឯសិកា ក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាមកស្សបៈ បណ្តាស្ត្រីទាំង ៤ នាក់នោះ ស្ត្រីម្នាក់ បានឃើញកិកុមួយអង្គ ជាអ្នកត្រាច់បិណ្ឌបាត្រជាវត្ត ក៏មានចិត្តជ្រះថ្លាហើយ បានប្រគេនផ្ការាជព្រឹក្សមួយបាច់ ដល់ព្រះកិក្ខុរូបនោះ, ស្ត្រីម្នាក់ទៀត បានប្រគេនផ្កាឧប្បលខៀវមួយបាច់ ដល់ព្រះកិក្ខុរូបនោះ ដូចគ្នាដែរ, ស្ត្រីម្នាក់ទៀត បានប្រគេនផ្កាឧប្បលមួយបាច់ ដល់ព្រះកិក្ខុរូបនោះ ដូចគ្នាដែរ, ស្ត្រីម្នាក់ទៀត បានប្រគេននូវផ្កាម្ជិះក្រពុំ ដល់ព្រះកិក្ខុរូបនោះ ដូចគ្នាដែរ ។ បាច់នៃផ្ការាជព្រឹក្ស

មង្គលត្ថទីបនីប្រែ

ឈ្មោះថា ឥន្ទីវរកលាបៈ ។ ជាច់ នៃផ្កាឧប្បលខៀវ ឈ្មោះថា នីលុប្បលហត្ថកៈ ។ ជាច់នៃផ្កាឈូក ឈ្មោះថា បទុមហត្ថកៈ ។ ផ្កាម្ទិះក្រពុំ ដែលមានសម្បុរដូចភ្នុកជ័រី ឈ្មោះថា សុមនមកុលៈ ។

ស្ត្រីទាំង ៤ នាក់នោះ លុះបានធ្វើបុណ្យ មានប្រមាណប៉ុណ្ណេះ យ៉ាងដូច្នេះហើយ ក្រោយមក ក៏បានធ្វើកាលកិរិយាហើយ បានទៅកើត ក្នុងទេវលោកជាន់តាវត្តិង្ស ម្នាក់ ៗ មានស្រីទេពអប្សរ ១ ពាននាក់ជាបរិវារ ។ ទេវតាទាំង ៤ អង្គនោះ សោយនូវទិព្វសម្បត្តិ ក្នុងកពតាវត្តិង្សនោះ រហូតអស់កំណត់ នៃជន្មាយុហើយ អន្ទោលទៅមក ក្នុងកពតាវត្តិង្សនោះឯង ដោយវិបាកដែលសេសសល់ នៃកម្មនោះឯង សូម្បីក្នុងពុទ្ធុប្បាទនេះ ក៏បានកើតហើយ ក្នុងកពតាវត្តិង្សនោះ ម្តងទៀត ដូចគ្នាដែរ ។

គ្រានោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ និមន្តចារិកទៅកាន់ទេវលោក បាននិមន្តទៅកាន់កពតាវត្តិង្ស ឃើញនាងទេព-ធីតាទាំង ៤ អង្គនោះ ក្នុងវិមានទាំង ៤ ដែលស្ថិតនៅតាមលំដាប់គ្នា ក្នុងកពតាវត្តិង្សនោះហើយ ក៏បានសួរនូវបុព្វកម្ម របស់នាងទេពធីតាទាំងនោះ ដោយន័យដែលបានពោលមកហើយ ក្នុងចតុវិត្តីវិមាន ។ ចំណែក នាងទេពធីតាទាំងនោះ បានប្រាប់ហើយនូវបុព្វកម្ម របស់ខ្លួន ដល់ព្រះថេរៈ ។

ពណ៌នាអំពីការបូជា

គ្រានោះ ព្រះថេរៈ សំដែងនូវអនុបុព្វីកថាហើយ ក៏បានប្រកាសនូវសច្ចៈទាំងឡាយ ដល់នាងទេពធីតាទាំង ៤ អង្គនោះ ។ ក្នុងពេលចប់សច្ចៈ នាងទេពធីតាគ្រប់ទាំង ៤ អង្គនោះ ព្រមទាំងបរិវារ បានសម្រេចជាព្រះសោតាបន្នហើយ ។ ព្រះថេរៈ បានមកអំពីទេវលោកហើយ និមន្តទៅកាន់វត្តជេតពន បានក្រាបទូលហើយនូវរឿងរ៉ាងទាំងអស់នោះ ដល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់ធ្វើនូវសេចក្តីនោះ ឲ្យជាហេតុកើតឡើងហើយ ទ្រង់សំដែងនូវព្រះធម៌ ដល់បរិស័ទអ្នកប្រជុំគ្នាហើយ ក្នុងវត្តជេតពននោះ ។ ទេសនានោះ ជាទេសនាប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់មហាជន ដោយប្រការដូច្នេះឯង ។

រឿង ស្ត្រី ៤ នាក់ ចប់ ។

(រឿងនាងលោជទេពធីតា)

(៦៨) បានឮមកថា ក្នុងទីក្រុងរាជគ្រឹះ ស្ត្រីអ្នកក្សត្រិស្រេស្រូវសាលីម្នាក់ បានគ្តិចទង្សស្រូវសាលី ធ្វើលាជហើយ ចិញ្ចឹមជីវិត ។ ក៏នៅក្បែរទីក្រុងរាជគ្រឹះ មានគុហាមួយ ។ គុហានោះ ប្រាកដ ឈ្មោះថា " បិប្ផលិគុហា " ព្រោះមានដើមជីប៊ីមួយដើមនៅក្បែរមាត់ទ្វារ (គុហានោះ) ។

ព្រះមហាកស្សបៈ ដ៏មានអាយុ ចូលកាន់និរោធសមាបត្តិ

មង្គលត្ថទីបនីប្រែ

មួយសប្តាហ៍ ក្នុងគុហានោះ ចេញ (អំពីសមាបត្តិ) ហើយ ត្រួតមើលនូវទីកន្លែងដើម្បីត្រាច់បិណ្ឌបាត ដោយទិព្វចក្ខុ ក៏បានឃើញនូវស្ត្រីនោះហើយ បានយកជាត្រនិងចីវរ ទៅឈរនៅក្បែរស្រែ ។ ស្ត្រីនោះ ឃើញព្រះថេរៈហើយ ក៏មានចិត្តជ្រះថ្លា បានដាក់លាជទៅក្នុងជាត្រ របស់ព្រះថេរៈហើយទើបប្រាថ្នាថា " បពិត្រព្រះគុណម្ចាស់ដ៏ចំរើន នាងខ្ញុំគប្បីជាអ្នកមានចំណែកនៃធម៌ ដែលព្រះគុណម្ចាស់បានឃើញហើយ " ដូច្នេះ, កាលបើព្រះថេរៈនោះ ពោលថា " សូមឲ្យសេចក្តីប្រាថ្នា ដែលនាងប្រាថ្នាទុកហើយ យ៉ាងនេះចូរបានសម្រេចចុះ " ដូច្នេះហើយ ក៏បានចៀសចេញទៅ, កាលពិចារណាទាន របស់ខ្លួនត្រឡប់មកវិញ ត្រូវពស់មានពិសដ៏ពន្លឹកលូនចេញអំពីរន្ធមួយមកខាំ ត្រង់ផ្លូវដែលជាទីដើរទៅ លើភ្លឺស្រែហើយ ដួលធ្លាក់នៅក្នុងទីនោះឯង ធ្វើកាលៈហើយ ក៏បានទៅកើតក្នុងវិមានមាសដែលបរិបូណ៌ ទៅដោយនាងទេពអប្សរ ១ ពាន់ ក្នុងកពតាវត្តិង្ស មានអត្តភាព ៣ គាវុត ប្រដាប់ប្រដាដោយគ្រឿងអលង្ការសព្វគ្រប់ ដូចដេកលក់ហើយ ក្រោកឡើងដូច្នោះ ស្មៀកសំពត់ទិព្វមួយ ជណ្តប់សំពត់ទិព្វមួយ មានប្រវែង ១២ យោជន៍ ឈរត្រង់មាត់ទ្វារនៃវិមាន ដែលប្រដាប់ដោយផ្តិលមាស ដែលពោរពេញទៅ ដោយលាជមាស កំពុងតែសំយុងចុះមក ដើម្បី

ពណ៌នាអំពីការបូជា

ប្រកាសនូវបុព្វកម្ម បានត្រួតពិនិត្យមើលសម្បត្តិ របស់ខ្លួនហើយ ក៏ពិចារណាដោយទិព្វចក្ខុ ថា " សម្បត្តិនេះ អាត្មាអញ បានហើយ ព្រោះកម្មអ្វី ? " ក៏បានដឹង ថា " ព្រោះការប្រគេនលាជ ដល់ព្រះមហាកស្សបត្ថេរ " ។ នាងទេពធីតានោះ ប្រាថ្នានឹងធ្វើសម្បត្តិរបស់ខ្លួនឲ្យបានស្ថិតស្ថេរ ទើបបានយកអំបោសនិងកញ្ជើសម្រាប់ចោលសម្រាម ដែលធ្វើដោយមាស មកបោសសំអាតបរិវេណរបស់ព្រះថេរៈហើយ តាំងនូវទឹកសម្រាប់ផាន់ និង ទឹកសម្រាប់ប្រើប្រាស់ តាំងតែអំពីព្រឹកព្រលឹម ។

ព្រះថេរៈ បានសម្គាល់ ថា " កិច្ចនេះ នឹងជាកិច្ចដែលកិក្ខុកំលោះ និងសាមណេរអង្គខ្លះ បានធ្វើហើយ " ដូច្នេះ ក្នុងថ្ងៃទី ៣ លោកបានបើកទ្វារ ក្រឡេកមើល ក៏បានឃើញនាងទេពធីតានោះហើយ ទើបពោលថា " នែនាងទេពធីតា ចូរនាងចៀសចេញទៅ, ចូរនាងកុំធ្វើនូវភាវៈនៃអាត្មាភាពដែលព្រះធម្មកថិកទាំងឡាយ ក្នុងអនាគត ចាប់ផ្តិតជីវិចិត្រ គប្បីពោលថា បានឮថា នាងទេពធីតាមួយអង្គ បានធ្វើវត្តិប្រតិបត្តិហើយ ចូលទៅតាំងនូវទឹកសម្រាប់ផាន់ និងទឹកសម្រាប់ប្រើប្រាស់ ប្រគេនដល់ព្រះមហាកស្សបត្ថេរដូច្នេះឡើយ, ចាប់តាំងអំពីថ្ងៃនេះតទៅ ចូរនាងកុំគេចមក ទីនេះទៀតឡើយ " ។

មង្គលត្ថទីបនីប្រែ

នាងទេពធីតានោះបានសូមអង្វរករជាញយៗ ថា “បពិត្រព្រះគុណម្ចាស់ដ៏ចំរើន សូមព្រះគុណម្ចាស់ កុំធ្វើឲ្យនាងខ្ញុំវិនាសឡើយ” ។ ព្រះថេរៈ បានទះម្រាមដៃ ដោយពោលថា “នាងមិនចេះស្គាល់នូវប្រមាណ របស់នាងសោះឡើយ” ។

នាងទេពធីតានោះ ក៏មិនអាច ដើម្បីនឹងឈរនៅ ក្នុងទីនោះបាន ទើបបានឈរស្រែកទួញយំ ឮដ៏អាកាសថា “ បពិត្រព្រះគុណម្ចាស់ដ៏ចំរើន សូមព្រះគុណម្ចាស់ កុំធ្វើនូវសម្បត្តិ ដែលនាងខ្ញុំបានហើយ ឲ្យវិនាសសាបសូន្យឡើយ, សូមព្រះគុណម្ចាស់មេត្តាឲ្យដើម្បីនាងខ្ញុំបានធ្វើ នូវសម្បត្តិដែលនាងខ្ញុំបានហើយ ឲ្យបានស្ថិតស្ថេរគង់វង្សផង ។

ព្រះសាស្តា ទ្រង់គង់នៅ ក្នុងព្រះគន្ធកុដិ ក្នុងវត្តជេតពន ដែលមានចម្ងាយ ៤៥ យោជន៍ ទ្រង់ព្រះសណ្តាប់សំឡេងស្រែកយំ របស់នាងទេពធីតានោះហើយ ទើបទ្រង់បានផ្សាយព្រះរស្មីទៅដូចជាទ្រង់គង់នៅ ចំពោះមុខនាងទេពធីតានោះហើយ ទ្រង់មានព្រះតម្រាស់ថា “ នែនាងទេពធីតា កិរិយាធ្វើនូវការសង្រ្គមនុ៎ះឯង ជាការកិច្ច របស់កស្សបៈ ជាបុត្ររបស់តថាគត, ចំណែកកិរិយាសម្គាល់ថា នេះជាប្រយោជន៍របស់អាត្មាអញដូច្នេះហើយ បំពេញនូវបុណ្យនុ៎ះឯង ជាការកិច្ច របស់ជនទាំងឡាយអ្នកត្រូវការបុណ្យ

ពណ៌នាអំពីការបូជា

ព្រោះថា កិរិយាបំពេញបុណ្យ ជាហេតុនាំសេចក្តីសុខមកប្រគល់ឲ្យ ក្នុងលោកទាំង ២ មែនពិត " ដូច្នេះហើយ ទ្រង់ត្រាស់នូវគាថានេះ ក្នុងបាបវគ្គ នៃធម្មបទ ថា ៖

បើបុរសធ្វើបុណ្យ [1] គួរតែធ្វើបុណ្យនោះ ឱ្យបានរឿយៗ, គួរធ្វើសេចក្តីពេញចិត្ត ក្នុងបុណ្យនោះ, ព្រោះថា កិរិយាសន្សំបុណ្យ រមែងនាំសេចក្តីសុខមកប្រគល់ឱ្យ ។

បណ្តាបទទាំងនោះ ២ បទថា " **បុញ្ញញ្ចេ បុរិសោ** " មានសេចក្តីថា បើបុគ្គលគប្បីធ្វើបុណ្យ មួយជង្គង់មួយកាល ។ បទថា " **កយិរាថេនំ** " មានសេចក្តីថា បុគ្គលមិនគួរបន្ធូរបន្ថយ ដោយតាំងចិត្ត ថា " អាត្មាអញ បានធ្វើបុណ្យ មួយជង្គង់រួចហើយ, គ្រប់គ្រាន់ហើយ ដោយបុណ្យ មានប្រមាណប៉ុណ្ណេះ " ដូច្នេះទៀត ត្រូវតែធ្វើបុណ្យនោះ ឱ្យបានញឹកញយ ។ បទថា " **តម្ហិ** " មានសេចក្តីថា បុគ្គលគួរធ្វើសេចក្តីពេញចិត្ត គឺការបូលចិត្ត បានដល់សេចក្តីប្រឹងប្រែង ក្នុងបុណ្យនោះ សូម្បីក្នុងខណៈដែលធ្វើ នូវបុណ្យនោះ ឱ្យទាល់តែបាន ។ ព្រោះហេតុអ្វី ។ ព្រោះថា កិរិយាសន្សំ គឺការចំរើននូវបុណ្យ ឈ្មោះថា រមែងនាំឱ្យបានសេចក្តីសុខ ព្រោះនាំសេចក្តីសុខមកឱ្យ ក្នុងលោកនេះ និង លោកខាងមុខ ។

១- សុត្តន្តបិដក ភាគទី ៥២ ទំព័រទី ៤៧ ។

មង្គលត្ថទីបនីប្រែ

ក្នុងទីបញ្ចប់នៃព្រះគាថា នាងទេពធីតានោះ បានសម្រេចជាព្រះសោតាបន្ន ហើយក៏បានទៅកាន់ទេវលោក ។

រឿងនាងលោជទេពធីតា ចប់ ។

(៦៩) សូម្បីការបូជាព្រះសាវ័ក ក៏រមែងនាំប្រយោជន៍សុខមកឲ្យ និង ព្រះសាស្តា ក៏ទ្រង់បានត្រាស់សរសើរហើយដែរដូច្នេះ ។ ក្នុងដំណើរនុ៎ះ មានរឿងនេះ (ជាឧទាហរណ៍) ដូចតទៅ៖

បានឮមកថា ព្រាហ្មណ៍ជាឪពុកធំ របស់ព្រះសារីបុត្តត្ថេរម្នាក់អាស្រ័យនៅ ក្នុងទីក្រុងរាជគ្រឹះ ។ ព្រាហ្មណ៍នោះ បានស្តាប់អំពីលោកគ្រូអាចារ្យ ថា " បុគ្គលឯណា បានធ្វើទាន ដោយការបរិច្ចាគទ្រព្យមួយពាន់ រៀងរាល់ខែ, បុគ្គលនោះ នឹងនៅកាន់ព្រហ្មលោក, ព្រោះថា នេះ ជាផ្លូវនៃព្រហ្មលោក " ដូច្នេះហើយ ក៏ធ្វើយ៉ាងដូច្នោះ បានធ្វើហើយនូវទាន ដល់ពួកនិគ្រន្ថទាំងឡាយ ។

ព្រះថេរៈ បាននិមន្តទៅកាន់សំណាក់ របស់ព្រាហ្មណ៍នោះ ហើយ ស្តាប់នូវរឿងព័ាវទាំងនោះ ទើបពោលថា " ទាំងអ្នក ទាំងអាចារ្យ របស់អ្នក រមែងមិនដឹងផ្លូវទៅកាន់ព្រហ្មលោកទេ, ព្រះសាស្តា របស់ពួកយើង តែមួយព្រះអង្គគត់ប៉ុណ្ណោះ រមែងទ្រង់ជ្រាប, ម្នាលព្រាហ្មណ៍ ចូរអ្នកអញ្ជើញមកចុះ, អាត្មាភាព នឹងក្រាបទូល ឲ្យព្រះសាស្តាអង្គនោះ ទ្រង់ត្រាស់សំដែង នូវផ្លូវទៅ

ពណ៌នាអំពីការបូជា

(រឿងព្រាហ្មណ៍ជាឪពុកធំព្រះសារីបុត្ត)

កាន់ព្រហ្មលោកដល់អ្នក " ដូច្នេះហើយ ក៏បាននាំព្រាហ្មណ៍នោះ មកកាន់វត្តវេឡុវន ហើយបានក្រាបទូលដល់ព្រះសាស្តា ។

គ្រានោះ ព្រះសាស្តា ទ្រង់ត្រាស់សំដែង ដល់ព្រាហ្មណ៍នោះថា " ម្នាលព្រាហ្មណ៍ ការក្រេឡេកមើលនូវព្រះសាវ័ក របស់តថាគត ដោយចិត្តជ្រះថ្លាហើយ សូម្បីត្រឹមតែមួយស្រេបក់ក្តី ការថ្វាយនូវភិក្ខា ប្រមាណ ១ វែកក្តី រមែងមានផលច្រើន ជាងទានដែលអ្នកបានឲ្យហើយ យ៉ាងដូច្នោះ រហូតដល់ ១០០ ឆ្នាំ " ដូច្នេះហើយ កាលទ្រង់ប្រកាស នូវការបូជាដល់ព្រះសាវ័ក ទើបទ្រង់ត្រាស់នូវគាថានេះ ក្នុងសហស្សវគ្គ នៃធម្មបទ ថា ៖

បុគ្គលណា បូជា (លោកិយមហាជន) ដោយ [1] ទ្រព្យមួយពាន់ រាល់ខែ ៗ អស់ ១ រយឆ្នាំគត់, បំណែកបុគ្គលណា គប្បីបូជាបំពោះបុគ្គល ដែលមានខ្លួនអប់រំហើយ តែ ១ នាក់ សូម្បីតែមួយរំពេច, ការបូជានោះឯង ប្រសើរជាងការបូជា របស់អ្នកដែលបូជា អស់ ១ រយឆ្នាំនោះ, ការបូជា អស់ ១ រយឆ្នាំ មិនប្រសើរសោះឡើយ ។

*បណ្តាបទទាំងនោះ បទថា "**សហស្សេន** " ដោយការ*

១- សុត្តន្តបិដក ភាគទី ៥២ ទំព័រទី ៤៤ ។

មង្គលត្ថទីបនីប្រែ

បរិច្ចាគទ្រព្យ ១ ពាន់ ។ បទថា “ **យាជេថ** ” បានដល់ គប្បីឲ្យទាន ដល់លោកិយមហាជន ។ បទថា “ **សតំ** ” គឺ ប្រមាណ ១០០ ឆ្នាំ ។ បទថា “ **សមំ** ” គឺ អស់រដូវក្តៅ បានដល់ ១ ឆ្នាំ ។ មែនពិត រដូវក្តៅ (ឆ្នាំ) លោកហៅថា “ **សមា** ” ព្រោះអត្ថវិគ្រោះថា “ ញុំាងបុគ្គលឲ្យគិត គឺឲ្យប្រព្រឹត្តទៅ ក្នុងសេចក្តីនៃបទ ” ។ បទថា “ **ឯកញ្ច** ” បានដល់ ដោយទីបំផុតសូម្បីព្រះសោតាបន្ន ម្នាក់គត់ ។ បទថា “ **ភាវិតត្តានំ** ” បានដល់ អ្នកមានខ្លួនដែលចំរើន គឺមានចិត្តចំរើនឡើងហើយ ដោយអំណាច នៃគុណ ។ បទថា “ **បូជយេ** ” មានសេចក្តីថា គប្បីបូជា ដោយអំណាចការឲ្យនូវកិក្ខា ១ វែក ឬ នូវអាហារ ដែលល្មមតែញុំាងអត្តភាព ឲ្យប្រព្រឹត្តទៅ ឬក៏ នូវសំពត់សាដកសាច់ដ៏គ្រាត ។ បទថា “ **សេយ្យោ** ” មានសេចក្តីថា ការបូជាឯណា ដែលបុគ្គលក្រៅអំពីនោះ បានបូជាហើយ អស់ ១ រយឆ្នាំ, ប្រសើរជាងការបូជា របស់បុគ្គលអ្នកដែលបូជា ១ រយឆ្នាំនោះ ។ ម៉្យាងទៀត សព្ទថា “ **យញ្ច** ” ជានិបាត ចុះក្នុងសេចក្តីដែលបជិសេធ ។ អធិប្បាយថា “ ការបូជានោះ ដែលបុគ្គលនោះ បានបូជាហើយ រហូតដល់ ១ រយឆ្នាំ មិនមែនជារបស់ប្រសើរនោះឡើយ ” ។

ក្នុងពេលចប់គាថា ព្រាហ្មណ៍បានសម្រេចជាសោតាបន្ន ។

ពណ៌នាអំពីការបូជា

រឿងព្រាហ្មណ៍ដែលជាក្មួយ របស់ព្រះថេរៈ ក្តី រឿងព្រាហ្មណ៍ដែលជាសំឡាញ់ព្រះថេរៈ ក្តី អ្នកសិក្សាគប្បីរួមរួបយកមកផងដែរ ។

(៧០) អាមិសបូជា រមែងមានផលច្រើន យ៉ាងដូច្នេះឯង, មិនចាំបាច់ពោលទៅធ្វើអ្វី ដល់បតិបត្តិបូជានោះទៀយ, ព្រោះកុលបុត្រទាំងឡាយណា បូជានូវព្រះដ៏មានព្រះភាគ ដោយគុណទាំងឡាយរបស់ខ្លួន គឺការដល់នូវសរណៈ ការទទួលសិក្ខាបទនិង ការសមាទានអង្គនៃឧបោសថក្តី គឺចតុប្បារិសុទ្ធសីលក្តី, អ្នកណាទៅហ្ន៎ នឹងពណ៌នា នូវផលនៃការបូជា របស់កុលបុត្រទាំងនោះបាន ។ ក៏កុលបុត្រទាំងឡាយនោះ លោកពោលថា " រមែងបូជានូវព្រះតថាគត ដោយការបូជា យ៉ាងប្រសើរក្រៃលែង " ។

សួរថា " អ្នកណា ពោលហើយ ? " ។

ឆ្លើយថា " ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហើយ " ។

មែនពិត ព្រះមានព្រះភាគ ទ្រង់ព្រះបន្ទូ លើគ្រែតូច ដែលជាទីមហាបរិនិព្វាន ក្នុងកាលណា, ក្នុងកាលនោះ ពួកទេវតា ក្នុងមួយម៉ឺនចក្រវាល ប្រជុំគ្នាហើយ ក្នុងចក្រវាលនេះ បានបូជា ព្រះមានព្រះភាគហើយ ដោយគ្រឿងបូជាទាំងឡាយ មានកម្រងផ្កាទិព្វជាដើម ។

គ្រានោះ ព្រះមានព្រះភាគទ្រង់ព្រះបន្ទូហើយ ទ្រង់ទតព្រះ

មង្គលត្ថទីបនីប្រែ

នេត្រយើញនូវមហាសក្ការៈ ដែលបរិស័ទបានប្រជុំគ្នា តាំងតែអំពីផ្ទៃនៃប្រឹថពី រហូតដល់ក្របមាត់ទ្វារនៃចក្រវាល និង តាំងតែអំពីក្របមាត់ទ្វារ នៃចក្រវាល រហូតដល់ព្រហ្មលោក បានធ្វើហើយដោយសេចក្តីឧស្សាហ៍ ដ៏ធំ ទ្រង់សំដែងហើយ នូវសក្ការៈនោះ ដល់ព្រះអានន្ទត្ថេរ ដោយនយដែលពោលហើយ ក្នុងមហាបរិនិព្វានសូត្រ កាលទ្រង់សំដែងនូវភាវៈនៃព្រះអង្គ គឺបរិស័ទនោះ មិនធ្វើសក្ការៈហើយសូម្បីដោយសក្ការៈនោះឯង ទើបទ្រង់ត្រាស់ថា " ម្នាលអានន្ទ តថាគត ជាអ្នកឈ្មោះថា គឺបរិស័ទធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែងហើយ ដោយគ្រឿងសក្ការៈមានប្រមាណប៉ុណ្ណេះក៏ទេដែរ " ។ មានព្រះតម្រាស់ដែលព្រះមានព្រះភាគ ទ្រង់សំដែងទុកថា " ម្នាលអានន្ទ អកិនីហារ្យ គឺមិនមែនតថាគត បានក្រាបក្រោមព្រះបាទមូល របស់ព្រះពុទ្ធទ្រង់ព្រះនាមទីបង្ករ បានធ្វើហើយដើម្បីប្រយោជន៍ ដល់ផ្កាកម្រងគ្រឿងក្រអូប គ្រឿងជូរតន្ត្រី និង គ្រឿងប្រគុំសោះឡើយ, ជារមីទាំងឡាយ គឺមិនមែនតថាគត បំពេញហើយ ដើម្បីប្រយោជន៍ ដល់ផ្កាកម្រងជាដើមសោះឡើយ, ព្រោះហេតុនោះ តថាគត ទើបមិនឈ្មោះថាជាអ្នកគឺបរិស័ទ បានបូជាហើយ ដោយគ្រឿងបូជា មានប្រមាណប៉ុណ្ណេះសោះឡើយ " ។

ពណ៌នាអំពីការបូជា

សួរថា " ក៏នៅក្នុងបាលីដទៃទៀត ព្រះមានព្រះភាគ ទ្រង់ត្រាស់ពណ៌នានូវវិបាកនៃការបូជា ដែលបុគ្គលកាន់យកនូវគ្រឿងសក្ការៈ សូម្បីត្រឹមតែផ្កាកប្បាស មួយទង់ហើយ នឹករលឹកនូវពុទ្ធគុណទាំងឡាយ (ជាអារម្មណ៍) បានធ្វើហើយ ថា ជាវិបាកសូម្បីតែព្រះពុទ្ធញ្ញាណ ក៏ទ្រង់កំណត់មិនបានឡើយ ព្រោះហេតុអ្វី បានជាក្នុងបាលីនេះ ទើបទ្រង់បដិសេធ នូវការបូជាដ៏ធំ យ៉ាងដូច្នេះទៅវិញ " ។

ឆ្លើយថា " ព្រោះទ្រង់អនុគ្រោះ ដល់បរិស័ទផង ទ្រង់មានព្រះបំណងដើម្បីនឹងឲ្យព្រះសាសនាស្ថិតនៅបានយឺនយូរផង " ។

មែនពិត បើព្រះដ៏មានព្រះភាគ មិនទ្រង់បដិសេធ យ៉ាងដូច្នេះទេនោះ, ក្នុងអនាគតកាល ពួកភិក្ខុទាំងឡាយ ក៏នឹងមិននាំគ្នាបំពេញសីល និងសមាធិជាដើម ឲ្យបានបរិបូណ៌ និង មិនញុំងវិបស្សនា ឲ្យកាន់យកនូវគតិ បានត្រឹមតែគ្រាច់ចរទៅ បបួលពួកឧបដ្ឋាក ឲ្យធ្វើតែការបូជាប៉ុណ្ណោះឯង ។ ក៏ធម្មតាអាមិសបូជានោះ មិនអាចដើម្បីនឹងទ្រទ្រង់ទុក នូវព្រះពុទ្ធសាសនាបាន អស់កាលសូម្បីត្រឹមតែកិរិយាហុត នូវបបរមួយគ្រួកឡើយ, ពិតមែនហើយ ព្រះវិហារ ១ ពាន់ ខ្នង ដូចជាព្រះមហាវិហារ ក្តី ចេតិយ ១ ពាន់អង្គ ដូចជាព្រះមហាចេតិយ ក្តី ក៏មិនអាច ដើម្បីនឹងទ្រទ្រង់

មង្គលត្ថទីបនីប្រែ

នូវព្រះសាសនាបានឡើយ, បុគ្គលណាធ្វើ ផលានិសង្ស នឹងមាន ដល់បុគ្គលនោះតែប៉ុណ្ណោះ ។ ចំណែកសម្មាបដិបត្តិ ជាការបូជា ដ៏សមគួរ ដល់ព្រះសាស្តា ។ ព្រោះថា សម្មាបដិត្តិ នោះ ព្រះអង្គ ទ្រង់ប្រាថ្នាហើយផង រមែងអាច ដើម្បីនឹងទ្រទ្រង់ នូវព្រះសាសនាបានផង ។ ព្រោះហេតុនោះ ព្រះសាស្តា ទ្រង់បដិសេធ នូវអាមិសបូជាហើយ កាលទ្រង់អនុញ្ញាតនូវបដិបត្តិបូជា ក្រៅពីនេះ ទើបទ្រង់ត្រាស់ថា " ម្នាលអានន្ទ បុគ្គលណាមួយ ទោះជា ភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ជាអ្នកប្រតិបត្តិនូវធម៌ ដ៏សមគួរដល់ធម៌ ជាអ្នកប្រតិបត្តិ ដោយត្រឹមត្រូវ ជាអ្នកប្រព្រឹត្តតាមធម៌ជាប្រក្រតី, បុគ្គលនោះ ឈ្មោះថា រមែងធ្វើសក្ការៈ ធ្វើនូវសេចក្តីគោរព រាប់អាន បូជា នូវព្រះតថាគត ដោយការបូជាដ៏ប្រសើរ, ម្នាលអានន្ទ ព្រោះហេតុនោះ អ្នកទាំងឡាយ ក្នុងព្រះធម្មវិន័យនេះ គប្បីសិក្សាយ៉ាងដូច្នេះថា អាត្មាអញទាំងឡាយ នឹងជាអ្នកប្រតិបត្តិ នូវធម៌ ដ៏សមគួរដល់ធម៌ ជាអ្នកប្រតិបត្តិ ដោយត្រឹមត្រូវ ជាអ្នកប្រតិបត្តិធម៌ ជាប្រក្រតី យ៉ាងដូច្នេះ, ម្នាលអានន្ទ អ្នកទាំងឡាយ គប្បីសិក្សា យ៉ាងដូច្នេះឯង " ។

(៧១) នយដែលមក ក្នុងអដ្ឋកថាមហាបរិនិព្វានសូត្រ ថា គប្បីជ្រាបសេចក្តីវិនិច្ឆ័យ ក្នុងព្រះពុទ្ធវចនៈនោះ (ដូចតទៅនេះ) ៖

ពណ៌នាអំពីការបូជា

ការប្រតិបត្តិ ជាចំណែកខាងដើម ដែលសមគួរ ដល់លោកុត្តរធម៌ ៩ ប្រការ ឈ្មោះថា ការប្រតិបត្តិ នូវធម៌ ដ៏សមគួរដល់ធម៌ ។ កិរិយាប្រតិបត្តិ ជាចំណែកខាងដើមនោះ ដោយសេចក្តី បានដល់ ព្រះបញ្ញត្តិខាងផ្លូវមារយោទ គឺសីល និង ការសមាទានធុតង្គ បានដល់ សម្មាបដិបត្តិ រហូតដល់គោត្រភូញ្ញាណនុ៎ះឯង ។ បុព្វភាគ-បដិបត្តិនោះឯង ព្រះអង្គត្រាស់ហៅថា " ត្រឹមត្រូវ " ព្រោះជាផ្លូវប្រតិបត្តិដ៏សមគួរ ។ បុគ្គលណា រមែងប្រតិបត្តិ ប្រព្រឹត្ត បំពេញ បុព្វភាគបដិបត្តិនោះ, បុគ្គលនោះ ព្រះអង្គទ្រង់ត្រាស់ហៅថា " ជាអ្នកប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ ជាអ្នកប្រតិបត្តិ ដោយត្រឹមត្រូវ ជាអ្នកប្រព្រឹត្ត តាមធម៌ជាប្រក្រតី " ។ ព្រោះហេតុ បព្វជិត អ្នកស្ថិតនៅ ក្នុងសេចក្តីមិនគោរព ៦ យ៉ាង ប្រព្រឹត្តល្មើសព្រះបញ្ញត្តិ ចិញ្ចឹមជីវិត ដោយអនេសនា ទើបមិនឈ្មោះថា ជាអ្នកប្រតិបត្តិ នូវធម៌ ដ៏សមគួរដល់ធម៌ឡើយ ។ បព្វជិត អ្នកដែលមិនប្រព្រឹត្តល្មើសនូវសិក្ខាបទ ដែលព្រះមានព្រះភាគ ទ្រង់បានបញ្ញត្តហើយ ដល់ខ្លួន គ្រប់ទាំងអស់នោះ សូម្បីបន្តិចបន្តួច ចិញ្ចឹមជីវិត ដោយធម៌ ទើបបានឈ្មោះថា ជាអ្នកប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ។

ចំណែកគ្រហស្ថ អ្នកធ្វើនូវពៀរ ៥ យ៉ាង និង អកុសល-កម្មបថ ១០ ប្រការ មិនបានឈ្មោះថា ជាអ្នកប្រតិបត្តិ នូវធម៌

មង្គលត្ថទីបនីប្រែ

សមគួរដល់ធម៌ទេ ។ តែបុគ្គលណា ជាអ្នកធ្វើឲ្យបានបរិបូណ៌ ក្នុងសរណៈ និង សីលទាំងឡាយ រក្សាឧបោសថ ១ ខែ ៨ ដង ឲ្យទាន ធ្វើការបូជា ដោយគ្រឿងក្រអូប និង ការបូជា ដោយផ្កាកម្រង ទំនុកបំរុងនូវមាតាបិតា និង ពួកសមណព្រាហ្មណ៍ អ្នកតាំងនៅក្នុងធម៌, បុគ្គលនេះ ទើបបានឈ្មោះថា ជាអ្នកប្រតិបត្តិនូវធម៌ ដ៏សមគួរដល់ធម៌ ។ ក៏ព្រះមានព្រះភាគ កាលទ្រង់ត្រាស់ថា "ដោយការបូជាយ៉ាងប្រសើរ" ដូច្នេះ ក៏ឈ្មោះថាទ្រង់សំដែងនូវអធិប្បាយនេះ ថា "ធម្មតា និពាមិសបូជា រមែងអាច ដើម្បីនឹងទ្រទ្រង់នូវព្រះសាសនា របស់តថាគតបាន, ព្រោះថា បរិស័ទទាំង ៤ នេះ នឹងបូជានូវតថាគត ដោយបដិបត្តិបូជានេះ ដរាបណា, ព្រះសាសនា របស់តថាគត ក៏នឹងរុងរឿង ប្រៀបដូចជាព្រះចន្ទពេញបូណ៌មី ត្រង់កណ្តាលនភាល័យ ដរាបនោះ" ។

សូម្បីក្នុងកាលមុន អំពីពេលនេះ ក៏ព្រះមានព្រះភាគ ទ្រង់សរសើរ នូវបដិបត្តិបូជា ដូចគ្នាដែរ ។ ក្នុងដំណើរនោះ មានរឿងទាំងនេះ (ជាឧទាហរណ៍) ៖

(រឿងព្រះពិស្សត្ថេរ)

(៧២) ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា " ម្នាលភិក្ខុទាំងឡាយ តាំងតែពីពេលនេះតទៅ ដោយកាលកន្លងទៅបាន ៤ ខែ

ពណ៌នាអំពីការបូជា

តថាគត និងបរិនិព្វាន " ដូច្នេះ ក្នុងកាលណា, ក្នុងកាលនោះ ពួកភិក្ខុជាបុថុជ្ជន មិនអាចដើម្បីនឹងទប់ទល់ នូវទឹកភ្នែកបានឡើយ ។ ពួកភិក្ខុទាំងនោះ ជាពួក ៗ ប្រឹក្សាគ្នា ថា "តើពួកយើង នឹងធ្វើយ៉ាងដូចម្តេចទៅហ្ន៎ " ហើយបាននៅ ក្នុងសំណាក់នៃព្រះសាស្តា ។

គ្រានោះ ព្រះថេរៈ ១ រូបឈ្មោះ តិស្សៈ គិតថា "បានឮថា ដោយកាលកន្លងទៅ ៤ ខែ ទៀត ព្រះសាស្តានឹងទ្រង់បរិនិព្វាន, ក៏អាត្មាអញ ជាអ្នកមានរាគៈមិនទាន់ទៅប្រាសហើយ, កាលបើព្រះសាស្តា ទ្រង់ជរមាននៅឡើយ, ការដែលអាត្មាអញ ឈោងយកនូវព្រះអរហត្តឲ្យបានទើបសមគួរ " ហើយក៏មិនបាននិមន្តទៅកាន់សំណាក់របស់ភិក្ខុទាំងនោះ និង មិនធ្វើនូវការសន្ទនា ប្រាស្រ័យជាមួយ នឹងអ្នកណាមួយឡើយ បាននៅតែមួយអង្គឯងប៉ុណ្ណោះ ក្នុងឥរិយាបថទាំង ៤ ។ ពួកភិក្ខុទាំងឡាយ បានក្រាបទូលកិរិយារបស់ព្រះតិស្សត្ថេរនោះ ដល់ព្រះសាស្តាហើយ ។

ព្រះសាស្តា ទ្រង់ឲ្យនិមន្តព្រះតិស្សត្ថេរនោះ មកហើយ ទ្រង់ត្រាស់សួរ ទ្រង់ព្រះសណ្តាប់សេចក្តីនោះហើយ ទើបទ្រង់ប្រទានសាធុការពរ ដល់ព្រះតិស្សត្ថេរនោះហើយ ទ្រង់ត្រាស់ ថា " ម្នាលភិក្ខុទាំងឡាយ បុគ្គលណា មានសេចក្តីស្រឡាញ់ ចំពោះតថាគត, បុគ្គលនោះ គប្បីដូចជាព្រះតិស្សត្ថេរនុ៎ះឯង, ព្រោះថា

មង្គលត្ថទីបនីប្រែ

ជនទាំងឡាយសូម្បីធ្វើនូវការបូជា ដោយវត្ថុទាំងឡាយមានគ្រឿងក្រអូប និង ផ្កាកម្រងជាដើម រមែងមិនឈ្មោះថា បូជានូវតថាគត ដោយពិតប្រាកដឡើយ, ចំណែកឯ ជនទាំងឡាយណា ជាអ្នកប្រតិបត្តិនូវធម៌ ដ៏សមគួរដល់ធម៌ទុំៈឯង ទើបបានឈ្មោះថា រមែងបូជានូវតថាគត" ដូច្នេះហើយ ទើបត្រាស់គាថានេះ ក្នុងសុខវគ្គនៃធម្មបទថា ៖

> ភិក្ខុ ធឹករសនៃវិវេកផង រសនៃព្រះនិព្វានដែល [1] ជាទីរម្ងាប់កិលេសផង ធឹករសនៃបីតិ ដែលកើតអំពីធម៌ផង ទើបជាអ្នកមិនមានសេចក្តីក្រវល់ក្រវាយ មិនមានសេចក្តីសៅហ្មងឡើយ ។

*បណ្តាបទទាំងនោះ បទថា "**បវិវេករសំ**" គឺ របស់ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់, អធិប្បាយថា "សេចក្តីសុខ ដែលកើតអំពីភាវៈនៃបុគ្គលម្នាក់ឯង" ។ បទថា "**បិត្វា**" មានសេចក្តីថា ព្រះខីណាស្រព អ្នកធ្វើកិច្ច មានការកំណត់ដឹង នូវទុក្ខជាដើម ផឹកហើយ (នូវរសវិវេក) ដោយអំណាចការធ្វើឲ្យជាក់ច្បាស់ ដោយអារម្មណ៍ ។ បទថា "**ឧបសមស្ស**" បានដល់ព្រះនិព្វាន ដែលជាទីរម្ងាប់កិលេស ។ បទថា "**និទ្ទរោ**" មាន*

១- សុត្តន្តបិដក ភាគទី ៥២ ទំព័រទី ៦៤ ។

ពណ៌នាអំពីការបូជា

សេចក្តីថា ឈ្មោះថា ជាអ្នកមិនមានសេចក្តីក្រវល់ក្រវាយ ព្រោះមិនមានសេចក្តីក្រវល់ក្រវាយ គឺ រាគៈ ជាដើម ព្ធដ៏ខាងក្នុង និង ឈ្មោះថា ជាអ្នកមិនមានបាប ព្រោះមិនមានបាប គឺរាគៈជាដើម ព្រោះផឹក នូវរសទាំងពីរយ៉ាងនោះ ។ បទថា “ ***ធម្មប្បីតិរសំ*** *” បានដល់ រសពោលគឺសេចក្តីឆ្អែកចិត្ត ដែលកើតឡើងហើយ ដោយអំណាចលោកុត្តរធម៌ ៩ ប្រការ ។ បទថា “* ***បិវំ*** *” ប្រែថា ការផឹក ។*

ក្នុងអវសានគាថា ព្រះតិស្សត្ថេរ ក៏បានសម្រេចព្រះអរហត្ត ។

រឿង ព្រះតិស្សត្ថេរ ចប់ ។

(រឿងព្រះអត្តទត្តត្ថេរ)

(៧៣) ឯព្រះអត្តទត្តត្ថេរ បានគិតហើយ យ៉ាងដូច្នេះដែរ មិននិមន្តទៅកាន់សំណាក់ នៃភិក្ខុទាំងឡាយឡើយ នៅតែម្នាក់ឯង ប៉ុណ្ណោះ ប្រតិបត្តិហើយ ដើម្បីបានសំរេចព្រះអរហត្តដោយពិត ។ ពួកភិក្ខុទាំងឡាយ បានក្រាបទូលសេចក្តីនោះ ដល់ព្រះសាស្តា ។

ព្រះសាស្តា ទ្រង់បានប្រទានសាធុការ ដល់ព្រះថេរៈនោះ ហើយទ្រង់ត្រាស់ថា “ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា មានសេចក្តីស្រឡាញ់ចំពោះតថាគត, ភិក្ខុនោះ គប្បីដូចជាព្រះអត្តទត្តត្ថេរចុះ, ជនទាំងឡាយ សូម្បីបូជាតថាគត ដោយគ្រឿងបូជាទាំងឡាយ

មង្គលត្ថទីបនីប្រែ

មានគ្រឿងក្រអូបជាដើម ក៏មិនឈ្មោះថា បូជាដែរ, ចំណែកឯ ជនទាំងឡាយដែលបូជានូវតថាគត ដោយការប្រតិបត្តិនូវធម៌ ដ៏សមគួរដល់ធម៌ ទើបបានឈ្មោះថា បូជាតថាគតពិតមែន ” ដូច្នេះហើយ ទ្រង់ត្រាស់ នូវព្រះគាថានេះ ក្នុងអត្តវគ្គ នៃធម្មបទ ថា ៖

បុគ្គល កុំគប្បីធ្វើប្រយោជន៍ខ្លួនឲ្យវិនាសឡើយ [(១)] ព្រោះប្រយោជន៍ របស់អ្នកដទៃ សូម្បីប្រើន, បើដឹងច្បាស់ នូវប្រយោជន៍ខ្លួនហើយ គប្បីជាអ្នកឃ្លាំឃាយ ក្នុងប្រយោជន៍របស់ខ្លួនឲ្យបាន ។

*បណ្តាបទទាំងនោះ បទថា “ **អត្តទត្ថំ** ” គឺ ប្រយោជន៍នៃខ្លួន សូម្បីមានប្រមាណមួយកាកណិក ។ ពីរបទថា “ **បរត្ថេន ពហុនាបិ** ” គឺ ព្រោះប្រយោជន៍ របស់អ្នកដទៃ សូម្បីមានប្រមាណមួយពាន់ ។ បទថា “ **ន ហាបយេ** ” មានសេចក្តីថា បុគ្គល មិនគួរធ្វើឲ្យវិនាសឡើយ, សម្រាប់គ្រហស្ថ ជាមុនសិនប្រយោជន៍របស់ខ្លួន សូម្បីមានប្រមាណមួយកាកណិក ក៏រមែងញុំាងរបស់ដែលគួរទំពាស៊ី និង របស់ដែលគួរបរិភោគប្រើប្រាស់ឲ្យសម្រេចបាន, ប្រយោជន៍ របស់អ្នកដទៃ មិនធ្វើឲ្យសម្រេចបានឡើយ ។*

១- សុត្តន្តបិដក ភាគទី ៥២ ទំព័រទី ៥៧ ។

ពណ៌នាអំពីការបូជា

ក៏ពាក្យថា ប្រយោជន៍របស់ខ្លួននេះ ព្រះមានព្រះភាគ មិនទ្រង់ត្រាស់ហើយដោយព្រះបំណងដូច្នេះឡើយ ទ្រង់ត្រាស់ដោយយកកម្មដ្ឋានជាប្រធាន ។ ព្រោះហេតុនោះ ភិក្ខុមិនគួរធ្វើកិច្ច មានការជួសជុលព្រះចេតិយជាដើម ដែលកើតឡើងហើយ ដល់ព្រះសង្ឃ ឬ វត្ត មានឧបជ្ឈាយវត្តជាដើម ឲ្យវិនាសសាបសូន្យទៅដោយគិត ថា " អាត្មាអញ នឹងមិនធ្វើនូវប្រយោជន៍ របស់ខ្លួនឲ្យវិនាសឡើយ " ។ ព្រោះថា ភិក្ខុ កាលបំពេញអភិសមាចារិកវត្ត ប៉ុណ្ណោះ ទើបធ្វើឲ្យជាក់ច្បាស់ នូវអរិយផលជាដើមបាន, ព្រោះហេតុនោះ ប្រយោជន៍នេះឯង ឈ្មោះថា ជាប្រយោជន៍ របស់ខ្លួនមែនពិត ។

ក៏ភិក្ខុរូបណា ជាអ្នកប្រារព្ធវិបស្សនា ដ៏ខ្ជាំងក្លា ត្រាច់ទៅប្រាថ្នានូវការត្រាស់ដឹង ដោយគិតថា " ក្នុងថ្ងៃនេះឯង ។ " ដូច្នេះ, ភិក្ខុរូបនោះ គប្បីធ្វើសូម្បីវត្ត មានឧបជ្ឈាយវត្តជាដើម ឲ្យវិនាសទៅហើយ ធ្វើកិច្ចរបស់ខ្លួន ដោយពិត " ។

បាទគាថាថា " ***អត្តទត្ថមភិញ្ញាយ*** " គឺសម្គាល់ប្រយោជន៍របស់ខ្លួន យ៉ាងដូច្នេះថា "ប្រយោជន៍នេះ គឺជាប្រយោជន៍ របស់ខ្លួនអញ " ។ បាទគាថា ថា " ***សទត្ថប្បសុតោ សិយា*** " មានសេចក្តីថា ភិក្ខុ គប្បីជាអ្នកខ្ពស់ខ្ពាយខ្នះខ្នែង ក្នុងប្រយោជន៍ដែល

ជារបស់ខ្លួននោះ ។

ក្នុងទីបញ្ចប់នៃគាថា ចំណែកព្រះអត្តទត្ថត្ថេរ បានសម្រេចហើយ នូវព្រះអរហត្ត ដោយប្រការដូច្នេះឯង ។

រឿង ព្រះអត្តទត្ថត្ថេរ ចប់ ។

សូម្បីរឿង របស់ព្រះធម្មាវាមត្ថេរ ក្នុងកិក្ខីវគ្គ នៃធម្មបទ ក៏គប្បីប្រមូលរួបរួម យកមកផងដែរ ។

(៧៤) បតិបត្តិបូជា ប៉ុណ្ណោះ គប្បីឃើញថា " ជាការបូជាដែលព្រះសាស្តាទ្រង់បានត្រាស់សរសើរហើយ និង ជាបូជាយ៉ាងប្រសើរខ្ពង់ខ្ពស់ " ដោយប្រការដូច្នេះឯង ។

បពិត្រជិត អ្នកបូជា ដោយអាមិស មិនឈ្មោះថា ជាអ្នកប្រតិបត្តិនូវធម៌ ដ៏សមគួរដល់ធម៌ទេ្បីយ យ៉ាងណាមិញ, គ្រហស្ថ មិនមែនជាអ្នក យ៉ាងដូច្នេះទេ្បីយ ។ ព្រោះថា គ្រហស្ថ សូម្បីជាអ្នកបូជា ដោយអាមិស ក៏ឈ្មោះថា ជាអ្នកប្រតិបត្តិនូវធម៌ ដ៏សមគួរដល់ធម៌ ។ ព្រោះហេតុនោះ ក្នុងអធិការនៃការប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ របស់គ្រហស្ថ ក្នុងអដ្ឋកថាមហាបរិនិព្វានសូត្រ ទើបលោកពោលថា " គ្រហស្ថតែងឲ្យទាន, ធ្វើនូវការបូជាដោយគ្រឿងក្រអូប និង ការបូជាដោយផ្កាកម្រង " ។ ក៏គ្រហស្ថ អ្នកបូជា ដោយអាមិស ឈ្មោះថា ធ្វើតាមឱវាទដែលព្រះសាស្តាទ្រង់

ពណ៌នាអំពីការបូជា

ជានប្រទានហើយ ដល់ខ្លួន និង អ្នកដែលធ្វើតាមឱវាទ ឈ្មោះថា តែងបូជា, ព្រោះហេតុនោះ គ្រហស្ថនោះ ទើបឈ្មោះថារមែងបូជា ព្រះសាស្តាដោយគុណរបស់ខ្លួន ពោលគឺការធ្វើអាមិសបូជាដែល ខ្លួនធ្វើឲ្យសមគួរ ដល់ព្រះឱវាទ របស់ព្រះសាស្តា ដូច្នេះឯង ។

(៧៥) បុគ្គលណា រមែងបូជា ធ្វើសក្ការៈ សរសើរ នូវ សប្បុរសទាំងឡាយ មានព្រះពុទ្ធជាដើម ជាអ្នកប្រសើរខ្ពង់ខ្ពស់ ចូលដល់ភាពជាអ្នកគួរបូជា តាមលំដាប់ ដោយការមិនសេពគប់ នូវជនពាល និង ដោយការសេពគប់នូវបណ្ឌិត ដូចបានពោល ហើយ, បុគ្គលនោះ រមែងប្រសព្វនូវប្រយោជន៍សុខ ដូចពណ៌នា មកនេះឯង, បុគ្គលណា រមែងបូជានូវពួកអសប្បុរស ដែលខុស ផ្សេងគ្នា អំពីពួកសប្បុរសទាំងនោះ, បុគ្គលនោះ រមែងបានជួប ប្រទះ នូវសេចក្តីទុក្ខ ។

ក្នុងដំណើរនោះ មានរឿងទាំងនេះ (ជាឧទាហរណ៍) ៖

(ព្រះបាទអជាតសត្រូវបូជាភិក្ខុទេវទត្ត)

(៧៦) បានឮថា ក្នុងគ្រាមួយ ភិក្ខុទេវទត្ត នៅក្នុងទីស្ងាត់ គិត ថា " ភិក្ខុទាំងឡាយនេះ យ៉ាងដូច្នេះ គឺ បរិស័ទរបស់ព្រះថេរៈ ឈ្មោះសារីបុត្រ, បរិស័ទ របស់ព្រះមោគ្គល្លាន ជាអ្នកមានធុរៈ ផ្សេង ៗ គ្នា, ចំណែកឯ អាត្មាអញ និងនាំនូវធុរៈ របស់ពួកគណៈ

មង្គលត្ថទីបនីប្រែ

មួយដែរ, តែបើប្រាសចាកលាភហើយ អាត្មាអញ ក៏មិនអាចនឹងញុំាងបរិស័ទ ឲ្យកើតឡើងបានឡើយ, ណ្ហើយចុះ អាត្មាអញ នឹងរួមជាមួយគ្នា នឹងព្រះបាទអជាតសត្រូវ ហើយនឹងញុំាងលាភ ឲ្យកើតឡើង " ដូច្នេះហើយ ក៏បានញុំាងព្រះបាទអជាតសត្រូវ ឲ្យទ្រង់ជ្រះថ្លាហើយ ដោយឥទ្ធិបាដិហារ្យ ដោយនយដែលមកហើយ ក្នុងសង្គីតេទក្ខន្ធកៈ ។

ព្រះបាទអជាតសត្រូវនោះ ទ្រង់បានជ្រះថ្លាហើយ ចំពោះព្រះទេវទត្តនោះ ទ្រង់លើកតម្កើង នូវព្រះទេវទត្តនោះ ដែលជាអស្សុរស ទ្រង់មានព្រះបំណង នឹងធ្វើនូវសក្ការៈ ដល់ព្រះទេវទត្តនោះ ទ្រង់បរិច្ចាគព្រះរាជទ្រព្យជាច្រើន ទ្រង់គ្រាស់ឲ្យកសាងព្រះវិហារ ក្នុងគយាសីសប្រទេស ទ្រង់បានព្រះរាជទាន នូវថាសភោជន ៥០០ សម្រាប់ ជាវៀងរាល់ថ្ងៃ និង ទ្រង់បានស្តេចយាងទៅកាន់ទីឧបដ្ឋាក នៃព្រះទេវទត្ត ទាំងល្ងាចព្រឹក ។ ព្រះអង្គទ្រង់ជឿពាក្យរបស់ព្រះទេវទត្ត ទ្រង់បានធ្វើគុតព្រះរាជបិតា ទ្រង់បានកាត់ផ្តាច់នូវឧបនិស្ស័យ នៃបឋមមគ្គ របស់ព្រះអង្គហើយ ទ្រង់ប្រសព្វទុក្ខ ដោយនយដែលបានពោលហើយ ឰដ៏ខាងក្រោយ ។

(រឿងសញ្ជីវិមាណ)

(៧៧) ព្រះបាទអជាតសត្រូវ អង្គនោះឯង ក្នុងអតីតកាល

ពណ៌នាអំពីការបូជា

ជាមាណព ឈ្មោះ សញ្ជីវៈ ដែល (រាប់បញ្ចូល) ក្នុងមាណព ៥០០ នាក់ ដែលជាអន្តេវាសិក របស់អាចារ្យទិសាបាមោក្ខ ក្នុងទីក្រុងពារាណសី ។ សញ្ជីវមាណពនោះ បានសិក្សាមន្តសម្រាប់ប្រោសមនុស្សដែលស្លាប់ហើយ ឲ្យក្រោកឡើយវិញតែម៉្យាង ក្នុងសំណាក់នៃអាចារ្យ មិនបានសិក្សានូវមន្តសម្រាប់ទុកការពារទេ ។

ក្នុងថ្ងៃមួយ សញ្ជីវមាណពនោះ បានចូលទៅព្រៃ ដើម្បីប្រយោជន៍ដល់ឧស ជាមួយនឹងមាណពទាំងឡាយ បានឃើញសត្វខ្លាស្លាប់ ទើបពោលថា “ ម្នាលអ្នកដ៏ចំរើន ខ្ញុំនឹងញុំាងសត្វខ្លានេះ ឲ្យក្រោកឡើងវិញ ” ។ មាណពទាំងនោះ ពោលថា “ បើអ្នកអាច, ចូរអ្នកញុំាងសត្វខ្លានេះឲ្យក្រោកឡើងចុះ ” ដូច្នេះហើយ ក៏បានឡើងទៅកាន់ដើមឈើ ។ សញ្ជីវមាណពនោះ បានរាយមន្តហើយ ក៏បានយកដុំក្រួសមកប្រហារសត្វខ្លានោះ ។ សត្វខ្លា បានក្រោកឡើងហើយ ក៏បានចោលទៅ យ៉ាងលឿន មកខាំនូវសញ្ជីវមាណព ត្រង់ដើមក បានញុំាងសញ្ជីវមាណពនោះ ឲ្យដល់នូវការអស់ទៅនៃជីវិតហើយ ក៏បានដួលចុះ ក្នុងទីនោះ ដូចគ្នាដែរ សត្វនិង មនុស្សទាំង ២ នោះ បានដេកស្លាប់ ក្នុងទីជាមួយគ្នានុ៎ះឯង ។

មាណពទាំងឡាយ មកហើយ ក៏បានប្រាប់ ដល់អាចារ្យ ។ អាចារ្យនោះ ពោលថា “ ម្នាលអ្នកទាំងឡាយ ធម្មតាបុគ្គលអ្នក

មង្គលត្ថទីបនីប្រែ

ធ្វើការលើកតម្កើងអសប្បុរស កាលធ្វើសក្ការៈ និង ការរាប់អាន ក្នុងហានៈដែលមិនសមគួរ តែងត្រឡប់បាននូវសេចក្តីទុក្ខ ដូច្នេះឯង" កាលសំដែងធម៌ ក៏បានពោលហើយនូវគាថានេះថា ៖

> បុគ្គលណា លើកតម្កើង នូវជនជាអសប្បុរសផង [(១)] ប្ញូលទៅសេពគប់នូវជនជាអសប្បុរសផង, ជនជាអសប្បុរសនោះ រមែងធ្វើបុគ្គលនោះឯង ឲ្យទៅជាអាហារ ដ្ឋិបសត្វខ្លារស់មានជីវិតឡើងវិញ ធ្វើសញ្ជឹវមាណព ឲ្យជាអាហារ ដ្ឋិច្មោះឯង ។

*បណ្តាបទទាំងនោះ បទថា " **អសន្តំ** " បានដល់ បុគ្គលដែលប្រកបដោយទុច្ចរិត ៣ យ៉ាង ជាអ្នកទ្រុស្តសីល មានធម៌ ដ៏លាមក ។ បទថា " **យោ** " គឺ បណ្តាបុគ្គលទាំងឡាយមានក្សត្រជាដើម បុគ្គល ឯណាមួយ ។ បទថា " **បគ្គណ្ហាតិ** " មានសេចក្តីថា រមែងលើកតម្កើង គឺធ្វើសក្ការៈ និង ការរាប់អាន នូវបព្វជិត ដោយការប្រគេនបច្ច័យមានចីវរជាដើម ឬ នូវគ្រហស្ថ ដោយការប្រគល់ ឲ្យនូវដំណែង មានហានន្តរសក្តិ ជាឧបរាជ និងសេនាបតី ជាដើម ។ បទថា " **ឧបសេវតិ** " បានដល់ រមែងសេពគប់ ។ ២ បទថា " **តមេវ ឃាសំ** " មានសេចក្តីថា បុគ្គលអ្នកទ្រុស្តសីល រមែងធ្វើនូវបុគ្គល អ្នកដែលលើកតម្កើងខ្លួននោះ*

១- សុត្តន្តបិដក ភាគទី ៥៨ ទំព័រទី ៦៦ ។

ពណ៌នាអំពីការបូជា

ឯង ឲ្យទៅជារបស់គួរទំពាស៊ី, អធិប្បាយថា " តែងស៊ី គឺទំពាស៊ីនូវជននោះ បានដល់ ឲ្យដល់នូវសេចក្តីវិនាស " ។ សួរថា " ប្រៀបដូចជាអ្វី " ។ ឆ្លើយថា " ប្រៀបដូចជាសត្វ ដែលស្លាប់ហើយ ត្រូវសញ្ជើវមាណពរាយមន្តហើយ លើកតម្កើង ដោយការឲ្យនូវជីវិតបានរស់មកវិញ ក៏ត្រឡប់ទៅជាសម្ងាប់សញ្ជើវមាណពអ្នកឲ្យជីវិត ដល់ខ្លួនទុំ៎ឯង ចាកជីវិត ហើយឲ្យដល់នូវសេចក្តីវិនាស ដូច្នេះឯង " ។

សូម្បីអ្នកជនៃ ក៏ដូច្នេះដែរ, បុគ្គលណា រមែងលើកតម្កើងនូវអស្បរសណា, អសប្បុរសនោះ ជាអ្នកទ្រុស្តសីល រមែងធ្វើ នូវបុគ្គលនោះ ជាអ្នកលើកតម្កើងខ្លួនទុំ៎ឯងឲ្យវិនាស, អធិប្បាយថា " ជនទាំងឡាយដែលលើកតម្កើង នូវអសប្បុរស រមែងដល់ នូវសេចក្តីវិនាស យ៉ាងដូច្នេះឯង " ។

រឿង សញ្ជើវមាណព មកក្នុងសញ្ជើវជាតក ក្នុងឯកនិបាត ។

(រឿងបរិព្វាជកអ្នកលើកតម្កើងពពែ)

(៧៨) ក្នុងអតីតកាល ក្នុងទីក្រុងពារាណសី មានបរិព្វាជកម្នាក់ ឈ្មោះចម្មសាដក: ។ បានឮថា ស្បែកតែប៉ុណ្ណោះ ជាសំពត់សំពាប់ស្មៀក និង ជណ្តាប់ របស់ចម្មសាដកបរិព្វាជកនោះ ។

ថ្ងៃមួយ បរិព្វាជកនោះ ដើរទៅដើម្បីសូមទានគេ ក្នុងក្រុង

មង្គលត្ថទីបនីប្រែ

ពារាណសី ក៏ទៅដល់ទីកន្លែងដល់ពពែទាំងឡាយ ។

គ្រានោះឯង សត្វពពែមួយ ឃើញនូវបរិព្វាជកនោះហើយ ប្រាថ្នានឹងដល់ ទើបបានថយហើយ ។ បរិព្វាជកនោះមិនបានថយចេញហើយ ដោយសម្គាល់ថា " ពពែនោះ ធ្វើនូវការគោរពកោតក្រែងដល់អញ " ហើយ គិតថា " ក្នុងចន្លោះ នៃមនុស្ស មានប្រមាណប៉ុណ្ណេះនេះ សត្វពពែ តែមួយនេះប៉ុណ្ណោះ ស្គាល់គុណរបស់អញ " ហើយ ក៏បានឈរផ្គងអញ្ជលី ចំពោះពពែនោះ ។ នាយពាណិជជាបណ្ឌិត អង្គុយក្នុងផ្សារ ឃើញហេតុនោះហើយ ទើបបានហាមឃាត់ថា "ម្នាលព្រាហ្មណ៍ ចូរអ្នកកុំដល់នូវការស្និទ្ធស្នាល ចំពោះសត្វជើង ៤ ដោយការឃើញ មួយខណៈឡើយ, ព្រោះសត្វពពែនោះ ប្រាថ្នានូវការដល់ឲ្យធ្ងន់ទើបថយ " ។

ក្នុងខណៈនោះ ពពែបានចោលមក យ៉ាងលឿន ហើយបុះនូវបរិព្វាជកនោះ ត្រង់ដើមទ្រូងឲ្យដួលហើយ ក្នុងទីនោះឯង ។ បរិព្វាជកនោះ ដល់នូវវេទនា ដេកនៅក្នុងទីនោះឯង ស្រែកយំ ថា៖

ខ្ញុំជាមនុស្សត្រឹមប្រាជ្ញា ត្រូវពពែបុះសម្លាប់ [1] ក្នុងថ្ងៃនេះ
យ៉ាងណាមិញ, បុគ្គលណា សរសើរបុគ្គលដែលមិនគួរបូជា
បុគ្គលនោះ ត្រូវបុគ្គលដែលមិនគួរបូជានោះ សម្លាប់ហើយ

១- សុត្តន្តបិដក ភាគទី ៥៨ ទំព័រទី ៦៦ ។

ពណ៌នាអំពីការបូជា

ដេកនៅ (ក្នុងទីនេះ) ក៏យ៉ាងនោះដែរ ។

ដូច្នេះ បានធ្វើកាលកិរិយាទៅហើយ ។

បណ្តាបទទាំងនោះ ច្រើនបទថា " **សោ និហតោ សេតំ** " មានសេចក្តីថា បុគ្គលនោះ គឺ អ្នកលើកតម្កើង នូវបុគ្គលដែលមិនគួរបូជា ត្រូវបុគ្គលដែលមិនគួរបូជានោះ សម្លាប់ហើយដេកនៅ ។ បទថា " **អបូជំ** " គឺ បុគ្គល ដែលគេមិនគួរបូជា ។ ពាក្យថា " **យថាហមជ្ជ** " បានដល់ ប្រៀបដូចជាខ្ញុំ ធ្វើការលើកតម្កើងនូវអសប្បុរស ស្ថិតនៅ ក្នុងថ្ងៃនេះ ។ បទថា " **បហដោ** " គឺ ត្រូវពពែបុះ ដោយការបុះយ៉ាងមាំ ។ បទថា " **ហតោ** " គឺ ឲ្យស្លាប់ហើយ ។ បទថា " **ទុម្មតិ** " គឺ ជាអ្នកឥតប្រាជ្ញា ។ មានពាក្យដែលបរិព្វាជកនោះ ពោលថា " សូម្បីបុគ្គល ដទៃទៀត ណាមួយ នឹងធ្វើនូវការលើកតម្កើង នូវអសប្បុរស, បុគ្គលនោះឯង នឹងបានទទួលនូវសេចក្តីទុក្ខ ដូចជាខ្ញុំ យ៉ាងដូច្នោះឯង " ។

បរិព្វាជកនោះឯង បានកើតជាបរិព្វាជក អ្នកមានឈ្មោះយ៉ាងដូច្នេះ ក្នុងទីក្រុងសាវត្ថី ក្នុងពុទ្ធុប្បាទនេះ ប្រតិបត្តិ យ៉ាងដូច្នោះឯង ត្រូវបានសត្វពពែប្រហារហើយ យ៉ាងដូច្នេះ ។

រឿង បរិព្វាជក មកក្នុងចម្មសាដកជាតក ក្នុងចតុក្កនិបាត ។

ពណ៌នាអំពីបុគ្គលដែលគួរបូជាដ៏ខ្ពង់ខ្ពស់ ចប់ ។

មង្គលត្ថទីបនីប្រែ

(៧៩) នយម៉្យាងទៀត ក្នុងបទថា " **បូជនេយ្យានំ** " នេះ គប្បីជ្រាបបូជនេយ្យបុគ្គលទាំងឡាយយ៉ាងនេះថា "បណ្តាបព្វជិត អាចារ្យ និង ឧបជ្ឈាយ៍ ជាបូជនេយ្យបុគ្គល របស់អន្តេវាសិក ទាំងឡាយជាដើម, ពួកភិក្ខុ ដែលចាស់ជាង ជាបូជនេយ្យបុគ្គល របស់ពួកភិក្ខុដែលថ្មី, ពួកបព្វជិតទាំងអស់ ជាបូជនេយ្យបុគ្គល របស់ពួកគ្រហស្ថ ។ ចំណែកបណ្តាគ្រហស្ថ បងប្អូនប្រុស-ស្រី ជាបូជនេយ្យបុគ្គល របស់ពួកប្អូនប្រុស-ស្រី មាតា និង បិតា ជា បូជនេយ្យបុគ្គល របស់បុត្រទាំងឡាយ, ស្វាមី, ឪពុកក្មេក និង ម៉ែក្មេក ជាបូជនេយ្យបុគ្គល របស់ស្ត្រីក្រមុំ ក្នុងត្រកូល " ។

ក៏ការបូជា ចំពោះបូជនេយ្យបុគ្គលទាំងនោះឯង ឈ្មោះថា ជាមង្គលទាំងអស់ ព្រោះជាការសមាទាននូវកុសលធម៌ និង ព្រោះ ហេតុនៃសេចក្តីចំរើន ដោយធម៌មានអាយុជាដើម ។

ព្រោះហេតុនោះ ក្នុងចក្កវត្តិសូត្រ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា " មនុស្សទាំងឡាយនោះ នឹងជាអ្នកប្រតិបត្តិ ដោយ ប្រពៃចំពោះមាតា ជាអ្នកប្រតិបត្តិដោយប្រពៃចំពោះបិតា ជាអ្នក ប្រតិបត្តិដោយប្រពៃ ចំពោះសមណៈ ជាអ្នកប្រតិបត្តិដោយប្រពៃ ចំពោះព្រាហ្មណ៍ ជាអ្នកប្រព្រឹត្តកោតក្រែង ដល់បុគ្គលដែលចំរើន ក្នុងត្រកូលជាប្រក្រតី, នឹងសមាទានប្រព្រឹត្ត នូវកុសលធម៌នេះ,

ពណ៌នាអំពីការបូជា

មនុស្សទាំងឡាយនោះ និងចំរើនដោយអាយុខ្លះ និងចំរើនដោយពណ៌សម្បុរខ្លះ ព្រោះហេតុសមាទាននូវកុសលធម៌ទាំងឡាយ” ។

បណ្តាបទទាំងនោះ បទថា “ ***តេ*** *” មានសេចក្តីថា ម្នាលកិក្ខុទាំងឡាយ មនុស្សទាំងឡាយណា ជាបុត្រ របស់មាតា និងបិតា ដែលមានអាយុប្រមាណ ២ ម៉ឺនឆ្នាំ និងជាមនុស្សដែលមានអាយុ ៤ ម៉ឺន ឆ្នាំ, ពួកមនុស្ស ដែលកើតជាបុត្រទាំងនោះ ។*

បទថា “ ***មាត្តេយ្យា*** *” បានដល់ ជាអ្នកទំនុកបម្រុងមាតា គឺជាអ្នកប្រតិបត្តិប្រពៃចំពោះមាតា ។ បទថា “* ***បេត្តេយ្យា*** *” គឺ ជាអ្នកទំនុកបម្រុងចំពោះបិតា ។ បទថា “* ***សមញ្ញា*** *” គឺ ជាអ្នកទំនុកបម្រុងចំពោះសមណៈ ។ បទថា “* ***ព្រហ្មញ្ញា*** *” គឺ ជាអ្នកទំនុកបម្រុងចំពោះព្រាហ្មណ៍ ។*

បទថា “ ***កុលេជេដ្ឋាបចាយិនោ*** *” មានសេចក្តីថា ជាអ្នកប្រព្រឹត្តកោតក្រែងជាប្រក្រតី គឺប្រព្រឹត្តបន្ទាបខ្លួន ចំពោះជនទាំងឡាយ ដែលជាអ្នករៀមច្បង គឺ ជាអ្នកចម្រើន មានឪពុកធំ, ឪពុកមា និង បងប្រុសជាដើម ក្នុងត្រកូលរបស់ខ្លួន ។ បទថា “****កុសលានំ****” បានដល់ ដែលមិនមានទោសជាលក្ខណៈ ។ បទថា “****សមាទានហេតុ****” គឺព្រោះហេតុនៃការសមាទានហើយប្រព្រឹត្ត ។*

ពណ៌នាអំពីការបូជាដូវបុគ្គលដែលគួរបូជា ចប់ ។

មង្គលត្ថទីបនីប្រែ

(សរុបសេចក្តីនៃគាថា ទី ១)

*(៨០) ព្រះមានព្រះភាគ ទ្រង់ត្រាស់មង្គល ៣ ប្រការ មានការមិនសេពគប់ នូវបុគ្គលពាលជាដើម ដោយព្រះគាថានេះ, មង្គល ៣ ប្រការទាំងអស់នោះ គប្បីជ្រាបថា " **ជាមង្គល** " ព្រោះជាហេតុនៃសេចក្តីចំរើន ដោយសម្បត្តិ មានការសរសើរ ក្នុងលោកនេះ ជាដើម ដោយនយដែលបានពណ៌នាមកនេះឯង ។*

*ចំណែកក្នុងអដ្ឋកថា លោកពោលថា " ការមិនសេពគប់នូវជនពាល ឈ្មោះថា **ជាមង្គល** ព្រោះជាហេតុនៃសេចក្តីចំរើនក្នុងលោកទាំង ២ ព្រោះការពារនូវហេតុនៃទុក្ខ មានភ័យជាដើម ដែលមានការសេពគប់ នូវជនពាលជាបច្ច័យ, ការសេពគប់ នូវបណ្ឌិត និង ការបូជានូវជនដែលគួរបូជា ឈ្មោះថា **ជាមង្គល** ព្រោះជាហេតុនៃព្រះនិព្វាន និង សុគតិ " ។*

សូម្បីពាក្យជាគាថានេះ ក៏ជាបហ្បាវត្តិ ដូច្នេះឯង ។

ពណ៌នាសេចក្តីនៃគាថា ទី ១ ចប់ ។

* * *

ពណ៌នាសេចក្តីនៃគាថា ទី ២

(៨១) គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថាទី ២ ។ ការរស់នៅក្នុងប្រទេសដ៏សមគួរ ឈ្មោះថា **បដិរូបទេសវាសៈ** ។ ក៏ឱកាសជាទីរស់នៅ របស់សត្វទាំងឡាយឯណានីមួយ មានស្រុក នគម និង ជនបទ ជាដើម, ឱកាសនោះ ឈ្មោះថា **ប្រទេស** ។

បទថា "**បុព្វេ**" ប្រែថា ក្នុងកាលមុន, អធិប្បាយថា "ក្នុងជាតិ ដែលកន្លងទៅហើយ" ។

ភាពជាអ្នកមានកុសល បានសន្សំទុកមកហើយ ឈ្មោះថា ភាពជាអ្នកមានបុណ្យបានធ្វើទុកហើយ ។

ការតាំងទុក ការជ្រាបថ្វា ការប្រកបនូវខ្លួន ដោយប្រពៃ ឈ្មោះថា **អត្តសម្មាបណីធិ** ។

បទថា "**ឯតំ**" មានសេចក្តីថា ម្នាលទេវតា អ្នកចូរប្រកាន់យកថា "ការនៅក្នុងប្រទេសដ៏សមគួរ ១ ភាពជាអ្នកមានបុណ្យបានធ្វើទុកហើយ ក្នុងកាលមុន ១ ការតាំងខ្លួនទុក ដោយប្រពៃ ១, កម្មទាំង ៣ យ៉ាងនេះឯង ជាមង្គលដ៏ឧត្តម" ។

សេចក្តីសង្ខេប ក្នុងគាថាទី ២ នេះ មានតែប៉ុណ្ណេះឯង ។

♣ ♣ ♣

ពណ៌នាការនៅក្នុងប្រទេសដ៏សមគួរ

ចំណែកសេចក្តីពិស្តារ ក្នុងគាថាទី ២ នេះ មានដូចតទៅ ៖

(៨២) បរិស័ទ ៤ រមែងគ្រាច់ទៅ, បុញ្ញកិរិយាវត្ថុទាំង ឡាយ មានទានជាដើម រមែងប្រព្រឹត្តទៅ, ពាក្យប្រៀនប្រដៅ របស់ព្រះសាស្តា ដែលប្រកបដោយអង្គ ៩ រមែងរុងរឿង ក្នុង ប្រទេសឯណា, ប្រទេសនោះ ឈ្មោះថា ប្រទេសដ៏សមគួរ ។ ការ រស់នៅ ក្នុងប្រទេសដ៏សមគួរនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ ថា " **ជាមង្គល** " ព្រោះបច្ច័យនៃការបំពេញបុណ្យ របស់សត្វទាំង ឡាយ ។ ក្នុងដំណើរនុ៎ះ មានរឿងនេះ (ជាឧទាហរណ៍) ៖

(រឿង ព្រានប្រមង់)

(៨៣) បានឮមកថា ព្រានប្រមង់ម្នាក់ ឈ្មោះ អរិយៈ អាស្រ័យនៅ ក្នុងទីក្រុងសាវត្ថី ។ ថ្ងៃមួយ ព្រានប្រមង់នោះកំពុង យកសន្ទូចសូចត្រី បានឃើញព្រះសាស្តា ស្តេចយាងបិណ្ឌបាត ក្នុងស្រុក ក្បែរមាត់ទ្វារ ទិសខាងជើង នៃទីក្រុងសាវត្ថី មានកិរិយា សង្ឃ ចោមរោមហើយ ស្តេចកំពុងតែយាងមក អំពីស្រុកនោះឯង ទើបបានដាក់ដងសន្ទូច ឈរហើយ ។

ព្រះសាស្តា ទ្រង់គង់នៅ ក្នុងទីមិនឆ្ងាយ នៃព្រានប្រមង់នោះ ហើយទ្រង់ត្រាស់សួរ នូវពួកព្រះសាវក មានព្រះសារីបុត្តត្ថេរ ជា ដើម ថា " តើអ្នកនោះ ឈ្មោះអ្វី " ។ ចំណែក ព្រះសាវកទាំងនោះ

មង្គលត្ថទីបនីប្រែ

ជានក្រាបទូលនូវឈ្មោះរបស់ខ្លួន ៗ ដោយនយ័ជាដើម ថា “ ខ្ញុំ ព្រះករុណា ឈ្មោះ សារីបុត្រ, ខ្ញុំព្រះករុណា ឈ្មោះ មោគ្គល្លាន” ។

ព្រោនប្រមង់ គិតថា “ព្រះសាស្តា ទ្រង់ត្រាស់សួរនូវឈ្មោះ របស់ពួកសាវ័កទាំងពួង, ព្រះអង្គឃើញថា នឹងទ្រង់ត្រាស់សួរ នូវ ឈ្មោះ របស់អញខ្លះ ” ។ ព្រះសាស្តា ទ្រង់ជ្រាបចិត្ត របស់ព្រោន ប្រមង់នោះហើយ ទើបទ្រង់ត្រាស់សួរថា “ ម្នាលឧបាសក តើអ្នក ឈ្មោះអ្វី ” ។ ព្រោនប្រមង់ បានក្រាបទូលថា “ បពិត្រព្រះអង្គ ដ៏ ចំរើន ទូលព្រះបង្គំ ឈ្មោះ អរិយៈ ” ។

គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងព្រោនប្រមង់ នោះ ថា “ ម្នាលឧបាសក បុគ្គលអ្នកសម្លាប់នូវសត្វមានជីវិត ដូច ជាអ្នក មិនឈ្មោះថា អរិយៈ ទេ, ចំណែក ព្រះអរិយៈទាំងឡាយ ស្ថិតនៅហើយ ក្នុងការៈគឺការមិនបៀតបៀន នូវសត្វទាំងឡាយ ” ដូច្នេះហើយ កាលទ្រង់ត្រាស់សំដែងនូវធម៌ ទើបត្រាស់គាថានេះ ក្នុងធម្មដ្ឋវគ្គ នៃធម្មបទ ថា ៖

បុគ្គល បៀតបៀនសត្វទាំងឡាយ ដោយហេតុណា [1] មិន
បានឈ្មោះថា ជាអរិយៈ ដោយហេតុនោះទេ, បុគ្គលដែល

១- សុត្តន្តបិដក ភាគទី ៥២ ទំព័រទី ៧៧ ។

មង្គលត្ថទីបនីប្រែ

តថាគត ហៅថា ជាព្រះអរិយៈ ព្រោះមិនបៀតបៀន
សត្វទាំងពួង ។

*បណ្តាបទទាំងនោះ បទថា "**តេន**" គឺ ដោយហេតុនោះ ។ បទថា "**ហឹសតិ**" ប្រែថា បៀតបៀន ។ បទថា "**អហឹសា**" មានសេចក្តីថា ព្រោះមិនបៀតបៀនសត្វទាំងពួង ដោយគ្រឿងប្រហារមានបាតដៃ ជាដើម ។ ចំទោគាថា ថា "**អរិយោតិ បវុច្ចតិ**" មានសេចក្តីថា បុគ្គលអ្នកដែលស្ងប់ នៅឆ្ងាយហើយ ចាកការបៀតបៀនប៉ុណ្ណោះ តថាគត ហៅថា ជាអរិយៈ ព្រោះជាអ្នកស្ងប់នៅហើយ ក្នុងភាវនា មានមេត្តា ជាដើម ដូច្នេះឯង ។*

ក្នុងទីបញ្ចប់នៃគាថា ព្រានប្រមង់ បានជាសោតាបន្ន ។

*ការរស់នៅ ក្នុងប្រទេសដ៏សមគួរ របស់ព្រានប្រមង់នោះ ឈ្មោះថា **ជាមង្គល** ព្រោះជាបច្ច័យនៃបុញ្ញកិរិយាវត្ថុ គឺការស្តាប់ ។*

រឿង ព្រានប្រមង់ ចប់ ។

(៨៤) ម៉្យាងទៀត ប្រទេសជាទីផុរផង់នៃប្រាជ្ញា ឈ្មោះថា ពោធិ (ជាគ្រឿងត្រាស់ដឹង) របស់ព្រះសាស្តា, ប្រទេស ដែលព្រះមានព្រះភាគ ទ្រង់ញុំាងព្រះធម្មចក្រ ឲ្យប្រព្រឹត្តទៅ, ប្រទេស គឺ គល់នៃឈើ ឈ្មោះថា គណ្ឋាម្ពព្រឹក្ស ដែលព្រះមានព្រះភាគទ្រង់

ពណ៌នាការនៅក្នុងប្រទេសដ៏សមគួរ

ជានសំដែងយមកប្បាដិហារិយ៍ ទំលាយសេចក្តីស្រវឹង របស់តិរ្ថិយ ទាំងពួង ត្រង់កណ្តាលនៃបរិស័ទ ប្រមាណ ១២ យោជន៍, ប្រទេសជាទីស្តេចយាងចុះអំពីទេវលោក ឬក៏ ប្រទេសជាទីគង់នៅ របស់ព្រះពុទ្ធ មានទីក្រុងសាវត្ថី និង ទីក្រុងរាជគ្រឹះជាដើម ទោះជាឯណានីមួយ, ប្រទេសនោះ ឈ្មោះថា **ប្រទេសដ៏សមគួរ** ។ ការរស់នៅក្នុងប្រទេសដ៏សមគួរនោះ ឈ្មោះថា **ជាមង្គល** ព្រោះជាបច្ច័យធ្វើឲ្យបាននូវអនុត្តរិយៈ ៦ របស់សត្វទាំងឡាយ ។

(៨៥) ក៏កិច្ច មានការឃើញរូបជាដើម ដែលវៀរចាកកិច្ចដទៃ ដែលប្រសើរ គឺ មិនមានកិច្ចដទៃ ប្រសើរជាង ឈ្មោះថា អនុត្តរិយៈ ។

អនុត្តរិយៈ ទាំងឡាយនោះ គប្បីជ្រាប ដោយនយដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហើយ ក្នុងអនុត្តរិយសូត្រ [1] ក្នុងឆក្កនិបាត អង្គុត្តរនិកាយនុ៎ះឯង ថា ៖

(ទស្សនានុត្តរិយៈ)

" ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ទៅមើលជំរីរតន៍ក្តី ទៅមើលសេះរតន៍ក្តី ទៅមើលមណិរតន៍ក្តី ឬក៏ ទៅមើលរបស់ធំ ក្តី - តូច ក្តី ទៅមើលសមណៈ ឬ ព្រាហ្មណ៍ ជា

១- សុត្តន្តបិដក ភាគទី ៤៦ ទំព័រទី ៩៣ ។

មង្គលត្ថទីបនីប្រែ

មិច្ឆាទិដ្ឋិ ជាអ្នកប្រតិបត្តិខុសក្តី, ម្នាលភិក្ខុទាំងឡាយ ការឃើញនុ៎ះ មាន, តថាគត មិនពោលថា ការឃើញនុ៎ះ មិនមែនមិនមានទេ ដូច្នេះ, ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែការឃើញនោះនុ៎ះ ជារបស់ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនប្រសើរ មិនមានប្រយោជន៍ មិនប្រព្រឹត្តទៅ ដើម្បីនឿយណាយទេ ដើម្បីប្រាសចាកតម្រេកទេ ដើម្បីរំលត់កិលេសទេ ដើម្បីស្ងប់រម្ងាប់ទេ ដើម្បីដឹងប្រសើរទេ ដើម្បីត្រាស់ដឹងទេ ដើម្បីព្រះនិព្វានទេ, ម្នាលភិក្ខុទាំងឡាយ លុះតែបុគ្គលណា ទៅឃើញ នូវតថាគត ឬ សាវ័កនៃតថាគត ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ ជ្រះថ្លាខ្លាំង, ម្នាលភិក្ខុទាំងឡាយ ការឃើញនុ៎ះ ទើបប្រសើរបំផុត ជាងការឃើញទាំងឡាយ (ព្រោះប្រព្រឹត្តទៅ) ដើម្បីសេចក្តីបរិសុទ្ធិ ដល់សត្វទាំងឡាយ ដើម្បីកន្ទងបង់នូវសេចក្តីសោក និងខ្សឹកខ្សួល ដើម្បីអស់ទៅនៃទុក្ខនិងទោមនស្ស ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវព្រះនិព្វាន, គឺនៅត្រង់បុគ្គល ទៅឃើញតថាគត ឬ សាវ័កបស់តថាគត ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន ជាអ្នកមានចិត្តស្រឡាញ់មាំ ជឿស៊ប់ ជ្រះថ្លាខ្លាំង, ម្នាលភិក្ខុទាំងឡាយ ការឃើញនេះ ទើបតថាគត ឲ្យឈ្មោះថា ការឃើញ ដ៏ប្រសើរបំផុត ។

ពណ៌នាការនៅក្នុងប្រទេសដ៏សមគួរ

(សវិនាឆុត្តរិយៈ)

ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ទៅស្តាប់សំឡេងស្តីក្តី ទៅស្តាប់សំឡេងពិនក្តី ទៅស្តាប់សំឡេងច្រៀងក្តី ឬ ទៅស្តាប់សំឡេងធំ-តូចណាមួយក្តី ទៅស្តាប់ធម៌របស់សមណៈ ឬ ព្រាហ្មណ៍ ជាមិច្ឆាទិដ្ឋិ ជាអ្នកប្រព្រឹត្តខុស ក្តី, ម្នាលភិក្ខុទាំងឡាយ ការស្តាប់នុ៎ះ មានមែន, តថាគត មិនពោលថា ការស្តាប់នុ៎ះ មិនមែនមិនមានទេ ដូច្នេះ, ក៏ប៉ុន្តែ ការស្តាប់នោះនុ៎ះឯង ជារបស់ថោកទាប ជារបស់អ្នកស្រុក ។ បេ ។ រមែងមិនប្រព្រឹត្តទៅដើម្បីព្រះនិព្វានទេ, ម្នាលភិក្ខុទាំងឡាយ លុះតែបុគ្គលណា ទៅស្តាប់ធម៌ របស់តថាគត ឬ សាវ័កនៃតថាគត ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ ជ្រះថ្លាខ្លាំង, ម្នាលភិក្ខុទាំងឡាយ ការស្តាប់នុ៎ះ ទើបប្រសើរបំផុត ជាងការស្តាប់ទាំងឡាយ (ព្រោះប្រព្រឹត្តទៅ) ដើម្បីសេចក្តីបរិសុទ្ធិ ដល់សត្វទាំងឡាយ ។ បេ ។ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវព្រះនិព្វាន, គឺនៅត្រង់បុគ្គលទៅស្តាប់ធម៌ របស់តថាគត ឬ សាវ័កនៃតថាគត ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន ។ បេ ។ ជាអ្នកជ្រះថ្លាខ្លាំង, ម្នាលភិក្ខុទាំងឡាយ ការស្តាប់នេះ ទើបតថាគត ឲ្យឈ្មោះថា ការស្តាប់យ៉ាងប្រសើរបំផុត ។

មង្គលត្ថទីបនីប្រែ

(លោភាវុត្តរិយៈ)

ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ បានលាភគឺកូនក្តី បានលាភគឺប្រពន្ធក្តី បានលាភគឺទ្រព្យក្តី ឬក៏ បានលាភធំ-តូចណាមួយក្តី បានសេចក្តីជឿ ក្នុងសមណៈ ឬ ព្រាហ្មណ៍ ជាមិច្ឆាទិដ្ឋិ ជាអ្នកប្រតិបត្តិខុសក្តី, ម្នាលភិក្ខុទាំងឡាយ លោកនុ៎ះ មានមែន, តថាគត មិនពោលថា លោកនេះ មិនមែនមិនមានទេ ដូច្នេះ, តែថា លោកនោះនុ៎ះឯង ជារបស់ដ៏ថោកទាប ជារបស់អ្នកស្រុក ។ បេ ។ រមែងមិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន, ម្នាលភិក្ខុទាំងឡាយ លុះតែបុគ្គលណា បានសេចក្តីជឿ ក្នុងតថាគត ឬ សាវ័ក នៃតថាគត ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន ។ បេ ។ ជ្រះថ្លាខ្លាំង, ម្នាលភិក្ខុទាំងឡាយ ការបាននុ៎ះ ជាការបានយ៉ាងប្រសើរបំផុត ជាងការបានទាំងឡាយ (ព្រោះប្រព្រឹត្តទៅ) ដើម្បីសេចក្តីបរិសុទ្ធិ ដល់សត្វទាំងឡាយ ។ បេ ។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន, គឺនៅត្រង់បុគ្គល បាននូវសេចក្តីជឿ ក្នុងតថាគត ឬ ព្រះសាវ័ក របស់តថាគត ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន ជាអ្នកមានចិត្តស្រឡាញ់មាំ ។ បេ ។ ជាអ្នកជ្រះថ្លាខ្លាំង, ម្នាលភិក្ខុទាំងឡាយ ការបាននេះ ទើបតថាគត ឲ្យឈ្មោះថា ជាការបានយ៉ាងប្រសើរបំផុត ។

ពណ៌នាការនៅក្នុងប្រទេសដ៏សមគួរ

(សិក្ខាផុត្តរិយៈ)

ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ សិក្សាវិជ្ជាជំរឿ ក្តី សិក្សាវិជ្ជាសេះ ក្តី សិក្សាវិជ្ជារថ ក្តី សិក្សាវិជ្ជាធនូជាវ ក្តី ឬ សិក្សាវិជ្ជាខ្ពស់-ទាប ក្តី សិក្សា (វិជ្ជា) របស់សមណៈ ឬ ព្រាហ្មណ៍ ជាមិច្ឆាទិដ្ឋិ ជាអ្នកប្រព្រឹត្តខុសក្តី, ម្នាលភិក្ខុទាំងឡាយ ការសិក្សានោះ មានមែន តថាគត មិនពោលថា ការសិក្សានោះ មិនមែនមិនមានទេ ដូច្នេះ, ម្នាលភិក្ខុទាំងឡាយ តែថា ការសិក្សាទាំងនោះនុ៎ះ ជារបស់ថោកទាប សម្រាប់អ្នកស្រុក ។បេ។ មិនមែនប្រព្រឹត្តទៅដើម្បីនិព្វានទេ, ម្នាលភិក្ខុទាំងឡាយ លុះតែបុគ្គលណា សិក្សាអធិសីលសិក្ខា សិក្សាអធិចិត្តសិក្ខា សិក្សាអធិប្បញ្ញាសិក្ខា ក្នុងធម្មវិនយ ដែលតថាគតសំដែងហើយ ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន ។បេ។ ជាអ្នកជ្រះថ្លាខ្លាំង, ម្នាលភិក្ខុទាំងឡាយ ការសិក្សានុ៎ះ ប្រសើរបំផុត ជាងការសិក្សាទាំងឡាយ (ព្រោះប្រព្រឹត្តទៅ) ដើម្បីសេចក្តីបរិសុទ្ធិ ជល់សត្វទាំងឡាយ ។ បេ ។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន, ម្នាលភិក្ខុទាំងឡាយ គឺនៅត្រង់បុគ្គលសិក្សាអធិសីលសិក្ខា ក្តី, ក្នុងធម្មវិនយដែលតថាគតសំដែងហើយ ។បេ។ ជាអ្នកជ្រះថ្លាខ្លាំង, ម្នាលភិក្ខុទាំងឡាយ ការសិក្សានេះ ទើបតថាគតឲ្យឈ្មោះថា ការសិក្សាយ៉ាងប្រសើរបំផុត ។

មន្តលត្តនីបនីប្រែ

(បារិបរិយាសុត្តវិយៈ)

ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ បម្រើ ក្សត្រិយ៍ក្តី បម្រើព្រាហ្មណ៍ក្តី បម្រើគហបតីក្តី ឬក៏ បម្រើបុគ្គល ធំ-តូច ណាមួយ ក្តី បម្រើសមណៈ ឬ ព្រាហ្មណ៍ ជាមិច្ឆាទិដ្ឋិ ជាអ្នកប្រព្រឹត្តខុសក្តី, ម្នាលភិក្ខុទាំងឡាយ ការបម្រើនុ៎ះ មានមែន តថាគត មិនពោលថា ការសិក្សានោះ មិនមែនមិនមានទេ ដូច្នេះ, ម្នាលភិក្ខុទាំងឡាយ តែថា ការបម្រើនោះនុ៎ះ ជារបស់ថោកទាប សម្រាប់អ្នកស្រុក ។បេ។ មិនមែនប្រព្រឹត្តទៅ ដើម្បីនិព្វានទេ, ម្នាលភិក្ខុទាំងឡាយ លុះតែបុគ្គលណា បម្រើតថាគត ឬ សាវ័កនៃ តថាគត ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន ជាអ្នកមានចិត្តស្រឡាញ់មាំ ។ បេ ។ ជាអ្នកជ្រះថ្លាខ្លាំង, ម្នាលភិក្ខុទាំងឡាយ ការបម្រើនុ៎ះ ជាការបម្រើ ដ៏ប្រសើរបំផុត ជាងការបម្រើទាំងឡាយ (ព្រោះ ប្រព្រឹត្តទៅ) ដើម្បីសេចក្តីបរិសុទ្ធិ ដល់សត្វទាំងឡាយ ។ បេ ។ ដើម្បីត្រាស់ដឹងមគ្គ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន, គឺនៅ ត្រង់បុគ្គល បម្រើតថាគត ឬ សាវ័កនៃតថាគត ។ បេ ។ ជាអ្នក មានសទ្ធាខ្ជាប់ខ្ជួន ជាអ្នកមានជ្រះថ្លាខ្លាំង, ម្នាលភិក្ខុទាំងឡាយ ការបម្រើនេះ ទើបតថាគត ឲ្យឈ្មោះថា ការបម្រើ យ៉ាងប្រសើរ បំផុត ។

ពណ៌នាការនៅក្នុងប្រទេសដ៏សមគួរ

(អនុស្សតាឥត្តរិយៈ)

ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ រពឹកនូវកូន ក្តី រពឹកនូវប្រពន្ធ ក្តី រពឹកនូវទ្រព្យ ក្តី ឬក៏ រពឹកនូវការបាន ទ្រព្យ ធំ-តូចក្តី រពឹកនូវសមណៈ ឬ ព្រាហ្មណ៍ ជាមិច្ឆាទិដ្ឋិ ជាអ្នក ប្រតិបត្តិខុស ក្តី, ម្នាលភិក្ខុទាំងឡាយ ការរពឹកនុ៎ះ មានមែន, តថាគត មិនពោលថា ការរពឹកនុ៎ះ មិនមែនមិនមានទេ ដូច្នេះ, ម្នាលភិក្ខុទាំងឡាយ តែថា ការរពឹកនោះនុ៎ះឯង ជារបស់ថោក ទាប ជារបស់អ្នកស្រុក ។បេ។ មិនប្រព្រឹត្តទៅ ដើម្បីព្រះ និព្វានទេ, ម្នាលភិក្ខុទាំងឡាយ លុះតែបុគ្គលណា រពឹកតថាគត ឬ សាវ័ក នៃតថាគត ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន ជាអ្នកមានចិត្ត ស្រឡាញ់មាំ ។បេ។ ជាអ្នកជ្រះថ្លាខ្លាំង, ម្នាលភិក្ខុទាំង ឡាយ ការរពឹកនុ៎ះ ជាការរពឹកដ៏ប្រសើរបំផុត ជាងការរពឹកទាំង ឡាយ (ព្រោះប្រព្រឹត្តទៅ) ដើម្បីសេចក្តីបរិសុទ្ធិ ដល់សត្វទាំង ឡាយ ។បេ។ ដើម្បីត្រាស់ដឹងមគ្គ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវ ព្រះនិព្វាន, គឺនៅត្រង់បុគ្គលរពឹកតថាគត ឬ សាវ័ក នៃតថាគត ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន ។បេ។ ជាអ្នកជ្រះថ្លាខ្លាំង, ម្នាល ភិក្ខុទាំងឡាយ ការរពឹកនេះ ទើបតថាគត ឲ្យឈ្មោះថា ការរពឹក ដ៏ប្រសើរបំផុត" យ៉ាងដូច្នេះ ។

មង្គលត្ថទីបនីប្រែ

(៨៩) នយដែលមក ក្នុងអដ្ឋកថាអនុត្តរិយសូត្រនោះ ថា " បណ្តាបទទាំងនោះ បទថា **ឧច្ចាវចំ** បានដល់ រូបឯណាមួយ ដែលធំ តូច ឬ ខ្ពស់ ទាប ។ បទថា " **ហីនំ** " គឺ ជ័រោកទាប ។ បទថា " **គម្មំ** " បានដល់ ដែលជារបស់អ្នកស្រុក ។ បទថា " **បោថុជ្ជនិកំ** " គឺ ដែលជារបស់ នៃមនុស្សបុថុជ្ជន ។ បទថា " **អនរិយំ** " គឺ មិនប្រសើរ មិនខ្ពង់ខ្ពស់ បានដល់ មិនបរិសុទ្ធ ។ បទថា " **អនត្ថសញ្ហិតំ** " គឺ មិនប្រកបដោយប្រយោជន៍ ។ បទថា " **និព្ពិទាយ** " គឺ ដើម្បីនឿយណាយ ក្នុងវដ្ដៈ ។ បទថា " **វិរាគាយ** " គឺ ដើម្បីប្រាសចាកនៃកិលេសទាំងឡាយ មានរាគៈជាដើម ។ បទថា " **និរោធាយ** " គឺ ដើម្បីរលត់ ដោយមិនមានការប្រព្រឹត្តិទៅ នៃកិលេសទាំងនោះ ។ បទថា " **ឧបសមាយ** " គឺ ដើម្បីស្ងប់រម្ងាប់ នៃកិលេសទាំងនោះ ។ បទថា " **អភិញ្ញាយ** " គឺ ដើម្បីត្រាស់ដឹងប្រសើរ ។ បទថា " **សម្ពោធាយ** " គឺ ដើម្បីត្រាស់ដឹង នូវមគ្គញ្ញាណ ៤ ពោលគឺ បញ្ញាគ្រឿងត្រាស់ដឹង ។ បទថា " **និព្វានាយ** " គឺ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ បទថា " **និវិដ្ឋស្សទ្ធោ**" គឺ ជាការមានសទ្ធា ស្ថិតនៅមាំហើយ ។ សូម្បីក្នុងបទ ទី ២ ក៏នយនេះដូចគ្នាដែរ ។ បទថា " **ឯកន្តគតោ** " បានដល់ ជាអ្នកដល់ហើយ ដោយចំណែកមួយ, អធិប្បាយថា

ពណ៌នាការនៅក្នុងប្រទេសដ៏សមគួរ

" ជាអ្នកមានសទ្ធា មិនកម្រើក " ។ បទថា " **អកិប្បសន្នោ** " គឺ ជាអ្នកជ្រះថ្លាក្រៃលែង ។ បទថា " **ឯតទានុត្តរិយំ** " កាត់បទជា **ឯតំ អនុត្តរិយំ** ។ បទថា " **វិសុទ្ធិយា** " គឺ ដើម្បីដល់នូវសេចក្តីបរិសុទ្ធិ ។ បទថា " **សោកបរិទេវានំ** " គឺ នូវសេចក្តីសោក និងសេចក្តីខ្សឹកខ្សួល ។ បទថា " **អដ្ឋង្គមាយ** " គឺ ដើម្បីដល់ នូវការតាំងនៅមិនបាន ។ បទថា " **ញាយស្ស** " គឺ ដើម្បីមគ្គដែលប្រកបដោយវិបស្សនា ។ បទថា " **និព្វានស្ស** " គឺ ដើម្បីព្រះនិព្វាន ដែលមិនមានបច្ច័យ ។ បទថា " **បុត្តលាភំ** " គឺ លាភពោលគឺបុត្រ ។ បទថា " **ហត្ថិស្មិំ** " មានសេចក្តីថា តែងសិក្សានូវសិល្បៈ មានជំរី ជានិមិត្ត ដែលគួរសិក្សា ឈ្មោះថា សិក្សាព្រោះរឿងជំរី ។ ក្នុងបទទាំងពួង ក៏នយនេះដែរ ។ ក៏ក្នុងបទ ថា " **ថរុស្មិំ** " នេះ អាវុធគ្រប់បែបយ៉ាង ឈ្មោះថា **ថរុ** ។ បទថា " **ឧច្ចាវចំ** " គឺ សិល្បៈ ធំ-តូច ។ ក្នុងអនុត្តរិយៈទាំង ៦ យ៉ាងនោះ បណ្តាការឃើញរូបទាំងឡាយ ការឃើញ យ៉ាងប្រសើរ ឈ្មោះថា **ទស្សនានុត្តរិយៈ** ។ ក្នុងបទទាំងពួង ក៏នយនេះ ។

មែនពិត ការឃើញ នូវព្រះសាស្តា ព្រះកិក្ខុសង្ឃ ឬ នូវនិមិត្ត មានកសិណ និង អសុភនិមិត្តជាដើម យ៉ាងណានីមួយ នៃបុគ្គលជាអ្នកមានសទ្ធាខ្ជាប់ខ្ជួនហើយ ឈ្មោះថា **ទស្សនានុត្តរិយៈ**,

មង្គលត្ថទីបនីប្រែ

ការឃើញនូវតេន: មានវតេន: គឺជំរីជាដើម មិនឈ្មោះថា ***ទស្សនានុត្តរិយ:*** *ទេឬយ ។*

ការស្តាប់នូវការពណ៌នាគុណព្រះរតេន:ត្រៃ និង ព្រះពុទ្ធ-វចន: គឺព្រះត្រៃបិដក ឈ្មោះថា ***សវនានុត្តរិយ:***, *ការស្តាប់ការពណ៌នាគុណនៃក្សត្រិយ៍ជាដើមមិនឈ្មោះថា* ***សវនានុត្តរិយ:*** *ទេ ។*

ការបាននូវអរិយទ្រព្យទាំង ៧ យ៉ាងប៉ុណ្ណោះ ទើបឈ្មោះថា ***លាភានុត្តរិយ:***, *ការបាននូវតេន: មានមណិរតេន: ជាដើម មិនឈ្មោះថា* ***លាភានុត្តរិយ:*** *ទេឬយ ។*

ការបំពេញត្រៃសិក្ខា ឲ្យបរិបូណ៌ប៉ុណ្ណោះ ទើបឈ្មោះថា ***សិក្ខានុត្តរិយ:***, *ការសិក្សាសិល្ប: មានសិល្ប: គឺជំរី ជាដើម មិនឈ្មោះថា* ***សិក្ខានុត្តរិយ:*** *ទេឬយ ។*

កិរិយាប្រតិបត្តិបម្រើ នូវព្រះរតេន:ត្រៃតែប៉ុណ្ណោះ ឈ្មោះថា ***បារិចរិយានុត្តរិយ:***, *កិរិយាប្រតិបត្តិបម្រើក្សត្រិយ៍ជាដើម មិនឈ្មោះថា* ***បារិចរិយានុត្តរិយ:*** *ទេឬយ ។*

ការនឹករឭកដល់គុណ នៃព្រះរតេន:ត្រៃប៉ុណ្ណោះ ឈ្មោះថា ***អនុស្សតានុត្តរិយ:***, *ការនឹករឭកដល់គុណ របស់ក្សត្រិយ៍ជាដើម មិនឈ្មោះថា* ***អនុស្សតានុត្តរិយ:*** *ទេឬយ" ។*

(៨៧) នយមក ក្នុងអដ្ឋកថាឯកនិបាត អង្គុត្តរនិកាយ ព្រម

ពណ៌នាការនៅក្នុងប្រទេសដ៏សមគួរ

ទាំងដីកា ថា " ព្រះអានន្ទត្ថេរ បានដើម្បីនឹងឃើញ នូវព្រះសាស្តា ដោយចក្ខុវិញ្ញាណ ក្នុងពេលល្ងាច-ពេលព្រឹក, នេះ ឈ្មោះថា **ទស្សនានុត្តរិយៈ** ។ លោកបានដើម្បីស្តាប់នូវព្រះតម្រាស់ របស់ព្រះសាស្តារឿយៗ, នេះ ឈ្មោះថា **សវនានុត្តរិយៈ** ។ លោក បាន នូវសេចក្តីជឿ ចំពោះព្រះសាស្តា ថា "ព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់បានត្រាស់ជីង ដោយប្រពៃ " ដូច្នេះ, នេះ ឈ្មោះ ថា **លាភានុត្តរិយៈ** ។ លោកសិក្សា នូវត្រៃសិក្ខា ក្នុងសាសនា របស់ព្រះសាស្តា, នេះ ឈ្មោះថា **សិក្ខានុត្តរិយៈ** ។ លោក បានប្រណិបត្តិ ធ្វើនូវការបម្រើ នូវព្រះសាស្តា ជារឿយ ។, នេះ ឈ្មោះថា **បារិចរិយានុត្តរិយៈ** ។ លោក នឹករឭកដល់គុណ ដែល ជាលោកិយៈ និង លោកុត្តរៈ របស់ព្រះសាស្តា, នេះ ឈ្មោះថា **អនុស្សតានុត្តរិយៈ** ។

ព្រះសោតាបន្ន ព្រះសកទាគាមី និង ព្រះអនាគាមីបុគ្គល សូម្បីដទៃទៀត ក៏ដូចជាព្រះអានន្ទត្ថេរដែរ បានឃើញ នូវព្រះ សាស្តា និង បានស្តាប់ព្រះតម្រាស់នៃព្រះសាស្តា, បាននូវសទ្ធា ក្នុងព្រះសាស្តា, សិក្សានូវត្រៃសិក្ខា ក្នុងព្រះសាសនា របស់ព្រះ សាស្តា, ប្រណិបត្តិបម្រើនូវព្រះសាស្តា នឹករឭកដល់គុណនៃព្រះ សាស្តា, ទាំងនោះឯង ឈ្មោះថា **ទស្សនានុត្តរិយៈ** ។បេ។

មង្គលត្ថទីបនីប្រែ

អនុស្សតានុត្តរិយៈ ។

*ចំណែកខាង កល្យាណបុថុជ្ជន ក៏ដូចជាព្រះអានន្ទត្ថេរដែរ បាននូវការយើញព្រះសាស្តា នឹងការបានស្តាប់ព្រះតម្រាស់នៃព្រះសាស្តា បានសទ្ធាចំពោះព្រះសាស្តា សិក្សាត្រៃសិក្ខា ក្នុងព្រះសាសនានៃព្រះសាស្តា ប្រណិបត្តិបម្រើព្រះសាស្តា នឹករឭកគុណរបស់ព្រះសាស្តា ចំរើនវិបស្សនា មានការយើញ, ការស្តាប់ការបាននូវត្រៃសិក្ខា, ការប្រណិបត្តិ បម្រើ និង ការតាមនឹករឭកនោះ ។ (ជាអារម្មណ៍) ហើយធ្វើខ្លួន ឲ្យបានសម្រេច នូវព្រះសោតាបត្តិមគ្គ, នេះ ទើបឈ្មោះថា **ទស្សនៈ**, **សវនៈ**, **លាភៈ**, **សិក្ខា**, **ជាវិចរិយា**, **អនុស្សតិ** ដោយពិតប្រាកដ ។ ចំណែកឯ ទស្សនៈ ដែលជាខាងដើម ឈ្មោះថា **ទស្សនានុត្តរិយៈ**, ការស្តាប់, ការបាន, ការសិក្សា, ការប្រណិបត្តិ និង ការតាមនឹងរឭកដែលជាខាងដើម ក៏យ៉ាងដូច្នោះដែរ គឺឈ្មោះថា **សវនានុត្តរិយៈ** ។ បេ ។ **អនុស្សតានុត្តរិយៈ** ។*

(៨៨) ក៏ក្នុងព្រះសូត្រនេះ ព្រះដ៏មានព្រះភាគ មិនទ្រង់ព្រះបំណងត្រឹមតែការយើញព្រះរូប របស់ព្រះសាស្តា ដែលជាអ្នកប្រសើរខ្ពង់ខ្ពស់ ថាជា ទស្សនានុត្តរិយៈ ឡើយ, តាមពិត ព្រះអង្គ ទ្រង់ប្រាថ្នានូវការយើញឈានចូល ក្នុងព្រះពុទ្ធគុណ ដោយ

ពណ៌នាការនៅក្នុងប្រទេសដ៏សមគួរ

សេចក្តីជ្រះថ្លា យ៉ាងក្រៃលែង មានការឃើញព្រះរូប របស់ព្រះអង្គ ជាប្រធាន (ថាជា ទស្សនានុត្តរិយៈ) ។ ព្រោះហេតុនោះ ទើប ព្រះអដ្ឋកថាចារ្យ ពោលថា ***អានន្ទត្ថេរោ*** *ដូច្នេះជាដើម ។*

រូបកាយ របស់ព្រះសាស្តា ឈ្មោះថា ***ទស្សនៈ*** *ក្នុងបទ ថា* ***ទស្សនានុត្តរិយំ*** *នោះ ព្រោះជាព្រះរូបដែលបុគ្គលគប្បីឃើញ, សូម្បីក្នុងបទថា* ***ទស្សនានុត្តរិយៈ*** *នោះ អាយតនៈ គឺរូប ក៏ឈ្មោះ ថា* ***ទស្សនៈ*** *ដោយការមិនប្លែកគ្នាឡើយ, ហេតុនោះ ទើបព្រះ អដ្ឋកថាចារ្យ ពោលថា* ***ចក្ខុវិញ្ញាណេន ទដ្ឋុំ*** *ដូច្នេះ ។*

ទស្សនៈ ដទៃ ក្រៃលែងជាងទស្សនៈ នេះ មិនមាន ហេតុ នោះ ទស្សនៈនេះ ទើបឈ្មោះថា ***អនុត្តរៈ*** *(មិនមានទស្សនៈ ដទៃក្រៃលែង ជាង), អនុត្តរៈ នោះឯង ឈ្មោះថា* ***អនុត្តរិយៈ***, *ទស្សនៈ នោះផង មិនមានទស្សនៈ ដទៃ ក្រៃលែងជាងផង ព្រោះហេតុនោះ ទើបឈ្មោះថា* ***ទស្សនានុត្តរិយៈ*** *។ សូម្បីក្នុង អនុត្តរិយៈ ដែលសេសសល់ ក៏នយនេះដូចគ្នាដែរ ។ ចំណែក សេចក្តីប្លែកផ្សេងគ្នា មានដូចតទៅនេះ ៖*

ដែលឈ្មោះថា ***សវនៈ*** *ព្រោះអត្ថថា គឺបុគ្គលតែងស្តាប់ គឺព្រះតម្រាស់ របស់ព្រះសាស្តា ។ ដែលឈ្មោះថា* ***លាភៈ*** *ព្រោះ អត្ថថា គឺបុគ្គលតែងបាន គឺការជឿចំពោះព្រះសាស្តា ។ ដែល*

មង្គលត្ថទីបនីប្រែ

ឈ្មោះថា **សិក្ខា** ព្រោះអត្ថថា គឺបុគ្គលគប្បីសិក្សា គឺសីលសមាធិនិងបញ្ញា ។ ការប្រតិបត្តិ ឈ្មោះថា **បាវិចរិយា** គឺ ការទំនុកបម្រុង ។ ការតាមរក្សា ឈ្មោះថា **អនុស្សតិ** បានដល់ ការរក្សានូវគុណ របស់ព្រះសាស្តា ។

ពាក្យថា " **ឥទម្បិ** " នេះ ព្រះអដ្ឋកថាចារ្យ ពោលហើយព្រោះមិនខុស អំពីពាក្យដែលលោកពោលហើយ ក្នុងកាលមុន ។

២ បទថា " **សត្ថុ ទស្សនំ** " មានសេចក្តីថា ប្រៀបដូចជាព្រះអានន្ទត្ថេរ បាននូវការឃើញព្រះសាស្តា ដែលមានការជ្រះថ្លាការកក្តី និង សេចក្តីមេត្តា ជាខាងដើម ។

បទថា " **សិក្ខាត្តយំ** " មានសេចក្តីថា សិក្សានូវត្រៃសិក្ខាដែលជាបុព្វភាគ ។ ២ បទថា " **តំ ទស្សនំ** " មានសេចក្តីថា ចំរើនវិបស្សនា ដែលប្រព្រឹត្តទៅ ដោយការឃើញជាប្រធាន ។

មែនពិត កល្យាណបុថុជ្ជន ចំរើនវារៈ នៃវិបស្សនា រហូតដល់ អនុលោមញាណ ដោយការឃើញជាប្រធានហើយ ឈានចូលដល់ភូមិ នៃអរិយៈ ទី ៨ ក្នុងលំដាប់ នៃអនុលោមញាណនោះ បាននូវទស្សនៈហើយ ទើបបានឈ្មោះថា ញុំាងខ្លួន ឲ្យបានសម្រេចមគ្គ ។

ទស្សនៈ ដែលប្រព្រឹត្តទៅ បន្ទាប់អំពីនេះ ឈ្មោះថា ទស្សនៈ

ពណ៌នាការនៅក្នុងប្រទេសដ៏សមគួរ

ជ័ពិតប្រាកដ ។ ទស្សនៈ ដែលជាខាងដើម ឈ្មោះថា **ទសន្ទ្យានុត្តរិយៈ** ព្រោជាហេតុ នៃការឃើញនូវសច្ចៈ ផងដែរ ។ សូម្បីក្នុងអនុត្តរិយៈ ជ័សេសសល់ ក៏នយនេះដូចគ្នាដែរ ។

កល្យាណបុថុជ្ជន ធ្វើញាណ ដែលមានអនុស្សតិ ជាអារម្មណ៍ ឲ្យកើតឡើង ដោយអំណាចនៃការនឹកព្រេកជល់ព្រះពុទ្ធគុណ ដោយនយមានជាអាទិ៍ ថា " **ឥតិបិ សោ ភគវា** " ដូច្នេះហើយ ធ្វើញាណនោះ ឲ្យជាបទដ្ឋាន ការចំរើនវិបស្សនា ព្រះអដ្ឋកថាចារ្យ ពោលថា ចំរើនវិបស្សនា មានកិរិយាព្រេក (ជាអារម្មណ៍) ដូច្នេះ ។

(រឿង វក្កលិព្រាហ្មណ៍)

(៨៥) បានឮថា ព្រាហ្មណ៍ម្នាក់ ឈ្មោះ វក្កលិ អាស្រ័យនៅក្នុងទីក្រុងសាវត្ថី ។ ថ្ងៃមួយ ព្រាហ្មណ៍នោះ ឃើញព្រះសាស្តាស្តេចកំពុងយាងបិណ្ឌបាត ក្នុងទីក្រុងសាវត្ថី មិនបានឆ្អែតឆ្អន់ហើយ ដោយការឃើញព្រះរូប របស់ព្រះសាស្តា បានទៅកាន់វត្តជេតពន ជាមួយនឹងព្រះសាស្តានុ៎ះឯង បានស្តាប់នូវទេសនារបស់ព្រះសាស្តា ក៏បានសទ្ធា ហើយបួស ក្នុងសំណាក់ នៃព្រះសាស្តា ដោយតាំងចិត្ត ថា " អញនឹងបានឃើញ នូវព្រះសាស្តាជាប់ជានិច្ច ដោយឧបាយយ៉ាងនេះ " ដូច្នេះហើយ, ក្នុងកាលដទៃ

មង្គលត្ថទីបនីប្រែ

ក្រៅអំពីកាលឆាន់អាហារ ខ្លួនបានឈរនៅ ក្នុងទីណា ហើយ ឃើញនូវព្រះសាស្តា, ក៏បានឈរនៅក្នុងទីនោះ បានលះបង់ចោល នូវកិច្ចទាំងឡាយ មានការស្វាធ្យាយ និង ការធ្វើទុកក្នុងចិត្ត ដោយ ឧបាយ ក្នុងកម្មដ្ឋានជាដើម ហើយបាននៅចាំមើលព្រះសាស្តា ។

ព្រះសាស្តា ទ្រង់រង់ចាំនូវការចាស់ក្លា នៃញាណរបស់ព្រះ វក្កលិ នោះ មិនទ្រង់ត្រាស់ព្រះតម្រាស់អ្វីឡើយ អស់កាលដ៏យូរ, កាលបើព្រះវក្កលិនោះ មានញាណ ចាស់ក្លាហើយ, ទើបទ្រង់ ត្រាស់ថា " ម្នាលវក្កលិ តើនឹងមានប្រយោជន៍អ្វី ដល់អ្នក ដោយ កាយដែលស្អុយ គឺអ្នកបានឃើញហើយនេះ, ម្នាលវក្កលិ បុគ្គល ណា ឃើញនូវធម៌ បុគ្គលនោះ រមែងឃើញនូវតថាគត, បុគ្គល ណា ឃើញនូវតថាគត បុគ្គលនោះ រមែងឃើញនូវធម៌, ម្នាល វក្កលិ ក៏បុគ្គលអ្នកឃើញនូវធម៌ ឈ្មោះថា ឃើញនូវតថាគត, បុគ្គល អ្នកឃើញនូវតថាគត ឈ្មោះថា ឃើញនូវធម៌ " យ៉ាងដូច្នេះ ហើយ, កាលបើថ្ងៃចូលព្រះវស្សា ជិតចូលមកដល់ហើយ, ទើប ស្តេចយាងទៅកាន់នគរវេរាជគ្រឹះ, ក្នុងថ្ងៃចូលព្រះវស្សា ទ្រង់បាន ត្រាស់បណ្តេញព្រះវក្កលិនោះ ថា " ម្នាលវក្កលិ ចូរអ្នកគេចចេញ (ឲ្យផុត) ទៅ " ។

ព្រះវក្កលិនោះ កាលមិនអាច ដើម្បីស្ថិតនៅបាន ទើបនឹក

ពណ៌នាការនៅក្នុងប្រទេសដ៏សមគួរ

គិត ថា " និងមានប្រយោជន៍អ្វី ដោយជីវិត របស់អាត្មាអញនោះ ដែលជាអ្នកមិនបានឃើញនូវព្រះសាស្តា" យ៉ាងដូច្នេះហើយ ក៏បានទៅជិតទៅកាន់ភ្នំគិជ្ឈកូដ ដើម្បីនឹងទម្លាក់ខ្លួនអំពីភ្នំ ។

ព្រះសាស្តា ទ្រង់ជ្រាបសេចក្តីនោះហើយ ទើបទ្រង់ព្រះតម្រិះថា " ព្រះវក្កលិនេះ កាលមិនបាន នូវសេចក្តីសប្បាយចិត្ត អំពីសំណាក់នៃតថាគតទេ នឹងគប្បីញុំាងឧបនិស្សយ នៃមគ្គផលឲ្យវិនាស " ដូច្នេះហើយ ទ្រង់គង់នៅ ក្នុងវត្តវេឡុវ័នន៏ុះឯង ទ្រង់បញ្ចេញ នូវព្រះរស្មីហើយ សំដែងព្រះអង្គ កាលទ្រង់ញុំាងបីតិ ដ៏មានកម្លាំង ឲ្យកើតឡើង ដល់ព្រះវក្កលិនោះ ទ្រង់បានត្រាស់ហើយ នូវព្រះគាថានេះ ក្នុងភិក្ខុវគ្គ នៃធម្មបទ ថា ៖

ភិក្ខុ អ្នកក្រាស់ដោយសេចក្តីរីករាយ ជ្រះថ្លា [1] ហើយ ក្នុងព្រះពុទ្ធសាសនា គប្បីបានសម្រេច នូវបទដ៏សូប់ ជាទីរម្ងាប់នូវសង្ខារ ជាសុខ ។

*បណ្តាបទទាំងនោះ បទថា " **បាមោជ្ជពហុលោ** " មានសេចក្តីថា ជាអ្នកចំរើន ដោយសេចក្តីរីករាយសូម្បីដោយប្រក្រតី ។ បទថា " **បសន្នោ** " បានដល់ ជាអ្នកបណ្តុះសេចក្តីជ្រះថ្លា ។*

*ចុងគាថា ថា " **អធិគច្ឆេ បទំ សន្តំ** " មានសេចក្តីថា*

1- សុត្តន្តបិដក ភាគទី ៥២ ទំព័រទី ១០១ ។

មង្គលត្ថទីបនីប្រែ

គប្បីបានសម្រេច នូវចំណែកដែលស្ងប់ ពោលគឺព្រះនិព្វាន ។

បាទគាថា ថា " **សង្ខារូបសមំ សុខំ** " មានសេចក្តីថា ជាធម៌ជាទីរម្ងាប់ នូវសង្ខារទាំងពួង ជាសុខ យ៉ាងក្រៃលែង ។

ក៏ព្រះសាស្តា លុះទ្រង់ត្រាស់ព្រះតម្រាស់នេះហើយ ទើបទ្រង់លាតព្រះហស្តហើយ ទ្រង់ត្រាស់ ថា " ម្នាលវក្កលិ ចូរអ្នកមកចុះ, ចូរអ្នកកុំភ័យខ្លាចឡើយ " ។

ព្រះវក្កលិនោះ គិតថា " អាត្មាអញ បានឃើញព្រះសាស្តាហើយ, សូម្បីព្រះតម្រាស់ថា ចូរអ្នកមកចុះ យ៉ាងដូច្នេះ ក៏អាត្មាអញបានហើយ " ដូច្នេះហើយ ក៏បានញាប់បីតិ ដ៏មានកម្លាំង ឲ្យកើតឡើង មិនទាន់បានដឹងច្បាស់នូវការៈ គឺការទៅ របស់ខ្លួនផង ថា " អាត្មាអញ នឹងទៅខាងណា " ដូច្នេះ ក៏ហោះទៅ ឰដ៏អាកាស នៅទីចំពោះព្រះភក្ត្រ នៃព្រះសាស្តា បានឈរនៅលើភ្នំ ដោយជើងទីមួយនុ៎ះឯង ហើយរឭកនូវគាថា ដែលព្រះសាស្តា ទ្រង់ត្រាស់ហើយ ទើបបានរម្ងាប់នូវបីតិ លើអាកាសនុ៎ះឯង ហើយសម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទាទាំងឡាយហើយ ចុះមកថ្វាយបង្គំព្រះសាស្តា ។

រឿង ព្រះវក្កលិ មកក្នុងអដ្ឋកថាធម្មបទ ជាដើម ។

(៩០) ការនៅក្នុងប្រទេស ដែលជាទីគង់នៅ នៃព្រះពុទ្ធ

របស់ព្រះវក្កលិនោះ ជាបច្ចយ នៃការបានចំពោះ នូវអនុត្តរិយៈ ៦ យ៉ាង គឺ ការឃើញព្រះរូប របស់ព្រះសាស្តា ជាទស្សនានុត្តរិយៈ, ការបានស្តាប់នូវទេសនា របស់ព្រះសាស្តា ជាសវនានុត្តរិយៈ, ការបានសទ្ធា ចំពោះព្រះសាស្តា ជាលាភានុត្តរិយៈ, ការបំពេញ ត្រៃសិក្ខា ជាសិក្ខានុត្តរិយៈ, ការប្រណិបត្តិ នូវព្រះសាស្តា ជាបារិចរិយានុត្តរិយៈ ការតាមរឭកព្រះគុណ របស់ព្រះសាស្តា ជាអនុស្សតានុត្តរិយៈ ដោយប្រការដូច្នេះឯង ។

(មជ្ឈិមប្រទេសជាប្រទេសដ៏សមគួរ)

(៩១) ម៉្យាងវិញទៀត ជនបទ ដែលមានឈ្មោះថា មជ្ឈិម-ប្រទេស ដែលលោកបានកំណត់ទុកហើយ ក្នុងចម្មក្ខន្ធកៈ យ៉ាងដូច្នេះ ថា " ក្នុងទិសបូព៌ា មាននិគម ឈ្មោះ កជង្គលៈ, តអំពីនិគម នោះទៅ មាននគរ ឈ្មោះមហាសាល, តអំពីមហាសាល-នគរ នោះទៅ ជាបច្ចន្តជនបទ រួមខាងក្នុង ជាមជ្ឈិមជនបទ,

ក្នុងទិសអាគ្នេយ៍ មានស្ទឹង ឈ្មោះ សល្លវតី, តអំពីស្ទឹង សល្លវតី នោះទៅ ជាបច្ចន្តជនបទ រួមខាងក្នុង ជាមជ្ឈិមជនបទ,

ក្នុងទិសទក្សិណ មាននិគម ឈ្មោះ សេតកណ្ណិកៈ, តអំពីសេតកណ្ណិកនិគម នោះទៅ ជាបច្ចន្តជនបទ រួមខាងក្នុង ជាមជ្ឈិម-ជនបទ,

មង្គលត្ថទីបនីប្រែ

ក្នុងទិសបស្ចឹម មានស្រុកព្រាហ្មណ៍ ឈ្មោះ ថូន:, តអំពីស្រុកព្រាហ្មណ៍ នោះទៅ ជាបច្ចន្តជនបទ រួមខាងក្នុង ជាមជ្ឈិម-ជនបទ,

ក្នុងទិសឧត្តរ មានភ្នំ ឈ្មោះ ឧសីរទ្ធជ:, តអំពីភ្នំនោះទៅ ជាបច្ចន្តជនបទ រួមខាងក្នុង ជាមជ្ឈិមជនបទ ឈ្មោះថា ប្រទេសដ៏សមគួរ ។

សូម្បីក្នុងអដ្ឋកថា ឯកនិបាត អង្គុត្តរនិកាយ លុះលោកសំដែងបាលី ក្នុងខន្ធក: យ៉ាងដូច្នេះឯងហើយ ទើបបានពោលថា " ក៏ជនបទនេះ មានទ្រង់ទ្រាយ ដូចជាស្គរសំកោរ ដោយត្រង់កន្លែងខ្ញុះ (វាស់) បាន ៨០ យោជន៍, កន្លែងខ្ញុះ បាន ១០០ យោជន៍, កន្លែងខ្ញុះ បាន ២០០ យោជន៍, តែត្រង់កណ្តាល បាន ៣០០ យោជន៍, ដោយជុំវិញ (វាស់) បាន ៩០០ យោជន៍ " ។

(មនុស្សកើតក្នុងប្រទេសដ៏សមគួរ)

ព្រះពុទ្ធ, ព្រះបច្ចេកពុទ្ធ, ព្រះមហាសាវ័កទាំងឡាយ មានព្រះសារីបុត្រ និង ព្រះមោគ្គល្លាន ជាដើម, អ្នកបម្រើព្រះពុទ្ធ, ព្រះពុទ្ធមាតា, ព្រះពុទ្ធបិតា និង ស្តេចចក្រពត្តិ រមែងកើតឡើងក្នុងមជ្ឈិមប្រទេសនោះ ។

បណ្តាសប្បុរសទាំងឡាយ មានព្រះពុទ្ធ ជាដើមនោះ សត្វ

ពណ៌នាការនៅក្នុងប្រទេសដ៏សមគួរ

*ទាំងឡាយ បានទទួលឱវាទ របស់ស្តេចចក្រពត្តិហើយ តាំងនៅក្នុងសីល ៥ ជាអ្នកមានស្ថានសួគ៌នៅខាងមុខ, តាំងនៅ ក្នុងឱវាទ របស់ព្រះបច្ចេកពុទ្ធ ក៏យ៉ាងដូច្នេះដែរ ។ តែកាលតាំងនៅ ក្នុងឱវាទ របស់ព្រះពុទ្ធ និង សាវ័ករបស់ព្រះពុទ្ធ ជាអ្នកមានព្រះនិព្វាន និង សុគតិនៅខាងមុខ ។ ព្រោះហេតុនោះ ការនៅ ក្នុងប្រទេសដ៏សមគួរនោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅថា " **ជាមង្គល** " ព្រោះជាបច្ច័យ នៃសម្បត្តិទាំងឡាយនេះ ។*

(៩២) ចំណែក ក្នុងអដ្ឋកថា ឯកនិបាត អង្គុត្តរនិកាយ លោក ពោលថា " នយមួយទៀត សូម្បីព្រោះការប្រៀបធៀប ក៏តែងបានមជ្ឈិមប្រទេស, មែនពិត ជម្ពូទ្វីបទាំងមូល ឈ្មោះថា មជ្ឈិមប្រទេស, ទ្វីបទាំងឡាយ ដែលសេសសល់ ចាត់ជា បច្ចន្ត-ជនបទ ។ ក្នុងតម្ពបណ្ណិទ្វីប អនុរាធបុរី ឈ្មោះថា មជ្ឈិមប្រទេស, ក្រៅអំពីនោះ ជាបច្ចន្តជនបទ ដូច្នេះឯង ។ សូម្បីពាក្យនោះ ក៏ត្រឹមត្រូវដែរ ។

(តំណៃទ្វិតិយវង្ស ក្នុងអនុរាធបុរី)

ក៏ក្នុងអនុរាធបុរី ព្រះរាជឱរស ទី ២ នៃព្រះបាទ មុដសីវៈ ទ្រង់ព្រះនាមថា ទេវានម្បិយតិស្សៈ ទ្រង់តាំងនៅ ក្នុងឱវាទ របស់ព្រះមហាមហិន្ទត្ថេរ ទ្រង់បានបំពេញបុណ្យជារាប្រើន ទ្រង់គ្រប់គ្រង

រាជសម្បត្តិ បាន ៤០ ព្រះវស្សា ហើយទ្រង់សោយព្រះទិវង្គត ទ្រង់បានកើតឡើងហើយ ក្នុងទេវលោក ជាន់តាវត្តិង្ស ។

តអំពីនោះមក ព្រះរាជឱរស ទី ៤ នៃព្រះបាទមុជសីវ: ទ្រង់ព្រះនាមឧត្តរិយ: គ្រប់គ្រងរាជសម្បត្តិបាន ១០ ព្រះវស្សា ។ ព្រះរាជឱរស ទី ៥ ទ្រង់ព្រះនាម មហាសីវ:, ព្រះរាជឱរស ទី ៧ ទ្រង់ព្រះនាម សូរតិស្ស: របស់ព្រះបាទមុជសីវ:នោះឯង ក៏យ៉ាងដូច្នោះដែរ គឺគ្រងរាជសម្បត្តិ បាន ១០ ព្រះវស្សាដែរ ។

ក្នុងកាលនោះ ព្រះរាជបុត្រនៃព្រះរាជាទមិឡ ២ ព្រះអង្គ គឺ ព្រះសេន: ១ ព្រះគុត្ត: ១ ទ្រង់បានបណ្តេញព្រះរាជាព្រះនាមសូរតិស្ស: ហើយគ្រងរាជសម្បត្តិ ក្នុងអនុរាធបុរី បាន ១២ ឆ្នាំ ។

ក្នុងកាលនោះ ព្រះរាជឱរស ទី ៩ នៃព្រះបាទមុជសីវ: ទ្រង់ព្រះនាម អសេល: ទ្រង់បានបណ្តេញព្រះបាទសេន: និង ព្រះបាទគុត្ត: ហើយបានឡើងគ្រប់គ្រងរាជសម្បត្តិ បាន ១០ ព្រះវស្សា ។

ក្នុងកាលនោះ ព្រះរាជាទមិឡ ព្រះនាមឯឡារ: ទ្រង់បានបណ្តេញព្រះបាទអសេល: ហើយគ្រងរាជសម្បត្តិបាន ៤៤ ឆ្នាំ ។

ក្នុងកាលនោះ ព្រះរាជបុត្រ នៃព្រះបាទកាកវណ្ណតិស្ស: ជាព្រះរាជនត្តា នៃព្រះបាទទេវានម្បិយតិស្ស: ទ្រង់មានព្រះនាមថាទុដ្ឋគាមណីអភ័យ ទ្រង់បានធ្វើគុតព្រះបាទឯឡារ: ហើយបានជា

ពណ៌នាការនៅក្នុងប្រទេសដ៏សមគួរ

ព្រះរាជាមួយព្រះអង្គ ក្នុងអនុរាធបុរី ក្នុងលង្កាទ្វីប ។

ព្រះបាទទុដ្ឋគាមណីអភ័យ អង្គនោះ ទ្រង់បានឡើងគ្រប់គ្រងរាជសម្បត្តិ ក្នុងទីបំផុតនៃឆ្នាំ ៩៦ ក្រោយពីឆ្នាំទ្រង់សោយទិវង្គតទៅ នៃព្រះបាទទេវានម្បិយតិស្សៈ មក ដោយប្រការដូច្នេះ ។

ក្នុងកាលនោះ ទេវានម្បិយតិស្សទេវបុត្រ ឃើញថា សង្ខារទាំងឡាយ ជារបស់មិនទៀងទាត់ស្ថិតស្ថេរ ទើបបានច្យុត ចាកកពតាវត្តិង្ស ដោយការធ្វើកាលកិរិយា គឺការបង្អោនចិត្តទៅ ហើយបានទៅកើត ក្នុងត្រកូលសេដ្ឋី ក្នុងលង្កាទ្វីប ក្នុងពេលមានអាយុបាន ៧ ឆ្នាំ ក៏បានបួសហើយ បានសម្រេចជាព្រះអរហន្ត ។

សូម្បីជនទាំងឡាយឯទៀត អ្នកនៅក្នុងលង្កាទ្វីបនោះ បានសម្រេចមគ្គផល ពណ៌នាគ្រាន់បន្តិចបានឡើយ ដូច្នេះឯង ។

ពណ៌នាអំពីការនៅក្នុងប្រទេសដ៏សមគួរ ចប់ ៚

ប្រែចប់ ថ្ងៃសៅរ៍ ៤ រោច ខែមិគសិរ ព.ស.២៥៣៦
ថ្ងៃទី ១ មករា ១៩៩៤ វេលាយប់

ពណ៌នាភាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន

(៩៣) បុគ្គល អ្នកមានកុសលបានសន្សំទុកហើយ គឺមានអធិការបានធ្វើទុកហើយ ប្រារព្ធនូវព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះខីណាស្រព ក្នុងជាតិដែលកន្លងទៅហើយ ឈ្មោះថា ជាអ្នកមានបុណ្យបានធ្វើទុកហើយ ក្នុងកាលមុន ។ មែនពិត បុគ្គលដូច្នេះ ជាអ្នកមានកុសលមូលដុះឡើងហើយ បានស្តាប់នូវទេសនារបស់ព្រះពុទ្ធ ឬ ព្រះសាវ័ក របស់ព្រះពុទ្ធហើយ រមែងបានសម្រេចព្រះអរហត្ត ដោយកុសលមូលនោះឯង ដូចជាព្រះបាទមហាកប្បិនៈ ជាដើម ។ ព្រោះហេតុនោះ ភាវៈនៃបុគ្គលដូច្នោះ ជាអ្នកមានបុណ្យបានធ្វើទុកហើយ ក្នុងកាលមុន ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា “**ជាមង្គល**” ។

ក្នុងដំណើរនោះ មានរឿងនេះ (ជាឧទាហរណ៍) ៖

(រឿង ព្រះមហាកប្បិនត្ថេរ)

(៩៤) ក្នុងអតីតកាល មានជាងតម្បាញចំនួន ១ ពាន់នាក់ អាស្រ័យនៅ ក្នុងស្រុកមួយ ក្បែរទីក្រុងពារាណសី ។

ក្នុងកាលនោះ ព្រះបច្ចេកពុទ្ធទាំងឡាយ ចំនួន ១ ពាន់រូប អាស្រ័យនៅ ក្នុងហិមវន្តប្រទេស អស់ ៨ ខែ ហើយប្រាថ្នាចង់នៅ ក្នុងជនបទ ៤ ខែ ដែលជារដូវភ្លៀង ទើបចុះនៅ ក្បែរព្រះនគរ

ពណ៌នាអំពីតាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន

ហើយ បានបញ្ជូនព្រះបច្ចេកពុទ្ធ ៨ រូបទៅ ដើម្បីសុំ នូវហត្ថកម្ម យកមកកសាងសេនាសន: ។

ក្នុងកាលនោះ ភរិយា របស់ជាងតម្បាញ ជាចម្បង ដើរទៅកាន់ព្រះនគរ ដោយការណីយកិច្ចបន្តិចបន្តួច បានជួបនឹងព្រះបច្ចេកពុទ្ធ ទាំងនោះ ក៏សួរ ស្តាប់រឿងនោះហើយ ទើបពោលថា " បពិត្រព្រះគុណម្ចាស់ដ៏ចំរើន យើងខ្ញុំទាំងឡាយមានគ្នា ១ ពាន់នាក់ នៅក្នុងស្រុកនេះ បណ្តាពួកនាងខ្ញុំទាំងឡាយ ម្នាក់ ៗ នឹងប្រគេនកិក្ខា ដល់ព្រះគុណម្ចាស់ ១ រូប ៗ, ក្នុងថ្ងៃស្អែកនេះ សូមព្រះគុណម្ចាស់ទាំងឡាយ ទទួលនូវកិក្ខា របស់ពួកនាងខ្ញុំ, ពួកនាងខ្ញុំ នឹងឲ្យគេកសាងសេនាសន: ប្រគេនព្រះគុណម្ចាស់ទាំងឡាយ " ហើយ ក៏បានចូលទៅកាន់ស្រុក បានប្រកាសប្រាប់ហើយ ដល់ពួកមនុស្សទាំងឡាយ ។

ថ្ងៃស្អែកឡើង ឯព្រះបច្ចេកពុទ្ធទាំងឡាយ ក៏បាននិមន្តចូលទៅកាន់ស្រុកនោះហើយ ។ មនុស្សទាំងឡាយ មានធន:តែមួយ ក៏បានប្រគេនកិក្ខា ដល់ព្រះបច្ចេកពុទ្ធទាំងនោះ ហើយនាំគ្នាកសាងនូវបណ្ណសាលា ១ ពាន់ខ្នង បានប្រគេនហើយ ដល់ព្រះបច្ចេកពុទ្ធទាំងឡាយនោះ ក្នុងពេលរួចភត្តកិច្ច ។ ពួកមនុស្សទាំងឡាយនោះ បានទំនុកបម្រុង នូវព្រះបច្ចេកពុទ្ធទាំងឡាយ ដែលបានគង់ចាំព្រះ

មង្គលត្ថទីបនីប្រែ

វស្សា ក្នុងបណ្ណសាលា របស់ខ្លួន ដោយគោរពហើយ ក៏បានប្រគេនចីវរទាំងឡាយ ដល់ព្រះបច្ចេកពុទ្ធទាំងនោះ ដែលបានចាំវស្សាហើយ ។ ព្រះបច្ចេកពុទ្ធទាំងឡាយ អនុមោទនាហើយ ទើបចៀសចេញទៅ ។

ជាឯតម្បាញទាំងនោះ ច្យុតចាកអត្តភាពនោះហើយ កើតមានឈ្មោះថា គណៈទេវបុត្រ ក្នុងតាវត្តិង្ស សោយទិព្វសម្បត្តិក្នុងភពតាវត្តិង្សនោះហើយ បានច្យុតចាកភពនោះ មកកើត ក្នុងត្រកូលកុដុម្ពី ក្នុងទីក្រុងពារាណសី ក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាមកស្សបៈ ។ បណ្តាជាឯតម្បាញទាំងនោះ ជាឯតម្បាញ ដែលជាចម្បង បានជាកូនរបស់កុដុម្ពីដែលជាចម្បង ។ ចំណែកភរិយារបស់គាត់ ក៏បានជាធីតារបស់កុដុម្ពី ដែលជាចម្បងដូចគ្នា ។ ជាឯតម្បាញ ដទៃទៀត ក្រៅពីនោះ បានជាបុត្រធីតា របស់កុដុម្ពី ដទៃក្រៅអំពីនោះ ។ ជនទាំងអស់នោះឯង ចំរើនវ័យហើយ បានជាភរិយាស្វាមី ដល់គ្នានឹងគ្នា រួបរួមទ្រព្យបានហើយ ទើបឲ្យគេធ្វើបរិវេណ ប្រដាប់ដោយបន្ទប់មួយពាន់ កាលធ្វើការឆ្លងបរិវេណ ក៏បានប្រគេនមហាទាន អស់មួយសប្តាហ៍ ដល់ភិក្ខុ ២ ហ្មឺនអង្គ មានព្រះពុទ្ធជាប្រធាន ក្នុងថ្ងៃបញ្ចប់ ក៏បានប្រគេនទូវចីវរ ។

ចំណែកភរិយា របស់កុដុម្ពី ដែលជាចម្បង ប្រាថ្នានឹងធ្វើឲ្យ

ពណ៌នាអំពីតាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន

ឱឡាវិក ទើបបានបូជាព្រះសាស្តា ដោយសំពត់សាដក មានពណ៌ដូចជាផ្កានោង មានតម្លៃ ១ ពាន់ និងដោយផ្កានោងទាំងឡាយ ហើយប្រាថ្នាថា " បពិត្រព្រះអង្គដ៏ចំរើន សូមឲ្យនាងខ្ញុំមានឈ្មោះថា **អនោជា** មានសរីរៈ មានពណ៌ដូចជាផ្កានោង ក្នុងទីដែលនាងខ្ញុំបានកើតហើយៗ " ។

ព្រះសាស្តា ទ្រង់បានអនុមោទនា ថា " ចូរសេចក្តីប្រាថ្នារបស់នាង បានសម្រេច យ៉ាងដូច្នោះចុះ " ។ ជនទាំងអស់នោះឯង អន្ទោលទៅមក ក្នុងទេវតា និង មនុស្សលោក អស់មួយពុទ្ធន្តរ ហើយ ក៏ច្យុតចាកទេវលោក មុនពេល ព្រះសាស្តា របស់យើង ស្តេចកើតឡើងហើយតែម្តង ។ បណ្តាជនទាំងនោះ កុដុម្ពី ដែលចម្បង បានកើត ក្នុងត្រកូលនៃព្រះរាជា ក្នុងកុក្កុដវតីនគរ បានជាព្រះរាជាទ្រង់ព្រះនាម មហាកប្បិនៈ ។ ចំណែកបុរសទាំងឡាយ ក្រៅពីនោះ ក៏បានកើតហើយ ក្នុងត្រកូល នៃអមាត្យ ក្នុងនគរឈ្មោះ កុក្កុដវតីនោះ ដូចគ្នាដែរ ។ ឯភរិយា របស់កុដុម្ពី ដែលជាចម្បង កើតជាធីតា របស់ព្រះរាជា ក្នុងសាគលនគរ ក្នុងមទ្ទរដ្ឋ ទ្រង់មានព្រះនាមថា អនោជា ព្រោះមានព្រះសរីរៈ មានពណ៌ដូចជាផ្កានោង ។ ឯស្ត្រីទាំងឡាយ ក្រៅពីនោះ ក៏បានជាធីតា របស់អមាត្យ ក្នុងសាគលនគរនោះ ដូចគ្នាដែរ ។ ជនទាំងអស់នោះ

មង្គលត្ថទីបនីប្រែ

ចំរើនវ័យហើយ ក៏បានទៅជាភរិយាស្វាមី ដល់គ្នានឹងគ្នាហើយ ។ កាលបើជនទាំងនោះ នៅរួមសាមគ្គីគ្នា យ៉ាងដូច្នេះ, ព្រះសាស្តា របស់យើង ទ្រង់បានស្តេចកើតឡើងហើយ ក្នុងលោក ទ្រង់គង់នៅ ក្នុងក្រុងសាវត្ថី ។

ក្រោយមក ថ្ងៃមួយ ព្រះរាជាព្រះនាមមហាកប្បិនៈ ទ្រង់ ព្រះសណ្តាប់ (ព័ត៌មាន) ចាកសំណាក់ពួកពាណិជ ដែលធ្វើដំណើរ មកអំពីទីក្រុងសាវត្ថី ថា " ព្រះពុទ្ធ ទ្រង់កើតឡើងហើយ, ព្រះធម៌ បានកើតឡើងហើយ, ព្រះសង្ឃ បានកើតឡើងហើយ " ដូច្នេះ ទ្រង់ កើតបីតិ និង សោមនស្សហើយ ទ្រង់បានបូជានូវពាក្យ របស់ ពាណិជទាំងនោះ ដោយទ្រព្យ ៣ សែន ហើយទ្រង់បានត្រាស់ថា " ម្នាលអ្នកទាំងឡាយ អ្នកទាំងឡាយ ចូរទៅកាន់សំណាក់ នៃព្រះ នាងទេវីហើយ ទទួលយកទ្រព្យ ៣ សែនចុះ " ដូច្នេះហើយ ទើប ទ្រង់ស្តេចយាងចេញទៅ ដោយយានដែលទឹមដោយសេះ ឧទ្ទិស ចំពោះព្រះសាស្តា មួយអន្ទើដោយអមាត្យ ១ ពាន់នាក់ ។

ក្នុងថ្ងៃនោះ ចំណែកព្រះសាស្តា ទ្រង់ត្រួតមើលសត្វលោក ក្នុងវេលាទៀបភ្លឺ ទ្រង់ទតព្រះនេត្រឃើញហើយ នូវឧបនិស្ស័យ នៃព្រះអរហត្ត របស់ព្រះរាជា ព្រមទាំងបរិវារ កាលទ្រង់ស្តេចយាង ទៅទទួលព្រះបាទមហាកប្បិនៈនោះ ទ្រង់បានយកបាត្រ និង ចីវរ

ពណ៌នាអំពីភាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន

ដោយព្រះអង្គឯងហើយ ស្តេចយាងទៅ ចាកទីក្រុងសាវត្ថី ១២០ យោជន៍ ទ្រង់គង់ បញ្ចេញព្រះធម្មណ្ឌវង្ស្រ ក្រោមគល់និគ្រោធ ក្បែរមាត់ស្ទឹងចន្ទភាគា ។

ក៏នៅត្រង់ផ្លូវដែលព្រះរាជាស្តេចយាងទៅ មានស្ទឹង ៣ គឺ ស្ទឹង ទី ១ ឈ្មោះ គង្គា, ទី ២ ឈ្មោះ នីលពាហា ជាស្ទឹងដ៏ធំមួយ មានបណ្តោយកន្លះយោជន៍, ទី ៣ ឈ្មោះ ចន្ទភាគា ។

ព្រះរាជា ព្រមទាំងបរិវារ ទ្រង់ស្តេចយាងទៅដល់មាត់ស្ទឹងទាំង ៣ នោះ ដោយលំដាប់ហើយ ទ្រង់ត្រាស់ថា " ធម្មតា ព្រះគុណនៃព្រះសាស្តាអង្គនោះ បានផ្សាយទៅ ឰដ៏ខាងក្រោម តាំងអំពីអវីចិនរក ខាងលើ រហូតទល់គ្នានឹងភវគ្គព្រហ្ម, បើព្រះសាស្តាអង្គនេះ ជាព្រះសម្មាសម្ពុទ្ធមែននោះ, សូមអានទាំងឡាយ (កែប) នៃសេះទាំងនេះ កុំទទឹកឡើយ" ដូច្នេះហើយ ទ្រង់ធ្វើសច្ចកិរិយាហើយ ទ្រង់បានបរសេះទៅ តាមខ្នងទឹក ។ សូម្បីតែអាននៃសេះមួយ ក៏មិនទទឹកឡើយ ។ ព្រះរាជាអង្គនោះ ព្រមទាំងបរិវារ បានឆ្លងនូវស្ទឹង ទី៣ ដោយអាការដូច្នោះឯង ទ្រង់ទតព្រះនេត្រឃើញនូវព្រះធម្មណ្ឌវង្ស្រហើយ ទ្រង់ស្តេចចុះអំពីខ្នងសេះ ទ្រង់បានឱនព្រះកាយហើយ ទើបស្តេចយាងទៅ កាន់សំណាក់ នៃព្រះសាស្តា ទ្រង់ថ្វាយបង្គំហើយ ទ្រង់គង់ព្រះសណ្តាប់ នូវអនុបុព្វីកថា ហើយ

មង្គលត្ថទីបនីប្រែ

ទ្រង់បានសម្រេចព្រះសោតាបន្ន ទ្រង់បានផ្ទួស ដោយភាពដែលជាឯហិភិក្ខុ ទ្រង់ប្រៀបបាននឹងព្រះថេរៈ ដែលមានព្រះវស្សា ១០០ ជាអ្នកទ្រទ្រង់នូវបរិក្ខារ ៨ ។

ចំណែក ព្រះនាងអនោជាទេវី ទ្រង់ព្រះសណ្តាប់នូវការកើតឡើងនៃព្រះពុទ្ធជាដើមហើយ ទ្រង់បានបូជានូវពាក្យរបស់ពាណិជទាំងឡាយ ដោយទ្រព្យ ៩ សែន ទ្រង់បញ្ជូនពួកពាណិជទាំងនោះទៅ ដោយព្រះតម្រាស់ថា " ម្នាលអ្នកទាំងឡាយ ចូរអ្នកទាំងឡាយអញ្ជើញទៅចុះ " យ៉ាងដូច្នេះហើយ មានពួកកវិយារបស់ពួកអមាត្យដែលទៅហើយ ជាមួយនឹងព្រះរាជា ចោមរោមហើយ ស្តេចយាងចេញទៅ ដោយយាន គឺ រថ ឧទ្ទិសចំពោះព្រះសាស្តា ទ្រង់បានឆ្លងហើយ នូវស៊ីងទាំងនោះ ដោយនយមុនទុំៈឯង ។

ព្រះសាស្តា ទ្រង់ព្រះតម្រិះ ថា " កាលបើស្ត្រីទាំងឡាយនេះ ឃើញពួកស្វាមី របស់ខ្លួន, ឆន្ទរាគៈ ក៏គប្បីកើតឡើងហើយ ធ្វើនូវសេចក្តីអន្តរាយដល់មគ្គ, ឆន្ទរាគៈនោះ នឹងមិនអាច ដើម្បីធ្វើយ៉ាងដូច្នេះបានឡើយ " ដូច្នេះ ទ្រង់បានធ្វើហើយ ដោយប្រការដែលជនទាំងឡាយនោះ នឹងមើលគ្នានឹងគ្នាមិនឃើញ ។

ស្ត្រីទាំងអស់នោះ បានឆ្លងស៊ីង ទី ៣ ហើយ ក៏ទៅកាន់សំណាក់ព្រះសាស្តា ថ្វាយបង្គំហើយ អង្គុយស្តាប់នូវអនុបុព្វីកថា

ពណ៌នាអំពីតាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន

ហើយ ក៏បានសម្រេចជាព្រះសោតាបន្ន ។ កិកុ ទាំងនោះ កាលស្តាប់នូវព្រះធម៌ ដែលព្រះសាស្តាទ្រង់សំដែងហើយ ដល់ពួកស្ត្រីទាំងនោះ ក៏បានសម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទាទាំងឡាយ ។ ព្រះសាស្តា ទ្រង់បានរម្ងាប់ នូវឫទ្ធាភិសង្ខារហើយ ។

លំដាប់នោះ ស្ត្រីទាំងនោះ បានឃើញស្វាមី របស់ខ្លួនទាំងនោះ បួសហើយ ទើបបានក្រាបទូលសុំបព្វជ្ជានឹងព្រះសាស្តា ។

ព្រះសាស្តា ទ្រង់ព្រះតម្រិះ ថា " នាងឧប្បលវណ្ណា ភិក្ខុនី ចូលមក " ។ ព្រះថេរី និមន្តមកហើយ បានញុំាងឲ្យស្ត្រីទាំងនោះ បួសហើយ បាននាំទៅកាន់សំណាក់នាងភិក្ខុនី ក្នុងក្រុងសាវត្ថី ។ នាងភិក្ខុនីទាំងនោះ បានសម្រេចព្រះអរហត្ត ទាំងអស់គ្នាហើយ ។

ចំណែក ព្រះសាស្តា ទ្រង់បាននាំភិក្ខុ ១ ពាន់អង្គ ទៅកាន់វត្តជេតពន តាមអាកាសហើយ ។

រឿង ព្រះមហាកប្បិនត្ថេរ មកក្នុងអដ្ឋកថាទាំងឡាយ មានអដ្ឋកថា ឯកនិបាត អង្គុត្តរនិកាយ ជាដើម ។

(សិរីស្តិតនៅធឹងអ្នកមានបុណ្យ)

(៩៥) ម៉្យាងទៀត ព្រោះបុគ្គលអ្នកមានបុណ្យ ដែលមិនបានធ្វើទុកមកហើយ សូម្បីបាននូវវត្ថុ ដែលដល់ព្រមដោយអានុភាព ក៏រមែងជួបប្រទះ នូវសេចក្តីទុក្ខ, បុគ្គលអ្នកមានបុណ្យ

ជានធ្វើទុកមកហើយ កាលបានវត្ថុយ៉ាងដូច្នោះ រមែងបានទទួលនូវសេចក្តីសុខ, មួយទៀត ព្រោះបុគ្គលអ្នកមានបុណ្យ មិនបានធ្វើទុកហើយ រមែងមិនអាច ដើម្បីនឹងទទួលយកនូវសិរី សូម្បីដែលបុគ្គលដទៃ ឲ្យហើយបានឡើយ, សិរីនោះ រមែងចូលដល់បុគ្គលអ្នកមានបុណ្យតែប៉ុណ្ណោះ ព្រោះហេតុដូច្នោះ ភាពនៃបុគ្គលអ្នកមានបុណ្យបានធ្វើទុកហើយ ក្នុងកាលមុន បុគ្គលគប្បីជ្រាបថា "**ជាមង្គល**" ។

ក្នុងដំណើរនោះ មានរឿងនេះ (ជាឧទាហរណ៍) ៖

(រឿង បុរសអ្នកមានវាសនា)

(៩៦) ក្នុងអតីតកាល ព្រាហ្មណ៍ ដែលជាបងប្អូនទើងគ្នា ៤ នាក់ ក្នុងក្រុងពារាណសី បួសជាតាបសឥសី ធ្វើបណ្ណសាលាតាមលំជាប់គ្នាហើយ នៅក្នុងហិមវន្តប្រទេស ។

បណ្តាតាបសទាំងនោះ តាបស ដែលជាចម្បង ធ្វើកាលៈហើយ ក៏បានទៅកើតជាស្តេចសក្កទេវរាជ ។ ស្តេចសក្កទេវរាជនោះ ជ្រាបហេតុនោះហើយ ថ្ងៃមួយ ក៏បានចូលទៅរកតាបសដែលជាប្រធាន ថ្វាយបង្គំហើយ សួរថា "បពិត្រព្រះគុណម្ចាស់ ដ៏ចំរើន តើព្រះគុណម្ចាស់ មានសេចក្តីត្រូវការ ដោយវត្ថុអ្វីខ្លះ" ។

ឯតាបសនោះ ជាអ្នកមានរោគលឿង ព្រោះហេតុនោះ

ទើបពោល ថា " អាត្មាភាព មានសេចក្តីត្រូវការដោយក្តៅ " ។

ស្តេចសក្កទេវរាជ ទ្រង់ត្រាស់ថា " បពិត្រព្រះគុណម្ចាស់ ដ៏ចំរើន បើព្រះគុណម្ចាស់ត្រូវការក្តៅ សូមព្រះគុណម្ចាស់ គប្បីយកដៃគោះ នូវកាំបិតព្រានេះ ហើយពោលថា ចូរអ្នកទៅរកឧសមក ហើយ បង្កាត់ក្តៅ យ៉ាងដូច្នេះ, កាំបិតព្រានេះ ក៏នឹងធ្វើតាម យ៉ាងដូច្នោះ " ដូច្នេះហើយ ទើបទ្រង់បានប្រទានកាំបិតព្រា ដល់តាបសនោះហើយ ។ កាំបិត ក្តី ប៉ូវថៅ ក្តី ឈ្មោះថា វាសីផរសុកៈ ដោយអំណាចញាត់បញ្ជូលទៅក្នុងជង្ឃបាន ។

ស្តេចសក្កទេវរាជ ទ្រង់បានស្តេចយាងទៅរកតាបស ទី ២ ហើយ ទ្រង់ត្រាស់សួរ យ៉ាងដូច្នោះដែរ ។ ផ្លូវនៃដំរី មាននៅក្បែរបណ្ណសាលា របស់តាបសនោះ ។ តាបសនោះ ត្រូវដំរីទាំងឡាយបៀតបៀនហើយ ទើបពោលថា " សេចក្តីទុក្ខ រមែងកើតឡើង ដល់អាត្មាភាព ដោយអំណាចនៃដំរីទាំងឡាយ, សូមព្រះអង្គ ញុំាងដំរីទាំងនោះ ឲ្យចៀសចេញទៅ " ។

ស្តេចសក្កទេវរាជ ទ្រង់ត្រាស់ថា " បពិត្រព្រះគុណម្ចាស់ដ៏ចំរើន កាលបើព្រះគុណម្ចាស់ ទះផ្ទៃនៃស្គរនេះ, ពួកបច្ចាមិត្ររបស់ព្រះគុណម្ចាស់ ក៏នឹងរត់ចេញទៅ, កាលបើព្រះគុណម្ចាស់ទះផ្ទៃស្គរនេះហើយ, សេនា ដែលមានអង្គ ៤ ក៏នឹងមានចិត្តប្រកប

ដោយមេត្តាហើយ មកចោមរោម " ដូច្នេះហើយ ទើបទ្រង់បានប្រទាននូវស្គរមួយ ដល់តាបសនោះ ស្រេចហើយ ទ្រង់ស្តេចយាងទៅរកតាបស ទី ៣ ទៀត ទ្រង់បានត្រាស់សួរ យ៉ាងដូច្នោះដែរ ។

តាបសនោះ មានរោគលឿង ព្រោះហេតុនោះ ទើបពោលថា " អាត្មាភាព មានសេចក្តីត្រូវការ ដោយទឹកដោះជូរ " ។

ស្តេចសក្កទេវរាជ ទ្រង់បានប្រទាន នូវក្រឡនៃទឹកដោះជូរមួយ ដល់តាបសនោះហើយ ទើបត្រាស់ ថា " បើព្រះគុណម្ចាស់ប្រាថ្នា សូមផ្តាប់ក្រឡនៃទឹកដោះជូរនោះ, ទឹកដោះជូរនេះ ក៏នឹងក្លាយទៅជាស្ទឹងដ៏ធំ ញាំងអន្ទង់ដ៏ធំ ឲ្យហូរទៅបាន ហើយអាចដណ្តើមយក នូវរាជសម្បត្តិ មកប្រគេន ដល់ព្រះគុណម្ចាស់បាន " ដូច្នេះហើយ ទើបស្តេចយាងចេញទៅ ។

ចាប់ដើមអំពីពេលនោះមក កាំបិតព្រា ក៏បង្កាត់ភ្លើង ដល់តាបសដែលជាប្រធាន ។ កាលបើតាបស ទី ២ ទះផ្ចៃ នៃស្គរហើយ, ជំរឿទាំងឡាយ ក៏ចោលរត់ទៅ ។ តាបស ទី ៣ ក៏ធាន់នូវទឹកដោះជូរ ។

ក្នុងកាលនោះ ជ្រូកមួយ កាលចោលទៅ ក្នុងទីស្ថាន នៃស្រុកចាស់ ក៏ឃើញជុំនៃកែវមណី ដែលដល់ព្រមដោយអានុភាព ទើបពាំដោយមាត់ហើយ ហោះទៅកាន់អាកាស ដោយអានុភាព

ពណ៌នាអំពីតាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន

នៃកែវមណីនោះ ឃើញកោះមួយ ត្រង់កណ្តាលសមុទ្រ ក៏ចុះមក ហើយ ដេកនៅក្រោមដើមឧទុម្ពរមួយដើម ។ ថ្ងៃមួយ ជ្រូកនោះ ជាក់ដុំកែវមណីទុក ខាងមុខ ហើយក៏ដេកលក់ ក្បែរគល់ឈើ ។

គ្រានោះ បុរសអ្នកនៅក្នុងដែនកាសីម្នាក់ ត្រូវម្តាយឪពុក បណ្តេញចេញពីផ្ទះ ជាកម្មកររបស់អ្នកនាវាទាំងឡាយ ឡើងទូក ហើយ, កាលបើទូកបែកផ្ងាយហើយ ត្រង់កណ្តាលសមុទ្រ, ក៏ ដេកបណ្តែកលើបន្ទះក្តារ បានទៅដល់កោះនោះ កាលស្វះស្វែង រកផលាផល ក៏ប្រទះឃើញជ្រូកនោះ កំពុងតែដេកលក់ ហើយ ដើរទៅលប ៗ យកដុំកែវមណី ហោះទៅកាន់អាកាស ដោយ អានុភាព នៃកែវមណីនោះ អង្គុយលើមែកឧទុម្ពរហើយ នឹកគិត ថា " ជ្រូកនេះ ដូចជាហោះទៅ លើអាកាស ដោយអានុភាព នៃកែវ មណីនេះ ទើបបាននៅ ក្នុងទីនេះ, ការដែលអញសម្លាប់ជ្រូកនេះ ស៊ីសាច់ហើយ ចាំធ្វើដំណើរទៅទើបគួរ" ដូច្នេះហើយ ក៏បានកាច់ មែកឈើមួយមែក ទម្លាប់លើ ក្បាលជ្រូកនោះ ។

ជ្រូកភ្ញាក់ឡើង កាលមិនឃើញកែវមណី ក៏ប្រាលចលា ចល់ ទៅខាងនេះផង ខាងនោះផង ។ បុរសនោះ បានសើចចំអក ឲ្យហើយ ។ ជ្រូក អើតមើលខាងលើ ឃើញបុរសនោះ ក៏យក ក្បាលជល់នឹងដើមនោះ ហើយបានស្លាប់ ក្នុងទីនោះភ្លាម ។

មង្គលត្ថទីបនីប្រែ

បុរសនោះ ចុះមក បង្ហាត់ភ្លើង អាំងសាច់ជ្រូកនោះ ស៊ី ហើយ ហោះទៅកាន់អាកាស កាលទៅតាមទីបំផុត នៃប្រទេស ហេមពាន្ត ឃើញអាស្រមបទ ក៏នៅ ក្នុងអាស្រមបទ នៃតាបស ជាចម្បង ២-៣ ថ្ងៃ បានឃើញអានុភាព នៃកាំបិតព្រា ទើប សំដែងអានុភាព នៃកែវមណីរបស់ខ្លួន ហើយពោលថា " បពិត្រ ព្រះគុណម្ចាស់ដ៏ចំរើន សូមព្រះគុណម្ចាស់ យកកែវមណីនេះចុះ ហើយឲ្យកាំបិតព្រា មកដល់ខ្ញុំ " ។

តាឥសី ច្រាច្នានឹងហោះទៅ លើអាកាស ទើបទទួលយក កែវមណីហើយ បានឲ្យកាំបិតព្រាមួយនេះ ដល់បុរសហើយ ។ បុរសនោះ ទទួលយកកាំបិតព្រាហើយ ដើរទៅបានបន្តិច ក៏គោះ កាំបិតព្រា ហើយពោលថា "ចូរអ្នកកាត់ក្បាលតាបសនោះហើយ នាំយកកែវមណីមកវិញ " ។ កាំបិតព្រា បានធ្វើហើយ យ៉ាង ដូច្នោះ ។ បុរសនោះ បានលាក់កាំបិតព្រា ក្នុងទីកំបាំង ហើយ ចូលទៅរកតាបស ទី ២ នៅបាន ពីរ-បី ថ្ងៃ ឃើញអានុភាព នៃស្គរ ទើបឲ្យកែវមណី ហើយទទួលយកស្គរ បានបញ្ជា ឲ្យ កាំបិតព្រាទៅកាត់ក្បាលតាបសទី ២ នោះ ដោយន័យមុនទុំ៉ះឯង ហើយចូលទៅរកតាបស ទី ៣ ឃើញអានុភាព នៃក្រឡទឹកដោះ ជូរហើយ ក៏បានឲ្យកែវមណី ហើយទទួលយកក្រឡ នៃទឹកដោះ

ពណ៌នាអំពីតាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន

ជូរ បានបញ្ជាឲ្យកាំបិតព្រា ទៅកាន់ក្បាលតាបស ទី ៣ នោះ យ៉ាងដូច្នោះដែរ ហើយបាននាំយកវបស់ទាំងពួង ហោះទៅកាន់អាកាស ចុះក្នុងទីមិនឆ្ងាយ ពីទីក្រុងពារាណសី ហើយបានបញ្ជូនសំបុត្រ ក្នុងដៃនៃបុរសម្នាក់ ទៅថ្វាយព្រះបាទក្រុងពារាណសី ថា " ព្រះរាជា ក្រុងពារាណសី នឹងឲ្យនូវការធ្វើសង្គ្រាម ឬក៏ ឲ្យនូវរាជសម្បត្តិ ដល់យើង " ។

ព្រះរាជា ទ្រង់ព្រះសណ្តាប់ព័ត៌មានហើយ ទ្រង់ស្តេចយាងចេញមក ដោយតាំងព្រះទ័យថា " អញនឹងចាប់ចោរ " ។ បុរសនោះ បានវាយស្គរហើយ ។ សេនា ប្រកបដោយអង្គ ៤ បាន ចោមរោមបុរសនោះហើយ ។ បុរសនោះ ដឹងថា ព្រះរាជា ទ្រង់លើកពលមក ក៏បានចាក់ក្រឡនៃទឹកដោះជូរហើយ ។ ស្ទឹងដ៏ធំ បានហូរទៅហើយ ។ មហាជន បានលង់ក្នុងទឹកដោះជូរហើយ មិនអាចដើម្បីនឹងឆ្លងបានឡើយ ។ បុរសនោះ បានគោះកាំបិតព្រា ហើយពោលថា "ចូរអ្នកនាំយកព្រះសិរសី របស់ព្រះរាជា មកចុះ " ។ កាំបិតព្រានោះ បានទៅនាំយកព្រះសិរសី មកដាក់ក្បែរជើងហើយ ។ ទាហាន ម្នាក់ ៗ មិនអាចដើម្បីនឹងលើកអាវុធបានឡើយ ។ បុរសនោះ ត្រូវពួកពលដ៏ច្រើន ចោមរោមហើយ ចូលទៅកាន់នគរ បានឲ្យគេធ្វើការអភិសេកហើយ ក៏បាន

មង្គលត្ថទីបនីប្រែ

ឡើងជាព្រះរាជា ព្រះនាមទធិវាហនៈ ។

រឿងជ្រូកបានកែវមណី មកក្នុងទធិវាហនជាតក ក្នុងទុក្កនិបាត ។

(រឿង ព្រាហ្មណ៍លួចសិរី)

(៥៧) បានឮមកថា ព្រាហ្មណ៍អ្នកដឹងនូវលក្ខណៈសិរីម្នាក់ អាស្រ័យនៅ ក្នុងក្រុងសាវត្ថី ។ ថ្ងៃមួយ ព្រាហ្មណ៍នោះ គិតថា " អនាថបិណ្ឌិកសេដ្ឋីនេះ ជាអ្នកក្រីក្រលំបាកហើយ ត្រឡប់ជាឥស្សរៈ ម្ដងវិញទៀត, ធ្វើដូចម្ដេចហ្ន៎ អាត្មាអញ នឹងគប្បីលួចនូវសិរី របស់សេដ្ឋីនោះ យកមកបាន " ដូច្នេះហើយ ក៏បានទៅផ្ទះរបស់អនាថបិណ្ឌិកសេដ្ឋី ។

ក៏សេដ្ឋី មានមាន់សសុទ្ធ ប្រៀបបាននឹងសង្ឃ៍ដែលគេខាត់ហើយ ក្រុងទុក ក្នុងទ្រុងមាស, សិរី តាំងនៅលើសិរមាន់នោះ ។

ព្រាហ្មណ៍បានទៅក្នុងផ្ទះនៃសេដ្ឋីនោះ ត្រូវសេដ្ឋីធ្វើសក្ការៈនិងការរាប់អានហើយ សួរថា " តើអ្នកមកដើម្បីប្រយោជន៍អ្វី? " ដូច្នេះ កាលត្រួតមើលថា " តើសិរី ស្ថិតនៅទីណាហ្ន៎? " ក៏ដឹងថា " នៅលើសិរមាន់ " ហើយពោលថា " បពិត្រលោកសេដ្ឋី ខ្ញុំនឹងប្រាប់នូវមន្តនឹងមាណព ៥០០ នាក់, មាណពទាំង ៥០០ នាក់នោះ និង យើងខ្ញុំអាស្រ័យមាន់ដែលរងាវមិនត្រូវកាល រមែងលំបាក, បានឮថា មាន់មួយនេះ រងាវត្រូវពេលវេលា, ខ្ញុំមកនេះ

ពណ៌នាអំពីតាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន

ដើម្បីត្រូវការមាន់នេះ, សូមលោកសេដ្ឋី ឲ្យមាន់នោះដល់ខ្ញុំផង" ។

សេដ្ឋីនោះ ពោលថា " ម្នាលព្រាហ្មណ៍ ចូរអ្នកចាប់យកចុះ, ខ្ញុំឲ្យនូវមាន់ ដល់អ្នក " ។ ក៏ក្នុងពេលដែលលោកសេដ្ឋីពោលថា " ខ្ញុំនឹងឲ្យ " ដូច្នោះឯង សិរី ក៏បានវត់ចេញបាត់ អំពីសិរមាន់នោះ ហើយទៅស្ថិតនៅលើកែវមណី ដែលលោកសេដ្ឋីតាំងទុក ព្ងជ័ក្បាលដំណេក ។ ព្រាហ្មណ៍ ជឹងរឿងនោះហើយ ទើបបានសុំ នូវកែវមណីទៀត ។ ក្នុងពេលដែលលោកសេដ្ឋីពោលថា " ខ្ញុំ នឹងឲ្យនូវកែវមណី " ប៉ុណ្ណោះឯង សិរី ក៏បានវត់ចេញបាត់អំពីកែវមណី ហើយទៅស្ថិតនៅលើចុងឈើច្រត់ ដែលលោកសេដ្ឋីបានតាំងទុកលើក្បាលដំណេក ។ ព្រាហ្មណ៍ ជឹងរឿងនោះហើយ ទើបបានសុំ នូវឈើច្រត់នោះទៀត ។ ក្នុងពេលដែលលោកសេដ្ឋី ពោលថា " ខ្ញុំ នឹងឲ្យ " ន៎ុះឯង សិរី ក៏បានវត់ចេញបាត់អំពីឈើច្រត់នោះហើយ ទៅស្ថិតនៅ លើសិរសី នៃអគ្គមហេសីរបស់សេដ្ឋី ឈ្មោះ នាងបុញ្ញលក្ខណាទេវី ។

ព្រាហ្មណ៍ ជឹងរឿងនោះហើយ ទើបគិត ថា " កណ្ហៈនោះគឺកវិយារបស់លោកសេដ្ឋី មិនព្រមលះបង់, អញ មិនអាចដើម្បីនឹងសូម (នូវកណ្ហៈន៎ុះ) បានឡើយ " ដូច្នេះហើយ ក៏បានប្រាប់តាមសេចក្តីពិត ដល់សេដ្ឋី ហើយពោលថា " ខ្ញុំ មិនអាច ដើម្បី

មង្គលត្ថទីបនីប្រែ

និងលួចនូវសិរី របស់លោកសេដ្ឋីបានឡើយ, របស់ដែលមាន នៅ នៃលោកសេដ្ឋី ចូរជារបស់ នៃលោកសេដ្ឋីដដែលចុះ" ដូច្នេះ ហើយ ក៏បានចៀសចេញទៅហើយ ។

*ភាពជាឥស្សរៈ ដែលព្រះដ៏មានព្រះភាគ ទ្រង់បានត្រាស់ សំដៅយកហើយ ក្នុងទេវតាសំយុត្ត ថា " **សិរិសួស្តី ជាលំនៅ នៃភោគៈទាំងឡាយ** " ដូច្នេះ ឈ្មោះថា **សិរី** ។*

*ក្នុងអដ្ឋកថាទេវតាសំយុត្តនោះ លោកពោលថា " ភាពជា ឥស្សរៈ ឈ្មោះថា **សិរី** ។ បទថា **អាសយោ** បានដល់ ជាទី សម្រាប់នៅ ។ មែនពិត កាលបើភាពជាឥស្សរៈ មាននៅចំពោះ មុខ, ភោគៈ ទាំងឡាយ រមែងមក តាមផ្លូវគោកខ្លះ តាមផ្លូវទឹកខ្លះ តែម្តង ។ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់បាន ត្រាស់ព្រះតម្រាស់នោះហើយ " ។*

ព្រោះហេតុនោះ សិរីនោះ រមែងសម្រេចបាន ដោយ អានុភាពនៃបុណ្យ ។ សិរីនោះឯង ដោយសេចក្តី គឺការដល់ព្រម នៃបុណ្យ កម្លាំងនៃបុណ្យនុ៎ះឯង, ព្រោះហេតុនោះ បុគ្គលអ្នកមាន បុណ្យតិច ក៏មិនអាច ដើម្បីនឹងទទួលយកនូវសិរី សូម្បីដែលពួក ជនដទៃ ឲ្យហើយបានឡើយ ដោយប្រការដូច្នេះ ។

រឿង ព្រាហ្មណ៍លួចសិរី ចប់ ។

ពណ៌នាអំពីតាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន

(៩៨) ក៏កាលបើព្រាហ្មណ៍នោះ ចៀសចេញទៅហើយ, លោកសេដ្ឋី ក៏បានទៅកាន់វត្តជេតពនហើយ ក្រាបទូលរឿងរ៉ាវទាំងអស់ ដល់ព្រះសាស្តា ។

ព្រះសាស្តា ទ្រង់ត្រាស់ថា " ម្នាលគហបតី សិរីរបស់ពួកជនដទៃ រមែងទៅក្នុងទីដទៃ ក្នុងពេលឥឡូវនេះ តែប៉ុណ្ណោះ ក៏ទេ, សូម្បីក្នុងកាលមុន សិរី ដែលពួកជនអ្នកមានបុណ្យតិច បានធ្វើឲ្យកើតឡើងហើយ ក៏បានទៅដល់ហើយ កែ្បរជើងរបស់ពួកជនអ្នកមានបុណ្យប៉ុណ្ណោះ " ដូច្នេះហើយ ត្រូវលោកសេដ្ឋីក្រាបទូលសុំហើយ ទើបទ្រង់បាននាំនូវអតីតនិទានមក (សំដែង) ថា ៖

(រឿង បុរសអ្នករកឧស)

ក្នុងអតីតកាល មានបុរស អ្នករកឧសម្នាក់ ក្នុងទីក្រុងពារាណសី ។ ថ្ងៃមួយ បុរសនោះ ដឹកឧសចេញមក អំពីព្រៃមិនអាច (ទៅទាន់) ទ្វារនគរ ក្នុងវេលាបាន ក៏បានដេក ក្នុងខួមនៃទេវតាមួយ ក្នុងវេលាល្ងាច ។

មាន់ជាច្រើន ដែលគេលែងចោល ក្នុងខួមទេវតា ដេកនៅលើដើមឈើមួយដើម ក្នុងទីមិនឆ្ងាយអំពីខួមទេវតានោះ ។ ក្នុងចំណោមហ្វូងមាន់ទាំងនោះ មាន់ដែលដេកនៅខាងលើមួយ បានជុះអាចម៍ជាក់ លើខ្លួនមាន់ ដែលដេកនៅ ខាងក្រោម ក្នុងពេល

មង្គលត្ថទីបនីប្រែ

ទៀបភ្លឺ, កាលបើមាន់ខាងក្រោម ស្រែកថា " អ្នកណា ជុះអាចម៍ជាក់ខ្លួនរបស់ខ្ញុំ ? " ដូច្នេះ ទើបស្រែកថា " ខ្ញុំមិនបានពិចារណា ទើបបានជាជុះជាក់ " ហើយ ក៏បានជុះជាក់មក ម្តងទៀត ។

បន្ទាប់មក មាន់ទាំង ២ នោះ ក៏បានធ្វើការឈ្លោះប្រកែកគ្នាថា " អ្វីជាកម្ចាំង របស់អ្នក ?, អ្វីជាកម្ចាំង របស់អ្នក ? " ។ គ្រានោះ មាន់ដែលនៅខាងក្រោម អួតអាង ថា " អ្នកណាសម្លាប់ខ្ញុំហើយ អាំងលើរងើកភ្លើង ស៊ីសាច់ដែលឆ្អិនហើយ នឹងបានទ្រព្យ ១ ពាន់ កហាបណៈ តាំងអំពីព្រឹកព្រលឹម " ។

ចំណែក មាន់ដែលនៅខាងលើ បានអួតអាងថា " នែអ្នកជ័ចំរើន អ្នកគម្រាម ដោយពាក្យប្រមាណប៉ុណ្ណេះ, ក៏អ្នកដែលស៊ីសាច់ដុំរបស់ខ្ញុំ នឹងបានជាព្រះរាជា, អ្នកដែលស៊ីសាច់ខាងក្រៅ បើបុរស ក៏នឹងបានតំណែងសេនាបតី, បើជាស្ត្រីវិញ ក៏នឹងបានតំណែងជាអគ្គមហេសី, ចំណែកអ្នកដែលស៊ីសាច់ជាប់ឆ្អឹង បើជាគ្រហស្ថ ក៏នឹងបានតំណែងជាអ្នកថែរក្សាឃ្លាំង, បើជាបព្វជិតវិញ ក៏នឹងបានជាអ្នកចូលកាន់រាជត្រកូល " ។

បុរសអ្នករកឧស បានឮពាក្យ របស់មាន់ទាំងគូនោះហើយ ទើបបានលប ៗ ឡើងទៅ ចាប់មាន់ដែលនៅខាងលើ យកមកសម្លាប់ហើយ គិតថា " អញ នឹងបានជាព្រះរាជា " ហើយ ក៏បាន

ពណ៌នាអំពីតាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន

ទៅកាន់ផ្ទះ បានឲ្យហើយ ដល់ភរិយា ដោយប្រាប់ថា " ចូរនាង ចាត់ចែង នូវសាច់មាន់នេះ ឲ្យបានល្អ " ។

ភរិយានោះ បានធ្វើ ដូចជាស្វាមីបញ្ជា ហើយពោល ថា " បពិត្រអ្នកប្តី ចូរបង់ពិសាចុះ " ហើយ ក៏បានបង្អោនចូលទៅ ។

ស្វាមីនោះ ពោលថា " នែនាងដ៏ចំរើន សាច់នេះ មានអានុភាពច្រើន, បង់បរិភោគសាច់នោះហើយ នឹងបានជាព្រះរាជា, អូនឯង នឹងបានជាព្រះអគ្គមហេសី, ចូរអូន នាំយកកក្តិ និងសាច់មកចុះ, ពួកយើង នឹងទៅងូតទឹក ក្នុងទន្លេគង្គាហើយបរិភោគ " ។ ស្វាមី និង ភរិយាទាំង ២ នាក់នោះ បាននាំគ្នាទៅហើយ ដាក់ថាសនៃកត្តិ ក្បែរមាត់ច្រាំងទន្លេគង្គា បានចុះទៅហើយ ដើម្បីនឹងងូតទឹក ។ ក្នុងខណៈនោះ ទឹក បានត្រូវខ្យល់ ធ្វើឲ្យកម្រើកហើយ ក៏បាននាំយកភាជនៈនៃកត្តិទៅហើយ ។

គ្រានោះ មហាអមាត្យម្នាក់ ជាអ្នកហ្វឹកជំរឹ កាលលាងជំរឹក្នុងទន្លេ ខាងក្រោម ក៏ឃើញ នូវភាជនៈនៃកត្តិនោះ ត្រូវខ្យល់ទឹកកំពុងផាត់មក ក៏បានឲ្យគេស្រង់ឡើងយកមក ឃើញនូវអាហារទាំងអស់នោះ ក៏បានបញ្ជាឲ្យបិទភាជនៈនៃកត្តិនោះ ហើយបញ្ជូនទៅ ដល់ភរិយា ។ ចំណែក បុរសអ្នករកឧសនោះឯង មានពោះឡើងប៉ោងហើយ ព្រោះទឹកលាយដោយជីខ្ជាច់ ហូរចូលទៅ ក្នុង

មាត់ បានវត់ទៅហើយ ។

លំដាប់នោះ តាបសក្អែកទិព្វ ដែលជាកុលុបកៈ របស់អ្នកហ្វឹកដំរី ១ រូប អាស្រ័យនៅក្នុងព្រះរាជឧទ្យាន ពិចារណា ដោយទិព្វចក្ខុ ថា " ឧបដ្ឋាក របស់អាត្មាអញ មិនព្រមលះបង់តំណែងនៃអ្នកហ្វឹកដំរី, តើពេលណាទៅហ្ន៎ គេនឹងបានទទួលនូវសម្បត្តិ " ដូច្នេះ បានដឹងនូវហេតុនោះហើយ ទើបបាននិមន្តទៅគង់នៅ លើភោងនៃអ្នកហ្វឹកដំរីជាមុន ។

ចំណែក អ្នកហ្វឹកដំរី បានមក អង្គុយហើយ ឲ្យបុគ្គលនាំយកភាជនកត្តមក បានប្រគេនហើយដល់តាបស ។ តាបស បានឲ្យបុគ្គលចែកសាច់ដុំជាដើម ជាចំណែកមួយ ៗ ឲ្យបុគ្គល ឲ្យហើយនូវសាច់ដុំដល់អ្នកហ្វឹកដំរី សាច់ខាងក្រៅ ដល់ភរិយារបស់គាត់ ខ្លួនឯង បានឆាន់សាច់ឆ្អឹង ស្រេចហើយ ពោលថា " ក្នុងថ្ងៃទី ៣ បន្ទាប់ពីថ្ងៃនេះទៅ លោក នឹងបានជាព្រះរាជា, សូមលោកកុំបីប្រមាទ " ដូច្នេះហើយ ក៏បាននិមន្តចេញទៅហើយ ។

ក៏ក្នុងថ្ងៃ ទី ៣ ព្រះរាជាជិតខាងមួយអង្គ ទ្រង់ស្តេចយាងមក ទ្បោមព័ទ្ធក្រុងពារាណសី ។ គ្រានោះ ព្រះរាជា ទ្រង់បានត្រាស់បញ្ជា ឲ្យមហាអាមាត្យអ្នកហ្វឹកដំរី ទទួលភេទជាព្រះរាជា ហើយទ្រង់ត្រាស់ ថា " ចូរអ្នកឡើងជិះដំរី ធ្វើសង្គ្រាមចុះ " ដូច្នេះ

ពណ៌នាអំពីតាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន

ហើយ ព្រះអង្គឯង ទ្រង់បានបន្ទំកេទ យាងត្រួតកងទ័ព ត្រូវកូនសរ ដែលមានកម្ទាំងខ្លាំងក្លាមួយ ចាក់ទំលុះ ទ្រង់បានសោយទិវង្គតហើយ ក្នុងខណៈនោះឯង ។

អ្នកហ្វឹកជំរី ជឹងថា ព្រះរាជាអង្គនោះ សោយទិវង្គតហើយ ទើបឲ្យគេនាំយកកហាបណៈ ជាច្រើនចេញមក បានឲ្យវាយស្គរប្រកាសថា " ជនទាំងឡាយអ្នកត្រូវការទ្រព្យ ចូរធ្វើសង្គ្រាម " ។ ពួកពល បានញាំងព្រះរាជាដែលជាសត្រូវ ឲ្យដល់ហើយនូវការអស់ទៅនៃព្រះជន្មាយុ ដោយកាលមួយភ្លែតប៉ុណ្ណោះឯង ។

ពួកអាមាត្យ បានថ្វាយព្រះភ្លើងព្រះសរីរកិច្ច របស់ព្រះរាជានៃខ្លួនហើយ ទើបប្រឹក្សាគ្នាថា " ព្រះរាជា កាលទ្រង់មានព្រះជន្មាយុនៅឡើយ ទ្រង់បានព្រះរាជទានហើយ នូវកេទរបស់ព្រះអង្គ ដល់អ្នកហ្វឹកជំរីនេះ, បុរសអ្នកហ្វឹកជំរីនុ៎ះឯង បានធ្វើសង្គ្រាមហើយ ដណ្តើមយកភាជសម្បត្តិមកបាន, ពួកយើង នឹងប្រគល់ភាជសម្បត្តិ ដល់បុរសអ្នកហ្វឹកជំរីនេះ " ដូច្នេះហើយ ទើបបានអភិសេកបុរសអ្នកហ្វឹកជំរី ក្នុងភាជសម្បត្តិហើយ និង បានតែងតាំងភរិយា របស់អ្នកហ្វឹកជំរីនោះ ជាព្រះអគ្គមហេសី ។ ចំណែកតាបស បានឡើងជាព្រះរាជកុលុបកៈហើយ ។

រឿង បុរសអ្នករកឧស ចប់ ។

មង្គលត្ថទីបនីប្រែ

(៩៩) ព្រះសាស្តា លុះទ្រង់នាំអតីតនិទាននេះ មកហើយ កាលទ្រង់សំដែងធម៌ដល់អនាថបិណ្ឌិកសេដ្ឋីនោះ ទើបទ្រង់ត្រាស់ ព្រះគាថាទាំងនេះ ក្នុងសិរីចោរជាតក [1] ក្នុងតិកនិបាត ថា ៖

ពួកបុគ្គលអ្នកឥតបុណ្យ មានសេចក្តីខ្វល់ខ្វាយ ទោះមានសិល្បៈក្តី មិនមានសិល្បៈក្តី ប្រមូលទ្រព្យណា បានមកដ៏ប្រើន, ឯអ្នកមានបុណ្យប៉ុណ្ណោះ រមែងបរិភោគទ្រព្យទាំងឡាយនោះ, ភោគៈទាំងឡាយ ជាប្រើន រមែងកន្លងនូវសត្វដទៃ (អ្នកឥតបុណ្យ) ហើយកើតឡើង ដល់បុគ្គលអ្នកមានបុណ្យបានធ្វើទុកហើយ ក្នុងទីទាំងពួងប៉ុណ្ណោះ, មួយទៀត ភោគៈទាំងឡាយដ៏ប្រើន រមែងកើតឡើង សូម្បីក្នុងទីមិនមែនជាកន្លែងសម្រាប់កើតឡើងទាំងឡាយ ។

បណ្តាបទទាំងនោះ បទថា “ ***យំ*** *” ប្រែថា ទ្រព្យឯណា ។ ជាបៈថា “* ***យេ*** *” ដូច្នេះ ក៏មាន ។ សេចក្តីថា “ បុរសទាំងឡាយឯណាមួយ ” ។ បទថា “* ***ឧស្សុក្កា*** *” បានដល់ ជាអ្នកដល់នូវការខ្វល់ខ្វាយ គឺ កើតសេចក្តីពេញចិត្ត ក្នុងការរួបរួមទ្រព្យ ។ បុគ្គលអ្នកមិនមានបុណ្យ ឈ្មោះថា* ***អលក្ខិកា*** *។ បុគ្គលអ្នកមិនមានបុណ្យទាំងនោះ មានសិល្បៈក្តី មិនមានសិល្បៈក្តី ដោយ*

១- សុត្តន្តបិដក ភាគទី ៥៨ ទំព័រទី ១៦៩ ។

ពណ៌នាអំពីតាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន

អំណាច នៃសិល្បៈ មានសិល្បៈ គឺជំរឿ ជាដើម ដោយហោចទៅសូម្បីធ្វើទូវការងារ ដោយថ្លៃឈ្នួល រួបរួម គឺ ប្រមូលទ្រព្យជាច្រើន ដោយសេចក្តីលំបាក ។ បទថា “ ***លក្ខី វ*** *” មានសេចក្តីថា បុរសដទៃទៀត អ្នកមានបុណ្យប៉ុណ្ណោះ សូម្បីមិនបានធ្វើការងារអ្វីមួយ ក៏រមែងបរិភោគទ្រព្យទាំងឡាយ គឺ ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា “ ទ្រព្យជាច្រើន ” ដោយផលបុណ្យរបស់ខ្លួន ។*

បទថា “ ***អតិច្ចា*** *” ប្រែថា កន្លងហើយ ។* ***ឯវ*** *សព្ទ ក្នុងពាក្យថា “* ***អញ្ញេវ*** *” គប្បីប្រកប ដោយបទថា “* ***សព្ពត្ត*** *” ទុំៈថា “ កោគៈទាំងឡាយដ៏ច្រើន រមែងកន្លងនូវសត្វទាំងឡាយដទៃ អ្នកមិនបានធ្វើបុណ្យទុកហើយ កើតឡើង ដល់បុគ្គលអ្នកបានធ្វើបុណ្យទុកហើយ ក្នុងទីទាំងពួងប៉ុណ្ណោះ ” ។*

បានគាថា ថា “ ***អបិ នាយតនេសុបិ*** *” មានសេចក្តីថា ម៉្យាងទៀត កោគៈទាំងឡាយជាច្រើន ទាំងមានវិញ្ញាណ និង ទាំងមិនមានវិញ្ញាណ រមែងកើតឡើង សូម្បីក្នុងទីមិនមែនជាកន្លែងសម្រាប់កើតទាំងឡាយ គឺ រតនៈទាំងឡាយរមែងកើតឡើង ក្នុងទីមិនមែនជាកន្លែងសម្រាប់កើតនៃរតនៈទាំងឡាយ, វត្ថុទាំងឡាយមានមាសជាដើម រមែងកើតឡើង ក្នុងទីមិនមែនជាកន្លែងសម្រាប់*

មង្គលត្ថទីបនីប្រែ

កើតនៃមាសជាដើម, សត្វទាំងឡាយ មានជំរីជាដើម រមែងកើតឡើង ក្នុងទីមិនមែនជាកន្លែងសម្រាប់កើតនៃជំរីជាដើម ។ បណ្តាភោគៈ ដែលមានវិញ្ញាណ និង មិនមានវិញ្ញាណទាំងនោះ ក្នុងការកើតឡើង ក្នុងទីមិនមែនជាកន្លែងសម្រាប់កើតឡើង នៃភោគៈដែលមិនមានវិញ្ញាណទាំងឡាយ មានកែវមុត្តា និង កែវមណីជាដើម គប្បីសំដែងរឿងនៃព្រះបាទទុដ្ឋគាមណីអភ័យ ។

(រឿង ព្រះបាទទុដ្ឋគាមិនីអភ័យ)

(១០០) បានឮថា មានព្រះរាជបុត្រ នៃព្រះរាជាព្រះនាមកាកវណ្ណតិស្សៈ ព្រះអង្គទ្រង់គ្រប់គ្រងរាជសម្បត្តិ ក្នុងមហាគ្រាមក្នុងរោហណជនបទ ទ្រង់ព្រះនាមថា ទុដ្ឋគាមណីអភ័យ ។ ដោយកាលដែលព្រះបិតា សោយទិវង្គតទៅ ព្រះបាទទុដ្ឋគាមណីអភ័យអង្គនោះ ទ្រង់បានឡើងគ្រងរាជសម្បត្តិ ក្នុងមហាគ្រាមនោះឯង ទ្រង់ស្តេចយាងអំពីមហាគ្រាមនោះហើយ ទ្រង់បានធ្វើគុតព្រះរាជាទមិឡ ទ្រង់ព្រះនាម ថា ឯឡារៈ ហើយទ្រង់បានជាព្រះរាជាមួយព្រះអង្គ ក្នុងអនុរាធបុរី ក្នុងលង្កាទ្វីប ។

ក្នុងឆ្នាំទី ៧២ រាប់តាំងអំពីឆ្នាំដែលព្រះសាស្តា ទ្រង់បានព្រះបរិនិព្វានទៅបាន ៣០០ ឆ្នាំ រតនៈទាំងឡាយ មានវ៉ែនៃមាសជាដើម កើតឡើងហើយ ជុំវិញនៃអនុរាធបុរី ដោយបុញ្ញានុភាព

ពណ៌នាអំពីតាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន

របស់ព្រះអង្គ ។ ពិតមែនដូច្នោះ វ៉ែនៃមាស ច្រើនជាអនេក មានប្រមាណមួយចំអាមខ្ទះ មានប្រមាណមួយជ្នាប់ខ្ទះ បានដុះឡើងហើយ លើផែនដីប្រមាណ ១៦ ករីស ក្នុងអាវរវិដ្ឋគ្រាម ចម្ងាយដល់ទៅ ៣ យោជន៍ ក្នុងទិសឦសាន អំពីទីក្រុង ។

ក្នុងទិសខាងកើត អំពីទីក្រុងនោះទៅ ចម្ងាយដល់ទៅ ៧ យោជន៍ វ៉ែនៃមាសពណ៌ក្រហម ដុះឡើងហើយ ក្នុងជនបទ ដែលមានឈ្មោះថា តម្ពបិដ្ឋិ ព្ធដ៏ត្រើយខាងនាយ នៃទន្លេគង្គា ។

ក្នុងទិសអាគ្នេយ៍ អំពីទីក្រុងនោះទៅ ចម្ងាយដល់ទៅ ៤ យោជន៍ កែវមណីទាំងឡាយ ដុះឡើង ក្នុងសុមនវាបីគ្រាម ។

ក្នុងទិសទក្សិណ អំពីទីក្រុងនោះទៅ ចម្ងាយដល់ទៅ ៨ យោជន៍ ច្រាក់ បានកើតឡើងហើយ ក្នុងគុហាមួយ ក្នុងជនបទឈ្មោះថា អម្ពដ្ឋកោលៈ ។

ក្នុងទិសបស្ចឹម អំពីទីក្រុងនោះទៅ ចម្ងាយដល់ទៅ ៥ យោជន៍ កែវមុត្តាទាំងឡាយ ដោយសណ្ឋាន ប្រមាណស្មើនឹងផ្លែកន្ទួចព្រៃខ្នាតធំ ផុតបានពេញ ៦០ រទេះ ព្រមទាំងកែវប្រពាឡទាំងឡាយ ឡើងមកលើគោក ត្រង់កំពង់ ឈ្មោះឧរុវេលៈ ។

ក្នុងទិសឧត្តរ អំពីទីក្រុងនោះទៅ ចម្ងាយដល់ទៅ ៧ យោជន៍ កែវមណីទាំងឡាយ ៤ បែប យ៉ាងល្អប្រសើរ មាន

មង្គលត្ថទីបនីប្រែ

ពណ៌សម្បុរ ស្មើនឹងផ្កាកប្បាស ដោយវែង ប្រវែង ១ ចំអាម ៤ ឆ្នាប់ ដោយមូលមានទំហំប៉ុនដុំថ្មតូចដែលគេកិនកំទេច បានផុសឡើងហើយ លើខ្នងនៃជីខ្យាច់ ក្បែរជ្រោះភ្នំ ដែលហូរទៅកាន់បឹងនៃបេឡិវាបិកគ្រាម ។

មនុស្សទាំងឡាយ ឃើញរតនៈទាំងឡាយ មានរ៉ែមាសជាដើមនោះហើយ ក៏បានក្រាបទូល ដល់ព្រះរាជា ។ ព្រះរាជាទ្រង់ត្រាស់បញ្ជា ឲ្យជញ្ជូនយករ៉ែមាសទាំងអស់នោះមកហើយ ។

រឿង ព្រះបាទ ទុដ្ឋគាមណីអភ័យ មកក្នុងបរិច្ឆេទ ទី ២៨ ក្នុងគម្ពីរមហាវង្ស ។

(១០១) ក៏ព្រះសាស្តា លុះទ្រង់ត្រាស់ ២ គាថានេះហើយ ទើបត្រាស់ ទៀតថា " ម្នាលគហបតី ឈ្មោះថា ទីជាទីកើត ដទៃដូចជាបុណ្យ នៃសត្វទាំងឡាយនេះ មិនមានសោះឡើយ, ព្រោះថា រតនៈទាំងឡាយ រមែងកើតឡើង សូម្បីក្នុងទីមិនមែនជាទីកើត ដល់ពួកបុគ្គល អ្នកមានបុណ្យ តែប៉ុណ្ណោះ " ដូច្នេះហើយ កាលទ្រង់សំដែងធម៌ ដោយនយដែលទ្រង់បានត្រាស់ទុកហើយ ក្នុងនិធិកណ្ឌ ទើបទ្រង់ត្រាស់ នូវព្រះគាថាទាំងនេះ ថា ៖

កំណាប់ទ្រព្យ គឺបុណ្យដ៏ ឱឡារិកៈ[1] ក្រៃប៉ាង

១- សុត្តន្តបិដក ភាគទី ៥២ ទំព័រទី ១៧ ។

ពណ៌នាអំពីភាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន

ដល់ទេវតា និង មនុស្សទាំងឡាយ, ទេវតា និង មនុស្សទាំងឡាយ ប្រាថ្នាណាស់ នូវផលណា ។, ផងទាំងពួងនោះ ។ រមែងបាន ដោយកំណប់ទ្រព្យ គឺបុណ្យនុ៎ះ ។

ភាពជាអ្នកមានសម្បុរផ្ងូរផង់ មានសំឡេងពីរោះ មានទ្រង់ទ្រាយល្អ មានរូបល្អ ភាពជាអធិបតី មានយសបរិវារ, ផលទាំងអស់ រមែងបាន ដោយកំណប់ទ្រព្យ គឺបុណ្យនុ៎ះ។

ភាពជាស្តេចប្រទេសរាជ ឥស្សរិយយស សេចក្តីសុខ របស់ស្តេចចក្រពត្តិ ជាទីស្រឡាញ់ ភាពជាស្តេច នៃទេវតា ក្នុងទេពនិកាយទាំងឡាយ, ផលទាំងអស់ រមែងបាន ដោយកំណប់ទ្រព្យ គឺបុណ្យនុ៎ះ ។

សម្បត្តិជារបស់មនុស្សណាផង សេចក្តីត្រេកអរ ក្នុងទេវលោកណាផង សម្បត្តិគឺព្រះនិព្វានណាផង, សម្បត្តិទាំងអស់ រមែងបាន ដោយកំណត់ទ្រព្យ គឺបុណ្យនុ៎ះ ។

ភាពនៃបុគ្គលកាលអាស្រ័យ នូវមិត្តសម្បទា បើប្រកបសេចក្តីព្យាយាម ដោយឧបាយដ៏លត្រឹមត្រូវ ជាអ្នកស្ទាត់ជំនាញ ក្នុងវិជ្ជា និង វិមុត្តិ, ឥដ្ឋផលទាំងអស់ រមែងបាន ដោយកំណប់ទ្រព្យ គឺបុណ្យនុ៎ះ។

មង្គលត្ថទីបនីប្រែ

បដិសម្ភិទា វិមោក្ខ សាវកបារមីញាណ បច្ចេកពោធិ-ញ្ញាណ និង ពុទ្ធភូមិញាណ ។, ឥដ្ឋផលទាំងអស់ រមែងបាន ដោយកំណប់ទ្រព្យ គឺបុណ្យនុ៎ះ ។

បុញ្ញសម្បទានេះ ឱ្យសម្រេចប្រយោជន៍ដ៏ធំ ដោយប្រការដូច្នេះឯង, ព្រោះហេតុនោះ បណ្ឌិតទាំងឡាយ ជាធីរ-ជន ទើបសរសើរនូវភាពនៃបុគ្គល ជាអ្នកមានបុណ្យធ្វើទុកហើយ ។

នយ ក្នុងអដ្ឋកថា និធិកណ្ឌ ថា " ក្នុងគាថានោះ កំណប់ទ្រព្យគឺបុណ្យ ឈ្មោះថា ***និធិ*** *។ មែនពិត បុណ្យនុ៎ះឯង ឈ្មោះថា* ***និធិ*** *ព្រោះអត្ថថា បុគ្គលគួរកប់ទុក ។*

ព្រះដ៏មានព្រះភាគ លុះទ្រង់ត្រាស់សំដែងផល ដែលបុញ្ញនិធិនោះ ឲ្យដល់ទេវតា និង មនុស្សទាំងឡាយនោះ ដោយសេចក្តីសង្ខេប ថា " ***កំណប់ទ្រព្យ គឺបុណ្យ ឲ្យនូវសេចក្តីប្រាថ្នាគ្រប់យ៉ាង ដល់ទេវតា និង មនុស្សទាំងឡាយ*** *" ដោយប្រការដូច្នេះហើយ ក្នុងពេលឥឡូវនេះ កាលនឹងទ្រង់សំដែង នូវសេចក្តីប្រាថ្នានោះ ថា ជាហេតុ ក្នុងការៈនៃបុញ្ញនិធិនោះ ឲ្យនូវសេចក្តីប្រាថ្នាគ្រប់យ៉ាង ព្រោះបុញ្ញនិធិនោះ នឹងឲ្យនូវសេចក្តីប្រាថ្នាគ្រប់យ៉ាងបាន ក៏ដោយសេចក្តីប្រាថ្នា ប្រាសចាកអំពីសេចក្តីប្រាថ្នា*

ពណ៌នាអំពីភាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន

ហើយ មិនអាចឲ្យនូវសេចក្តីប្រាថ្នា គ្រប់យ៉ាងបានឡើយ ទើបទ្រង់ត្រាស់កន្ទុះគាថា មានជាអាទិ៍ថា “**យំ យំ**” ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងកន្ទុះគាថា ថា “**យំ យំ**” ជាដើមនោះ ដូចតទៅ ពាក្យថា “**យំ យំ**” ប្រែថា ផលណា ៗ ។ ពាក្យថា “**ទេវា**” បានដល់ ទេវតា និង មនុស្សទាំងឡាយ ។ ជនទាំងអស់នោះ រមែងបាន ដោយបុញ្ញនិធិនុ៎ះ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សំដែង នូវផលទាំងពួងនោះ ដែលបានដោយបុញ្ញនិធិនុ៎ះ ដោយផ្នែកៗ ទើបទ្រង់ត្រាស់ ៥ គាថា មានជាអាទិ៍ថា “**សុវណ្ណតា សុស្សរតា**” ។

(១០២) ក្នុង ៥ គាថានោះ គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថាទី ១ (ដូចតទៅ) ភាពជាអ្នកមានសម្បុរប្រសើរ ភាពជាអ្នកមានសាច់ស្បែកភ្លឺថ្លា ប្រៀបដូចជាមាស ឈ្មោះថា ភាពជាអ្នកសម្បុរផូរផង់ ។ ភាពជាអ្នកមានសំឡេងដូចជាសំឡេងនៃព្រហ្ម ភាពជាអ្នកប្រក្រតីស្រដី ដូចសត្វករវិក ឈ្មោះថា ភាពជាអ្នកមានសំឡេងពីរោះ ។ ភាពជាអ្នកមានអវយវៈ ស្ថិតនៅ ដោយល្អ, មានពាក្យដែលលោកពោលថា ការតាំងនៅព្រមនៃអវយវៈ តូច ធំ ទាំងឡាយ ក្នុងទីសមគួរ ស្មើ ពេញ និងមូល ដោយភាពជារបស់ស្មើ ពេញ និង មូល ឈ្មោះថា ភាពជាអ្នកមានទ្រង់

ទ្រាយល្អ ។ ភាវៈនៃរូប ពោលគឺសរីរៈទាំងមូលល្អ, មានពាក្យដែលលោកពោលទុកហើយថា ភាពនៃបុគ្គលជាអ្នកមិនខ្ពស់ពេក មិនទាបពេក មិនស្គមពេក មិនធាត់ពេក មិនខ្មៅពេក និង មិនសពេក ដូច្នេះ ឈ្មោះថា ភាពជាអ្នកមានរូបល្អ ។ ភាពជាអធិបតី, អធិប្បាយថា ភាពជាធំ ដោយភាពជាស្តេចមហាសាលជាដើម ឈ្មោះថា ភាពជាអធិបតី ។ ភាពជាអ្នកមានពួកបរិវារ ឈ្មោះថា ភាពជាអ្នកមានយសបរិវារ ។ បទថា “ **សព្ពំ** ” គឺ ផល ៦ យ៉ាង មានភាពជាអ្នកមានសម្បុរល្អជាដើម ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ដោយផ្នែក ៗ ឈ្មោះថា ផលទាំងពួង ។

(១០៣) ព្រះមានព្រះភាគ លុះទ្រង់សំដែងនូវសម្បត្តិ ក្នុងទេវតា និង មនុស្ស ដែលទាបជាងរាជសម្បត្តិ ដែលបុគ្គលគប្បីបាន ដោយអានុភាពនៃបុណ្យ ដោយគាថានេះ ដូចពណ៌នាមកហើយ ឥឡូវនេះ កាលនឹងទ្រង់សំដែងរាជសម្បត្តិទាំង ២ យ៉ាងនោះ ទើបទ្រង់ត្រាស់ហើយនូវគាថា ទី ២ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថាទី ២ នោះ (ដូចតទៅនេះ) ៖ ភាពជាព្រះរាជា ក្នុងប្រទេសមួយ ៗ លើផែនដី មិនដល់នូវទ្វីប ១ ទាំងមូលឡើយ ឈ្មោះថា ភាពជាស្តេចប្រទេសរាជ ។ ភាពជាធំ ឈ្មោះថា ឥស្សរិយយស ។ ព្រះមានព្រះភាគ ទ្រង់សំដែង នូវ

ពណ៌នាអំពីភាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន

ភាពជាស្តេចចក្រពត្តិចំពោះទ្វីប ដោយបទនេះ ។ សេចក្តីសុខ របស់ស្តេចចក្រពត្តិ ឈ្មោះថា សេចក្តីសុខ នៃស្តេចចក្រពត្តិ ។ បទថា " **បិយំ** " បានដល់ ជាទីប្រាថ្នា គួរចង់បាន ជាទីពេញចិត្ត ។ ព្រះមានព្រះភាគ ទ្រង់សំដែង នូវភាពជាស្តេចចក្រពត្តិ ដែលជាឥស្សរៈ លើផែនដី មានសមុទ្រសាគរទាំង ៤ ជាទីបំផុត ដោយបទនេះ ។ ភាពជាព្រះរាជា ក្នុងពួកទេវតាទាំងឡាយ ឈ្មោះថា ភាពជាស្តេចនៃទេវតា ។ ព្រះមានព្រះភាគទ្រង់សំដែង នូវភាពជាស្តេច ក្នុងទេវតា សូម្បីរបស់មនុស្សទាំងឡាយ មានព្រះបាទមន្ធាតុជាដើម ដោយបទនេះ ។

ពាក្យថា " **អបិ ទិព្វេសុ** " បានដល់ ភាពជាព្រះរាជា នៃទេវតា សូម្បីក្នុងទេពនិកាយទាំងឡាយ ។ ទេវតាទាំងឡាយណានោះ ដែលលោកហៅថា **ទិព្វ** ព្រោះកើតក្នុងពពួកដែលទិព្វ, ព្រះមានព្រះភាគ ទ្រង់សំដែង នូវភាពនៃទេវតា ដែលជាស្តេច សូម្បីនៃទេវតាទាំងឡាយ ដែលកើតហើយ ក្នុងពួកទិព្វនិកាយទាំងឡាយនោះ ដោយបទនេះ ។ ផល មានភាពជាស្តេចប្រទេសរាជ ជាដើម ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ដោយផ្នែក ៗ ឈ្មោះថា ផលទាំងពួង ។

(១០៤) ព្រះមានព្រះភាគ លុះទ្រង់សំដែង នូវរាជសម្បត្តិ

មង្គលត្ថទីបនីប្រែ

ក្នុងទេវតា និង មនុស្ស ដែលបុគ្គលគប្បីបាន ដោយបុញ្ញានុភាព ដោយគាថានេះ ដូចបានពណ៌នាមកនេះ ឥឡូវនេះ កាលនឹងទ្រង់រួបរួមសម្បត្តិ ដែលទ្រង់ត្រាស់ហើយ ដោយ ២ គាថា ដោយសង្ខេប សំដែងសម្បត្តិ គឺព្រះនិព្វាន ទើបទ្រង់ត្រាស់គាថា ទី ៣ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថាទី ៣ នោះ (ដូចតទៅនេះ) ៖ សម្បត្តិនេះ ជារបស់មនុស្សទាំងឡាយ ព្រោះហេតុនោះ ទើបឈ្មោះថា មានុសី, មានុសីនុ៎ះឯង ឈ្មោះថា មានុសិកា ។ ការដល់ព្រម ឈ្មោះថា សម្បត្តិ ។ ទេវតា និង មនុស្សទាំងឡាយ រមែងត្រេកអរ ដោយសម្បត្តិនុ៎ះ ដែលកើតឡើង ខាងក្នុងក្តី ដែលជាឧបករណ៍ ខាងក្រៅក្តី ព្រោះហេតុនោះ សម្បត្តិនោះ ទើបឈ្មោះថា រតិ (ជាហេតុត្រេកអរនៃទេវតា និង មនុស្សទាំងឡាយ) បានដល់ សេចក្តីសុខ និង ហេតុជាទីតាំងនៃសេចក្តីសុខ ។ ព្រះនិព្វាននុ៎ះឯង ឈ្មោះថា និព្វានសម្បត្តិ ។ ផល មានសម្បត្តិដែលជារបស់មនុស្សជាដើម ដែលព្រះអង្គត្រាស់ហើយ ដោយផ្នែក ៗ ឈ្មោះថា ផលទាំងពួង ។

(១០៥) ព្រះមានព្រះភាគ លុះទ្រង់សំដែងសូម្បីនូវសម្បត្តិ គឺ ព្រះនិព្វាន ដែលគប្បីសម្រេច ដោយអំណាចការៈ នៃព្រះអរិយបុគ្គល ដែលជាសទ្ធានុសារី ជាដើម ដែលគប្បីបាន ដោយ

ពណ៌នាអំពីភាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន

បុញ្ញានុភាព ដោយគាថានេះ ដូចដែលបានពណ៌នាមកនេះហើយ ឥឡូវនេះ កាលនឹងទ្រង់សំដែង នូវព្រះនិព្វាននោះឯង ដែលគប្បីសម្រេច សូម្បីដោយអំណាចការៈ នៃព្រះអរិយបុគ្គល ដែលជាតេវិជ្ជៈ និង ឧភតោភាគវិមុត្តិ និងឧបាយនៃព្រះនិព្វាននោះ ទើបត្រាស់គាថា ទី ៤ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថា ទី ៤ នោះ (ដូចតទៅនេះ) ៖ បុគ្គល រមែងដល់ព្រម គឺបានសម្រេច នូវសេចក្តីចំរើន នៃគុណ ដោយសម្បត្តិទុំៈ ព្រោះហេតុនោះ សម្បត្តិទុំៈ ទើបឈ្មោះថា សម្បទា (ធម្មជាតិជាហេតុដល់ព្រម) ។ សម្បទា គឺ មិត្រ ឈ្មោះថា មិត្តសម្បទា ។ នូវសម្បទា គឺ មិត្រនោះ ។

បទថា "**អាគម្ម**" មានសេចក្តីថា អាស្រ័យនូវព្រះសាស្តា ឬ សព្រហ្មចារីបុគ្គល ណាមួយ ដែលជាអ្នកគួរដល់ នូវហានៈគួរគោរពហើយ ទទួលយកនូវឱវាទានុសាសនី អំពីព្រះសាស្តា ឬ សព្រហ្មចារីបុគ្គល ដែលជាអ្នកគួរនូវហានៈ គួរគោរពនោះ ។

បទថា " **យោនិសោ** " គឺ ដោយឧបាយ ។ បទថា " **បយុញ្ជតោ** " គឺ ធ្វើនូវសេចក្តីប្រឹងប្រែងជាហេតុព្យាយាម ។ ភាពជាអ្នកឈ្មោះថា ស្ងាត់ជំនាញ ព្រោះអត្ថថា មិនប្រព្រឹត្តយឺតយូរ ដោយប្រការនោះ ។ ក្នុងវិជ្ជា ៣ មាន បុព្វេនិវាសានុស្សតិ-

មង្គលត្ថទីបនីប្រែ

ញាណជាដើម និង វិមុត្តិ ដែលផ្សែងដោយសមាបត្តិ ៨ និង ព្រះនិព្វាន ឈ្មោះថា ភាពជាអ្នកស្ងាត់ជំនាញ ក្នុងវិជ្ជា និង វិមុត្តិ ។ ភាពជាអ្នកស្ងាត់ជំនាញ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ដោយផ្នែក ៗ ឈ្មោះថា ផលទាំងពួង ។

(១០៦) ព្រះដ៏មានព្រះភាគ លុះទ្រង់សំដែងនិព្វានសម្បត្តិ ដែលគប្បីសម្រេច សូម្បីដោយអំណាចភាវៈ នៃព្រះអរិយបុគ្គល ដែលជាតេវិជ្ជៈជាដើម ដែលគប្បីបាន ដោយបុញ្ញានុភាពដែលជាចំណែកនៃភាពជាអ្នកស្ងាត់ជំនាញ ក្នុងវិជ្ជានិងវិមុត្តិ ដែលខ្លួនបានធ្វើទុកហើយ ក្នុងកាលមុន ដោយគាថានេះ ដូចបានពណ៌នាមកហើយនេះ..., ព្រះអរិយបុគ្គលទាំងឡាយទាំងពួង ជាអ្នកសម្រេចនូវភាពជាអ្នកស្ងាត់ជំនាញ ក្នុងវិជ្ជា និង វិមុត្តិ នោះ សូម្បីជាព្រះអរិយបុគ្គល ដែលជាតេវិជ្ជៈ និង ឧភតោភាគវិមុត្តិ រមែងបានសេចក្តីចំរើន ដោយគុណ មានបដិសម្ភិទា ជាដើម, មួយទៀត រមែងបាន សូម្បីសេចក្តីចំរើនដោយគុណ មានបដិសម្ភិទាជាដើមនោះ ដោយបុញ្ញសម្បទានេះ ដែលខ្លួនបានធ្វើទុកហើយ ដោយប្រការនោះ ៗ ដោយអំណាចជាបទដ្ឋាន នៃសេចក្តីចំរើននោះ ព្រោះហេតុណា, ព្រោះហេតុនោះ ឥឡូវនេះ កាលនឹងទ្រង់សំដែងសូម្បីនូវសេចក្តីចំរើន ដោយគុណនោះ ទើបទ្រង់ត្រាស់ នូវ

ពណ៌នាអំពីភាពជាអ្នកធ្វើបុណ្យខុសគ្នួនកាលមុន

គាថា ទី ៥ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថាទី ៥ នោះ (ដូចតទៅនេះ) ៖ បញ្ញា ដែលដល់នូវការចាក់ធ្លុះ ក្នុងធម៌ អត្ថ និរុត្តិ និង បដិភាណ ឈ្មោះថា បដិសម្ភិទា ។ វិមោក្ខ ដែលជាលោកិយ ៨ ប្រការ ឈ្មោះថា វិមោក្ខ ។ ជ្ឈានី ដែលញុំាងសាវកសម្បត្តិ ឲ្យសម្រេច ឈ្មោះថា សាវកជ្ឈានី ។ ជ្ឈានី ដែលញុំាងភាពជាព្រះសយម្ភូ ឲ្យបានសម្រេច ឈ្មោះថា បច្ចេកពោធិ ។ ជ្ឈានី ដែលញុំាងភាពជាអ្នកប្រសើរបំផុត នៃសត្វទាំងពួង ឲ្យបានសម្រេច ឈ្មោះថា ពុទ្ធភូមិ ។ ផល មានបដិសម្ភិទា ជាដើម ដែលព្រះអង្គទ្រង់ត្រាស់ទុកហើយ ដោយផ្នែក ៗ ឈ្មោះថា ផលទាំងពួង ។

ព្រះមានព្រះភាគ លុះទ្រង់សំដែងនូវផល ដែលព្រះអង្គទ្រង់បានត្រាស់ទុកហើយ ក្នុងកន្លះគាថានោះ ថា “ ***ទេវតា និង មនុស្សទាំងឡាយ ជ្រាប្ចាណាស់ នូវផលណា ៗ ផលទាំងពួង នោះ ៗ រមែងបាន ដោយបុញ្ញនិធិនុ៎ះ*** *” ដូច្នេះ ដោយផ្នែក ៗ ដោយគាថាទាំងឡាយ ៥ នេះ ដូចបានពណ៌នាមកហើយនេះ ឥឡូវនេះ កាលនឹងទ្រង់ត្រាស់សរសើរ នូវបុញ្ញសម្បទា ដែលយល់បានថា ឲ្យនូវសេចក្តីជ្រាប្ចា គ្រប់យ៉ាងនោះឯង ទើបទ្រង់ត្រាស់គាថាទីបញ្ចប់ ។*

មង្គលត្ថទីបនីប្រែ

គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថាទីបញ្ចប់នោះ (ដូចតទៅនេះ) ៖ ពាក្យថា **ឯវំ** *ជាពាក្យសំដែងនូវសេចក្តីដែលកន្លងទៅហើយ ។ ប្រយោជន៍ជាច្រើន មានដល់បុញ្ញសម្បទានុ៎ះ ព្រោះហេតុនោះ បុញ្ញសម្បទានោះ ទើបឈ្មោះថា មានប្រយោជន៍ច្រើន ។ អធិប្បាយថា រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដ៏ច្រើន ។ បាឋៈថា "* **មហិទ្ធិយោ** *" ដូច្នេះ ក៏មាន ។*

ពាក្យថា " **ឯសា** *" ជាពាក្យសំដែងឡើង ។ ព្រះមានព្រះភាគ ទ្រង់សំដែង នូវបុញ្ញសម្បទា ដែលព្រះអង្គទ្រង់ត្រាស់ហើយ ដោយបទនោះ ។*

សព្ទថា " **យទិទំ** *" ជានិបាត ចុះ ក្នុងអត្ថថា ធ្វើបទឲ្យត្រង់ ។ ដោយបទថា "* **យទិទំ** *" នោះ ព្រះមានព្រះភាគ ទ្រង់ធ្វើបទ ឲ្យត្រង់នឹងគ្នា ថា "* **យា ឯសា** *" ដូច្នេះ ដើម្បីនឹងទ្រង់សំដែងបង្ហាញ នូវបទដែលទ្រង់សំដែងឡើងហើយថា "* **ឯសា** *" យ៉ាងដូច្នេះ ។ ការដល់ព្រម នៃបុណ្យទាំងឡាយ ឈ្មោះថា បុញ្ញសម្បទា ។*

បទថា " **បសំសន្តិ** *" មានសេចក្តីថា រមែងសរសើរដោយព្រះតម្រាស់ ដែលព្រះអង្គទ្រង់បានត្រាស់ទុកហើយ ក្នុងនិធិកណ្ឌ ថា ៖*

ពណ៌នាអំពីភាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន

កំណាប់ទ្រព្យ គឺបុណ្យ មិនទូទៅ ដល់ពួកជនដទៃ ជារបស់ដែលចោរលួចយកទៅមិនបាន, កំណាប់ទ្រព្យ គឺបុណ្យណា ជាប់តាមខ្លួនទៅបាន, អ្នកមានប្រាជ្ញា គួរធ្វើនូវកំណាប់ទ្រព្យ គឺបុណ្យនោះ

និង ដោយព្រះតម្រាស់ ដែលព្រះអង្គបានត្រាស់ទុកហើយ ក្នុងសត្តកនិបាត អង្គុត្តរនិកាយថា " ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយ កុំខ្លាចបុណ្យឡើយ, ម្នាលភិក្ខុទាំងឡាយ ពាក្យថា បុណ្យ ។ នេះ គឺជាឈ្មោះ នៃសេចក្តីសុខ " ដូច្នេះជាដើម ។

*បទថា " **កតបុញ្ញតំ** " ប្រែថា ភាពជាអ្នកបានធ្វើបុណ្យទុកមកហើយ ក្នុងកាលមុន " ដូច្នេះ ។*

ក៏គាថាទាំង ៧ នេះ ព្រះធម្មសង្គាហកាចារ្យ បានលើកឡើងហើយកាន់ចាលី ក្នុងនិធិកណ្ឌសូត្រ ក្នុងខុទ្ទកបាឋៈ ព្រោះហេតុណា, ព្រោះហេតុនោះ ទើបលោក មិនបានលើកឡើងកាន់ចាលី ក្នុងសិរីវោរជាតក, លើកឡើងកាន់ចាឋៈ ក្នុងអដ្ឋកថាតែប៉ុណ្ណោះឯង ។

ពណ៌នាអំពីភាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន ចប់ ។

ប្រែចប់ ថ្ងៃព្រហស្បតិ៍ ៩ រោច ខែមិគសិរ ឆ្នាំ ច ឆស័ក ព. ស. ២៥៣៧
ថ្ងៃទី ៦ មករា ១៩៩៤ វេលាយប់

ពណ៌នាអំពីការតម្កល់ខ្លួនដោយប្រពៃ

(១០៧) ចិត្ត ឈ្មោះថា ខ្លួន, ម៉្យាងទៀត អត្តភាពទាំងមូល ឈ្មោះថា ខ្លួន ។ មែនពិត ចិត្ត និង អត្តភាពទាំង ២ យ៉ាងនោះ លោកហៅថា " **ខ្លួន** " ព្រោះអត្ថថា ត្រាច់ទៅ បានដល់ សុះទៅ កាន់កពតូចនិងកពធំ ជួបប្រសព្វ គឺ ជួបប្រទះនូវសេចក្តីទុក្ខ ក្នុងសង្សារ ផ្សេងដោយជាតិ និង ជរាជាដើម ជាប់តគ្នា ។ **អត្ត** ជាតុប្រព្រឹត្តទៅ ក្នុងកិរិយាទៅជារឿង ៗ, កិរិយាប្រព្រឹត្តទៅ មិនខាតរយៈ ឈ្មោះថា កិរិយាប្រព្រឹត្តិទៅរឿយ ៗ ។

ម៉្យាងទៀត ដោយអំណាចសេចក្តីផ្សេងអំពីនេះ ចិត្ត និង អត្តភាពទាំង ២ យ៉ាងនេះ លោកហៅថា " ខ្លួន " ព្រោះអត្ថ ថា ការប្រកាន់ ថា អញ តាំងនៅស៊ប់ហើយ ក្នុងអត្តភាពនេះ និង ព្រោះអត្ថ ថា រមែងទំពាស៊ី បានដល់ រមែងសោយ នូវសេចក្តីសុខ និង សេចក្តីទុក្ខ ។

និងពណ៌នាអំពីការតម្កល់ខ្លួនទុកដោយប្រពៃ (ដូចតទៅ) ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ រមែងញុំាងខ្លួន ដែលទ្រុស្តសីល ឲ្យតាំងនៅក្នុងសីល ញុំាងខ្លួនដែលមិនមានសទ្ធា ឲ្យតាំងនៅក្នុងការជល់ព្រមដោយសទ្ធា ញុំាងខ្លួនដែលកំណាញ់ស្វិតស្វាញ ឲ្យតាំងនៅ ក្នុងការជល់ព្រមដោយការបរិច្ចាគ, នេះហៅថា ការតម្កល់

ខ្ជនទុក ដោយប្រពៃ ។

(១០៨) បណ្តាពាក្យទាំងនេះ ក្នុងពាក្យថា "ញុាំងខ្ជនដែលទ្រុស្តសីល ឲ្យតាំងនៅក្នុងសីល" នេះ នឹងពោលរឿង (តទៅ) ៖

(រឿង ចោរ ៥០០ នាក់)

ក្នុងអតីតកាល ក្នុងកាលនៃព្រះពុទ្ធ ទ្រង់ព្រះនាមកស្សបៈ មានចោរ ៥០០ នាក់ ធ្វើកម្មទាំងឡាយ មានការសម្លាប់អ្នកស្រុកជាដើម ហើយចិញ្ចឹមជីវិត ដោយចោរកម្ម ។

ថ្ងៃមួយ ពួកចោរទាំងនោះ ត្រូវពួកមនុស្សជេញតាមមក កាលរត់គេចចូលទៅព្រៃ ក៏ជួបនឹងភិក្ខុដែលនៅ ក្នុងព្រៃជាវត្ត ១ រូប ក្នុងទីនោះ ទើបថ្វាយបង្គំហើយ ពោលថា " បពិត្រព្រះគុណម្ចាស់ដ៏ចំរើន សូមព្រះគុណម្ចាស់ជាទីពឹង នៃពួកយើងខ្ញុំផង " ។

ភិក្ខុរូបនោះ ពោលថា " ឈ្មោះថា ទីពឹងស្មើដោយសីលមិនមានឡើយ, ពួកអ្នកទាំងអស់គ្នា ចូរសមាទានសីល ៥ ចុះ " ដូច្នេះហើយ ក៏បានឲ្យសីល ដល់ពួកចោរទាំង ៥០០ នោះហើយ ទូន្មានពួកចោរទាំង ៥០០ នោះ ថា " ឥឡូវនេះ ពួកអ្នកទាំងឡាយជាអ្នកមានសីល, ពួកអ្នកទាំងឡាយ មិនគួរប្រព្រឹត្តកន្លងសីលសូម្បីព្រោះហេតុនៃជីវិតឡើយ, មិនគួរធ្វើការប្រទូសរ៉ាយនៃចិត្តឡើយ " ។ ពួកចោរទាំងនោះ ទទួលព្រមថា "ប្រពៃហើយ" ។

ពណ៌នាអំពីការតម្កល់ខ្លួនដោយប្រពៃ

គ្រានោះ មនុស្សទាំងឡាយ មកដល់ទីនោះហើយ ក៏បានសម្ងាប់ពួកចោរទាំងអស់នោះហើយ ។ ពួកចោរទាំងនោះ មានសីលមិនខាត បានធ្វើកាលកិរិយាទៅកើត ក្នុងទេវលោកហើយ ។ បណ្តាពួកចោរទាំងនោះ មេចោរ បានជាប្រធាននៃទេវបុត្រ ។ ទេវបុត្រទាំងឡាយនោះ អន្ទោលទៅមក ក្នុងទេវលោក អស់ ១ ពុទ្ធន្តរ ដោយអំណាចអនុលោម និង បដិលោម ឥឡូវនេះ បានច្យុតចាក អំពីអត្តភាពនោះហើយ ក៏បានមកកើត ក្នុងស្រុកអ្នកព្រានប្រមង់ ដែលមាន ៥០០ ត្រកូល ក្បែរមាត់ទ្វារ ទីក្រុងសាវត្ថី ។ បណ្តាទេវបុត្រទាំងនោះ ទេវបុត្រជាប្រធាន កើតក្នុងក្រកូលនៃព្រានប្រមង់ ដែលជាប្រធាន បានជាកុលបុត្រ ឈ្មោះថា យសោជៈ ជាបុរសប្រសើរបំផុតជាងបុរសទាំងឡាយនោះ ។ ពួកកុលបុត្រដទៃទៀត បានកើតហើយ ក្នុងត្រកូលផ្សេងពីនេះ ។

ថ្ងៃមួយ កុលបុត្រទាំងឡាយនេះ បង់សំណាញ់ ក្នុងស្ទឹងអចិរវតី ចាប់បានត្រីមួយ មានសម្បុរដូចជាមាស ទើបប្រឹក្សាគ្នាថា " ត្រីនេះ មានសម្បុរដូចមាស, ពួកយើង នឹងបង្ហាញត្រីនោះថ្វាយ ដល់ព្រះរាជា " ហើយ ក៏ជាក់ត្រីនោះលើទូក លើកទូកហើយទើបសំដែងដល់ព្រះបាទកោសលរាជ ។ ព្រះរាជាទ្រង់បានត្រាស់ ឲ្យពួកកុលបុត្រទាំងនោះឯង នាំយកត្រីនោះទៅ ហើយ

មង្គលត្ថទីបនីប្រែ

ស្តេចយាងទៅកាន់វត្តជេតពន ទ្រង់បង្ហាញ ដល់ព្រះសាស្តា ។

ព្រះសាស្តា កាលទ្រង់សំដែងនូវធម៌ ដែលសមគួរដល់ខណៈនោះ ទ្រង់បានធ្វើត្រើនោះ ឲ្យជាហេតុកើតឡើងនៃរឿង ទើបទ្រង់សំដែងកបិលសូត្រ ក្នុងសុត្តនិបាត ហើយទ្រង់បានត្រាស់នូវគាថាទាំង៤ឡាយ ៤ ថា " **មនុជស្ស បមត្តចារិនោ** " ដូច្នេះជាដើម ក្នុងតណ្ហាវគ្គ នៃធម្មបទ ម្តងទៀត ។

ក្នុងពេលចប់គាថា ពួកព្រានប្រមង់ទាំងនោះ កើតសេចក្តីសង្វេគ តក់ស្លុតហើយ បួសក្នុងសំណាក់នៃព្រះសាស្តា ក្រោយមក ក៏បានសម្រេចព្រះអរហត្ត ដោយនយដែលព្រះអង្គ ទ្រង់សំដែងទុកហើយ ក្នុងយសោជសូត្រ ក្នុងតតិយវគ្គ នៃឧទាន ជាអ្នកមានបរិក្ខារ ជាមួយគ្នា នឹងព្រះសាស្តា ដោយធម្មបរិភោគ គឺសមាបត្តិ ជាគ្រឿងនៅមិនញាប់ញ័រ ។

រឿង ចោរ ៥០០ ក្នុងអដ្ឋកថាកបិលសូត្រជាដើម ចប់ ។

សូម្បីរឿងចោរ ដែលជ្រះថ្លាហើយ ក្នុងសង្គិច្ចសាមណេរ និង អធិមុត្តកសាមណេរ ក្នុងគាថាវណ្ណនា ជាដើមថា " **យោ ច វស្សសតំ ជីវេ ទុស្សីលោ** " ដូច្នេះ ក្នុងសហស្សវគ្គ ក៏គួរសំដែងផងដែរ ។

(១០៩) ចំណែក ក្នុងពាក្យថា " ញុំាងខ្លួន ដែលមិនមាន

ពណ៌នាអំពីការតម្កល់ខ្លួនដោយប្រពៃ

សទ្ធា ឲ្យតាំងនៅក្នុងសទ្ធាសម្បទា" នេះ និងពោលរឿង (តទៅ)៖

(រឿង ព្រះភារទ្វាជត្ថេរ)

ព្រាហ្មណ៍ឈ្មោះថាភារទ្វាជគោត្រ ជាមិច្ឆាទិដ្ឋិក៍ អាស្រ័យនៅក្នុងទីក្រុងរាជគ្រឹះ ។ ព្រាហ្មណ៍នោះ ជាអ្នកមិនមានសទ្ធា ជាអ្នកមិនជ្រះថ្លាហើយ, កាលបើបុគ្គលពោលថា " ***ព្រះពុទ្ធ ព្រះធម្ម ព្រះសង្ឃ*** *" ដូច្នេះ, តែងបិទនូវត្រចៀកទាំង ២ ជាអ្នករឹងត្អឹងប្រៀបដូចជាជង្គត់នៃឈើសង្កែ ។ ចំណែកនាងព្រាហ្មណី ឈ្មោះធនញ្ជានី របស់ព្រាហ្មណ៍នោះ ជាសោតបន្ន ជាអ្នកមានសទ្ធាជ្រះថ្លាហើយ ។ តាមប្រក្រតី នាងព្រាហ្មណីនោះ ទោះជាឈរក្តី អង្គុយក្តី ក្អកក្តី កណ្តាស់ក្តី តែងធ្វើការនមស្សការ ថា "* ***នមោ ពុទ្ធស្ស*** *" ដូច្នេះជាដើម ។*

ក្រោយមក ថ្ងៃមួយ ព្រាហ្មណ៍ប្រាថ្នានឹងឲ្យបាយបាយាសដែលមានទឹកតិច ដល់ព្រាហ្មណ៍ ៥០០ នាក់ ទើបអញ្ជើញព្រាហ្មណ៍ទាំងឡាយ ដើម្បីបរិភោគអាហារក្នុងថ្ងៃស្អែក បានប្រាប់នឹងនាងព្រាហ្មណី ថា " ម្នាលនាងដ៏ចំរើន ក្នុងថ្ងៃស្អែកនេះ ពួកព្រាហ្មណ៍ចំនួន ៥០០ នាក់ នឹងបរិភោគ ក្នុងផ្ទះ របស់យើង, នាងធ្វើនូវការនមស្សការណា ដល់សមណៈត្រង់លានោះ, ក្នុងថ្ងៃស្អែក តឹមតែមួយថ្ងៃ ចូរនាងកុំធ្វើនូវការនមស្សការនោះឡើយ,

មង្គលត្ថទីបនីប្រែ

ព្រោះថា ព្រាហ្មណ៍ទាំងឡាយ បានឮពាក្យនោះហើយ នឹងមិនពេញចិត្ត, ចូរនាងកុំបំបែកបង់អំពីព្រាហ្មណ៍ទាំងឡាយឡើយ ។

នាងព្រាហ្មណី ពោលថា " ចូរអ្នកបែកអំពីពួកព្រាហ្មណ៍ឬក៏ ពួកទេវតាក៏ដោយ, នាងខ្ញុំរឭកនូវព្រះសាស្តាអង្គនោះ កាលមិនបាននមស្សការ នឹងមិនអាច ដើម្បីនឹងស្ថិតនៅបានឡើយ " ។

ព្រាហ្មណ៍នោះ ទាញយកជាវមកហើយ ពោលថា " នែនាងដ៏ចំរើន បើថ្ងៃស្អែក កាលបើពួកព្រាហ្មណ៍ទាំងនោះ អង្គុយហើយ, នាងនមស្សការ នូវសមណៈត្រង៉ៅលនោះ, ខ្ញុំ នឹងកាត់នាងឯង ដោយជាវនេះ " ។

ធម្មតា ព្រះអរិយសាវ័កទាំងឡាយ ជាអ្នកដែលបុគ្គលធ្វើឲ្យកម្រើកញាប់ញ័របាន ដោយលំបាក ដូចជាផែនដី និង ជាអ្នកដែលគេបង្វិលត្រឡប់បាន ដោយលំបាក ដូចបានភ្នំព្រះសុមេរុ, ព្រោះហេតុនោះ នាងព្រាហ្មណីនោះ ទើបពោល យ៉ាងដូច្នេះ ថា ៖

ម្នាលព្រាហ្មណ៍ បើអ្នកកាត់ នូវនាងខ្ញុំ ទៅជាកំណាត់តូច-ធំពិតមែន, នាងខ្ញុំ នឹងមិនវៀរចាកសាសនា នៃព្រះពុទ្ធជាអ្នកប្រសើរបាន ឡើយ ។

ព្រាហ្មណ៍នោះ កាលមិនអាចដើម្បីនឹងប៉ះពាល់ឬក៏ប្រហារនូវនាងព្រាហ្មណីនោះបាន ទើបពោលថា " ចូរនាងធ្វើ នូវបស់

ដែលនាងចូលចិត្តចុះ" ហើយ ក៏បានចោះដាវទៅលើទីដេក ។

ក្នុងថ្ងៃស្អែកឡើង ព្រាហ្មណ៍បានចាត់ចែងហើយ នូវបាយ បាយាស ដើម្បីព្រាហ្មណ៍ទាំងឡាយ បានឲ្យគេប្រាប់ពេលវេលា ហើយ ។ ព្រាហ្មណ៍ទាំងនោះ បានមកអង្គុយហើយ ។ ចំណែក ព្រាហ្មណ៍ ក៏បានអង្គុយលើជួរជាមួយគ្នានឹងព្រាហ្មណ៍ទាំងនោះ ។

គ្រានោះ នាងព្រាហ្មណី ចាប់វែកមាស អង្គាសព្រាហ្មណ៍ ទាំងឡាយ ក្នុងរោងកត្ត កាលបង្អោនកត្តទៅ ដើម្បីព្រាហ្មណ៍នោះ ក៏បានរអិលជួល លើបន្ទះក្តារ ដែលក្រាលហើយមិនល្អ ។ ទុក្ខ វេទនា បានឡើងហើយ ។ ក្នុងខណៈនោះឯង នាងព្រាហ្មណី រឭកដល់ព្រះសាស្តា ផ្តងអញ្ជលីលើក្បាល, វត្តវេឡុវន ស្ថិតនៅ ដោយទិសណា, ក៏បានប្រណម្យអញ្ជលី ដោយទិសនោះហើយ បានបន្ទឹខទាន ៣ ដង ថា " ***នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស*** " ដូច្នេះ ។

ក៏ក្នុងខណៈនោះ បណ្តាព្រាហ្មណ៍ទាំងនោះ ពួកព្រាហ្មណ៍ ខ្លះ បរិភោគហើយ, ពួកខ្លះកំពុងតែបរិភោគ, ពួកខ្លះ គ្រាន់តែផ្តើម ជាក់ដៃចុះ, ពួកខ្លះគ្រាន់តែគេជាក់ភោជននៅខាងមុខ ។ ព្រាហ្មណ៍ ទាំងនោះ គ្រាន់តែឮសំឡេងនោះ ប្រៀបដូចជាត្រូវញញួរ ទំហំ ប៉ុនភ្នំសុមេរុ ប្រហារហើយ ចំលើក្បាល ប្រៀបដូចជាត្រូវលំពែង

មង្គលត្ថទីបនីប្រែ

ចាក់ទម្លុះ ត្រង់ត្រចៀកទាំង ២ ដល់នូវទុក្ខទោមនស្សហើយក្រោធ
ខឹង ថា " ពួកយើង ត្រូវមនុស្សអ្នកកាន់លទ្ធិដទៃនេះ ឲ្យចូលមក
កាន់ផ្ទះហើយ " ដូច្នេះ បានចោលដុំបាយក្នុងដៃ ខ្ជាក់ដុំបាយដែល
បៀមនឹងមាត់ចោល បានដេរប្រទេចព្រាហ្មណ៍ ចៀសចេញទៅ ។

ចំណែកព្រាហ្មណ៍ ក៏បានដេរប្រទេច នូវនាងព្រាហ្មណី
ដោយប្រការផ្សេង ៗ កាលមិនអាច ដើម្បីនឹងធ្វើអ្វីបាន ទើប
ពោលថា " ក៏វាយ៉ាងដូច្នេះឯង នាងថោកទាបនេះ ទើបសរសើរ
គុណ របស់សមណៈត្រង៉ៅលនោះ ក្នុងទីគ្រប់ទីកន្លែង, នែនាង
ថោកទាប អញនឹងលើកវាទៈនៃសាស្តារបស់នាងនោះឥឡូវនេះ "
ហើយ បានក្រោធខឹង មិនពេញចិត្ត ដើរទៅវត្តវេឡុវន មិនថ្វាយ
បង្គំព្រះសាស្តាឡើយ បានអង្គុយ ក្នុងទីដ៏សមគួរ ហើយក្រាប
ទូលសួរបញ្ហា ថា ៖

បុគ្គលសម្លាប់នូវអ្វីហ្ន៎ ទើបនៅជាសុខ, បុគ្គលសម្លាប់នូវអ្វី
ហ្ន៎ ទើបមិនសោកសៅ, បពិត្រព្រះគោតម ព្រះអង្គទ្រង់
ពេញព្រះទ័យ នូវការសម្លាប់ធម៌ឯកអ្វី ។

ក្នុងគ្រានោះ ព្រះសាស្តា កាលនឹងទ្រង់ធ្វើឲ្យជាក់ច្បាស់
នូវបញ្ហា ដល់ព្រាហ្មណ៍នោះ ទើបទ្រង់ត្រាស់ ថា ៖

បុគ្គល សម្លាប់សេចក្តីក្រោធបានហើយ រមែងនៅជាសុខ,

ពណ៌នាអំពីការតម្កល់ខ្លួនដោយប្រពៃ

បុគ្គល សម្លាប់សេចក្តីក្រោធបានហើយ រមែងមិនសោក សៅ, ម្នាលព្រាហ្មណ៍ ព្រះអរិយទាំងឡាយ រមែងសរសើរ នូវការសម្លាប់នូវសេចក្តីក្រោធ ដែលមានឫសជាពិស មានរសផ្អែមឆ្ងាញ់ ជាទីបំផុត, ព្រោះថា បុគ្គល សម្លាប់ នូវសេចក្តីក្រោធនោះបានហើយ រមែងមិនសោកសៅ ។

បណ្តាបទទាំងនោះ បទថា “ ***ឃត្វា*** *” ប្រែថា សម្លាប់បានហើយ ។ សូម្បីក្នុងគម្ពីរសេទ្ទនីតិ ក៏លោកពោលនយទុកហើយថា “* ***ហន*** *ធាតុ ប្រព្រឹត្តទៅ ក្នុងការបៀតបៀន សម្រេចរូប ថា* ***ឃត្វា*** *ប្រែថា សម្លាប់ហើយ ” ។ ២ បទថា “* ***សុខំ សេតិ*** *” មានសេចក្តីថា បុគ្គល ឈ្មោះថា រមែងនៅជាសុខ ព្រោះកាវៈជាអ្នកដែលសេចក្តីក្តៅក្រហាយ គឺសេចក្តីក្រោធដុតរោលមិនបាន ។ ឈ្មោះថា រមែងមិនសោកសៅ ព្រោះជាអ្នកមានទោមនស្ស សាបសូន្យហើយ ព្រោះការសាបសូន្យទៅនៃសេចក្តីក្រោធ ។ បទថា “* ***វិសមូលស្ស*** *” បានដល់មានទុក្ខជាផល ។ បទថា “* ***មធុរគ្គស្ស*** *” គឺ មានសេចក្តីសុខជាទីបំផុត ។ មែនពិត សេចក្តីសុខ រមែងកើតឡើង ព្រោះជេរតប ដល់បុគ្គលដែលជេរហើយ និង ព្រោះប្រហារតប ដល់បុគ្គលដែលជេរហើយ, ព្រោះហេតុនោះ ពាក្យថា “* ***មធុរំ*** *” ព្រះមានព្រះភាគ ទ្រង់ត្រាស់សំដៅយកសេចក្តី*

*សុខនោះ ។ ក៏ **អគ្គ** សព្ទ ក្នុងបទថា " **អគ្គស្ស** " នេះ ជាសព្ទ សំដែង នូវទីបំផុត ។ បណ្ឌិតទាំងឡាយ មានព្រះពុទ្ធ ជាដើម ឈ្មោះថា ព្រះអរិយៈ ។*

ព្រាហ្មណ៍ បានស្តាប់ទេសនា របស់ព្រះសាស្តា ត្រឡប់ ជាមានសទ្ធា បានបួសហើយឧបសម្បទ ក្នុងសំណាក់ព្រះសាស្តា ហើយ ក៏បានសម្រេចជាព្រះអរហន្ត អស់កាលមិនយូរឡើយ ។

រឿង ព្រះភារទ្វាជត្ថេរ មកក្នុងអដ្ឋកថាព្រាហ្មណសំយុត្ត ។

សូម្បីរឿងកាឡកសេដ្ឋី ក្នុងអដ្ឋកថា កាឡការាមសូត្រ ក្នុងចតុកនិបាត អង្គុត្តរនិកាយ ក៏គប្បីសំដែងផងដែរ ។

(១១០) ក៏ក្នុងពាក្យថា " ញាំងខ្លួន ដែលកំណាញ់ស្វិត ស្វាញ ឲ្យតាំងនៅក្នុងចាគសម្បទា" នេះ នឹងសំដែងរឿង (តទៅ) ៖

(រឿង កោសិយសេដ្ឋី)

ក្នុងទីក្រុងពារាណសី សេដ្ឋីម្នាក់ មានទ្រព្យ ៨០ កោដិ បានឲ្យបុគ្គលកសាងរោងទាន ៦ ខ្នង គឺ ក្បែរទ្វារព្រះនគរ ៤ ខ្នង ត្រង់កណ្តាលព្រះនគរ ១ ខ្នង និង ក្បែរទ្វារ នៃទីលំនៅ ១ ខ្នង បានលះបង់ទ្រព្យ ៦ សែន ឲ្យមហាទាន រៀងរាល់ថ្ងៃ ។ សេដ្ឋីនោះ ឲ្យទានហើយ ទូន្មានកូន រហូតអស់ជីវិត ថា " ចូរកូន កុំកាត់ផ្តាច់ នូវតំណនៃទាន របស់ឪពុកនេះឡើយ " ហើយ បាន

ពណ៌នាអំពីការតម្កល់ខ្លួនដោយប្រពៃ

កើតជាស្តេចសក្កទេវរាជ ក្នុងទីបំផុតនៃជីវិត ។

ចំណែកកូន របស់សេដ្ឋីនោះ ក៏បានឲ្យទាន យ៉ាងដូច្នោះដែរ ហើយកើតជាចន្ទទេវបុត្រ ។ បុត្រ របស់ចន្ទទេវបុត្រនោះ កើតជាសុរិយទេវបុត្រ, បុត្រ របស់សុរិយទេវបុត្រនោះ កើតជាមាតលីទេវបុត្រ, បុត្រ របស់មាតុលីទេវបុត្រនោះ បានកើតជាបញ្ចសិខទេវបុត្រ ។ ក៏បុត្រ របស់បញ្ចសិខទេវបុត្រនោះ បានកើតជាសេដ្ឋី ឈ្មោះថា កោសិយៈ ជាអ្នកមានទ្រព្យ ៨០ កោដិ ដូចគ្នាដែរ ។

កោសិយសេដ្ឋីនោះ គិតថា " ឪពុក និង ជីតា របស់អញ ជាមនុស្សល្ងង់ខ្លៅ បានលះបង់ចោលនូវទ្រព្យ ដែលកើតមានមកដោយលំបាក, អញនឹងថែរក្សាទ្រព្យនោះ, នឹងមិនឲ្យទ្រព្យអ្វីមួយដល់អ្នកណាមួយឡើយ " ដូច្នេះហើយ ទើបឲ្យបុគ្គល រុះរើរោងទានទាំងឡាយចោលហើយ ឲ្យយកក្តីងដុត ជាអ្នកវឹងគ្នឹង និង កំណាញ់ស្វិត ប្រមូលទ្រព្យទុកតែម៉្យាង មិនបរិភោគខ្លួនឯង មិនចែកឲ្យ ដល់បុគ្គលដែលគួរឲ្យ មានកូន និង ប្រពន្ធ ជាដើម ។

ក៏សេដ្ឋីនោះ បរិភោគនូវភត្ត ព្រមទាំងកន្ទក ដែលមានទឹកជ្រាយ ជាគម្រប់ ២ ស្លៀកសំពត់សាច់គ្រើម ជាំងធ្លាប់ដែលធ្វើដោយស្បែកឈើ លើក្បាល ធ្វើដំណើរ ដោយរថចាស់ ដែលទឹម

ដោយគោចាស់ ។ ទ្រព្យដែលមានចំនួនប៉ុណ្ណោះ របស់សេដ្ឋី ជាអសប្បុរសនោះ កើតប្រៀបដូចជាផ្លែដូង ដែលសុនខបានហើយ ជូរច្នោះឯង ។

ថ្ងៃមួយ សេដ្ឋីនោះ កាលទៅកាន់ព្រះរាជដំណាក់ ទើបគិតថា " អញ នឹងនាំយកអនុសេដ្ឋីទៅផង " ដូច្នេះហើយ ក៏បានទៅកាន់ផ្ទះ របស់អនុសេដ្ឋីនោះហើយ ។

ក្នុងខណៈនោះ អនុសេដ្ឋីនោះ កំពុងតែបរិភោគ នូវបាយបាយាស ដែលផ្សំហើយ ដោយទឹកដោះខាប់ ទឹកដោះថ្លា ទឹកឃ្មុំ ដែលរម្ងាស់ហើយ និងផង់នៃស្ករក្រួស ឃើញសេដ្ឋីនោះដើរមក ក៏ក្រោកចាកអាសនៈហើយ ពោលថា " ម្នាលមហាសេដ្ឋី សូមលោកអញ្ជើញ មកចុះ, សូមអញ្ជើញអង្គុយក្នុងទីនេះ, ពួកយើងនឹងបរិភោគ " ។

សេដ្ឋីនោះ គ្រាន់តែឃើញ នូវបាយបាយាសតែប៉ុណ្ណោះ ក៏កើតទឹតមាត់ច្រោក នៅក្នុងមាត់ ជាអ្នកប្រាថ្នា ដើម្បីនឹងបរិភោគ ក៏ពិតមែន ទោះជាដូរច្នោះក៏ដោយ គាត់គិតថា " បើអញបរិភោគ, ក្នុងពេលដែលអនុសេដ្ឋីនេះ មកផ្ទះរបស់អញ អញនឹងត្រូវតែធ្វើសក្ការៈតបវិញ, កាលបើដូរច្នោះ, ទ្រព្យរបស់អញ ក៏នឹងវិនាសសាបសូន្យ " ដូច្នេះ គ្រាន់តែអង្គុយប៉ុណ្ណោះ សូម្បីអនុសេដ្ឋីនោះ

ពណ៌នាអំពីការតម្កល់ខ្លួនដោយប្រពៃ

ជណ្តើងសួរញ្ជួយ ៗ ក៏ពោលថា " ខ្ញុំទើបតែនឹងបរិភោគ អម្បាញ់មិញនេះឯង, ខ្ញុំបរិភោគឆ្អែត គ្រប់គ្រាន់ហើយ " ដូច្នេះហើយ មិនបរិភោគសោះឡើយ ។

ក្នុងពេលដែលអនុសេដ្ឋីបរិភោគរួចហើយ មហាសេដ្ឋីនោះ ក៏នាំអនុសេដ្ឋីនោះ ទៅកាន់ព្រះរាជដំណាក់ ត្រឡប់មកកាន់ផ្ទះរបស់ខ្លួនវិញហើយ សូម្បីត្រូវសេចក្តីចំណង់ ក្នុងបាយបាយាសបៀតបៀនហើយ ក៏មិនជ្រាប់ដល់អ្នកណាមួយឡើយ ព្រោះភ័យតែអស់ទ្រព្យ កាលខំអត់ទ្រាំនឹងសេចក្តីស្រេកឃ្លាន ក៏កើតជាមនុស្សមានរោគលឿង ៗ ហើយ ដោយលំដាប់ ។ កាលបើដូច្នោះ, មហាសេដ្ឋីនោះ ក៏មិនជ្រាប់ ព្រោះភ័យខ្លាចតែអស់ទ្រព្យក្រោយមក មានកម្លាំងទន់ខ្សោយ ចូលទៅដេក ឱបនូវទីដេក ត្រូវភរិយាសួរញ្ជួយ ៗ ទើបជ្រាប់នូវហេតុនោះហើយ ។

ភរិយានោះ ស្តាប់ហេតុនោះហើយ ពោលថា " តើបង ជាមនុស្សក្រីក្រឬ, នាងខ្ញុំ នឹងជាំបាយបាយាស ធ្វើឲ្យគ្រប់គ្រាន់ដល់ជនទាំងឡាយដែលរស់នៅ ក្នុងក្រុងពារាណសីទាំងមូល " ។

សេដ្ឋីនោះ ក្រោធខឹង ដូចជាគេយកជំបងមកវាយចំក្បាលហើយពោល ថា " បងដឹងថា នាងជាអ្នកមានទ្រព្យច្រើន, បើទ្រព្យដែលនាងនាំមកហើយ អំពីផ្ទះនៃត្រកូល របស់នាងមាន, ចូរ

នាងចម្អិនបាយបាយាស ឲ្យដល់ពួកអ្នកនគរទាំងឡាយចុះ” ។

ករិយា. បើដូច្នោះ នាងខ្ញុំនឹងចម្អិនបាយបាយាស ឲ្យបានគ្រប់គ្រាន់ ដល់ពួកជនដែលនៅ លើថ្ពល់ជាមួយគ្នា ។

មហាសេដ្ឋី. នឹងមានប្រយោជន៍អ្វី ដោយជនទាំងនោះ ។

ករិយា. បើដូច្នោះ នាងខ្ញុំនឹងចម្អិនបាយបាយាស ឲ្យបានគ្រប់គ្រាន់ ដល់ពួកជនដែលនៅ ក្នុងផ្ទះមួយ ៗ ៧ ៗ គ្រួសារ ខាងនេះផង ខាងនោះផង, បើដូច្នោះ នាងខ្ញុំ នឹងចម្អិន ឲ្យគ្រប់គ្រាន់ ដល់ជនអ្នកនៅជិតខាង ក្នុងផ្ទះនេះ, បើដូច្នោះ នាងខ្ញុំ នឹងចម្អិន ឲ្យបានគ្រប់គ្រាន់ ដល់ជនដែលជាផៅពង្សតែប៉ុណ្ណោះ ។

មហាសេដ្ឋី. នឹងមានប្រយោជន៍អ្វី ដោយជនទាំងនោះ ។

ករិយា. បើដូច្នោះ នាងខ្ញុំ នឹងចម្អិន ឲ្យបានគ្រប់គ្រាន់ ដល់បងផង ដល់នាងខ្ញុំផង ។

មហាសេដ្ឋី. នាងឯង ជាអ្នកណាទៅ, បាយបាយាស រមែងមិនគួរ ដល់នាងឡើយ ។

ករិយា. បើដូច្នោះ នាងខ្ញុំ នឹងចម្អិន ឲ្យបានគ្រប់គ្រាន់ ដល់បង តែម្នាក់ឯងប៉ុណ្ណោះ ក៏បានដែរ ។

មហាសេដ្ឋីនោះ ពោលថា “ ត្រូវហើយ ! ទោះបីជានាងចម្អិន ដើម្បីបង ចូរនាងកុំចម្អិន ក្នុងទីនេះឡើយ, ជនជាច្រើន

ពណ៌នាអំពីការតម្កល់ខ្លួនដោយប្រពៃ

និងប្រាថ្នាប៉ុនប៉ង, ចូរនាងឲ្យនូវអង្ករ ១ កំបង់, ទឹកដោះស្រស់ ៤ ភាគ, ស្ករក្រួស ត្រឹមតែមួយចឹប, ទឹកដោះជូរ ពេញ ១ ដប, ទឹកឃ្មុំប្រមាណប៉ុណ្ណោះដែរ និង ភាជន:សម្រាប់ចម្អិន ១ ផងដែរ, បងនឹងចូលទៅព្រៃហើយ ចម្អិនបរិភោគ ក្នុងទីនោះ" ។

ភរិយានោះ បានធ្វើហើយ យ៉ាងដូច្នោះឯង ។

មហាសេដ្ឋីនោះ ប្រើឲ្យអ្នកបម្រើយករបស់របរទាំងអស់នោះទៅព្រៃហើយ ឲ្យធ្វើជើងក្រាន ក្បែរគុម្ពឈើមួយ ជិតមាត់ស្ទឹង ឲ្យនាំយកឧស និង ទឹកមកហើយ បញ្ជូនអ្នកបម្រើនោះទៅ ដោយប្រាប់ថា " ចូរអ្នកទៅឈរត្រង់ផ្លូវមួយ ឃើញអ្នកណាមួយ ភ្លាមហើយ ចូរអ្នកឲ្យសញ្ញាដល់អញ, ក្នុងពេលដែលអញហៅអ្នកមកហើយ អ្នកគប្បីមក " យ៉ាងដូច្នេះហើយ ក៏បានបង្គាត់ក្លើង ចម្អិនជាយជាយាសតែម្នាក់ឯង ។

ក្នុងខណៈនោះ ស្តេចសក្កទេវរាជ កាលទ្រង់ត្រួតមើលនូវជំណាំនៃទាន របស់ព្រះអង្គ ទ្រង់ជ្រាប នូវហេតុទាំងអស់នោះហើយ ទើបទ្រង់ព្រះតម្រិះ ថា " មហាសេដ្ឋីនេះ ចំជាមនុស្សកំណាញ់ កាត់ផ្តាច់នូវវង្ស របស់អញហើយ នឹងកើត ក្នុងនរក, អញនឹងឲ្យនូវឱវាទ ដល់មហាសេដ្ឋីនោះហើយ ធ្វើឲ្យគួរដល់ការកើតឡើង ក្នុងទីនេះ" ដូច្នេះហើយ ទ្រង់ត្រាស់ហៅចនូទេវបុត្រ

មង្គលត្ថទីបនីប្រែ

ជាដើមមក គ្រាស់ប្រាប់នូវរឿងព័ត៌មានទាំងអស់ហើយ ទ្រង់ត្រាស់ថា " ខ្ញុំនឹងទៅមុន, ក្នុងពេលដែលខ្ញុំសុំ នូវបាយបាយាស ហើយ អង្គុយ ពួកអ្នកទាំងឡាយ គប្បីមក តាមលំដាប់ លំដោយចុះ " ដូច្នេះហើយ ទ្រង់បានបន្ទំកេទ ជាព្រាហ្មណ៍ ស្តេចយាងទៅកមហាសេដ្ឋីនោះ ទ្រង់ត្រាស់សួរថា " ម្នាលអ្នកដ៏ចំរើន តើផ្លូវទៅកាន់ក្រុងពារាណសី គឺផ្លូវខាងណា ? " ។

សេដ្ឋី ពោលថា " តើអ្នកជាមនុស្សឆ្កួតឬ មិនស្គាល់ទាំងផ្លូវទៅកាន់ក្រុងពារាណសីសោះនោះ, ចូរអ្នកកុំមក ខាងផ្លូវនេះ សូមអញ្ជើញទៅ ខាងផ្លូវនុ៎ះចុះ " ។

ស្តេចសក្កទេវរាជ ទ្រង់ធ្វើដូចជាស្តាប់មិនឮ ទ្រង់ត្រាស់សួរថា " តើអ្នកនិយាយថា ដូចម្តេច " ហើយ ទ្រង់ស្តេចយាងទៅកមហាសេដ្ឋីនោះភ្លាម ។

មហាសេដ្ឋីនោះ ស្រែកថា " នែវ៉ើយ ព្រាហ្មណ៍អ្នកមានជាតុថ្ងន់ តើអ្នកមក ខាងផ្លូវនេះធ្វើអ្វី ចូរទៅ ខាងផ្លូវនុ៎ះទៅ " ។

ស្តេចសក្កទេវរាជ ទ្រង់ត្រាស់សួរថា " ម្នាលអ្នកដ៏ចំរើន អ្នកស្រែក ព្រោះហេតុអ្វី, ផ្សែងនិងភ្លើង រមែងប្រាកដ, អ្នកកំពុងតែចម្អិនបាយបាយាស, ទីជាទីអញ្ជើញព្រាហ្មណ៍ គប្បីមាន, ក្នុងពេលដែលពួកព្រាហ្មណ៍បរិភោគ សូម្បីខ្ញុំ ក៏នឹងបានបន្តិចបន្តួច

ផងដែរ" ។

មហាសេដ្ឋី. ក្នុងទីនេះ មិនមានការអញ្ជើញព្រាហ្មណ៍ទេ, ចូរអ្នកអញ្ជើញទៅ ខាងផ្លូវផ្សេងទៀតចុះ ។

ស្តេចសក្កទេវរាជ. បើដូច្នោះ ក្នុងពេលដែលអ្នកបរិភោគ ខ្ញុំ និងបានបន្តិចបន្តួចផងដែរ ។

មហាសេដ្ឋី. សូម្បីតែមួយគ្រាប់ ក៏ខ្ញុំមិនឲ្យដល់អ្នកដែរ, ចាយចាយាសបន្តិចបន្តួចនេះ ល្មមគ្រាន់តែញ៉ាំងអត្តភាព របស់ខ្ញុំ ឲ្យប្រព្រឹត្តទៅបាន ។

ស្តេចសក្កទេវរាជ ទ្រង់បានព្រះសណ្តាប់ពាក្យនោះហើយ ទើប ទ្រង់ត្រាស់គាថា ថា ៖

បុគ្គល គប្បីឱ្យនូវវត្ថុតិច អំពីវត្ថុតិច គប្បីឱ្យវត្ថុ [1] ៣ក់ កណ្តាលអំពីវត្ថុ៣ក់កណ្តាល គប្បីឱ្យវត្ថុច្រើនអំពីវត្ថុច្រើន, ការមិនឱ្យ មិនសមគួរទេ, ម្នាលកោសិយសេដ្ឋី ព្រោះហេតុនោះ ខ្ញុំ សូមនិយាយនឹងអ្នក ចូរអ្នកឱ្យទានទាំង១ាយផង ចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គផង, បុគ្គលបរិភោគម្នាក់ឯង មិនបានសេចក្តីសុខឡើយ ។

*បណ្តាបទទាំងនោះ ជាទគាថាថា "**អនុមជ្ឈតោ មជ្ឈកំ**"*

១- សុត្តន្តបិដក ភាគទី ៥៩ ទំព័រទី ៥៣ ។ ភាគទី ៦១ ទំព័រទី ១៣១ ។

មង្គលត្ថទីបនីប្រែ

មានសេចក្តីថា គប្បីបែងចែកសូម្បីវត្ថុតិច ត្រង់ពាក់កណ្តាល ធ្វើទៅជា ២ ចំណែកហើយ ឲ្យមួយចំណែក ទើបបែងចែក ត្រង់ពាក់កណ្តាល សូម្បីចាកវត្ថុពាក់កណ្តាល ដែលសេសសល់ អំពីវត្ថុតិចនោះម្តងទៀត ហើយឲ្យមួយចំណែកតែម្តង ។

បាទគាថាថា " **អទានំ នុបបជ្ជតិ** " មានសេចក្តីថា បុគ្គលនឹងឲ្យវត្ថុតិច ឬ ច្រើន ក៏ដោយចុះ, ធម្មតា ការមិនឲ្យ រមែងមិនសមគួរទេ, ការឲ្យនោះឯង រមែងមានផលច្រើន ដោយពិត ។

ពាក្យថា " **តំ តំ** " មានសេចក្តីថា ព្រោះហេតុនោះ ខ្ញុំនឹងនិយាយនឹងអ្នក គឺ អ្នកដ៏ចំរើន ។ បទថា " **កុញ្ញ ច** " មានសេចក្តីថា ចូរអ្នកឲ្យទានទាំងឡាយផង ចូរបរិភោគខ្លួនឯងផង ។

បាទគាថា ថា " **អរិយមគ្គំ សមារុហ** " មានសេចក្តីថា ចូរអ្នកឡើងកាន់មាគ៌ា នៃព្រះអរិយៈទាំងឡាយ បានដល់ សប្បុរសទាំងឡាយ មានព្រះពុទ្ធជាដើម ជាអ្នកត្រេកអរក្រៃលែងក្នុងទាន ។ បទថា " **ឯកាសី** " បានដល់ អ្នកបរិភោគ តែម្នាក់ឯង ។ បទថា "**លភតេ**" ប្រែថា រមែងបាន ។

សេដ្ឋីស្តាប់ពាក្យនោះហើយ ពោលថា " ម្នាលព្រាហ្មណ៍ អ្នកនិយាយចំជាត្រូវចិត្តខ្ញុំ, អ្នកនឹងបានបន្តិច, អញ្ជើញអ្នកអង្គុយសិនចុះ " ។

ពណ៌នាអំពីការតម្កល់ខ្លួនដោយប្រពៃ

ស្តេចសក្កទេវរាជ ទ្រង់គង់ហើយ ។

បន្ទាប់ពីនោះមក ចន្ទទេវបុត្រ ក៏បានមក ដោយនយ័ នោះឯង ហើយបានពោលគាថា ថា ៖

បុគ្គលណា កាលភ្ញៀវអង្គុយហើយ បរិភោគ [1] ភោជន តែម្នាក់ឯង, ការបូជា របស់បុគ្គលនោះ ឈ្មោះថា ឥតអំពើ ផង, ការព្យាយាមញុំាងទ្រព្យឲ្យកើតឡើង របស់បុគ្គលនោះ ឈ្មោះថាឥតអំពើផង, ម្នាលកោសិយសេដ្ឋី ព្រោះហេតុនោះ ខ្ញុំសូមនិយាយនឹងអ្នក ។ល។ បុគ្គលបរិភោគម្នាក់ឯង មិន បានសេចក្តីសុខទេ ។

ការធ្វើពលិកម្ម ក្នុងស្ថានទីទាំងឡាយ មានស្រះនិងទន្លេ ជាដើម ដើម្បីឲ្យកើតទ្រព្យ ឈ្មោះថា ការបូជា ក្នុងគាថានោះ ។ សេចក្តីព្យាយាម ដែលតាំងទុក ដោយអំណាចការញុំាងទ្រព្យឲ្យ កើតឡើង ឈ្មោះថា សេចក្តីព្យាយាមញុំាងទ្រព្យឲ្យកើតឡើង ។

សេដ្ឋី ពោលថា “ បើដូច្នោះ ចូរអ្នកអង្គុយសិនចុះ, អ្នក នឹងបានបន្តិច ” ។ ចន្ទទេវបុត្រនោះឯង បានអង្គុយហើយ ។

បន្ទាប់ពីនោះមក សុរិយទេវបុត្រ ក៏បានមក ដោយនយ័ នោះដូចគ្នាដែរ ហើយពោលគាថា ថា ៖

១- សុត្តន្តបិដក ភាគ ទី ៥៩ ទំព័រទី ២៥៣ ។

មន្តលត្តនីបនីប្រែ

បុគ្គលណា កាលភ្ញៀវអង្គុយហើយ មិនបរិភោគភោជន តែម្នាក់ឯង, ការបូជារបស់បុគ្គលនោះ ឈ្មោះថា រមែងមានផលពិតផង ការព្យាយាម ញុំាងទ្រព្យឲ្យកើត របស់បុគ្គលនោះ ឈ្មោះថា រមែងមានផលពិតផង, ម្នាលកោសិយសេដ្ឋី ព្រោះហេតុនោះ ខ្ញុំសូមនិយាយនឹងអ្នក ។ល។ បុគ្គលបរិភោគម្នាក់ឯង មិនបានសេចក្តីសុខទេ ។

ពាក្យដែលសេសសល់ ដូចគ្នានឹងពាក្យមុនដែរ ។

បន្ទាប់ពីនោះមក មាតលិទេវបុត្រ មកហើយបាននិយាយថា

បុគ្គលណា ប្ងូលទៅរកស្រះទាំងពួងហើយ ប្ងូជាក្នុងទន្លេផង ក្នុងស្រះបោក្ខរណីផង ក្នុងកំពង់ ឈ្មោះ ទោណៈផង ក្នុងកំពង់ ឈ្មោះតិម្ពរុផង ក្នុងស្នឹងធំដែលមានខ្សែទឹករហ័សផង, ប្រសិនបើការបូជារបស់បុគ្គលនោះ ក្នុងទីនោះ មានផល និងការព្យាយាមញុំាងទ្រព្យឲ្យកើត របស់បុគ្គលនោះ ក្នុងទីនោះ មានផលមែន, បុគ្គលណា កាលដែលភ្ញៀវអង្គុយហើយ មិនបរិភោគភោជន តែម្នាក់ឯង, ពាក្យដែលគួរពោល ក្នុងបុគ្គលនោះ រមែងមិនមាន, ម្នាលកោសិយសេដ្ឋី ព្រោះហេតុនោះ ខ្ញុំសូម និយាយនឹងអ្នក ។ល។ បុគ្គលបរិភោគម្នាក់ឯង មិនបានសេចក្តីសុខទេ ។

ពណ៌នាអំពីការតម្កល់ខ្លួនដោយប្រពៃ

បណ្តាបទទាំងនោះ ២ បទថា "**សវំ សព្ភំ**" មានសេចក្តីថា បុរសណា កាលធ្វើ នូវពលិកម្ម ដល់អមនុស្សទាំងឡាយ មាននាគ និងយក្សជាដើម ចូលទៅ ក្នុងទីទាំងឡាយមានសមុទ្រ ត្រពាំង និង ស្រះបោក្ខរណីជាដើម ស្រះណាមួយ ហើយបូជា គឺធ្វើពលិកម្ម ក្នុងទីនោះ ។ បទថា " **ពហុកាយ** " បានដល់ ក្នុងស៊ីង ។ បទថា " **គយាយ** " បានដល់ ក្នុងស្រះបោក្ខរណី ។ បទថា " **ទោណេ** " បានដល់ ក្នុងកំពង់ ឈ្មោះថា ទោណៈ ។ បទថា " **តិម្ពរុតិត្ថស្មិ** " បានដល់ ក្នុងកំពង់ ឈ្មោះ តិម្ពរុផង ។ បទថា " **មហាវហេ** " បានដល់ ក្នុងស៊ីងធំ ដែលមានខ្សែទឹករហ័សផង ។

បទថា " **អត្រ** " បានដល់ ក្នុងទីទាំងឡាយ មានស្រះជាដើមនោះ ។ សព្ទ ថា " **ចេ** " ប្រែថា ប្រសិនបើ ។ បទថា " **អស្ស** " មានសេចក្តីថា ការបូជា និង សេចក្តីព្យាយាមញុំាងទ្រព្យឲ្យកើតឡើង របស់បុគ្គលនោះ រមែងមាន គឺ រមែងមានផល មានសេចក្តីសុខជាកម្រៃ រមែងសម្រេច, បុគ្គលណា កាលដែលក្បៀវ គឺអាគន្តុកៈ អង្គុយហើយ មិនបរិភោគភោជន តែម្នាក់ឯង, ពាក្យដែលគួរនិយាយ ក្នុងបុគ្គលនោះ នឹងមិនមានឡើយ ។

ពាក្យដែលសេសសល់ ដូចគ្នានឹងពាក្យមុនដែរ ។

មង្គលត្ថទីបនីប្រែ

បន្ទាប់ពីនោះមក បញ្ចសិខទេវបុត្រ មកហើយ ពោលថា៖

បុគ្គល ណា កាលដែលភ្ញៀវអង្គុយហើយ បរិភោគនូវភោជន តែម្នាក់ឯង, បុគ្គលនោះ ឈ្មោះថា រមែងលេបនូវសន្ទូប ដែលមានខ្សែវែង ព្រមទាំងរនង ។ ម្នាលកោសិយសេដ្ឋី ព្រោះហេតុនោះ ខ្ញុំសូមនិយាយនឹងអ្នក ។ល។ បុគ្គលបរិភោគម្នាក់ឯង មិនបានសេចក្តីសុខទេ ។

សេដ្ឋី ស្តាប់ពាក្យនោះហើយ ក៏ជកដង្ហើមធំ ព្រោះការជួបប្រទះនឹងសេចក្តីទុក្ខ ទើបពោលថា " បើដូច្នោះ សូមអ្នកអញ្ជើញអង្គុយចុះ, អ្នកនឹងបានបន្តិច " ។ ឯបញ្ចសិខទេវបុត្រនោះ បានអង្គុយហើយ ។ កាលបើព្រាហ្មណ៍ទាំង ៥ នាក់នោះអង្គុយហើយយ៉ាងដូច្នេះឯង, សេដ្ឋី ក៏បានចម្អិននូវបាយបាយាសឆ្អិនហើយ ។ សេដ្ឋី លើកចុះអំពីជើងក្រាន ហើយពោលថា "ចូរអ្នកទាំងឡាយបេះស្ងឹកឈើមក " ។

ព្រាហ្មណ៍ទាំងនោះ អង្គុយ ក្នុងទីនោះឯងហើយ លាតដៃទៅបេះស្ងឹកជ្រៃ អំពីហិមវន្តប្រទេស ។

សេដ្ឋី ពោលថា " បាយបាយាសដែលខ្ញុំគប្បីដាក់ឲ្យ ក្នុងស្ងឹកឈើទាំងឡាយនេះ មិនមានទេ, ចូរអ្នកទាំងឡាយ នាំយកស្ងឹកសង្កែមកចុះ ។

ពណ៌នាអំពីការតម្កល់ខ្លួនដោយប្រពៃ

ព្រាហ្មណ៍ទាំងនោះ នាំយកស្វ៊ីកសង្កែទាំងឡាយនោះ មកហើយ ។ បណ្តាស្វ៊ីកសង្កែទាំងនោះ សន្ធឹកមួយ ៗ មានទំហំប៉ុនក្រម៉ែលទាហាន ។ សេដ្ឋីនោះ បានយកវែកជូសបាយបាយាស ឲ្យដល់ព្រាហ្មណ៍ទាំងអស់គ្នាហើយ ។

ក្នុងពេលដែលសេដ្ឋី ឲ្យបាយបាយាស ដល់ព្រាហ្មណ៍ចុងក្រោយគេបង្អស់ ការខ្វះខាត ក្នុងឆ្នាំង មិនមានប្រាកដឡើយ ។ សេដ្ឋីនោះ លុះបានឲ្យ (បាយបាយាស) ដល់ព្រាហ្មណ៍ទាំងនោះហើយ ក៏បានអង្គុយកាន់ឆ្នាំង ។

ក្នុងខណៈនោះ បញ្ចសិខទេវបុត្រ បានប្រែក្លាជាសត្វសុនខ ដើរបន្ទោបង់បស្សាវៈ ខាងមុខព្រាហ្មណ៍ទាំងឡាយនោះ ។ ព្រាហ្មណ៍ទាំងឡាយ បានយកដៃគ្របបាយបាយាស របស់ខ្លួន ។ ចំណែកសេដ្ឋី ក៏បានគ្របហើយ យ៉ាងដូច្នោះដែរ ។ ក៏តំណក់ទឹកបស្សាវៈ ធ្លាក់លើខ្នងដៃ របស់សេដ្ឋីនោះហើយ ។ សេដ្ឋីនោះ ប្រាថ្នានឹងលាងដៃ ទើបពោលថា “ ចូរអ្នកទាំងឡាយ មើលនូវឆ្នាំងបាយ របស់ខ្ញុំផង ” ដូច្នេះហើយ ក៏បានចុះទៅកាន់ស្ទឹង ។

ក្នុងខណៈនោះឯង សត្វសុនខ ក៏បានបន្ទោបង់បស្សាវៈ ជាក់លើឆ្នាំងបាយ ។ សេដ្ឋីឃើញសត្វសុនខនោះ កំពុងបន្ទោបង់បស្សាវៈ បានចាប់ដំបងយ៉ាងធំ គម្រាមមកហើយ ។ សត្វសុនខ

មង្គលត្ថទីបនីប្រែ

ក្តាយទៅជាសត្វមានមាឌធំ ប៉ុនសេះអាជានេយ្យ បានដេញតាម
សេដ្ឋីនោះ ដែលទៅហើយ ក្នុងទីនោះ ៗ ។ សេដ្ឋីនោះ ភ័យ
ហើយ ព្រោះមរណភ័យ ទើបចូលទៅរកព្រាហ្មណ៍ទាំងឡាយ ។
ព្រាហ្មណ៍ទាំងនោះឯង ក៏បានហោះទៅ ស្ថិតនៅ លើអាកាស ។

សេដ្ឋីនោះ ឃើញនូវឫទ្ធិ របស់ព្រាហ្មណ៍ទាំងនោះហើយ
ទើបសួរថា “តើពួកអ្នកទាំងឡាយ ជាអ្នកណាគេ ?” ។

លំដាប់នោះ ស្តេចសក្កទេវរាជ ទ្រង់ត្រាស់ថា “ អ្នកនេះ
ជាចន្ទទេវបុត្រ, អ្នកនេះ ជាសុរិយទេវបុត្រ, អ្នកនេះ ជាមាតលិ-
ទេវបុត្រ, ខ្ញុំជាស្តេចសក្កទេវរាជ, សត្វសុនខនេះ ជាបញ្ចសិខ-
ទេវបុត្រ ” ហើយ ទ្រង់ត្រាស់ថា “ ពួកយើង មិនមែនមកហើយ
ដើម្បីត្រូវការចាយចាយាស របស់អ្នកឡើយ, តែអ្នកជាញាតិ
របស់ពួកយើង, ឥឡូវនេះ អ្នកជាបុគ្គលកំណាញ់ស្វិតស្វាញ, ក៏
ធម្មតា ពួកមនុស្សកំណាញ់ រមែងទៅកើត ក្នុងនរក, ពួកមនុស្ស
ដែលមិនកំណាញ់ រមែងទៅកើត ក្នុងស្ថានសួគ៌, ព្រោះហេតុនោះ
យើងទាំងឡាយ មកហើយ ព្រោះសេចក្តីអាណិតអាសូរ ចំពោះ
អ្នកតែម៉្យាងប៉ុណ្ណោះ ” ។

សេដ្ឋីនោះ ស្តាប់ពាក្យនោះហើយ មានចិត្តត្រេកអរ ថា
“ បានឮថា ពួកទេវតាទាំងនេះ ជាអ្នកប្រាថ្នាប្រយោជន៍ ចំពោះ

ពណ៌នាអំពីការតម្កល់ខ្លួនដោយប្រពៃ

អញ ជាអ្នកប្រាថ្នានឹងលើកអញ ឲ្យរួចផុតអំពីនរកហើយ ឲ្យស្ថិតនៅ ក្នុងស្ថានសួគ៌ ” ដូច្នេះហើយ ទើបពោលថា “ ចាប់ផ្តើមអំពីពេលនេះ តទៅ សូម្បីវត្ថុពាក់កណ្តាល ៗ អំពីជុំបាយ របស់អញ ឈ្មោះថា អញមិនគប្បីឲ្យ មិនមានឡើយ, មួយវិញទៀត អញបាននូវទឹក សូម្បីត្រឹមតែមួយទូកដៃ មិនបានឲ្យ (ដល់អ្នកណា) ហើយ ក៏នឹងមិនផឹកឡើយ ” ដូច្នេះហើយ បានទទួលពរក្នុងសំណាក់ នៃស្តេចសក្កទេវរាជ ។

ស្តេចសក្កទេវរាជ ទ្រង់អប់រំទូន្មានសេដ្ឋីនោះហើយ ទ្រង់ញុំាងសេដ្ឋីនោះ ឲ្យស្គាល់ផលនៃទាន ទ្រង់បានប្រទានបញ្ចសីលហើយ ទ្រង់ស្តេចយាងទៅកាន់ទេវលោក ព្រមទាំងទេវបុត្រទាំងឡាយ មានចន្លុះទេវបុត្រជាដើម ។

ចំណែកសេដ្ឋីនោះ ចូលទៅកាន់ព្រះនគរ បានញុំាងព្រះរាជា ឲ្យទ្រង់ត្រាស់អនុញ្ញាតឲ្យហើយ ទើបប្រកាសថា “សូមពួកជនទាំងឡាយ ញុំាងភាជនៈ ដែលខ្លួនកាន់ហើយ ៗ ឲ្យពេញបរិបូណ៌ហើយ នាំយកទៅចុះ ” ដូច្នេះហើយ បានឲ្យទ្រព្យ ដល់ពួកយាចកទាំងឡាយ ចេញហើយ ក្នុងខណៈនុ៎ះឯង បានកសាងបណ្ណសាលា ក្នុងចន្លោះ នៃទន្លេគង្គា និង ស្រះដែលកើតឯងមួយខាងទិសទក្សិណ អំពីហិមវន្តប្រទេស បួសហើយ អាស្រ័យនៅ

មង្គលត្ថទីបនីប្រែ

ក្នុងទីនោះ អស់កាលដ៏យូរ ធ្វើកាលកិរិយាហើយ ក៏បានកើតជាឧបបាតិកទេវបុត្រ បានឡើងជិះរថវេជយន្ត ដែលស្តេចសក្ក-ទេវរាជ ទ្រង់បានបញ្ជូនទៅហើយ ក៏បានទៅកាន់សំណាក់ស្តេចសក្កទេវរាជ មួយអន្ទឹដោយមាតលិទេវបុត្រ ។

ស្តេចសក្កទេវរាជ ទ្រង់ទតព្រះនេត្រឃើញទេវបុត្រនោះហើយ ទ្រង់មានព្រះទ័យត្រេកអរ ទ្រង់បានប្រទានហើយ នូវព្រះធីតា ព្រះនាមហិរីទេវី ដល់ទេវបុត្រនោះ ។ ឥស្សរិយយស ដែលរកប្រមាណមិនបាន កើតមានហើយ ដល់ទេវបុត្រនោះ ។ ក្នុងពុទ្ធុប្បាទនេះ ទេវបុត្រនោះ កើតជាកុលបុត្រ ក្នុងទីក្រុងសាវត្ថី ស្តាប់ទេសនា របស់ព្រះសាស្តាហើយ ក៏បានបួស មានប្រក្រតីធ្វើឲ្យបរិបូណ៌ក្នុងសីល ដល់ព្រមហើយដោយគុណ គឺធុតង្គ មានអជ្ឈាស្រ័យ ក្នុងទាន ត្រេកអរខ្លាំងក្លា ក្នុងទាន ជាអ្នកបំពេញសារាណិយធម៌ កាលបើបដិគ្គាហកៈ មាន សូម្បីជាអ្នកអត់អាហារ ក៏ឲ្យនូវវត្ថុដែលខ្លួនបានហើយទាល់តែបាន ។

ព្រះសាស្តា ទ្រង់ធ្វើសេចក្តីត្រេកអរដ៏ក្រៃលែង ក្នុងទាននោះ របស់កិក្ខុរូបនោះ ឲ្យជាហេតុកើតឡើងហើយ ទើបទ្រង់ត្រាស់ថា “ ម្នាលកិក្ខុទាំងឡាយ ក្នុងកាលមុន កិក្ខុរូបនេះ ជាអ្នកមិនឲ្យទានជាប្រក្រតី ជាមនុស្សកំណាញ់ មិនឲ្យសូម្បីទាំងប្រេង

ពណ៌នាអំពីការតម្កល់ខ្លួនដោយប្រពៃ

មួយតំណាក់ ដោយចុងស្មៅ, កាលបើដូច្នោះ តថាគត បានអប់រំទូន្មានភិក្ខុរូបនោះហើយ ពណ៌នាផលនៃទាន បានឲ្យស្ថិតនៅស៊ប់ក្នុងទានហើយ, ភិក្ខុរូបនោះ បានតាំងចិត្តថា អាត្មាអញ បានទឹកសូម្បីមួយទូកដៃ មិនបានឲ្យ ដល់អ្នកណាមួយ ហើយ នឹងមិនផឹកឡើយ ដូច្នេះហើយ បានទទួលពរ ក្នុងសំណាក់នៃតថាគត ព្រោះផលនៃទាននោះ ភិក្ខុរូបនោះ ទើបជាអ្នកមានអធ្យាស្រ័យក្នុងទាន ជាអ្នកត្រេកអរខ្លាំង ក្នុងទាន " ដូច្នេះហើយ ទើបត្រាស់នូវសុធាភោជនជាតក ក្នុងអសីតិនិបាត ។

រឿង មច្ឆរិកោសិយៈ មកក្នុងអដ្ឋកថា សុធាភោជនជាតក ។

*(១១១) រឿង របស់ឥល្លិសេដ្ឋី អ្នកផឹកសុរា កែ្បរគុម្ពឈើមួយដើម ជាអ្នកដែលស្តេចសក្ក ជាស្តេចនៃទេវតា បានទូន្មានហើយ ស្គាល់ផលនៃទាន បានធ្វើបុណ្យហើយ ក៏បានទៅកើតក្នុងឋានសួគ៌ ក្នុងអដ្ឋកថាឥល្លិសជាតក ថា " **ឧភោ ឧញ្ញោ ឧភោ កុណ្ឌី** " ដូច្នេះ ជាដើម ក្នុងអដ្ឋមវគ្គ នៃឯកនិបាតក្តី, រឿងសេដ្ឋីកំណាញ់ដែលព្រះមោគ្គល្លានត្ថេរ ដឹងថា សេដ្ឋីនោះ បានអង្គុយលើផ្ទៃខាងលើ នៃប្រាសាទ ទី ៧ ដើម្បីបរិភោគនំអំបែងហើយនិមន្តទៅទូន្មាន ក្នុងទីនោះហើយ ប្រគេននំ ក្រោយមក បានទៅកាន់វត្តជេតពន ស្តាប់នូវទេសនា របស់ព្រះសាស្តាហើយ ក៏បាន*

មង្គលត្ថទីបនីប្រែ

*សម្រេចសោតាបត្តិផល ក្នុងអដ្ឋកថានៃគាថាថា " **យថាបិ រហមេ បុប្ផំ** " ដូច្នេះជាដើម ក្នុងបុប្ផវគ្គនៃធម្មបទក្តី ក៏គប្បីសំដែងផង ។*

ជនទាំងអស់នោះ តាំងខ្លួនដែលទ្រុស្តសីល មិនមានសទ្ធា កំណាញ់ស្វិតស្វាញ ក្នុងគុណទាំងឡាយ មានសីលជាដើមហើយ ក៏បានសម្រេចអានិសង្សផ្សេង ៗ គ្នា ដោយប្រការដូច្នេះឯង ។

*មួយទៀត ពៀរឯណា មានការទ្រុស្តសីលជាដើមជាហេតុ ដែលជនទាំងនោះគប្បីបាន ក្នុងបច្ចុប្បន្ន និង សម្បរាយកភព, ពៀរនោះ គឺជនទាំងនោះ រមែងលះបង់បាន ខាងក្រោយ អំពីពេលដែលខ្លួនតាំងនៅ ក្នុងគុណ មានសីលជាដើម, ព្រោះហេតុនោះ ការតាំងខ្លួនទុក ដោយប្រពៃ គប្បីជ្រាបថា " **ជាមង្គល** " ។*

ព្រោះហេតុនោះ ក្នុងអដ្ឋកថា ទើបលោកពោលថា " ការតាំងខ្លួនទុកដោយប្រពៃនោះឯង ជាមង្គល ។ ព្រោះហេតុអ្វី ? ។ ព្រោះជាហេតុលះបង់ពៀរដែលប្រព្រឹត្តទៅ ក្នុងបច្ចុប្បន្ន និង ក្នុងសម្បរាយកភព និង សម្រេចអានិសង្សផ្សេងៗ គ្នា " ដូច្នេះឯង ។

(១១២) មែនពិត ចិត្តដែលបុគ្គលបានតាំងទុកប្រពៃហើយ រមែងអាច ដើម្បីនឹងឲ្យនូវសម្បត្តិ គ្រប់យ៉ាងបាន ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ ថា " បិយជនទាំងឡាយ មានមាតាជាដើម មិនអាចដើម្បីនឹងឲ្យ នូវសម្បត្តិណាមួយ បាន

ពណ៌នាអំពីការតម្កល់ខ្លួនដោយប្រពៃ

ទ្បើយ, ចិត្ត ដែលបុគ្គលបានតម្កល់ទុកប្រពៃហើយ ដែលប្រព្រឹត្ត ទៅ ពួជ៏ខាងក្នុង នៃសត្វទាំងឡាយនេះប៉ុណ្ណោះឯង រមែងឲ្យ នូវ សម្បត្តិនោះបាន " ដូច្នេះហើយ ទើបទ្រង់ត្រាស់នូវគាថានេះ ក្នុង ចិត្តវគ្គ នៃធម្មបទ (១) ថា ៖

> មាតាបិតា មិនគប្បីធ្វើហេតុនោះបាន, ឬ ជនទាំងឡាយដទៃ ជាញាតិ ក៏មិនគប្បីធ្វើ នូវហេតុនោះបាន, បំណែកខាងចិត្ត ដែលបុគ្គលតម្កល់ទុក ត្រូវហើយ តែងធ្វើបុគ្គលនោះ ឱ្យ ប្រសើរជាងហេតុនោះបាន ។

*បណ្តាបទទាំងនោះ បទថា " **ន តំ** " មានសេចក្តីថា ម្នាលភិក្ខុទាំងឡាយ មាតាគប្បីធ្វើនូវហេតុនោះ មិនបានទ្បើយ, បិតា ក៏មិនបាន, ជនទាំងឡាយដទៃ ជាញាតិ ក៏មិនបានដែរ ។*

*បទថា " **សម្មាបណិហិតំ** " បានដល់ ដែលបុគ្គលតាំងទុកហើយ ក្នុងកុសលកម្មបថ ១០ ប្រការ ។ បានគាថា ថា " **សេយ្យសោ នំ តតោ ករេ** " មានសេចក្តីថា រមែងធ្វើបុគ្គលឲ្យប្រសើរជាង គឺឲ្យខ្ពង់ខ្ពស់ជាងហេតុនោះ ។ មែនពិត មាតា និងបិតា កាលនឹងឲ្យនូវទ្រព្យដល់កូនទាំងឡាយ រមែងអាចដើម្បី ឲ្យកូនមិនចាំបាច់ធ្វើការងារ ចិញ្ចឹមជីវិតរស់នៅ ដោយស្រួលបាន*

๑- សុត្តន្តបិដក ភាគទី ៥២ ទំព័រទី ៣០ ។

មង្គលត្ថទីបនីប្រែ

ក្នុងអត្តភាពនេះតែប៉ុណ្ណោះ, តែឈ្មោះថា មាតាបិតា ជាអ្នកអាច ដើម្បីឲ្យនូវសិរីគឺចក្រពត្តិ ដល់កូនទាំងឡាយ មិនមានឡើយ, នឹង ពោលធ្វើអ្វី ដល់មាតាបិតា ជាអ្នកអាចដើម្បីឲ្យ នូវទិព្វសម្បត្តិ ឬ សម្បត្តិ មានបឋមឈាន ជាដើមបាននោះ, មិនចាំបាច់និយាយ ក្នុងការឲ្យនូវលោកុត្តរសម្បត្តិឡើយ ។ ចំណែកខាង ចិត្តដែល បុគ្គលតម្កល់ទុកត្រូវហើយ រមែងអាចដើម្បីឲ្យនូវសម្បត្តិទាំងពួង នោះបាន, ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះ តម្រាស់នោះទុកហើយ ។

ព្រោះហេតុនោះ ចិត្តសូម្បីបុគ្គលណាមួយក៏ដោយ ត្រូវតែ តម្កល់ទុក ដោយប្រពៃ ទើបឲ្យនូវសេចក្តីសុខ គ្រប់យ៉ាងបាន ។

(១១៣) មែនពិត ចិត្ត ដែលបុគ្គលតម្កល់ទុកខុសហើយ រមែងឲ្យនូវសេចក្តីទុក្ខ គ្រប់យ៉ាងបាន, ព្រោះហេតុនោះ ទើបព្រះ មានព្រះភាគទ្រង់ត្រាស់ថា "ពួកចោរ ពួកជនអ្នកមានពៀរ រមែង មិនអាចដើម្បីធ្វើនូវសេចក្តីវិនាស ណាមួយបានឡើយ, ចិត្តដែល បុគ្គលតម្កល់ទុកខុសហើយ ឰដ៏ខាងក្នុង នៃសត្វទាំងឡាយនេះ តែប៉ុណ្ណោះ រមែងធ្វើ នូវសេចក្តីវិនាសនោះបាន " ដូច្នេះហើយ ទើបទ្រង់ត្រាស់គាថានេះ ក្នុងចិត្តវគ្គ [1] នៃធម្មបទន៏ឯង ថា ៖

១- សុត្តន្តបិដក ភាគទី ៥២ ទំព័រទី ៣០ ។

ពណ៌នាអំពីការតម្កល់ខ្លួនដោយប្រពៃ

ចោរ ក្រឡេកឃើញចោរផងគ្នា ឬក៏ បុគ្គលមានពៀរក្រឡេកឃើញបុគ្គលមានពៀរផងគ្នា គប្បីធ្វើនូវសេចក្តីវិនាស ណាមួយ (ដល់គ្នា), បិតុ ដែលបុគ្គលតម្កល់ទុកខុសហើយ រមែងធ្វើបុគ្គលនោះ ឱ្យអាក្រក់ក្រៃលែង ជាងសេចក្តីវិនាសនោះទៅទៀត ។

ចោរ ឈ្មោះថា ***ទិសោ*** *ក្នុងគាថានោះ ។ បទថា “* ***ទិសំ*** *” ប្រែថា នូវចោរ ។ គប្បីបន្ថែមជាលីដែលនៅសល់ថា “* ***ទិស្វា*** *” ប្រែថា ឃើញហើយ ។ ២ បទថា “* ***យន្តំ កយិរា*** *” មានសេចក្តីថា គប្បីធ្វើនូវសេចក្តីវិនាស ឯណាមួយ ដល់ចោរ ដែលខ្លួនបានឃើញហើយនោះ ដោយអំណាចការបៀតបៀនបុត្រ និង ភរិយា ការញុំាងអសង្ឃារិមទ្រព្យ មានស្រែជាដើម ឲ្យវិនាសសាបសូន្យ និង ការផ្តាច់បង់ចាកជីវិត ។ បុគ្គលអ្នកចងពៀរទុក ដោយហេតុណាមួយប៉ុណ្ណោះ ឈ្មោះថា អ្នកមានពៀរ ។*

បទថា “ ***វេរិនំ*** *” ប្រែថា ឃើញបុគ្គលអ្នកមានពៀរនោះ ។ បទថា “* ***មិច្ឆាបណិហិតំ*** *” មានសេចក្តីថា ដែលបុគ្គលតម្កល់ទុកហើយ ក្នុងអកុសលកម្មបថ ១០ ប្រការ ។ បទថា “* ***បាបិយោ*** *” ប្រែថា ឲ្យអាក្រក់ក្រៃលែងជាង ។ បទថា “* ***នំ*** *” បានដល់ នូវបុគ្គលដែលតម្កល់ចិត្តទុកខុសហើយនោះ ។*

មង្គលត្ថទីបនីប្រែ

បទថា " **តតោ** " មានសេចក្តីថា ជាង់បុគ្គលដែលជាចោរ និង បុគ្គលដែលមានពៀរ គឺ ចោរ និង បុគ្គលមានពៀរទាំង់ឡាយ ឃើញហើយនោះ, មួយទៀត ជាង់សេចក្តីវិនាសនោះ ។ បទថា " **ករេ** " ប្រែថា គប្បីធ្វើ ។

ដូចព្រះតម្រាស់ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ថា " ចោរ ឬ បុគ្គលមានពៀរ កាលប្រព្រឹត្តខុស ក្នុង់បុត្រ ភរិយា ស្រែចំការ គោ និង ក្របីជាដើម, ខ្លួនប្រព្រឹត្តខុស ចំពោះចោរ និង បុគ្គលអ្នកមានពៀរណាមួយ, ឃើញសូម្បីនូវចោរ និង បុគ្គលអ្នកមានពៀរនោះ ដែលប្រព្រឹត្តខុសចំពោះខ្លួន ដូច្នោះដែរ រមែង់ធ្វើនូវសេចក្តីវិនាសណាមួយ ដល់ចោរ និង បុគ្គលអ្នកមានពៀរនោះ, ចិត្តដែលបុគ្គលតម្កល់ទុកខុសហើយ គប្បីធ្វើនូវបុគ្គលនោះ ឲ្យអាក្រក់ក្រៃលែង់ជាង់ចោរ ឬ បុគ្គលអ្នកមានពៀរ គប្បីធ្វើដល់គ្នា ឬ ជាង់សេចក្តីវិនាសនោះទៅទៀត ។ មែនពិត ពួកចោរ និង បុគ្គល អ្នកមានពៀរទាំង់ឡាយ គប្បីធ្វើសេចក្តីទុក្ខ ឲ្យកើតឡើង ឬ គប្បីធ្វើនូវការអស់ទៅនៃជីវិត ក្នុង់អត្តភាពនេះ តែប៉ុណ្ណោះឯង, ចំណែកខាង ចិត្ត ដែលបុគ្គលតម្កល់ទុកខុសហើយ ឲ្យដល់សេចក្តីវិនាស ក្នុង់បច្ចុប្បន្ននេះហើយ បានទំលាក់ចោលទៅ ក្នុង់អបាយទាំង ៤ មិនឲ្យងើបក្បាលឡើងរួច អស់មួយ

សែនអត្តភាពថែមទៀត ។ ព្រោះហេតុនោះ អ្នកណាក៏ដោយ មិនគួរតម្កល់ចិត្តខុសឡើយ ។

(១១៤) ក៏បុគ្គលណា តម្កល់ចិត្តដែលប្រតិបត្តិខុស ក្នុងកាលមុន ដោយប្រពៃ ក្នុងកាលជាខាងក្រោយមក, បុគ្គលនោះ លោកឲ្យឈ្មោះថា " ជាអ្នកមានខ្លួនបានអប់រំហើយ " ។ ធម្មតាបុគ្គលដែលមានខ្លួន បានអប់រំហើយ រមែងទៅកាន់ទិស ដែលខ្លួនមិនធ្លាប់បានទៅដល់, ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់ទូន្មានន្ទវកិក្ខុ ១ រូប ដែលធ្លាប់ជាអ្នកហ្វឹកដំរី ទើបទ្រង់ត្រាស់គាថានេះ ក្នុងនាគវគ្គ នៃធម្មបទ ថា ៖

> បុគ្គល ទូន្មានខ្លួនបានបទហើយ ទូន្មានខ្លួនល្អហើយ ឈ្មោះថា ទូន្មានហើយ រមែងទៅកាន់ទិស ដែលខ្លួនមិនធ្លាប់ទៅ គឺព្រះនិព្វានបាន ពុំមែនដូចជាបុគ្គលទៅកាន់ទិស ដែលខ្លួនមិនធ្លាប់ទៅ ដោយសារយានទាំងឡាយនោះឡើយ ។

បណ្តាបទទាំងនោះ បទថា " ***អគតំ*** " បានដល់ ដែលខ្លួនមិនធ្លាប់បានទៅដល់ហើយ សូម្បីដោយការយល់សប្តិ ។ បទថា " ***ទិសំ*** " បានដល់ ព្រះនិព្វាន ។ បទថា " ***អត្តនា*** " បានដល់ ចិត្ត ។ បទថា " ***សុទន្តេន*** " មានសេចក្តីថា ដែលបានទូន្មានល្អហើយ ដោយល្អ ដោយភាវនា ដែលសម្បយុត្ត ដោយ

មង្គលត្ថទីបនីប្រែ

អរិយមគ្គ ។ បទថា “ **ទន្តោ** *” ជានដល់ ជាអ្នកមានការសេពគប់ខុស អស់ហើយ ។ បទថា “* **ទន្តេន** *” ជានដល់ ដែលខ្លួនទូន្មានហើយ ដោយការទូន្មាន នូវឥន្ទ្រីយ៍ ។ សមដូចជាព្រះតម្រាស់ដែលព្រះមានព្រះភាគ ត្រាស់ទុកហើយថា “ បុគ្គលអ្នកមានប្រាជ្ញា ទូន្មានខ្លួនហើយ មានខ្លួនជានទូន្មានហើយ ក្នុងចំណែកខាងដើម ក្នុងកាលក្រោយមក ទូន្មានជានល្អហើយ រមែងទៅកាន់ទិស ដែលខ្លួនមិនធ្លាប់ជានទៅ គឺ ទៅដល់ភូមិដែលអប់រំហើយ យ៉ាងណាមិញ, បុគ្គលខ្លះ គប្បីទៅកាន់ទិសដែលខ្លួនមិនធ្លាប់ទៅដល់ ដោយយានទាំងឡាយ មានយានដែលទឹម ដោយជំរីជាដើមនោះ យ៉ាងដូច្នោះ មិនជានឡើយ, ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ការទូន្មានខ្លួនប៉ុណ្ណោះ ជាធម្មជាត ដ៏ប្រសើរសម្រាប់អ្នក ដោយប្រការដូច្នេះឯង ” ។*

ពណ៌នាអំពីការតម្កល់ខ្លួនដោយប្រពៃ ចប់ ។

(១១៥) មង្គល ៣ ប្រការ គឺ ការរស់នៅ ក្នុងប្រទេសដ៏សមគួរ ១ ភាពជាអ្នកមានបុណ្យជានធ្វើទុកហើយ ក្នុងកាលមុន ១ ការតម្កល់ខ្លួនទុកដោយប្រពៃ ១ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ដោយគាថានេះឯង ដោយប្រការដូច្នេះ ។

មង្គលត្ថទីបនីប្រែ

*បាទ ទី ១ ក្នុងគាថា ទី ២ នេះ មាន ៩ អក្សរ ជូចគ្នា នឹងគាថា ទី ៥ ថា " **ការឲ្យទាន** ១ **ការប្រព្រឹត្តិធម៌** ១ **តបៈ** ១ **កិរិយាប្រព្រឹត្តិប្រសើរ** ១ " យ៉ាងដូច្នេះដែរ ។*

បាទ ទី ២ ប្រកបដោយលក្ខណៈ នៃបាទ ទី ២ នៃ បឋ្យាវត្ត ។ កន្ទះគាថា ទី ២ ជាបឋ្យាវត្ត ដូច្នេះឯង ។

ពណ៌នាសេចក្តីនៃគាថា ទី ២ ចប់ ។

ប្រែចប់សព្វគ្រប់
នៅថ្ងៃអង្គារ ១៣ រោច ខែបុស្ស ឆ្នាំ ច ឆស័ក ព. ស. ២៥៣៧
ថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ ១៩៩៤
វេលា ម៉ោង ៩:៣៤ យប់

ពណ៌នាសេចក្តីនៃគាថា ទី ៣

(១១៦) គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថា ទី ៣ ។ ភាវៈនៃបុគ្គលអ្នកមានកិរិយាស្តាប់ច្រើន ឈ្មោះថា **ពាហុសច្ចៈ** ។ ភាពជាអ្នកឆ្លាតវាងវៃ ក្នុងហត្ថកម្ម ណាមួយ ឈ្មោះថា **សិល្បៈ** ។ សូម្បីក្នុងជីកាវាសេដ្ឋសូត្រ ក្នុងមជ្ឈិមបណ្ណាសក: ក៏លោកពោលហើយថា " ភាពជាអ្នកឆ្លាតវាងវៃក្នុងហត្ថកម្ម ឈ្មោះថា **សិល្បៈ** ព្រោះអត្ថថា គឺបុគ្គលគប្បីសិក្សា ដោយឧបាយនោះៗ " ។

ច្បាប់សម្រាប់ទូន្មាន នូវកាយ វាចា និង ចិត្ត អធិប្បាយថា " គ្រឿងហាមឃាត់ គ្រឿងហាមប្រាម នូវកាយ វាចា និង ចិត្ត ទាំងឡាយនោះ ចាកអាបត្តិខ្លះ ចាកទោសគ្រឿងទ្រុស្តសីលខ្លះ ចាកអកុសលកម្មបថខ្លះ តាមសមគួរ " ឈ្មោះថា **វិនយៈ** ។

ចំណែក ក្នុងអដ្ឋកថាទាំងឡាយ មានអដ្ឋកថា សាមន្តបាសាទិកា ជាដើម លោកបានពោល សំដៅយកព្រះវិនយបិដក តែម៉្យាងថា " ឧបាយនុ៎ះ រមែងទូន្មាន នូវកាយផង វាចាផង ព្រោះហាមឃាត់នូវអជ្ឈាចារ ដែលប្រព្រឹត្តទៅតាមផ្លូវកាយ និង វាចា ព្រោះហេតុនោះ ឧបាយនោះ ទើបឈ្មោះថា វិនយៈ " ។

ក្នុងអដ្ឋកថា លោកពោលហើយថា បទថា " **សុសិក្ខិតោ** គឺ ដែលបុគ្គលសិក្សាហើយ ដោយល្អ ។ បទថា **សុភាសិតា** គឺ

មង្គលត្ថទីបនីប្រែ

ដែលបុគ្គលពោលហើយ ដោយល្អ ។ សព្ទថា **យោ** ជាសព្ទសំដែងនូវសេចក្តីដែលមិនមានកំណត់ ។ វាចា ដែលបុគ្គលគប្បីពោលគឺ វាចា ដែលជាផ្លូវ ឈ្មោះថា **វាចា** ” ។

អដ្ឋកថា នៃរូបកណ្ឌ ថា “ សទ្ទជាតិ ណា ដែលបុគ្គលពោល ហេតុនោះ សទ្ទជាតិ នោះ ឈ្មោះថា **វាចា** ។ សទ្ទជាតិ ណា ដែលបុគ្គលនិយាយ ហេតុនោះ សទ្ទជាតិ នោះ ឈ្មោះថា **គិរា** ។ ការបញ្ចេញវាចា ឈ្មោះថា វាចាដែលជាផ្លូវ ។ វាចា នោះផង ជាផ្លូវផង នៃពួកជន ដែលប្រាថ្នាចង់ដឹងខ្លួនឯង និង ប្រាថ្នាចង់ឲ្យអ្នកដទៃដឹង នូវសេចក្តី ហេតុនោះឯង វាចា នោះទើបឈ្មោះថា វាចា ដែលជាផ្លូវ ” ដូច្នេះ ។

អដ្ឋកថាមុសាវាទសិក្ខាបទ ថា “ ពាក្យដែលជាផ្លូវ ឈ្មោះថា **ព្យបថោ** ។ មែនពិត វាចានុ៎ះឯង ជាផ្លូវរបស់ជនទាំងឡាយ អ្នកដល់នូវទិដ្ឋានុគតិ សូម្បីនៃពួកជនដទៃ ទើបលោកហៅថា **ព្យាបថោ** ” ។

ផ្ទាស់ **វាចា** សព្ទ ទៅជា **ព្យៈ** ព្រោះ **បថ** សព្ទ ខាងដើម ដោយសូត្រ ក្នុងសទ្ទនីតិ ដែលសំដែងអំពីសន្ធិកប្បៈ ថា “ ផ្ទាស់ វាចាសព្ទ ទៅជា **ព្យៈ** ព្រោះ **បថ** សព្ទ ” ក៏បាន ដោយមហាព្រឹទ្ធិ ក៏បាន ។

មង្គលត្ថទីបនីប្រែ

បទថា “ **ឯតំ** *” មានសេចក្តីថា ម្នាលទេវតា អ្នកចូរប្រកាន់យកថា “ភាវៈនៃបុគ្គលជាអ្នកមានកិរិយាស្តាប់មកច្រើន ១ សិល្បៈ ១ វិនយ ដែលបុគ្គលបានសិក្សាល្អហើយ ១ វាចា ដែលបុគ្គលពោលល្អហើយ ១, កម្មទាំង ៤ យ៉ាងនេះ ជាមង្គលដ៏ឧត្តម ” ។*

សេចក្តីសង្ខេប ក្នុងគាថា ទី ៣ នេះ មានត្រឹមតែប៉ុណ្ណេះ ។
ចំណែកសេចក្តីពិស្តារ ក្នុងគាថា ទី ៣ នេះ មានដូចតទៅនេះ ៖

❋ ❋ ❋

ពណ៌នាអំពីភាពជាអ្នកបានស្តាប់ច្រើន

(១១៧) ភាវៈនៃបុគ្គលជាអ្នកមានកិរិយាស្តាប់មកច្រើន ឈ្មោះថា **ពាហុសច្ចៈ** ។ ដោយសេចក្តី ពាហុសច្ចៈ បានដល់ ភាពជាអ្នកឆ្លាតវាងវៃ ក្នុងកិច្ចការនោះ ។ ដែលកើតឡើង ព្រោះសិក្សាខ្លះ ព្រោះស្តាប់ខ្លះ នូវព្រះពុទ្ធវចនៈ ឬ សិល្បៈ ខាងក្រៅលើកលែង នូវភាពជាអ្នកឈ្លាសវៃ ក្នុងហត្ថកម្ម ដែលព្រះមានព្រះភាគ ទ្រង់ប្រកាន់យកហើយ ដោយសិប្បសព្វ ដែលបំរុងនឹងពោលចេញ ។ ពាហុសច្ចៈ នោះ មាន ២ យ៉ាង ដោយអំណាច ពាហុសច្ចៈ របស់បព្វជិតនិងគ្រហស្ថ ។ បណ្តាពាហុសច្ចៈទាំង ២ យ៉ាងនោះ ភាពជាអ្នកចងចាំ នូវពាក្យប្រៀបប្រដៅ របស់ព្រះសាស្តា ដែលព្រះមានព្រះភាគ ទ្រង់សំដែងទុកហើយ ក្នុងព្រះសូត្រទាំងឡាយ មានខុរុវេលសូត្រជាដើម ដោយនយជាអាទិ៍ យ៉ាងនេះថា " ភិក្ខុ ជាអ្នកមានកិរិយាស្តាប់មកច្រើន ជាអ្នកទ្រទ្រង់ព្រះសូត្រ ជាអ្នកមានព្រះសូត្រជាទីសន្សំទុក " យ៉ាងដូច្នេះ ឈ្មោះថា ពាហុសច្ចៈ របស់បព្វជិត ។

ខុរុវេលសូត្រ មកក្នុងបឋមបណ្ណាសកៈ បតុក្កនិបាត អង្គុត្តរនិកាយ ។

(១១៨) អដ្ឋកថា នៃខុរុវេលសូត្រនោះ ថា " សុតៈ គឺ ពាក្យប្រៀនប្រដៅ របស់ព្រះសាស្តា ប្រកបដោយអង្គ ៩ របស់

មង្គលត្ថទីបនីប្រែ

កិក្ខុនោះច្រើន អធិប្បាយថា ជាព្រះសូត្រ ដែលកិក្ខុនោះ សិក្សាហើយ ដោយអំណាចនៃអក្ខរៈ ខាងដើម និង ខាងចុង នៃបាលី និង អនុសន្ធិ ដូច្នេះ, កិក្ខុនោះ ឈ្មោះថា ពហុស្សុត្រ ។ បទថា ***សុតធរោ*** គឺ ជាអ្នកទ្រទ្រង់នូវព្រះសូត្រ ។ មែនពិត ព្រះពុទ្ធវចនៈ គឺ កិក្ខុរូបណា រៀនហើយ អំពីបាលីនេះ រមែងបាត់សូន្យទៅ ចាកបាលីនេះ មិនស្ថិតនៅ ដូចជាទឹក ក្នុងឆ្នាំងដែលធ្លុះ, កិក្ខុរូបនោះ រមែងមិនអាច ដើម្បីនឹងសំដែង ឬ ជ្រាប់នូវព្រះសូត្រ ឬ ជាតកមួយ ក្នុងកណ្តាលបរិស័ទបានឡើយ, កិក្ខុរូបនេះ មិនបានឈ្មោះថា ជាអ្នកទ្រទ្រង់ព្រះសូត្រទេ ។ ចំណែកព្រះពុទ្ធវចនៈ ដែលកិក្ខុរូបណា រៀនហើយ រមែងដូចជាពេលដែលខ្លួនបានរៀនមកហើយនុ៎ះឯង, កាលបើកិក្ខុរូបនោះ មិនធ្វើការស្វាធ្យាយ រហូតដល់ ១០ ឆ្នាំ ក្តី ២០ ឆ្នាំ ក្តី ក៏រមែងមិនវិនាសបាត់ទៅ, កិក្ខុរូបនេះ ទើបឈ្មោះថា ជាអ្នកទ្រទ្រង់ព្រះសូត្រ ។ បទថា " ***សុតសន្ធិចយោ*** " គឺជាអ្នកសន្សំនូវព្រះសូត្រ ។ មែនពិត ព្រះសូត្រ គឺកិក្ខុ រូបណាសន្សំទុកហើយ ក្នុងទូ គឺហឫទ័យ រមែងស្ថិតនៅ ដូចជាស្នាមចារឹកលើសីលា និង ដូចជាខ្លាញ់ពងពជសីហ៍ ដែលគេចាត់ទុកហើយ ក្នុងឆ្នាំងមាស, កិក្ខុរូបនោះ ទើបឈ្មោះថា ជាអ្នកសន្សំនូវព្រះសូត្រ " យ៉ាងដូច្នេះឯង ។

ពណ៌នាអំពីភាពជាអ្នកបានស្តាប់ច្រើន

ដីកា នៃខុរវេលសូត្រនោះ ថា " ព្រះបរិយត្តិធម៌ ឈ្មោះថា សុតៈ ព្រោះជាធម៌ដែលបុគ្គលអ្នកមានសេចក្តីត្រូវការ ដោយការចៀសចេញ ចាកសេចក្តីទុក្ខ ក្នុងវដ្តៈ គប្បីស្តាប់, កិក្ខុ រូបណា ទ្រទ្រង់នូវសុតៈនោះ ហេតុនោះ កិក្ខុរូបនោះ ឈ្មោះថា ជាអ្នកទ្រទ្រង់នូវសុតៈ ។ សុតៈ មានបទតែមួយ មិនវិនាសបាត់ទៅ សូម្បីតែអក្ខរៈ ១ រមែងសន្សំទុក ហេតុនោះ សុតៈ នោះ ទើបឈ្មោះថា របស់ដែលសន្សំទុក, សុតៈ ជារបស់សន្សំទុក មាននៅ ក្នុងកិក្ខុរូបនោះ ហេតុនោះ កិក្ខុរូបនោះ ឈ្មោះថា ជាអ្នកមានសុតៈ ជាទីសន្សំទុក " ។

(១១៩) ក៏បុគ្គលណា ជាពហុស្សុត ជាអ្នកប្រកបដោយសុតៈ, បុគ្គលនោះ ព្រះសាស្តាទ្រង់ត្រាស់សរសើរហើយ ។ មែនពិត ព្រះមានព្រះភាគទ្រង់ត្រាស់ទុកហើយ ក្នុងអប្បស្សុតសូត្រ ក្នុងបឋមបណ្ណាសកៈ ចតុក្កនិបាត អង្គុត្តរនិកាយ [1] ថា ៖

" ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺ បុគ្គលមានសេចក្តីចេះដឹងតិច មិនបានប្រកបដោយការចេះដឹង ១ មានសេចក្តីចេះដឹងតិច បានប្រកបដោយការចេះដឹង ១ មានសេចក្តី

១- សុត្តន្តបិដក ភាគទី ៤២ ទំព័រទី ១៣ ។

មជ្ឈលត្តនីបនីប្រែ

ចេះដឹងច្រើន មិនបានប្រកបដោយការចេះដឹង ១ មានសេចក្តីចេះដឹងច្រើន ហើយបានប្រកបដោយការចេះដឹង ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមានសេចក្តីចេះដឹងតិច មិនបានប្រកបដោយការចេះដឹង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ព្រះពុទ្ធវចនៈ គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ មានតិច ដល់បុគ្គលពួកខ្លះ ក្នុងលោកនេះ, បុគ្គលនោះ មិនចេះអដ្ឋកថា មិនចេះបាលីនៃពុទ្ធវចនៈដែលមានប្រមាណតិចនោះ ជាអ្នកមិនប្រតិបត្តិនូវធម៌ ដ៏សមគួរដល់ធម៌, ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមានសេចក្តីចេះដឹងតិច ហើយមិនបានប្រកប ដោយការចេះដឹង យ៉ាងដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលអ្នកមានសេចក្តីចេះដឹងតិច បានប្រកបដោយការចេះដឹងតិច តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ព្រះពុទ្ធវចនៈ គឺ សុត្តៈ ។ល។ វេទល្លៈ មានតិច ដល់បុគ្គលពួកខ្លះក្នុងលោកនេះ, បុគ្គលនោះ ចេះអដ្ឋកថា ចេះបាលី នៃពុទ្ធវចនៈដែលមានប្រមាណតិចនោះ ជាអ្នកប្រតិបត្តិនូវធម៌ ដ៏សមគួរដល់ធម៌ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ឈ្មោះថា បុគ្គលអ្នកមានសេចក្តីចេះដឹងតិច បានប្រកបដោយការចេះដឹង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលអ្នកមានសេចក្តីចេះដឹងច្រើន តែមិនបាន

ពណ៌នាអំពីភាពជាអ្នកបានស្តាប់ច្រើន

ប្រកបដោយការចេះដឹង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ព្រះពុទ្ធវចនៈ គឺ សុត្តៈ គេយ្យៈ ។ល។ វេទល្លៈ មានច្រើន ដល់បុគ្គលពួកខ្លះ ក្នុងលោកនេះ, បុគ្គលនោះ មិនចេះអដ្ឋកថា មិនចេះបាលី នៃពុទ្ធវចនៈ ដែលមានប្រមាណច្រើននោះ ជាអ្នកមិនប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ឈ្មោះថា បុគ្គលអ្នកមានសេចក្តីចេះដឹងច្រើន តែមិនបានប្រកបដោយការចេះដឹង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលអ្នកមានសេចក្តីចេះដឹងច្រើន បានប្រកបដោយការចេះដឹង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ព្រះពុទ្ធវចនៈ គឺ សុត្តៈ គេយ្យៈ ។ល។ វេទល្លៈ មានច្រើន ដល់បុគ្គលពួកខ្លះ ក្នុងលោកនេះ, បុគ្គលនោះ ចេះអដ្ឋកថា ចេះបាលីនៃពុទ្ធវចនៈដែលមានប្រមាណច្រើននោះ ជាអ្នកប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ឈ្មោះថា បុគ្គលអ្នកមានសេចក្តីចេះដឹងច្រើន បានប្រកបដោយការចេះដឹង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំងឡាយ ៤ ពួកនេះឯង រមែងមាននៅ ក្នុងលោក" ។

(ព្រះមានព្រះភាគ បានត្រាស់ព្រះសូត្រនោះហើយ លុះព្រះសុគត ជាសាស្តា ទ្រង់ត្រាស់ព្រះសូត្រនោះរួចហើយ ទើបទ្រង់ត្រាស់នូវគាថាពន្ធនេះ តទៅទៀតថា ៖)

មន្តលត្តនីបនីប្រែ

(១២០) បើបុគ្គលមានសេចក្តីចេះដឹងតិច [1] ទាំងមិនបានបិតនៅ ក្នុងសីលទាំងឡាយ, អ្នកប្រាជ្ញទាំងឡាយ រមែងតិះដៀលបុគ្គលនោះ ដោយហេតុទាំង ២ គឺ សីល ១ សេចក្តីចេះដឹង ១ ។ បើបុគ្គលមានសេចក្តីចេះដឹងតិច តែបិតនៅខ្ជាប់ខ្ជួន ក្នុងសីលទាំងឡាយ, អ្នកប្រាជ្ញទាំងឡាយ រមែងសរសើរនូវបុគ្គលនោះ តែដោយសីល, ប៉ុន្តែ សេចក្តីចេះដឹង មិនបានសម្រេច ដល់បុគ្គលនោះទេ ។ បើបុគ្គលមានសេចក្តីចេះដឹងច្រើន តែមិនបិតនៅខ្ជាប់ខ្ជួន ក្នុងសីលទាំងឡាយទេ, អ្នកប្រាជ្ញទាំងឡាយ រមែងតិះដៀលបុគ្គលនោះ ដោយសីល, ប៉ុន្តែ សេចក្តីចេះដឹង រមែងសម្រេច ដល់បុគ្គលនោះ ។ បើបុគ្គលមានសេចក្តីចេះដឹងច្រើន ទាំងបិតនៅខ្ជាប់ខ្ជួន ក្នុងសីលទាំងឡាយ, អ្នកប្រាជ្ញទាំងឡាយ តែងសរសើរបុគ្គលនោះ ដោយហេតុទាំង ២ គឺសីល ១ សេចក្តីចេះដឹង ១ ។ អ្នកណា គួរនិន្ទាបុគ្គលអ្នកមានសេចក្តីចេះដឹងច្រើន ទ្រទ្រង់នូវព្រះធម៌ មានបញ្ញា ជាពុទ្ធសាវ័កនោះ ដែលដួចជាដុំ នៃមាសជម្ពូនទបាន, ស្មើដោយទេវតា និង មនុស្សទាំង

១- សុត្តន្តបិដក ភាគទី ៤២ ទំព័រទី ១៦ ។

ពណ៌នាអំពីភាពជាអ្នកបានស្តាប់ច្រើន

ឡាយ ក៏រមែងសរសើរ នូវបុគ្គលនោះ, សូម្បីព្រហ្ម ក៏សរសើរដែរ ។

*អដ្ឋកថា នៃអប្បស្សុតសូត្រនោះ ថា បណ្តាបទទាំងនោះ បទថា "**អនុបបន្នោ**" ប្រែថា មិនចូលទៅជិតហើយ ។*

*ដីកា នៃអប្បស្សុតសូត្រនោះថា ២ បទថា "**អប្បកំ សុតំ**" មានសេចក្តីថា បណ្តាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ដែលប្រកបដោយអង្គ ៩ អង្គណា មួយដ៏ដោយ ចាត់ជាសុតៈ ទាំងអស់ ដើម្បីនឹងទ្រង់សំដែងនូវអង្គ ៩ នេះនោះ ទើបព្រះអង្គទ្រង់ត្រាស់ថា "**សុត្តៈ គេយ្យៈ**" ជាដូច្នេះជាដើម ។*

*នយដែលមក ក្នុងអដ្ឋកថា នៃសូត្រនោះ ថា ច្រើនបទថា "**អត្តមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ**" មានសេចក្តីថា ជាអ្នកចេះដឹងអដ្ឋកថា និង ពាលីហើយ ប្រតិបត្តិនូវបដិបទា ដែលជាចំណែកខាងដើម ព្រមទាំងសីល ដែលសមគួរ ដល់លោកុត្តរធម៌ ៩ ប្រការ ។ បណ្តាបុគ្គល ៤ ពួកនោះ បុគ្គលពួកទី ១ គឺព្រះមានព្រះភាគទ្រង់ត្រាស់ សំដៅយក អ្នកមានកិរិយាស្តាប់តិច និង ជាអ្នកទ្រុស្តសីល, ពួក ទី ២ ជាអ្នកមានកិរិយាស្តាប់តិច តែ ជាព្រះខីណាស្រព, ពួក ទី ៣ ជាអ្នកមានកិរិយាស្តាប់ច្រើន (តែ) ជាអ្នកទ្រុស្តសីល, ពួក ទី ៤ ជាអ្នកមានកិរិយា*

ស្តាប់ច្រើនផង ជាព្រះខីណាស្រពផង " ។

អដ្ឋកថា នៃសូត្រនោះថា បទថា " ***អសមាហិតោ*** " គឺ ជាអ្នកមិនធ្វើឲ្យបរិបូណ៌ ។ បាទគាថាថា " ***សីលតោ ច សុតេន ច*** " គឺ ទាំងផ្នែកសីល ទាំងផ្នែកសុតៈ ។ អធិប្បាយថា បណ្ឌិតទាំងឡាយ តែងតិះដៀលបុគ្គលនោះ យ៉ាងនេះថា " បុគ្គលនេះ ជាអ្នកទ្រុស្តសីល និង មានការស្តាប់តិច " ។ បាទគាថា ថា " ***តស្ស សម្បជ្ជតេ សុតំ*** " មានសេចក្តីថា កិច្ច គឺសុតៈ គឺ បុគ្គលនោះ ធ្វើហើយ ដោយសុតៈនោះ ព្រោះហេតុណា, ព្រោះហេតុនោះ សុតៈ ឈ្មោះថា រមែងសម្រេច ដល់បុគ្គលនោះ ។ ២ បទថា " ***នាស្ស សម្បជ្ជតេ*** " មានសេចក្តីថា ព្រោះបុគ្គលនោះ មិនបានធ្វើកិច្ច គឺសុតៈ ទើបសុតៈ មិនបានសម្រេច ។ បទថា " ***ធម្មធរំ*** " បានដល់ ជាអ្នកទ្រទ្រង់នូវព្រះធម៌ គឺសុតៈ ។ បទថា " ***សប្បញ្ញំ*** " គឺ អ្នកមានបញ្ញាល្អ ។ បាទគាថា ថា " ***និក្ខំ ជម្ពូនទស្សេវ*** " មានសេចក្តីថា មាសតាមធម្មជាតិ លោកហៅថា មាសជម្ពូនទ, ប្រៀបដូចជាដុំ នៃមានជម្ពូនទនោះ, អធិប្បាយថា ដូចជាផែននៃមាស ដែលមានប្រមាណបញ្ចសុវណ្ណ (១ និក្ខៈ) យ៉ាងដូច្នេះ " ។

(១២១) សូម្បីព្រះអានន្ទត្ថេរ អាស្រ័យនូវភាវៈនៃខ្លួនជា

ពណ៌នាអំពីភាពជាអ្នកបានស្តាប់ច្រើន

អ្នកមានកិរិយាស្តាប់ច្រើន ទើបដល់នូវភាពជាអ្នក គឺព្រះសាស្តាទ្រង់ត្រាស់សរសើរថា “ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុអ្នកមានកិរិយាស្តាប់ច្រើន ដែលជាសាវក របស់តថាគត ស្រេចតែនឹងព្រះអានន្ទ ជាអ្នកប្រសើរជាងគេ ” ។ មួយទៀត ភិក្ខុ ដែលជាពហុស្សូត រមែងជាអ្នកមានលាភកើតឡើង ដោយមិនលំបាក ។

ក្នុងដំណើរនោះ មានរឿងនេះ (ជាឧទាហរណ៍) ៖

(រឿង ព្រាហ្មណ៍បូជាភិក្ខុជាពហុស្សូត)

បានឮថា ព្រាហ្មណ៍ម្នាក់ គិតថា “ ការបូជាព្រះពុទ្ធរតនៈនិង ព្រះសង្ឃរតនៈ រមែងប្រាកដ, ព្រះធម្មរតនៈ នឹងបានឈ្មោះថា គឺអាត្មាអញ បូជាហើយ យ៉ាងដូចម្តេចទៅហ្ន៎ ” ដូច្នេះហើយ ទើបចូលទៅគាល់ព្រះសាស្តា ក្រាបទូលសួរនូវសេចក្តីនោះ ។

ព្រះសាស្តា. ម្នាលព្រាហ្មណ៍ បើអ្នកប្រាថ្នា ដើម្បីនឹងបូជាព្រះធម្មរតនៈ ចូរអ្នកបូជានូវភិក្ខុជាពហុស្សូត ១ រូបចុះ ។

ព្រាហ្មណ៍. បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គ ទ្រង់ត្រាស់ប្រាប់នូវភិក្ខុជាពហុស្សូតឲ្យទានផង ។

ព្រះសាស្តា. ចូរអ្នកសួរនូវព្រះភិក្ខុសង្ឃចុះ ។

ព្រាហ្មណ៍នោះ បានចូលទៅរកព្រះភិក្ខុសង្ឃហើយ សួរថា “ បពិត្រព្រះគុណម្ចាស់ដ៏ចំរើនទាំងឡាយ សូមព្រះគុណម្ចាស់

មេត្តាច្រាប់ នូវភិក្ខុដែលជាពហុស្សុតផង ” ។

ភិក្ខុទាំងឡាយ. នៃព្រាហ្មណ៍ ព្រះអានន្ទត្ថេរជាពហុស្សុត។

ព្រាហ្មណ៍ បានបូជាព្រះថេរៈ ដោយចីវរដែលមានតម្លៃមួយពាន់ ។

រឿងនេះ មកក្នុងអដ្ឋកថាមហាគោសិង្គសាលសូត្រ ។

(១២២) ពាហុសច្ចៈ របស់ពហុស្សុតបុគ្គល ឈ្មោះថា **ជាមង្គល** ព្រោះជាហេតុនៃឥដ្ឋផល មានការសរសើរជាដើម និងបានឈ្មោះថា ជាមង្គល សូម្បីព្រោះហេតុនៃការលះ នូវអកុសល និងបានសម្រេចនូវកុសល ដោយប្រការដូច្នេះឯង ។ សមដូចជាព្រះតម្រាស់ ដែលព្រះមានព្រះភាគ ទ្រង់បានត្រាស់ហើយ ក្នុងនគរោបមសូត្រ ក្នុងទុតិយវគ្គ នៃទុតិយបណ្ណាសកៈ ក្នុងសត្តក-និបាត អង្គុត្តរនិកាយ យ៉ាងដូច្នេះ ថា “ ម្នាលភិក្ខុទាំងឡាយ ក៏ព្រះអរិយសាវ័ក អ្នកបានស្តាប់ហើយនុ៎ះឯង រមែងលះបង់ នូវអកុសលបាន ចំរើនកុសល ឲ្យកើតមានឡើង, រមែងលះបង់នូវកម្មដែលមានទោស ចំរើនកម្មដែលគ្មានទោស ឲ្យកើតឡើង រមែងបរិហារខ្លួន ឲ្យបានបរិសុទ្ធ ” ។

(១២៣) អដ្ឋកថា នៃសូត្រទីមួយ នៃសូត្រទាំងពួង ក្នុងទុក្កនិបាត អង្គុត្តរនិកាយថា បណ្តាពាក្យទាំងនោះ ក្នុងពាក្យថា

ពណ៌នាអំពីភាពជាអ្នកបានស្តាប់ច្រើន

" ***សុទ្ធមត្តានំ បរិហារតិ*** " នេះ សេចក្តីបរិសុទ្ធិ មាន ២ យ៉ាង គឺ ដោយបរិយាយ ១ ដោយនិបរិយាយ ១ ។ ក៏ព្រះអរិយសាវ័ក បរិហារខ្លួន ដោយសរណគមន៍ ឈ្មោះថា បរិហារខ្លួន ឲ្យបរិសុទ្ធ ដោយបរិយាយ ។ សូម្បីបរិហារខ្លួន ដោយសីល ៥ សីល ១០ ចតុប្បារិសុទ្ធិសីល បឋមមជ្ឈាន ។ល។ នេវសញ្ញានាសញ្ញាយតនៈ សោតាបត្តិមគ្គ សោតាបត្តិផល ។ល។ អរហត្តមគ្គ ក៏ឈ្មោះថា បរិហារខ្លួន ឲ្យបរិសុទ្ធ ដោយបរិយាយ ដូចគ្នាដែរ ។ ចំណែកខាង ព្រះអរិយបុគ្គល ដែលឋិតនៅ ក្នុងអរហត្តផល ជាព្រះខីណាស្រព កាលញុំាងបញ្ចក្ខន្ធ ដែលមានមូលកាត់ផ្តាច់ហើយ ឲ្យងូតក្តី ឲ្យទំពាសុីក្តី ឲ្យអង្គុយក្តី ឲ្យដេកក្តី បណ្ឌិតគប្បីជ្រាបថា រមែងបរិហារ គឺ ប្រតិបត្តិខ្លួន ឲ្យបរិសុទ្ធ គឺ ឲ្យអស់មន្ទិល ដោយនិបរិយាយ មែនពិត ដូច្នេះ " ។

ជីកា នៃបឋមសូត្រនោះថា បទថា " ***ឆិន្នមូលកេ*** " បានដល់ ឈ្មោះថា មានមូលបានកាត់ផ្តាច់ហើយ ព្រោះមូលគឺតណ្ហា គឺលោកបានជីករំលើងអស់ហើយ ។

អដ្ឋកថា នៃអធិប្បតេយ្យសូត្រ ក្នុងចតុត្ថវគ្គបឋមបណ្ណាសក: ក្នុងតិកនិបាត អង្គុត្តរនិកាយថា អធិប្បាយថា ភិក្ខុ បរិហារ គឺ ប្រតិបត្តិ គ្រប់គ្រងខ្លួន ធ្វើឲ្យបរិសុទ្ធ គឺឲ្យអស់មន្ទិល ។

មង្គលត្ថទីបនីប្រែ

ក៏ភិក្ខុ រូបនេះ បរិហារខ្លួន ឲ្យបរិសុទ្ធ ដោយអរហត្តមគ្គ ឈ្មោះថា រមែងបរិហារខ្លួនឲ្យបរិសុទ្ធ ដោយបរិយាយ, ចំណែកព្រះអរិយបុគ្គល ដែលបានសម្រេចផលហើយ ទើបឈ្មោះថា រមែងបរិហារខ្លួន ឲ្យបរិសុទ្ធ ដោយនិបរិយាយ ។

ជីកា នៃអធិប្បតេយ្យសូត្រនោះ ថា ២ បទថា " **និម្មលំ កត្វា** " មានសេចក្តីថា ធ្វើឲ្យប្រាសចាកមន្ទិល ព្រោះកំចាត់បង់នូវមន្ទិលទាំងឡាយ មានរាគៈ ជាដើម ។ បទថា " **គោបយតិ** " ប្រែថា រមែងរក្សាចាកអនត្ថៈ គឺសង្កិលេស ។ បទថា " **អយំ** " ជាដើម មានសេចក្តីថា ភិក្ខុអ្នកប្រតិបត្តិបានយ៉ាងដូច្នេះ ឈ្មោះថា បរិហារខ្លួន ឲ្យបរិសុទ្ធ ព្រោះមិនមានសូម្បីកិលេស ដែលជាហេតុមិនបរិសុទ្ធ ។

លោក មិនបានពណ៌នាពាក្យអ្វីមួយទៀយ ក្នុងអដ្ឋកថា និង ជីកា នៃនគរោបមសូត្រ ព្រោះលោកបានពណ៌នាទុកហើយ ឮជ៏ខាងដើម យ៉ាងដូច្នេះឯង ។

(១២៤) មួយទៀត ពាហុសច្ចៈ ឈ្មោះថា ជាមង្គល ព្រោះជាហេតុ នៃការធ្វើឲ្យជាក់ច្បាស់បរមត្ថសច្ចៈ ដោយលំដាប់មែនពិត ។ សមដូចជាព្រះតម្រាស់ ដែលព្រះមានព្រះភាគ កាលនឹងទ្រង់សំដែងនូវធម៌ ដល់ព្រាហ្មណ៍ ឈ្មោះថា ភារទ្វាជៈ ទ្រង់

គ្រាស់ទុកហើយ ថា " កុលបុត្រ ដែលកើតសេចក្តីជ្រះថ្លាហើយ រមែងចូលទៅរក, លុះចូលទៅរកហើយ រមែងអង្គុយជិត, កាលអង្គុយជិត រមែងផ្អៀងនូវត្រចៀកចុះ, ផ្អៀងត្រចៀកចុះហើយ រមែងស្តាប់នូវធម៌, លុះស្តាប់ហើយ រមែងទ្រទ្រង់ចាំធម៌ទុក, រមែងពិចារណានូវសេចក្តី នៃធម៌ទាំងឡាយ ដែលបានទ្រទ្រង់ទុកហើយ, កាលបើកុលបុត្រនោះ ពិចារណានូវសេចក្តី, ធម៌ទាំងឡាយ រមែងអត់ធន់នូវការសំឡឹងរំពៃ, កាលបើមានការអត់ធន់នូវការសំឡឹងនូវធម៌, សេចក្តីពេញចិត្ត រមែងកើតឡើង, កុលបុត្រនោះ កើតសេចក្តីពេញចិត្តហើយ រមែងព្យាយាម, លុះព្យាយាមហើយ រមែងត្រិះរិះ, លុះត្រិះរិះហើយ រមែងតាំងសេចក្តីព្យាយាម, កុលបុត្រនោះ មានខ្លួនតាំងព្យាយាមហើយ រមែងធ្វើឲ្យជាក់ច្បាស់នូវបរមត្ថសច្ចៈ ដោយកាយ និង រមែងឃើញ នូវការចាក់ធ្លុះ នូវបរមត្ថសច្ចៈនោះ ដោយបញ្ញា " ។

ចប់ក្នុងចង្កីសូត្រ ក្នុងបញ្ចមវគ្គ នៃមជ្ឈិមបណ្ណាសកៈ ។

(១២៥) អដ្ឋកថានៃចង្កីសូត្រនោះថា បទថា "**បយិរុបាសតិ** " គឺអង្គុយ ក្នុងសំណាក់ ។ បទថា " **សោតំ** " បានដល់សោតប្រសាទ ។ បទថា " **ធម្មំ** " បានដល់ ទេសនាធម៌ ។ បទថា " **ធារេតិ** " គឺទ្រទ្រង់ទុក ធ្វើឲ្យស្ទាត់ជំនាញ ។ បទថា

មង្គលត្ថទីបនីប្រែ

" **ឧបបរិក្ខតិ** " បានដល់ រមែងពិចារណា ដោយអត្ថ និង ដោយហេតុការណ៍ ។ បទថា " **និជ្ឈានំ** " គឺ រមែងអត់ធន់នូវការត្រួតពិនិត្យមើល, អធិប្បាយថា ធម៌ទាំងឡាយ រមែងប្រាកដ យ៉ាងដូច្នេះថា សីល គឺព្រះមានព្រះភាគ ទ្រង់សំដែងហើយ ក្នុងទីនេះ, សមាធិ គឺព្រះអង្គទ្រង់សំដែងហើយ ក្នុងទីនេះ ដូច្នេះជាដើម ។ សេចក្តីពេញចិត្ត គឺភាពជាអ្នកប្រាថ្នា ដើម្បីនឹងធ្វើ ឈ្មោះថា ឆន្ទៈ ។ បទថា " **ឧស្សហតិ** " ប្រែថា រមែងព្យាយាម ។ បទថា " **តុលយតិ** " ប្រែថា រមែងពិចារណា ដោយអំណាចត្រៃលក្ខណ៍មាន អនិច្ចលក្ខណៈជាដើម ។ បទថា " **បទហតិ** " ប្រែថា រមែងចាប់ផ្តើមនូវសេចក្តីព្យាយាម ដែលរាប់បញ្ចូល ក្នុងមគ្គ ។ ពាក្យថា " **ការយេន ចេវ បរមត្តសច្ចំ** " មានសេចក្តីថា រមែងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដោយសហជាតនាមកាយ និង កំចាត់ចោលហើយ នូវកិលេសទាំងឡាយ រមែងឃើញព្រះនិព្វាននោះឯង ច្បាស់លាស់ គឺពិតប្រាកដ ដោយបញ្ញា ។

ជីកានៃចង្កីសូត្រនោះថា បទថា " **បយិរុបាសតិ** " គឺចូលទៅអង្គុយជិត ដោយអំណាចនៃការឧបដ្ឋាក ។ ព្រះអដ្ឋកថាចារ្យពោលថា បទថា " **សោតំ** " បានដល់ សោតប្រសាទ ដូច្នេះដោយប្រាថ្នាថា ក៏សោតប្រសាទនោះ គឺបុគ្គលគប្បីផ្អៀងចុះដើម្បី

ពណ៌នាអំពីភាពជាអ្នកបានស្តាប់ច្រើន

ស្តាប់ ។ បទថា "**ជានតិ**" គឺទ្រទ្រង់ទុកដោយហេឫទ័យ បានដល់រមែងតាំងធម៌នោះទុក ក្នុងហេឫទ័យនោះ ។ បទថា " **អត្ថតោ** " គឺ ដោយសេចក្តីនៃធម៌ តាមដែលបានទ្រទ្រង់ហើយ ។ បទថា "**ការណាតោ**" បានដល់ ដោយសមគួរ គឺដោយហេតុ ឧទាហរណ៍ ដោយគួរ ។ បទថា " **ឧភយោកនំ** " មានសេចក្តីថា ធម៌ទាំងឡាយរមែងអត់ធន់ គឺ អត់ទ្រាំបាន នូវភាវៈជាធម៌ ដែលបុគ្គលគប្បីយល់បាន ដោយបញ្ញាចក្ខុ តាមសេចក្តីពិតថា ខន្ធ យ៉ាងដូច្នេះឯង ។ កិរិយាអត់ធន់នោះ ក៏គឺកិរិយាដែលសេចក្តីជ្រាកដ ក្នុងចិត្ត ព្រោះបានសម្រេច ដូចជាព្រុយនៃត្រីក្រោយដូច្នោះ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលពាក្យថា **ឥធ** ដូច្នេះ ជាដើម ។ សេចក្តីពេញចិត្ត ក្នុងកុសល ពោលគឺភាពជាអ្នកជ្រាថ្នា ដើម្បីធ្វើ ឈ្មោះថាឆន្ទៈ ភាពជាអ្នកជ្រាថ្នានឹងធ្វើ ។ បទថា "**វាយមតិ**" គឺ រមែងធ្វើនូវសេចក្តីព្យាយាម គឺ សេចក្តីប្រឹងប្រែង ដោយអំណាចញុំាងសេចក្តីបរិសុទ្ធិទាំងឡាយ ៤ យ៉ាង ខាងដើម ឲ្យបានដល់ព្រម ។ បទថា "**មគ្គប្បជានំ**" មានសេចក្តីថា រមែងតាំងសេចក្តីព្យាយាមត្រូវ ៤ យ៉ាង ដែលនាំមកនូវមគ្គ គឺដែលរាប់បញ្ចូលក្នុងមគ្គ បានដល់ រមែងញុំាងសេចក្តីព្យាយាមត្រូវ ៤ យ៉ាងនោះ ឲ្យបរិបូណ៌ ដោយអំណាចនៃការតាំងសេចក្តីព្យាយាម ។ បទថា

មង្គលត្ថទីបនីប្រែ

" ***បរមត្ថសច្ចំ*** " បានដល់ សច្ចៈ ឈ្មោះថា បរមត្ថ ព្រោះជាធម៌ដែលមិនទទេ ។ បទថា "***សហជាតនាមកាយេន***" មានសេចក្តីថា បញ្ញា ណា ញុំាងព្រះនិព្វាន ឲ្យដល់ព្រម ដោយសហជាតនាមកាយ, បញ្ញា នោះ កាលធ្វើនូវព្រះនិព្វាន ដែលខ្លួនកំពុងធ្វើ ដោយសហជាតនាមកាយនោះឯង ឲ្យជាក់ច្បាស់ គឺ ឲ្យប្រាកដច្បាស់ ឈ្មោះថា ឃើញ គឺ ធ្វើឲ្យប្រត្យក្ស ដោយសច្ឆិកិរិយាភិសមយ ។

(១២៦) ភាពជាអ្នកឈ្លាសវៃ នៃពួកគ្រហស្ថ ដែលកើតខ្លឹង ព្រោះស្តាប់ ឬក៏ រៀននូវសិល្បៈខាងក្រៅ ឈ្មោះថា ពាហុសច្ចៈ របស់គ្រហស្ថ ។ សូម្បីក្នុងពាហុសច្ចៈ របស់គ្រហស្ថនោះ ពាហុសច្ចៈណា មិនមានទោស, ពាហុសច្ចៈនោះ ឈ្មោះថា ជាមង្គល ព្រោះជាហេតុនាំប្រយោជន៍សុខមកឲ្យ ក្នុងលោកទាំង ២ ។

ក្នុងដំណើរនោះ មានរឿងនេះ (ជាឧទាហរណ៍) ៖

(រឿង សេនកបណ្ឌិត)

ក្នុងអតីតកាល ព្រះពោធិសត្វកើតជាព្រាហ្មណ៍ ឈ្មោះថា សេនកៈ ក្នុងទីក្រុងពារាណសី បានរៀនសិល្បសាស្ត្រគ្រប់បែបយ៉ាង ក្នុងទីក្រុងតក្កសីលា ចប់ស្រេចហើយ ក៏បានវិលត្រឡប់មកទីក្រុងពារាណសីវិញ ។

ពណ៌នាអំពីភាពជាអ្នកបានស្តាប់ច្រើន

ក្នុងកាលនោះ ព្រះរាជាក្រុងពារាណសីទ្រង់ព្រះនាមជនក: ទ្រង់បានព្រះរាជទានដំណែង ជាអមាត្យ ព្រមទាំងយសស័ក្តិ ដ៏ធំ ដល់ព្រះពោធិសត្វនោះ ។ ព្រះពោធិសត្វនោះ ជាអមាត្យអ្នក បង្រៀនអត្ថ: និង ធម៌របស់ព្រះរាជា ក្នុងថ្ងៃនៃបក្សទាំងឡាយ បាន អង្គុយសំដែងធម៌ ដោយពុទ្ធលីលា លើធម្មាសន: ដែលបុគ្គល តាក់តែងទុកហើយ លើធម្មសភា ដែលព្រះរាជាជាដើម ទ្រង់ ត្រៀមទុកហើយ ។

គ្រានោះ ព្រាហ្មណ៍ចាស់ម្នាក់ ដើរសុំទ្រព្យគេ បាន ១ ពាន់ កហាបណ: យកទៅផ្ទើរទុក ក្នុងត្រកូលព្រាហ្មណ៍មួយហើយ ក៏បានដើរទៅរកសុំគេទៀត ។ ត្រកូលព្រាហ្មណ៍នោះ ក៏បានដើរ ទៅរកសុំគេទៀត ។ ត្រកូលព្រាហ្មណ៍នោះ បានប្រើប្រាស់ កហាបណ:អស់ហើយ, កាលបើព្រាហ្មណ៍ចាស់នោះ ត្រឡប់ មកវិញ, ក៏មិនអាចសងវិញបាន ទើបបានលើកកូនក្រមុំ របស់ ខ្លួន ធ្វើជាបាទបរិចារិកា ដល់ព្រាហ្មណ៍ចាស់នោះ ។ គាត់ ក៏បាន នាំយកនាងទៅ អាស្រ័យនៅ ក្នុងស្រុកព្រាហ្មណ៍ ក្បែរទីក្រុង ពារាណសី ។ ចំណែក នាងព្រាហ្មណីនោះ មិនឆ្អែតឆ្អន់ ដោយ មេថុនធម្ម ព្រោះនាងនៅវ័យក្មេងខ្ចី ទើបប្រព្រឹត្តមិច្ឆាចារ ជាមួយ នឹងព្រាហ្មណ៍កំលោះម្នាក់ គិតថា “ដោយឧបាយយ៉ាងនេះ អញ

មង្គលត្ថទីបនីប្រែ

នីងជាអ្នកមិនមានភ័យ ធ្វើ (អ្វីមួយស្រេចតែនីងក្បាលចិត្ត)" ដូច្នេះ ហើយ ថ្ងៃមួយ ក៏បាននិយាយនីងព្រាហ្មណ៍ ដូច្នេះថា " ម្នាល ព្រាហ្មណ៍ នាងខ្ញុំមិនអាចធ្វើកិច្ចការងារ ក្នុងផ្ទះ របស់អ្នកបាន ឡើយ, ចូរអ្នកយកទ្រព្យដែលសុំគេបានមក នាំយកទាសាឬទាសី មកឲ្យនាងខ្ញុំ ចុះ " ។ ព្រាហ្មណ៍នោះ ធ្លាក់ក្នុងអំណាច របស់នាង ព្រាហ្មណីនោះ ទើបពោលថា "ប្រពៃហើយ" ដូច្នេះហើយ បាន ស្តាយស្បោងស្បែក ដែលពេញដោយសជូវ ត្រាច់ទៅ ក្នុងទីទាំង ឡាយ មានស្រុក និងនិគមជាដើម បាននូវទ្រព្យ ៧៧ កហាបណៈ ហើយ ទើបត្រឡប់មកវិញ អង្គុយបរិភោគសជូវ ក្រោមដើមឈើ ដែលមានប្រហោងមួយដើម ត្រង់ចន្លោះផ្លូវ មិនបានចងមាត់ស្បោង ក៏ស្រាប់តែចុះទៅផឹកទឹក ។

ក្នុងគ្រានោះ ពស់វែកជំបូក ក្នុងដើមឈើ ដែលមានរន្ធ មួយ បានវារមកចូលស្បោង ដោយក្លិននៃសជូវ ហើយបានដេក វៀនស៊ីនូវសជូវ ។ ព្រាហ្មណ៍មកហើយ មិនទាន់បានត្រួចមើល ខាងក្នុងផង ក៏បានចងមាត់ស្បោងស្តាយដើរចេញទៅ បានស្តាប់ ពាក្យរបស់រុក្ខទេវតា ១ អង្គ ប្រាប់ថា " ម្នាលព្រាហ្មណ៍ ថ្ងៃនេះ បើអ្នកនីងសំណាក់នៅតាមផ្លូវ, ខ្លួនអ្នកឯង នីងត្រូវស្លាប់, តែថ្ងៃ នេះ បើអ្នកនីងទៅដល់ផ្ទះ, ភរិយា របស់អ្នក ក៏នីងត្រូវស្លាប់ "

ពណ៌នាអំពីភាពជាអ្នកបានស្តាប់ច្រើន

ដូច្នេះហើយ ទើបតក់ស្លុតចំពោះមរណភ័យ ស្រែកទួញយំ បានធ្វើដំណើរទៅដល់មាត់ទ្វារក្រុងពារាណសីហើយ ។ ក្នុងពេលនោះជាថ្ងៃឧបោសថ ទី ១៥ ។ មនុស្សទាំងឡាយ យកគ្រឿងក្រអូប និងផ្កាកម្រងជាដើម ទៅស្តាប់ធម៌ព្រះពោធិសត្វ ។ ព្រាហ្មណ៍នោះ ឃើញមនុស្សទាំងនោះហើយ ក៏សួរ បានដឹងសេចក្តីនោះហើយ ទើបគិតថា " បានឮថា សេនកបណ្ឌិត ជាអ្នកសំដែងធម៌, លោកនឹងសំដែងធម៌ណាមួយ កំចាត់នូវសេចក្តីសោក របស់អញបាន, ការដែលអញទៅ ក្នុងទីនោះ ស្តាប់ធម៌ ទើបសមគួរណាស់" ហើយ ក៏បានទៅជាមួយមនុស្សទាំងនោះ បានឈរស្រែកយំ នៅត្រង់ទីបំផុតនៃបរិស័ទ មានស្បោងសដូវដែលជាប់នៅលើ-ក ។

ព្រះពោធិសត្វឃើញព្រាហ្មណ៍នោះហើយគិតថា "សេចក្តីសោកសៅ ដែលអាចឲ្យកើតទឹកភ្នែក ឮដ៏ខាងក្នុងព្រាហ្មណ៍នោះ គង់នឹងមានពិត " ហើយបានសួរពីហេតុនៃសេចក្តីសោកនោះ ។

ព្រាហ្មណ៍នោះ បានប្រាប់ពាក្យដែលទេវតាប្រាប់ហើយ សួរថា " ខ្ញុំបាទ បានឮពាក្យនេះហើយ ទើបសោកសៅ, ម្នាលបណ្ឌិត អ្វីហ្ន៎ ជាហេតុនៃសេចក្តីស្លាប់របស់ខ្ញុំបាទ និង ភរិយា " ។

ព្រះពោធិសត្វ កាលពិចារណាមើល ក៏បានដឹងហេតុ-ការណ៍ទាំងអស់ ដោយញាណ គឺភាពជាអ្នកឈ្លាសវៃ ក្នុងឧបាយ

របស់ខ្លួនបានតែម្តង ដូចឃើញដោយភ្នែកទិព្វ ហើយបានសួរ ថា “ម្នាលព្រាហ្មណ៍ ក្នុងស្បោងរបស់អ្នកនុ៎ះ មានសជ្ជុវខ្លះឬទេ” ។

ព្រាហ្មណ៍ . បពិត្រលោកបណ្ឌិត មាន ។

សេនកៈ . ក្នុងពេលបរិភោគអាហារព្រឹក ថ្ងៃនេះ តើអ្នកបរិភោគសជ្ជុវ នៅទីណា ។

ព្រាហ្មណ៍ . ក្រោមគល់ឈើ ក្នុងព្រៃ ។

សេនកៈ . អ្នកបរិភោគសជ្ជុវហើយ កាលចុះទៅផឹកទឹក តើបានចងមាត់ស្បោងដែរឬទេ ។

ព្រាហ្មណ៍ . ខ្ញុំបាទ មិនបានចងទេ ។

សេនកបណ្ឌិត ប្រាប់ថា “បើដូច្នោះ ខ្ញុំយល់ថា ក្នុងពេលដែលអ្នកចុះទៅផឹកទឹក ពស់វែកជំពូកមួយ បានវារចូលស្បោង ព្រោះក្លិននៃសជ្ជុវ ដូច្នេះ, បើថ្ងៃនេះ អ្នកនឹងឈប់សម្រាកនៅតាមផ្លូវ អ្នកបរិភោគសជ្ជុវ ក្នុងពេលល្ងាច នឹងលូកដៃចូលទៅ ក្នុងស្បោង, កាលបើដូច្នេះ អ្នកនឹងត្រូវពស់ខាំដៃស្លាប់, នេះ គឺជាហេតុនៃសេចក្តីស្លាប់របស់អ្នក, បើអ្នកនឹងទៅដល់ផ្ទះ ក្នុងថ្ងៃនេះ ប្រពន្ធរបស់អ្នកនឹងលូកដៃចូលទៅ ក្នុងស្បោង ដើម្បីយកទ្រព្យ, កាលបើដូច្នេះ ប្រពន្ធរបស់អ្នកនោះ នឹងត្រូវពស់ខាំដៃស្លាប់, នេះ គឺជាហេតុ នៃសេចក្តីស្លាប់ របស់ប្រពន្ធ របស់អ្នកនោះ, ទេវតា

ពណ៌នាអំពីភាពជាអ្នកបានស្តាប់ច្រើន

បានពោល យ៉ាងដូច្នោះ គឺសំដៅយកហេតុ នៃសេចក្តីស្ងាប់នេះ, ព្រោះហេតុនោះ ចូរអ្នកទម្លាក់ស្បែងនោះ ដាក់ត្រង់កណ្តាលបរិស័ទ ស្រាយមាត់ស្បែងចេញហើយ ចៀសចេញទៅ ឈរយកដំបងគោះស្បែង " ។ ព្រាហ្មណ៍ ក៏បានធ្វើ យ៉ាងដូច្នោះ ។ ពស់ដកពពារ ឲ្យសំឡេង " សុ ៗ " បានវារចេញមកហើយ ។

គ្រានោះ គ្រូពស់ម្នាក់ បានចាប់ពស់នោះ យកទៅលែងចោល ក្នុងព្រៃហើយ ។ មនុស្សទាំងឡាយ រីករាយសប្បាយចិត្ត ថា " សេនកបណ្ឌិតនេះ រមែងព្យាករ ដូចជាព្រះសព្វញ្ញុពុទ្ធ " ហើយក៏នាំគ្នា ញុំាងសែននៃការលើកផ្ទាំងបដា សែននៃការទះដៃនិង សែននៃការឲ្យសាធុការ ឲ្យប្រព្រឹត្តទៅហើយ ។ សំឡេងឲ្យសាធុការ កើតដូចជាសំឡេងនៃការរបើកមហាប្រឹថពី, ភ្លៀងរតន: ៧ ប្រការ បានធ្លាក់មក ដូចជាភ្លៀងធ្លាក់ព្រិល ដើម្បីបូជា ចំពោះព្រះពោធិសត្វ ។ ចំណែកព្រាហ្មណ៍ក៏បានបូជាព្រះពោធិសត្វនោះ ដោយកហាបណ: ដែលខ្លួនបានមកហើយ ។ ព្រះពោធិសត្វ មិនបានទទួលយកហាបណ:ទាំងនោះទេ ត្រឡប់ជាបន្ថែមឲ្យ ៣០០ កហាបណ:ទៀត ដល់ព្រាហ្មណ៍ ដើម្បីគម្រប់ ១ ពាន់ ហើយសួរថា " តើអ្នកណា បញ្ជូនអ្នកទៅ ដើម្បីសុំទ្រព្យ " ។

ព្រាហ្មណ៍ . បពិត្រលោកបណ្ឌិត ករិយា របស់ខ្ញុំបាទ ។

មង្គលត្ថទីបនីប្រែ

សេនកៈ . កវិយា របស់អ្នកនោះ តើចាស់ ឬ ក្មេង ។

ព្រាហ្មណ៍. បពិត្រលោកបណ្ឌិត នាងជាស្រីវ័យក្មេង ។

ព្រះពោធិសត្វ បានពន្យល់ថា " បើដូច្នោះ កវិយា របស់អ្នកនោះ គង់ធ្វើទូវមិច្ឆាចារ ជាមួយនឹងបុរសដទៃ ទើបបានបញ្ជូនអ្នកទៅ, ក៏បើអ្នក នឹងនាំយកកហាបណៈទាំងនេះ ទៅផ្ទះ, កវិយា របស់អ្នកនោះ នឹងឲ្យដល់ប្រុសជាសាហាយ, ព្រោះហេតុនោះ អ្នកគប្បីលាក់ទុកនៅកន្លែងណាមួយ ខាងក្រៅផ្ទះសិនហើយ សឹមចូលទៅផ្ទះ " ហើយក៏បានបញ្ជូនព្រាហ្មណ៍នោះទៅ ។ ព្រាហ្មណ៍នោះ បានធ្វើយ៉ាងដូច្នោះហើយ បានឈរនៅ ក្បែរមាត់ទ្វារផ្ទះ ស្រែកហៅថា " នែនាងដ៏ចំរើន " ។

ក្នុងខណៈនោះ ឯកវិយានោះ អង្គុយជាមួយនឹង ប្រុសជាសហាយ បានឮសំឡេងស្វាមីនោះ ក៏ពន្លត់ប្រទីប បិទទ្វារ, កាលបើស្វាមីនោះ ចូលទៅ (ក្នុងផ្ទះ), ក៏នាំប្រុសសហាយ ចេញទៅឈរនៅ ក្បែរទ្វារហើយ បានចូលទៅកាន់ផ្ទះ សួរថា "តើបង់បានអ្វីមកខ្លះ" ។ ព្រាហ្មណ៍នោះប្រាប់ថា "បង់បានទ្រព្យ ១ ពាន់ បង់ទុក ក្នុងទីឯណោះ" ។ កវិយានោះ បានទៅប្រាប់ប្រុសសហាយ ។ ប្រុសសហាយនោះ ក៏បានទៅយកទ្រព្យនោះ រត់ចេញទៅបាត់ ។

លុះថ្ងៃស្អែកឡើង ព្រាហ្មណ៍ មិនឃើញទ្រព្យនោះ ទើប

ពណ៌នាអំពីតាពជាអ្នកបានស្គាប់ច្រើន

ចូលទៅរកព្រះពោធិសត្វ (ច្រាប់រឿងវ៉ាវអស់) ហើយ ។ ព្រះពោធិសត្វ ដឹងសេចក្តីនោះហើយ បានឲ្យស្បៀង ដល់ព្រាហ្មណ៍នោះ ល្មមនឹងគ្រប់ ៧ ថ្ងៃ ហើយបានច្រាប់ថា " ក្នុងថ្ងៃដំបូង ចូរអ្នកអញ្ជើញព្រាហ្មណ៍ ១៤ នាក់ មកជប់លៀង គឺ ព្រាហ្មណ៍ជាកុលុបក: របស់អ្នក ៧ នាក់, ព្រាហ្មណ៍របស់ភរិយានៃអ្នក ៧ នាក់ ចាប់តាំងអំពីថ្ងៃស្អែកឡើងទៅ ចូរជកចេញម្ខាងមួយ ៗ ក្នុងថ្ងៃទី ៧ ចូរអ្នកអញ្ជើញតែព្រាហ្មណ៍ ២ នាក់ គឺ ព្រាហ្មណ៍ របស់អ្នកម្នាក់ របស់ភរិយានៃអ្នកម្នាក់, បណ្តាព្រាហ្មណ៍ទាំង ២ នាក់នោះ កុលុបក: របស់ភរិយានៃអ្នករូបណា មកជាប់ជានិច្ច រហូត ៧ ថ្ងៃ, ចូរអ្នកច្រាប់កុលុបក: រូបនោះ ដល់យើងចុះ " ។

ព្រាហ្មណ៍នោះ បានធ្វើយ៉ាងដូច្នោះ ហើយច្រាប់ ដល់ព្រះពោធិសត្វ ។

ព្រះពោធិសត្វ បានញុំាងពួកបុរសទាំងឡាយ ឲ្យនាំយកព្រាហ្មណ៍នោះមកហើយ សួរថា " តើអ្នកបានយកទ្រព្យ ១ ពាន់ កហាបណ: របស់ព្រាហ្មណ៍នេះ អំពីគល់ឈើឯណោះឬទេ " ។

ព្រាហ្មណ៍ . បពិត្រលោកបណ្ឌិត ខ្ញុំមិនបានយកទេ ។

សេនក: . ខ្ញុំ ឈ្មោះសេនកបណ្ឌិត, អ្នកមិនស្គាល់ទេឬ ។

ព្រាហ្មណ៍នោះ ភ័យហើយ ទើបច្រាប់ថា " ខ្ញុំ បាទបាននាំ

យកទៅកប់ទុក ក្នុងទីឈ្មោះនោះ” ។

ព្រះពោធិសត្វ បានប្រើពួកបុរស ឲ្យនាំយកទ្រព្យនោះមក ហើយ ឲ្យជាក់ពជអាជ្ញាជល់ព្រាហ្មណ៍ជាចោរ ឲ្យនិរទេសចេញ ពីព្រះនគរហើយ ឲ្យទ្រព្យ ១ ពាន់នោះ ព្រមទាំងយសសក្តិ ដ៏ធំ ជល់ព្រាហ្មណ៍ក្រៅពីនេះ បានឲ្យព្រាហ្មណ៍នោះ ព្រមទាំងភរិយា អាស្រ័យនៅ ក្នុងសំណាក់របស់ខ្លួនហើយ ។ ព្រះពោធិសត្វនោះ បំពេញបរមត្ថបារមី ឲ្យបរិបូណ៌ ដោយការរំដោះព្រាហ្មណ៍ ឲ្យរួច ចេញអំពីសេចក្តីទុក្ខ ដោយប្រការដូច្នេះឯង ។

ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ទុក ហើយ ក្នុងចរិយាបិដក ថា ៖

(១២៧) តថាគត កាលពិចារណាដោយបញ្ញា ទើបបាន រំដោះព្រាហ្មណ៍ ឲ្យរួចចាកសេចក្តីទុក្ខ, គុណជាតដទៃ ស្មើនឹងបញ្ញា របស់តថាគត មិនមានឡើយ, នេះ គឺជា បញ្ញាបារមី របស់តថាគត ។

សូម្បីក្នុងអដ្ឋកថាអដ្ឋសាលិនី ក៏លោកពោលទុកហើយ ថា “ ភាវៈជាបញ្ញាបារមី របស់ព្រះពោធិសត្វ អ្នកសំដែងពស់ ដែល នៅខាងក្នុងស្បោង ឈ្មោះថា ជាបរមត្ថបារមី ” ។

ក៏កិរិយាពោល ដោះស្រាយនូវបញ្ហា ប្រាកដដូច្នេះ ដោយ

ពណ៌នាអំពីភាពជាអ្នកបានស្តាប់ច្រើន

ពុទ្ធលីលា, មិនមែនជាកម្ចាំងនៃជាតិទេ មិនមែនជាកម្ចាំងនៃគោត្រ ត្រកូល, ប្រទេស, យស, សក្តិ និង ទ្រព្យឡើយ, តាមពិត គឺជាកម្ចាំងនៃបញ្ញា ។ ព្រោះថា បុរសអ្នកមានបញ្ញា ចំរើនវិបស្សនា ហើយ រមែងបើកទ្វារ គឺអរិយមគ្គ ចូរទៅកាន់នគរ គឺព្រះនិព្វាន រមែងចាក់ផ្តុំសាវ័កបារមីខ្លះ បច្ចេកពោធិញ្ញាណខ្លះ សម្មាសម្ពោធិញ្ញាណខ្លះ ។ មែនពិត បណ្តាធម៌ដែលញុំាងបុគ្គលអ្នកប្រតិបត្តិ ឲ្យបានសម្រេចព្រះនិព្វាន, បញ្ញាប៉ុណ្ណោះឯង ជាគុណជាតិប្រសើរបំផុត, ធម៌ទាំងឡាយ ដ៏សេស សុទ្ធតែជាបរិវារ របស់បញ្ញានោះ ។

ដោយហេតុនោះ សក្កឥន្ទ្រាសា ត្រូវស្តេចសក្កៈ ដែលជាស្តេច នៃទេវតា ត្រាស់សួរហើយ យ៉ាងដូច្នេះ ថា ៖

(១២៨) បណ្ឌិតទាំងឡាយ ពោលនូវសីលផង [1] សិរីផង ធម៌របស់សប្បុរសផង ប្រាជ្ញាផង (ថា) តើគុណជាតិណា ប្រសើរជាងគេបំផុត

ដូច្នេះហើយ ទើបបានពោល ថា ៖

អ្នកឈ្លាសវៃទាំងឡាយ រមែងពោលថា ប្រាជ្ញាគុំ៎ឯង ជាគុណជាតិដ៏ប្រសើរបំផុត ដ្បិតជាស្តេចនៃផ្កាយ (ព្រះបន្ទ) ដ៏ប្រសើរជាងផ្កាយទាំងឡាយ, ទុកជាសីលក្តី សិរីក្តី ធម៌របស់

១- សុត្តន្តបិដក ភាគទី ៦០ ទំព័រទី ២៣៩ ។

មង្គលត្ថទីបនីប្រែ

សប្បុរសក្តី ក៏រមែងប្រព្រឹត្តទៅ តាមបុគ្គលអ្នកមានប្រាជ្ញា ។

បណ្តាបទទាំងនោះ បទថា “ ***សីលំ*** *” បានដល់ សីល គឺ មារយាទ ។ បទថា “* ***សិរី*** *” បានដល់ ភាពជាឥស្សរៈ ។ ពាក្យ ថា “* ***បញ្ញា ហិ*** *” មានសេចក្តីថា បពិត្រស្តេចសក្កទេវរាជ បុគ្គលអ្នកឈ្លាសវៃទាំងឡាយ មានព្រះពុទ្ធជាដើម រមែងពោល ថា “ បណ្តា ធម៌ ៤ ប្រការនេះ គុណជាតិដែលឈ្មោះថា បញ្ញា នុ៎ះឯង ប្រសើរបំផុត ” ។ បទថា “* ***នក្ខត្តរាជារិវ*** *” បានដល់ ដូច ជាព្រះចន្ទដ៏ប្រសើរជាងតារាទាំងឡាយ ។ បទថា “* ***អន្វាយិកា*** *” មានសេចក្តីថា ធម៌ទាំង ៣ យ៉ាងនេះ រមែងប្រព្រឹត្តទៅតាមបុគ្គល អ្នកមានប្រាជ្ញា តែប៉ុណ្ណោះ, អធិប្បាយថា “ ជាបរិវារ របស់បញ្ញា ប៉ុណ្ណោះឯង ” ។*

សេនកបណ្ឌិត បានសម្រេចនូវប្រយោជន៍ ក្នុងលោកនេះ ពោលគឺជំណែងនៃអមាត្យ ជាដើមហើយ បានធ្វើកម្មដែលជាហេតុ នាំមកនូវប្រយោជន៍ ក្នុងលោកខាងមុខ ព្រោះការសំដែងធម៌ ដល់ មនុស្សទាំងឡាយ និង ព្រោះការរំដោះព្រាហ្មណ៍ ឲ្យរួចផុតអំពី សេចក្តីទុក្ខ ព្រោះភាពនៃខ្លួនជាពហុស្សុត ដោយប្រការដូច្នេះ ។

រឿង សេនកបណ្ឌិត មកក្នុងអដ្ឋកថាសត្តភស្តជាតក ក្នុងសត្តនិបាត ។

ពណ៌នាអំពីតាពជាអ្នកបានស្តាប់ច្រើន

សូម្បីរឿង របស់ព្រះរាជឱរស នៃព្រះបាទព្រហ្មទត្ត ដែលទ្រង់សិក្សានូវសិល្បសាស្ត្រគ្រប់យ៉ាង និង មន្តដែលជាហេតុដឹងនូវសំឡេងសត្វយំទាំងពួង ក្នុងក្រុងតក្កសីលាហើយ ទ្រង់ស្តេចយាងមកវិញ ត្រូវព្រះរាជបិតាតែងតាំងហើយ ក្នុងដំណែងឧបរាជក្រោយមក ទ្រង់បានឡើងគ្រងរាជសម្បត្តិ ទ្រង់បានបំពេញបុណ្យមានទាន ជាដើមហើយ ទ្រង់មានស្ថានសួគ៌ ប្រព្រឹត្តទៅ ខាងមុខដែលមកហើយ ក្នុងអដ្ឋកថា បវរន្តបជាតក ក្នុងសត្តកនិបាត នោះឯង ក៏គប្បីប្រមូលយកមកផងដែរ ។

ពណ៌នាអំពីតាពជាអ្នកបានស្តាប់ច្រើន ចប់ ។

❊ ❊

បានប្រែចប់សព្វគ្រប់
ថ្ងៃអាទិត្យ ៣ កើត ខែមាឃ ឆ្នាំ ច ឆស័ក ព. ស. ២៥៣៧
ថ្ងៃទី ១៣ ខែកុម្ភៈ ១៩៩៤

ពណ៌នាអំពីសិល្បៈ

(១២៩) ភាពជាអ្នកឈ្លាសវាងវៃ ក្នុងហត្ថកម្ម មាន ២ យ៉ាង ដោយអំណាចនៃសិល្បៈ របស់បព្វជិត និង គ្រហស្ថ ឈ្មោះថា សិល្បៈ ។

(សិប្បៈ របស់បព្វជិត)

បណ្តាសិល្បៈ ទាំង ២ យ៉ាងនោះ ការចាត់ចែងសមណ-បរិក្ខារ មានការពិចារណា និង ការដេរចីវរជាដើម ដែលព្រះមានព្រះភាគ ទ្រង់បានត្រាស់សំដែងហើយ ក្នុងសត្តមសូត្រ ក្នុងទុតិយវគ្គ នៃទសកនិបាត អង្គុត្តរនិកាយ យ៉ាងដូច្នេះ ថា " ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ អំពើទាំងឡាយណា ដែលខ្ពស់ និង ទាប ដែលពួកសព្រហ្មចារីបុគ្គលត្រូវសួរគ្នីគ្នា ហើយទើបធ្វើ, ភិក្ខុជាអ្នកឈ្លាសវៃ មិនខ្វិលច្រអូស ក្នុងអំពើនោះ ប្រកបព្រមដោយបញ្ញា ជាគ្រឿងពិចារណា ដោយឧបាយ ក្នុងអំពើនោះ ថាគួរធ្វើ គួរចាត់ចែងបាន, ម្នាលភិក្ខុទាំងឡាយ អំពើទាំងឡាយណា ដែលខ្ពស់ និង ទាប ដែលពួកសព្រហ្មចារីបុគ្គល ត្រូវសួរគ្នីគ្នា ហើយទើបធ្វើ, ភិក្ខុ ជាអ្នកឈ្លាសវៃ ។ល។ គួរធ្វើ គួរចាត់ចែងបាន, ធម៌នេះឯង ឈ្មោះថា នាថករណធម៌ " ដូច្នេះ ឈ្មោះថា សិល្បៈ នៃបព្វជិត ។

មង្គលត្ថទីបនីប្រែ

(១៣០) អដ្ឋកថា សត្តមសូត្រនោះថា បណ្តាបទទាំងនោះ បទថា " **ខុទ្ទាវចានិ** " ប្រែថា ខ្ពស់ និងទាប ។ កិច្ចការងារដែលបុគ្គលគប្បីពោល យ៉ាងដូច្នេះថា ខ្ញុំ នឹងធ្វើកិច្ចការអ្វី ដូច្នេះហើយទើបធ្វើ ឈ្មោះថា ការងារដែលបុគ្គលគប្បីសួរគ្នីគ្នាហើយ ទើបធ្វើ ។ បណ្តាការងារខ្ពស់ និង ទាបទាំង ២ យ៉ាងនោះ ការងារជាអាទិ៍ យ៉ាងនេះ គឺ ការធ្វើ ការជ្រលក់នូវចីវរ កម្ម គឺការលាបកំបោរ លើព្រះចេតិយ ការងារដែលបុគ្គលត្រូវធ្វើ ក្នុងវេន ឧបោសថ វេនព្រះចេតិយ និងវេនដើមពោធិ ឈ្មោះថា ការងារខ្ពង់ខ្ពស់ ។ ការងារតិចតួច មានការលាងនិងការលាបជើងជាដើម ឈ្មោះថាការងារទាប ។ បទថា "**តត្រុបាយាយ**" ប្រែថា ប្រព្រឹត្តចូលទៅ ក្នុងការងារដែលគប្បីសួរគ្នីគ្នាធ្វើនោះ ។ បទថា " **អលំ កាតុំ** " គឺ ជាអ្នកអាចដើម្បីធ្វើបាន ។ បទថា " **អលំ សំវិធាតុំ** " គឺជាអ្នកអាច ដើម្បីចាត់ចែងបាន ។ បទថា "**នាថការណា**" បានដល់ ធ្វើការៈជាទីពឹង របស់ខ្លួន, អធិប្បាយថា ធ្វើនូវទីពឹងពំនាក់យ៉ាងដូច្នេះ ។

ជីកាសត្តមសូត្រនោះថា បទថា " **ខុទ្ទនីចានិ** " គឺ ធំ និងតូច ។ បទថា " **តត្រុបគមនិយោ** " មានសេចក្តីថា ដំណើរការចូលទៅ ក្នុងការងារធំ និង តូចនោះៗ ដោយអំណាចធ្វើឲ្យបាន

ពណ៌នាអំពីសិល្បៈ

*សម្រេច គឺអាចក្នុងការញ៉ាំងកិច្ចការងារនោះៗ ឲ្យបានសម្រេច ។ បទថា " **តត្រុបាយោយ** " បានដល់ ជាឧបាយក្នុងកិច្ចការនោះ ៗ ដែលគប្បីធ្វើឲ្យសម្រេច ។ កិក្ខុ លោកហៅថា នាថៈ ព្រោះអត្ថថា រមែងរក្សា ថែទាំ គ្រប់គ្រង(នូវខ្លួន)ដោយធម៌ទុំ៉ះឯង ព្រោះមានធម៌ជាទីពឹងពាក់, ធម៌ ដែលធ្វើនូវភាពជាទីពឹង របស់កិក្ខុនោះ លោកហៅថា នាថករណធម៌ ដូច្នេះឯង ។*

ក៏សេចក្តីនេះ បណ្ឌិត គប្បីត្រួតពនិត្យ សូម្បីក្នុងសង្គីតិ-សូត្រ ព្រមទាំងអដ្ឋកថា និង ដីកា ។

*(១៣១) សិល្បៈ របស់បព្វជិតនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា **ជាមង្គល** ព្រោះនាំមកនូវប្រយោជន៍សុខ ក្នុងលោកទាំង ២ ដល់ខ្លួនឯងផង ដល់ពួកជនដទៃផង ។*

ក្នុងដំណើរនោះ មានរឿងទាំងនេះ (ជាឧទាហរណ៍) ៖

(រឿង ព្រះអានន្ទ)

សម័យមួយ ព្រះមានព្រះភាគ កាលស្តេចយាងចារិកទៅក្នុងទក្ខិណាគិរីជនបទ [1] ទ្រង់ទតព្រះនេត្រឃើញស្រែអ្នកដែនមគធៈ ទើបទ្រង់ត្រាស់ថា " ម្នាលអានន្ទ តើអ្នកអាច ដើម្បីនឹងចាត់ចែងធ្វើចីវរបែបនេះ ដល់កិក្ខុទាំងឡាយ បានដែរឬទេ " ដូច្នេះ

១- សុត្តន្តបិដក ភាគទី ៨ ទំព័រទី ១១៧ ។

មង្គលត្ថទីបនីប្រែ

ហើយ ទើបស្តេចយាងទៅកាន់ទីក្រុងរាជគ្រឹះ ។ ព្រះថេរៈ ព្រោះខ្លួនជាអ្នកឈ្លាសវៃ ក្នុងហត្ថកម្ម ទើបក្រាបទូលថា " បពិត្រព្រះអង្គដ៏ចំរើន ទូលព្រះបង្គំអាចចាត់ចែងបាន" ដូច្នេះហើយ ទើបបានចាត់ចែងនូវចីវរ មានរូបដូច្នោះ សំដែងថ្វាយ ដល់ព្រះសាស្តា ។

ព្រះសាស្តា កាលទ្រង់សរសើរ នូវព្រះថេរៈនោះ ទើបទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមក ថា " ម្នាលភិក្ខុទាំងឡាយ អានន្ទជាបណ្ឌិត ម្នាលភិក្ខុទាំងឡាយ អានន្ទ មានប្រាជ្ញាច្រើន, ព្រោះថា អានន្ទ អាចដឹងច្បាស់នូវសេចក្តី នៃពាក្យដែលតថាគតសំដែងហើយដោយសង្ខេប បានដោយពិស្តារ ហើយចេះធ្វើ នូវសំពត់ឈ្មោះកុសិផង ឈ្មោះអឌ្ឍកុសិផង ឈ្មោះមណ្ឌលផង ឈ្មោះអឌ្ឍមណ្ឌលផង ឈ្មោះវិវដ្ដៈផង ឈ្មោះអនុវិវដ្ដៈផង ឈ្មោះគីវេយ្យកៈផង ឈ្មោះជង្ឃេយ្យកៈផង ឈ្មោះពាហន្តៈផង, ហើយសំពត់នោះ ក៏ព្រះអានន្ទ បានកាត់ដាច់ ឲ្យសៅហ្មង ដោយមុខកាំបិត ឲ្យសមគួរដល់សមណៈ ឲ្យជារបស់មិនគួរប្រាថ្នា ដល់ពួកចោរជាសឹកសត្រូវ ។ ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតសង្ឃាដីកាត់ ឧត្តរាសង្គៈកាត់ អន្តរវាសកៈកាត់ " ។

(១៣២) បណ្តាបទទាំងនោះ បទថា " **យត្រ ហិ** " គឺ **យោ** ប្រែថា ព្រះអានន្ទ ណា ។ ផ្ទាំងសំពត់វែង មានអនុវាត ជា

ពណ៌នាអំពីសិល្បៈ

ដើម ទាំងបណ្តោយ ទាំងទទឹង ឈ្មោះថា កុសិ ។ ផ្ទាំងសំពត់ដែលខ្វិ ក្នុងចន្លោះ ៗ ឈ្មោះថា អឌ្ឍកុសិ ។ មណ្ឌលធំ ក្នុងខ្នង់នីមួយ ៗ ឈ្មោះថា មណ្ឌល ។ មណ្ឌលតូច ឈ្មោះថា អឌ្ឍមណ្ឌល ។ ខ្នង់ត្រង់កណ្តាល ដែលគេដេរនូវមណ្ឌល និង អឌ្ឍមណ្ឌល បញ្ចូលជាមួយគ្នា ឈ្មោះថា វិវដ្ដៈ ។ ២ ខ្នង់ គឺ ខាងមួយ ៗ នៃវិវដ្ដៈ មានមួយខ្នង់ ៗ ក្នុងចីវរ ដែលមានខ្នង់ ៥ (និង) ៤ ខ្នង់ គឺ ក្នុងខាងទាំង ២ នៃវិវដ្ដៈ ក្នុងចីវរដែលមានខ្នង់ ៧ មានខ្នង់ ២ ៗ ឈ្មោះថា អនុវិវដ្ដៈ ។ ផ្ទាំងសំពត់ដែលបន្ថែមចូលមក ដែលគេដេរភ្ជាប់នឹងអំបោះផ្សេងទៀត ដើម្បីធ្វើឲ្យណែនត្រង់ទីកន្លែងដែលឃ្មុំ-ក ឈ្មោះថា គីវេយ្យកៈ ។ ផ្ទាំងសំពត់ដែលគេដេរភ្ជាប់ យ៉ាងដូច្នោះដែរ ត្រង់ទីកន្លែងដែលគ្របជង្គង់ ឈ្មោះថា ជង្ឃេយ្យកៈ ។ អាចារ្យពួកខ្លះ ពោលថា “ ផ្ទាំងសំពត់ដែលនៅត្រង់កន្លែង-ក (ឈ្មោះថា គីវេយ្យកៈ) និង ត្រង់កន្លែងជង្គង់ (ឈ្មោះថា ជង្ឃេយ្យកៈ) ” ដូច្នេះក៏មាន ។ ខ្នង់មួយ ៗ ខាងក្រៅអនុវិវដ្ដៈ ឈ្មោះថា ពាហន្តៈ ។

ចំណែកក្នុងមហាអដ្ឋកថា លោកពោលថា “ ជាយទាំងឡាយពីរ ដែលកិក្ខុកាលគ្រងចីវរដែលត្រូវខ្នាត មួលមកពាក់លើដើមដៃ មានមុខស្ថិតនៅខាងក្រៅ, ពាក្យថា “ **ពាហន្តៈ** ” នុ៎ះ ជា

ឈ្មោះ នៃជាយទាំង ២ នោះ" ។

ព្រះមានព្រះភាគ លុះទ្រង់សំដែងនូវចីវរ ៩ យ៉ាង ដោយអំណាចកុសិជាដើម យ៉ាងដូច្នេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់សំដែង ថា " ចីវរ ទាំងអស់នុ៎ះ គឺកិក្ខុត្រូវតែកាត់ " ដូច្នេះ ទើបទ្រង់ត្រាស់ថា "**ឆិន្នកញ្ចុ**" ដូច្នេះជាដើម ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងពាក្យទាំងនោះ ។ បទថា "**ឆិន្នកញ្ចុ**" គឺ ឈ្មោះថាចីវរ ដែលកាត់ហើយ ដោយប្រការមានកុសិជាដើម ។ បទថា " **បច្ចត្ថិកានំ** " បានដល់ ពួកចោរដែលជាសឹកសត្រូវដល់ព្រះសាសនា ។ បទថា " **អនភិជ្ឈាកតំ** " គឺ មិនធ្វើការសំឡឹងរំពៃហើយ, អធិប្បាយថា មិនចង់បានហើយ ។ ហេតុនោះ ចីវរទាំង ៣ នោះឯង កិក្ខុ ត្រូវតែកាត់ ។ បើកិក្ខុកាត់ចីវរ ៣, សំពត់មិនគ្រប់គ្រាន់, កិក្ខុត្រូវកាត់ចីវរ ២ ។ សូម្បីកាលបើ កិក្ខុកាត់ចីវរ ២, សំពត់ ក៏មិនគ្រប់គ្រាន់, កិក្ខុត្រូវកាត់ចីវរ ១, សូម្បីកាលបើ កិក្ខុ កាត់ចីវរ ១, សំពត់ក៏មិនគ្រប់គ្រាន់ដែរ, កិក្ខុ ត្រូវបន្ថែមសំពត់អាគន្តុកៈ (សំពត់ថ្មី) មកទៀត ។

ក្នុងដំណើរនោះ មានបាលីនេះ (ជាឧទាហរណ៍) ៖

(បាលី ក្នុងចីវរក្ខន្ធកៈ)

(១៣៣) ក៏សម័យនោះឯង ពួកកិក្ខុ កំពុងធ្វើចីពរ (ឲ្យ)

ពណ៌នាអំពីសិល្បៈ

កិក្ខុ ១ រូប, [1] លុះកិក្ខុកាត់ចីវរទាំងអស់ទៅហើយ សំពត់ មិនគ្រប់គ្រាន់ ។ (ពួកកិក្ខុ ក្រាបទូលនូវសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ឲ្យហៅកិក្ខុទាំងឡាយមកហើយ ទ្រង់ត្រាស់អនុញ្ញាត ថា) " ម្នាលកិក្ខុទាំងឡាយ តថាគត អនុញ្ញាតឲ្យកាត់ចីវរ ២ (៦) ចីវរ ១ មិនបាច់កាត់ ក៏បានដែរ " ។ ពួកកិក្ខុនោះ បានកាត់ចីពរ ២, មិនបានកាត់ ១ សំពត់ ក៏នៅតែមិនគ្រប់គ្រាន់ទៀត ។ (បន្តែមសេចក្តីដូចមុន) ។ " ម្នាលកិក្ខុទាំងឡាយ តថាគត អនុញ្ញាតចីវរ ២ មិនបាច់កាច់ទេ, ឲ្យកាត់តែចីវរ ១ បាន " ។ ពួកកិក្ខុទាំងនោះ មិនបានកាត់ចីវរ ២, បានកាត់តែចីវរ ១, សំពត់ ក៏នៅតែមិនគ្រប់គ្រាន់ទៀត ។ (បន្តែមសេចក្តីដូចមុន) ។ "ម្នាលកិក្ខុទាំងឡាយ តថាគត អនុញ្ញាតដើម្បីឲ្យកិក្ខុលើកឡើង (ប៉ះ) សូម្បីនូវសំពត់អាគន្តុកៈ (សំពត់ថ្មី) ទៀត ។ ម្នាលកិក្ខុទាំងឡាយ ក៏កិក្ខុមិនត្រូវគ្រងចីវរ ដែលមិនបានកាត់ទាំងអស់ឡើយ, កិក្ខុណា គ្រង, កិក្ខុនោះ ត្រូវអាបត្តិទុក្កដ " ។

*អដ្ឋកថា នៃចីវរក្ខន្ធកៈ នោះ ថា ក្នុងពាក្យថា " **អន្ធាធិកំបិ អារោបេតុំ** " គឺ ដើម្បីបន្តែម នូវសំពត់អាគន្តុកៈ ។ តែសំពត់អាគន្តុកៈនេះ បើសំពត់ មិនគ្រប់គ្រាន់ កិក្ខុគប្បីប៉ះបាន ។ បើ*

១- សុត្តន្តបិដក ភាគទី ៨ ទំព័រទី ១៤៤ ។

មង្គលត្ថទីបនីប្រែ

សំពត់ គ្រប់គ្រាន់, ការដែលភិក្ខុប៉ះ នូវសំពត់អាគន្តុកៈ មិនគួរទេ, ចីវរទាំងអស់ ភិក្ខុត្រូវតែកាត់ឲ្យទាល់តែបាន" ។

*អនុដីកា នៃវិមតិវិនោទនី ដែលសំដែងអំពីគណភោជន-សិក្ខាបទ ថា បទថា "**អាគន្តុកបជំ**" ព្រះអដ្ឋកថាចារ្យ ពោលសំដៅយកចីវរ ដែលមិនបានកាត់ហើយ លើកឡើង (ប៉ះ) នូវសំពត់អាគន្តុកៈ ធ្វើ" ។*

រឿង ព្រះអានន្ទត្ថេរ ចប់ ។

(រឿង ភិក្ខុ មួយរូប)

((១៣៤) ក្នុងគ្រានោះ ភិក្ខុ ១ រូប មានស្បង់ធ្លុះហើយ ។ ភិក្ខុនោះ គិតថា "ចីវរ ៣ គឺ សង្ឃាដី ២ ជាន់ ឧត្តរាសង្គៈ ១ ជាន់ អន្តរវាសកៈ ១ ជាន់ ព្រះមានព្រះភាគ ទ្រង់បានអនុញ្ញាតហើយ, ឯអន្តរវាសកៈ របស់អាត្មាអញនេះ ធ្លុះហើយ, បើដូច្នោះ គួរតែអាត្មាអញប៉ះនូវបំណះ, (កាលបើដូច្នោះ) អន្តរវាសកៈនោះ នឹងទៅជា ២ ជាន់ ដោយជុំវិញ, កណ្តាល ១ ជាន់" ដូច្នេះហើយ ទើបបានប៉ះនូវបំណះ ។

ព្រះសាស្តា ទ្រង់ជ្រាបនូវរឿងនោះហើយ [1] ទ្រង់ធ្វើដូចជាស្តេចយាងចារិកទៅ ក្នុងវិហារ ទ្រង់ស្តេចយាងដូចទៅរកភិក្ខុរូប

១- សុត្តន្តបិដក ភាគទី ៨ ទំព័រទី ១២៣ ។

នោះហើយ ទ្រង់ត្រាស់សួរថា “ នែកិកុ តើអ្នកធ្វើអ្វី ” ។

កិកុនោះ ក្រាបទូលថា “ បពិត្រព្រះមានព្រះភាគ ដ៏ចំរើន ទូលព្រះបង្គំប៉ះនូវបំណះ ” ។

ព្រះសាស្តា ទ្រង់ត្រាស់ថា “ ម្នាលកិកុ ប្រពៃហើយ ។, ម្នាលកិកុ ប្រពៃហើយ អ្នកបានប៉ះនូវបំណះ ” ដូច្នេះហើយ ទើប ទ្រង់ត្រាស់ហៅកិកុទាំងឡាយមកថា “ ម្នាលកិកុទាំងឡាយ កាល បើសំពត់នៅថ្មោង ឬក៏ សំពត់ដែលគេបានលាង ម្តងរួចហើយ, តថាគត អនុញ្ញាត (ឲ្យអ្នកទាំងឡាយធ្វើ) សង្ឃាដី ២ ជាន់ ឧត្តរាសង្គៈ ១ ជាន់ អន្តរវាសកៈ ១ ជាន់, (បើ) សំពត់ដែល គេរើឡើងពីរដូវ (សំពត់ចាស់), តថាគត អនុញ្ញាតឲ្យអ្នកទាំង ឡាយធ្វើនូវសង្ឃាដី ៤ ជាន់ ឧត្តរាសង្គៈ ២ ជាន់ អន្តរវាសកៈ ២ ជាន់, អ្នកទាំងឡាយ គប្បីធ្វើសេចក្តីប្រឹងប្រែង ក្នុងសំពត់ បង្សុកូល ក្នុងសំពត់ដែលធ្លាប់ចុះ ក្នុងទីផ្សារ តាមសេចក្តីត្រូវការ, ម្នាលកិកុទាំងឡាយ តថាគត អនុញ្ញាតនូវបំណះ នូវការជុល នូវ ក្រវិលកណ្តុំ នូវកណ្តុំ នូវការធ្វើឲ្យមាំទាំ ” ។

(១៣៥) បណ្តាបទទាំងនោះ បទថា “**អហតកប្បានំ**” បាន ដល់ សំពត់ដែលគេបោកម្តងហើយ ។ បទថា “**ឧតុទ្ធានំ** ” បាន ដល់ សំពត់ដែលគេរើឡើង អំពីរដូវ គឺ អំពីកាលដ៏យូរ ។ មាន

មង្គលត្ថទីបនីប្រែ

ព្រះតម្រាស់ដែលព្រះអង្គ ទ្រង់ត្រាស់ថា " បើសំពត់ចាស់ ដែលមានពណ៌សាកអស់ហើយ " ។ បទថា " **បាបណិកេ** " បានដល់ ក្នុងសំពត់ចាស់ដែលធ្លាក់ចុះ អំពីចន្ទោះនៃទីផ្សារ ។ ការស្វែងរក ឈ្មោះថា សេចក្តីឧស្សាហ៍ ។ តែសំពត់បង្សុកូល និងសំពត់ដែលធ្លាក់ចុះ ក្នុងទីផ្សារនោះ មិនមានកំណត់ទេ, សូម្បី ១០០ ជាន់ ក៏គួរដែរ ។ ពាក្យទាំងអស់នេះ លោកពោលហើយសម្រាប់ភិក្ខុដែលត្រេកអរ ។ បទថា " **អគ្គឡំ** " បានដល់ កំណាត់សំពត់ (ថ្មី) ដែលគេរើ (សំពត់ចាស់) ចេញហើយប៉ះ ។ បទថា " **តុន្នំ** " គឺសំពត់ដែលគេដេរហើយដោយចេស ។ បទថា "**ឧវដ្តិកំ**" គឺការចោះហើយធ្វើ (ប្រហោង) ។ បទថា "**កណ្ឌាសកំ**" គឺ កណ្តាំ ។ បទថា " **ទន្ធីកម្មំ** " បានដល់ កំណាត់សំពត់ ដែលមិនបានរើ ធ្វើសម្រាប់ទ្រ ហើយប៉ះចូលគ្នា ។

រឿងភិក្ខុមួយរូប ចប់ ។

(១៣៦) ភាពនៃបុគ្គលជាអ្នកឈ្លាសវៃ ក្នុងហត្ថកម្ម របស់បុគ្គលទាំងឡាយនេះ ដែលប្រកបហើយ ក្នុងហានៈ រមែងនាំមកនូវសេចក្តីសរសើរ ដែលរាប់ចូលក្នុងប្រយោជន៍សុខ ក្នុងលោកនេះ ដោយប្រការដូច្នេះ ព្រោះហេតុនោះ ទើបចាត់ថា **ជាមង្គល** ។ តែដែលប្រកបហើយ ក្នុងទីមិនមែនជាហានៈ មិនចាត់ថា ជាមង្គល

ពណ៌នាអំពីសិល្បៈ

ទ្បើយ ព្រោះហេតុនាំមកនូវសេចក្តីនិន្ទា ។

ក្នុងដំណើរនោះ មានរឿងនេះ (ជាឧទាហរណ៍) ៖

(រឿង ព្រះលោលុទាយី)

បានឮថា ព្រះលោលុទាយី ជាអ្នកល្អិត ជាអ្នកអាចធ្វើនូវចីវរកម្មបាន ។ ព្រះលោលុទាយីនោះ ដេរចីវរ ដើម្បីនាងភិក្ខុនី ដែលជាភរិយាចាស់របស់ខ្លួន ជ្រលក់ហើយ ធ្វើរូបភាពដ៏វិចិត្រ ដែលសម្រេចដោយការឈ្វាសវៃត្រង់កណ្តាល បត់ស្រេចហើយ ពោលថា " នែប្អូនស្រី បើដូច្នោះ ចូរនាងយកចីវរដែលបងបានបត់ហើយនេះ ទៅទុកជាក់ចុះ, ក្នុងពេលណា នាងភិក្ខុនីសង្ឃ មកដើម្បីទទួលឱវាទ, ចូរគ្រងចីវរនេះហើយ និមន្តមកខាងក្រោយ ។ ក្នុងពេលនោះចុះ " ។ នាងភិក្ខុនីនោះ បានធ្វើយ៉ាងដូច្នោះហើយ ។ ពួកមនុស្ស ឃើញភិក្ខុនោះហើយ ក៏បានលើកទោស ។ នាងភិក្ខុនីនោះ បានប្រាប់ ដល់ពួកនាងភិក្ខុនី ។ ពួកនាងភិក្ខុនី បានប្រាប់ដល់ពួកភិក្ខុ ។ ពួកភិក្ខុ បានក្រាបទូលសេចក្តីនោះ ដល់ព្រះដ៏មានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់បានតិះដៀលភិក្ខុឧទាយី ដោយអនេកបរិយាយ ហើយទ្រង់បានបញ្ញត្តចីវរសិព្វនសិក្ខាបទ ក្នុងភិក្ខុនីវគ្គ ថា " ក៏ភិក្ខុណា ដេរខ្លួនឯង ក្តី ប្រើគេឲ្យដេរ ក្តី នូវចីវរដើម្បីនាងភិក្ខុនី ដែលមិនមែនជាញាតិ, ភិក្ខុនោះ ត្រូវបាចិត្តិយៈ " ។

មង្គលត្ថទីបនីប្រែ

បទថា “ ***បដិភានចិត្តំ*** *” បានដល់ ចិត្រកម្មដែលធ្វើហើយ ដោយបដិភាណរបស់ខ្លួន, អធិប្បាយថា “ រូបភាពរបស់ស្ត្រី និង បុរសដែលសេពនូវមេថុនធម្មពុំទាន់រួច ដែលខ្លួនធ្វើហើយ ដោយ ពណ៌ផ្សេង ៗ ” ។*

រឿង ព្រះលោលុទាយី ចប់ ។

(អាគារិយសិល្បៈ)

(១៣៧) ឈ្មោះថា សិប្បៈរបស់គ្រហស្ថ មាន ២ យ៉ាង ។ បណ្តាសិប្បៈទាំង ២ យ៉ាងនោះ កិច្ចការណា ដែលវៀរចាកការ បៀតបៀនជីវិត នៃសត្វដទៃ វៀរចាកអកុសលកម្ម មានកិច្ចការ ងារ របស់ជាងកែវមណី និង ជាងមាសជាដើម, កិច្ចការងារនោះ ឈ្មោះថា ជាមង្គល ព្រោះនាំប្រយោជន៍ ក្នុងលោកនេះមកឲ្យ ។

ក្នុងដំណើរនោះ មានរឿងនេះ (ជាឧទាហរណ៍) ៖

(រឿង ជាងកែវមណី)

ក្នុងអតីតកាល ក្នុងស្រុកមួយ ក្នុងទីក្រុងពារាណសី ក្នុង ដែនកាសី មានសេដ្ឋីម្នាក់ ជាអ្នកមានទ្រព្យសម្បត្តិច្រើន ។ ក៏ទ្រព្យ ដែលគាត់កប់ទុក មានដល់ទៅ ៤០ កោដិ ។ ចំណែក ភរិយា របស់សេដ្ឋីនោះ ធ្វើកាលៈហើយ ក៏បានទៅកើតជាសត្វកណ្តុរញី លើខ្នងនៃទ្រព្យ ព្រោះសេចក្តីស្រឡាញ់ ក្នុងទ្រព្យ ។ ត្រកូលទាំង

អស់នោះ ជល់នូវសេចក្តីវិនាស ដោយលំដាប់ ។ ឯផ្ទះនោះ ត្រូវគេបោះបង់ចោលហើយ ក៏ជល់នូវសេចក្តីសាបសូន្យផងដែរ ។

គ្រានោះ ជាងកែវមណីម្នាក់ ប្រាថ្នាចង់ជំនួសហើយ យកនូវកែវមណី ទើបរើយកថ្ម ក្នុងទីនៃផ្ទះចាស់នោះមកដំ ។ សត្វកណ្តុរញីនោះ កាលបោលរកស៊ី ក៏ឃើញជាងកែវមណីនោះញីកញាប់ ទើបកើតសេចក្តីស្រឡាញ់ហើយ គិតថា " ទ្រព្យជាច្រើន របស់អញនឹងវិនាសបាត់ទៅ ដោយមិនសមហេតុ, អញនឹងរួមជាមួយនឹងជាងកែវមណីនេះ ហើយប្រើប្រាស់ទ្រព្យនោះ" ដូច្នេះហើយ ក៏បានពាំទ្រព្យ ១ កហាបណៈ បោលទៅកាន់សំណាក់ជាងកែវមណីនោះ ។ ជាងកែវមណីនោះ ឃើញសត្វកណ្តុរញីនោះហើយ កាលនិយាយរាក់ទាក់នឹងកណ្តុរញីនោះ ដោយវាចាដ៏ពីរោះ ទើបពោលថា " នែនាង តើនាងពាំកហាបណៈ មកធ្វើអ្វី " ។ សត្វកណ្តុរពី ឆ្លើយថា "ម្នាលអ្នក ចូរអ្នកនាំយកកហាបនៈនេះ ទៅប្រើប្រាស់ដោយខ្លួនឯងចុះ, ចូរអ្នកនាំយកសាច់ មកឲ្យនាងខ្ញុំផងណា " ។ ជាងកែវមណីនោះ បាននាំយកកហាបណៈ ទៅកាន់ផ្ទះហើយ បានទិញយកសាច់ នាំទៅឲ្យ ជល់សត្វកណ្តុរញីនោះ ។ សត្វកណ្តុរញីនោះ បានពាំយកសាច់ ទៅកាន់ទីលំនៅ របស់ខ្លួនហើយស៊ី ។ កណ្តុរញីនោះ បានពាំទ្រព្យ ឲ្យជល់ជាងកែវមណី

នោះឯង ហើយទទួលយកសាច់ ដោយនយនេះជារៀងរាល់ថ្ងៃ ។ សត្វកណ្តុរញីនោះ បានពាំទ្រព្យទាំងអស់នោះ យកទៅ ឲ្យដល់ជាងកែវមណីនោះឯង ដោយលំដាប់ ដោយប្រការដូច្នេះឯង ។

រឿង ជាងកែវមណី មកក្នុងអដ្ឋកថាពុទ្ធជាតក ក្នុងវគ្គទី ១៤ នៃឯកនិបាត ។

*(១៣៨) ក៏ព្រោះលោកពោលហើយ ដោយមិនខុសប្លែកអំពីគ្នាថា "ភាពជាអ្នកឈ្លាសវៃក្នុងហេតុកម្មឯណាមួយ ឈ្មោះថា សិប្ប: " ដូច្នេះហើយ សិប្ប: របស់ជាងត្បាញផែងជាដើមក្តី សិប្ប: របស់អ្នកផ្ចាត់គ្រាប់ក្រួសក្តី ដែលមកហើយ ក្នុងវិកប្ប នៃឱមសវាទសិក្ខាបទ ក៏រាប់បញ្ចូលបានដូចគ្នាដែរ ។ ជាងតបាញផែង ឈ្មោះថា ទទ្បការ ក្នុងពាក្យ ថា " **ទទ្បការាទិសិប្បញ្ចេវ** " នោះ ។ សូម្បីសិប្ប: របស់ជាងតបាញផែងនោះ ក៏ឈ្មោះថាជាមង្គល ផងដែរ ព្រោះជាហេតុនាំមកនូវប្រយោជន៍ ។*

ក្នុងដំណើរនោះ មានរឿងទាំងនេះ (ជាឧទាហរណ៍) ៖

(រឿង ព្រះបេរ: ថ្វាយកន្ទេល)

ក្នុងអតីតកាល ជាងតបាញផែងម្នាក់ក្នុងក្រុងតីវរនគរ បានថ្វាយនូវកន្ទេល ដើម្បីបូជាចំពោះព្រះមានព្រះភាគ ទ្រង់ព្រះនាម សិទ្ធត្ថ: ព្រោះកម្មនោះ ទើបអន្ទោលទៅ តែក្នុងសុគតិភព រហូត ៩៤ កប្បប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទនេះ កើតជាកុលបុត្រ បានបួស

ពណ៌នាអំពីសិល្បៈ

ក្នុងព្រះសាសនាហើយ បានសម្រេចព្រះអរហត្ត ។ ព្រះថេរៈនោះ កាលនឹងប្រកាសការប្រព្រឹត្តិមិនដាច់រយៈ ក្នុងកាលមុន របស់ខ្លួន ទើបបានពោលគាថាទាំងនេះ ក្នុងចតុត្ថីសមវគ្គ នៃអបទាន [1] ថា

កាលនោះ ខ្ញុំបានកើតជាអ្នកត្បាញផែង ក្នុងតិវរបុរី ដែលជាទីរមណីយដ្ឋាន, ឯប្រជុំជន បានជ្រះថ្លាហើយ បំពោះព្រះសិទ្ធត្ថសម្ពុទ្ធ ព្រះអង្គទ្រង់បំភ្លឺលោក ក្នុងកាលនោះ ។ ប្រជុំជនតាំងគ្នាស្វែងរកកន្ទេល ដើម្បីប្លាជា បំពោះព្រះលោកនាថ, ខ្ញុំបានឱ្យកន្ទេល ដល់ពួកជនអ្នកធ្វើពុទ្ធបូជាហើយ ។ រហូត ៩៤ កប្ប អំពីកប្បនេះទៅ ព្រោះកម្មដែលខ្ញុំបានធ្វើហើយ ក្នុងកាលនោះ ទើបខ្ញុំមិនដែលបានស្គាល់ទុគ្គតិឡើយ, នេះជាផលនៃកន្ទេល ។ ក្នុងកប្បទី ៣៣ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ព្រះនាមឋាជលន្ធរៈ ទ្រង់បរិបូណ៌ ដោយកែវ ៧ ប្រការ ជាអ្នកមានកម្លាំងប្រើន ។ ធម៌ទាំងឡាយនេះ គឺ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ គឺខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

រឿង ព្រះថេរៈថ្វាយកន្ទេល ចប់ ។

๑- សុត្តន្តបិដក ភាគទី ៧៣ ទំព័រទី ๑๗๒ ។

មង្គលត្ថទីបនីប្រែ

(រឿង ព្រះបាទមហាបតាទ:)

(១៣៩) ក្នុងអតីតកាល ក្នុងទីក្រុងពារាណសី ជាងត្បាញផែង កាលទៅស្រែ បានឃើញព្រះបច្ចេកពុទ្ធមួយអង្គ ទើបបានបញ្ជូនទូវទាសាទាសី ដោយប្រាប់ថា " ចូរអ្នកទាំងឡាយ ព្រោះចុះ " ដូច្នេះហើយ ខ្លួនឯងក៏បានត្រឡប់ទៅវិញហើយ នាំព្រះបច្ចេកពុទ្ធអង្គនោះទៅផ្ទះ ញុាំងព្រះអង្គឲ្យឆាន់ហើយ នាំទៅកាន់មាត់ទន្លេគង្គាម្តងទៀត ព្រមទាំងកូន បានធ្វើទូវបណ្ណសាលាដែលមានជើងជញ្ជាំង ធ្វើដោយដើមឧទុម្ពរ មានជញ្ជាំង ធ្វើដោយដើមបបុស និង ធ្វើទូវទីចង្រ្កមហើយ និមន្តព្រះបច្ចេកពុទ្ធអង្គនោះ ឲ្យគង់ចាំវស្សា ក្នុងទីនោះ រហូត ៣ ខែ ។ បិតានិងបុត្រទាំង ២ នាក់ ញុាំងព្រះបច្ចេកពុទ្ធ ដែលគង់ចាំព្រះវស្សាហើយ ឲ្យគ្រងចីវរហើយ ទើបបានជូនទៅ, បិតា និង បុត្រទាំង ២ នាក់នោះ ញុាំងព្រះបច្ចេកពុទ្ធទាំងឡាយ ៧ អង្គ ឲ្យនៅចាំវស្សាហើយ ក្នុងទីនោះ បានប្រគេនត្រៃចីវរ ដោយទំនងនេះ ។ អាចារ្យពួកខ្លះពោលថា " បិតានិងបុត្រទាំង ២ នាក់ កើតជាជាងត្បាញផែង កំពុងតែស្រង់ឫស្សី ក្បែរមាត់ច្រាំងទន្លេគង្គា ក៏បានឃើញព្រះបច្ចេកពុទ្ធហើយ បានធ្វើយ៉ាងនេះ " ដូច្នេះ ក៏មាន ។ ជនទាំង ២ នោះ ធ្វើកាល:ហើយ បានទៅកើត ក្នុងកពតាវត្តិង្ស ត្រាច់សោយសម្បត្តិ

ទិព្វ ក្នុងឆកាមាវចរសួគ៌ ដោយអនុលោមបដិលោម ។ បណ្តាជនទាំង ២ នាក់នោះ បិតាបានស្លាប់ទៅហើយ ក្នុងទេវលោកនុ៎ះឯង ។ ចំណែកឯ បុត្រ ច្យុតចាកទេវលោកនោះហើយ បានមកកើត ក្នុងព្រះគភ៌នៃព្រះរាជទេវីព្រះនាមសុមេធា នៃព្រះរាជាព្រះនាម សុរុចិ ក្នុងទីក្រុងមិថិលា ក្នុងដែនវិទេហៈ ដោយកាលកន្លងទៅបាន ១០ ខែ ក៏បានប្រសូតចេញមកហើយ ។ ព្រះបិតា និង ព្រះមាតា បានប្រទានព្រះនាម ដល់ព្រះរាជបុត្រនោះថា " ព្រះមហាបនាទៈ " ។ ព្រះរាជកុមារនោះ ក្នុងពេលដែលមានព្រះជន្មាយុបាន ១៦ ព្រះវស្សា ទ្រង់បានដល់ហើយនូវសេចក្តីសម្រេច ក្នុងសិល្បសាស្ត្រគ្រប់យ៉ាង ។ ព្រះរាជា ទ្រង់បានត្រាស់បញ្ជាឲ្យពួកអាចារ្យដែលចេះដឹងវិជ្ជាត្រួតពិនិត្យផែនដី ថា " នែអ្នកទាំងឡាយ ចូរអ្នកទាំងឡាយ រកជាងមក ឲ្យកសាងប្រាសាទ ដើម្បីព្រះរាជបុត្រ (របស់យើង) យើងនឹងអភិសេកព្រះរាជបុត្រនោះ ក្នុងរាជសម្បត្តិ " ។ ពួកអាចារ្យទាំងនោះ ទទួលព្រះរាជឱង្ការថា "ប្រពៃហើយ" ទើបទៅត្រួតពិនិត្យមើលភូមិប្រទេស ។

គ្រានោះ អាសនៈ របស់ស្តេចទេវរាជ សំដែងហើយ នូវអាការក្តៅ ដោយអានុភាពនៃបុណ្យ របស់ព្រះរាជកុមារនោះ ។ ស្តេចសក្កទេវរាជនោះ ទ្រង់ជ្រាបរឿងនោះហើយ ទើបទ្រង់ត្រាស់

មង្គលត្ថទីបនីប្រែ

បញ្ជូនវិស្សកម្មទេវបុត្រទៅ ដោយព្រះតម្រាស់ ថា " ចូរអ្នកទៅកសាងប្រាសាទចុះ " ។ ព្រះវិស្សកម្មទេវបុត្រនោះបានប្រែក្រឡាជាជាង ទៅកាន់សំណាក់ នៃពួកជាងហើយ ប្រាប់ថា " ពួកអ្នកបរិភោគអាហារ ពេលព្រឹកហើយ ចូរមកចុះ " ហើយ បានបញ្ជូនពួកជាងទាំងនោះទៅហើយ យកឈើពស្រាបផែនដី ។

ក្នុងខណៈនោះឯង ប្រាសាទ ៧ ជាន់ សម្រេចដោយកែវ ៧ ប្រការ មានទទឹងនិងបណ្តោយកន្លះយោជន៍ មានកំពស់ ២៥ យោជន៍ បានផុះឡើងហើយ ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សំដៅយកហើយ ក្នុងមហាបទានជាតក នៃតិកនិបាត[1] ថា ៖

(១៤០) ព្រះរាជអង្គនោះ ទ្រង់ព្រះនាមបតាទៈ មានប្រាសាទមាស មានទទឹងប្រវែងកិរិយាធ្លាក់ចុះ នៃក្អូនសរ ១៦ (កន្លះយោជន៍) អ្នកប្រាជ្ញទាំងឡាយ ពោលថា ប្រាសាទនោះកំពស់ ១ ជាន់តំណា នៃក្អូនសរ (២៥ យោជន៍) ។ ប្រាសាទនោះ កំពស់ ១ ជាន់តំណានៃក្អូនសរ មានជាន់ប្រាំពីរ បរិបូណ៌ដោយទង់ ព័ទ្ធព័ន្ធហើយដោយកែវមណីមានពណ៌ខៀវ, ពួកអ្នករបាំ ៦ ជាន់ បែកជា ៧ ក្រុម បានរាំហើយ លើប្រាសាទនោះ ។

១- សុត្តន្តបិដក ភាគទី ៥៨ ទំព័រទី ១៥០ ។

ពណ៌នាអំពីសិលា

បណ្តាបទទាំងនោះ បទថា "**ឃ្លោ**" ប្រែថា ប្រាសាទ ។ បាទគាថា ថា " **តិរិយំ សោឡសុព្ភេ** " គឺ ដោយទទឹង មានប្រវែងកិរិយាចាក់ជ្រុះ នៃកូនសរ ១៦ ។ បាទគាថា ថា " **ឧច្ចមាហុ សហស្សេ**" គឺ អ្នកប្រាជ្ញទាំងឡាយពោលនូវពាក្យកំពស់ដោយការរាប់ នៃកិរិយារសាត់ទៅ នៃកូនសរ ១ ពាន់ ។ ក៏លោកសំដែងប្រមាណ ២៥ យោជន៍ ដោយការរាប់នូវកិរិយារសាត់ទៅ នៃកូនសរ ១ ពាន់, ព្រោះហេតុនោះ ទើបលោកសំដែងប្រមាណកន្លះយោជន៍ ដោយការរាប់នូវកិរិយារសាត់ទៅ នៃកូនសរ ១៦ ។ បទថា " **សហស្សកណ្ឌោ** " គឺ មានកំពស់ ១ ពាន់តំណ នៃកូនសរ ។ បទថា " **សត្តគេណ្ឌុ** " គឺ ជាប្រាសាទ ៧ ជាន់ ។ បទថា " **ធជាលុ** " គឺ បរិបូណ៌ដោយទង់ ។ បទថា "**ហរិតាមយោ**" គឺ បិទជុំវិញហើយដោយកែវមណីពណ៌ខៀវ ។ ចាលីក្នុងអដ្ឋកថា ថា " **សសាលុ** " ជួរច្នេះក៏មាន ។ អធិប្បាយថា " ដែលប្រកបព្រមហើយ ដោយមេទ្វារនិងបង្អួច ដែលធ្វើដោយកែវមណីពណ៌ខៀវ ។ បានឮមកថា ពាក្យថា "**សស**" ជាឈ្មោះនៃមេទ្វារនិង បង្អួច ។ បទថា " **អនច្ចុំ** " គឺ រាំហើយ ដើម្បីញ៉ាំងសេចក្តីត្រេកអរឲ្យកើតឡើង ដល់ព្រះរាជា ។ បទថា " **តត្ថ** " បានដល់ ក្នុងប្រាសាទនោះ គឺក្នុងជាន់ទី ៧ នៃប្រាសាទនោះ ។ ពួក

មង្គលត្ថទីបនីប្រែ

អ្នករថាំ ឈ្មោះថា គន្ធព្វា ។ បាទគាថា ថា " **ឆ សហស្សានិ សត្តជា** " បានដល់ អ្នករថាំ ៦ ពាន់ បែងចែកជា ៧ ក្រុម ។

(១៤១) ព្រះបាទមហាបនាទៈ ទ្រង់បានបំពេញបុណ្យ មានទានជាដើម សោយទិវង្គតទៅហើយ ក៏បានទៅកាន់ទេវលោក តាមដើម ។ ប្រាសាទនោះ បានជាប់ ទៅតាមខ្សែទឹក នៃទន្លេគង្គា ហើយ ។ ក្នុងទីត្រង់មុខជណ្តើរក្បែរប្រាសាទនោះ គេបានកសាង នគរ ឈ្មោះថា បយាគប្បតិដ្ឋាន, ក្នុងទីត្រង់កំពូលប្រាសាទនោះ មានស្រុក ឈ្មោះថា កោដិគ្រាម ។ ក្នុងពុទ្ធុប្បាទនេះ នឡការ-ទេវបុត្រនោះ ច្យុតចាកទេវលោកហើយ បានកើតជាបុត្រ របស់ កទ្ទិយសេដ្ឋី អ្នកមានសម្បត្តិ ៨០ កោដិ ក្នុងកទ្ទិយនគរ ឈ្មោះ កទ្ទជិកុមារ ។

ក្នុងកាលនោះ ព្រះមានព្រះភាគ ទ្រង់អាស្រ័យកទ្ទិយនគរ គង់នៅក្នុងជាតិយាវន ។ ពួកអ្នកនគរ បានសាងមណ្ឌលសម្រាប់ ធ្វើទាន ត្រង់កណ្តាលព្រះនគរហើយថ្វាយមហាទាន។ ព្រះសាស្តា ទ្រង់ធ្វើភត្តកិច្ច ក្នុងទីនោះ រួចហើយ ទ្រង់បានធ្វើអនុមោទនា ។ ឯកទ្ទជិកុមារ ចូលទៅគាល់ព្រះសាស្តាហើយ ស្តាប់ធម៌ ក៏បាន សម្រេចព្រះអរហត្ត បានទៅកាន់ព្រះវិហារ ព្រមជាមួយនឹងព្រះ សាស្តា បានបព្វជ្ជាឧបសម្បទាហើយ ។ ព្រះសាស្តា ទ្រង់គង់នៅ

ពណ៌នាអំពីសិល្បៈ

ក្នុងទីនោះ អស់ ៧ ថ្ងៃហើយ កាលស្តេចចារិកទៅដល់កោដិគ្រាម ទ្រង់ធ្វើកត្តកិច្ចហើយ ទ្រង់បានធ្វើនូវអនុមោទនា ។ ព្រះកទូជិត្តេរ ក្នុងពេលដែលព្រះអង្គធ្វើអនុមោទនា បាននិមន្តទៅ ខាងក្រៅផ្ទះ អធិដ្ឋាន ក្នុងចិត្តថា " ក្នុងពេលដែលព្រះសាស្តាស្តេចយាងមក ភ្លាម អាត្មាអញនឹងក្រោកទទួល " ដូច្នេះហើយ គង់ចូលឈាន ក្រោមគល់ឈើ កែ្បរកំពង់ទន្លេគង្គា, សូម្បីកាលបើពួកព្រះថេរៈ ដែលចាស់ជាងនិមន្តមក, ក៏មិនក្រោកទទួល ក្នុងពេលដែលព្រះ សាស្តាស្តេច យាងមកដល់ភ្លាម ទើបក្រោកទទួល ។ ពួកកិក្ខុជា បុថុជ្ជន បានលើកទោសព្រះកទូជិត្តេរនោះហើយ ។ ព្រះសាស្តា ទ្រង់គង់នៅ លើទូកហើយ ទ្រង់បានត្រាស់ថា " ម្នាលកទូជិ អ្នក ចូរមក ចូរឡើងជិះទូកមួយ ជាមួយនឹងតថាគត " ។ ព្រះថេរៈ បានហោះឡើង ទៅគង់លើទូក ជាមួយនឹងព្រះអង្គ ។ ក្នុងពេល ទៅដល់ពាក់កណ្តាលទន្លេគង្គា ព្រះសាស្តាទ្រង់ត្រាស់ថា " ម្នាល កទូជិ ក្នុងពេលដែលអ្នកជាព្រះរាជា ព្រះនាមថា មហាបនាទៈ ប្រាសាទ ដែលអ្នកនៅគ្រប់គ្រង តើនៅក្នុងទីណា " ។ ព្រះថេរៈ នោះ ក្រាបទូលថា " បពិត្រព្រះអង្គដ៏ចំរើន ប្រាសាទនោះ លិច ហើយ ក្នុងទីនេះ " ហើយ ថ្វាយបង្គំព្រះសាស្តា ទៅដោយកម្លាំង នៃឫទ្ធិ បានយកម្រាមដៃកៀរកំពូលប្រាសាទ ហោះឡើងទៅលើ

មង្គលត្ថទីបនីប្រែ

អាកាសហើយសំដែង ដើម្បីកាត់សេចក្តីសង្ស័យរបស់ពួកបុថុជ្ជន ហើយ ក៏បានទំលាក់ចោល ។ ប្រាសាទ ស្ថិតនៅហើយ ក្នុងទី ដើមនុ៎ះឯង មិនអន្តរធានហើយ រហូតដល់សព្វថ្ងៃនេះ ។ សួរថា "ព្រោះហេតុអ្វី ទើបមិនអន្តរធាន" ។ ឆ្លើយថា " ព្រោះអានុភាព នៃនឡការទេវបុត្រដែលកើតជាបិតា ក្នុងកាលមុន" ។ ក៏ទេវបុត្រ នោះ នឹងបានជាស្តេចចក្រពត្តិ ព្រះនាមសង្ខៈ ក្នុងអនាគតកាល, ប្រាសាទនោះ នឹងផុសឡើង ដើម្បីជារបស់ប្រើប្រាស់ របស់ព្រះ អង្គ, ព្រោះហេតុនោះ ប្រាសាទនោះ ទើបមិនបានអន្តរធាន " ។

បន្ទាប់ពីនេះទៅ គប្បីញុំាងពាក្យ ដែលលោកពោលហើយ ក្នុងចក្កវត្តិសូត្រ ព្រមទាំងអដ្ឋកថា ឲ្យពិស្តារ ។

ចំណែកសេចក្តីសង្ខេប ក្នុងរឿងនេះ មានដូចតទៅនេះ ៖

ព្រះរាជាអង្គនោះ នឹងទ្រង់គ្រប់គ្រងប្រាសាទនោះ ទ្រង់ ជ្រាបថា ព្រះមានព្រះភាគ ទ្រង់ព្រះនាមមេត្តេយ្យ ស្តេចកើតឡើង ហើយ ទ្រង់មានព្រះបំណង ចង់ព្រះរាជទានប្រាសាទនោះហើយ ទើបទ្រង់ព្រះផ្នួស ទ្រង់ញុំាងព្រះទ័យ ឲ្យកើតឡើងថា " ប្រាសាទ នេះ ចូរខ្ចាត់ខ្ចាយទៅចុះ " ។ ប្រាសាទនោះ នឹងខ្ចាត់ខ្ចាយទៅជា កំណាត់តូច-ធំ ។ ព្រះរាជា ទ្រង់មិនមានព្រះទ័យជាប់ជំពាក់ នឹងប្រាសាទនោះឡើយ នឹងទ្រង់ប្រកាសថា " បុគ្គលណា ប្រាថ្នា

ប៉ុន្មាន, បុគ្គលនោះ ចូរប្រមូលយកប៉ុណ្ណោះចុះ " ដូច្នេះហើយ ទ្រង់ព្រះរាជទាន ដល់សមណៈព្រាហ្មណ៍ មនុស្សកំព្រា មនុស្សដើរផ្លូវ វណិព្វក: និង យាចកទាំងឡាយ ទ្រង់ផ្ចឹស ក្នុងសំណាក់នៃព្រះមានព្រះភាគព្រះនាមមេត្តេយ្យហើយ ទ្រង់បានសម្រេចព្រះអរហត្ត ដូច្នេះឯង ។

រឿងជាងត្បាញផែង មកក្នុងអដ្ឋកថាសុរុចិជាតក ក្នុងបកិណ្ណកនិបាត ក្នុងអដ្ឋកថាមហាបនាទជាតក និង ក្នុងអដ្ឋកថាចក្កវត្តិសូត្រ ។

(១៤២) ចំណែកសិប្បៈនៃការផ្ចាត់គ្រាប់ក្រួសដែលបុគ្គលប្រកបហើយ ក្នុងហាន: ក៏ចាត់ថាជាមង្គល, ដែលបុគ្គលប្រកបហើយ ក្នុងទីមិនមែនជាហាន: មិនចាត់ថា ជាមង្គលឡើយ ។

រឿងដែលសំដែងនូវសេចក្តីនោះ មានដូចតទៅនេះ ៖

(រឿង បុរសខ្វិន ផ្ចាត់គ្រាប់ក្រួស)

ក្នុងអតីតកាល ក្នុងក្រុងពារាណសី មានបុរសខ្វិនម្នាក់ ជាអ្នកឆ្លាតក្នុងសិប្បៈផ្ចាត់គ្រាប់ក្រួស ។ ពួកក្មេងអ្នកស្រុក លើកបុរសខ្វិននោះ ទៅដាក់លើរថហើយ បាននាំទៅកាន់ដើមជ្រៃធំ ដែលស្ថិតនៅក្បែរមាត់ទ្វារព្រះនគរហើយ ឲ្យទ្រព្យមានមួយកាកណិក ជាដើម ហើយពោលថា " ចូរអ្នកធ្វើរូបដំរី, ចូរអ្នកធ្វើរូបសេះ " ។

មង្គលត្ថទីបនីប្រែ

បុរសទ្វិននោះ ផ្ចាត់គ្រាប់ក្រួស សំដែងរូបផ្សេង ៗ លើស្ទឹកដៃទាំងឡាយ ។ ព្រះរាជា កាលទ្រង់ស្តេចយាងទៅព្រះឧទ្យាន ទ្រង់ស្តេចយាងទៅដល់ទីនោះហើយ ។ ពួកក្មេង ៗ បានរត់ចេញទៅគ្រប់គ្នាហើយ ព្រោះខ្លាចចំពោះការត្រួតត្រា ។ បុរសទ្វិន បានដេកនៅ ក្នុងចន្ទោះក្រោមដើមដៃ ។ ព្រះរាជា ទ្រង់ទតឃើញស្ទឹកឈើទាំងឡាយ មានប្រហោង ទើបទ្រង់ត្រាស់សួរថា " ស្ទឹកឈើទាំងឡាយនេះ តើអ្នកណាធ្វើហើយ យ៉ាងនេះ " ។ ពួកអាជ-បុរសបានក្រាបទូលថា " បពិត្រព្រះសម្មតិទេព បុរសទ្វិនបានធ្វើហើយ " ។ ព្រះរាជា ទ្រង់ត្រាស់បញ្ជា ឲ្យហៅបុរសទ្វិននោះមកហើយ ទ្រង់ត្រាស់សួរថា " នែអ្នក បុរោហិត របស់យើង ជាអ្នកមាត់រឹង ជាអ្នកនិយាយច្រើន, បើបុរោហិតនោះ ផ្តើមនិយាយឡើង, អ្នកជាទៃមិនបានឱកាសឡើយ, តើអ្នកអាច ដើម្បីទីងធ្វើឲ្យបុរសនោះ ស្ងាត់សំឡេងបានឬទេ " ។ បុរសទ្វិននោះ ក្រាបទូលថា " បពិត្រព្រះសម្មតិទេព កាលបើទូលព្រះបង្គំបាន នូវអាចម៍ពពែ ប្រមាណ ១ នាឡិ នឹងអាចធ្វើបាន " ។ ព្រះរាជា ទ្រង់នាំនូវបុរសនោះ ទៅកាន់ព្រះដំណាក់ហើយ ទ្រង់បានឲ្យគាត់អង្គុយ ខាងក្នុងវាំងនន ទ្រង់ត្រាស់ឲ្យធ្វើប្រហោងវាំងននហើយ ទ្រង់ត្រាស់ ឲ្យដាក់អាចម៍ពពែស្ងួត ប្រមាណ ១ នាឡិ នៅក្បែរ

ពណ៌នាអំពីសិល្បៈ

បុរសខ្វិននោះ ទ្រង់គ្រាស់ឲ្យក្រាលអាសនៈ ដល់បុរោហិត មានមុខត្រង់ប្រហោង ទ្រង់ឲ្យបុរោហិតនោះ ដែលមកហើយ ក្នុងពេលឧបដ្ឋាក អង្គុយហើយ លើអាសនៈនោះ ទ្រង់បានគ្រាស់សន្ទនាហើយ ។ បុរោហិត មិនផ្តល់ឱកាស ដល់អ្នកណាមួយឡើយ ផ្តើមសន្ទនា ជាមួយនឹងព្រះរាជាហើយ ។

គ្រានោះ បុរសខ្វិន បានផាត់អាចម៍ពពែ ម្តងមួយគ្រាប់ ៗ ចូលទៅក្នុងមាត់ របស់បុរោហិតនោះ ។ បុរោហិត ក៏លេបអាចម៍ពពែដែលមកហើយ ៗ ដូចជានំបង់ល្ង ។ ឯអាចម៍ពពែទាំងអស់ក៏បានអស់ហើយ ។ ព្រះរាជា ទ្រង់ជ្រាបថា អាចម៍ពពែទាំងនោះអស់ហើយ ទើបគ្រាស់ថា “ នែអាចារ្យ ព្រោះខ្លួនលោក ជាអ្នកមាត់រឹង សូម្បីលោកលេបអាចម៍ពពែ មានប្រមាណមួយនាឡិក៏មិនដឹងអ្វីបន្តិចឡើយ, ក៏ឥឡូវនេះ លោកអាចារ្យ នឹងមិនអាចញុំាងអាមច៍ពពែដែលច្រើនជាងនោះ ឲ្យរលាយបានឡើយ, ចូរលោកអាចារ្យអញ្ជើញទៅចុះ ចូរពិសាទឹកប្រយង្គ សម្រកចេញហើយធ្វើខ្លួនកុំឲ្យមានរោគចុះ ” ។ តាំងពីពេលនោះមក បុរោហិតនោះ ដូចជាបិទមាត់ជិតហើយ ជាអ្នកមិនសូវសន្ទនាជាប្រក្រតីជាមួយព្រះរាជា សូម្បីទ្រង់គ្រាស់រកក៏ដោយ ។ ព្រះរាជា ទ្រង់ព្រះតម្រិះថា “ បុរសខ្វិននោះ ធ្វើឲ្យអាត្មាអញ សប្បាយត្រចៀក

ហើយ " យ៉ាងដូច្នេះ ទ្រង់បានព្រះរាជទានហើយ នូវស្រុកសួយ ៤ កន្លែង ក្នុងទិសទាំង ៤ ដែលមានសួយសារអាករឡើង ១ សែន ដល់បុរសខ្វិន ។

ក្នុងគ្រានោះ អាមាត្យជាបណ្ឌិតម្នាក់ ចូលទៅគាល់ព្រះរាជាហើយ ក្រាបទូលថា " បពិត្រព្រះសម្មតិទេព ធម្មតាសិប្បៈក្នុងលោក ពួកបណ្ឌិតត្រូវសិក្សា, សូម្បីដោយសិល្បៈត្រឹមតែការផ្ចាត់គ្រាប់ក្រួស ក៏បុរសខ្វិន បានសម្បត្តិយ៉ាងនោះទៅហើយ, ឪ កំណត់អានិសង្សនៃសិល្បៈទាំងឡាយ ដូចម្តេចបាន" ដូច្នេះហើយ កាលសំដែងគុណនៃសិល្បសាស្ត្រ ទើបបានពោលគាថានេះ ថា៖

> ធម្មតាសិល្បសាស្ត្រ យ៉ាងណាក៏ដោយ សុទ្ធតែ [1] សម្រេបប្រយោជន៍ពិត, សូមព្រះអង្គ ទ្រង់ទតព្រះនេត្រមើលបុះស្រុកសួយទាំង ៤ ទិស ដែលបុរសខ្វិនបានហើយ ដោយការផ្ចាត់អាបម៌ពពៃ ។

*បណ្តាបទទាំងនោះ បទថា " **បស្ស** " មានសេចក្តីថា បពិត្រព្រះមហារាជ សូមព្រះអង្គ ទ្រង់ទតមើលចុះ ។ បទថា " **អជប្បហារេន** " មានសេចក្តីថា អាមាត្យនោះ ពោលនូវគុណនៃសិល្បសាស្ត្រថា "ស្រុកសួយ ៤ ទាំង ៤ ទិស គឺបុរសខ្វិន*

๑- សុត្តន្តបិដក ភាគទី ៥៨ ទំព័រទី ៤៨ ។

បានហើយ ដោយការផ្ចាត់អាចម៍ពពែ, និងកំណត់រាប់អានិសង្ស នៃសិល្បសាស្ត្រទាំងឡាយសូម្បីដទៃទៀត យ៉ាងដូចម្តេចបាន" ។

រឿង បុរសទ្វិន ចប់ ។

(រឿង ភិក្ខុសម្លាប់ហង្ស)

(១៤៣) បុរសទ្វិននោះឯង ឥឡូវនេះ កើតជាកុលបុត្រ ដែលធ្លាត ក្នុងសិល្បៈផ្ចាត់ក្រួសនុ៎ះឯង ក្នុងក្រុងសាវត្ថី ក្នុងថ្ងៃមួយ បានស្តាប់ព្រះធម៌ហើយ ក៏បានបព្វជ្ជាឧបសម្បទ ។ ថ្ងៃមួយ ភិក្ខុនោះ បាននាំភិក្ខុកំលោះ ១ រូប ទៅកាន់ស្ទឹងអចិរវតី ស្រង់ទឹកហើយ ក៏បានឈរនៅ ក្បែរមាត់ស្ទឹង ។

ក្នុងខណៈនោះឯង សត្វហង្ស ២ ហើរទៅ ឰដ៏អាកាស ។ ភិក្ខុនោះ ពោលនឹងភិក្ខុកំលោះនោះ ថា " ខ្ញុំ នឹងយកក្រួសប្រហារហង្សដែលនៅក្រោយនោះ ត្រង់ក្អែកហើយ ធ្វើឲ្យធ្លាក់នៅក្បែរជើង " ។ ភិក្ខុកំលោះក្រៅនេះ ពោលថា "លោកនឹងមិនអាច" ។ ភិក្ខុនោះ ពោលថា "បើដូច្នោះ ចូរអ្នកចាំមើលចុះ" ហើយ បានផ្ចាត់ក្រួស ១ គ្រាប់ រាង ៣ ជ្រុង ទៅខាងក្រោយហង្សនោះ ។ គ្រាប់ក្រួស បានធ្វើសំឡេង " វុង ៗ " ។ ហង្ស បានងាកមកក្រឡេកមើលហើយ ។ ក្នុងខណៈនោះឯង ភិក្ខុនោះ ក៏ផ្ចាត់គ្រាប់ក្រួសមួល ១ គ្រាប់ទៅត្រង់ក្អែកម្ខាងទៀត របស់ហង្សដែលកំពុង

តែងាកមកក្រឡេកមើលនោះ ។ គ្រាប់ក្រួស បានទម្លុះភ្នែកម្ខាង ទៀតជ្រាយទៅហើយ ។ ហង្ស ស្រែកយ៉ាងខ្លាំង ធ្លាក់ហើយក្បែរជើងនុ៎ះឯង ។ ពួកកិក្ខុ ជឹងសេចក្តីនោះហើយ ក៏បានក្រាបទូលដល់ព្រះសាស្តា ។ ព្រះសាស្តា ទ្រង់តិះដៀលកិក្ខុនោះ ដោយអនេកបរិយាយ ។

រឿង កិក្ខុសម្លាប់សត្វហង្ស មកក្នុងអដ្ឋកថាសាលិត្តកជាតក ។

(រឿង សង្ខ្លីកូដប្រែត)

(១៤៤) បុរសម្នាក់ រៀនសិល្បសាស្ត្រនោះ ក្នុងសំណាក់របស់បុរសទ្វិននោះដូចគ្នាដែរ ។ គ្រានោះ បុរសទ្វិន ប្រាប់បុរសនោះ ថា " នែអ្នក អ្នកកាលសាកល្បងសិល្បៈ ចូរត្រួតមើលបុគ្គលណាមួយ ដែលមិនមានម្តាយនិងឪពុក កាលបើអ្នកប្រហារហើយ នឹងមិនមានពិន័យ ព្រោះបើអ្នកសម្លាប់គោ នឹងត្រូវជាក់ពិន័យ ១០០ បើសម្លាប់មនុស្ស ក៏នឹងត្រូវជាក់ពិន័យ ១ ពាន់នោះចុះ " ។ បុរសនោះ វេចគ្រាប់ក្រួសជាក់ក្នុងថ្នក់ កាលត្រួតមើលបុគ្គលបែបនោះ ថ្ងៃមួយ បានឃើញព្រះបច្ចេកពុទ្ធ ព្រះនាមសុនេត្ត កំពុងយាងទៅ កាន់ព្រះនគរ ដើម្បីទ្រង់បិណ្ឌបាត ទើបគិតថា " ព្រះបច្ចេកពុទ្ធអង្គនេះ ជាអ្នកមិនមានមាតាបិតា " ដូច្នេះហើយ ទើបបានផ្ចាត់គ្រាប់ក្រួស សំដៅវន្តត្រចៀកខាងស្តាំ របស់

ព្រះបច្ចេកពុទ្ធអង្គនោះ ។ គ្រាប់ក្រួសចូលទៅហើយ ធ្លាយចេញ ទៅ តាមរន្ធត្រចៀកខាងឆ្វេង ។ ព្រះបច្ចេកពុទ្ធអង្គនោះ កើត ទុក្ខវេទនាហើយ កាលមិនអាចដើម្បីយាងទៅបិណ្ឌបាតបាន ទើប ទ្រង់ហោះទៅតាមអាកាស ទ្រង់បរិនិព្វានហើយ ក្នុងបណ្ណសាលា របស់ព្រះអង្គ ។

ពួកមនុស្ស ក្នុងគោចរគ្រាម ដឹងថា ព្រះបច្ចេកពុទ្ធអង្គនោះ មិនយាងមក ទើបគិត ថា " ការមិនសប្បាយអ្វី ។ គង់នឹងមាន " ដូច្នេះ ក៏បានទៅ ក្នុងទីនោះ ឃើញព្រះបច្ចេកពុទ្ធអង្គនោះ ទ្រង់ បរិនិព្វាន ទើបខ្សឹកខ្សួលហើយ ។ បុរសអាក្រក់នោះឯង ចាំព្រះ បច្ចេកពុទ្ធអង្គនោះបាន ក្នុងទីនោះ ទើបពោលថា " ខ្ញុំ កាលសាក ល្បងមើល នូវសិល្បៈរបស់ខ្លួន បានប្រហារ នូវព្រះបច្ចេកពុទ្ធ អង្គនោះហើយ " ។ ពួកមនុស្ស ស្តាប់ពាក្យនោះហើយ ក៏បាន វាយបុរសអាក្រក់នោះ ឲ្យស្លាប់ហើយ ។ បុរសអាក្រក់នោះ ឆេះ ហើយ ក្នុងអវិចីនរក រហូតដល់ផែនដីនេះ ដុះឡើងបាន ប្រមាណ ១ យោជន៍ ក៏បានកើតជាសដ្ឋិកូដប្រេត លើភ្នំគិជ្ឈកូដ ដោយ ផលកម្មដែលសេសសល់, សរីរៈ របស់ប្រេតនោះ កំពស់ ៣ គាវុត, ដៃកញ្ជ្រោ ៦ ម៉ឺន ត្រូវភ្លើងឆេះ សន្ធោសន្ធៅហើយ បាន ដំហើយដំទៀត លើអំបែងក្បាលប្រេតនោះ ទំលាយក្បាលហើយ,

មង្គលត្ថទីបនីប្រែ

ក្បាលដែលបែកហើយ ៗ ក៏ត្រឡប់កើតឡើងជាថ្មីទៀត ។

រឿង សដ្ឋីកូដប្រេត មកក្នុងពាលវគ្គ នៃធម្មបទ ។

(១៤៥) ម៉្យាងទៀត ក្នុងគម្ពីរសុទ្ធវគ្គជីកាជាដើម សូម្បីជាងចាំង ក៏លោកហៅថា "អ្នកមានសិល្បៈ" យ៉ាងដូច្នេះ ថា ៖

ជាងចាំង ជាងតម្បាញ ជាងជ្រលក់ ជាងកាត់សក់ ជាងសែ្បក ជាគម្រប់ ៥ លោកហៅថា ជាងអ្នកមានសិល្បៈ ។

មែនពិត ជាងចាំងជាដើម លោកហៅថា " ជាង " ព្រោះអត្ថថា " តែងធ្វើ គឺ ស្ថាបនា នូវរបស់ដែលគួរស្ថាបនា មានកិច្ចការ របស់ជាងចាំងជាដើម " និង លោកហៅថា " អ្នកមានសិល្បៈ " ព្រោះអត្ថថា " ជនទាំងឡាយនោះ មានសិល្បៈ " ដូច្នេះ, ព្រោះហេតុនោះ សូម្បីការងារបស់ជាងចាំង ក៏ឈ្មោះថាជាសិល្បៈដែរ ។ មែនពិតសូម្បីសិល្បៈនោះ ក៏ចាត់ថា ជាមង្គលដែរ ព្រោះជាហេតុនាំមកនូវប្រយោជន៍ ។

ក្នុងដំណើរនោះ មានរឿងទាំងនេះ (ជាឧទាហរណ៍) ៖

(រឿង ព្រះបាទ កដ្ឋវាហនៈ ទី ១)

(១៤៦) ព្រះរាជកុមារ ដែលជាព្រះរាជបុត្រ នៃព្រះបាទពិម្ពិសារ ទ្រង់ព្រះនាមថារោធិ ទ្រង់ត្រាស់បញ្ជាឲ្យសាងប្រាសាទ ឈ្មោះថា កោកនទ មានរូបរាង មិនដូចប្រាសាទទាំងឡាយ ដទៃ

ពណ៌នាអំពីសិល្បៈ

ទៀត ក្នុងផ្ទៃនៃប្រឹថពី ប្រៀបដូចជាអណ្តែត ឰដ៏អាកាស ទ្រង់ត្រាស់សួរនូវជាង៥ថា " ប្រាសាទបែបនេះ តើអ្នកធ្លាប់បានធ្វើមកឬទេ, ឬក៏ នេះជាសិល្បៈលើក ទី ១ បង្អស់ របស់អ្នក " ។

ជាង៥នោះ ក្រាបទូលថា " បពិត្រព្រះសម្មតិទេព នេះ គឺជាសិល្បៈ លើក ទី ១ របស់ទូលព្រះបង្គំមែនពិត " ។

ព្រះរាជកុមារ ទ្រង់ព្រះតម្រិះ ថា " បើជាង៥នេះ និងកសាងនូវប្រាសាទបែបនេះ ដល់ជនដទៃទៀត, ប្រាសាទនេះ ក៏និងមិនក្លាយជារបស់ដែលអស្ចារ្យ, ការដែលអាត្មាអញ សម្លាប់ជាង៥នេះចោល ឬ កាត់ដៃ និង ជើង របស់ជាង៥នេះ ឬក៏ ខ្ទេះភ្នែកទាំង៥គូ របស់គាត់ចោល ទើបគួរ " ដូច្នេះហើយ ទើបទ្រង់ត្រាស់ប្រាប់រឿង៥នោះ ដល់មាណព ឈ្មោះសញ្ជិកាបុត្តិ ដែលជាសំឡាញ់ជាទីស្រឡាញ់ របស់ព្រះអង្គ ។ មាណព គិតថា " បុគ្គលអ្នកមានសិល្បៈជាអ្នករកតម្លៃជាក់គ្មាន, កាលបើអាត្មាអញឃើញ, ជាង៥នេះចូរកុំវិនាសឡើយ " ដូច្នេះហើយ ក៏បានឲ្យសញ្ញាដល់ជាង ។ ជាង៥ពោលថា " បពិត្រលោកចៅហ្វាយ លោកកាលប្រាប់ដល់ខ្ញុំឈ្មោះថា បានធ្វើកិច្ចល្អហើយ, ខ្ញុំបាន៥ជីង៥នូវកិច្ច ដែលខ្ញុំបានគប្បីធ្វើ ក្នុងរឿង៥នេះ " ។

ក្រោយមក ថ្ងៃមួយ ព្រះរាជកុមារ ទ្រង់ត្រាស់សួរថា " តើ

កិច្ចការកសាង ជ្រាសាទ បានសម្រេចហើយឬនៅ" ។

ជាង. បពិត្រព្រះសម្មតិទេព មិនទាន់សម្រេចទេ, កិច្ចការមាននៅសេសសល់ជាច្រើនទៀត ។

ព្រះរាជកុមារ. តើកិច្ចការ ឈ្មោះអ្វីខ្លះ ដែលនៅសល់ ។

ជាង. បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំ នឹងក្រាបទូលនៅពេលក្រោយ, សូមព្រះអង្គ ទ្រង់ត្រាស់បញ្ជា ឲ្យរាជបុរសនាំយកឈើស្ងួតទាំងឡាយ ដែលមិនមានខ្វិមមកជាមុនសិនចុះ ។

ព្រះរាជា ទ្រង់ត្រាស់បញ្ជាឲ្យរាជបុរស នាំយកឈើទាំងនោះមកហើយ ។

គ្រានោះ ជាង ក៏បានក្រាបទូលព្រះរាជកុមារអង្គនោះ ថា "បពិត្រព្រះសម្មតិទេព ចាប់តាំងពីថ្ងៃនេះទៅ អ្នកណា ក៏មិនគួរមកកាន់សំណាក់ នៃទូលព្រះបង្គំទ្បើយ, ព្រោះថា កាលបើទូលព្រះបង្គំកំពុងធ្វើការងារដ៏ប្រណីត កាលនិយាយ ជាមួយនឹងអ្នកណាម្នាក់, សេចក្តីរាយមាយចិត្តក៏នឹងមាន, តែក្នុងពេលបរិភោគអាហារ ភរិយានៃទូលព្រះបង្គំប៉ុណ្ណោះ នឹងនាំយកអាហារមក" ។

ព្រះរាជកុមារនោះ ទ្រង់ត្រាស់ ថា " ល្អហើយ " ហើយទ្រង់ជាក់ការរក្សា ទ្បោមជុំវិញផ្ទះ ដើម្បីប្រយោជន៍កុំឲ្យជាងនោះរត់ចេញទៅបាន ។ ចំណែក ជាងអង្គុយ ក្នុងបន្ទប់ ចាំងឈើទាំង

ពណ៌នាអំពីសិល្បៈ

នោះ ធ្វើជាសត្វគ្រុឌហើយ ប្រាប់ភរិយាដែលមកហើយ ក្នុងពេលអាហារថា " នែនាងដ៏ចំរើន ចូរអូនលក់របស់របរទាំងអស់ដែលមាននៅ ក្នុងផ្ទះហើយយកប្រាក់និងមាសទុក " ដូច្នេះ ក្នុងពេលដែលសត្វគ្រុឌសម្រេចហើយ ទើបប្រាប់ថា "ក្នុងថ្ងៃនេះ អូនគប្បីនាំយកកូនទាំងអស់មក " ។ ភរិយានោះ បានធ្វើហើយ យ៉ាងដូច្នោះ ។ នាយជាងនោះ ជាអ្នកបរិភោគអាហារពេលព្រឹកហើយ ព្រមទាំងបុត្រ និង ភរិយា អង្គុយ ក្នុងពោះនៃសត្វ រត់ចេញទៅតាមបង្អួចហើយ ចុះ ក្នុងព្រៃហិមពាន្ត កសាងព្រះនគរហើយ គ្រប់គ្រងរាជសម្បត្តិ ក្នុងទីនោះ ក៏បានទ្បើងជាព្រះរាជា ទ្រង់ព្រះនាមថា កដ្ឋវាហនៈ ។

រឿង ព្រះបាទកដ្ឋវាហនៈ មកក្នុងអត្តវគ្គ នៃធម្មបទ ។

(រឿង ព្រះបាទកដ្ឋវាហនៈ ទី ២)

(១៤៧) ក្នុងអតីតកាល ក្នុងក្រុងពារាណសី មានជាងឈើ ម្នាក់ មិនមានសិស្ស ទី ២ ក្នុងបុគ្គលជាអាចារ្យរបស់ខ្លួន ។ ជាងឈើនោះ មានកូនសិស្ស ១៦ នាក់ ។ ក្នុងកូនសិស្ស ១៦ នាក់នោះ កូនសិស្សម្នាក់ ៗ មានអន្តេវាសិស្ស ១ ពាន់នាក់ ។ បុគ្គលទាំងអស់នោះ មានប្រមាណ ១៦,០១៧ ដោយប្រការដូច្នេះ ។ ជាងឈើទាំងនោះ ទៅព្រៃហើយ ធ្វើប្រាសាទផ្សែង ។

មង្គលត្ថទីបនីប្រែ

ច្រើនបែប ក្នុងទីនោះ ចង់ក្បួន នាំមកកាន់ក្រុងពារាណសី តាមទន្ទេគង្គា ហើយលក់ចិញ្ចឹមជីវិត ។

ក្នុងថ្ងៃមួយ ពួកជាងឈើទាំងនោះ ក៏ប្រឹក្សាគ្នាថា " ពួកយើង មិនអាចដើម្បីនឹងចិញ្ចឹមជីវិត ជាប់ជានិច្ច ដោយការងារជាងឈើបានឡើយ, ព្រោះកិច្ចនោះ ក្នុងពេលដែលយើងចាស់ជរា ជាកិច្ចការ ដែលធ្វើបានដោយលំបាក " ដូច្នេះហើយ ទើបយកឈើដែលគ្មានខ្វិម មានដើមខុទុម្ពរជាដើម ធ្វើជាសត្វហើយ ក៏បានចូលទៅ ខាងក្នុងសត្វទាំងនោះ ព្រមទាំងបុត្រ និង ភរិយា ហោះទៅ កាន់ហិមវន្តប្រទេស ទទួលយកពាជសម្បត្តិ ក្នុងនគរក្នុងព្រៃនោះ ។

គ្រានោះ សិស្សទាំង ១៦ នាក់នោះ អភិសេកអាចារ្យ ក្នុងរាជសម្បត្តិហើយ ខ្លួនឯងក៏បានស្ថិតនៅ ក្នុងតំណែងនៃអមាត្យ ។ ព្រះរាជានោះ ទ្រង់ប្រោកជថា " ព្រះរាជាព្រះនាមកដ្ឋវាហនៈ " ។ សូម្បីព្រះនគរនោះ ក៏ប្រោកជឈ្មោះថា កដ្ឋវាហនៈដែរ ព្រោះជាព្រះនគរ ដែលព្រះអង្គទ្រង់ទទួលយកហើយ, សូម្បីរដ្ឋទាំងមូលក៏មានឈ្មោះ យ៉ាងដូច្នោះដែរ ។

ក្នុងចំណោរកាលក្រោយមក ព្រះបាទកដ្ឋវាហនៈ ទ្រង់ព្រះសណ្តាប់ ថា ព្រះពុទ្ធព្រះនាមកស្សបៈ ទ្រង់ស្តេចកើតឡើងហើយ

ពណ៌នាអំពីសិល្បៈ

ទើបទ្រង់បានបញ្ជូនពួកអមាត្យធំ ៗ ១៦ នាក់ ព្រមទាំងបរិវារទៅ ដោយព្រះតម្រាស់ថា " នែអ្នកទាំងឡាយ ចូរពួកអ្នកអញ្ជើញទៅ ចូរជីងនូវរឿងរ៉ាវ " ។ ពួកអមាត្យទាំងនោះ កាលទៅ បានក្រាបទូលថា " បើព្រះពុទ្ធ ទ្រង់កើតឡើងហើយ, ពួកទូលព្រះបង្គំ នឹងមិនត្រឡប់មកទេ, បើព្រះពុទ្ធ មិនបានកើតឡើងហើយ, ពួកទូលព្រះបង្គំ នឹងត្រឡប់មកវិញ " ។

គ្រានោះ ព្រះរាជា ទ្រង់ត្រាស់នឹងអមាត្យម្នាក់ ដែលរាប់ចូល ក្នុងអាមាត្យទាំង ១៦ នាក់ ដែលជាព្រះភាគិនេយ្យៈ របស់ព្រះអង្គថា " នែអ្នក ចូរអ្នកត្រឡប់មកវិញ ជ្រាប់យើងផង " ។ អមាត្យនោះបានទទួលព្រះរាជឱង្ការថា "ព្រះករុណាថ្លៃវិសេស" ។ អមាត្យទាំងអស់នោះ បានទៅដល់ក្រុងពារាណសី ដោយការដេកផ្លូវតែមួយរាត្រីគត់ ក្នុងទីទាំងពួង ។ តែកាលបើអមាត្យទាំងនោះទៅដល់ហើយ, ព្រះសាស្តា ទ្រង់បរិនិព្វានហើយ ។ ពួកអមាត្យទាំងនេះ ខ្សឹកខ្សួលថា " មិនគួរបើសោះ ពួកយើងមក អស់រយៈផ្លូវដ៏ឆ្ងាយ មិនបានហើយសូម្បីនូវហេតុត្រឹមតែការឃើញ" ដូច្នេះ ជាអ្នកមានបំណងចង់ធ្វើនូវឱវាទ ដែលព្រះសាស្តា ទ្រង់ប្រទានហើយ លើកលែងតែអមាត្យ ដែលជាព្រះភាគិនេយ្យនោះចេញហើយ គ្រប់គ្នាទាំងអស់ បានបួសហើយ ។ ចំណែក អមាត្យ ជា

មង្គលត្ថទីបនីប្រែ

ព្រះភាគិនេយ្យៈ បានទទួលយកព្រះបរិភោគជាតុពោលគឺធម្មក្រក របស់ព្រះសាស្តា និង ព្រះថេរៈ ១ រូប ទៅកាន់រដ្ឋកដ្ឋវាហនៈ ។

ព្រះរាជា ទ្រង់ព្រះសណ្តាប់ធម៌របស់ព្រះថេរៈហើយ ទ្រង់ត្រាស់ឲ្យកសាង់ព្រះវិហារ ទ្រង់ឲ្យប្រតិស្ថានព្រះចេតិយហើយ ទ្រង់បំពេញបុណ្យមានទានជាដើម ទ្រង់ស្ថិតនៅ រហូតដល់អស់ព្រះជន្មាយុហើយ ទ្រង់បានទៅកើត ក្នុងទេវលោក ។ ចំណែកឯអមាត្យ ដែលបានបួសហើយទាំងនោះ លុះធ្វើកាលកិរិយាហើយ ក៏បានជាបរិវារបស់ព្រះរាជាអង្គនោះឯង ។ ពួកទេវបុត្រទាំងនោះ ញុាំងពុទ្ធន្តរមួយ ឲ្យអស់ហើយ ក្នុងទេវលោកទាំងឡាយ, កាលបើព្រះសាស្តា របស់ពួកយើង មិនទាន់កើតឡើងនុ៎ះឯង, ច្យុតហើយចាកទេវលោក ។ បណ្តាទេវបុត្រទាំងនោះ ទេវបុត្រដែលជាអាចារ្យ កើតហើយក្នុងត្រកូលនៃបុរោហិត របស់ព្រះរាជាទ្រង់ព្រះនាមមហាកោសល ។ កុមារនោះ មានឈ្មោះថា “ ពាវរី ” ។ ទេវបុត្រ ដែលសេសសល់ទាំងឡាយ កើតហើយ ក្នុងត្រកូលព្រាហ្មណ៍ ក្នុងទីក្រុងសាវត្ថី ។ បណ្តាជនទាំងនោះ ក្នុងគ្រាដំបូងអន្តេវាសិកដែលធំជាងគេ ១៦ នាក់ បានសិក្សានូវសិល្បសាស្ត្រក្នុងសំណាក់នៃព្រាហ្មណ៍ពាវរី ។ ពួកអន្តេវាសិក ដទៃទៀត បានសិក្សាសិល្បសាស្ត្រ ក្នុងសំណាក់ នៃអន្តេវាសិក ដែលធំជាងគេ

ពណ៌នាអំពីសិល្បៈ

ទាំង ១៦ នាក់ ។

ក្នុងកាលនោះ ព្រះរាជា ទ្រង់ព្រះនាម មហាកោសល ទ្រង់បានសោយទិវង្គតហើយ ។ ព្រះរាជាកុមារព្រះនាមបសេនទិ ទ្រង់ឡើងជាព្រះរាជា ទ្រង់បានព្រះរាជទាន នូវដំណែងដែលព្រះរាជបិតារបស់ព្រះអង្គ ទ្រង់ព្រះរាជទានហើយ និង ភោគៈផ្សេងទៀត ដល់ព្រាហ្មណ៍ពាវរីហើយ ។ បានឮថា ព្រះបាទសេនទិ-កុមារនោះ ទ្រង់បានសិក្សាសិល្បសាស្ត្រ ក្នុងសំណាក់ព្រាហ្មណ៍ពាវរី ក្នុងពេលដែលព្រះអង្គជាព្រះរាជកុមារ ។

ក្នុងពេលក្រោយមក ព្រាហ្មណ៍ពាវរី ក្រាបទូលសុំព្រះរាជានុញ្ញាត្តហើយ ព្រមទាំងសិស្សទាំងឡាយ បួសជាតាបសហើយទៅកាន់ឆ្នេរស៊ីងគោធាវរី ដោយលំដាប់ អាស្រ័យនៅ ក្នុងទីនោះហើយ បានចិញ្ចឹមជីវិត ដោយផលាផល ។ កាលបើព្រាហ្មណ៍ពាវរី កំពុងនៅក្នុងទីនោះ, ព្រះសាស្តានៃពួកយើង ទ្រង់ស្តេចកើតឡើងហើយ ក្នុងលោក ។ ក្រោយមក ព្រាហ្មណ៍ពាវរីនោះ បានស្តាប់នូវការកើតឡើងនៃព្រះពុទ្ធ ទើបបានបញ្ជូនពួកអន្តេវាសិក ជាចម្បង ១៦ នាក់ ព្រមទាំងបរិវារទាំងអស់ ទៅដោយន័យមុនន៏ុះឯង ។ ពួកអន្តេវាសិកទាំងនោះ ទៅហើយ បានស្តាប់ទេសនា របស់ព្រះសាស្តា ក៏បានសម្រេចព្រះអរហត្ត ព្រម

ទាំងបដិសម្ភិទាទាំង៤ឋាយ ហើយបានសម្រេចជាឯហិកិក្ខុ លើកលែងតែមាណព ឈ្មោះបិង្គិយៈ ចេញ ដោយនយដែលលោកពោលហើយ ក្នុងបាពយនវគ្គ ក្នុងទីបំផុត នៃសុត្តនិបាត ។ ក៏បិង្គិយមាណពនោះ ជាកូនក្មួយរបស់ព្រាហ្មណ៍ពាវរី រាប់ចូលក្នុងអន្តេវាសិក ជាចម្បង ១៦ នាក់ គិតថា “ លោកអុំ របស់ពួកយើង៥ មិនបានស្តាប់ទេសនា ដ៏ពីរោះចាប់ចិត្ត យ៉ាងនេះឡើយ ” ដូច្នេះហើយ ព្រោះសេចក្តីរាយមាយចិត្ត ដោយអំណាចសេចក្តីស្រឡាញ់នោះ ទើបមិនអាចសម្រេច នូវព្រះអរហត្តបានទេ បានសម្រេច ត្រឹមតែ ព្រះអនាគាមី និង៥ ឯហិកិក្ខុ ហើយបានត្រឡប់មកវិញ ប្រាប់ការកើតឡើង៥នៃព្រះពុទ្ធ ដល់ព្រាហ្មណ៍ពាវរី បានអង្គុយពណ៌នាគុណនៃព្រះសាស្តា ។ ឯព្រាហ្មណ៍ពាវរី ក៏អង្គុយស្តាប់ការពណ៌នាគុណ នៃព្រះសាស្តានោះ ដូចគ្នាដែរ ។

ក្នុង៤ខណៈនោះ៥ឯង ព្រះសាស្តា ទ្រង់ជ្រាបនូវការចាស់ក្លានៃញាណ របស់អ្នក៤ទាំង ២ នោះហើយ ទ្រង់គង់នៅ ក្នុងទីក្រុងសាវត្ថី៤ឯង ទ្រង់បានបញ្ចេញហើយ នូវព្រះរស្មីដូចជាមាស ។ បិង្គិយៈ ឃើញព្រះរស្មីនោះហើយ គិតថា “ នេះជាអ្វីហ្ន៎ ” កាលក្រឡេកទៅ ក៏ឃើញព្រះសាស្តា ដូចជាទ្រង់គង់នៅ ចំពោះមុខនៃខ្លួន ទើបពោលថា “ព្រះសាស្តា ស្តេចយាង៤មកហើយ” ។

ពណ៌នាអំពីសិល្បៈ

ព្រាហ្មណ៍ពាវរី ក្រោកចាកអាសនៈហើយ បានឈរផ្គងអញ្ជលី ។ ព្រះសាស្តា ទ្រង់បញ្ចេញព្រះរស្មីទៅហើយ ទ្រង់សំដែងព្រះអង្គ ដល់ព្រាហ្មណ៍ពាវរី ទ្រង់សំដែងធម៌ដែលជាទីសប្បាយ ដល់អ្នក ទាំង ២ នាក់នោះហើយ ។

ក្នុងទីបញ្ចប់ទេសនា បិង្គិយៈ បានសម្រេចជាព្រះអរហន្ត, ព្រាហ្មណ៍ពាវរី បានសម្រេចជាព្រះអនាគាមី ។

រឿង ព្រះបាទអបរកជ្ជវាហនៈ មកក្នុងអដ្ឋកថាបាចយនវគ្គ ។

ការពណ៌នាអំពីសិល្បៈ ចប់ ។

(**មង្គលត្ថទីបនីប្រែ ភាគទី ១ ចប់តែប៉ុណ្ណេះ**)

សូមសិក្សាភាគ ទី២ បន្តទៀត

បានប្រែចប់ ថ្ងៃសុក្រ ១៥ កើត ខែមាឃ ឆ្នាំ ច ឆស័ក ព. ស. ២៥៣៧
ថ្ងៃទី ២៥ ខែ កុម្ភៈ ១៩៩៤

បានវាយចប់ឡើងវិញ នៅថ្ងៃ អង្គារ ទី០៥ ខែមិថុនា ២០១២
វេលាម៉ោង ២:២០ នាទី យប់

បានកែចប់ ថ្ងៃអាទិត្យ ១២ រោច ខែផល្គុន ព. ស. ២៥៥៧
ថ្ងៃទី០៧ ខែមេសា ២០១៣ ម៉ោង ១២:៣៤ យប់

♣ ❊ ♣

សៀវភៅ “**មង្គលត្ថទីបនីប្រែ**” ទាំង ៤ ភាគនេះ ខ្ញុំបានឱ្យ វាយបម្លង និង បានរៀបរៀងកែសម្រួលសាជាថ្មីម្តងទៀត នៅក្នុង ព. ស. ២៥៥៦-២៥៥៧ ដោយបានសហការគ្នា យ៉ាងសកម្ម ពីព្រះ សង្ឃជាច្រើនអង្គ ដូចមានរាយព្រះនាមខាងក្រោមនេះ ៖

មង្គលត្ថទីបនី ភាគទី ១ បានវាយបម្លងដោយ ភិក្ខុ អេប-ចាប បានបបរិប្ប្ូរ នៅថ្ងៃអង្គារ ៥ រោច ខែជេស្ឋ ឆ្នាំរោង បត្វាស័ក ព. ស. ២៥៥៦ ត្រូវនឹងថ្ងៃ ទី ០៥ ខែមិថុនា ឆ្នាំ ២០១២ ។

មង្គលត្ថទីបនី ភាគទី ២ បានវាយបម្លងដោយ ភិក្ខុ ផាង-សាន្ត និង ភិក្ខុ សុីន-សុខ បានបបរិប្ប្ូរ នៅថ្ងៃព្រហស្បតិ៍ ១ កើត ខែទុតិយាសាឍ ឆ្នាំរោង បត្វាស័ក ព. ស. ២៥៥៦ ត្រូវនឹងថ្ងៃ ទី ១៩ ខែកក្កដា ឆ្នាំ ២០១២ ។

មង្គលត្ថទីបនី ភាគទី ៣ បានវាយបម្លងដោយ ភិក្ខុ យន់-សុផា បានបបរិប្ប្ូរ នៅថ្ងៃពុធ ៤ កើត ខែភទ្របទ ឆ្នាំរោង បត្វាស័ក ព. ស. ២៥៥៦ ត្រូវនឹងថ្ងៃ ទី ១៩ ខែកញ្ញា ឆ្នាំ ២០១២ ។

មង្គលត្ថទីបនី ភាគទី ៤ បានវាយបម្លងដោយ ភិក្ខុ គុណ-សារីម បានបបរិប្ប្ូរ នៅថ្ងៃពុធ ៩ រោច ខែជេស្ឋ ឆ្នាំរោង បត្វាស័ក ព. ស. ២៥៥៦ ត្រូវនឹងថ្ងៃ ទី ១៣ ខែមិថុនា ឆ្នាំ ២០១២ ។

បំបាត់ការចងគំនុំ

សូមខេមរជនគ្រប់ៗ រូប ជួយនាំគ្នាស្តារ និង លើកស្ទួយនូវសាមគ្គីធម៌ ព្រហ្មវិហារធម៌ សច្ចធម៌ និង សង្គហធម៌ ដែលយើងធ្លាប់មានមក អំពីកាលមុន ជាយូរអង្វែងមកហើយ ឲ្យស្ថិតនៅជាប់ ក្នុងដួងចិត្ត របស់យើងគ្រប់ៗ គ្នា ឡើងវិញ ហើយនាំគ្នាកំ ចាត់ចោលនូវការចងក្រោធទុក ការចងកម្ម ចងពៀរវេរានឹងគ្នា ការចងគំនុំ គុំកួនគ្នា និង ការព្យាបាទបៀតបៀនដល់គ្នានឹងគ្នា មិនចេះឈប់ឈរ ឲ្យប្រាសចាកអំពីខន្ធសន្តានរបស់យើង ដើម្បី ទទួលយក នូវសេចក្តីសុខសន្តិភាព ទាំងផ្លូវកាយ-ចិត្ត ដ៏ពិតប្រាកដ តាមមាគ៌ា នៃព្រះពុទ្ធសាសនា ។

មែនពិត អំពើអាក្រក់ទាំងប៉ុន្មានខាងលើនេះ មិនដែលធ្វើឲ្យមនុស្សយើង បានចំរើនឡើយ គឺ មានតែធ្វើឲ្យមនុស្សយើងវិនាស ហិនហោច អន្តរធាន តែម៉្យាងប៉ុណ្ណោះឯង ។

ស្រលាញ់ជាតិ

អ្នកណា គោរពច្បាប់រដ្ឋ គោរពសុចរិត យុត្តិធម៌ និង គោរពសិទ្ធិសេរីភាព របស់ប្រជាជន មានព្រហ្មវិហារធម៌ ក្នុងចិត្ត ជាប់ជានិច្ច
អ្នកនោះ ទើបឈ្មោះថា ស្រលាញ់ជាតិ ពិតប្រាកដ ។

សៀវភៅមង្គលត្ថទីបនីប្រៃ ដែលព្រះតេជគុណ អស់លោក លោកស្រី ពុទ្ធបរិស័ទ កំពុងតែអាននៅនឹងដៃនេះ គឺជាស្នាព្រះហស្ត ប្រែនិងរៀបរៀង ដោយ ព្រះភិក្ខុវិនយធរោ មហាយិន ឡឿន ដែលគណៈកម្មការ ពុទ្ធិកវប្បធម៌អង្គការមូលនិធិវត្តបញ្ញាធំ បានទទួលយល់ព្រមយកទៅបោះពុម្ព ផ្សាយជាធម្មទាន ក្រោមការឧបត្ថម្ភបោះពុម្ពរបស់មូលនិធិពុទ្ធិកសិក្សានៅតៃវ៉ាន់ (The Corporate Body of the Buddha Educational Foundation) ។

ការទទួលយកទៅបោះពុម្ពផ្សាយជាធម្មទាននេះ ដោយអាស្រ័យលើការ មើលឃើញនូវកត្តាចាំបាច់មួយចំនួនដូចខាងក្រោម៖

- រក្សាស្នាដៃវប្បធម៌ព្រះពុទ្ធសាសនាឲ្យគង់វង្សស្ថិតស្ថេរ
- តម្រូវការរបស់សិក្ខាកាមអ្នកប្រាថ្នាចង់យល់ដឹងនូវខ្លឹមសារពុទ្ធសាសនា
- ផ្សាយនូវធម្មទាន ធ្វើឲ្យព្រះពុទ្ធសាសនាកាន់តែមានភាពរីកចម្រើនរុង-រឿងក្នុងលោក

MAHA PANNA VIHARA FOUNDATION ORGANIZATION
大般若寺基金會

ក្នុងករណីដែលលោកអ្នកអានបានប្រទះឃើញនូវសៀវភៅនេះមានជាក់លក់ នៅកន្លែងណា ឬបានឃើញនូវកំហុសឆ្គងណាមួយ ចង់ឲ្យយើងកែតម្រូវ ឬចង់បានសៀវភៅធម៌យកទៅអាន

សូមទាក់ទងមកយើងខ្ញុំតាមអាសយដ្ឋានដូចខាងក្រោម:

វត្តបញ្ញា សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

លេខទូរស័ព្ទ: (៨៥៥) ១២ ៩៦១ ៤២៩, (៨៥៥) ៨៨៧ ៩៦១ ៤២៩

អ៊ីមែល: maha.panna@gmail.com

គេហទំព័រ: http://www.mahapanna.org

"Wherever the Buddha's teachings have flourished,

either in cities or countrysides,

people would gain inconceivable benefits.

The land and people would be enveloped in peace.

The sun and moon will shine clear and bright.

Wind and rain would appear accordingly,

and there will be no disasters.

Nations would be prosperous

and there would be no use for soldiers or weapons.

People would abide by morality and accord with laws.

They would be courteous and humble,

and everyone would be content without injustices.

There would be no thefts or violence.

The strong would not dominate the weak

and everyone would get their fair share."

~THE BUDDHA SPEAKS OF
THE INFINITE LIFE SUTRA OF
ADORNMENT, PURITY, EQUALITY
AND ENLIGHTENMENT OF
THE MAHAYANA SCHOOL~

With bad advisors forever left behind,
From paths of evil he departs for eternity,
Soon to see the Buddha of Limitless Light
And perfect Samantabhadra's Supreme Vows.

The supreme and endless blessings
of Samantabhadra's deeds,
I now universally transfer.
May every living being, drowning and adrift,
Soon return to the Pure Land of Limitless Light!

✻ The Vows of Samantabhadra ✻

I vow that when my life approaches its end,
All obstructions will be swept away;
I will see Amitabha Buddha,
And be born in His Western Pure Land of
Ultimate Bliss and Peace.

When reborn in the Western Pure Land,
I will perfect and completely fulfill
Without exception these Great Vows,
To delight and benefit all beings.

✻ The Vows of Samantabhadra Avatamsaka Sutra ✻